ភាវនាសុទ្ធិយា

ទស្សនាវដ្តី ជ្រោយដំណាំងខាងសាសនា និងអក្សរសាស្ត្រ






ឆ្នាំទី ៣២ លេខ ៧ ខែកក្កដា

ព. ស. ២៥០៣ គ. ស. ១៩៦០

ក្នុង ៩៦ ទំព័រ





កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញវាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
-	ពុទ្ធដំរីប្បវត្តិ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	៧២១
-	មហានាវកស្សបជាតក លោក ឃួរ-អ៊ុន ប្រែរៀបរៀង . . .	៧៣៤
-	ព្រះអភិធម្មបិដក (គម្ពីរព្រះពុទ្ធាវត្ត) (តមក) លោក ប៊ូ-ប៉ូ រៀបរៀង .	៧៤៨
-	មធុរសារិហិណី (តមក) សម្តេចព្រះធម្មលិខិត ល្វី - ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈីន ពិនិត្យ	៧៥៧
-	មហោសថជាតក (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្វាក់តែ ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ	៧៧១
	ផ្នែកអក្សរសាស្ត្រ	
-	រឿងមរណមាន (តមក) លោក ប៉ី-សុវណ្ណ ចម្លងពីសាស្ត្រាស្វាក់តែ . .	៧៧៧
-	រឿងព្រេងប្រទេសក្រិក ភិក្ខុ ម៉ែខ-រៀម ប្រែពីភាសាអង់គ្លេស . .	៨០១
-	រឿងព្រេងនិងរឿងបុរាណដ៏ចំណូងចំណាមសម័យ លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង .	៨១៦
-	រឿងសាមកុក (តមក) ទកញ៉ា ភួ - ភន ប្រែ	៨២៥
-	ពាក្យវិឃ្ឃធម៌ លោក ខាង-ហ៊ូ រៀបរៀង លោក សម-ជាំង ពិនិត្យ .	៨៣៩
	ផ្នែកកំណត់ទិដ្ឋិប្រវត្តិការណ៍	
-	ពត៌មានផ្សេងៗ របស់ក្រសួងធម្មការ	៨៣៥
-	វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង . .	៨៣៨

មួយឆ្នាំ មាន ១២ សៀវភៅ ដំណៃជាវ ៤៣០០

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom Penh

sommaire

Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT. . . 721
— Maha Narada Kassapajataka traduit du pali par M. YOU-OUN 734
— Prah Abhidhammapitaka (Prah Kathavathu) (suite) par M. BOU-PO 748
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén-NHEAN CHHOEUN 757
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 771

Partie littéraire :

— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 777
— Contes et Légendes grecs traduits de l'anglais par le bonze MEN-RIEM 801
— Contes et Légendes du Japon au moyen âge traduits par M. RAY-BUC 816
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 825
— Activités de la Commission Culturelle par M NEANG HOU revues par M SAM-THANG. . . . 829

Notes et Chroniques :

— Nouvelles diverses du Ministère des Cultes 835
— Dictionnaire Sanscrit-khmer (suite) par le Vén-PANG-KHAT 838

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ពុទ្ធជីវប្បវត្តិ

(តមក)

ព្រះមហា ប៉ាង-ភត់ រៀបរៀង

អរិទ្ធរេនិទាន លក្ខណប្បដិគ្គហនកថា ទី ៣

១ កាឡទេវិលតាបសថ្វាយព្រះពរព្រះវរបិតា ២- ថ្វាយព្រះនាមព្រះរាជបុត្រ ៣-មហាបុរិសលក្ខណៈ ៤- ទ្រង់ប្រសូតបាន ៧ ថ្ងៃ ព្រះជននីស្តេចទិវង្គត ។

១- កាឡទេវិលតាបសថ្វាយព្រះពរព្រះវរបិតា

ថ្ងៃនោះ ពួកទេពនិកាយក្នុងតាវតឹង្សព្រហ្ម មានអមរន្ទ្រាធិបតីជាប្រធាន មានសេចក្តីត្រេកអរគ្រេកក្រៃ បបួលគ្នាយកគ្រឿងសក្ការបូជាថ្វាយពារសព្ទសាធុការកងរំពងខ្ទរខ្ទាយដោយទេវលោកថា « ឥឡូវនេះ ព្រះពុទ្ធនុសនៃព្រះបាទសុទ្ធោទនៈប្រសូតហើយ ព្រះពុទ្ធនុសនេះ ជាព្រះពោធិសត្វមហាបុរសត្ត ទីបំផុតនៃវដ្តសង្សារ ហើយសំដែងធម្មទេសនា យើងទាំងឡាយទើបបានស្តាប់ធម្មទេសនាពុំខាន » ។

លុះដាច់នោះ កាឡទេវិលកុលបតតាបស ជាដីតុនព្រះបាទសុទ្ធោទនៈ បានសមាបត្តិ ៨ បានឮបពួកសាធុការនៃពួកទេពនិកាយអើងកងរំពងទាំងទេវលោកដូច្នោះ ក៏ចូលទៅកាន់ក្រុងកបិលព័ស្តុ ថ្វាយព្រះពរព្រះបាទសុទ្ធោទនៈសូមជួបនឹងព្រះពុទ្ធនុស ជ្រាបហើយស្តេចទ្រង់បង្គាប់ឲ្យពួក

ស្រីស្នំនាំព្រះពោធិសត្វយកមកថ្វាយបង្គំតាបស តែពោធិសត្វមិនថ្វាយបង្គំ
ត្រឡប់ជាយកព្រះបាទរាំងគូរដៅប្រតិស្ថាននៅលើជាតាបសវិញ, នេះ
ជាធម្មតារបស់ព្រះបរមពោធិសត្វ ក្នុងបច្ចុប្បន្នជាតិ មិនមានអ្នកណាមួយល្មម
គួរដល់ព្រះអង្គនឹងថ្វាយបង្គំឡើយ បើអ្នកណាបង្គំឲ្យថ្វាយបង្គំ អ្នកនោះ
នឹងបែកក្បាល ៧ ភាគមិនខាន ។ ពេលនោះ កាឡទេវិលកុលបុត្រតាបស
ក្រោកឡើងថាកអាបនៈ ឈរសំឡឹងមើលសិរីលក្ខណសម្បត្តិព្រះបរម
ពោធិសត្វគ្រប់ប្រការ កើតសេចក្តីអស្ចារ្យក្នុងចិត្ត ទើបលើកទុសករប្រ-
ណម្យទូលព្រះបាទរាំងគូនៃព្រះបរមពោធិសត្វពីចារណាសព្វគ្រប់ហើយ
ក៏ញញឹមប្រឹមប្រិយ រួចហើយបែរជាយំខ្សឹកខ្សួល ។ ព្រះបាទសុទ្ធោទនៈ
ស្តេចទតឃើញហេតុអស្ចារ្យដូច្នេះ ទើបលើកព្រះហស្តប្រណម្យព្រះពុ-
ទ្ធមារ ។ ការលើកព្រះហស្តប្រណម្យនេះជាបឋម ។ ស្តេចត្រាស់សួរ
កាឡទេវិលតាបសអំពីហេតុញញឹមនឹងយំនោះ ។ តាបសឆ្លើយថា "អាត្ម
ភាពជាញញឹម ព្រោះពិចារណាឃើញថា ព្រះអយ្យបុត្រនេះ ប្រកប
ដោយលក្ខណៈគ្រប់ប្រការ តទៅស្តេចនឹងបានត្រាស់ជាអគ្គព្រះសម្ម-
សម្ពុទ្ធប្រាកដក្នុងលោកនេះ, អាត្មាយំព្រោះខ្លួន ព្រោះពិចារណាឃើញ
ថា អាត្មាភាពនឹងធ្លាក់ចាលកំរោតស្ងួតទៅក្នុងអបាយភព មុនការត្រាស់
ដឹងរបស់ព្រះអង្គ ហើយនឹកស្តាយក្រោយពន់ពេក" ។

លុះសន្ទនាគ្នារួចហើយ កាឡទេវិលតាបសថ្វាយព្រះពរលាចាក

ពជនិវសែនត្រឡប់ទៅកាន់លំនៅអាត្មាវិញ ទៅដល់ហើយ ផ្តាំទុកនឹងកូនប្អូនម្នាក់ ឈ្មោះនាងរួកៈឲ្យចាំបួសតាមថា ព្រះពាជនុសេព្រះបាទសុទ្ធោទនៈអង្គនេះ ជាពុទ្ធង្កុរ ព្រោះព្រះអង្គប្រកបដោយទ្វត្តឹង្សមហាបុរិសលក្ខណៈអំណើះតទៅ លុះស្តេចបានព្រះជន្ម ៣៥ ឆ្នាំគត់ ស្តេចនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយ ចូរអ្នកបញ្ជាទៅបួសតាមព្រះអង្គកុំខាន" ។

២-ប្តីរយព្រះនាមព្រះរាជបុត្រ

កាលព្រះពោធិសត្វប្រសូតកន្លងទៅបាន ៥ ថ្ងៃ ព្រះបាទសុទ្ធោទនៈទ្រង់ប្រជុំព្រះពាជវង្សានុវង្សត្រមាំងសេនាមាត្យ រៀបធ្វើនាមគ្គហាណមង្គលថ្វាយព្រះពាជបុត្រ ទ្រង់បង្គាប់ឲ្យអញ្ជើញពួកព្រាហ្មណ៍បុរោហិត ១០៨ នាក់ ដែលបេះបបំត្រៃវេស្សាត់ជំនាញមកទទួលភោជនាហារ (១) ក្នុងពួកព្រាហ្មណ៍បុរោហិតទាំង ១០៨ នេះ ស្តេចជ្រើសយកតែព្រាហ្មណ៍ ៨ នាក់ ដែលសុទ្ធតែជាអ្នកបង្ហើកខេសមានការបេះដឹងជាងគេ ហើយទ្វាប់មានការពិសោធន៍ទំនាយថ្វាយ កាលព្រះនាងមហាមាយាទ្រង់ព្រះសុបិនមិត្តមកផង ឯព្រាហ្មណ៍ទាំង ៨ នាក់នោះគឺ កម្រព្រាហ្មណ៍ ១ លក្ខណព្រាហ្មណ៍ ១ យញ្ញព្រាហ្មណ៍ ១ ធជព្រាហ្មណ៍ ១ គោជព្រាហ្មណ៍ ១ សុទត្តព្រាហ្មណ៍ ១ សុយាមព្រាហ្មណ៍ ១ គោណ្ឌញ្ញព្រាហ្មណ៍ ១ ។

១-ការនិមន្តន៍ព្រាហ្មណ៍មកទទួលភត្តនេះ ជាប្រពៃណីនៅប្រទេសឥណ្ឌៀ មានលក្ខណៈផ្ទៃបការនិមន្តន៍ព្រះភិក្ខុសង្ឃមកទទួលភត្តជាមង្គលក្នុងពុទ្ធសាសនាដែរ ។

ព្រាហ្មណ៍ទាំងនោះ បានថ្វាយព្រះបរមនាមព្រះពោធិសត្វថា អគ្គិ-
វេសកុមារ ព្រោះព្រះអង្គមានវេស្សន្តរយេញពីព្រះវេសារកាយ ទើបសិទ្ធត្ថ-
កុមារ(១) ព្រោះព្រះអង្គញុំាងប្រយោជន៍ឲ្យសម្រេចដល់ជនទាំងពួង ។

៣- មហាបុរិសលក្ខណៈ

ពួកព្រាហ្មណ៍ពិនិត្យមើលឃើញថា ព្រះរាជបុត្រអង្គនេះប្រកបដោយ
មហាបុរិសលក្ខណៈ ៣២ប្រការ ទើបអនុព្យញ្ជនៈ៨០ប្រការ ជាគ្រឿង
សំគាល់លក្ខណៈនៃមហាបុរសត្នេអស្ចារ្យក្នុងលោក, ព្រាហ្មណ៍ ៧ នាក់
លើកម្រាមដៃពីរដោតពីរយ៉ាង ឡើងព្យាករពីរមាត៌ថា "បើព្រះរាជកុមារអង្គ
នេះស្តេចនៅគ្រប់គ្រងគេហដ្ឋាន ទើបបានជាស្តេចចក្រពត្តិរាជជាស្តេច
ទ្រង់ធម៌ មានជ័យជំនះ ផ្សាយអំណាចរហូតដល់នៃនដីដែលមានមហា
សមុទ្រសាគរទាំង ៤ ព័ទ្ធជុំវិញ ប៉ើស្តេចចេញចាកគេហដ្ឋានៅទ្រង់ព្រះ
ផ្នួស ទើបបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដម្បូល
គឺកិលេសបើកចេញហើយ" ។ ឯកាណ្ឌញ្ញព្រាហ្មណ៍ម្នាក់ឯង លើកម្រាម
ដៃតែមួយឡើងព្យាករថា "ព្រះរាជបុត្រអង្គនេះ ស្តេចទើបចេញចាកគេហ-
ដ្ឋាន ទៅទ្រង់ព្រះផ្នួស ហើយទើបបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធ
ពិតប្រាកដ" ។ ការព្យាករណ៍នៃព្រាហ្មណ៍ទាំងប្រាំពីរនាក់ទាំងឡាយនេះ ត្រឹម
ត្រូវតាមក្បួនមហាបុរិសលក្ខណៈ ដែលមានប្រាកដ ទៅក្នុងគម្ពីរសាសនា

-១- សិទ្ធត្ថៈ ពោតមគោត្រ, ពោត ប្រែថា រង្សីអភិវឌ្ឍ ។

ព្រាហ្មណ៍ទីនៃព្រះពុទ្ធសាសនា ព្រោះមហាបុរសដែលប្រកបដោយមហា-
បុរិសលក្ខណៈ ៣២ ប្រការយ៉ាងនេះហើយ តែងភ្ជាក់ចុះក្នុង(១) គតិតែពីរ
យ៉ាងប៉ុណ្ណោះ មិនមែនភ្ជាក់ទៅក្នុងគតិដទៃឡើយគឺ

១) បើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន ទីឯបានជាស្តេចចក្រ-
ពត្រាធិរាជជាស្តេចទ្រង់ធម៌ មានជ័យជំនះ ផ្សាយអំណាចរហូតដល់ផែន
ដីដែលមានមហាសមុទ្រសាគរជាទីឆ្កែព័ទ្ធជុំវិញ ទ្រង់ប្រកបដោយរតនៈ ៧
ប្រការគឺ ចក្ករតនៈ១, ហត្ថិរតនៈ ១, អស្សរតនៈ ១, មណិរតនៈ ១,
ឥត្ថីរតនៈ ១ គហបតិរតនៈ ១, បរិណាយករតនៈ ១,

២) បើមហាបុរស ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស ទីឯបាន
ត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធឯកកនៃលោក ។

មហាបុរិសលក្ខណៈ ៣២ ប្រការ(២)

១-សុបតិដ្ឋិតបាទោ មហាបុរសមានផ្ទៃព្រះបាទប្រតិស្ឋានដោយ
ប្រពៃ គឺមានផ្ទៃព្រះបាទតាំងត្រូវបស្មើសព្វ
អន្ទឺ ដូចជាផ្ទៃនៃសុតណ្ហិបាទុកា(ទ្រនាប់
ដើងមាស) ។

១.លក្ខណសូត្រ បាដិកវគ្គ, ទីឃ, សៀវ. ១៩ ទំព័រ ៨ ។ ២ លក្ខណសូត្រ
បាដិកវគ្គ. ទីឃ, សៀវ. ១៩ ទំព័រ ១៥ ។

២- ចាតុតលេស្យ ចក្ខ្វាធិ ជាតាធិ ត្រង់ផ្លែព្រះចាតុតាំងគូមាន
រូបចក្រប្រកបដោយកណ្តាប់កង់ ទឹងដុំព្រម
តាំងកាំ១៣ខាន់ មានចន្ទោះស្មើគ្រាប់អន្ទឹង។

៣-អាយតបណ្តាំ មានព្រះបណ្តៀតែងវែង (បើចែកសរីរប្ប.
ទេសត្រង់នោះ ជា៤ភាគ, ពីរភាគ ជាបុង
ព្រះថុរ, ១ភាគជាកព្រះចាតុ, មួយភាគជា
ព្រះបណ្តៀ) ។

៤- ទីឃង្គុលី មានព្រះអង្គុលី តឹម្រាមព្រះហស្ត ទឹងម្រាម
ព្រះចាតុវែង ។ (ចំណែកខាងព្រះហស្ត
ម្រាមតាំង៤វែងស្មើគ្នា, ព្រះចាតុ ម្រាមតាំង
៥វែងស្មើគ្នា, ម្រាមតាំងអស់មូលត្រសូល
រៀវល្អ ដូចជាធង់មនោលិលា ដែលប
គេលាយប្រេងលញ់) ។

៥- មុទុតសុណាហត្ថាតោ មានផ្លែព្រះហស្តទឹងផ្លែព្រះចាតុខន់
ស្មើ (ដូចដុំសំឡីដែលគេវេចអស់មួយ
រយដង) ។

៦-ជាលហត្ថាតោ មានផ្លែព្រះហស្ត ទឹងផ្លែព្រះចាតុ ប្រតាក់

ដោយក្រឡាដូចជាសំណាញ់ ។

៧-ឧស្សន្នុចាគោ មានព្រះចុងដូចជាអណ្តែតឡើង៧ខាងលើ ហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះចុង ។

៨-ឥណិជរង្សា មានព្រះជង្ឃា គឺស្នងរៀមូលត្រសូលស្រដៀងនឹងស្នងសត្វក្រាយ (ពុំនោះសោតស្រដៀងគ្នាបង្គើមស្រូវ) ។

៩-ឋិតោយេវ អនោនមន្តោ កាលបើទ្រង់ប្រថាប់ គឺកាលបើទ្រង់ឈរ មិនទន្ទ្រេអង្គចុះ អាចស្ទាបព្រះជាណុគឺជង្គង់ ដោយព្រះហស្តទាំងពីរបាន ។

១០-តោសោ ហិតវត្តុយ្ហោ មានព្រះអង្គាវយវៈដែលគប្បីហៅឲ្យកំបាំងដោយសំពត់ស្តិតទៅក្នុង ស្រោម (ប្រហែលដូចជាអង្គជាតិនៃដំរី ឬគោឈ្មោលជាដើម) ។

១១-សុវណ្ណវណ្ណោ មានឆវីវណ្ណ គឺពណ៌សម្បុរថ្លៃ (លឿងភ្លឺគន្ធង់) ដូចជាសម្បុរនៃមាស ។

១២-សុទ្ធមន្តវិ មានព្រះឆវី គឺសម្បុរថ្លៃ ល្អិតផូរផង់ រលើនស្រិលរវេលដូលីដាក់មកត្រូវមិនជាប់ ។

១៣-ឯកោកាសោមោ មានព្រះសោមាគឺ ភេមកដ៏រណ្តៅមួយ ។ តែមួយសរសៃ។ (ពស់រណ្តៅចំណងអស់) ។

១៤-ឧទ្ធុក្កាសោមោ មានព្រះសោមា មានចុងឡើងលើ (ជាខ្លួណាវដ្តវិលវង់ ព័ទ្ធគេនបែរទៅខាងស្តាំ មានសម្បុរខៀវខ្ចីស្រស់ដូចជាផ្កាអញ្ជន ។

១៥-ព្រហ្មាជុកន្តោ មានព្រះកាយត្រង់ដូចជាកាយព្រហ្ម ។

១៦-សត្តុស្សទោ មានព្រះមំសៈ គឺសាច់ឯអន្ទេ្ធពេញបរិបូណ៌ (ព្រះមំសៈ ៧ អន្ទេ្ធនោះគឺត្រង់ខ្នងព្រះហស្តចំណីពីរ, ព្រះអំសកូដគឺចង្កេះស្មាចំណីពីរ, នឹងត្រង់ព្រះខន្ធប្បទេសគឺត្រង់ក សរីរប្បទេស ចំណីឯអន្ទេ្ធនេះ មានសាច់ពេញកន្ទក្កល្អ ឥតឃើញមានសរសៃ តិចតួចឡើយ) ។

១៧-សីហបុព្វទ្ធកាយោ មានចំណែកកន្ទុះព្រះកាយខាងដើមស្រដៀងនឹងចំណែកកន្ទុះកាយ នៃពស់ហ៍ (ត្រង់កន្ទែងដៃលគួរតែ.ង គួរខ្លី គួរធាត់ គួរស្តម ឬគួរវៀរ គួរមូល, កំរែង ខ្លី ធាត់ ស្តម

ប្តរៀវ មូលសមល្អឥតមានធ្ពង) ។

១៨.បិតន្តរំសោ មានចង្ហ្វ៍ព្រះប្រិស្ឋប្រទេស ពេញបរិបូណ៌ គឺមានខ្នងពេញស្មើ ឥតមានចង្ហ្វ៍ផតខ្នងត្រង់កណ្តាលឡើយ ។

១៩.ឯក្រោធបរិមណ្ឌលោ មានទ្រង់ទ្រាយព្រះកាយ ប្រហែលនឹងបរិមណ្ឌលនៃដើមជ្រៃ គឺ មានកាយនឹងព្យាមប្រវែងគ្នា (ដូចជាជ្រៃមានប្រវែងដើមនឹងមែក មិនលើស មិនខ្វះ ហួសគ្នាប៉ុន្មាន) ។

២០.សមវដ្តក្ខន្ធោ មានព្រះខន្ធប្បទេសដ៏មូលសម ។

២១.វស្តក្ខសក្តិ មានព្រះប្រសាទ គឺសរសៃសន្ធិតខ្នាដំលើសលែង សម្រាប់ទទួលរសអាហារ គឺមានសរសៃយ៉ាងខ្នាស្តិត ៧ ពាន់ប្រជុំស្រោបត្រង់ក សម្រាប់ទទួលនាំរសអាហារឲ្យជ្រួតជ្រាបផ្សព្វផ្សាយ ក្នុងកាយទាំងមូលបាន ឥតមានខ្វះខាត់ (សូម្បីអាហារយ៉ាងតូចតិចត្រឹមប៉ុនគ្រាប់ល្ង ១ ក៏អាចជ្រួតជ្រាប

សព្វសត្តានំកាយបានំ ។

๒๒-សីហាហនុ មានព្រះហនុគឺចង្កាមានសណ្ឋានស្រដៀងនឹងចង្កានៃរាជសីហ៍ (គេញុះរំបូរណាដូចជាព្រះចន្ទ្រត្រង់ថ្ងៃ ១៦ កើត) ។

๒๓-ចត្តាឡីសទន្តោ មានព្រះទន្តគឺធ្មេញ ๔๐ គត់ (ខាងលើ ๒๐ ខាងក្រោម ๒๐) ។

๒๔-សមទន្តោ មានព្រះទន្តរាបស្មើ (មិនប្រជ្រួសប្រជ្រៃតើសខ្ពស់ទាបដូចជាធ្មេញនៃសាមញ្ញមនុស្សពួកខ្លះនោះឡើយ) ។

๒๕-អវិរឡទន្តោ មានព្រះទន្តជិតស្និទ្ធល្អ ។

๒๖-សុសុក្កាទាឍោ មានព្រះទាឍា គឺចង្កឹម (ចាំង ๔) សស្អាត (ភ្លឺរុងរឿងដូចពន្លឺនៃផ្កាយព្រឹក) ។

๒๗-មហាតជិវ្ហោ មានព្រះជិវ្ហាគឺអណ្តាតល្មមល្មៃ (ប្លែកជាងអណ្តាតនៃមនុស្សទាំងអស់ក្នុងលោក) ។

๒๘-ព្រហ្មស្សរោ ការវិកភាណី មានព្រះសូរសៀង គឺសូរសព្វសំឡេងគ្រាន់ក្រអៅ ដូចជាសំឡេងនៃព្រហ្ម ; កាលបើបញ្ចេញវាចាលាន់ឮ

ពីពេះដូចជាសំឡេងនៃសត្វតេរិក ។

២៨-អកិនីលនេត្តា មានព្រះនេត្រខៀវស្រស់ (ត្រង់កន្ទុងដែលគួរខៀវក៏ខៀវស្រស់ ដូចជាផ្កាត្រគៀតឬផ្កាកណ្តៀង, ត្រង់ដែលគួរលឿងក៏លឿងស្រស់ដូចជាផ្កាកណ្ណិការ, . . . ក្រហមស្រស់ដូចជាផ្កាច្បារ, . . . សច្ឆាត្រចះដូចជាផ្កាយព្រឹក, ... ខ្មៅស្រស់ដូចជាផ្លែផ្នាំ ។

៣០-គោបខុមោ មានដងព្រះនេត្រស្រដៀងនឹងដងក្អែកនៃកូនគោ (គឺមានដងព្រះនេត្រពាំងពីរ ថ្ងាយង់ ស្រដៀងនឹងដងក្អែក នៃកូនគោ សម្បុរក្រហម ដែលទើបនឹងសម្រាលមួយរំពេចនោះ) ។

៣១-ឧណ្ណាភមុកន្ធវេ ជាតា មានព្រះឧណ្ណាលោមគឺពេមដុះត្រង់ចន្ទោះព្រះភ្នែម (ចិះញ្ចើម) មានសម្បុរសក្បុសទន់ល្អើយដូចជាសំឡី ។

៣២ ឧណ្ហីសសីសោ មានព្រះសិរ្សហាក់ដូចជាប្រដាប់ដោយ

ក្សាំងស្រេចស្រាច់ (រុងរឿងដូចជាព្រះមហាក្សត្រដែលទ្រង់នូវក្សាំងព្រ័កក្រ្ត) , មានន័យមួយទៀតថា មានព្រះសិរីរួមល្អបរិបូណ៌ល្អដូចជាមកុដ, ម្ហូបហាក់ជាវត្ថុដែលគេក្រឡឹងហើយយកមកដាក់ , ពុំនោះសោត ម្ហូបហាក់ដូចជាតពុះចំកដែលចោងឡើង ។

៤-ទ្រង់ប្រសូតបាន ៧ ថ្ងៃព្រះនាងធីស្នេហទេវិទ្ធគ

លុះកន្លងពីការប្រសូតបាន ៧ ទិវារហើយ ព្រះនាងមហាមាយាស្នេហសោយព្រះវិលាល័យ ទៅកើតក្នុងពួកទេវនិកាយជាន់តុសិត សមដូចសេចក្តីដែលព្រះសម្ពុទ្ធត្រាស់ចំពោះអានន្ទថា (១)

" ម្នាលអានន្ទ ! ត្រឹមត្រូវហើយ សេចក្តីនេះពិតមែន មាតានៃពោធិសត្វ មានជន្មាយុគិចណាស់ កាលទ្រង់ប្រសូតពោធិសត្វហើយបាន ៧ ថ្ងៃ ទ្រង់ទិវង្គតទៅ ហើយបួលទៅកាន់ទេវនិកាយជាន់តុសិត " ។

๑-អច្ឆរិយព្ភុតសូត្រ ,សោណវគ្គ ឧទាន ។ ព្រះនាងសិរីមហាមាយា ស្នេហទិវង្គតនេះជាប្រពៃណីព្រះមាតាព្រះពោធិសត្វក្នុងគ្រប់ជាតិ ។

តមក ព្រះបាទសុទ្ធោទនៈទ្រង់លើកព្រះនាងមហាមាយាជាបតិគោតមី ដែលត្រូវជាព្រះពាជកនិដ្ឋភគិនីរបស់ព្រះនាងមហាមាយា ជម្ពល់ឲ្យជាអគ្គមហេសី ឡើង ហើយប្រគល់ព្រះបរមពោធិសត្វថ្វាយឲ្យព្រះនាងថែរក្សាក្នុងឋានៈជាមាតា ។ ឯពួកព្រាហ្មណ៍ទាំង ៨ នាក់ បានយកកូនមួយម្នាក់ ៗ គ្រប់គ្នាចូលទៅថ្វាយព្រះបរមពោធិសត្វ ទុកជាពាជបរិវារតាមបំរើ ព្រះពាជកុមារបានត្រាស់ជាព្រះពុទ្ធក្តី ស្តេចទៅគ្រប់គ្រងព្រះពាជគេហដ្ឋានក្តី តាមតែព្រះពាជចិត្តា ហើយផ្តាំកូនគ្រប់គ្នាថា " បើព្រះពាជកុមារនេះបានត្រាស់ជាព្រះពុទ្ធ , បើអ្នកទាំងឡាយត្រូវការ, ចូរអ្នកគ្រប់គ្នាចូលទៅបួសតាមព្រះមហាបុរសចុះ ", លុះចំណេរតមក, ព្រាហ្មណ៍ ៧ នាក់ដល់នូវជាភាព កំឡើនវ័យរណាស្លាប់ទៅតាមយថាកម្មរបស់ខ្លួនអស់ទៅ នៅសល់តែកោណ្ឌញ្ញព្រាហ្មណ៍ដែលនៅក្មេងជាងគេ[1]ម្នាក់ឯង ។

១-កាលព្រះពោធិសត្វចេញសាងអភិនិស្ក្រមនៈ កូនព្រាហ្មណ៍ ៤ នាក់នឹងកោណ្ឌញ្ញព្រាហ្មណ៍ ចេញទៅបួសតាម ដែលប្រាកដឈ្មោះថាបញ្ចវគ្គីភិក្ខុ ។ កូនព្រាហ្មណ៍ ៣ នាក់ទៀត ក្នុងអដ្ឋកថានិយាយថាទៅបួសដែរ តែមិនដឹងជាទៅបួសបែបដូចម្តេច (អរិយវោនិទាន)។

(នៅមានត)

ដោយ ឃុនសុវត្ថិវេធី ឃ្លូរ-អ៊ុង ក្រុមជំនុំព្រះត្រៃបិដក

មិនតែឥឡូវនេះទេ ដែលមានគេយល់ ថា កុសល សីល ទាន គ្មានផល ថា បរលោក ក៏គ្មាន

ខ្លួចមានន័យថា តាំងនេះទំ

ក្នុងកាលពីព្រេងនាយ មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាម អង្គតិ សោយរាជ្យនៅនគរវិទេហៈ ។ ស្តេចអង្គនេះនឹងហៅថា ព្រះបាទវិទេហរាជ ក៏បាន ។ ទ្រង់ជាស្តេចមានឥទ្ធានុភាពខ្លាំងពូកែ មានអេហ៍តលច្រើន ប្រមាណមិនបាន មានស្តេចក្នុងប្រទេសជាខែជាច្រើនមកចំណុះបុះពួលព្រះអង្គ ។ កាលនៅថ្ងៃ ១៥ កើតខែកត្តិក ជាកាលខែបំផុតរដូវភ្លៀង ព្រះបាទវិទេហរាជ ទ្រង់ប្រជុំអាមាត្យរាជបណ្ឌិត ៣ នាក់ ឈ្មោះវិជ័យ ១ សុនាម: ១ អលាត: ១ ហើយទ្រង់ត្រាស់សួរថា "ថ្ងៃនេះ ជាថ្ងៃ ១៥ កើត ខែកត្តិក ជាកាលខែបំផុតនៃរដូវភ្លៀង ព្រះចន្ទមានមណ្ឌលពេញវង់ មានរស្មីភ្លឺត្រចះ តើយើងគួរធ្វើយ៉ាងណា ឲ្យ

ជាទសប្បាយក្នុងចិត្ត ? សូមលោកទាំង ៣ នាក់ តោលតាមសេចក្តីយល់
រៀងខ្លួន ប្រាប់ខ្ញុំមកមើល" ។

ខណៈនោះ អលាតសេនាបតី ក្រាបទូលថា « សូមទ្រង់ព្រះមេត្តា
ប្រោស! ទូលព្រះបង្គំយល់ឃើញថា គួរចាត់ចែងកងទ័ពលើកទៅច្បាំងនឹង
ព្រះពជាអង្គណា ដែលមិនទាន់ចំណុះព្រះអង្គនោះឡើយ ចាប់ស្តេចអង្គនោះ
ឲ្យមកចុះចូលនឹងព្រះអង្គ, ទូលព្រះបង្គំសូមធ្វើការណ៍នេះថ្វាយ, ព្រះអង្គកំ
ណត់ជាទសប្បាយព្រះទ័យ ថ្លៃងព្រះកត្តិយសរោយសារជ័យជំនះនោះ"។

សុនាមអាមាត្យ ក្រាបទូលថា « ទូលព្រះបង្គំជាខ្ញុំមិនពេញចិត្ត
នឹងធ្វើចម្បាំងទេ ព្រោះស្តេចជាសត្រូវទាំងអស់ សឹងចាត់បបួចគ្នាចមក
ចំណុះក្នុងអំណាចព្រះអង្គស្រាប់ហើយ ចាំចាប់ទៅធ្វើចម្បាំងអ្វីទៀត,ក្នុងថ្ងៃ
ជាខក្ខត្តបក្សនេះ សូមទ្រង់ក្រសាលព្រះទ័យ ដោយល្បែងកំប្រៀនប្រតំ
ត្បូរតន្ត្រី ជាល្បែងនាំឲ្យតម្រេកក្នុងកាម ទើបប្រសើរជាងធ្វើចម្បាំង" ។

វិជ័យអាមាត្យ ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស! ការ
កំប្រៀនដោយមានត្បូរតន្ត្រីប្រគំឮពីពេះ ជាល្បែងសំរើបតំលេស ព្រះ
អង្គមានជ័យជំនះស្រាប់ហើយ, បើទ្រង់មានចំណងក្រសាលពេលណា ក៏
អាចសម្រេចបានពេលនោះ, ព្រោះហេតុនោះ ការសប្បាយដោយល្បែង
ប្រៀនកំ ជាការសប្បាយធម្មតា ទូលព្រះបង្គំជាខ្ញុំពុំពេញចិត្តផងទេ, ក្នុងថ្ងៃ

ជាខត្តិយកុលនេះ ខ្ញុំសូមព្រះបង្គំជាខ្ញុំយល់ឃើញថា គួរទ្រង់ស្តេចចូលទៅសាកសួរប្រស្នាជមិនអាច ចំពោះសមណព្រាហ្មណ៍ណា ដែលជាអ្នកចេះដឹងច្បាស់ឆន្ទៈនេះ ទើបគេញ៉ាំងការសប្បាយប្រកបដោយធម៌ ។

ព្រះបាទអង្គតិទ្រង់ត្រាស់ថា « លោកវិជ័យពោលនេះ គេញ៉ាំងចិត្តខ្ញុំហើយ ចុះលោកណាបានដឹងច្បាស់ទេ តើសមណព្រាហ្មណ៍ណា ? នៅទីណា ? ដែលជាពហុស្សូត ជាអ្នកចេះអត្ថចេះធម៌ យ៉ាងជ្រាលជ្រៅ អាចកាត់សេចក្តីសង្ស័យយើងបាន ? "

អលាតសេនាបតីក្រាបទូលថា « មានអចេលកៈឈ្មោះគុណៈជាកស្សបគោត្រ ជាគណាចារ្យ ជាអ្នកប្រាជ្ញធំ លោកតាំងនៅក្នុងមិគទាយវ័ន; លោកគ្រូនេះអាចនឹងបន្ទោបង់សេចក្តីសង្ស័យនៃទ្រង់បាន, សូមទ្រង់ស្តេចចូលទៅកាន់ជួបនឹងលោកគ្រូគុណៈនោះចុះ ។

ព្រះបាទវិទេហរាជទ្រង់ជឿតាមពាក្យដែលអលាតសេនាបតីក្រាបទូល ទើបទ្រង់ស្តេចយាងទៅកាន់មិគទាយវ័ន ដោយមានរដ្ឋមន្ត្រីនិងអ្នករាជការជាច្រើន តាមព្រះអង្គទៅផង ។ កាលទ្រង់ស្តេចទៅដល់ហើយ ក៏ប្រថាប់លើកម្រាលមានសម្ផស្សទន់ រួចទ្រង់មានព្រះពាក្យរាក់ទាក់ស្រស់ស្រាយ ទៅកាន់អចេលកៈឈ្មោះគុណៈនោះថា « លោកម្ចាស់សុខសប្បាយក្នុងខ្លួនទេឬ ? ឈឺក្នុងខ្លួនដើរស្រួលទេឬ ? លោកចិញ្ចឹម

ជីវិតមិនលំបាកទេឬ ? ក្អែកលោកមិនឆ័ឆឹតទេឬ ?"

-ថ្វាយព្រះពរមហាក្សត្រ ! អាត្មាភាពសុខសប្បាយទេ ឥរិយាបថខ្លួនស្រួលទេ អាត្មាភាពចិញ្ចឹមជីវិតមិនលំបាកទេ ក្អែកមិនខាន់ឆ័ឆឹតទេ ។

-បពិត្រលោកម្ចាស់ជាក្សត្រគោត្រ ! ខ្ញុំដែលមកនេះ ដោយមានចំណងចង់សប្បាយក្នុងការសាកសួរដល់លោកម្ចាស់, ហេតុនេះ សូមលោកម្ចាស់ចាំដោះស្រាយប្រស្នា ដែលខ្ញុំនឹងសួរដូចតទៅនេះ៖

"បុត្តធីតាត្រូវប្រព្រឹត្តធម៌ដូចម្តេចក្នុងមាតាបិតា ? មាតាបិតាត្រូវប្រព្រឹត្តធម៌ដូចម្តេចក្នុងបុត្តធីតាវិញ ? សិស្សនឹងគ្រូ, ប្តីនឹងប្រពន្ធ, មនុស្សចាស់នឹងក្មេង, សមណព្រាហ្មណ៍នឹងគ្រហស្ថ, ទាសកម្មករនឹងនាយចៅហ្វាយ, ពលរដ្ឋនឹងស្តេចផែនដី តើត្រូវប្រព្រឹត្តធម៌ដូចម្តេច ចៅវិញចៅមកវិញគ្នា ? ពួកសត្វប្រព្រឹត្តធម៌ដូចម្តេច កាលលះលោកនេះហើយ ឋានចៅកើតកើតសុគតិសួគ៌ទៅលោក ? "

-ថ្វាយព្រះពរមហាក្សត្រ ! ផលល្អនឹងផលអាក្រក់ របស់សត្វអ្នកប្រព្រឹត្តធម៌ មិនមានទេ តាំងពីលោកក៏មិនមានដែរ កាលបើផលល្អផលអាក្រក់របស់កម្មនឹងពីលោកមិនមានហើយ ពួកសត្វចាំជាប់ប្រព្រឹត្តធម៌អ្វី ក្នុងមាតាបិតា ក្នុងគ្រូអាចារ្យ ក្នុងសមណព្រាហ្មណ៍ ក្នុងនាយចៅហ្វាយ ក្នុងស្តេចផែនដី ។ បពិត្រមហាក្សត្រ ! ផលនៃទានសីលមិនមានទេ

ទានក្តី សីលក្តី តែមនុស្សពោលតាំងខ្លួនជាបណ្ឌិតទេ ដែលបញ្ញត្តឲ្យ
កើតមានឡើង ព្រោះហេតុនោះ ឋានសួគ៌សម្រាប់មនុស្សប្រព្រឹត្តធម៌
ល្អគ្មានឡើយ ឋាននរកសម្រាប់មនុស្សប្រព្រឹត្តអាក្រក់ ក៏មិនមានដែរ ។
មួយទៀត ភ្លើង, ទឹក, ដី ខ្យល់, សុខ, ទុក្ខ, ទឹងជីវិត ទាំង ៧ នេះ ជា
របស់ទៀង សម្រាប់ពួកសត្វកល់រូប សុខទុក្ខកើតឯងៗគ្មានអ្នកផ្តល់ឲ្យទេ
មួយវិញទៀត ពួកសត្វកាលអន្ទោលទៅក្នុងសង្សារអស់ ៨៤ កប្ប ក៏ឥតឃើ
ឃាសុទ្ធឯង កាលបើមិនទាន់ដល់កម្រិតនេះទេ បើទុកជាប្រព្រឹត្តធម៌
តឹងតែងយ៉ាំងណា ក៏មិនឃើញសុទ្ធដែរ ។

កាលអចេលកៈឈ្មោះគុណៈ ពោលយ៉ាំងនេះចប់ហើយ អាឡារ.
សេនៈបតីបានពោលតបថា "លោកម្ចាស់ពោលនេះត្រូវពិត ខ្ញុំក៏យល់
ឃើញយ៉ាំងនេះដែរ ព្រោះខ្ញុំជាតិរបស់ខ្លួនក្នុងកាលមុន កាលដែល
កើតជាបុរសឈ្មោះ បិង្គលៈ ជាអ្នកសម្លាប់គោ ក្នុងក្រុងពារាណសី ។
ក្នុងជាតិនោះ ខ្ញុំមិនសម្លាប់តែគោទេ ខ្ញុំធ្វើអំពើបាបផ្សេងៗឯទៀតជាច្រើន
លុះខ្ញុំស្លាប់ពីនោះមក បានមកកើតក្នុងត្រកូលនៃសេនាបតី ក្នុងនគរនេះ
ផលបាបរបស់ខ្ញុំមិនមានពិត បានជាខ្ញុំមិនទៅកើតក្នុងនរក ។

ក្នុងសម័យនោះ មានបុរសកំសត់ម្នាក់ជាខ្ញុំគេ ឈ្មោះវិជកៈ នៅ
អាស្រ័យក្នុងក្រុងមិថិលា ជាអ្នករក្សាទ្វារបាសថ បានបួសទៅអង្គុយស្តាប់

ការរោះស្រាយនៃលោកគ្រូគុណៈនោះដែរ ។ រីឯកៈ លុះបានស្តាប់ពាក្យលោកគ្រូគុណៈ ខឹងពាក្យអលាតសេនាបតីហើយកំរើបច្ចីរទឹកក្នែក ។ ព្រះបាទមង្គិតត្រង់ទតឃើញអាការនៃជីវកៈហើយ ក៏ត្រាស់ថា «នែវីរជកបុរស! ហេតុដូចម្តេចក៏អ្នកយំសោក អ្នកមានទុក្ខវេទនាដូចម្តេច ? »

-បពិត្រព្រះមហាក្សត! ខ្ញុំលព្រះបង្គំគ្មានទុក្ខវេទនាអ្វីទេ តែខ្ញុំលព្រះបង្គំរលឹកឃើញ ទ្វេសេចក្តីសុខរបស់ខ្ញុំលព្រះបង្គំពីកន្លងជាតិមុន កាលដែលកើតជា ភាវសេដ្ឋី ក្នុងនគរសោកេត ។ ភាវសេដ្ឋី ជាអ្នកមានគុណធម៌ក្នុងខ្លួន តែងចែករំលែកទានដល់សម្ចុំ ជាអ្នកប្រព្រឹត្តសុចរិតត្រង់ត្រង្គោ ។ កាលខ្ញុំលព្រះបង្គំច្យុតពីភាវសេដ្ឋីនោះ បានមកកើតជាកូនកុម្ភទាសី ឧត្តិត មានឈ្មោះថា វីជកៈ នៅក្នុងក្រុងមិថិលា ។ តាំងពីកើតមក ខ្ញុំលព្រះបង្គំចំលក្រក្រៃលែង ទុគ៌តយ៉ាងនេះ ក៏ខ្ញុំលព្រះបង្គំនៅតែកក្សាទុះថ្មសម័ស ទំលែបន្សល់កត្តពាក់កណ្តាលឲ្យទានដល់សម្ចុំ ។ អំពើជាកុសលដែលខ្ញុំលព្រះបង្គំធ្វើក្នុងជាតិជាភាវសេដ្ឋីក្តី ក្នុងជាតិនេះក្តី ជាអំពើគ្មានឲ្យផលទាល់តែសោះ ទុះថ្មសម័ស ជារបស់គ្មានប្រយោជន៍ទេ ។ ដែលខ្ញុំលព្រះបង្គំទួលទុក្ខទោសចំលក្រ ជាក់ស្តែងយ៉ាងនេះ ព្រោះហេតុតែកើតកន្លងត្រកូលអ្នកក្រខ្សត់ ដូចអ្នកលេងល្បែងក្តាល់ចាញ់គេ ព្រោះហេតុតែមិនចេះប្តូរចេះតិច ក្នុងកលល្បិចល្បែងក្តាល់ ។

ទូលព្រះបង្គំរកឮរបេញទៅឯនសួគ៌ពុំឃើញទេ ព្រោះហេតុនេះ ទើប
ទូលព្រះបង្គំយំសោកស្តាយអំពើកុសលដែលធ្វើមើយ ។

ព្រះបាទអង្គតិច្រង់ត្រាស់តបនឹងវិដកៈថា "អើវិដកៈ ភ្លាសុគតិមិនមាន
ដូចអ្នកថាមែនហើយ" រួចច្រង់ត្រាស់ព្រះបន្ទូលសាអចេលកឈ្មោះគុណៈ
ទៅកាន់ព្រះបរមរាជវាំងវិញ ហើយត្រាស់ហៅអាមាត្យទាំង ៣ នាក់ មក
ប្រគល់ទុកជាក់ការផែនដី ឲ្យអាមាត្យទាំង ៣ នោះ កាន់ការជំនួស
ច្រង់ឈប់រវល់នឹងការផែនដី ច្រង់យកព្រះទ័យទុកជាក់ តែក្នុងកាមគុណ
ត្រេកត្រអាលក្នុងកាមរាគជាមួយស្រីស្នំ ទំនងវិស្សនច្រៀងរាំ នៅក្នុង
ប្រាសាទវិមានចន្ទក៍ រាល់ថ្ងៃ ។

កន្លងត្រីនៃថ្ងៃទី ១៤ (មិនប្រាកដជាខែណា) មានព្រះរាជកញ្ញាមួយ
ព្រះអង្គព្រះនាម រ៉ូបា ជាធីតាបង្កើតនៃព្រះបាទអង្គតិ ព្រះនាងជាទី
ស្រឡាញ់ពេញព្រះទ័យនៃព្រះរាជបិតាយ៉ាងក្រៃលែង ។ ក្នុងវេលាយប់
នោះព្រះនាងបានស្តេចយាងទៅគាល់ព្រះបាទអង្គតិ ជាព្រះបិតាជាមួយនឹង
ពួកកុមារីច្រើននាក់ ក្នុងព្រះរាជតំណាក់វិមានចន្ទក៍ ដែលជាប្រាសាទព្រះ
បិតាគង់នៅ ។ លុះព្រះនាង រ៉ូបា បានធ្វើគារវកិច្ចរួចហើយ ព្រះបាទអង្គតិ
កាលឃើញការប្រជុំនៃនាង រ៉ូបា និងពួកកុមារី ដូចជាទីប្រជុំនៃស្រីទេព
អប្សរ ក៏ច្រង់សំណោះសំណាលទៅកាន់តាសំឡាញ់ថា "ឧកូនស្រីឪពុក!

នាងមានសេចក្តីសប្បាយ ក្នុងស្រះចោកឬណៃដែរឬទេ? មានគេនាំយក
ទំវាន្តមកឲ្យនាងសព្វពេលដែរឬ? ពួកកុមារីនាំយកតម្រងផ្កា ធ្វើផ្ទះ
គួចៗសម្រាប់លេងឲ្យនាងដែរឬ? មួយទៀត កូនស្រីខ្វះខាតអ្វី បង់បាន
អ្វី កូនស្រីប្រាប់មកចុះ ឪពុកនឹងផ្តល់ឲ្យ មិនឲ្យកូនអាក់ចិត្តទេ»។

-បពិត្រព្រះកដបិតា! របស់ទាំងអស់នោះ ខ្ញុំម្ចាស់តែងបានសព្វ
កាលវេលា ដោយសារបុណ្យចាមើនៃព្រះអង្គ, តែថ្ងៃស្អែកនេះ ជាថ្ងៃ
១៥ ត្រូវខ្ញុំម្ចាស់រក្សាទុបោសថសីល ហើយនឹងឲ្យទានដល់ពួកវណិព្វកជន
តាមទំនងដែលខ្ញុំម្ចាស់ធ្លាប់រក្សាធ្លាប់ឲ្យមក ហេតុនេះ សូមព្រះបិតា
មេត្តាព្រះកដទានច្រាក់ ១០០០ កហាបណៈដល់ខ្ញុំម្ចាស់ ដើម្បីយកទៅ
ធ្វើបុណ្យឲ្យទាន តាមត្រូវការ»។

-ម្នាលកូនស្រីអើយ! កូនឯងបំផ្លាញទ្រព្យឪពុកអស់ជាច្រើនណាស់
ហើយ ព្រោះតែឲ្យទានរក្សាសីល ដែលជាអំពើឥតផលឥតប្រយោជន៍
សោះ។ នាងរក្សាទុបោសថសីល មិនចរិកោគបុយល្អាប ជាការឥត
ប្រយោជន៍ទេ។ ម្នែនាងវុចា! បើនាងមានជីវិតរស់នៅដកបណា នាងមិន
ត្រូវរក្សាទុបោសថឥតបាយល្អាយឡើយ នាងចំប្រើនឲ្យលុំបាកធ្វើអ្វី នាង
ចូរមើលអហតសនាបតីនឹងវិដកបុរសជាតំរូវស្រាប់, ឥលាតសេនាបតី
កាលពីជាតិមុន ជាមនុស្សធ្វើបាបគ្រប់យ៉ាង ដល់ស្លាប់ពីជាតិនោះ បាន

មកកើតជាអលាតសេនាបតី មិនឃើញទៅរើឧក្កដ្ឋនរកឯណាសោះ ។ ឯវិជកៈកាលតំជាតិមុន រក្សាទុច្ចរិតសុចរិត ដល់មកជាតិនេះទៀត ក៏នៅតែរក្សាទុច្ចរិតសុចរិត តាំងឲ្យគានផង ក៏ត្រឡប់ទៅជាទំលក្រ មិនឃើញបានខួលផលជាសុខសោះ ។

-បពិត្រព្រះពុជបិតា ! តាំងដើមខ្ញុំម្ចាស់គ្រាន់តែឮ ថ្ងៃនេះ ខ្ញុំម្ចាស់ឃើញច្បាស់ហើយថា បុគ្គលណាសេពគប់នឹងជនពាល បុគ្គលនោះនឹងទៅជាពាលដែរ បុគ្គលវង្វែង គប់រកបុគ្គលវង្វែង រមែងវឹងតែតែវង្វែងខ្លាំងឡើង ។ អលាតសេនាបតីនឹងវិជកៈបុរស គួរតែវង្វែងទៅចុះ ចុះព្រះអង្គជាស្តេចសោយរាជ្យត្រឡប់ឯង ព្រមទាំងមានព្រះប្រាជ្ញាឈ្លាសវៃជ្រាបសេចក្តីចំរើននឹងសេចក្តីវិនាស ហេតុម្តេចក៏ត្រឡប់ជាយល់ឃើញស្មើនឹងមនុស្សថោកទាបទៅវិញ ។ ហេតុម្តេចក៏ព្រះអង្គប្រញាប់ជឿពាក្យលោកគ្រូគុណៈម៉្លេះ ? ព្រះអង្គមិនពិចារណាពីមនុស្សក្នុងលោកដែលផ្សេងគ្នាដោយមានប្រាជ្ញាឥតប្រាជ្ញា ដោយសុខទុក្ខ ដោយរូបអាក្រក់ល្អ ដោយបុណ្យកុសនាទាបខ្ពស់ សូម្បីកើតក្នុងត្កូលក្សត្រក៏មិនស្មើគ្នាដែរ ខ្លះល្ងង់ខ្លះមានប្រាជ្ញា ខ្លះបានសោយរាជ្យ មកពីអ្វីចៃកមនុស្សទាំងនោះឲ្យផ្សេងគ្នា ? មិនតឹមតែពីមួយជាតូដ នាំចំបែរសត្វទ្រុស ។ គ្នា, លោកគ្រូគុណៈបដិសេធមានសីលថា ឥតផល ឥតប្រយោជន៍ គំនិតជំរុសេធកម្ម

នោះឯង បើគ្មានកម្ម សត្វកំគ្មានទុំសគ្នាដែរបើគ្មានកម្ម ផ្សេរបេស់លោក គ្រូគុណៈ កំឥតប្រយោជន៍ ម្តេចកំលោកបួសធ្វើអ្វី ? មួយទៀត លោក គ្រូគុណៈពោលថា បរលោកគ្មានទេ ពុះព្រះអាទិត្យព្រះចន្ទនៅកន្លែងលោក នេះ ឬនៅកន្លែងលោកដទៃ? មិនមែននៅកន្លែងលោកយើងនេះទេ ព្រោះនៅ ឆ្ងាយពីយើងក្រៃលែង តែនៅកន្លែងលោកឯទាយ បើដូច្នោះ បរលោក ពិតជាមាន ម្តេចព្រះបិតាមិនសួរដេញដោលត្រង់រឿងនេះផង ។

លោកអលាតសេនាបតី ដឹងជាតិបានត្រឹមតែ ១ ជាតិ មិនបានដឹង ច្រើនជាតិ តែដឹងត្រឹមតែកាលដែលខ្លួនកើតជាបុរសឈ្មោះចិង្គុលៈ ជាអ្នក សម្លាប់សត្វបុំណ្ណោះ ជាតិក្រៅពីនេះដែលបានធ្វើបុណ្យកុសល លោក អលាតសេនាបតីមិនដឹងទេ ទើបយល់ថាបាបកម្ម គ្មានឲ្យផល នេះហៅ ថាមនុស្សយើញខ្វី ។ តាមដែលពិត អលាសេនាបតី កាលដែលកើតជា ចិង្គុលៈធ្វើបាប តែបុណ្យដែលធ្វើពីជាតិមុន ។ មានកម្លាំងខ្លាំង ទើប បង្អាក់បាប នាំចិង្គុលៈឲ្យមកកើតជាអលាតៈ ក្នុងត្រកូលសេនាបតី ។

ចំណែកវីដកៈបុរសជាខ្ញុំគេ តែដឹងជាតិខ្លួនបានត្រឹមតែ ១ ជាតិដែរ ជាតិលើសពីនោះមិនដឹង តែដឹងត្រឹមតែកាលដែលខ្លួនកើតជាការសេដ្ឋី ជាអ្នកមានគុណធម៌ ប្រព្រឹត្តសុចរិតត្រង់ត្រឹមត្រូវ ត្រង់ដែលខ្លួនកើតជាតិ ក្រៅពីនេះ ហើយប្រព្រឹត្តខុសច្បាប់ វីដកៈមិនបានដឹង ទើបយល់ថាបុណ្យ

កុសលតិចនស័ល គ្មានឲ្យផល នេះហៅថាមនុស្សមិនឃើញផ្លាយ ។

បពិត្រព្រះពដចិតា ! ខ្ញុំម្ចាស់ដឹងជាតិខ្លួន ឃ្លាតជាតិដែលកន្លងទៅ
ហើយ (អតីតជាតិ) ទីធ ๗ ជាតិទៀតដែលនឹងមានទៅខាងមុខ (អនា-
គតជាតិ) ។ កន្លងអតីតជាតិ ពីមុនជាតិនេះទៅ នៅជាតិទី ๗ នោះ ខ្ញុំ
ម្ចាស់កើតជាកូនជាងមាស មានភេទជាប្រុស នៅក្នុងក្រុងជគហបុរី ដែន
មគធៈ ជាអ្នកសេពគប់មិត្តអាក្រក់ មិត្តនោះនាំឲ្យប្រព្រឹត្តបាបកម្ម គឺ
សេពប្រពន្ធបុគ្គលដទៃ ។ ឃាតកម្មនេះតម់នៅក្នុងខ្លួនខ្ញុំម្ចាស់នោះ ដូចភ្លើង
កប់កន្លះផេះ ។ លុះខ្ញុំម្ចាស់ស្លាប់ពីជាតិនោះ ដោយអំណាចកុសលកម្មដទៃ
បានមកកើតជាកូនប្រុសនៃសេដ្ឋី ក្នុងក្រុងសោសម្ពី ។ ក្នុងជាតិនេះ ខ្ញុំ
ម្ចាស់គប់មិត្តល្អ មិត្តល្អដឹកនាំឲ្យខ្ញុំម្ចាស់ប្រព្រឹត្តកុសលផ្សេង ។ មានសទ្ធា
ទេ្ឋាសឋជាដើម ។ កុសលកម្មនេះ តម់នៅក្នុងសន្តានខ្ញុំម្ចាស់ប្លែចតំណាប់
ទ្រព្យក្នុងទឹក ។ លុះខ្ញុំម្ចាស់ស្លាប់ពីកូនសេដ្ឋីនោះ តំរៅកើតក្នុងភេរព
នរក ដោយអំណាចបាបកម្មនៃខ្ញុំម្ចាស់ កាលដែលកើតជាកូនជាង
មាសនោះ ។ រួចពីភេរពនរក មកកើតជាតិតៃរ្ឋាល ត្រូវគេក្រៀវអង្គ-
ជាត ។ តមកកើតជាស្វាឈ្មោល ត្រូវស្វាជាមេហ្វូងខាំកាត់អង្គជាត ។
តមកទៀតកើតជាគោឈ្មោល ត្រូវគេក្រៀវទៀត ។ រួចកើតជាមនុស្ស
ខ្ទើយ ក្នុងដែនវង្គី ។ លុះស្លាប់ពីមនុស្សខ្ទើយ ដោយអំណាចនៃ

កុសលកម្មដែលបានធ្វើក្នុងជាតិជាកូនស្ដេចក្នុងក្រុងកោសម្ពីនោះ ខ្ញុំម្ចាស់
កំពៅកើតជាស្រីខេតអប្បរ ក្នុងហានតាវត្តិង្ស ។ ដោយអំណាចកុសល
ជវដែលនេះ នាំឲ្យខ្ញុំម្ចាស់មកកើតក្នុងត្រកូលនៃទ្រង់នេះឯង មានទាមថា
នាង វុថា តែមិនអាចរួចចាកកេរជាស្រីទៅជាប្រុសវិញបានទេ ។
បពិត្រព្រះពជបិតា ! ក្នុងថ្ងៃនេះ ស្រីខេតកញ្ញាជាច្រើននាក់ កំពុងតែក្រង
ផ្កាក្នុងនន្ទវនឧទ្យាន នាហានតាវត្តិង្ស ដើម្បីយកទៅថ្វាយខេវបុត្តឈ្មោះ
ជវៈ ដែលត្រូវជាប្ដីខ្ញុំម្ចាស់ ក្នុងជាតិជាបន្ទាប់ពីជាតិនេះ ។ លុះអនាគត
ជាតិ នៅជាតិជាតំរប់ ៧ ខ្ញុំម្ចាស់នឹងបានកើតជាខេវតាប្រុស ជាខេវបុត្រ
មានឥទ្ធានុភាពខ្លាំងណាស់ ជាងខេវតាទាំងឡាយ ។ តពីនោះទៅ ខ្ញុំ
ម្ចាស់ប្រែកេរជាប្រុស រហូតអាសាជាតិ ។

បពិត្រព្រះសម្មតិទេត ! ប្រុសបើចង់បានកេរជាប្រុសពាល់ ។ ជាតិ
ត្រូវរៀបប្រពន្ធនៃបុគ្គលដទៃ ស្រីបើចង់បានកេរជាប្រុសវិញ ត្រូវគោរពប្ដី
ដូចស្រីខេតអប្បរគោរពព្រះឥន្ទ ។ បុគ្គលដែលបានសម្បត្តិទិព្វ គឺ អាយុ
យស ទីធសេចក្ដីសុខជាទិព្វ ព្រោះរៀបអំពើបាប ប្រព្រឹត្តអំពើបុណ្យ ។

ក្នុងពេលដែលព្រះនាងវុថា កំពុងតែមានព្រះសង្វេគយ៉ាងក្រៃលែង
នៃព្រះពជបិតានោះ ព្រហ្មឈ្មោះនារទៈ នៅឯព្រហ្មលោក បានប្រមើល
មើលមកដល់ខ្លួន ក៏ឮយើញព្រះបាទអង្គតិ កំពុងតែទ្រង់ព្រះសណ្ដាប់

ព្រះនាងរុចាឲ្យលុះថ្វាយធម្មទាន ។ នាវព្រហ្មកំពុងណែនាំខ្លួនជាឥស្សរ មក
បិតនៅលើអាកាស ខាងក្នុងប្រាសាទវិមានចន្ទក នៅខាងមុខព្រះថ្កាន
អង្គុត ។ ព្រះនាងរុចាឃើញហើយក៏ថ្វាយបង្គំ ឯព្រះថ្កានអង្គុតទ្រង់ក័យ
តក់ស្លុតក៏ចុះចាកអាសនៈ ត្រាស់សួរថា «លោកជាអ្វី? មកអំពីណាមក?» ។

-អាត្មាភាពជាព្រហ្ម ឈ្មោះនារទៈ មកពីព្រហ្មលោក ។

-ទ្រង់ព្រួយរូបឆោមរបស់លោក សម្បុរល្អាស់ លោកដើរក្តី
ឈរក្តី នៅតែលើអាកាស ជើងមិនដល់ដីសោះ ការណ៍នេះឃើញថា
អស្ចារ្យណាស់ តើឫទ្ធិរបស់លោកនេះ កើតមានដោយសារអ្វី ?

-កើតមានដោយសារគុណធម៌ គឺសច្ចៈ, ធម្មៈ,
ទមៈ ចាគៈ កាលពីជាតិមុន ។

-បពិត្រព្រះនារទៈ! ចុះទេវតាមានឬ មានតាបថតាមានគុណឫ
បរលោកមានឬទេ ?

-ថ្វាយព្រះតេ! មាន តែពួកជនមានមោហៈក្រាស មិនដឹងថា
មាន ។

-បពិត្រព្រះនារទៈ! បើដូច្នោះ ខ្ញុំសូមខ្ចីប្រាក់លោក ចំនួន ៥០០
គហាបណៈ, ហើយខ្ញុំនឹងសងលោកវិញជា ១០០០គហាបណៈ តែសូម
លោកតាមទៅនាយកតំបន់ខ្ញុំឯបរលោកចុះ ។

-ថ្វាយព្រះពរមហាភាជ! ប្រសិនបើទ្រង់ធ្វើអំពើអាក្រក់ ដល់ទ្រង់ទៀតទៅ។ កើតកងនរក ឆេះក្តៅ ដោយភ្លើងកម្ទេចផ្សែង។ ត្រមាំធំ ខោះមានសត្វសាហាវ មានក្តោងឆេះសន្ធោសន្ធៅគាត់ផ្លូវ ឬជាពីធីដឹតសូន្យឈឺងជាដើម តើឲ្យអាត្មាភាពទៅតាតីទ្រង់ម្តេចបាន។

ព្រះបាទអង្គតិតាលទ្រង់ព្រះសណ្តាប់ហើយ ក៏មានព្រះទ័យភ័យតក់ស្លុតនឹងអំពើបាប ទើបក្រាបបង្គំសុំឲ្យនារទព្រហ្ម ជួយស្រោចស្រង់ឲ្យឆ្ងាយផុតចាកទុក្ខកងនរកផង សុំឲ្យប្រាប់ផ្លូវបរិសុទ្ធ ដើម្បីឲ្យបានដល់ទីដ៏ក្សេមផង។

នារទព្រហ្មបានឲ្យឧបាយដល់ព្រះរាជា ដោយអនេកបរិយាយ.....។

ប្រជុំជាតក: អលាតសេនាបតី ចេរវិលវិដ្ឋមកជាទេវទត្ត, សុនាមអាមាត្យ ជា កុក្កដ, វិដ្ឋយអាមាត្យ ជា សារីបុត្ត, វិដកបុរស ជាមោគ្គល្លាន, អចេលកៈ ឈ្មោះ គុណៈ ជា សុនក្ខត្តលិច្ឆវិបុត្ត, នាងវុឌ្ឍា ជា អានន្ទ, ព្រះបាទអង្គតិ ជា ទុរវេឡកស្សប, នារទតាបសព្រហ្ម ជា ព្រះអរហន្តសម្មាសម្ពុទ្ធ ជាគ្រូនៃយើងខ្ញុំឯង។

ចប់មហានារទកស្សបជាតក

ព្រះអភិធម្មបិដក

(គម្ពីរព្រះកថាវត្ថុ)

(តមក)

លោក ជួ - ជួ រៀបរៀង

ឧមត្ត សុតតស្ស

ឯសន្ថោ ទេវលោកស្មឹ ទេវសង្ឃបុរក្ខំតោ
សទេវកស្ស លោកស្ស សត្ថា អប្បដិបុគ្គលោ
សព្វបញ្ញត្តិកុសលោ បញ្ញត្តិបវរឧត្តមំ
វត្វា បុគ្គលបញ្ញត្តឹ លោកេ ឧត្តមបុគ្គលោ
កថាវត្ថុបករណំ អទេសយីតំ ។

លំដាប់នេះ ខ្ញុំនឹងបានពណ៌នាកង់គម្ពីរព្រះកថាវត្ថុតទៅ ដំណើរសេចក្តីថា សត្ថា រតនត្តយម្ចប់ព្រះបរមសាស្តា អប្បដិបុគ្គលោ រកបុគ្គលប្រៀបផ្ទឹមមិនបានក្នុងលោកធាតុ លោកេ ឧត្តមបុគ្គលោ ព្រះអង្គទ្រង់ឧត្តមជាងសត្វលោកទាំងពួង ទេវសង្ឃបុរក្ខំតោ គឺពួកទេវតាទាំងឡាយ មានសម្តេចឥន្ទ្រជាប្រធានចោមរោមជុំវិញ ព្រះអង្គតម្កើងក្រមដើមបានរៀបចំគម្ពីរ បញ្ញត្តិកុសលោ ព្រះអង្គឈ្លាសវៃក្នុងបញ្ញត្តិ ត្រាស់ទេសនាគម្ពីរព្រះបុគ្គលបញ្ញត្តិចប់ចុះហើយ លំដាប់ព័ន្ធនេះខ្ញុំនឹងត្រាស់ទេសនាព្រះកថាវត្ថុបករណ៍ ដោយយ៉ាងខ្លីរៀងដូចតទៅ

គ្រប់ព្រះគម្ពីរ នេះជាពុទ្ធវិស័យរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

មានពាក្យបុច្ឆាថា ហេតុដូចម្តេច បានជាព្រះគម្ពីរនេះទើបឈ្មោះថា កថាវត្ថុ ? ។

វិសជ្ជនាថា បុគ្គលកថាជាធម៌ វត្ថុតាវតោ បានជាឈ្មោះថា កថាវត្ថុនោះ ព្រោះហេតុថាជាទីទេសនាចាំងច្បាយ មានបុគ្គលកថាជាដើម ។

មានពាក្យបុច្ឆាថា ហេតុដូចម្តេច ព្រះសាស្តាទើបត្រាស់ទេសនាបំប្រួញឲ្យខ្វីក្រៃលែងជាងគ្រប់ព្រះគម្ពីរ ? ។

វិសជ្ជនាថា ព្រោះហេតុព្រះអង្គទុកឧកាសឲ្យព្រះមោគ្គលីបុត្តតិស្សត្ថេរដែលនឹងសំដែងឲ្យពិស្តារកន្លងកាលខាងមុខ ទ្រង់តំាថាណាជ្រាបថា លុះដល់ពុទ្ធសាសនាកាលកន្ទួលរលែងៗបាន ២១៨ ឆ្នាំ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ធ្វើតតិយសង្គាយនា នឹងសំដែងគម្ពីរព្រះកថាវត្ថុនេះ បំពេញតាមពុទ្ធាធិប្បាយ បរិយាយសេចក្តីពន្យ្រិកចេញៗជាសកវាទីច្រាំរយ, បរវាទីច្រាំរយ រួមជាមួយនាទព្រះសូត្រ យកមករួមបញ្ចូលក្នុងគម្ពីរកថាវត្ថុនេះ ស្មើនឹងគម្ពីរឱយនិកាយ ហេតុនេះ បានជាព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាបំប្រួញសេចក្តីឲ្យខ្វីក្រៃលែងជាងព្រះគម្ពីរទាំងពួង ។

មានពាក្យបុច្ឆាថា បើនឹងលើកគម្ពីរព្រះកថាវត្ថុនេះចេញ ព្រោះជា

ថេរកោសិត ទំនឹកចង់តែត្រឹមច្រាំមួយព្រះគម្ពីរបានឬទេ ? ដ្បិតព្រះមោគ្គលីបុត្តតិស្សត្ថេរទំនឹងសំដែងឲ្យពិស្តារកន្លងកាលខាងមុខ ទំនឹងហៅគម្ពីរកថាវត្ថុនេះថាជាពុទ្ធកាសិតគួរដែរឬទេ ? ។

វិសជ្ជនាថា គម្ពីរព្រះកថាវត្ថុនេះ កំពុងចូលកន្លងគម្ពីរព្រះអភិធម្ម ៧ ព្រះគម្ពីរ ទំនឹកចង់គម្ពីរមហាធម្មហង្សឲ្យផ្សំចូលផង ហើយគម្ពីរព្រះកថាវត្ថុនេះ ក៏ឈ្មោះថាពុទ្ធកាសិត ដ្បិតព្រះមោគ្គលីបុត្តតិស្សត្ថេរ ទំនឹងសំដែងឲ្យពិស្តារខាងមុខ ក៏សំដែងអនុលោមទៅតាមក្រសែព្រះពុទ្ធដីកាលើកបទមាតិកាឡើងជាមុនទើបសំដែងបាន មិនមែនសំដែងតាមបញ្ញារបស់ខ្លួនឯងទេ ។

ឧទេសេ្តា ហិ សម្មាសម្ពុទ្ធោ មែនពិត សម្តេចព្រះសម្មាសម្ពុទ្ធជាអម្ចាស់ កាលទំនឹងទ្រង់សំដែងគម្ពីរព្រះកថាវត្ថុនេះ ត្រាស់ជាសកវាទីទំនឹងបរវាទី ចោទសួរហើយ ដោះស្រាយៗហើយចោទសួរ ត្រាស់ជាសកវាទីមុនដំបូងថា ៖

សកវាទី – "បុគ្គលោ ឧបលព្ភតិ សច្ចិកត្ថបរមត្ថេន" សត្វសត្វកើតមកកន្លងសង្សារវដ្ត រមែងសំគាល់កន្លងរូបកាយថា សត្វ, ថាបុគ្គល, ថាជាប្រុស, ថាជាស្រី បើទំនឹងថាដោយបរមត្ថនោះតើមានសត្វ, មានបុគ្គល, មានប្រុស, មានស្រី មែនឬមិនមែនទេ ?

បរវាទី- "អាមន្តា" ដូចយើងខ្ញុំលពាក្យរបស់អ្នក! ពាក្យដែលថាសត្វ, ជាបុគ្គល, ជាប្រុស, ជាស្រី, បើនឹងថាដោយបរមត្ថនោះក៏មានពិតមែនដូចអ្នកថា ។

សភវាទី- "យោ សច្ចិកត្តោ" ពាក្យដែលអ្នកថាសត្វ, បុគ្គល, ប្រុស, ស្រី, មានពិតមែនដោយបរមត្ថនោះ យើងនៅមានសេចក្តីសង្ស័យនឹងដឿជាក់ជាពិតប្រាកដមិនទាន់ឃានទេ ខ្ញុំសូមត្រូវប្រសួរនឿងនោះតទៅទៀត ចុះរបស់ណាជាសត្វ, ជាបុគ្គល, ជាប្រុស, ជាស្រី ១ខ្នងគឺងប្រាំឬ ឈ្មោះថាសត្វ, បុគ្គល, ប្រុស, ស្រី ឬថាអាយតន:១២, ឬថាធាតុ១៨, ឬថាឥន្ទ្រិយ ២២ ឈ្មោះថាសត្វ, បុគ្គល, ប្រុស, ស្រី? ។

បរវាទី- "ន មោរំ វត្តព្វេ" កុំគប្បីថាយ៉ាងនេះ មិនគួរទេ ។ ១ខ្នង, អាយតន:១២, ធាតុ១៨, ឥន្ទ្រិយ ២២ នោះទើងបានឈ្មោះថាសត្វ, បុគ្គល, ប្រុស ស្រី ដូចពាក្យអ្នកថានោះក៏ទេ ។

សភវាទី- ពាក្យខាងដើមនោះយើងសួរអ្នកថា ដោយបរមត្ថនោះ សត្វ, បុគ្គល, ប្រុស, ស្រី មានពិតមែនឬមិនមែនទេ? អ្នកក៏ឆ្លើយតបថា មានពិតមែនហើយ ។ លុះដល់យើងសួរថា ១ខ្នងឬអាយតន: ឬធាតុ ឬឥន្ទ្រិយ ឈ្មោះថាសត្វ, បុគ្គល, ប្រុស,

ស្រី នោះអ្នកក៏បដិសេធថាមិនមែនទេ ។ កំណត់តើតមកដារូបជាកាយ
ហើយ ជាទីប្រជុំនៃខន្ធ៥, អាយតន:១២, ធាតុ១៨ ឥន្ទ្រិយ២២
បើអ្នកថាមិនមែនជាសត្វ , បុគ្គល, ប្រុស, ស្រីហើយ តើអ្វីហៅថាសត្វ,
បុគ្គល, ប្រុស, ស្រី ទៅវិញ ? ។

បរវាទី - ពាក្យដែលយើងឆ្លើយថា សត្វ, បុគ្គល, ប្រុស, ស្រី
មានពិតមែន ព្រោះយើងបានឃើញព្រះសុត្តន្តបិដក លើកវឿងមក
ពោលទុកថា កុសលំ ភោ ឆ្លោ ជននៅក្នុងស្រុកនោះ ឈ្មោះនោះ
ធ្វើកុសលនោះ លុះរលត់បញ្ចក្ខន្ធបានទៅកើតក្នុងស្ថានសួគ៌ជាន់នោះ
សោយទិព្វសម្បត្តិបរិបូណ៌យ៉ាងនោះ មានបរិវារច្រើនប៉ុណ្ណោះ ហើយ
សេសសល់កុសលនោះតាមអំណាចផល គឺបុគ្គលនោះបានឲ្យបដិសន្ធិ
ជាតន, ស្រីឈ្មោះនោះ, ប្រុសឈ្មោះនោះ បានវត្ថុស័ល ៥, ស័ល
៨, ស័ល ១០, ស័ល ២២៧ កាលនៅត្រាច់ឆ្ពោះត់ក្នុងកាលវដ្តសង្សារ
បានសោយសុខក្នុងមនុស្សលោកទំនឹងក្នុងទេវលោក លុះដល់ជាតិជាទី
បំផុតបានជាអង្គព្រះអរហន្តសម្រេចព្រះអរហត្តភាត់ផ្លាបធម៌បាន ។

ប្រការមួយទៀត ចំណែកខាងអកុសលក៏មានចែងថា បុគ្គលប្រុស
ស្រីឈ្មោះនោះ នៅក្នុងស្រុកនោះ ធ្វើអកុសលកម្មយ៉ាងនោះ គឺធ្វើ
បាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ, មុសាវាទ, សេពសុក.

មើយលុះក្រុយជីវិតហើយ អំណាចនៃអកុសលកម្មដែលខ្លួនបានធ្វើបេ
មកហើយនោះ ឲ្យធលឲ្យធ្លាក់ទៅនរក ទើបទៅកើតជាប្រេតពួកនោះជា
អសុរកាយពួកនោះ ជាសត្វតិរច្ឆានយ៉ាងនោះ ។ យើងយើញមាន
សេចក្តីកង្វល់សុគន្ធចិដកយ៉ាងនេះ ។ បានជាយើងហ៊ានគោលថា មាន
សត្វ, មានបុគ្គល, មានប្រុស, មានស្រី ។

សកវាទី- បើអ្នកអាងថាយើញសត្វ, បុគ្គល, ប្រុស, ស្រី
មានពិតមែនដូច្នោះ អ្នកចូរសំដែងឲ្យបានសំលាស់ ១ទ្ធ៩, អាយតនៈ-
១២, ធាតុ ១៨ ទើងឥន្ទ្រិយ ២២ ឈ្មោះថាសត្វ, បគ្គល, ប្រុស ស្រី
ចូរថាឲ្យយើញពិត ឲ្យយើងមស់សង្ស័យផង ? ។

បវាទី- ដែរបេយើងថា មានសត្វ, បុគ្គល, ប្រុស, ស្រីនោះ
ថាតាមយើងយើញក្នុងព្រះសូត្រ មិនមែនថាតាមបរមត្ថទេ សូម្បីយើង
ថាតាមបរមត្ថនោះទៀត ក៏ថាគ្មានសត្វទើបុគ្គល, គ្មានប្រុសទើស្រីដែរ
គ្រាន់តែមានខន្ធ, ធាតុ, អាយតនៈ ទើឥន្ទ្រិយប៉ុណ្ណោះ ។

សកវាទី- ហេតុអ្វី បានជាអ្នកធ្វើយយ៉ាងនេះ ដើមធំបួងយើង
សួរអ្នកថា បើនិយាយតាមបរមត្ថ តើមានសត្វ, មានបុគ្គល, មានប្រុស,
មានស្រីដែរឬទេ? អ្នកឆ្លើយថាមាន, យើងសួរអ្នកតទៅទៀតថា ខន្ធឬ-
ធាតុ, ឬអាយតនៈ, ឬឥន្ទ្រិយ អ្នកត្រឡប់ជាធ្វើយថា គ្មានសត្វ, គ្មាន

បុគ្គល, គ្មានប្រុស, គ្មានស្រីទេ មានតែខន្ធ, ធាតុ, អាយតនៈ, ឥន្ទ្រិយ
ទៅវិញ ហើយបែរជាឆ្លើយថា មានសត្វ, មានបុគ្គល, មានប្រុស,
មានស្រីនោះគឺថាតាមព្រះសូត្រមិនមែនថាតាមបរមត្ថ, យើងសួរពីបរមត្ថ
អ្នកទៅឆ្លើយឯព្រះសូត្រវិញ ពាក្យមុនទឹងពាក្យក្រោយបេះអ្នកមិនស្របគ្នាសោះ
អាជានាហិ និក្កង្ខោ អ្នកចូរដឹងចោមថាគួរតែខ្ញុំសង្កត់
សង្កិន ដ្បិតអ្នកថា សត្វ, បុគ្គលមាន ដល់ខាងក្រោយត្រឡប់ជា
គេចតែថាគ្មានទៅវិញ ។

បរវាទី - ខ្ញុំសូម ហួរត្រឡប់ទៅអ្នកម្ចាស់វិញថា ធម្មតាបុគ្គលតាំង
ពួន រមែងសំគាល់ក្នុងរូបកាយថាជាសត្វ, បុគ្គល, ប្រុស, ស្រី បើនឹង
ថាតាមបរមត្ថ មិនមែនឈ្មោះថាសត្វ, បុគ្គល, ប្រុស, ស្រីទេ ចាត់ជា
ខន្ធ, ធាតុ, អាយតនៈ, ឥន្ទ្រិយទៅវិញ យ៉ាងនេះពិតប្រាកដមិនពិតទេ ?

សកវាទី - ពិតដូចពាក្យអ្នកថានោះហើយ បើនឹងថាតាមបរមត្ថ
នោះ រូបកាយតាំងពួននេះ ចាត់ជាខន្ធ, ជាធាតុ, ជាអាយតនៈ,
ជាឥន្ទ្រិយ ។ បើនឹងថាផ្សំផ្គុំតសុទ្ធមកពុះទៅទៀត កំមានតែកងរូប,
វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ។ ឯរូបកាយនេះជាទីប្រតិស្ឋាននៃ
អាយតនៈ គឺចក្ខុ, សោត, ឃាន, ជិវ្ហា, កាយ, មន ។ រូបកាយនេះ
ជាទីប្រជុំនៃធាតុ ១៨ មានចក្ខុធាតុ, រូបធាតុ, ចក្ខុវិញ្ញាណធាតុជាដើម ។

រូបកាយនេះ មានតែឥន្ទ្រីយ ៦ មានចក្ខុន្ទ្រីយជាដើម ទើបមានសត្វ, បុគ្គល, ប្រុស, ស្រីនោះ កំឥតអង្គីមានឡើយ អ្នកគប្បីចូលចិត្តដូច្នេះចុះ ។

បរវាទី- ពាក្យក្នុងព្រះសូត្រថា ស្រីឈ្មោះនោះ ប្រុសឈ្មោះនោះ ធ្វើទុច្ចរិតដោយកាយវាចាចិត្ត លុះលះបង់ក្នុងន្លះហើយ បានទៅកើតក្នុងទុគ្គតិចតុកថាយ ដោយសេសបាបទៅសល់ខ្លះនោះ លុះមកកើតក្នុងមនុស្សលោកប្រកបដោយអាការគួរឱ្យខ្ពើមឆ្អើមជាដើម ។ ម្យ៉ាងទៀត ប្រុសឈ្មោះនេះ ស្រីឈ្មោះនេះ បានធ្វើសុចរិតដោយកាយវាចាចិត្ត លុះអស់ជីវិតហើយ បានទៅកើតក្នុងសុគតិសួគ៌ ពាក្យក្នុងព្រះសូត្រដែលថាយ៉ាងនេះមានជាច្រើនកន្លែងណាស់ ពាក្យមិនអស់ទេ បើដូច្នេះមិនខុសទៅហើយឬ ? ។

សកវាទី- ពាក្យក្នុងព្រះសូត្រ ទើបក្នុងបរមត្ថនោះ មិនខុសគ្នាទេ ជាទីពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក ជាពាក្យពិតប្រាកដដូចគ្នាទាំងព្រះសូត្រទាំងបរមត្ថ ។

ពាក្យក្នុងព្រះសូត្រថា សត្វ, បុគ្គល, ប្រុស, ស្រីដូច្នេះ ហៅតាមសម្មុតិសច្ច, ដែលហៅថា ខន្ធ, អាយតន, ធាតុ, ឥន្ទ្រីយនោះហៅតាមបរមត្ថសច្ច ។ ឯសម្មុតិសច្ច ទើបបរមត្ថសច្ចទាំង ២ ប្រការនោះអាស្រ័យខ្នុំគ្នាទីពឹងគ្នា បើបរមត្ថសច្ចកើតមានឡើងក្នុងកាលណា សម្មុតិសច្ចក៏

កើតមានឡើងក្នុងកាលខោះដែរ ប្រៀបដូចសូរសំឡេងដែលឮតាមកងរំពងក្នុងព្រៃ ទើបកើតមានឡើងបានតំណាស្រាយតែបុគ្គលអ្នកនៅក្បែរព្រៃស្រែកបន្ទឺឡើង មានឧបមាយ៉ាងណា សម្មតិសច្ចទើបមានសច្ច កំមានឧបមេយ្យយ៉ាងនោះ ។ សត្ត បុគ្គល, ប្រុស, ស្រី ទើបកើតមានឡើងបាន កំព្រោះតែ ខន្ធ, ធាតុ, អាយតនៈ, ទើបឥន្ទ្រីយកើតមានឡើងដែរ ត្រូវអ្នកបួលចំគ្គតាមន័យនេះចុះ ។

តីហាអរហាកកថា

តីហា អរហាកកថា អត្ថំ តីហា អរហាទីណាសវោ អនុប្បត្តសធម្មោ ខុទាហុ ធម្មំ បញ្ញបេតោ យេវ អរហា ហោតិ ខុទាហុ អត្ថំតិ ។

ក៏នេះ ទើបបានវិសជ្ជនាក្នុងតីហាអរហាកកថា ដែលមានមកក្នុងព្រះកថាវត្ថុបករណ៍តទៅ ដំណើរសេចក្តីថា សម្តេចព្រះមានព្រះភាគ ត្រាស់ទេសនាជាសកវាទីនិងបរវាទី ដូចតទៅនេះ ៖

សកវាទី– " អត្ថំ តីហាអរហោ " បុគ្គលជាត្រហស្ថ បានសម្រេចអរហត្តភាត់កំលេសជាច់ជាសមុច្ឆេទបហាន អស់អាសវៈពាំនឹងប្តូនប្រការហើយ ទើបមានប្រយោជន៍នៃខ្លួន តំព្រះអរហត្តផលបានដល់ហើយ មានខ្លះដែរឬទេ ឬក៏មានចំពោះតែបព្វជិតមួយពួកប៉ុណ្ណោះ ? ។

(នៅមានត)

សម្តេចព្រះធម្មលិខិត ល្វី ឯម ប្រែរៀបរៀង

(ត)

ឯស្តេចឃាបនោះសោត បានស្តាប់តាក្យនោះហើយ ក៏ឆន់ពុំលែង ខ្សោយ ត្រាស់បង្គាប់មន្ទុស្សទាំងឡាយថា អ្នកទាំងឡាយត្រូវចាប់ នាងខៅនេះ ឲ្យដំដៃនឹងជើង ហើយបោះទៅក្នុងគំនរនៃក្លែងឲ្យឆាប់ ។ ឯមន្ទុស្សទាំងឡាយនោះ ក៏បានព្រួតគ្នាចាប់ព្រះនាងខៅនោះបោះទៅក្នុងគំនរនៃក្លែងតាមបង្គាប់នៃស្តេចឃាបនោះឯង ។

បពិត្រអើយ! គួរអោសូព្រះនាងខៅនោះពន់ពេក កាលណាបើគេចាប់បោះទៅក្នុងក្លែងហើយ នាងក៏គិតពិចារណាថា ឱអញអើយ! បុគ្គលឯណាមួយជាទីពឹងអញក្នុងទីនេះ ពុំមានសោះឡើយ, មានតែព្រះគន្ធត្រយជាទីពឹងទីរឭកទើបបាន, នាងខៅគិតដូច្នេះហើយ, ក៏ពោលថា ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ប្រែថា ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក, សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក, សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក នាងខៅពឹងគិតរឿយៗតែដោយចិត្តពុំជាប់ ហើយដួល

ចុះទៅក្នុងគំនរក្លែងនោះឯង ។

ដោយតេជៈគុណព្រះរតនត្រ័យ សូមម្បីតំនរក្លែងនេះទៀងសន្ធៃ សន្ធៅក្រហមដូច្នោះក្តី កំតង់ពុំអាចដើម្បីធ្វើឲ្យរំចំហាយក្តៅសូម្បីត្រាន់តែរណ្តៅកេមមួយ ឲ្យកើតឡើងក្នុងសរីរៈនៃព្រះនាងទេវីនោះឡើយ ។ ឯព្រះនាងទេវីនោះ មានសរីរៈពាំងអស់ ដ៏ត្រជាក់ស្រួលជាប្រក្រតី ដូចជាចួលទៅកាន់ផ្ទៃនៃផ្កាឈូក ឥតមានក្តៅក្រហាយអ្វីតិចតួចឡើយ ។ ឯព្រះចាតុបច្ចន្តរាជ ស្តេចឃ្លានទៅឃើញសេចក្តីអស្ចារ្យនោះហើយ ក៏មានព្រះទ័យសង្វេគព្រឺព្រួចព្រះលោមា លីលាចួលទៅជិត ដោយរហ័សរួសរាន់ ហើយលើកឡើងដោយព្រះហស្តទាំងពីរ ក្រោបបុះខៀបទ្រូងព្រះនាងទេវី ផ្គងឡើងទៅអញ្ជលី ហើយត្រាស់សួរព្រះនាងទេវីថា ក្លែងនេះពុំចាននរលោកក្តៅនេះទេ្យសរីរៈនាងតើព្រោះហតុអ្វី ? ។

ឯព្រះនាងវិសាខាមិគារទេវីនោះសោត កាលសម្តែងទូន្មហេតុនោះ ក៏សូត្រជាបទព្រះគាថាដូច្នេះថា ៖

មាតាបិតា ច ញាតិ ច បរិជាតា ច សោទរា
មិត្តាសជ្ជាទយោបិ ច មហេសក្ខា ច នេរវា,
ឯតេ ចញ្ញេ ច ភូបាល សត្តានំ កយមាកតា
រក្ខិតុំ នេវ សក្កោន្តិ ហិត្វាន សរណាគ្គយំ ។

សេចក្តីថា បពិត្រព្រះភូបាល ! បុគ្គលទាំងឡាយដទៃនេះ គឺមាតា

ចិតាក្តី ញាតិទាំងឡាយក្តី បរិវារទាំងឡាយក្តី បងប្រុសបងស្រីកើតក្នុងផ្ទៃ
មាតាជាមួយគ្នាក្តី ម្យ៉ាងទៀត បុគ្គលដែលចេះមន្តចេះថ្នាំ ទុសជាដើមក្តី
ទៅតាទាំងឡាយដែលមានសក្តិធំក្តី លះចេញរឿយៗនៃតែគុណព្រះរតន-
ត្រ័យចេញ. អ្នកទាំងអស់នោះ គេចបីមកដល់ហើយ ក៏ធំពុំអាចដើម្បី
ធ្វើឱ្យក្បាការតាទៅកើតអន្តរាយ ដែលបង្កើតដល់សត្វទាំងឡាយបានឡើយ ។ មានតែគុណព្រះរតនត្រ័យ ទើបអាចធ្វើឱ្យជួយការពារទៅកើត
អន្តរាយបានដោយពិត ។

បត្តាហំ ពុទ្ធំ សរណំ គច្ឆាមេ សរណំ នតិ
តេន តេជេន មំ ភទ្ទំ ឧលន្តោ អក្ខិ នោ ឧហិ។

ខ្ញុំម្ចាស់ បានដល់នូវព្រះពុទ្ធជាទីពឹងដូច្នេះថា ព្រះពុទ្ធជាទីពឹងរបស់
ខ្ញុំពិត, បពិត្រព្រះអង្គជាស្តេច ! ដោយតេជៈនោះហើយ បានជាភ្លើង
ដែលឆេះរុងរឿងខ្លាំង ក៏ពុំអាចធ្វើឆេះរលាកខ្ញុំឡើយ ។

បត្តាហំ ធម្មំ សរណំ គច្ឆាមេ សរណំ នតិ
តេន តេជេន មំ ភទ្ទំ ឧលន្តោ អក្ខិ នោ ឧហិ។

ខ្ញុំម្ចាស់ បានដល់នូវព្រះធម៌ជាទីពឹងដូច្នេះថា ព្រះធម៌ជាទីពឹង
របស់ខ្ញុំពិត, បពិត្រព្រះអង្គជាស្តេច ! ដោយតេជៈនោះហើយ បានជាភ្លើង
ដែលឆេះរុងរឿងខ្លាំង ក៏ពុំអាចធ្វើឆេះរលាកខ្ញុំឡើយ ។

បត្តាហំ សង្ឃំ សរណំ សង្ឃោ មេ សរណំ នតិ

តេន តេជេន មំ ភគ្គ ជលន្តោ អត្តំ នោ ឧហិ ។

ខ្ញុំម្ចាស់ បានដល់នូវព្រះសង្ឃជាទីពឹងដូច្នេះថា ព្រះសង្ឃជាទីពឹងរបស់ខ្ញុំតែ បពិត្រព្រះអង្គដ៏ចម្រើន ! ដោយតេជៈនោះហើយ បានជាភ្លើងដែលឆេះរុងរឿងខ្លាំង ក៏ពុំអាចនឹងឆេះលោកខ្ញុំឡើយ ។

ឃវំ មហានុភាវន្តំ បច្ចន្តំ ឃហិ បស្សតុ
ជាតោ បន្ធវធំ សិនំ ជាតាសម្បត្តិជាយកំ
សរណាគតាយ ហិ សោ សត្តោ ឧ សមាជាយ កណ្ហាតិ
ឥធ ភ បរត្ថ ភ លោកេ សោ សុខំ ជានុកោសតិ ។

សត្វឯណា បានឃើញនូវប្រដុំចំនៃព្រះរតនៈគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលមានអានុភាពធំយ៉ាងនេះ អាចកំចាត់បង់នូវទុគ្គតផ្សេងៗ អាចឲ្យនូវសម្បត្តិផ្សេង ។ ដោយចំណែកមួយឯតគ, សត្វនោះមើពុំបានសមាទានកាន់យកនូវព្រះត្រៃបរណគមន៍ហើយ សត្វនោះនឹងពុំបានសោយនូវសេចក្តីសុខ ក្នុងលោកនេះឯង ក្នុងលោកខាងមុខផង ដោយពិត ។

សរណាគតាយ ហិ សោ សត្តោ សុសមាជាយ កណ្ហាតិ
ឥធ ភ បរត្ថ ភ លោកេ សោ សុខំ ឧ វិជ្ជមានិ
តស្មា តុវម្បិ ភូចាល កណ្ហាហិ សរណាគតាយ

តន្តេ ភវតិ សព្វត្ថ តាណំ លេណំ បភាយនំ ។

សេចក្តីពិតថា សត្វនោះ បើបានសមាគមល្អ ការយកនូវគុណ
ព្រះតេនត្រ័យជាទីពឹងហើយ, សត្វនោះ តុំបានលះបង់នូវសេចក្តីសុខ គឺ
ថាទីឆ្ងាយបានសោយសេចក្តីសុខក្សេមក្សាន្តក្នុងលោកនេះផង ក្នុងលោក
ខាងមុខផងដោយពិត. បពិត្រព្រះកូបាល ! ព្រោះហេតុដូច្នោះ សូមព្រះ
អង្គការយកនូវគុណព្រះតេនត្រ័យជាទីពឹងចុះ ឯគុណព្រះតេនត្រ័យនោះ
ទីឆ្ងាយចើតជាទីពឹងជាទីអាងពំនាក់ភាក់ពួនជ្រកកោន ប្រព្រឹត្តទៅខាងមុខ
ដល់ព្រះអង្គក្នុងកាលចាំដួងដោយពិត ។

ឯព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ព្រះគាថានោះហើយ មានព្រះ
ហឫទ័យជ្រះថ្លាពន់ពេក ព្រះអង្គសូមទ្បើព្រះនាងទេវីនោះអត់ទោសដល់
ព្រះអង្គ ស្រេចហើយស្តេចធ្វើសក្ការៈបាយាំងធំបំផុតពោលថា ចាប់
ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះនាងទេវីធ្វើជាព្រះមាតានៃខ្ញុំ ដោយពិត,
រួចស្តេចដណ្តើមព្រះនាងទេវីនោះកន្លងទីជាព្រះមាតាបង្កើតរបស់ព្រះអង្គហើយ
បានទទួលយកព្រះវៃស្រវណគមន៍តាំងបី ជាទីពឹងទីពួកក្នុងកាលនោះ
ឯង ។ ឯមហាជនតាំងម្ភាយ ដែលបានមកប្រជុំក្នុងទីនោះតាំងប៉ុន្មាន
បានឃើញបាដិហារ្យជាអស្ចារ្យដូច្នោះ ក៏មានសេចក្តីជ្រះថ្លា បាន
ស្ថិតនៅក្នុងសរណគមន៍តាំងបីជាទីពឹងផង បានស្ថិតនៅក្នុងសីលតាំង

ប្រាំផង, ហើយតែងប្រព្រឹត្តធ្វើនូវបុញ្ញកម្មជាំងឡាយមានទានជាដើម ជាប់ពុំដាច់ដរាបដល់អស់ជីវិត ក៏បានទៅកាន់ស្ថានសួគ៌ សោយទិព្វសម្បត្តិដ៏សមគួរតាមកុសលកម្មរបស់ខ្លួនទៀតៗ ទៅហោង ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តជាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

តំ សរណំ វរំ សា តេសំ ទុក្ខហេតូ
ជលិតនហានមជ្ឈេ សីតភាវំ ว បត្តា
បរមសរណាសីលំ ចាលយន្តា តេ ភេ
ន លភថ ភវភោគំ និព្វតិញ្ចាបិ អន្តេ ว

សេចក្តីថា ព្រះនាងទេវីព្រះនាមវេស្សាមិត្តា នាងបានទទួលកាន់យកនូវព្រះរតនត្រ័យជាំងបីជាទីពឹងដ៏ប្រសើរ, កាលបានរក្សានូវសរណៈនឹងសីលដ៏ខ្ពង់ខ្ពស់យ៉ាងនេះ តែប៉ុណ្ណោះ ព្រះនាងទេវីក៏បានដល់នូវភាវៈត្រជាក់ ក្នុងកណ្តាលនៃគំនរភ្លើងដ៏ឆេះរុងរឿងគួរសោក ហើយពុំបានឆេះពុំបានរលាកឡើយ, ចំណែកឯអ្នកជាំងឡាយជាសប្បុរស ដែលបានដល់នូវសរណៈនឹងសីលជាទីពឹងហើយ នឹងពុំបាននូវភោគសម្បត្តិក្នុងភពនឹងព្រះនិព្វានជាទំលត់នូវកងទុក្ខជាំងពួង ក្នុងទីបំផុតជាតិដូចម្តេច

មុខជានឹងបានសម្រេចសម្បត្តិ នឹងព្រះនិព្វានជាយ៉ាងពិត ។

សម្តែងរឿងនិទានវេស្សាមិត្តាខេរីជាគំរប់ ៧ ក្នុងវគ្គមួយ ក៏ចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណេះឯង ។

៩- មហាមង្ឃាតុវគ្គកថា សម្តែងរឿងនិទានព្រះបាទមន្ធាតុព្រះបរមចក្រពត្រាធិរាជគ ៧ខៀត តាមបទព្រះបាលីថា ៩ តោ កិរ ឯក្ខ ឧបាតិ កប្បមត្តកេ ដូច្នេះជាដើម អធិប្បាយស្រាយជាសេចក្តីថា កិរ បានឮរឿង ។ មកកាន់ចំបងនៃកប្ប ៩១ អំពីកប្បយើងនេះ មានព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមវិបស្សី ព្រះអង្គបានត្រាស់បរមាភិសេកសម្ពោធិញ្ញាណ ជាព្រះពុទ្ធប្រាកដក្នុងលោក ព្រះអង្គមានព្រះធម៌ដ៏ប្រសើរ បំភ្លឺចជាកងចក្ខុបានឲ្យប្រព្រឹត្តទៅហើយក្នុងលោក, តិសត្វលោកទាំងឡាយ ព្រមទាំងទេវតា បានបួងជាទមស្ការព្រះអង្គហើយ ព្រះអង្គតម៌ទៅកាន់ខន្ធាវតារក្នុងកាលនោះឯង ។

គ្រានោះ ព្រះបាទមន្ធាតុ បានទៅកើតជាជាន់ជុលសំពត់កាន់ខន្ធាវតារនោះឯង ជាអ្នកលក់ក្រកេស៊ីចិញ្ចឹមជីវិតដោយតុច្ឆកម្ម (អំពើធ្វើការឈ្លេសជុលសំពត់)ឲ្យគេ យកថ្លៃឈ្លេសចិញ្ចឹមជីវិតជានិច្ច ។ ឯមនុស្សទាំងឡាយដែលទៅកាន់ខន្ធាវតារទាំងអស់ កំបានទិន្នព្រះតំកូរសង្ឃជាច្រើន មានព្រះពុទ្ធជាប្រធាន បានថ្វាយទូរមហាទានក្នុងកាលនោះឯង ។

ឯបុរសកំសត់នោះ កំពុងរំពឹងគិតពិចារណាថា មនុស្សដែលនៅកន្លែងព្រះខន្ធគ្រាំងអស់ គេបានចាត់ចែងឲ្យមហាជន, ដល់ព្រះភិក្ខុសង្ឃមានអគ្គព្រះពុទ្ធជាប្រធាន ឯអាត្មាអញជាមនុស្សសេសសល់តែម្នាក់ឯងផ្តេសផ្តាស ព្រោះអញជាអ្នកកំសត់ បើអាត្មាអញមិនបានជាំពូជបុណ្យទុកក្នុងព្រះពុទ្ធសាសនានេះទេ អញនឹងពុំបានដោះខ្លួនឲ្យរួចអំពីសេចក្តីទុក្ខលំបាកយាល់ក្រនេះឡើយ, តទៅជាតិខាងមុខ អញក៏នឹងតែកំសត់ដ៏ក្រលែងជាងនេះទៀត ដោយពិត ។ បុរសកំសត់នោះបានគិតយ៉ាងនេះហើយ ក៏ដើរស្វែងរកក្នុងទីគម្មស៊ីឈូសដុលសំពត់ឲ្យគេដោយឆាប់រួសរាន់ បានខ្ចប់ក្រាក់បន្តិចបន្តួចមួយមាសក, កាលបើបានឧកាសល្មមឲ្យបានដល់កិក្ខុមួយរូប ដោយប្រាក់មួយមាសនោះហើយ ក៏ដើរចូលទៅកាន់ពន្លារ បានទិញយកខ្ចប់សណ្តែកពងមាស បានចំនួនមួយដើងភាជនតូច ហើយកាន់យកចូលទៅកាន់ភេនកត្តដែលជាទីប្រជុំនៃព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយរំពឹងគិតដូច្នេះថា ឥឡូវនេះអញពុំមានឧកាសនឹងជាក់ចុះ ខ្ចប់សណ្តែកពងមាសក្នុងជាត្រនៃភិក្ខុបានឡើយ សូម្បីតែភិក្ខុមួយរូបក៏អញឲ្យពុំបាន សេចក្តីពិតត្រូវតែអញបាចសណ្តែកពងមាសទាំងឡាយនេះ ទៅលើអាកាសទើបបាន, ឯសណ្តែកពងមាសទាំងឡាយនោះ កាលបើធ្លាក់ចុះអំពីអាកាសមកហើយ

កំតង់មានសណ្តែកមួយគ្រាប់តាគ្រាប់ ធ្លាក់ចុះក្នុងជាត្រកិក្តុមួយរូបតុំលែង
ឡើយ សណ្តែកដែលបានធ្លាក់ចុះក្នុងជាត្រកិក្តុមួយរូបប៉ុណ្ណោះ កំមានផលានិសង្ស អាចនាំមកនូវប្រយោជន៍ នឹងសេចក្តីសុខ សេចក្តីចំរើនដល់អញ្ញមស់គាលជាយូរអង្វែងទៅអនាគតដោយពិត ។ បុរសនោះឃានតិតយ៉ាងនេះហើយ កំមានចិត្តជ្រះថ្លាមានសទ្ធាជឿជាក់ទស្សាហ៍កើតឡើង កំពាប់សណ្តែកពងមាសទាំងឡាយចុចទៅលើអាកាស ដើម្បីនឹងឲ្យបានធ្លាក់ចុះកន្លងជាត្រនៃព្រះកិក្តុសង្ឃទាំងអស់ មានជាត្រព្រះពុទ្ធជាប្រធាន ។ ឯគ្រាប់សណ្តែកពងមាសទាំងឡាយនោះ គាលអណ្តែតទៅលើអាកាសជាអស្ចារ្យ ហើយធ្លាក់ចុះពីអាកាសនោះ កំពុំបានធ្លាក់ចុះខុសជាត្រទៅខាងក្រៅឡើយ សឹងធ្លាក់ចុះក្នុងជាត្រនៃព្រះកិក្តុសង្ឃទាំងទស់ មានជាត្រព្រះមានព្រះភាគជាដើម ដោយគេជានុភាពនៃទៅតាទាំងឡាយផង នៃព្រះមានព្រះភាគផង ដោយវិសេសពិត ។ ឯបុរសកំសត់នោះ បានឃើញនូវសេចក្តីអស្ចារ្យនោះហើយ មានចិត្តប្រកបដោយបីតិសោមនស្សជ្រះថ្លាពន់ពេក លើកទញ្ជលីផ្គងឡើងលើសិរសា ហើយតាំងនូវសេចក្តីប្រាថ្នាយ៉ាងនេះថា ៖

« ដោយសេចក្តីជ្រះថ្លា ដែលខ្ញុំបានធ្វើបូជារំពឹក្រលែងនេះ ទៅអនាគតកាលខ្ញុំសូមប្រាថ្នាឲ្យបានជាបុគ្គលដ៏ប្រសើរ ជាធំបំផុតជាងបុគ្គល

តាំងឡាយ ដែលជាអ្នកបរិភោគនូវកាមគុណក្នុងលោក បើខ្ញុំអនុញ្ញាត
ទៅកើតក្នុងជាតិតាំងក្នុងកតាហើយ ខ្ញុំលើកដៃឡើងខំសំឡឹងមើលនូវ
អាកាសក្នុងកាលឯណា សូមផ្ទៃអាកាសបណ្តាលកើតឡើងជាភ្លឿនតែវ
ប្រការ បង្អុរធ្លាក់ចុះមកសព្វកាលតាំងតួង" ។

ចាប់ដើមតាំងតែពីកាលនោះមក បុរសកំសត់នោះបានតាំងសេចក្តី
ប្រាថ្នាយ៉ាងនេះហើយ កំពុងតែស៊ូចិញ្ចឹមជីវិតដោយសុចរិតទៀងត្រង់ល្អ
ដំរាបដល់អស់ជីវិតទៅ កំបានអនុញ្ញាតទៅអនុញ្ញាតមកតែក្នុងស្ថានមនុស្ស
ដ៏ខ្លីតែតាំងឡាយ តែងចេញនូវមិត្តសម្បត្តិដ៏ប្រសើរ លុះមកដល់
កប្បនេះ មានព្រះបរមគ្រូតិរ្ថ័យមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទ
មហាសម្មតិទេព ជាគ្រូតិរ្ថ័យខាងដើមវង្សក្នុងកប្បនេះ, ស្តេចមហាសម្មតិ-
ទេពនោះ មានព្រះរាជបុត្រាមួយព្រះនាម រោជៈ បានសោយរាជ្យត
រៀងមក, ព្រះរាជបុត្រចេស់ស្តេចរោជៈនោះ ព្រះនាមវររោជៈ ព្រះរាជ
បុត្រចេស់ស្តេចវររោជៈនោះ ព្រះនាមកល្យាណៈ ព្រះរាជបុត្រចេស់ស្តេច
កល្យាណៈនោះ ព្រះនាមមន្ធាតុ គឺបុរសកំសត់ដែលបានឲ្យទានសណ្ឋាគ
ភជមាសក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ។ ដោយអំណាចផលា-
និសង្ស ដែលបានឲ្យទានសណ្ឋាគភជមាសស្មោរនោះ កំបានកើតជា
អស្ចារ្យពន់ពេកណាស់ កាលទៅជាកុមារលេងអាចម៍ដី, កាលចេះសព្វាយ

ព្រះជ័យ លើកដៃខាងឆ្វេងឡើងចុះដោយដៃខាងស្តាំកាលណា ស្រាប់តែមានផ្លែឪកាសបណ្តាលឡើងជាភ្លៀវតែ ៧ ប្រការ ធ្លាក់ចុះមកមួយរំពេច ទឹងប្រមាណពុំបានឡើយ ក្នុងកាលនោះឯង, ដែលទៅតំលើងជាកុមារចំនួនប្រាំបីម៉ឺនបួនសាន់ន្នាំ ដល់បាទឡើងទីជាព្រះមហាឧបភជបានប្រាំបីម៉ឺនបួនសាន់ន្នាំទៀត, បានចូលកជាកំសេកជាស្តេចព្រះបរមចក្រពត្តិ ប្រកបដោយភជប្បទំពាំងបួន ទឹងចក្រពាំង ៧ ប្រការ មានចក្រកែវជាដើម ហេយភជសម្បត្តិក្នុងទ្វីបធំពាំងបួន មានទ្វីបតូចពីរពាន់ជាបរិវារ ព្រមទាំងព្រះទាមព្រះបាទមន្ធាតុព្រះបរមចក្រ សឹងមានតួកមហាក្សត្រិយ៍សុទ្ធក្នុងទ្វីបធំពាំងបួនជាក់វណបម្រើ ក្នុងមួយថ្ងៃ ៗ ប្រាំបីម៉ឺនបួនសាន់ព្រះអង្គពុំដែលដាច់ឡើយ ។

ចំណែកឯអាយុមនុស្សពាំងឆ្ងាយក្នុងកាលនោះ កំណត់មួយអសំខ្យដោយពិត ។

ឯព្រះបាទមន្ធាតុព្រះបរមចក្រនោះ ព្រះអង្គបានសោយភជ្ឈាស្តេចចក្រពត្តិបានចំនួនប្រាំបីម៉ឺនបួនសាន់ន្នាំហើយ មានសម័យថ្ងៃមួយ ព្រះអង្គពុំអាចឆ្អែតឆ្អន់នឹងកាមតណ្ហា សេចក្តីប្រាថ្នាក្នុងកាមគុណឱ្យតេជាព្រះជ័យបានឡើយ ហើយព្រះអង្គសម្តែងនូវអាការអផ្សុកជាទុក្ខ ព្រួយព្រះជ័យដ៏មានព្រះតក្តីក្រៃក្រៃមក្រំសៅហ្មងក្នុងកាលនោះឯង ។

ឯអាមាត្យតំឆ្កែយ ឃើញព្រះបរមក្សត្រ្យ៍ព្រះអង្គមានព្រះតក្រ្តសៅហ្មងដូច្នោះហើយ កំក្រមខ្លួលសួរថា "បពិត្រព្រះសម្មតិទេព! ព្រះអង្គទ្រង់អផ្សុកព្រួយព្រះទ័យដូចម្តេច?" ។

ឯព្រះបាទមន្ធាតុព្រះបរមចក្រនោះ ព្រះអង្គត្រាស់ថា! ម្នាលអ្នកតំឆ្កែយដ៏ចំរើន! កាលអញពិចារណាមើលទ្រព្យប្តូរកម្មរបស់អញជាអស្ចារ្យ អញយល់ឃើញថា រាជសម្បត្តិនេះ មិនល្មមសមគួរដល់បុណ្យអញឡើយ ទំឯណាដែលជាទីតម្រេកដោយវិសេសដ៏ទៀតមានដែរឬទេ? ។ អាមាត្យតំឆ្កែយក្រាបទូលថា បពិត្រមហារាជ! ទីដែលជាទីតម្រេកដោយវិសេស មានតែកន្លែងស្ថានចាតុមហារាជិកាទេវលោកទើបមាន សូមព្រះអង្គជ្រាប ។

ឯព្រះបាទមន្ធាតុបរមចក្រនោះ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយ កំស្តេចចាប់ចក្រកែវគ្រីតាមជ្រុងថ្ងាព្រះអង្គ ដោយឥទ្ធានុភាព ចក្រកែវក៏បណ្តាលកើតឡើងជាភ្នាន់ដំនិះមួយរំពេច ស្តេចក៏ឡើងគង់លើរាជយានត្រមាំងបរិស័ទហោះអណ្តែតទៅលើអាកាសវេហាស៍ ឋានទៅដល់ទេវលោកឈ្មោះចាតុមហារាជិកាមួយរំពេចនោះឯង ។ ចំណែកឯស្តេចធំតំឆ្កែយបួនព្រះអង្គ សឹងមានដៃកាន់ខ្សែផ្កាកម្រងទំនងគ្រឿងក្រអូបដ៏ជាទិព្យ ជំមានតួកទេវតាតំឆ្កែយចោមរោមជាបរិវារ ចេញ

ទៅខួលដំណើរព្រះបរមពោធិសត្វ ហើយបានទាំព្រះអង្គត្រមាំងបរិវារ
ចូលទៅកាន់ស្ថានចាតុមហារាជិកាទេវលោក ហើយលើកពាជសម្បត្តិដ៏
ជាទិព្វថ្វាយជល់ព្រះបាទមន្ធាតុព្រះបរមចក្រ ។ សោយពាជក្នុងកាលនោះ
ឯង ។ កាលបើព្រះបាទមន្ធាតុព្រះបរមចក្រ បានឲ្យបរិស័ទព្រះអង្គ
ត្រឡប់មកកាន់ស្ថានមនុស្សលោកវិញហើយ, ព្រះអង្គទ្រង់សោយពាជ
ក្នុងស្ថានចាតុមហារាជិកានោះជាសុខក្សេមក្សាន្ត ជាកន្លងទៅអស់កាល
យូរអង្វែង ចំនួនប្រាំលាមុឺមបួនពាន់ឆ្នាំមនុស្ស, ហើយព្រះអង្គពុំអាចនឹង
ញាំងកាមតណ្ហា សេចក្តីប្រាថ្នាកាមគុណ ឲ្យគេចព្រះទ័យបាន
ក្នុងស្ថានចាតុមហារាជិកានោះឡើយ ស្តេចមានសេចក្តីអផ្សុកពុំសប្បាយ
ព្រះទ័យ សម្តែងទ្វារគាគារធំមានព្រះកន្ត្រកពុំរីកឈ្ងៃ ក្នុងវេលានោះឯង ។

លំដាប់នោះ ព្រះមហារាជទាំងឡាយបួនព្រះអង្គក៏បានក្រាបទូលសួរថា បពិត្រមហារាជ! ព្រះអង្គទ្រង់ព្រួយព្រះកាយព្រះទ័យកើតទុក្ខអផ្សុកដូចម្តេច ។ ព្រះបាទមន្ធាតុត្រាស់ថា ខ្ញុំកន្លែងដែលជាទីត្រេកអរដោយវិសេសដាច់ទេវលោកនេះមានដែរឬដូចម្តេច? ។

ស្តេចលោកបាលទាំងបួន ក្រាបទូលតបថា បពិត្រព្រះសម្មតិទេព! យើងទាំងឡាយអ្នកបម្រើព្រះអង្គក្នុងស្ថានេះ ប្រហែលដូចជាមនុស្សដែរ, មានតែស្ថានគារតែងឮទេវលោកទើបបាននាំឈ្មោះថាជាទីត្រេក

ដោយវិសេសមួយយ៉ាងគុណជាធ្ងន់ចាកគុមហាកដីកានេះដោយពិត, សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះបាទមន្ធាតុទ្រង់ព្រះសណ្តាប់ហើយ ក៏ត្រឡប់ក្រសែរដោយមហិទ្ធិរិទ្ធិហោះទៅលើអាកាសវេហាស៍ មានទាំងទេវចរិស័ទចោមរោមជាបរិវារ មានព្រះកត្តាន្តោះទៅកាន់ស្ថានតាវតឹង្សពិភព ចាន់ទៅដល់មួយរំពេចនោះឯង ។

ចំណែកឯព្រះសក្កទេពិន្ទ្រាធិរាជ ដែលមានព្រះហស្តកាន់យកខ្លួវផ្កាកម្រងនិងគ្រឿងក្រអូបដ៏ជាទិព្វ ព្រមទាំងពួកទេវតាទាំងឡាយ ចោមរោមជាបរិវារ ចេញទៅទទួលដំណើរ ហើយនាំព្រះបាទមន្ធាតុបរមពោធិសត្វនោះ ចាប់ក្តីងព្រះហស្តនាំចូលទៅក្នុងកតក្រាបទូលថា បពិត្រមហាកដ ! សូមព្រះអង្គយាងមកខាងនេះ, លុះដល់សម្តេចសក្កទេវរាជចាន់នាំព្រះបាទមន្ធាតុបរមពោធិសត្វទៅដល់សីតវរបស់ខ្លួនហើយ ក៏ធ្វើបៃតិចំណែកទេវតាទាំងឡាយឲ្យជាតំរាចំណែក ហើយលាយបៃតិចំណែកជាសម្បត្តិទិព្វបរស់ខ្លួនតាក់តាំងថ្វាយដល់ព្រះបាទមន្ធាតុ ។ ព្រះបរមពោធិសត្វនោះ ទ្រង់សោយរាជសម្បត្តិដ៏ជាទិព្វតាក់តាំងល, ក្នុងឋានតាវតឹង្សទេវលោកនោះឯង ។

(នៅមានត)

មហោសធជាតក

(តមក)

លោក អឹម.កន បម្លងពីសាស្ត្រសំស្ក្រឹតនៃ

ព្រះពុទ្ធវង្ស កឹម-តូរ ពន្ធិត្យ

អស់ខ្ញុំប្រុស ស្រី ដំរី សេះ រទេះ គោ ក្របីផងសឹងមាន កំទឹង ដើរហែហមបួនទៅហោង ។ ប្រយោជន៍អ្វីនឹងអាកន្តិលតាចកន្ទ្រៀនេះ ចូលកានធ្វើដោយពាក្យអញគាប់ហោង ។ រីមេទឃតាហលា ឮនូវពាក្យអាទឃបង្ខំថាដូច្នោះហើយ ក៏កាត់ក្តីស្រឡាញ់ទឹងប្តីអាត្មាវិញហោង, ក្នុងណោះមានចិត្តប្រតិព័ទ្ធគិតចូលចិត្តទឹងអាទឃបង្ខំ ទទួលយកពាក្យអានោះហើយថាចៅអើយ ថាបើចៅមិនលះបង់ស្រេចិត អញនឹងធ្វើដោយពាក្យចៅហោង ។ អាទឃបង្ខំថា ម្តេចកានថាដូច្នោះ គោះថា គោះកាចម្តេចៗ ក្តីនាអញនឹងចំញឹមក្បាកានហោង រីវាំង ២ នោះទៅដល់ត្រើយ ហើយវាមានចិត្តត្រេកអរនឹងគ្នា កំលះបង់ចោលអាគោធកាឡ, ហើយវាស្រែកថា អាគោធកាឡអើយ, ចូរព្រះស្តេងទៅនោះហោង, អាគោធកាឡមើលយល់វាធ្វើសុកឡុក, វាំង ២ នោះវាឆ្ងំចំណីអាហារហើយ ដោះឡើងវើរទៅហោង, អាគោធកាឡកាលបើយល់ហើយគិតថា វានេះបមវាបួប

ចិត្តដាមួយទឹងកំរោអញ ហើយវាលះបង់អញរត់ទៅ, អាគោធកាឡនោះ កន្ទក់កន្ទេញវារត់ប្រាស់ប្រាល់ចុះទ័កបន្ទិចហើយ ដួយក្រោយតើតរឡើងវិញ ដោយចិត្តកំហឹងទឹងវាគាំង២នោះ ចុះហើយឡើងរហើយចុះ. ក្បាលនោះក្បូមីមាចងឹកឡូនខ្លាប់ហើយវាថា ហឺះស្អាប់តឹស្អាប់អេះ ម្ចាំះហើយតឹរត់ស្រឡាបៗទៅដល់មាត់ច្រាំង វាអើលដើងប្រុសខ្លាក់ប្រុង ដៃតក់ខ្លួនតួងថា ហឺះ វាតក់ខ្លួវាអេះ លុយទឹកទៅដល់ត្រើយហើយរត់តាមទៅពាន់ ហើយស្រែកថា ពះវ ចោរកំណាច ទឹងអាចនាំកំរោអញទៅឯណាហ្នឹង? ឯអា. ទ័ឃចិដ្ឋថាតះវាតន្ទិលរមៀលនឹងដីនេះ កំណាចហាងចុនឥឯណា មេនេះកំរោអញក្បូវ ។ ថាអម្បាលនោះហើយ តឹចាប់តអាគោធកាឡមិញចោះចេញទៅ ។ ឯអាគោធកាឡនោះមិញ ដោះឡើងតខ្លះកន្ទុយចាប់ដៃមេដំយតាហាលហើយថា មេឈប់។ មេទឹងទៅឯណាហ្នឹង? អញធ្លើការបំរើក្មេងនេះម្ចាយ៩ពុកមេអស់ ៧ ឆ្នាំទើបអញចុនមេជាកំរោ តឹមទឹងលះអញទៅឯណាហ្នឹង? អាគោធកាឡធ្លើដម្ងោះមួយអន្ទេទឹងអានោះ បណ្តើរគ្នា ទៅដល់បរមសាលាព្រះមហាសត្វហើយ, រីអស់មហាជនធងឹច្រើនមកជួបជុំជុំទុំគ្នា ម៉ើលបុរសនោះរឈ្លោះគ្នា, រីថាមហាសថអ្នកច្រាជ្ញអ្នកដណ្តឹងថា សត្វអ្វីដួចោះហ្នឹង? ។ អ្នកផងឹថា សត្វជំលោះ, ទើបអ្នកប្បៀហាវាងឹ២ នោះមកដល់ហើយ អ្នកស្តាប់ពាក្យវាស្រដីតបតពាក្យ

គ្នាទៅវិញទៅមកហើយអ្នកដំឆីថា ៗ នេះជាចោរលួចប្រាក់គេ មួយនេះ ៗ ជាប្តី, អ្នកថាព្រះស្តេចតាំង ២ បិតដោយបង្គាប់អញឬ ម្តេច? ៗ រីអ្នកតាំង ២ ថាអម្ចាស់ យើងខ្ញុំបិតដោយបង្គាប់អម្ចាស់ហោង ៗ ព្រះមហាសត្វ អ្នកឲ្យហៅ អាខ័យចិដ្ឋនោះជាដើម ហើយអ្នកដណ្តឹងថា ព្រះស្តេចឈ្មោះអ្វី? ៗ អានោះថា អម្ចាស់ ខ្ញុំឈ្មោះ អាខ័យចិដ្ឋ, ចុះប្រពន្ធព្រះស្តេចឈ្មោះអ្វី? អានោះក៏មិនចាន់ស្គាល់ឈ្មោះមេនោះ, ក៏ថាជាឈ្មោះឯទៀតវិញ ឈ្មោះ ហលតិកតា, អ្នកដណ្តឹងថា ម្តាយនុពុកព្រះស្តេចឈ្មោះអ្វី? អានោះក៏ថាឈ្មោះដូច្នេះៗ, អ្នកថា ម្តាយនុពុកប្រពន្ធព្រះស្តេចតើឈ្មោះម្តេចហ៎? អានោះក៏មិនស្គាល់ឡើយ ក៏ថាឈ្មោះឯទៀតវិញ ៗ លំដាប់នោះ ព្រះមហាសត្វអ្នកឲ្យពាលអ្នកកត់ជាចំណាំពាក្យនោះហើយ នាំអានោះចេញទៅ ហើយអ្នកឲ្យអាគោធគាឡនោះចូលមក ហើយអ្នកដណ្តឹងអស់ប្រការដូចដំណើរនៃអ្នកដណ្តឹងមុននោះហោង ៗ រីអាគោធគាឡ ហេតុក៏ស្គាល់ពិត ក៏ប្រាប់តុំខុសឡើយ ព្រះមហាសត្វអ្នកយកអាគោធគាឡនោះចេញទៅ ហើយអ្នកហៅមេខ័យតាហលមក អ្នកដណ្តឹងថា មេឈ្មោះអ្វី? មេនោះថា ខ្ញុំឈ្មោះមេខ័យតាហលា, ចុះអ្នកជាប្តីមេឈ្មោះអ្វី? មេនោះក៏មិនចាន់ស្គាល់ ក៏ថាឈ្មោះឯទៀតវិញ, អ្នកថា ម្តាយនុពុកមេឈ្មោះអ្វី? មេនោះក៏ថា

មានឈ្មោះដូច្នោះ។ អ្នកថា ម្ដាយឪពុកឯង្ហ៎ីមេឈ្មោះអ្វី? មេនោះវាថា មិនចាន់ស្គាល់ វាថាឈ្មោះឯទៀតវិញ, អ្នកថា ម្ដាយឪពុកមេឈ្មោះអ្វី? មេនោះថា មានឈ្មោះដូច្នោះ។, អ្នកថា ម្ដាយឪពុកឯង្ហ៎ីមេឈ្មោះអ្វី? មេនោះវាពុំចាន់ស្គាល់នៅឡើយ វាថាលលើកៅអីមកអៀម វាថាជាឈ្មោះឯទៀតវិញ ។ រីឯៅមហាសេដ្ឋអ្នកប្រាជ្ញ អ្នកឲ្យយកតំណាត់ពាក្យអ្នកពាល ៣ នោះមកមើល ឲ្យអស់មហាជនផងស្ដាប់ ហើយអ្នកដណ្ដឹងថា ម្ចាស់អ្នកពាលឲ្យាយអើយ! រីពាក្យនេះមែនដូចពាក្យអាទ័យចិដ្ឋ ឬដូចអាគោធកាឡ? អស់មហាជនផងស្ដាប់ហើយថា បពិត្រៅអ្នកប្រាជ្ញអើយ, រីពាក្យមេទ័យតាហាលានេះ ដូចពាក្យអាគោធកាឡហោង, រីអាគោធកាឡនេះ ជាប្ដីមេពិត, រីអាមួយនេះ ពុំជាប្ដីឡើយ ។ លំជាប់នោះ ព្រះមហាសត្វអ្នកដណ្ដឹងថា ព្រះស្ដេចជាចោរមែនពិតហ៎ះ, រីអាទ័យចិដ្ឋថា អម្ចាស់អើយ ខ្ញុំជាចោរមែនពិតហោង, ។ ព្រះមហាសត្វអ្នកឲ្យដំនូរដំណាំក្ដីនោះជាចោរហើយ ទើបព្រះពោធិសត្វ អ្នកឲ្យដំបូន្មាន អាទ័យចិដ្ឋថា ព្រះស្ដេចកុំធ្វើពុតកំណាចជាអកុសលដូច្នេះវើយ នាលោកយនេះ ព្រះស្ដេចបានជាបង្ក្រាបជនឥរ្យាវនេះឯង, រីបាបៅបរលោកនោះ ជាសែនគុណវិញហោង ។ ម្ចាំះហើយព្រះស្ដេចកុំបីធ្វើនូវអំពើអធម្មកម្មដូច្នេះវិញទៀតឡើយ ។ រីអា

គោធកាឡ កាលណាបើបានកន់យោងដោយនូវបុណ្យគុណព្រះមហាសត្វ
អ្នកបង្គាប់ហើយ ត្រេកអរសាទរសរសើរព្រះមហាសត្វ ហើយនាំយក
កន់យោងទៅហោង ។ ស្រេចហើយអ្នកឲ្យដំណើរគោគោធកាឡនោះទៅ
ហោង ។ រីគោលាឡង់គោធកាឡនេះមិញ ស្រេចដោយនូវប្រការអម្បាល
នេះហោង ។

វត្ថោតិ ។ រីគោលាឡង់រនេះមានដូច្នេះ ។ តទា ឃគោ បុរិសោ
វនេ ឯសីឯត្វា មុខនោវនត្តាយ តាមតោ ឯក្ខមិ ។ ឮដំ
កាលនោះមានបុរសមួយដឹះរនេះបរទៅ ប្រយោជន៍ដើម្បីនឹងលុបលាងមុខ។
មាត់ក្បាំណានោះព្រះឥន្ទ្រាធិរាជមើលមើលមកដោយនូវព្រះទិព្វចក្ខុ យល់
ព្រះមហាសត្វហើយព្រះឥន្ទ្រាំតឹងថា អញនឹងធ្វើឲ្យពន្ធកព្រះពុទ្ធនោះ ឲ្យ
យល់ស្តែងច្បាកដអានុភាពច្បាស់ដល់អ្នកហោង, ព្រះឥន្ទ្រាធិរាជអ្នកច្រឹង
ព្រះចិត្តអម្បាលនោះហើយ ចុះចាកតិមានឋានសួគ៌មកយកកៀសជា
បុរសមួយ ដើរមកកាន់កន្លែរនេះ រីឯបុរសនាដឹះរនេះនោះមិញ យល់
ហើយដណ្តឹងថា ហៃព្រះស្តែងមកប្រយោជន៍អ្វី ? រីព្រះឥន្ទ្រាថា អញ
មកប្រយោជន៍ចំពោះព្រះស្តែងហោង, រីបុរសនោះទទួលបេយកពាក្យថា តាប់
ហោង, ហើយបុរសនោះចុះពីលើរនេះទៅក្រៃម្ល ។ ក្បាំណានោះ
ព្រះឥន្ទ្រាធិរាជឡើងដឹះលើរនេះនោះហើយចរតេង្រត់ទៅហោង ។ រីឯ

ម្ចាស់រនេះ មកអំពីព្រៃនោះមិញ ឃើញគេបររនេះតន្ត្រៃទៅដូច្នេះហើយ បុរសនោះតាមទៅដោយឆន្ទៈកំឡាំងហើយស្រែកថា រើយឈប់ ព្រះស្តេចបររនេះអញទៅណាហ្នឹង ? ព្រះឥន្ទ្រស្រែកទៅវិញថា រនេះអ្វីព្រះស្តេច គេអ្នកឯទៀត តើគេគ្មានរនេះផងហ៎ះ ! លលាក់លលើ ! ទៅទៅ ! នេះរនេះអញកូវហ៎ះ, នាពាក្យព្រះឥន្ទ្រថាដូច្នេះ រីបុរសនោះឈ្មោះនន្ទិព្រះឥន្ទ្រ បណ្តើរគ្នារៀនទៅដល់ទ្វារសាលាព្រះមហាសត្វ អ្នកជណ្តើងថា សំពួអ្វីដូច្នោះហ៊ឹង, ? ទើបឲ្យហៅអ្នកទាំង ២ នោះមក, ព្រះមហាសត្វអ្នកស្គាល់ថា អ្នក ទះជាព្រះឥន្ទ្រាធិរាជ, នាអ្នកស្គាល់នេះ ហេតុមិនខ្វាចមួយ, ហេតុពុំប៉ះប៉ូវនឹកមួយ, រីបុរសមួយនេះជាអម្ចាស់រនេះមែន, សូម្បីស្គាល់អម្បាលនោះហើយក្តី កំអ្នកជណ្តើងហេតុឈ្មោះគ្នានោះសព្វគ្រប់ហើយអ្នកថា អ្នកទាំង ២ បិតាដោយបង្គាប់អញឬម្តេច ? រីអ្នកទាំង ២ ថាបពិត្រអម្ចាស់អើយ យើងខ្ញុំបិតាដោយបង្គាប់អម្ចាស់ហោង ។ ព្រះមហាសត្វអ្នកបង្គាប់ថា អញបររនេះនេះតន្ត្រៃទៅ រីព្រះស្តេចទាំង ២ ចូរកាន់កន្ទៃរនេះនេះរត់ទៅតាមក្រោយ នរអ្នកឯណាជាម្ចាស់រនេះ កំអ្នកនោះពុំលះបង់រនេះឡើយ , នរអ្នកឯណាមិនអង្គុយជាម្ចាស់រនេះ អ្នកនោះលះបង់រនេះហោង , អ្នកថាអម្បាលនោះហើយ កំប្រែតលអ្នកបររនេះតន្ត្រៃទៅ, រតលនោះធ្លើយដោយអ្នកប្រែនោះហោង ។ (នៅមានត)

រឿងមរណមាត

(ពមក)

លោក ប៉ី-សុវណ្ណ បម្រួលពីសាស្ត្រាស្ងឹករឹត

មរណមាត នាងទៅឯណា ទើបអស់អក់យោយ ពួលថានាងគង់ព្រះអង្គសប្បាយ នាងយាងជជាប មកគាល់នោះហាង ។ ស្តេចឆ្ងល់ណា ដណ្តឹងពាល់គ្នា ពីរដងមីដង ម៉ិនមានម្ចាក់ដឹង ដំណឹងឡើយហោង ទើបក្សត្រប្បាស់ប្បូង មានព្រះឧទ្ធារ ។ ថាចាំព្រឹកឯញ ខ្ញុំតទើបអង្គអញ ឲ្យទាំចារណា សួរកេដំណឹង ឲ្យដឹងកិច្ចការ ត្រាស់ហើយក្សត្រា ប្តូលទីបង្គំ ។ អក់យោយស្រឡាំង ភ័យកំតកាល់គ្នា ធុញថៃថប់ធំ តុះពាល់ប្រាជ្ញា ឧពក្រៀមក្រំ ខ្លះថាឆ្កួលធំ ឪងមហាក្សត្រា ។ ព្រះអគ្គមហេសី បមេក្សត្រី មរណមាត នាងយាងមកគាល់ ដល់ខ្ញុំបក្សត្រា ម្តេចស្តេចត្រាស់ថា សួរកេអ្វីខ្ញុំត ។ ខ្លះថាក្រែងអង្គមហេសីពីរពង្ស ទើបស្តេចឈ្លបធ្វើត ទំសួរកំញើញ ឲ្យយើញមួយខ្ញុំត តិតទៅចង្អើតអញចង់តែយំ ។ ខ្លះថាមេចោរ ស្តីអ្វីខ្លា ។

មេនេះព្រើលធំ មិនដឹងមហេសី ក្សត្រីទត្តម តែមួយជាធំ ជាម្ចាស់ពាល់គ្នា ។ មេមួយឆ្លើយវិញ អើឆ្កួតតែអញ ហាងឯងអ្នកជា តាលស្តេចដណ្តឹង ដំណឹងពាល់គ្នា ថ្លៃហាងមិនថា ទឹងស្តេចតាលណោះ ។ មួយឆ្លើយថាអើ បើឯងគ្រាន់បើ មិនចូលទៅចុះ ទៅចូលព្រះអង្គ ឯក្នុងឯណោះ អង្គុយតែឈ្លោះ គ្នាឯងធ្វើអ្វី ។ មេមួយទៀតថា អើមានប្រាជ្ញា ប្រសប់ប្រក្រតី បើមានដំណើរ ពឹងធ្វើស្មាក្តី ចៅក្រមអ្វី ។ គ្រាន់យកម្រាក់ស៊ី ។ យាយម៉ុចថាអេះ មេដែងអស់នេះ ខូចខាតដល់ពី ចេះសដែក ប្រកែកវែកវី មេខូចទេមណ៏ អញដេកពុំបាន ។ អញទើបនឹងផ្ទេច លលឹមបានតិច ប្រកែកគ្នាសាន រកគ្នាទឹងដេក ឲ្យសុខមិនបាន មេផេះបង្ក្រាន ប្រកែកគ្នាថ្វី ។ អក់យាយជាធំ នាយលើសអស់ស្មុំ ឃាត់ថាកុំស្តី ដេកមានតម្លាំង ទឹងតាំងតក្តី ព្រឹកព្រះចន្ទ្រ ដណ្តឹងពាល់គ្នា ។ សឹមទៅដដែក ប្រកួតប្រកែក ទឹងព្រះពជា កុំឈ្លោះគ្នាឯង កែងៗឥតការ ស្តីឲ្យនេះណា គេស្តាប់មាសមេ ។ ស្រីគ្នាពាំងឮយ ស្តាប់ពាក្យអក់យាយ ខ្លះឃាត់ថានែ នាំគ្នាស្ងៀមស្ងាត់ ចាត់មាត់ច្រាដប្រៃ ដេកដោយសព្វតែ លុះលក់ដ្រងំ ។ ទំយេនេះស្ទុះនី— ពានតគំពី ក្សត្រីទត្តម កាលជួកគ្នាក្នុងប្រេង កន្ទែងក្តៅធំ រលួយរលំ រលាកអាត្មា ។ មានទេពទេវី មួយឈ្មោះតិរ

មេទលធ័តា ដែលនៅថែទាំ ទុត្តមក្ខោ សព្វទិនទាំ មិនមានឃ្លា
ឃ្លាត ។ ឯទេពាទេវី យល់នាងគិរី មេទលទារាថ ជាឆ្នាំនៅចាំ ថែ
ទាំក្នុងជាតិ នាងចូលអកាច់ សុំទិព្វនុសថ ។ គិរីមេទល ចិត្តជាកុសល
ព្រឺព្រួចបំហុត នាងដើរបួតបេះ ប្រឡេះនុសថ ជាន់ត្រង់នាងផ្តត់ ផ្តួ
ផ្តាច់ផ្សែផ្សំ ។ ស្រេចទើបធីតា ហិចហោះលើលា វិលដល់ដៃធំ
ឡើងគង់លើហាន ពាមានតាម្យ ហើយនាងរៀបចំ ថ្នាំទិព្វទុកល្អ ។
នាងទេពាទេវី ចុះចាកអំពី និត្រោធបវរ យាសយាងបាត រោលឈប់
ឈរ ទតឃើញឆ្នងកែ ពុទ្ធាអនិច្ចា ។

បឧត្រហ្មភីតិ

ទីទើបនារ័ត្ន ឈោងលើកហត្ថទាំងខ្ទេហារ ចាប់យកឆ្នងសំរោ
ឆ្នងឆ្នងថ្នាមទាំងពីរស្មើត ។ ឆ្នងកទាំងឆ្នងស្មា ឆ្នងទកវៀបប្រកិត ឆ្នងខ្ទង
ជងកាំបិត ឆ្នងជំទីរទាំងស្តាំឆ្វេង ។ ឆ្នងដៃទាំងខ្ទេហារ ឆ្នងថ្នាការ
វៀបផ្សេង វៀបឆ្នុំជាក់ស្តាំឆ្វេង ដោយអណ្តាប់អណ្តោយគ្នា ។ ឆ្នង
ម្រាមដៃទាំងសង វៀបឆ្នងស្មងម្រាមថ្នាត ឆ្នងលោងទាំងខ្ទេហារ វៀប
ជិតឆ្នងទ្រគាកឆ្នុំ ។ ឆ្នងសាមសិបកំណាត់ ដោយសង្កាត់តាមតួចធំ
វៀបប្តូជាក់ឆ្នងឆ្នុំ រុំសំពត់ទិព្វសស្អាត ។ ស្រេចហើយទើបទេវី យក
ទឹកព័ត្តទ្ធមាទន៍ មកផ្សំត្រៃបម្ងៃស្អាត សូត្រគាគមដោះប្រញាប់ ។ ទម:

មហាជាស់កាំង ឧសថំសិទ្ធិស្ងា· ហៈសូត្រត្រង់ ៣ សា ផ្ទង់មាត់ធ្នុំ ដង្ហើមខៅ ។ ត្រូវលើកឧសថ ដោយមុនមុតពួកខៅ ហើយយក ថ្នាំនោះខៅ លុបលាបលើឆ្នងនោះណា ។ លាបស្រេចសាច់ដុះជាល ដុះតាក្បាលខៅដល់ស្មា រហូតដល់ជាខ ដុះសរសៃធំតូចគ្រប់ ។ កើត ដួងកែវពាំងបួន រួបសមសួនល្អចំប្រប់ កំរិយាសពាង្គសព្វ ឥតចន្លោះ ដួចមុនមាន ។ រៃងល្អលើសរូបមុន រូបល្អះល្អង់អស់អង្គច្បាណ លើស លែងខេតសួគ៌ឋាន គ្មានខ្ចីងធ្ងឹមប្រៀបខបមា ។ ហើយខើបនារីវ័ត្ត នាង គន់គិតឆ្ងល់ចិត្តា ដប់ស្រូបដួងដីវ៉ា មានរូបារស់ជីវិត ។ កើតខ្យល់បក់ ចេញចូល បក់ប្រមូលដល់ដួងចិត្ត សួតថ្លើមដង្ហើមពិត មានជីវិត រស់រូបច្បាណ ។ គ្រានោះខើបធីតា យល់ដាយាមានវិញ្ញាណ ជា មនុស្សបរិបូណ៌ជាន នាងសូត្រសេកចិត្តមន្តថ្លៃ ។ ដប់កើតជាសំពត់ ចិត្តបរិសុទ្ធឈ្មោះកោសេយ្យ ស្បៀកពាក់ឱ្យស្រួលថ្លៃ ភ្លឺចិញ្ចាចសឹង សុវណ្ណ ។ ឯក្សត្រ័បវរ នាមនាងមរណមាតា នាងភ្ញាក់ដឹងអាត្មា ហើយ ក្សត្រីក្រោកឡើងគង់ ។ ព្រះនេត្រខតសព្វកាយ រៃងធ្លល់ឆ្ងាយកង ព្រះអង្គ យល់ថ្លែកចំថ្លែកទ្រង់ នាងរៃងធ្លល់សែនអស្ចារ្យ ។ នាងខឹក ដល់ជក្រី ជាស្វាមីនៅស័មា ខឹកស្ងំក្រមបរិពារ ច្បាសាខហានចិត្ត មន្ទិល ។ សោយសោកសែនសោកសោះ សែនគាល្ងោះថែមទុក្ខលំ

វង្វេងវង្វិលវល់ ពុំបើងជាន់ផ្លូវត្រង់ណា ។ ទុកម្នាអើយធ្ងន់ពេក កម្មចំឡែក
ស៊ុនណាស់ណា នេះម្តងរងទុក្ខ តាំងពីតូចលុះដល់ធំ ។ លុះដល់មហា
ក្សត្រា ទ្រង់ករុណាប្រទានស្នំ ស្រីឆ្លាវបំពាក់ផ្ទុំ លើកជាឯកអគ្គជាយា ។
ឥឡូវម្តេចប្រែប្រាស ព្រាត់ទឹកសម្តៅហើយណា នៅម្នាក់ឯងឯកា កង
ព្រៃធំហួត់សូន្យសល់ ។ ជាន់ផ្លូវទៅតិចក៏ ទីឆ័យគ្រាកន្ទរសពល ព្រះ-
អើយសមខ្ញុំដល់ ជន្មជីវិតក្ស័យអសារ ។ គ្រានោះទើបទៅ យល់នារី-
សោយសោក នាងនិម្មិតកាយា ឈរចំពោះមុខក្សត្រី ។ ទើបនាងលួង
លោមថា មាសមាតាកុំយំថ្ងី កុំទុក្ខខ្លួញណាស្រី ម្តាយប្រាប់កូនកែវ
កល្យាណ ។ កុដម្ពីក៏កាលនោះ ចិត្តមិត្រទ្រុស្តនន់ប្រមាណ ឥស្សប់នាង
កល្យាណ ណេមបញ្ឆោតឲ្យនាងទៅ ។ ជាន់លើក្តារយន្តនោះ ធ្លាក់
នាងចុះក្នុងប្រេងក្តៅ នាងក៏ស្លាប់ទៅ នៅតែធ្មឹងទើបកាល ។
ឃាតមកចោលកងហ៊ន ព្រៃស្មសានមិនប្រណី យើងមានចិត្តមេត្រី យក
ថ្នាំចិញ្ចឹមកត្រួសប្រុស ។ លុបលាបនៃសព្វាង្គ កាយទើបនាងបានរួចរស់
ចិញ្ចឹមទើបជ្រាប់សព្វសុះ សព្វភាក្យពោលតុំវាទី ។ នាងស្តាប់ទើបចរចា
ទើបធឺតាលើកអញ្ជលី ប្រណម្យថ្វាយវន្ទី វន្ទាទូលទើបធឺតា ។ បពិត្រ
ព្រះមេមាន គុណប្រជានលើសិរសា ព្រះមេត្រីមេត្តា ជ្រោសខ្ញុំរស់
បរិបូណ៌ហើយ ។ ធ្វើម្តេចខ្ញុំបានទៅ ទំលំទៅដូចដើមវិញ ព្រះមេ

មានគុណដើយ ច្រើសច្រាប់កូនឲ្យដឹងការ ។ ទើបនាងនាវ័ត្ន ច្រាប់
ទៅថ្វាត់វិញទៀតថា ចូលនាងបរិភោគ្គា ថ្នាំទឹកទៅទើបប្រែកាយ ។
ខ្លួនឯងជាសារិកា ដឹងការមនុស្សទាំងឡាយ ហើចហើរលេងសប្បាយ
ចរចូលដល់មហាក្សត្រក្បាន្ត ។ បើនាងទំងំទៅជា គេមនុស្សទំនក្រចាន
បើចូលដល់ក្សត្រក្បាន្ត ស្តេចសន្ទុះព្រះចិត្តា ។ ថារស្រេចនាវ័ត្ន យក
ទសថដីថ្លៃថ្លា ហុចឲ្យទៅធីតា នាងទទួលរួចលេបទៅ ។ ភ្លាយខ្លួន
ជាសារិកា បង្គំលាទើបចមទៅ ហើយនាងហើរឆ្ពោះទៅ ក្រុងវិទេហ៍ភជ
ប៉ុរី ។ និទានខ្លោះទៀងទេ តត់ខ្សែប៉ើសេចក្តី កាលនាងជាបក្សី
សារិកាកែវកើតទុក្ខា ។

បទកាកគតិ

នេះទំនិថ្លាថ្លែង សណ្តាប់ស្តាំដែង សំដីសាសន៍ តាំងតត់ខ្សែ
ប្លួនមែរជួបបង ជួបចាប់ទំនង ព័នាងសារិកា ។ លាទេពាទេវី ចេញ
ជាកំពី ព្រះថ្លៃសាខា ហើរកាត់ដំរង់ មុខត្រង់រង្គ វិទេហ៍មហា
ប៉ុរីរម្យ៉ែង ។ នាងនឹកកស្តា ស្ងាមក្សត្រា ធិរាជបក្រតត្តិ ថារទ្រព្រះ
ចៅ យាងទៅព្រៃចាត់ ម្ល៉ះហើយមហាក្សត្រ វិលវិញដឹងហើយ ។
ឬមួយក្សត្រថ្លៃ ប្រាកតព្រឹក្សព្រៃ សប្បាយព្រងើយ បើក្សត្រវិលថ្លាន
ព្រះប៉ានវិញៈហើយ ម្តេចស្តេចគោះតើយ មិនទឹកប្លួនក្លា ។ ប្លួនៅ

ម្នាក់ឯង កណ្តោចកណ្តែង កណ្តាលអង្វា លន្ទង់លន្ទោច ត្រមោច
កំព្រា នឹកព្រះពាជា មិនស្បើយស្រាកស្រាន្ត ។ នាងនឹកក្សត្រា ខន់
អស់កាយា ស្ទើរខេម៉ាំពុំបាន អាសូរបក្សី ក្សត្រីកល្យាណ ទំហើរពុំក្សាន្ត
ដោកដល់នេត្រា ។ នាងហើរបណ្តើរ នេត្រនាងមៀងមើល៍ បក្សីបក្សា
បក្សាតក្អាតក្អែក ក្អូរកែកក្រសា ក្រសាលបរបា តៀងគូរផ្លៀងផ្លង ។
ឧសភូបក្សា តត់តង់តូវ៉ា សប្បាយសាសង់ កម្មវ៉ីអង្គអញ្ជា តេកតេញ
សៅហ្មង មានវេរវេង ព្រាត់ប្រាសក្សត្រា ។ ម្ល៉ះក្សត្រីចត្តម ពុំជ្រាបជាខ្ញុំ ហ្មងមានទុក្ខា ដល់ក្ស័យមង់ឃ្នាត់ ប្រាស់ព្រាត់ក្សត្រា បើជ្រាបហើយណា សមស្តេចកណ្តែង ។ សែនសោយសោកក្រៃ អាឡោះអាល័យ សង្រៃសង្រេង ត្រាស់ប្រើសេនា យោធាផ្សែង ។ រកត្រង់កន្លែង ដំណើរបន្ថែកក្សា ។ ហើរហើយសោយសោក សែនសស៊ាំយោគ កាន់តាំងអង្គា តិតក្សត្រីចត្តម ក្រៀមក្រំមហិមា ទំដើរវេក ខន្ធាបស្ងាប
ទៅ ។ ចូលដល់ខនរ ទីទេម៉ាបវរ ប៉ុរីឈប់ទៅ ប្រុបប្រាង្គ័រចនា
ក្សត្រាចមហៅ ទំទៀបទិត្យទៅ បង្ខំក្សត្រា ។

បទតំណោល

ន័យនេះឈប់ស្តេចណានា ពោលពីក្សត្រា ទៅមលធម្មាជដៀស្ត
ជ័យ ។ ព្រឹកព្រាងស្រេចស្រាងទ័យ តើនចាកសុខសេយ្យ ស្រប់

តំក្រែស្រេចបើកកៅវតា ។ បក្សីមារីសារិកា ហើរទំនេះនា កង្ក្រាមហា-
ក្សត្រក្សាន្ត ។ ស្តេចឃើលអរពន់ប្រមាណ ព្រះហស្តក្សត្រក្សាន្ត កំដុមនាង
នាថសារិកា ។ ជាក់លើទ្រូក្សត្រា អង្អែលសារិកា ហើយត្រាស់
ដណ្តឹងស្នេះស្នង ។ ថាម្លៃសារិកាកល្យាណ នាងមកពីហន ឯណា
ចូលលែងចរចា ។ នាងស្តាប់ព្រះកដទង្ការ ទើបទូលភ្លាថា ខ្ញុំមកអំពី
ព្រៃធំ ។ ស្តេចស្តាប់សូរខឿតដោយដំ- ណើរនាងមកអំ- ពីហេតុដូច
ម្តេចចូរថ្លែង ។ នាងទូលក្សត្រក្សាន្តតម្តែង ខ្ញុំម្ចាស់សូរសែ្នង មកមើល
ឈើមាសខ្ទូហារ ។ ទើបស្តេចដណ្តឹងខឿតថា ហេតុម្តេចសារិកា
សឹងដឹងកន្លងនេះមាន ។ សុវណ្ណពជ្រក្សត្តើងថ្កាន ចូរថ្លែងតតិមាន
ឲ្យដឹងដំណើរដើមអាទិ៍ ។ ទើបនាងគាងស្វាបអង្គាល ចង្កុំព្រះបាទ
ព្រះបពិត្រកដកស្តា ។ នាងទូលពីដើមព្រឹក្ស ឈើមាសខ្ទូហារ ខ្ញុំ
ម្ចាស់ដាំពិតស្នេះស្នេះ ។ ស្តេចថាហេតុម្តេចដូច្នោះ នាងថាឈើនោះ
នាងដាំពីកាលឯណា ។ នាងទូលថាខ្ញុំនាមា មរណាមាតា ដាំកាល
នៅជាកុមារ៉ ។ ស្តេចស្តាប់ព្រឺព្រឺតហឫទ័យ ព្រះទស្សប្រឹមប្រឹយ
ត្រេកអរសោមនស្សផ្សព្វផ្សាយ ។ ត្រាស់ថាសារិកាឆោមឆាយ ហេតុម្តេច
កើតក្តាយ ខ្ទួនជាបក្សីដូច្នោះ ។ ចូរនាងច្រាច់បងឲ្យស្មោះ ពីខ្ទួននាងនោះ
ឲ្យអស់ដំណើរអតីតា ។ ទើបនាងច្រាច់ហេតុដើមថា កាលឫសក្សា

ជាមាតាបុងខ្ញុំនោះ ។ ប្រើកូនស្រីតាំងពីរស្មោះ ឈ្មោះចន្ទីនោះ មួយ
ឈ្មោះចន្ទណីមោហា ។ កូតប្រាប់ខ្ញុំថាបិតា ឈឺធ្ងន់មហិមា ខ្ញុំម្ចាស់ក៏ដឿ
អស់ចិត្ត ។ ស្មានជាគេថាត្រង់ពិត ទើបខ្ញុំរៃគិត ទីឯអ្នកអស់យោយ
ពាស់ពុំ ។ ជំនុំព្រមគ្នាចាំខ្ញុំ ចេញទៅដល់លំ- នៅនៃនោះប្រាប់ខ្ញុំថា ។
ឥឡូវនេះកូវបិតា ឈឺធ្ងន់មហិមា កុំឲ្យមនុស្សម្នាចូលផង ។ ឲ្យខ្ញុំ
ទៅម្នាក់ឯងហោង ទើបវាលួងលង កូតថាឲ្យស្រង់គង្គា ។ ខ្ញុំដឿផ្ទាស់
ព័ស្ត្រពស្ត្រា ដើរជាន់លើក្តារ ឃុនឡាក់ទៅកងប្រេងក្តៅ ។ ខ្ញុំក្រឡុយ
ប្រឡាយដន្ទៅ កូនខ្លះប្រេងក្តៅ ទើបមេកាលីឮស្បា ។ វាយក
គ្រឿងចិញ្ចរចនា អម្ពរពស្ត្រា ដែលខ្ញុំផ្ទាស់ពុកនោះឱ្យ ។ រៀបស្អាង
មេចន្ទណី ស្រេចហើយកាលី នាំជូនមកដល់បរិវារ ។ ឲ្យឡើង
គង់គ្រែសុវណ្ណា អស់ស្ងំចរិវារ តុំស្គាល់ចន្ទណីឡើយ ។ ពុកចិត្តថាខ្ញុំ
ម្ចាស់ហើយ ហៃមកព្រងើយ ឡើងគង់ក្រសាទរង្សី ។ ឯឆ្អឺនខ្ញុំ
នោះកាលី ឃានជាសេប្រកខ្លី ចាក់ចោលក្នុងព្រៃស្មសាន ។ មាន
ទេពធីតាកល្យាណ យកថ្នាំចិញ្ចឹមបាន មកប្រោះខ្ញុំសះរួចា ។ ខ្ញុំនឹក
រលឹកក្សត្រា ប្រះប្រាណសាកា ខ្លឹកខ្លួលក្តៅក្តួលម្នាក់ឯង ។ ខ្ញុំ
ដំទ្រូងយំក្តែងៗ កំតក់យំខ្លាចក្រែង ក្សត្រីក្សត្រក្នុងព្រៃអសារ ។ រី
ឯនាងទេពធីតា ប្រាយប្រាប់ខ្ញុំថា បើនាងចង់ទៅបុរី ។ នឹងទៅជា

មនុស្សក្រក្រី ក្រែងក្សត្រជិតតី រង្គាសរង្គៀលចិត្តា ។ ចើក្មាយខ្លួន
ជាបក្សា បក្សីសារិកា ហើរចូលក្នុងវាំងជានាយ ។ ទើបប្រាប់
ប្រដៅៗថាយ តលកិច្ចយើញនាយ ខ្ញុំដឿចូលចិត្តចិត្តា ។ ហើយទើប
ហុចទុសថា ខ្ញុំលេបប្រែជា សារិកាហើរមកហើយហោង ។ ស្តេច
ស្តាប់សារិកាស្នេហ៍ស្នង ទូលតាមទំនង កំដឿឥតមានសង្ស័យ ។ ទើប
ស្តេចបន្ទូលថាហៃ សារិកាថ្លាថ្លៃ ក្មាយជាមនុស្សវិញជានទេ ។ ទើប
នាងបង្គំទូលថៃ ថាចាំដៅឯ រឹមាននាងខេតធីតា ។ ទើបស្តេច
កិច្ចការ ស្តេចត្រាស់សួរថា នាងខេតធីតាចមថៅ ។ នាងតបវិញណា
និត្យនៅ សារិកាទូលថៅ ថាតបវិញកុំតន្ធមាទន៍ ។ ខ្ញុំសូមក្រាបលា
ព្រះថ្លង់ ថៅកុំតន្ធមាទន៍ ទើបសួរឡើងកិច្ចការ ។ សឹមមកទូលមហា-
ក្សត្រា ទើបស្តេចឃាត់ថា សារិកាកុំគាលថៅអី ។ ទើបស្តេចត្រាស់
ហៅថៅស្រី ស្រីឆ្លាវនោះនៃ យកនំចំណីទឹកឃ្មុំ ។ យកលាជប្រឡាក់
ច្រមុំ ហើយយកចេកពុំ ប្រគេនសារិកាកោតា ។ ប្រើជាងដំកន
សុវណ្ណា ឲ្យនាងសារិកា ក្សត្រាយកព្រះទំរង់ ។ មាសថ្លៃប្រពៃ
បញ្ចង្គ្ន ឋបញ្ចើអស់អង្គ្ន ជាកន៍ជាក់ដើងសារិកា ។ ត្រាស់ប្រើស្នំមួយ
រក្សា យកនាងសារិកា ស្រេចហើយក្សត្រាថ្លៃទុត្តម ។ ស្តេចចេញ
ចាកព្រះបន្ទំ ទ័ពទើបសុខុម ស្តេចសោយព្រះស្នេហ៍ទ្រាថ្លៃ ។ សោយ

ស្រេចសម្តេចជៀស្ងដ៏យ ស្តេចយាងគង់ឮ ទ័គាល់ទ្រង់ពុំកែកយ ។
ត្រាស់ប្រើហៅអស់អគ្រយាយ ស្រីឆ្លាតាំងឡាយ កុំកិតស្ងុតស្ងន់ស្មារតី ។
ទើបត្រាស់ប្រើស្ងំសាវស្រី ហៅបន្ទូណា មកដល់គង់គាល់ពុំឆ្ងាយ ។
ទើបស្តេចត្រាស់សួរអគ្រយាយ ថាដូនតាំងឡាយ ស្គាល់ទេនាងនេះ
ឈ្មោះអ្វី ។ អគ្រយាយក្រាបទូលបង្គំ នេះអង្គមហេសី ក្សត្រីមរ-
ណាមាតា ។ ទើបស្តេចប្រែព្រះកត្តា បើកព្រះឧង្ការ ដណ្តឹងមេបន្ទូណា ។
ថានែនាងឯងឈ្មោះអ្វី ឯបន្ទូណា ក្រាបទូលដោយពាក្យមុសា ។ ថា
ឈ្មោះមរណមាតា ស្តេចប្រែកត្តា ដណ្តឹងទៅស្រីព្រះស្ងំ ។ ដែល
ជាលក្ខណ្ឌបន្ទំ ហើយដណ្តឹងអំ- ពីពាក្យបក្សីសារិកា ។ ទើបស្តេច
ត្រាស់សួរទៅថា នែហាងាល់គ្នា ឥឡូវអគ្រយាយតាំងនោះ ។ អញ
ហៅមកសួរពិគ្រោះ ដណ្តឹងរកឈ្មោះ នាងនោះឈ្មោះអ្វីតេថា ។
ឈ្មោះនាងមរណមាតា មែនថ្នាលគ្នា ចូរចែងថ្វាថ្វែងឲ្យស្មោះ ។ ឯពួក
ស្រីស្ងំតាំងនោះ លើកដៃប្រូងប្រុះ ស្រុះស្រួលទូលព្រមគ្រប់គ្នា ។
សូមទានក្រាបទូលក្សត្រា មិនមែនព្រះមហា មហេសីក្សត្រីទត្តម ។
នាងនោះមានយោធពុំសម ដៃជើងធំៗ ជាស្រីឥតលក្ខណា ។ ឈាម
មុខមិនសូវស្រស់ថ្លា ស្រដីគរលណា សំឡេងឮក្អេងដូចប្រុស ។ ម្ចាស់
យើងមិនយាងដូច្នោះ នាងនេះមែនខុស ជាមនុស្សឥតយសសក្តា ។

ព្រះមហាមរហេសីក្សត្រា មរណមាតា កិរិយាថ្លែកផ្សែងពេកក្រៃ ។
ព្រះអង្គស្រួលស្រស់ល្មមល្មៃ ព្រះកន្ត្រៃប៉ែថ្លៃ ចំប្រមញញឹមស្រេចស្រស់ ។ ទំហំសក់សមកំពស់ សំឡេងពីពេះ ខន់ផ្អែមល្ហែមទាំងសំដី ។ សមជាអគ្គមហេសី សម្តេចចក្រី ឥស្សរឯកអគ្គភរិយា ។ ស្តេចស្តាប់ត្រាស់សួរកេរ៉ាំគ្នា ថាអើនរណា នាំយកមហេសីអញទៅ ។ ខ័ណ្ឌឲ្យខូចហ្នឹងសៅ ចូរប្រាប់ដោយខ្លួវ ពាក្យពិតកុំពោលមុសា ។ ចាស់ទុំបង្គំទូលថា ពុំចេរក្សត្រា ស្តេចទ្រង់ប្រោសប្រាណប្រណី ។ ថ្ងៃមួយសម្តេចក្សត្រី មានព្រះសារីយ ត្រាស់ថាបិតាឈឺធ្ងន់ ។ ដួលជាបតិចខ្មៅពេកពន់ នាងកើតទុក្ខធ្ងន់ ឲ្យអស់យើងខ្ញុំជូនទៅ ។ ដល់ហើយយើងទៅខាងក្រៅ ឯនាងឡើងទៅ លំនៅបិតាឯកអគ្គ ។ យើងខ្ញុំក្រាបទូលតាមត្រង់ កិច្ចការឯកន្ត ឃើងខ្ញុំពុំដឹងម្តេចម្តា ។ ស្តេចស្តាប់ព្រៃព្រះកន្ត្រៃ ចេីកព្រះទ្វារ ដណ្តឹងទៅនាងចន្ទណី ។ ត្រាស់ថានាងឯងឈ្មោះអ្វី ឯបន្ទណី ថាឈ្មោះមរណមាតា ។ ស្តេចត្រាស់ថាពជ្រឹក្សា តាំងតួរខោះណា ខរណាមកដាំនោះឯង ។ ឯបន្ទណីឥតព្រែង ហ៊ានទូលជាក់ស្តែង ថាឈើនេះខ្ញុំដាំពិត ។ ស្តេចស្តាប់នាងទូលច័ឃកិត ទើបស្តេចតំនិត្យ ដណ្តឹងទៅវិញទៀតថា ។ ចើនាងដាំដើមព្រឹក្សា អញឥតសង្ស័យ ប៉ុន្តែឥឡូវឈើនោះ ។ ក្សីណាក្សយប្រល័យដូច្នោះ នាងធ្វើឲ្យស្រស់ ដូចដើមវិញបានឬអេ ។ នាងស្តាប់ឆ្លើយ

វិញថាឯ ព្រឹក្សាតាំងទ្វេ ក្សីណាក្សីងប្រលីយពោះមិញ ។ ធ្វើម្តេច
ឲ្យឯងសៅវិញ ដ្បិតឈើនោះមិញ ក្សីណាក្សីយវិនាសទៅហើយ ។
ស្តេចស្តាប់នាងចន្ទណីធ្វើយ ទឹកភ្នែកត្រឡើង ទើបស្តេចត្រាស់ប្រើស្រីគ្នារ។
ឲ្យចូលទៅទីក្រវ្យា បន្ទំសយនា យកនាងសារិកាមកឆាប់ ។ ស្រីគ្នារ
ម្នីម្នាប្រញាប់ រួតរត់ដល់ឆាប់ អញ្ជើញខ្លួនាងសារិកា ។ នាំចេញ
មកថ្វាយក្សត្រា បើកព្រះទ្វារ ដណ្តើងសារិកាវិញហោង ។ ថាហៃ
សារិកាស្នេហ៍ស្នង ចូរនាងច្រាប់បង នាងនោះតើនាមឈ្មោះអ្វី ។
សារិកាថាឈ្មោះចន្ទណី កូនយាយគាលី ពុំចេះច្រើនជ្រាបចិត្តា ។
ទើបស្តេចដណ្តើងសារិកា ថានាងនាមា ឈ្មោះអ្វីចូរចែងឲ្យច្បាស់ ។ សា-
រិកាទូលថាខ្ញុំម្ចាស់ ក្រាបទូលឲ្យច្បាស់ ខ្ញុំឈ្មោះមរណមាតា ។ ស្តេច
ទូលថាដើមព្រឹក្ស តាំងគួនោះណា នរណាជាម្ចាស់ដើមដាំ ។ នាង
ទូលថាជាដំណាំ ឈើខ្ញុំម្ចាស់ដាំ ថែទាំរក្សាមែនហើយ ។ ស្តេចថា
ហៃសារិកាអើយ នាងតាំងពីធ្វើប ចម្ងើយហាក់ជាខុសគ្នា ។ នាង
មនុស្សថាខ្លួននាងមរណមាតា ព្រឹក្សថាខ្លួនដាំស្មោះ ។ សារិកាធ្វើយ
ថាខ្ញុំនោះ គឺខ្លួនជាឈ្មោះ មរណមាតាដូចដែល ។ ពាក្យតែងនាក់
តុំប្រហែល សួរទៅដែលៗ មិនដឹងជាដូរឹងណា ។ បើចេះហៃនាង
សារិកា ឈើមាសខ្ញុំហារ ឥឡូវក្សីណាក្សីយដូចម្តេះ ។ តែនាងគាប

ធ្វើឈើនោះ ឲ្យរស់ឡើងស្មោះ ដូចដើមវិញក្នុងបន្តេ ។ សារិកា
ទូលថាតុំបេរ ឈើមាសតាំងខ្ញុ ខ្ញុំធ្វើឲ្យរស់ឡើងបាន ។ ស្តេចថា
បើនាងកល្យាណ ធ្វើឲ្យរស់បាន យើងជឿនាងពិតជូចថា ។ ដូច្នោះ
ប្តូនាងសារិកា ទៅធ្វើឲ្យថា ឲ្យរស់ដូចមុនវិញនៃ ។ សារិកាស្តាប់ព្រះ
ជៀស្តដ៏ឃ បន្ទូលក្សត្រថ្លៃ នាងអរទូលព្រះទង្ការ ។ ហើយហើរទៅ
ដល់ព្រឹក្សា ទឹកតាំងសត្យា សច្ចាជាបទគាថំ ។ មមអន្តកម្បំ
មេត្តាយមំ សអកិក្ខតិ ។ សចេធុរំមេបិ មាតាទម្ហិ ជាកតាយវុឡ្ហ
តុ ។ បន្ទែប្រែតាមអន្ត សុទ្ធិវិសុ វិសុទ្ធិវិសេសវិថ្លថ្លា ។ អម្ម បពិត្រ
មាតា អម្ចាស់សិរសោ ប្រកបព្រះគុណធ្ងន់ក្រៃ ។ ព្រះមែ៉ចញ៉ឹមខ្ញុំនៃ
រក្សាប្រពៃ ដោយនៅកម្ចាំងមាតា ។ សូមជួយអន្តគ្រោះដោះសា
ដោះសែនខ្ញុំក្លា ឲ្យស្រាលឲ្យស្រួកក្នុងប្រាណ ខ្លួនខ្ញុំជាកូនតុំមាន ទ
ពឹងពាក់ប្រាណ តុំបានដូចអ្នកឡើយណា ។ ម៉ែសុវណ្ណមាសព្រឹក្សា ចាំង
គួជាក់ជា ទង្ខិមាតាត្រង់ពិត ។ ចូរឲ្យចំរើនជីវិត ទង់ស្នឹកដុះដិត
ប្តូជាផលាដូចមុន ។ ប្រកបទឹងក្តែកមហាជន ឲ្យល្អលើសមុន ក្នុង
កាលគ្រានេះឯងថ្ងាត់ ។ តេជៈតបៈពាក្យសត្យ សារិកាតែវត្តិ៍ មាន
ចិត្តខ្ចីខ្ចាវឿងស្រដី ។ នាងសាងដោយបទជាលី បរិបូណ៌សេចក្តី រឹង
សុវណ្ណព្រឹក្សា ។ លួតលាស់ល់ពង់សាខា សន្ធឹកបុប្ផ ផ្លែផ្ការុងស្គាល

ដ្ឋិនន្តៀ ។ ហាក់ដូចតុំមាសសន្ធៀ មហាជនមើលៗ តំរៃស្រែកឡៃ
សាធុការ ។ គ្រែកអវតរបើឧបមា សារសើរសេម្ភារ សាកាកៃមាន
បុណ្យក្រៃ ។ ព្រះបាទវិមលក្សត្រថ្លៃ ទ្រង់ជ្រាបព្រះទ័យ ស្តេចទ្រង់
អវតរឧបមា ។ ទើបស្តេចប្រែព្រះភក្ត្រា បើកព្រះឧស្ការ ដណ្តឹងឆ
ៅមេចន្ទណី ។ ថានែហាងឯងឈ្មោះអ្វី ឯចន្ទណី តិតព័ងពុំហ៊ាន
មុសា ។ សូមមានក្រាបទូលកុរ្តា ខ្ញុំខ្ញុំនាមា ឈ្មោះចន្ទណីប្រា-
កដ ។ ស្តេចស្តាប់ហាថ្ងៃយន្តន់ ក្រៃរៃក្រោធំអត់ ទ្រង់ត្រាស់ដណ្តឹងឆ
ៅវិញ ។ អាពុកម្តាយហាងនោះមិញ ឈ្មោះអ្វីប្រាប់អញ ឲ្យពិត
កុំពោលមុសា ។ នាងទូលដោយពិតៗថា បិតានាមា នាមឈ្មោះ
កុដ្ឋម៉ីក់សេដ្ឋ ។ មាតាខ្ញុំឈ្មោះកាលី ទើបព្រះបក្រី ស្តេចត្រាស់
ដណ្តឹងទៀតថា ។ ហេតុម្តេចហាងហ៊ានពុះពារ មិនខ្លាចចេស្តា ចូល
ចូមមកនៅកងហាន ។ នាងទូលវិញថាសូមមាន ខ្ញុំមកព្រោះមាន
មាតាបិតាប្រើខ្ញុំ ។ ឲ្យចូលមកកងឯបរម ពាជកំងិចត្តម តុំចេរទ្រង់ព្រះ
មេត្តា ។ ស្តេចស្តាប់ត្រាស់ទៀតៗថា មកមានប្រការ ដូចម្តេចហាង
ប្រាប់មកអញ ។ នាងស្តាប់ស្តេចសួរហ្នោះមិញ នាងក្រាបទូលវិញ តុំ
ហ៊ានពោលពាក្យមុសា ។ រៀបរាប់សព្វគ្រប់ប្រការ ដូចបានពណិនា
អំពីមុនមកនោះហោង ។ ស្តេចស្តាប់នាងទូលចំនង សព្វគ្រប់ហ្នោះហោង

ត្រូវដួចពាក្យទាងសារគា ។ ពុំមានមន្ទិលចិត្ត ជ្រាបត្រង់ប្រការ ប្រាៈ
កជកំត្រូវក្រោធក្រៃ ។ ហាក់ដូចអគ្គីវិស័យ ឆេះកងហួយ រន្ធត់
កងព្រះអង្គា ។ ព្រះកក្រុងុំខែងមហិមា ខេត្រប្រាលតហុលា ក្រុងខ
ជង្ហឹនថីសន្ធាប់ ។ មានព្រះទង្គារគ្នាប់ ។ បន្ទូលបង្គាប់ ថាហៃតេជ្ស-
ឃាតត្រង់គ្នា ។ ចូលធាប់ប្រញាប់ម្ដង ចាប់យកខ្លួនវា មេចន្ទណី
ឃោរឃៅ ។ កន្ត្រាក់ខំលាក់ចុះទៅ នាំចេញទៅក្រៅ តាឃាតជន្ម
ជាតិមរណា ។ រួចហើយប្រឡេះសាច់ភ្ញា កំណាចមិត្តា ធ្វើផ្នក
ប្រកាងនាំធាប់ ។ ហើយចិទ្ធជ្រងជាប់ នាំចេញប្រញាប់ ទៅ
ជូនអាពុកម្ដាយវា ។ ប្រាប់ថាតាកូនបុត្រភ្ញា នោះនាងទាមា ឈ្មោះ
ចន្ទណីពន្ធក ។ ប្រើឲ្យយើងនាំសាច់ផ្នក នេះឯងជូនមក ចិតាមាតា
តាសា ។ តេជ្សឃាតស្ដាប់ព្រះទង្គារ ធ្វើតាមអាជ្ញា ព្រះទុស្ដព្រះអង្គ
បង្គាប់ ។ ភាញ្ជៃកន្ត្រាក់ឆក់ធាប់ ឆក់នាំងក្រឡាប់ ក្រឡេក
ក្រឡៃនេត្រា ។ ចនិចំណងជ្រុំប្រការ តប់ខ្នះសំរេច ក្រញ៉ឹងក្រញាំខ្លួន
ខ្លាំង ។ ដឹកមុខនាំទៅកញ្ចាំង ធីរជើងរឹងតាំង រង្គៀករង្គើពុំបាន ។
បណ្ដើរនាងចេញចាកហាន នាងគិតញ័រជ្រាណ ពុំដឹងស្មារតីកយមាយ ។
ឈាមហូរស្រក់សព្វស្រោបកាយ ទឹកភ្នែកហូរខ្លាយ ខ្លុកឆ្ងន់ពេកពន់
ប្រមាណ ។

បទត្រហ្មកិត្តិ

រីឯបន្ទូលលើ នៅកន្លែងក្តីគ្រាំគ្រាប្រាណ កិតស្តូតបាត់វិញ្ញាណ ក្ខេច
ស្មារតីដូចមរណា ។ ឈានដើងដើរពុំដឹង ដើរហើយប្រឹងចប់ឧត្តុ
ពជ្ឈឃាតទឹងមហិមា ដឹកកន្ត្រាក់ដួលផ្កាប់មុខ ។ ទឹងឃកដៃកៅ ឯ
គេចាប់ចងរួចជាប់ខ្នុក ដួលស្រួសដល់ដីមុខ ឈាមប្រមុះហូរជ្រោច
ចោណ ។ ទំក្រោកឡើងឈានឈរ ទឹងដំហរដើរកៅបាទ ពេជ្ឈ-
ឃាតតប់ជាល់ប្រាណ ត្រូវដំណឹកក្រមហិមា ។ សាច់ដោរដាំរតាម ក្អក
ភ្នាក់ឈាមតាមផ្លូវភ្លា រៃរឹងខ្នុកវេទនា ឆ្ងន់ពោរខន់ពាំងកាយ ។ បង
សាច់រឹតរឹងតាំង តឹងឆ្ងន់ពាំងកាយរោរ កំរើកមិនរួចខ្លួន ដើរទ្រេតទ្រោត
ស្ទើរលំ ។ នាងនឹកដល់មាតា ទឹកនេត្រាហូរជន់ដុំ ឈឺផ្សាកាយក្រៃ
ដោយពេជ្ឈឃាតធ្វើពោសា ។ ពេជ្ឈឃាតខ្ញុះស្តីឡក ស្តីចំអកឲ្យទៅ
ថា អើនេះហៅហ៊ានក្លា បង់ពិសាជល់តាជន៍មាស ។ ស៊ីស្តូកគោក
កំបែក បើបង់ថ្លៃកស្មើត្រឹមថាស ម្តេចហ៊ានឡើងកខ្ញុះ តោងតាជន៍មាស
របូតកឹង ។ ភ្នាក់ក្លាយជាដំរី ដើរដោយដីត្រូវខ្ទឹង បើទាងឯង
បង់ដឹង ចោលទៅចុះបើគ្រាន់បើ ។ ខ្ញុះថាដើរឲ្យលឿន កុំតយ៉ើង
ធ្វើញាំញ៉ើ មិនពាន់ដឹងខ្លះតើ នេះហៅដៃប្រាំដំឡឹង ។ ខ្ញុះថាទំតា-
វនា យកជម្ងាជាទឹងឹ កុំក្រែកុំក្រោធទឹង កុំព្យាបាទយើងកាល់គ្នា ។

ហេតុនោះព្រះទ្រង់ញាណ ទ្រង់ទំនាន់ថ្ងៃនឹងម្ចាស់ សំដែងពីវេក កម្ម
ព្យាបាទខ្លួនជន ។ ចូរស្តាប់គំតសង្ឃាត កុំព្យាបាទវៀរពេសធ្ងន់
កុំលោភឡើសលន់ កុំចងពៀរដូចកាលី ។ បាបនោះធ្ងន់ពេកពន់
តាមពាន់ហាន់ឃើញថ្មី។ តាមពាន់កន្លះលោកិយ ពិតពុំឃ្លាតដួងព្នាះឯង ។
បណ្តើរនោងតៗ ដល់ទីត្រៀកត្រៃឡែងកែង ទីនោះសម្រាប់តែង ទុំង
ពិឃាតអ្នកពេសធ្ងន់ ។ នាងបានឃើញដួងព្នាះ ញ័រពុងពោះខ្លួនពោះខ្ទន
ខ្ទេតស្ទុតស្ទុងស្ទន់ ថ្លង់មុខមាត់ជាត់ស្មារតី ។ ពេជ្ឈឃាតឈប់ហើយ
ហោង ស្រាយចំណងចន្ទណី ខ្លះថាប្រយ័ត្នរ៉ី កុំស្រាយអស់ពេក
ដួងព្នាះ ។ ហើយស្រាយដោះចាងណាង រៀបឲ្យនាងអង្គុយចុះ យក
ដៃចិចមុខនោះ ហើយពេជ្ឈឃាតស្តីប្រាប់ថា ។ នែនាងចន្ទណី តាំង
ស្មារតីខំភាវនា កុំចងពៀរវេក ទុំងអស់យើងខ្ញុំតដួញ្ជះ ។ ស្រេច
ហើយហូតដាវយោរ ផ្តាច់ដន្ទាក់ក្បាលចុះ ហើយយកសាច់នាងនោះ
មកប្រឡេះច្រឡំគ្នា ។ ម្រាមដៃម្រាមជើងនោះ កាត់ចេញអស់ចាំង
ខ្លួហោរ ខ្លះយកតាងម្ចាស់ បុកអំបិលធ្វើជាផ្លុក ។ ពុះក្បាលជាជើង
ក្អែក ចាំងសាច់ស្បែកលើកញាត់ប្រក ជាក់ក្បាលក្រាមសាច់ផ្លុក ពាស
មាត់ពាងដិតចិចដី ។ អាជ្ញាសែងយកៗ ដល់លំនៅផ្ទះគាលី ប្រាប់
ជាចន្ទណី ឲ្យយកសាច់ផ្លុកមកជូន ។ បិតានៅមាតា ឲ្យពិសាចំណីកូន

ឥនាងប្រើមកជូន ជាចំណីប្រសើរគាប់ ។ ថាហើយអស់អាជ្ញា សំពះលា
លែប្រញាប់ កាលរៀបផ្លូវផ្ទាប់ មានចិត្តត្រេកអរពេកយ ។ ប្រាប់ប្តីនៃអាត្មា
ថាប្រាជ្ញាយើងគិតឆ្ងាយ គិតឃ្លានជាសប្បាយ ជួចចិត្តយើងចំណ្រប្ញាជ្ញ
ដឿខេប្រាជ្ញាស្រី ថាកាលីមានប្រាជ្ញា ខេប្តីនេះហៅជា ហៅខេះគិត
ក្តីសុខុម ។ ព្រោះប្រាជ្ញាកាលី គិតឲ្យប្តីបានជាធំ តីថ្ងៃនេះអ្នកកុំ
ព្រួយចិត្តគិតការអ្វីៗ ។ ខុកជាឲ្យប្រពន្ធ នឹងគិតបុណ្យឲ្យស្វាមី ប្រាជ្ញា
ឆ្នើមបុរី រកនរណាដូចមិនបាន ។ មេមរណមាតា បុត្រសង្ឃរតែវ
កល្យាណ អ្នកឯងស្រឡាញ់ស្មាន គិតនឹងលើកមុខចិតា ។ វាបាន
ជាកូត្រី អគ្គមហេសីស្តេចកុណា នៅយូរអង្វែងជា ប៉ុន្មាំហើយគ្មាន
កំសុកអ្វី ។ បពោជ្ឈនចិតា សូឲ្យឥតការចិត្តតិរ័យ ឯនាងចន្ទណី កូនស្រី
យើងគិតគុណក្រៃ ។ ទើបបានជាមហេសី ព្រះចក្រកូត្រថ្ងាថ្ងៃ ទើប
បានច្រាំមួយថ្ងៃ មានចិត្តនឹករលឹកដល់ ។ ចិតាខ្លួនមាតា រកកំសុ
ការយ៉ាងខ្លាយខ្លល់ បម្រើប្រើមកដល់ មកឲ្យយើងទាំងទ្វេហារ ។
កុដុម្ពកំស្តាប់ហើយអារ សៃនសាទរត្រេកចិត្តា លុះល្ងាចចូលនិទ្រា ដេក
លុះលក់អស់ពាត្រី ។ លុះព្រឹកព្រាងសុរិយោ លុបតក្រាហើយកាលី
គិតនឹងនាងកូនស្រី ឲ្យយកផ្កាមកជូនទោះ ។ នឹងលួកមកស្វាសុី ប្រើ
ចន្ទីលាងឆ្នាំងចុះ ឯខ្លួនកាលីទោះ បើកមាត់ឡើងហើយលួកថៅ ។

លួកម្ដងឃើញតែសាច់ លួកខៀតស្រេចឃើញឈាមផ្ដៅ មន្ដិលលួក
ខៀតទៅ ឃើញម្រាមដៃម្រាមជាជា ។ សំឡឹងមើលតិនិត្យ ហើយ
គន់គិតឲ្យល់មហិមា លួកខៀតឃើញសិរសោ មើលមុខមាត់ទ្រង់ទ្រាយ
ជាក់ ។ ស្គាល់ជាមុខកូនស្រី ចន្ទណីទើបភ្ញាក់ភ្ញាក់ តក់ទ្រូងយំអួល
អាក់ អួលទាំងវែងក្រៀមក្រំ ។ កុដ្ឋម៉ឺក៏សួរថាថ្វី នាងកាលីថ្វីក៏យំ តក់ទ្រូង
ស្ទើរទ្រឹងក្រំ មានហេតុអ្វីក៏ដូច្នោះ ។ កាលីថាអ្នកអើយ ម្ចាស់ប្អូន
ហើយមកមើលបុះ សាច់ផ្អកអ្វីដូច្នោះ សឹងសុទ្ធសាច់មនុស្សទេណា ។
កុដ្ឋម៉ឺក៏ជ្រាបស្គាល់ជាក់ តិតភ្ញាក់ក្រោកម៉ឺម៉ា មកមើលហើយស្គាល់ជា
ជាក់ជាក្បាលចន្ទណី ។ ហើយឃាត់ប្រពន្ធថា កុំសោកាទួញយំថ្វី
ក្រែងឮខ្លាយសំដី អស់អ្នកស្រុកគេសង្កា ។ កាលីឮថ្ដីឃាត់ ស្ងៀម
ជាត់មាត់ជូតនេត្រា ទើបតិតជំនុំគ្នា ជានាងអើយអស់ជាន់ទុ ។
អស់ជាន់ទីសប្បាយ កើតអន្ដរាយរត់ចោលស្រុក តាំងថ្ងៃនេះទៅមុខ
មានតែទុក្ខភ័យជាអាទិ៍ ។ នេះសមកម្មអំពើ ដែលយើងធ្វើចិត្ដប្រមាទ
ពៀរដែលយើងពិឃាត នៃនាងមរណាមគា ។ ស្ដេចជ្រាបជាក់ច្បាស់ដូច
ទើបមហាក្សត្រស្ដេចក្រោធ ត្រាស់ប្រើអស់អាជ្ញា ឲ្យសម្លាប់ចន្ទណី ។
ធ្វើដូចនាំមកឲ្យ ត្រូវឆ្លាយតិតតិចអ្វី អាសូរនាងកូនស្រី ក្សត្រីជាតិបុត្រ
ម្ដាយប្រើ ។ ថាហើយអង្គុយតេប មាត់រៃថ្ងៃបយំបណ្ដើរ ប្ដីឃើញ

ឃាត់ថាយើ យំដល់ណាមិនរីតិត ។ ធ្វើម្តេចនឹងរួចព័ទ្ធ រួចពីក្ស័យ
ជន្មជីវិត ម្ចាំរសមព្រះបពិត្រ ស្តេចទ្រង់ក្រៃក្រាធគណនា ។ កាលី
ធ្វើយវិញទៅ យើងនឹងនៅស្រុកមិនជា សមស្តេចប្រើយោធា ឲ្យមក
ចាប់យើងពុំទាន ។ សម្ងាប់ដួចកូនស្រី ចន្ទណីខែនមិនទាន យើងរក
ទីពឹងគ្មាន ឥតសង្ឃឹមសោះទៅហើយ ។ កុដុម្ភ័ក្តស្តាប់កាលី ទើបស្រដីថា
នាងអើយ គួរនិតិតទ្បៃហើយ កុំបង្អង់ឲ្យធាប់។ ។ យើងនៅយូរមិន
ឃាន ស្អែកក្សត្រក្សាត្តឲ្យមកចាប់ យកយើងទៅសម្ងាប់ ពិតប្រាកដកុំ
សង្ស័យ ។ គួរយើងគិតរត់ចេញ ពីស្រុកវិញចរចូលព្រៃ កុំប្រាប់អ្នក
ដទៃ ណាឲ្យដឹងដល់មួយឡើយ ។ កុដុម្ភ័ក្តាលីគិត ព្រមគំនិតដូច្នោះ
ហើយ បរិភោគពុំយូរឡើយ រៀបរកវេចទ្រព្យល្អ។ ។ រួចដាក់កន្ត
ក្តក យកដាលមកប្រកអង្កែ ថាសផ្តិលចានយ៉ាងល្អ យកតិចតួចល្មម
តែរែក ។ កាលីវេចសំពាយ មាត់ពេជ្រាយស្រក់ទឹកភ្នែក តឹងទ្រូង
ស្ទើរនឹងបែក ស្ទើរនឹងបោកខ្លួនសម្ងាប់ ។ កើតទុក្ខច្រើនប្រការ ឧអនិច្ច
ខ្លួនអស់ព្វ ប្រើកូនឲ្យចង់តាប់ ប្រែថាស្ងាប់ទៅអសារ ។ មិនស្ងាប់ត្រឹម
តែកូន ទោសដល់ខ្លួនផ្ទួនទុក្ខា មិនចង់សៅឥតការ អនិច្ចាកូនស្ងាប់បាត់ ។
កូនអើយកើតទុក្ខធំ ទុក្ខក្រៀមក្រំដួនប្រមាត់ ថាហើយពេជ្រាប្រមាត់
ខ្ចាចអ្នកស្រុកគេដឹងជាន ។ លង់លុះដល់ព្រលប់ ឆឹតយប់កុដុម្ភ័ក្តបាន

ដងវែករៀបប្រុងប្រាណ ឯកាលខ្លួលដើរមុន ។ ចន្លើដើរកណ្តាល តុំ
ត្រអាលកើតទុក្ខច្រួន កុដុម្ពីក៍ដើរក្រោយគន់– គិតរំពៃមើលឆ្វេងស្តាំ ។
អនិច្ចាចាស់ហើយវែក ស្រែកឮកង្កែកហូរសស្រាំ ស្តាយផ្ទះកូមិដំណាំ
គោក្របីស្រែចំការ ។ បណ្តើរគ្នាបីនាក់ យំសស្រាក់ទុលទុក្ខា ចរចូល
ក្នុងព្រឹក្សា ព្រៃស្រោងស្រឹងត្រឈឹងស្ងាត់ ។ ដើរយប់មិនឈប់ខាន
មិនសម្រាន្តស្រួតរួតកាត់ ប្រទះសត្វហូងសត្វ ខ្លាដំរីមាសក្តាន់ ។
ខន្សោងក្តោងគោព្រៃ រីករីបីច្រែនតាប់តាន់ កាលិតតែកាំងតាន់ ចាប់
ដឹកដៃមេចន្លើ ។ នាំរត់ចៀសហូងសត្វ រត់ចោលថ្នាត់ព្រាត់កុដុម្ពីក៍ រត់
រកកងខ្លួលទើ ទៅប្រទះបានជួបគ្នា ។ បណ្តើរគ្នាទាំងបី ទាំងរកត្រមិន
រោក ប្រទះសត្វច្រែនគ្រា ភ័យខន្តេតអស់អង្គប្រាណ ។ ដើរតាំងពី
ព្រលប់ ដើរមិនឈប់មិនសម្រាន្ត ទៀបហតតុំតិតប្រាណ លុះព្រឹក
ព្រាងព្រះសុរិយោ ។ ដល់ទៅស្រុកមួយធំ ឈ្មោះនោះតុំចែងចរចា តាម
ក្នុងបទគាថា ព្រះចុលីពុំសម្តែង ។ កុដុម្ពីក៍កាលទៅ ឈប់ទៀបទៅ
ស្រុកនោះឯង ស្រុកនោះវែងត្រធំជេង មានមហាជនច្រើនកុះករ ។
ទៀបទីស្រុកនោះមាន ខ្លួលធំស្តេចពីកបល្ល មានស្រះដ៏ចរ៉ែ ធំ
ខ្លួលយ៉ងទឹកថ្លាយង់ ។ ឈូកសឈូកច្រាលប្រុះ ផ្កាស្តាយស្តុះដុះរហាំ
ព្រលិតស្តួនលំចង់ សម្បុរដកបន្ទូវបុប្ផា ។ សាកយសួនកន្ទែត ផ្កាសសែត

ឆុំគន្ធា ក្រអូបសឹងកូនផ្កា ដូចអ្នកអប់តេញតាំងព្រៃ ។ មច្ឆោមច្ឆាផង
ហែលត្រសង៍ក្នុងដលស័យ ហាចហក់ហែលជ្រៀវប្រៃ ច្រើនអនេកឥតគណនា ។ កុដុម្ពីក៍ទូកាលី ឃើញប្រុសស្រីឈប់អេក រៃគិតនឹងអាយោ
ត្រមចោយឈប់នៅពីនោះ ។ ត្រោមឈើធំត្រសាយ ម្លប់រៃងឆ្ងាយមិនភ្លៀស្អុះ ឈប់ហើយកុដុម្ពីក៍ចុះ ទៅក្នុងស្រះដងគង្គា ។ យកមកឲ្យកាលី
ទ្វើចំណីបានកោគ្គា ឆ្អិនស្រេចហើយនាំគ្នា រៀបចរកោគជួនកាលនោះ ។
មានតាបសមួយអង្គ ដើរត្រាច់ត្រង់មកចំពោះ គង់ប្រុបឆ្នេរស្រះនោះ
ខៀបកុដុម្ពីក៍ឈប់នោះណា ។ កុដុម្ពីក៍ឃើញតាបស កើតសប្បុរសចិត្តសទ្ធា និមន្តគង់អាសនា ក្រាលស្បែកឈើផ្អប់ផ្អាល់ដី ។ ប្រគេនកោជនាហារ ថ្វាយព្រះតាបសឥសី ធាន់ស្រេចមានមេត្រី សួរកុដុម្ពីក៍
កាលីថា ។ ឧបាសកតាំងប៉ា នៅបុរីស្ថានស្រុកណា ឥឡូវនេះយាត្រា
ទៅទីណាច្រាប់អាចក្តី ។ កុដុម្ពីក៍ថ្វាយបង្គំ ក្រាបប្រណម្យទុនសិរសី
ថ្វាយខ្លួលតាមសេចក្តី រៀនរៀបពាក់ត្រប់ប្រការ ។ ដូចបានឱវាទមុន
មិនអៀនអន់ក្នុងចិត្តា ហើយខ្លួលអង្វរថា ខ្ញុំកុណាតាំងប៉ាតាក់ ។ តុំមាន
អ្នកឯណា បានដាគ្នាគ្រាន់ពីងពាក់ សត្វថ្លៃថ្លូមតុំនាក់ យកព្រះអង្គជាទីពឹង ។ តាបសស្តាប់សំដី អ្នកតាំងប៉ាឥតតុំនឹង យកខ្លួនជាទីពឹង ទីតុំ
នាក់ផ្ទៀងថ្កា ។ នោះទើបព្រះឥសី តបសេចក្តីទៅវិញថា អើញោម

អើយអាត្មា- ភាពសង្រ្គាះអ្នកចាំដ៏ប៉ិ ។ តាបសលោកពូន្នាន ទាន
ទានតាមសេចក្តី បរិយោយធម៌មេត្រី ឲ្យមានចិត្តជឿកុសល ។ ពីថ្ងៃនេះ
ទៅមុខ ចូលតាំងខុកចិត្តដំកល់ សតិនឹកកុសល ទំរក្សាសីលចាំង
ថ្ងៃ ។ កាន់ខ្ជាប់ចាំងថ្ងៃយប់ កុំត្រឡប់ទៅធ្វើកម្ម ប្រព្រឹត្តខ្លួនតាមធម៌ថ្ងៃ
ជាពិតពីងអង្គអាត្មា ។ កើតមកជារូបពង ធម៌ពីរយ៉ាងគួរវេក្ខ គឺទាន
និងសីលា ជាពំនាក់រូបសត្វថ្ងៃ ។ ចូរញោមចាំងប៉ិច្រាណ មកស្មាទាន
ចាំសីលថ្ងៃ កុដម្ពីក៍ស្តាប់លើកដៃ បង្គំប្រណម្យសូត្រថា ។ ទាសមយំ
ភន្តេតំដល់យាចា ខុតៈខើបព្រះតា- បសយកម្ដីតចាំងព្រះកក្តី ស្រែច
តាំងនមោតស្សា ប៉ិចប៉ច្បាស់មិនអៀនគាក់ ស្រែចយើយសាសូត្រសាក់
ឲ្យត្រែសរណគមន៍តាប់ ។ ព្រះទុស្ដមិនរង្កើល មិនរង្កើលមិនញ័រញោប់
ខើបអ្នកសូត្រប្រែសំពូ ប្រែសីលច្រាំងដោយសុចរិត ។ ចាណាតិចាតា
ចាកកំរើយាញ៉ាំងដ៏រិត មនុស្សសត្វកុំប្រព្រឹត្ត ធ្វើដោយកាយវាចាក្តី ។
អទិន្នាទានា ប្រែតាមវារៈចាលី ព្រឮគេច្រែនតិចក្តី រៀកុំដែលចូលមួម
ចូន ។ កាមេសុមិច្ឆា បរទារកាប្រពន្ធ រៀរចាតសេតមេចុន ជារបស់
អ្នកដទៃ ។ មុសាវាទាទៀង ពាក្យកុំស្លៀងកូតឡើយនៃ រៀរចាកចាំ
សត្វថ្ងៃ ជាពុំនាក់អង្គអាត្មា ។

(ទៅមានត)

រឿងព្រេងប្រទេសក្រិក

« ចែងអំពីបុត្រព្រានព្រៃ »

កិក្ខុ ម៉ែន - រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជ

ប្រែពីភាសាអង់គ្លេស

សម័យមួយ មានព្រានព្រៃមួយរូប ដែលមានបុត្រម្នាក់ ។ កាលដែលគាត់ជិតធ្វើកាលកិរិយា, គាត់ផ្តាំប្រពន្ធគាត់ថា :

– ការបង្ហាញជាដំរាតមួយយ៉ាប់ណាស់, ដូច្នេះបូរឱ្យកូនយើងប្រកបរឿងដំរាតាមរបៀបដទៃទៀតហ្ន៎ ! កុំឱ្យគេស៊ីបង្ហាញដូចអញឱ្យសោះ ។

ផ្តាំរួច ព្រានព្រៃបានធ្វើមរណកាលទៅ ។ កាលវេលាក៏ចេះតែកន្លងទៅ ។ បុត្រព្រានព្រៃបានចូលមកកន្លែរយកំបោរហើយ ។

ថ្ងៃមួយ អ្នកកំបោរ បានសួរម្តាយខ្លួនថា :-

– ម៉ែ ! ម៉ែដ៏ឆ្ងល់ណាស់ តើគាំភ្លើងលោកឪពុកនោះ គាត់ទុកកន្លែងណា ?

– កូន ! ចំណង់ខ្មោចឪពុកឯង គឺគេមិនបង់ឱ្យឯងរកស៊ីបង្ហាញដូចខ្លួនគេទេ, ប៉ុន្តែ គេបង់ឱ្យឯងរកស៊ីតាមរបៀបផ្សេងវិញ ។

– ម៉េចអ៊ីចឹង មានតែការបរបាញ់នេះ មិនសមរម្យដល់លោក ឪពុកខ្ញុំឬ ? ។

ថាហើយ បុរសចាប់គាំកែវដ៏ខ្មៅចឪពុកខ្លួន លីចូលទៅក្នុងព្រៃ ជាន់ ។ គេត្រាច់ចុះ-ឡើងតេញដងព្រៃដរាបដល់ជួបក្តាន់មួយ ។ បុរសបាញ់ក្តាន់នោះ, លើកលីដាក់លើស្មា ហើយនាំសំដៅទៅលក់នៅទីផ្សារ ។ កាលបុរសកំពុងតែអង្គុយលក់, មានរដ្ឋមន្ត្រីម្នាក់របស់ព្រះពជាដើរតាមថ្នល់ ហើយសួរអ្នកលក់ក្តាន់ថា ៖

– ក្តាន់នេះ ឯងលក់ថ្ងៃប៉ុន្មាន ?

– ចុះលោកហ៊ានឲ្យតម្លៃក្តាន់នេះប៉ុន្មាន ? (បុរសសួរតបវិញ)

– ដប់ហ្សាំស្ត្រូ (មន្ត្រីឆ្លើយ)

– ទេលោក, តម្លៃនេះ មិនល្មមទេ, លោកឲ្យនេះថាតណាស់ !

ឮប្រកែកមិនព្រមលក់ដូច្នោះ, មន្ត្រីនេះត្រឡប់ជាខឹងហើយចង់តំនុំថា ខឹងធ្វើឲ្យបុរសលក់ក្តាន់នេះ ព្រមលក់ក្តាន់តាមតម្លៃយ៉ាងថោក ជាងមុនទៀត ។ ដូច្នេះហើយ មន្ត្រីក៏ទូលទៅគាល់ព្រះពជា, ក្រាបទូលថា ៖

– មានបុរសម្នាក់លក់ក្តាន់នៅផ្សារតន់ទីក្រុង ហើយថាក្តាន់នោះសមគួរជាម្ហូបលើតុព្រះអង្គ ប៉ុន្តែសូមព្រះអង្គកុំឲ្យតម្លៃក្តាន់នោះ ឲ្យលើសតម្លៃយហ្សាំស្ត្រូកន្លះឲ្យសោះ ។

ព្រះមហាក្សត្រ ឃាននឹងគេហៅបុរសលក់ក្តាន់, បុរសកំលោក្តាន់ ចូលក្រាបបង្គំគាល់ តាមព្រះពជបញ្ជា ។ ទ្រង់សួរថា ៖

- តើអ្នកត្រូវការតម្លៃប៉ុន្មាន លើក្តាន់អ្នកឯង ?

- ក្រាបទូល ព្រះអង្គទ្រង់ជ្រាបតម្លៃដ៏សមគួរដល់ក្តាន់ទូលព្រះបង្គំស្រាប់ហើយ,

- តម្លៃដ៏សមគួរ គឺ មួយបាំស្ត្រីកន្ទុះ ! (ស្តេចទ្រង់តប)

តាមធម្មតា មនុស្សម្នាក់ ។ មិនអាចដេញដោលរកខុសត្រូវជាមួយស្តេចឡើយ ។ ម្ល៉ះហើយ បុរសលក់ក្តាន់ ក៏ទទួលយកប្រាក់មួយបាំស្ត្រីកន្ទុះនោះ រួចក្រាបបង្គំលាចេញទៅ ។

ថ្ងៃក្រោយមក ស្តេចទ្រង់បញ្ជាឲ្យបុរសនេះ ចូលទៅមកក្រាបបង្គំគាល់ទៀត ។ ម្តងនេះ ទ្រង់មានបន្ទូលថា ៖

- ខ្ញុំត្រូវការប្រាសាទមួយ ដែលធ្វើពីភ្នុកដំរី សំរាប់ទ្រទ្រង់ខ្ញុំផ្ទាល់, អ្នកឯងជាអ្នកបង្គាញ ហើយអ្នកឯងជាបុរសម្នាក់ដែលបានជួបប្រទះហ្វូងដំរី ទើងអាចយកភ្នុកវា មកឲ្យខ្ញុំបាន, កាលណាអ្នកបានភ្នុកហើយ, ត្រូវអ្នករៀបចំសាងប្រាសាទ ដោយភ្នុកនោះឲ្យខ្ញុំ ។

ឮព្រះពជបញ្ជាយ៉ាងនេះ, កូនព្រានព្រៃឥតមានវាចាអ្វីហើបឡើងសោះ ។ ស្តេចត្រាស់សួរថា ៖

ម្តេចបានជាអ្នកបាត់មាត់យ៉ាងនេះ ? បើអ្នកឯងអាចធ្វើបានក្តី មិនអាចក្តីក៏ត្រូវតែនិយាយមក, តែបើអ្នកឯងមិនអាចទេ អ្នកនឹងត្រូវពិយាជបង់ ។

– ក្រាបទូល, ខ្ញុំព្រះអង្គអាចធ្វើបាន, (បុរសធ្វើយ)

ប៉ុន្តែបុរសក្រាបបង្គំលាចេញទៅ ដោយឥតមានសេចក្តីក្លាហាន, ព្រោះថា តើអ្នកណាទៅ ដែលអាចនឹងស្វែងរកកូកឲ្យល្មមគ្រប់គ្រាន់ដើម្បីធ្វើប្រាសាទ ? ។ បុរសបានត្រឡប់ទៅផ្ទះរបស់ខ្លួន, និយាយប្រាប់ម្តាយថា ៖

–ម៉ែ ! ខ្ញុំមើលទៅ មិនអាចរស់នៅក្នុងពិភពលោកនេះឲ្យវែងតទៅទៀតបានទេ ព្រោះព្រះពជាទ្រង់បង្គាប់ឲ្យខ្ញុំទៅរកកូកដ៏រឹ មកធ្វើប្រាសាទថ្វាយព្រះអង្គ, កាលបើខ្ញុំធ្វើតាមព្រះពជបញ្ជានេះមិនសំរេច, ទ្រង់នឹងសំឡាប់ខ្ញុំចោលហើយ ។

រួចហើយ បុរសប្រាប់ម្តាយទៀត អំពីរឿងកំរឹដែលបណ្តាលឡើងហើយនិយាយថា ៖

–ម៉ែ ! សូមម៉ែឲ្យស្បៀងមួយមកខ្ញុំ ព្រមទាំងនំបុ័ងបន្តិចមកផង ព្រោះខ្ញុំត្រូវតែឃ្លាតចេញពីផ្ទះ ទៅកាន់ទីដែលខ្ញុំមិនទាន់ជួបប្រទះហើយ ។

ម្តាយរបស់បុរសប្រាប់ថា :

– កូន! ម្តាយចាំប្រាកដនូវពាក្យដែលឪពុកឯងតែងតែនិយាយថា

ខ្ញុំដើរទៅលើមហាបពិតឯណោះ ដំរីទាំងពួយ តែងមកផឹកក្នុងត្រពាំងដ៏ថ្កុំធ្ងន់មួយ រៀងរាល់អាទិត្យ , បើប្រសិនណាជាព្រះរាជា ទ្រង់ទតឃើញក្នុងទីកន្លែងនេះ អញនឹងយកក្នុងដំរីទាំងអស់ឲ្យបាន គឺអញបួមរឹតចេញពីត្រពាំងនោះឲ្យអស់ រួចចាក់ស្រោចំពេញវិញ ។ ពេលនោះ កាលណាដំរីមក, វាទំនឹងផឹកស្រារួចមុខជាស្រវឹងមិនខាន, ហើយអញក៏នឹងអាចយកក្នុករាប់បាន ពិតប្រាកដ ។

កាលបើបុរសឮដូច្នេះ, គេត្រឡប់ជាក្តាហានឡើងវិញ, ដើរទៅកាន់សំណាក់ព្រះរាជា ហើយទូលថា :

– ខ្ញុំព្រះអង្គ រៀបចំខ្លួនទៅយកក្នុកដំរីរួចរាល់ហើយ, សូមព្រះអង្គទ្រង់ព្រះកដ្ឋានដល់ទូលបង្គំជាខ្ញុំ ខ្លួរស្រាចំនួន ៤០ ធុង នឹងកម្មការទៅធ្វើការជាមួយខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គនឹងចាប់ផ្តើមធ្វើការភ្លាយ ។

ស្តេចទ្រង់អនុញ្ញាតតាមពាក្យសុំ ។ កម្មការទាំងឡាយនាំគ្នាសែងធុងស្រា ហើយបុរសត្រានត្រៃបាននាំអ្នកទាំងនោះទៅកាន់មហាបពិត ។ គេបានបួមរឹតអស់ពីត្រពាំង, ចាក់ស្រោចំពេញដំនួស រួចគេនាំគ្នាទៅលាក់ខ្លួនពួនអាត្មាក្នុងព្រៃនោះ ។ កាលដែលដំរីមកដល់ត្រពាំង ក៏នាំគ្នាផឹកស្រា, អំណាចស្រាធ្វើឲ្យដំរីទាំងនោះស្រវឹង ខ្លះដើរទ្រេតទ្រោតជ្រុលត្រពាំង រកជួយគ្នាមិនបាន, ខ្លះទៀតដួលចុះ ហើយដេកលក់តែម្តង ។

ដំរីពាំងនោះ ទៅជាធំធុល រកការពារខ្លួនឯងមិនកើត ។ ពេលនោះ បុត្រព្រានព្រៃ ទើបកម្មករពាំងឡាយ នាំគ្នាចេញពីក្នុងព្រៃមក, អារយកភ្លុកដំរីពាំងនោះ ហើយសែងនាំចូលទៅកាន់ទីក្រុង ត្រង់កន្លែងដែលត្រូវសាងប្រាសាទក្នុកថ្វាយស្តេច ។

ការដ្ឋមន្ត្រីនៃព្រះរាជា ដែលជាអ្នកបង្កបង្កើតសេចក្តីចង្អៀតចង្អល់ បានឃើញបុរសព្រានព្រៃ សំរេចដោតដំយកភ្លុកដ៏តំចុងការដូច្នេះ, កំហឹងរបស់គាត់ រីឡើងតែលួតលាស់ខ្លាំងឡើង ។ មន្ត្រីនេះ បានចូលទៅគាល់ព្រះរាជា, បានសំរេចចិត្តពេលនេះថា ឱកាសធ្វើការបំបរបង់ចំពោះកូនព្រានព្រៃ ឲ្យបាត់ស្រមោលតែម្តង ។ គាត់ទូលព្រះរាជាថា :

-បពិត្រព្រះអគ្គ, ទៅលើភ្នំមួយឆ្ងាយទៅទិសខាងត្បូងឯណោះ, មានបុរសជាបងប្អូនធំគ្នាប្រាំពីរនាក់ទៅក្នុងទីនោះ, បុរសពាំងនេះ មានប្អូនប្រុសម្នាក់មួយប្រកបដោយរូបឆោមល្អឆើត សមគួរជាអគ្គមហេសីនៃព្រះអគ្គ ក្នុងព្រះរាជដំណាក់ក្នុកដ៏មនោរម្យនេះ, សូមព្រះអង្គបញ្ជូនកូនព្រានព្រៃ ឲ្យទៅយកព្រះនាងទៅបាន ។

ព្រះមហាក្សត្រទ្រង់ព្រះចិត្តអំពីការនេះ រួចទ្រង់ដូចជាមានតម្រេកត្រេកត្រអាលជាខ្លាំង ។ ដូច្នេះហើយ ក៏ទ្រង់បញ្ជាឲ្យកូនព្រានព្រៃ ចូលគ្រាបបង្គំគាល់ ហើយទ្រង់បង្គាប់ឲ្យបុរសកំឡោះ ធ្វើដំណើរទៅកាន់ភ្នំ

ទាន់ស្លឹងនោះ ដើម្បីទៅយកទាន់កញ្ចាដ៏ច្រើនច្រើយនៃបងប្អូនច្រាំពីនោក់នោះ ថ្ងាយទ្រង់ ។

ដោយឥតមានសេចក្តីសង្ឃឹមចង្កិចសោះនោះ, បុរសកំឡោះ តំចាប់ស្ពាយស្បៀងរបស់ខ្លួន រួចចាប់ផ្តើមធ្វើដំណើរចេញទៅ, មិនដឹងថាតើខ្លួនបានត្រឡប់វិលវិញ ឬមិនបានទោះសោះឡើយ ។ គេធ្វើដំណើរទៅឆ្ងាយ . . . ហើយថ្ងៃមួយ បានទៅដល់ទន្លេដ៏ធំមួយ ថែមទាំងបានជួបបុរសម្នាក់ អង្គុយលើច្រាំងទន្លេ ហើយគិតតែងឆកទឹក; ឆកហើយឆកទៀត ឆកបណ្តើរនិយាយបណ្តើរថា « ខ្ញុំស្រេកទឹក ! ខ្ញុំស្រេកទឹក ! ខ្ញុំមិនដែលបានឆកទឹកឲ្យឆ្អែតមួយសោះ ! » ។ ទន្លេដ៏ខ្ពស់ខ្ពស្ហាយ បានហូរយ៉ាងត្រកួញ ន្តោះទៅតែនឹងដែលបុរសដ៏តឆក ។

ឃើញដូច្នោះ, បុរសកំឡោះក្មួនព្រានត្រេស្តូរវាថា :

-អ្នកឯងដ៏ជាមនុស្សយ៉ាងម៉េច បានជាស្រេកទឹកខ្លាំងម្ល៉ះ ?

-ចាខ, (វាឆ្លើយ) ខ្ញុំចាខជាអ្នកស្រេកជាងគេ ហើយខ្ញុំចាខជាមនុស្សកំព្រាគោកយ៉ាក ព្រោះខ្ញុំធ្វើដំណើរតែម្នាក់ឯង, បើប្រសិនជាខ្ញុំមានសំឡាញ់ម្នាក់ ខ្ញុំមុខជាលែងតោកយ៉ាកហើយមើលទៅ ! ។

-បើដូច្នោះ ត្រូវយកគ្នាជាសំឡាញ់, រួចយើងធ្វើដំណើរទៅទាំងអស់គ្នា, (កូនព្រានត្រេនិយាយ) ។

កាលគេធ្វើដំណើរឆ្ពោះទៅទិសខាងត្បូងនោះ គេស្រាប់តែជួបរាក់ក្រាក់ធំមនុស្សម្នាក់ទៀត ដែលកំពុងតែប្រប្លុកប្រប្លល់ព័ទ្ធគំនរកូនដំសន្ធោសន្ធៅមួយកន្ត្រក់ ។ ប៉ុស្តែថ្មីនេះ ចេះតែនិយាយដដែល ។ ថា : « ខ្ញុំរងា ! ខ្ញុំរងា ! គ្មានកំដៅកូនតូចណាមួយឲ្យបានត្រជាក់ត្រាន់សោះ ! » ។ កូនព្រានព្រៃ បានយកបុរសនេះជាសំឡាញ់ទៀត រួចគេបន្តដំណើរឆ្ពោះទៅទិសខាងត្បូងជាមួយគ្នា ។

តាមផ្លូវ គេបានជួបមនុស្សចំឡែកម្នាក់ទៀត កំពុងតែអួរលេបម្ហូបអាហារមួយចំនួនធំ ។ មួយចានហ៊ាយមួយចានទៀត គាត់ចេះតែដួសស៊ី ។, ស៊ីផង និយាយផងថា : « ខ្ញុំឃ្លាន ! ខ្ញុំឃ្លាន ! » ។

កូនព្រានព្រៃ បានយកបុរសនេះ ជាសំឡាញ់ម្នាក់ទៀត រួចបាន ៤ នាក់ បានបន្តដំណើរទៅជាមួយគ្នា ។

កាលគេធ្វើដំណើរទៅ គេជួបមនុស្សម្នាក់ទៀត ដោយកត្រចៀកផ្លុំខ្លាំងដ៏ ដើម្បីស្តាប់ស្តាន់ការណ៍ដែលលេចឡើងក្នុងពិភពលោក ។ គេក៏យកបុរសនេះជាមិត្តទៀត, រួមបាន៥នាក់ហើយ ។

ពេលនោះ គេបានទៅជួបប្រទះនឹងបុរសម្នាក់ទៀត ជាអ្នកខាងលោតយកចម្ងាយ ។ បុរសនេះ ច្រវាក់ជាប់នៅកន្ទុយដែរ ហើយត្រូវដើរដុំថ្មនោះទៅខាងក្រោយ រួចគាត់លោតផ្លោះទៅខាងមុខ កន្លងទៅជាមួយ

គ្នា ។ ការត្រៃដែងដុំថ្មទៅក្រោយ កន្លងពេលដែលគាត់ទៅមុខដូច្នេះ ធ្វើឲ្យគាត់លោតផ្លោះយកចម្ងាយយ៉ាងអស្ចារ្យមោ ។ ក្មួនព្រានត្រៃ កំពុងយកបុរសខេះជាសំឡាញ់ទឹងគ្នាទៀត, ហើយឥឡូវបានគ្នា ៦ នាក់ហើយ ។

ទីបំផុត, កាលគេធ្វើដំណើរទៅមុខ គេបានជួបទឹងបុរសម្នាក់ទៀត ដែលអាចធ្វើឲ្យដែនដីកក្រើកញាប់ញ័របាន ។ រួបរួមគាំងបុរសថ្មីនេះឥឡូវមានគ្នាគាំងអស់ចំនួន ៧ នាក់ ។

បុរសគាំង ៧ នាក់នេះ នាំគ្នាធ្វើដំណើរឆ្ពោះទៅមហាឋានជាទីដែលបងប្អូន ៧ នាក់រស់នៅ ។

កាលបងប្អូនគាំង ៧ នាក់នោះ ក្រឡេកឃើញមិត្រយើង គេក៏ស្គុះចូលមក ដើម្បីបំផ្លាញជីវិតយើង ។ ប៉ុន្តែដោយឃើញថា គ្នាយើងជាយុវជនខ្លាំងពូកែ គេក៏រួញរា ហើយត្រឡប់ជាសួរយើងថា ៖

– ពួកអ្នកឯងមកកន្លងទីនេះធ្វើអ្វី ? ត្រូវការអ្វី ?

– យើងមកដើម្បីប្អូនក្រមុំឯង, (ក្មួនព្រានត្រៃធ្វើឯ) , ស្តេចយើងត្រូវការនាងធ្វើជាអគ្គមហេសី ហើយនាងនឹងបានសុខដុមក្នុងប្រាសាទភ្នំកប៉ូ ជាមួយព្រះអង្គតទៅ ! ។

ភាគរៈគាំង ៧ នាំគ្នាចូលទៅផ្ទះវិញ រួចចាប់ធ្វើគ្រោងការមួយ ។

កូនព្រានព្រៃ នឹកឆ្ងល់ក៏សួរគ្នាយើងថា "តើគេកំពុងនិយាយពីអ្វី?" ។ គ្នាយើងម្នាក់ ដែលយកត្រចៀកផ្ទប់ផែនដី ស្តាប់រឿងរ៉ាវកិច្ចពិភពលោក កំចាប់ប្រតិបត្តិការភ្លាម, រួចបានដឹងថា ភាតរៈទាំងនោះនឹងយកមហាភាជន៍ ពេញដោយភោជនមកឲ្យគ្នាយើងបរិភោគ, បើយើងអាចបរិភោគអស់, គេនឹងឲ្យប្អូនក្រមុំនោះមកយើង, បើយើងមិនអាចទេ គេពុំព្រមឡើយ ។ ដឹងដូច្នេះ កូនព្រានព្រៃក៏ពិភាក្សាសួរថា :

– តើយើងអាចសំរេចការនេះដូចម្តេចកើត ?

បុរសដែលឃ្វានជានិច្ច ឆ្លើយថា :

– យី, សំឡាញ់ឯងភៀតព្រួយធ្វើអ្វី ? ក្រែងខ្ញុំនៅក្នុងពិនេះដែរឬ ? ភ្លាមនោះ ភាតរៈទាំង ៧ បាននាំគ្នាយើងចូលទៅកន្លែងគេ រួចគេលើកមហាភាជន៍ពេញដោយភោជនចំនួន ៧ មកដាក់ពីមុខកនយើង ។ គ្នាយើង ៦ នាក់ បរិភោគតែបន្តិចក៏ស្កប់ស្កល់គល់ផ្ទៃ មិនបន្តសកម្មភាពទៅទៀតបាន ប៉ុន្តែគ្នាយើងម្នាក់ដែលឃ្វានជានិច្ចនោះ បានត្រវែងស្ទាបត្រាចោល តាំងចាប់បរិភោគដោយផ្ទាល់ដៃតែម្តង ។ កាលដែលភោជនជាច្រើនអស់ហើយ គាត់ចាប់យកភោជនអ្នកដទៃទៀតមកបន្ថែម លុះត្រាតែលើងឆេងពីមហាភាជន៍ទាំង ៧ ។

ប៉ុន្តែភាតរៈទាំង ៧ មិនមានសុខចិត្តប្រគល់ប្អូនស្រីខ្លួន ឲ្យគ្នា

យើងនៅឡើយទេ, គេគិតរកការល្បងខ្លះទៀត មកពិសោធយើង ។ គេបានយកទឹក ៧ ពាងយ៉ាងធំ មកឲ្យកូនយើងផឹក ។

ពេលនេះ គ្នាយើងម្នាក់ដែលស្រែកជាទិច្ចនោះ បានសម្លឹងតាមពាង ៧ យ៉ាងក្បែរហែង ។ អស់ហើយ គាត់ស្រែកថាទៀតថា :

- យកអ្វី ។ មកឲ្យខ្ញុំផឹកទៀត ! ខ្ញុំស្រែកណាស់ !

ជួនច្នេះ, កាត:ពាង ៧ បានរះរកទឹកស័ង្គជនៃទៀត មកកំដរដំណើរមិត្រយើង ។ គេនិយាយមកកាន់គ្នាយើងថា :

-កូនចំណោមអ្នកពាក់អស់ ត្រូវជនម្នាក់មកអត់ទ្រាំកំដៅយ៉ាងខ្លាំងឲ្យបាន ទៅកូនបន្ទប់ចំហាយរបស់យើង មុនដែលយើងលើកបួនស្រីឲ្យ ។

ម្ដងនេះ បុរសដែលតែងតែរអ៊ាជាទិច្ចនោះ ពោលអះអាងថា :.

- សូមទុកឲ្យខ្ញុំធ្វើការនេះ, ខ្ញុំអត់ទ្រាំនឹងកាកាស (ត្រជាក់) ស្រុកខាងត្បូងនេះ មិនបានទេ !

ពេលនោះ បុរសនេះ បានចូលទៅកូនកំដៅដ៏អស្ចារ្យនៃបន្ទប់ចំហាយ ។ កាត:បានដំឡើងកំដៅយ៉ាងខ្លាំង ល្មមឲ្យមនុស្សធម្មតាស្លាប់បានដោយសារកំដៅនោះ ។ គេរង់ចាំមើល តែពុំបានឮសូរសំឡេងអ្វីលាន់ចេញពីបន្ទប់នោះសោះ ។ គេបានទៅបើកទ្វារបន្ទប់ (ស្មានថាគាត់ស្លាប់ទៅហើយ) រួចអើតមើលទៅខាងកូន កំត្រូវកូនយើងនោះ

ស្រែកគំហកឲ្យថា :

– ចំខ្វាតៅ ! អ្នកឯងកុំមកធ្វើឲ្យគាត់ស្រក់ចួលទឹកនេះ ! គ្នាកំពុងតែស្រួល !

ឃើញដូច្នេះ គេបានទាំបុរសនោះ ចេញពីបន្ទប់មកវិញ ហើយពេលនោះ ភាតរៈទាំង ៧ ឃានឧយ្យោយថា :

– ឧអ្នកទាំងអស់គ្នា, យើងបានឲ្យអ្នកធ្វើអ្វី អ្នកបានបំពេញការនោះចប់សព្វគ្រប់ហើយ, ប៉ុន្តែយើងនៅមានការពិសោធន៍មួយទៀតចំពោះអ្នកទាំងអស់គ្នា, បើអ្នកអាចធ្វើការនោះបាន យើងនឹងប្រគល់ប្អូនស្រីយើងឲ្យអ្នកហើយ , ហ្ន៎ ! នៅលើកំពូលភ្នំឯណោះ មានកន្ទេះទឹកផុសមួយ , ជនម្នាក់ក្នុងចំណោមពួកអ្នក ត្រូវទៅយកទឹកពីកន្ទេះនោះឲ្យបាន, យើងឲ្យប្អូនស្រីយើងទៅយកទឹកនោះដែរ បើអ្នកអាចនាំយកទឹកនោះមកជូនមុន នោះទើបអ្នកអាចយកប្អូនស្រីយើងបាន , តែបើផ្ទុយពីនេះទៅវិញ ចេសកកម្មរបស់អ្នក គ្មានផលអ្វីឡើយ ។

ក្បែរណានោះ គ្នាយើងម្នាក់ដៃលប៉ុនខាងលោត បានគាន់យកទូរថ្មដ៏ធ្ងន់ពីដុំកូនដៃ រួចគាត់ត្រវែងទៅខាងក្រោយ នៅពេលដែលគាត់ដើរទៅខាងមុខ កូនល្បែនលោតផ្លោះយ៉ាងសម្បើម, ធ្វើយ៉ាងនេះចប់តាមផ្លូវ ទៅកាន់ភ្នំទឹកផុសនោះ ។ គាត់បានបំពេញទឹកកូនដប រួច

ត្រឡប់វិញដោយដំណើរដដែល ។

តាមផ្លូវ គាត់ឃើញនាងកញ្ញាដែលកំពុងតែដើរទៅយកទឹកផុសនោះនៅឡើយ ។ គាត់និយាយទៅកាន់នាងថា :

– នាងក្រមុំ ! ដូចនាងឃើញស្រាប់ហើយ, ខ្ញុំមានជំងឺដំនេរលើនាងហើយ ! បើអីចឹង តួរយើងអង្គុយនិយាយគ្នាលេងមួយសន្ទុះសិន !

ពេលនោះ នាងគិត្រមអង្គុយលេង, ប៉ុន្តែអកលោតដំចំណាប់របស់យើង ស្រាប់តែទៅជាងុយដេក រួចដេកលក់តែម្តងទៅ ។ ឃើញដៃហើយ, នាងស្រីគំចាក់ផ្លែយកទឹកពីជបគ្នាយើងនេះ ទៅក្នុងជបរបស់នាង រួចធ្វើដំណើរត្រឡប់មកផ្ទះវិញ ។

ខេសកាលអ្វីបណ្តាលឲ្យកូនពានព្រៃ ទឹកពិកាល់ធ្លាក់ក្នុងចិត្តចង់ដឹងថា តើមានហេតុការណ៍អ្វីកើតឡើងដល់អ្នកទៅយកទឹក ឬ គ្មានទេ ។ ដើម្បីបំបាត់សង្ស័យនេះ, គ្នាយើងម្នាក់ឃើញជាក់ត្រចៀកផ្ទប់ទៅនឹងដី រួចថ្លែងថា :

–កនយើង ចាញ់គេហើយ ! មិត្រយើងដេកលក់, ហើយនាងកញ្ញាបានផ្លែយកទឹកមិត្រយើង, ឥឡូវនាងកំពុងតែត្រឡប់មកវិញ ។

ប៉ុន្តែ យើងមានសំឡាញ់ម្នាក់ទៀត ដែលចេះធ្វើឲ្យផែនដីរញ្ជួយ និយាយជានាថា ពុកឲ្យខ្ញុំជាស់គាត់ ! « ពុកឲ្យខ្ញុំជាស់គាត់ ! » ។

បុរសនេះ បានធ្វើឲ្យគេយួយញ៉ាវ ហើយអ្នកលោតកំភ្លាក់ដឹងខ្លួនឡើង,មើលនាយមើលអាយ បានដឹងថា នាងស្រីយកទឹកខ្លួនអស់ រួចរត់ទៅបាត់ដូច្នេះ គាត់ក៏ចាប់ធ្វើការលោតផ្ទះជាច្រើនដងទៀត ខ្ពោះទៅកាន់ទីដែលស្ត្រីកំពុងតែរត់ ។ ខាន់ហើយ គាត់ចាក់ផ្ទេរយកទឹកពីនាងវិញ ហើយដោយការលោតផ្ទះម្តងទៀត គាត់បានទៅដល់ទីដែលសំឡាញ់ធំចាំ ។

ឥឡូវនេះ ដោយតិច្ចការត្រង់យ៉ាង ត្រូវសំឡាញ់យើងបានបំពេញដោយវាងវាតជ័យយ៉ាងនេះ , ភាតរៈទាំង ៧ មិនអាចកែការពិសោធន៍ដទៃទៀត មកធ្វើមិត្រយើងធ្វើឡើយ ។ ម្ល៉ោះហើយ គេក៏ព្រមប្រគល់ប្អូនស្រីនោះ មកសំឡាញ់យើងតាមសន្យា ។

បុត្រព្រានវៃ្រ នឹងសំឡាញ់ខ្លួន បាននាំនាងកញ្ញាត្រឡប់ទៅកាន់សំណាក់នៃព្រះមហាក្សត្រវិញ ។

ព្រះរាជា កាលទ្រង់យល់ខ្លួវៃ្រវែកញ្ញាដ៏តើតឆាយនោះហើយ ព្រះទ័យព្រះអង្គ ក៏ពុះពារដោយសេចក្តីរីករាយហួសប្រមាណ ។ តែរដ្ឋមន្ត្រីនៃព្រះអង្គ , ដោយឃើញបុត្រព្រានវៃ្រ បានសំរេចដោតជ័យក្នុងការចំបាបាំដូច្នេះ ក៏ជាផ្ទុះចេញខ្លួរកំហឹងយ៉ាងពន្លឹក ។

ចំណែកខាងនាងកញ្ញា , នាងត្រឡប់មើលស្តេច , មើលរដ្ឋមន្ត្រីរបស់ស្តេច ហើយនាងតយគន់ប្រាសាទក្នុងរួចសួរថា ៖

– នរណារកកូនមកធ្វើប្រាសាទនេះ

– កូនព្រានព្រៃ ! (ស្តេចឆ្លើយ)

– ចុះនរណាសាងប្រាសាទនេះ ?

– កំកូនព្រានព្រៃ !

ហើយនរណាទៅដែលធ្វើដំណើរទៅយកខ្ញុំពីក្នុងឆ្នងត្បូងមក ?

– ទឹងកំកូនព្រានព្រៃដែរ !

– យី , ចុះបើកូនព្រានព្រៃ ធ្វើកិច្ចការគ្រប់បែបយ៉ាងនេះ ម្តេចក៏ខ្ជួនខ្ជុំត្រូវអតិសេកជាមួយព្រះអង្គវិញ ?

ពេលនោះ នាងប្រកាសថា ៖

– ដោយចរិយាដ៏លាមករបស់ខ្ញុំ , ចូរជួមន្ត្រីនៃទ្រង់ក្លាយខ្ញុំជាកណ្តុរ ! ឯទ្រង់ជាឆ្មា ! ត្នាចូរដេញចាប់កណ្តុរ !

ដូចសេចក្តីនាងប្រកាសមែន , ជួមន្ត្រីបានក្លាយទៅជាកណ្តុរ ឯព្រះមហាក្សត្រទៅជាឆ្មា រួចដេញចាប់កណ្តុរនោះ ។

មហាជនបានលើកកូនព្រានព្រៃ អតិសេកធ្វើជាស្តេចថ្នូរបស់ខ្ញុំ ។ ព្រះមហាក្សត្រីយ៍ បានតាំងស្ត្រីនោះ ជាមហេសីទ្រង់ , បានតង់នៅក្នុងប្រាសាទក្នុងទាំង៤ព្រះអង្គ ដោយរីករាយតមក . . . ។

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុនក្នុងមធ្យមសម័យ

លោក ភ័យ-ប៊ុក ប្រែរៀបរៀង

រឿងពលិកម្មនៃលោកកាណាម៉ុតស៊ូ

ក្នុងបុរាណសម័យក្តី មធ្យមសម័យក្តី នៅប្រទេសជប៉ុន មានស្តេចគ្រាញ់ជាច្រើន ។ ស្តេចគ្រាញ់ទាំងនោះ តែងកសាងប្រាសាទយ៉ាងល្អៗ ដូចជាប្រាសាទនៃស្តេចគ្រាញ់ម្នាក់ព្រះនាម ម៉ណាអ៊ូតូ ដែលបិតនៅលើភ្នំតូចមួយ ។ ជញ្ជាំងប្រាសាទនោះមានសភាពយ៉ាងមាំមួន រចនាដោយដុំថ្មធំៗ គ្មានបាយអស្ចារ្យទេ ។ នៅខាងក្រោយអង្គស់ មានសើនមួយខ្ពស់ដែលជាលំនៅរបស់ព្រះអង្គ ។

ព្រះអង្គម្ចាស់ទ្រង់ស្តេចយាងទៅ-មក ក្នុងបន្ទប់ធំមួយនៃសើននោះ ទ្រង់មានព្រះដំណើរញាប់ញ័រ ទៅតាមសភាពព្រះកូសាវែង ទំនស្ងាប់ព្រះជន្មរបស់ទ្រង់ធំសមានបុណ្យអូសដី ។ ពេលនោះ ពួកស្រីស្នំគ្រាន់តែបានក្រឡេកឃើញផ្កាន់នៅលើព្រះនលាដជ្រួញជាច្រើនផ្គត់, តន្ត្រីព្រះបាទាលើព្រះធរណីជាច្រើនលើក-ច្រើនសា កំបានយល់ថា ព្រះអង្គទ្រង់ពិរោធជាខ្លាំង ។

គេមិនអាចដឹងបាន អំពីហេតុដែលធ្វើឲ្យព្រះអង្គទ្រង់ព្រះពិរោធ

ដូច្នេះសោះ ប៉ុន្តែ បន្តិចមក ទ្រង់មានព្រះបន្ទូល ឲ្យព្រះពាជបុត្រមេស់ព្រះង្គអញ្ជើញព្រះនាម ត្សុណីម៉ូតូ ឲ្យវិលត្រឡប់ពីព្រះវិហារព្រះពុទ្ធសាសនា ដែលទ្រង់បានបំពេញការសិក្សានៅក្រោមឫទ្ធានៃលោកគ្រូ ខ្លួលអប៉ំម្នាក់ឈ្មោះ ណាកាម៉ុតស៊ូ ។

ព្រះពាជបុត្រព្រះនាម ត្សុណីម៉ូតូ ទ្រង់ត្រឡប់មកកាន់ពាជធានីវិញជាមួយលោកគ្រូណាកាម៉ុតស៊ូ ទើបកូនលោកម្នាក់ឈ្មោះតាកាម៉ុតស៊ូ ។

ដល់ហើយព្រះអង្គម្ចាស់ ទើបអ្នកទាំងពីរកើចូលទៅក្រាបថ្វាយបង្គំតាមទំនៀម ។

គ្រានោះ ស្តេចត្រាញ់មានព្រះបន្ទូលទៅកាន់ព្រះពាជបុត្រថា កូនឯងដឹងទេ ? ការណ៍យកចិត្តជាបឋមរបស់មនុស្ស គឺការធ្វើតាមបង្គាប់ឥតមានរួញរា តាំងពីថ្ងៃចាស់ទន្ទឹមហួតដល់ថ្ងៃមរណៈ ចំពោះអ្នកខ្ពស់គឺបិតានឹងចៅហ្វាយនាយ ។

ព្រះពាជបុត្រត្សុណីម៉ូតូបានក្រាបបង្គំទូលថា "ពិតប្រាកដមែនបិតា!"។

- " កូនឯងដឹងទេ ? អ្នកណាដែលមិនស្គាល់ការណ៍យកចិត្តនេះនឹងត្រូវខ្លួនឯងក្លាយជាឥតន័យវិនាសចំផុត" ។

- "ពិតមែនបិតា!" (ព្រះពាជបុត្រក្រាបទូលព្រះបិតា) ។

- " កូនឯងដឹងទេ? តញ្ញាបានបញ្ជូនឯងទៅកាន់ព្រះវិហារព្រះពុទ្ធ-

សាសនា ដើម្បីឲ្យឯងសិក្សាស្ទួនច្បាប់ព្រះពុទ្ធសាសនា អំពីសំណាក់លោកគ្រូណាគាម៉ុតសូ តើឯងបានបំពេញកិច្ចតាមបង្គាប់អញឬទេ ? " ។

- " បពិត្របិតា ! កូនមិនបានធ្វើតាមបង្គាប់បិតាទេ , គួរតែកូនធ្វើតាមទើបសម កូនសូមអភ័យទោស " ។

- " ឯងមិនទៅសិក្សាច្បាប់ព្រះពុទ្ធសាសនាតាមបង្គាប់អញ ឯងត្រឡប់ជារៀនស្ទួនចំបាំងទៅវិញមែនឬ ? " ។

- " កូនសូមសំដែងសេចក្តីស្តាយជាខ្លាំងបំផុត ដែលមិនបានធ្វើតាមព្រះពាដបញ្ជាខែព្រះបិតា " ។

-" អញដឹងថា ឯងជាកូនចៅនៃពួកយោធា ពេញចិត្តខាងគ្រឿងសស្ត្រាវុធជាងការសរសេរៀនសូត្រខ្លាញ, តែកូនចៅនៃពួកយោធា ត្រូវឲ្យចេះដឹងគុណគេ ជាអ្នកធ្វើតាមបង្គាប់អញបំពោះមុខអ្នកដទៃ.. ឯងមិនធ្វើតាមបង្គាប់អញសោះ អញមិនឲ្យមនុស្សទៅក្រោមបង្គាប់ចំណងាស់ដឹងអញទេ, ឯងជាកូនអញ ។ ត្រូវតែប្រឹងតឹងជាងអ្នកដទៃទៀត អញត្រូវជាក់ចំណុកម្នាឯង គឺប្រហារជីវិតបង់ " ។

ព្រះពាដបុត្រក៏ក្រាបបង្គំទូលថា " តាមតែព្រះហឫទ័យព្រះបិតាចុះ " ។

គ្រានោះ ពួកសេវាគាមាត្យ ជានចិត្តតក់ស្លុតជាខ្លាំងចំពោះការសម្រេចនៃព្រះអង្គយ៉ាងនេះ ។

ចំណែកខាងលោកណាកាមុតស៊ូ កំសុះចូលទៅចំពោះព្រះភក្ត្រ ព្រះអង្គក្រាបទូលថា:-

សូមទ្រង់ព្រះមេត្តាប្រោស! កុហុសទាំងអស់ធ្លាក់មកលើខ្ញុំ ព្រះបង្គំទេ ខ្ញុំព្រះបង្គំគួរតែបង្រៀនព្រះអង្គម្ចាស់ឲ្យមាំមួន, សូមព្រះអង្គជាក់ទណ្ឌកម្មខ្ញុំព្រះបង្គំចុះ ហើយទ្រង់សន្ទោសប្រោសប្រណីទោសដល់ព្រះពជបុត្រវេស់ព្រះអង្គ, សូមទ្រង់អនុញ្ញាតឲ្យព្រះអង្គម្ចាស់ត្រឡប់ទៅកាន់ព្រះវិហារព្រះពុទ្ធសាសនាវិញ ដើម្បីទំនប់ធនសិក្សាព្រះ-ត្រៃបិដកតាមព្រះពជបញ្ជាតទៅ ។

គ្រានោះ ស្តេចត្រាញ់ មានព្រះបន្ទូលតបវិញថា:-

ម៉េចក៏អ្នកឯង ហ៊ានពោលពាក្យទំនឹងមុខអញ :ជាយអញមិនបានសួរដូច្នេះ ឯងហ៊ានខំទំនាស់ទំនឹងអញ។ត្រូវតែដាក់សេចក្តីសម្រេចរបស់អញជាអចិន្ត្រៃយ៍មិនប្រែប្រួល ហើយអញត្រូវដាក់ទណ្ឌកម្មឯងខ្លាំងឯងត្រូវប្រតិបត្តិតាមបង្គាប់អញ, នេះព្រះទំនងរបស់អញ ឯងត្រូវយកព្រះទំនងនេះកាត់ក្បាលកូនអញ ហើយឯងយកក្បាលមកឲ្យអញក្នុងព្រឹកស្អែកកុំខាន ។ តមក ទ្រង់ខតចំទៅព្រះពជបុត្រតូណីម៉ូតូថា:-

"ឥឡូវនេះ ត្រូវឯងទៅជាមួយលោកគ្រូណាកាមុតស៊ូចុះ" ។

លោកគ្រូណាកាមុតស៊ូ យំសោកនឹងព្រះពជបុត្រថា:

«ខ្ញុំព្រះបង្គំត្រូវតែធ្វើតាមព្រះពាជបញ្ជា , តែខ្ញុំព្រះបង្គំធ្វើ
ពុំបានទេ តើឲ្យខ្ញុំព្រះបង្គំធ្វើយ៉ាងណា ចំពោះព្រះបន្ទូលសម្រេច
ជាអវសានរបស់ព្រះអង្គម្ចាស់ប៊ិតា ? ខ្ញុំព្រះបង្គំពេញចិត្តខាងជួយស្រោច
ស្រង់ព្រះអង្គឲ្យមានព្រះជន្មតទៅទៀត . គឺទ្រង់វិលត្រឡប់ទៅព្រះវិហារ
ព្រះពុទ្ធសាសនាវិញ » ។

-"ទេលោកគ្រូ ! ខ្ញុំត្រូវតែខ្វល់ខ្វាយកម្មតាមព្រះពាជបញ្ជា
ជូតព្រះបិតាខ្ញុំ រង់ចាំខ្វល់ក្បាលខ្ញុំ" ។

-«បើខ្ញុំព្រះបង្គំនៅក្មេង ខ្ញុំព្រះបង្គំនឹងកាត់ក្បាលខ្ញុំ
ព្រះបង្គំយកទៅថ្វាយព្រះអង្គម្ចាស់ប៊ិតា ប្រហែលជាព្រះអង្គទ្រង់កាន់
ប្រឡាំពុំខាន , តែពេលនេះ ក្បាលខ្ញុំព្រះបង្គំមានសក់សង្រោងដូច្នេះ
មុខជាព្រះអង្គពុំជឿឡើយ" ។

ឯកូនរបស់លោកគ្រូណាកាម៉ុតស៊ូស្រែកឡើងថា «ឧប៉ា ! ខ្ញុំ
ឯណេះនៅក្មេង សូមប៉ាកាត់ក្បាលកូនយកទៅថ្វាយព្រះអង្គម្ចាស់ប៊ិតា
ចុះ ខ្ញុំជាពូជសាមុរ៉ៃ (១) , ពូជសាមុរ៉ៃ ត្រូវរស់នៅ ឬស្លាប់ដើម្បី
លោកដៃមីយូ (២) , ខ្ញុំប្លាសតស្លាយជីវិតទេ ព្រោះតវណីយកិច្ច
របស់កូនបិតនៅពីនេះហើយ , ។

---

(១) ពួកយោធា ។ (២) ជៅហ្វាយតាយ ស្តេចគ្រាញ់ អភិជនណាមួយ ។

ព្រះអង្គម្ចាស់តូណាម៉ូតូកំមានព្រះបន្ទូលថា ខ្ញុំមិនត្រូវការឲ្យកូនលោកគ្រូធ្វើតលិកម្មដូចេ្នះទេ ត្រូវតែខ្លួលស្វាប់តាមព្រះរាជបញ្ជា ។

លោកគ្រូណាកាម៉ុតស៊ូ ឆ្លើយតបវិញមកវិលក៏ពោលថា:

ឥតុកអគ្គុណានឹងកូនហើយ សូមថ្វៃដន្ធូរសេចក្តីសរសើរចំពោះកល្យាណកិច្ចនេះ កូនឯងជាភូដសាម៉ុរ៉ែពិតប្រាកដមែន ព្រោះបានយល់ច្បាស់នូវការណ៍យកិច្ចរបស់ខ្លួន , ក្នុងពេលរសៀលនេះ ឥតុកនឹងធ្វើតាមការណ៍យកិច្ចដែលគួរធ្វើ ។

ក្នុងពេលរសៀលខោះ លោកគ្រូណាកាម៉ុតស៊ូបានកាត់ក្បាលកូនគាត់ យកទៅថ្វាយព្រះបាទម៉ណាម៉ូតូ ។ ទ្រង់យល់ថា គេធ្វើតាមព្រះរាជបញ្ជារបស់ព្រះអង្គហើយ ទ្រង់មិនបានពិនិត្យឲ្យម៉ត់ចត់នូវក្បាលខោះទេ ។ លុះព្រឹកឡើង ទ្រង់ត្រាស់ហៅលោកគ្រូណាកាម៉ុតស៊ូមកសួរថា " តើអ្នកឯងធ្វើតាមបង្គាប់យើងហើយឬ ? " ។

-" ព្រះករុណាថ្លៃវិសេស " (លោកគ្រូណាកាម៉ុតស៊ូក្រាបទូល)។

-" តើកូនយើងស្លាប់ដៃមណា ? ប្រហែលជាស្លាប់ដោយកំសាកខេដឹង ? " ។

-"សូមទ្រង់ព្រះមេត្តាជ្រាស ! ព្រះរាជបុត្រនៃព្រះអង្គ ទ្រង់បានបង្គំឲ្យខ្លួលព្រះបង្គំធ្វើតាមព្រះរាជបញ្ជា ទ្រង់ជាអ្នកមានសេចក្តីភ្ញាហាន

អង់អាចចំពោះសេចក្តីស្លាប់ណាស់ តាំងមានសភាពថ្លៃថ្លាដូចជាព្រះរាជ
ខត្តោនៃព្រះអង្គដូច្នេះ" ។

-ល្អហើយ ! ល្អហើយ ! ឥឡូវ យើងមានរឿងមួយទៀត ដែលត្រូវនិយាយទំនងអ្នកឯង គឺយើងគ្មានព្រះរាជបុត្រទំនងសោយរាជ្យស្នងយើងទេ យើងមានសេចក្តីពេញចិត្តចំពោះអ្នកឯង ដែលមានចិត្តស្មោះត្រង់ទំនងយើង, អ្នកឯងជាពូជសាមុរៃពិត ។ បុត្រាបស់អ្នកឯងប្រហែលជាមានគុណសម្បត្តិដូចអ្នកឯងពុំមាន ហើយជាកល្យាណមិត្រទំនងត្បូណាម៉ូតូជាកូនរបស់យើង, បុត្រាបស់អ្នកឯងនេះហើយ ដែលយើងត្រូវជ្រើសយកមកជំនួសត្បូណាម៉ូតូ ដើម្បីទំនងសោយរាជ្យស្នងយើង ចូរអ្នកឯងចាត់ការនេះឲ្យបានសម្រេច ។

លោកត្រូណាកាម៉ូតស៊ូកំទើតក្នុងចិត្តថា ឥតរួចឲ្យអនិច្ចាតាកាម៉ូតស៊ូកូនអញ ។ រំដួលចិត្តខ្លាំងណាស់ អញមិនអាចក្រាបទូល នូវការពិតចំពោះព្រះចាខម៉ាណាម៉ូតូសោះឡើយ ក្រែងព្រះអង្គទ្រង់ព្រះពិរោធចំពោះព្រះអង្គម្ចាស់ត្បូណាម៉ូតូ អញត្រូវកុហកម្តងទៀតហើយ ។ ក្រាបទូលព្រះចាខម៉ាណាម៉ូតូថា :-

សូមទ្រង់ព្រះមេត្តាប្រោស ! ឥឡូវនេះ កូនរបស់ទូលព្រះបង្គំចេញចាកផ្ទះទៅហើយ ចាខគោរសក់ដូចជាព្រះសង្ឃដូច្នេះ ។

តមក លោកគ្រូណាកាមុតសូ កំក្រាបថ្វាយបង្គំលាព្រះបាទមីណាម៉ូតូ ចេញពីព្រះពន្ធកំង លោកមានមុខមាំងតមានតក់ស្លុតអ្វីសោះឡើយ ។

លុះបួនដងបាត់ថ្ងៃក្រោយមក មានព្រះសង្ឃមួយអង្គនិមន្តពីព្រះវិហារពុទ្ធសាសនាដើម្បីចូលមកគាល់ព្រះបាទមីណាម៉ូតូ ។ ព្រះសង្ឃអង្គនេះមានថេរដីកាចំពោះព្រះបាទមីណាម៉ូតូថា :-

«នេះចំណាមហាតលិកម្មយ៉ាងអស្ចារ្យ ដែលលោកតាកាមុតសូបានធ្វើ ហើយដែលនឹកលោកបានយល់ព្រមផង, ក្នុងនាមនៃមហាតលិកម្មនេះ អាត្មាសុំព្រះអង្គទ្រង់ព្រះការុណ្យតែលើកទោស ចំពោះព្រះអង្គម្ចាស់តូណាម៉ូតូ ដែលទ្រង់វិលទៅកាន់ព្រះវិហារពុទ្ធសាសនាវិញ ទ្រង់បានតាំយាមសិក្សាក្សួនតម្រាព្រះពុទ្ធសាសនា តាមព្រះពន្ធបញ្ជានៃព្រះអង្គ" ។

ទ្រង់ព្រះសណ្តាប់ដូច្នោះ ព្រះបាទមីណាម៉ូតូ ទ្រង់មានព្រះពន្ធឲ្យហៅលោកគ្រូណាកាមុតសូមកគាល់ព្រះអង្គ ដើម្បីបង្ហាញអំពីរឿងនេះ។

លោកគ្រូណាកាមុតសូក៏មកដល់ មានសាមុរ៉ៃ ជាកល្យាណមិត្តម្នាក់មកជាមួយផង បានក្រាបទូលនូវព្រឹត្តិការណ៍ផ្សេង ចំពោះព្រះបាទមីណាម៉ូតូ ។ ទ្រង់ព្រះសណ្តាប់នូវពាក្យលោកគ្រូណាកាមុតសូដោយព្រះភក្ត្រមាំ ។

លំដាប់មក ព្រះអង្គទ្រង់មានព្រះរាជឧង្ការថា ណាកាមុំតសូ ! ដោយហេតុការធ្វើមហាយ័ញ្ញដ៏ប្រសើរ យើងអត់ទោសឲ្យអ្នកឯង តែមែនតែអ្នកឯងមិនបានប្រតិបត្តិតាមបង្គាប់យើង, ម្យ៉ាងទៀត យើងអត់ទោសឲ្យកូនយើងដោយលើកខ្លួនណា ចាប់តាំងពីថ្ងៃនេះតទៅ ត្រូវតែកូនយើងស្គាល់តម្លៃនៃការប្រព្រឹត្តិប្រតិបត្តិតាម ។

លោកគ្រូណាកាមុំតសូកំពុងក្បាលគោរពព្រះបាទមណាម្ពូ ។ ឯសាមុរ៉ៃជាកល្បាណមិត្តបានពោលថា ៖

ឯងសប្បាយចិត្តណាស់ ! ព្រោះឯងបានខូលអកយ៉ាទោសអំពីព្រះបាទមណាម្ពូចំពោះព្រះរាជបុត្រ ---- ។ ឯងសប្បាយចិត្តណាស់ព្រោះតែម្យ៉ាលមិញ ឯងបានកាត់ក្បាលកូនឯង ---- ។

លោកគ្រូណាកាមុំតសូតបថា អើខ្ញុំសប្បាយចិត្តមែន ។ តែក្នុងមួយរំពេចនោះ លោកណាកាមុំតសូយកដៃជាំងកែកដើម្បីនឹងកុំឲ្យគេឃើញទឹកភ្នែកគាត់ ដែលកំពុងហូរចេញមក ។

ឯកល្បាណមិត្តរបស់លោក បានខូលតុក្កដាចំពោះព្រះសង្ឃថា លោកណាកាមុំតសូយំនេះ គឺមិនមែនយំ ព្រោះកូនលោកដែលខូលមរណាភាពទេ គឺប្រាកដជាលោកគិតថា មានសេចក្តីស្តាយណាស់ដោយកូនលោកមិនបានចំរើព្រះរាជបុត្រតទៅមុខទៀត ។

ចប់រឿងពលិកម្មនៃលោកណាកាមុំតសូ

(នៅមានត)

កណ្ឌទី ៤១

ទេសនាប្រៀបធៀបនឹងកន្លែងដែលមានសេចក្តីសុខ

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះខួរយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ។

ចូរធ្វើកិច្ចរៀបចំនេះ ១ គូ ឲ្យបាំងថងដុះ ១ ជិះខ្លួនឯង ១ ហើយនាំចេញទៅមើលលើកំពូលភ្នំ បាំងថងពិគ្រោះមើលហើយ គិតក្នុងសេចក្តីថា ដែលមហាទេពាដតាំងបន្ទាយនេះ ជាជាន់ដើងបន្ទាយពាយមែបនឹងមាត់ព្រៃ យកដើងភ្នំជាខ្ទីតឹងគ្រប់បន្ទាយ ហើយមានទ្វារចេញចូលហូតដល់គ្នាយ៉ាងស្រួល ឯក្បួនខ័ណ្ឌដែលតាំងបន្ទាយនេះ មាំមួនលើសជាងគ្រាស៊ុនចិនតាំងក្បួនខ័ណ្ឌដូច្នោះ ទឹងរកអ្នកឯណាស្មើគ្មាន ទោះបីស៊ុនចិនទោះទឹងមានជីវិតរស់ឡើងវិញ ហើយមកធ្វើការតទឹងលោកគ្រានេះក៏មិនឈ្នះលោកឡើយ។ ចូរតបថា អ្នកកុំលើកបញ្ហាខ្ញុំហួសពេក

បើយើញខាស់ខុសត្រង់កន្លែងណា ត្រូវតែអ្នកជួយណែនាំលើក ខ្ញុំនឹងសុំយកតម្រិះប្រាជ្ញាអ្នកតទៅ ហើយចូរធ្វើកំនាំចាំងឯងចុះមើលខ្លះតទៀត ។

ចាំងឯង ក្រឡេកឃើញខ្លួនចម្បាំងធំ ។ ចេញទៅចតជាប់ឆ្នាយពីខាងក្រៅ ទុកចន្លោះប្រហែល ២០ អន្លើ ឯខ្លួនតូច ។ កំចតចេញពីខាងក្នុង មានខ្លួនយាមល្បាតសម្រាប់ប្រើប្រាស់ជាការហ៊ានច្រើន ចាំងឯងគិតសង្កេតហើយថា ដែលមហាឧបរាជចាត់របៀបឆ្នាយខ្លាំងគាត់ចតនេះ ត្រឹមត្រូវនឹងល្បួនចេញខ្លាតចាំងអស់ សម ដូចពាក្យមនុស្សនិយាយសរសើរឲ្យឮល្បីចេញទៅប្រាកដមែន , ដ៏ឃើញគ្រានេះ មុខជាទំនាស់ទៅក្នុងគណបក្សដែរបស់មហាឧបរាជប្រាកដមិនខាន ។ ចូរធ្វើបានឮដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណ ទើបនាំចាំងឯងចូលទៅក្នុងឆ្នាយចំរកាតអាហារ ហើយចូរក្លែងដេញដោលដាំងឯងក្នុងការសង្គ្រាមច្រើនណាស់ ។ ចាំងឯងក៏អធិប្បាយកែទំនាស់បំភ្លឺឲ្យចូលចិត្តគ្រប់ប្រការ មិនបានធ្វើយឲ្យខាស់អស្រ័យអ្វីមួយសោះ ។ ចូរក៏តែងមានចិត្តត្រេកអរណាស់ទៅទៀត រាប់អានចាំងឯងជាដូចគ្រូអាចារ្យ ។ ចាំងឯងក៏សួរចូរថា លោកលើកទ័ពមកគ្រានេះមានពេទ្យសម្រាប់កងទ័ពមកដែរឬទេ ? ។ ចូរតបថា អ្នកសួរពេទ្យនោះនឹងប្រាជ្ញប្រយោជន៍អ្វី ? ។ ចាំងឯងថា ខ្ញុំខុសគេទាំង ខ្លាចក្រែងឈឺក្តៅគ

ត្រូវគ្នា បើមានពេទ្យនឹងបានព្យាបាលក្សា ។ បន្ទូលថ្វាយថាពេទ្យនោះ
មានសម្រាប់ទ័ពដាវច្រើនណាស់ ។ ចាំនឹងថនក្មែនសួរថាកងទ័ពគោកទ័ពទឹក
ដែលលោកចាត់ចែងនេះ ល្អត្រឹមត្រូវហើយ តែទ័ពទឹកនោះខ្ញុំបាទគិត
ស្តាយការម្យ៉ាង លោកទៅមិនទាន់បានធ្វើផង ។ បន្ទូលសួរដេញដោល
ដល់២-៣ដងថា ការអ្វីដែលខ្វះ ? ។ ចាំនឹងថនក្មែនជាព្រះនើយកន្តើយបីដូច
ជាវិធីខឹងពុំបាន កំនើយតបទៅវិញថា គំនិតរបស់ខ្ញុំបាទដែលឃើញនៅ
ខ្វះនោះ ព្រោះពាហនទូកចម្បាំងរបស់លោក ច្រើនតែពួកអ្នកត្រៃលើ
មិនសូវចុំនប្រសប់ខាងការទេ ឯការខាងទន្លេនោះសឹងប្រកបទៅដោយ
រលកខ្យល់ជាច្រើន ពាហនពួកនោះ មិនធ្លាប់តឹងនឹងមានពុលរលក
បែកខ្ញែកអស់ទៅ ព្រោះទូកចម្បាំងនោះ ឃ្លោងផ្លៀងជាងកប ការដែល
ច្បាំងប្រយុទ្ធគ្នាក៏ងាយបាត់មិនបានស្រួលហើយ បើប្រសិនជាយកទូកធំ ។
មកជាក់ផ្ទុំជាប់គ្នានឹងទូកតូច ហើយតាបចងឲ្យរឹងទៅជាផែនដុំ៤០,១ដុំ៥០
ហើយចងឈើមកតាបធ្វើជាក្បូន តេចងខាងក្បាលនឹងកន្ទៃឲ្យជាប់គ្នា
ហើយយកសោច្រវាក់ចាក់ភ្ជាប់ជាលំដាប់រៀងទៅ រួចយកក្តារមកក្រាល
ពីលើឲ្យរហូតផុតទូកទាំងអស់ តាបឃ្លាបឲ្យរឹងណែនជូបផែនដី ទើបឲ្យ
តាំងបន្ទាយឡើង ពុកសម្រាប់ការពារ កាលបើទូកចម្បាំងទាំងពួងនឹង
ណែនល្អអស់ហើយ ពាហនរបស់យើងក៏អស់ភ័យនឹងពុលរលក តោះបី

សេះឬមនុស្សក៏ដើរហួតទៅមកបាន ទ័ពបានជួយការពារគ្នាយ៉ាងចំណាប់ ។

ចូឆូឮដូច្នោះ ក៏មានតន់តិតតែមានសេចក្តីត្រេកអរណាស់ ក្រោកឡើងគំនាប់ជាំដ៏ថនហើយថា ឯតម្រែដែលរៃគិតរបស់អ្នកនេះល្អណាស់ គ្រានេះមុខជាទ័ពបានស្រុកកាំនតាំន ព្រោះអ្នកប្រាប់កិច្ចកលឲ្យយើង, ហើយបង្គាប់អ៊ីតមទ័ពម៉ាយដែលជានាយទ័ពទឹក ឲ្យទំស្រួតធ្វើការតាំនពួនតាមបង្គាប់ជាំដ៏ថន តែខ្លួកបម្បាំនតូច ។ ឲ្យដកខ្លុកប្រើប្រាស់ ១០០ ឬ ២០០-៣០០ អ៊ីតម, ម៉ាយកំបង្គំឲ្យទាហានធ្វើការតាមបង្គាប់ ។ ជាំដ៏ថនក៏ភ្លែនថា ខ្ញុំបានឃើញទ័ប្រឹក្សាទ័ងសេនាទាហានតាំនពួនដែលមកក្នុនទ័ពជាវៃនោះ មានសេចក្តីតូចចិត្តទ័ងជាវៃជាច្រើន ខ្ញុំបានទ័ងសុំអាសាទៅបញ្ចុះបញ្ចូលមនុស្សតាំនអម្បាលនោះឲ្យមកនៅទ័ងមហាឧបរាជ ឯជាវៃក៏ទ័ងអស់តម្រិះរិះគិតចុះជាលំដាប់ លោកក៏ទ័ងពាប់ខ្លួនបានដោយងាយ ប្រសិនបើបានខ្លួនជាវៃហើយ ឯទ្បៅតាទ័ងខ្លុនបេនក៏ដូចជានៅក្នុនកណ្តាប់ដៃលោក ។ ចូឆូមិនបានដឹនកលមានចិត្តត្រេកអរហើយនិយាយថា បើអ្នកទ័ងជួយការៈគ្រានេះសម្រេចហើយ ខ្ញុំទ័ងបានទូលស្តេចតាប់ប្រសើរ ឲ្យព្រះចៅហៀនតេតាំងអ្នកជានាម៉ុនធំ ។

(នៅមានត)

ពាក្យវិប្បដិមិ

លោក នាង-ហ៊ូ រៀបរៀង

លោក សម-ថាំង ពិនិត្យ

អស់លោកអ្នកអានទាំងឡាយ !

ឧកាសនេះ ខ្ញុំសូមរៀបរៀងសេចក្តីជារបៀបពន្យល់ពាក្យ, របៀបបង្ហាត់ប្រើពាក្យខ្លះ ដែលគណៈកម្មការវិប្បដិមិ បានបង្កើតរួចមកហើយ, ហើយនឹងលើកយកពាក្យណា ដែលខ្មែរយើងធ្លាប់ប្រើតាមផ្លូវការក្តី តាមផ្លូវសារពត៌មានក្តី ដោយឃ្លាតគ្នាអំពីន័យរបស់ពាក្យនោះៗ ដែលគណៈកម្មការបានរៀបចំរួចមកហើយ មកពន្យល់ឲ្យមានការយល់ស្របគ្នាទៅតាមការសម្រេចរបស់គណៈកម្មការ, ព្រោះតាមដែលខ្ញុំបានសង្កេតឃើញសព្វថ្ងៃ យើងពាំងអស់គ្នាប្រើប្រាស់ភាសាជាតិ ច្រើនតែបណ្តាយទៅតាមចំនើនចិត្តរៀងៗខ្លួន ពុំសូវបានពិនិត្យពិនិស្ច័យ អំពីការខុសត្រូវជាមុនសិន ហើយសឹមប្រើប្រាស់ពាក្យនីមួយៗនោះឡើយ ម្ល៉ោះហើយការមិនស្របគ្នា ដោយការបកប្រែពាក្យពីភាសាបាំងឆមកជាខ្មែរកំមាន ដោយការយល់ឃ្លាតគ្នាអំពីក្បួនវេយ្យាករណ៍កំមាន ដោយអក្ខរាវិរុទ្ធកំមាន ។ កំប៉ុន្តែកង្វល់នាមនៃគណៈកម្មការវិប្បដិមិ ខ្ញុំមានការណ៍យកចិត្តទុកដាក់យ

ពន្យល់តែអំពីពាក្យណាដែលគណៈកម្មការ ជាន់បង្កើតឡើងហើយ ។ យើងនៅតែខ្វះច្បាប់ប្រើប្រាស់ដោយការយល់ខុស, ព្រមទាំងរៀបរៀងជារបៀបបង្ហាត់ប្រើប្រាស់ពាក្យ ដែលគណៈកម្មការជាន់បង្កើតរួចមកហើយ យកទៅផ្គូផ្គងនឹងពាក្យចាំាង ដើម្បីឲ្យជនរួមជាតិ ជាន់ជ្រាបនូវន័យរបស់ពាក្យនីមួយ ។ តាមចំនងដែលខ្ញុំអាចនឹងពន្យល់ទៅជាន ។

ក្នុងពេលនេះ ខ្ញុំសូមលើកយកពាក្យដែលខ្ញុំជាន់សំគាល់ឃើញជនរួមជាតិភាគខ្លះធ្លាប់ប្រើប្រាស់ខុស ដោយការនិយាយ ឬក៏ដោយការសរសេរជាលាយលក្ខណ៍អក្សរ យកមកដាក់ជាមុនសិន

អំពីពាក្យថា ក្រសួង :- ពាក្យនេះកន្លងមកនៅក្នុងវចនានុក្រមភាគទី ១ លោកថា « មុខងារ, មុខការ » ខ្មែរយើងប្រើពាក្យក្រសួងសព្វថ្ងៃ សំដៅកន្លែងស្តីការរាជការគ្រប់ក្រមទៅវិញដូចជាថា " ក្រសួងគំាង, ក្រសួងគយនិងរដ្ឋាករ, ក្រសួងពេទ្យសត្វ, ក្រសួងពេទ្យ, ក្រសួងសុរិយោដី, ក្រសួងត្រួតត្រាជនចូលស្រុក, ក្រសួង គង្គា វត្តា ប្រមាញ់ នឹងនេសាទ, ក្រសួងកងក្រវៃល ។ ល ។

ការប្រើប្រាស់ពាក្យថាក្រសួង សំដៅទៅលើក្រមរាត់ការរាជការធំៗខ្លះដូចជំពូកខាងលើនេះ ពុំមានជាការខុសឆ្គងនឹងនរណាស់ទៅឡើយទេ ឃើញនៅមានប្រើប្រាស់ សំដៅទៅលើក្រមរាជការតូច ។ ខ្លះទៀត ដូចជា

ថា ក្រសួងផែកផ្លែរថយន្ត , ក្រសួងពន្ធ, ក្រសួងអនាម័យ, ក្រសួងគុក, ។ ល ។ ដូច្នេះក៏រ៉ាំរ៉ៃតែតែខុសធ្ងន់ខ្លាំងតទៅទៀត ។

បានជាខ្ញុំដំកថា ការប្រើប្រាស់ពាក្យថា ក្រសួង ដូចឧទាហរណ៍ខាងលើនេះខុកជាខុស ព្រោះពាក្យថា ក្រសួងនេះ គណៈកម្មការវិឡ្ឍមិបានសំរេចរួចទៅហើយ ទាំងបានបុះផ្សាយក្នុងសារពើធ្មក្រម ភាគទី១ ត្រង់ទំព័រ ៨៩ ថា ពាក្យក្រសួងនេះត្រូវគ្នានឹងពាក្យបារាំងថា (Ministère) សំដៅយកទីស្តីការរបស់រដ្ឋមន្ត្រី ។ បើពោលឲ្យងាយយល់ ពាក្យក្រសួង ប្រើបានចំពោះតែទីស្តីការរដ្ឋមន្ត្រី ។ ក្រសួងធម្មការ , ក្រសួងយុត្តិធម៌, ក្រសួងមហាផ្ទៃ, ក្រសួងសិក្សាធិការ ។ ល ។ សូមធ្វើប្រយោគជាឧទាហរណ៍ជូនដូចតទៅនេះ ៖

ខ្ញុំបានសុំអនុញ្ញាតឈប់ កសាងវត្តច្បាំមួយ, ឥឡូវសំណុំរឿងនោះបានបញ្ជូនទៅដល់ក្រសួងធម្មការហើយ ។ កាលពីថ្ងៃមុនរដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់ របស់ក្រសួងយុត្តិធម៌ ស្តីពីទម្ងន់ទោស លើអ្នកលេងល្បែងស៊ីសងជាប្រាក់ ។ លោកចៅហ្វាយស្រុក១រូប បានសុំអនុញ្ញាតពីក្រសួងមហាផ្ទៃដើម្បីឈប់សំពកមួយខែ ។ សៀវភៅសម្រាប់សិក្សាដែលខ្ញុំបានរៀបរៀងរួចហើយនោះ ក្រសួងសិក្សាធិការពុំទាន់អនុញ្ញាតឲ្យប្រើប្រាស់ជាផ្លូវការនៅឡើយ ។ ដូច្នេះពាក្យថា ក្រសួង

ប្រើប្រាន់តែចំពោះមន្ត្រីរដ្ឋការរបស់រដ្ឋមន្ត្រីទេ សព្វថ្ងៃក្នុងប្រទេសយើងមាន
ទីស្តីការរដ្ឋមន្ត្រី ១៦ មន្ទីរ ពាក្យថាក្រសួងនេះ គំរប្រើប្រាន់តែចំពោះមន្ទីរ
ចាំង ១៦ នោះតែប៉ុណ្ណោះដែរ គឺ: ក្រសួងសិក្សាធិការ, ក្រសួងធម្មការ,
ក្រសួងយុត្តិធម៌, ក្រសួងមហាផ្ទៃ ក្រសួងការបរទេស, ក្រសួងការងារ
និងសង្គមកិច្ច, ក្រសួងការពារប្រទេស, ក្រសួងការពារលើផ្ទៃប្រទេស,
ក្រសួងសន្តិសុខ, ក្រសួងហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ច, ក្រសួងកសិកម្ម,
ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសុខភាពបាល, ក្រសួង
ឃោសនាការ និង ក្រសួងផែនការ ។ ឯកន្លែងចាត់ការពាក់ការឯទៀត ។
ដែលនៅក្រោមបង្គាប់ ក្រសួងរដ្ឋមន្ត្រីមួយ ។ ត្រូវនិយាយ ឬសរសេរថា
ក្រុម ឬ ដំបន់ទៅវិញ ដូចជាក្រសួងតិញទៅជាក្រុមព្រះនគរបាលជាតិ,
ក្រសួងគយនិងរដ្ឋាករទៅជាក្រុម គយ និងរដ្ឋាករ, ក្រសួងពេទ្យសត្វទៅ
ជាក្រុមបសុពេទ្យ ឬ ពេទ្យសត្វ, ក្រសួងពេទ្យទៅជាក្រុមពេទ្យ ក្រសួង
សុរិយោដីទៅជាក្រុមសុរិយោដី, ក្រសួងត្រួតត្រាជនចូលស្រុក ទៅជា
ក្រុមអន្តោប្រវេសន៍, ក្រសួងគង្គា វុត្តា ប្រមាញ់ និងនេសាទទៅជាក្រុម
គង្គា វុត្តា ប្រមាញ់ និងនេសាទ ក្រសួងកងក្រវែលទៅជាក្រុមកងក្រវែល,
ក្រុមនៃគរនេរវេយន្ត, ក្រុមពន្ធ, ក្រុមអនាម័យ, ក្រុមពន្ធនាគារ ដូច្នេះ
វិញទើបស្របនឹងន័យពាក្យថាក៏ជា (Service) ដែលគណៈកម្មការបាន

ប្រែថា "ក្រុម" (Service des Eaux et Forêts. Service des D. et R. Service de contrôle des autos) ។

ម៉្យាងទៀតពាក្យថាក្រសួងនេះ ដែលគណៈកម្មការបានប្រែមកពីពាក្យបារាំងថា (Ministère) នោះមិនមែនមានន័យប៉ុន្តែទេ ក្រសួងប្រើបានចំពោះតែទីស្តីការដ្ឋមន្ត្រី ឯពាក្យបារាំងថា (Ministère) មានន័យប្រើនយ៉ាងទៅទៀត គឺ:

ក)- មុខងារ ឬ ភារៈ ដែលគេត្រូវបំពេញ ។ L'Avocat rempli ses devoirs dans son ministère មេធាវី បំពេញភារៈកិច្ចតាមមុខងារបស់ខ្លួន ។

ខ)-សន្ធានកម្ម, ការជួយឈ្លាសយកអាសា ។ L'O.N.U. offert son ministère dans le conflit de canal de Suez) : អ. ស. ប. បានធ្វើសន្ធានកម្ម កន្លងរឿងព្រៃកជីកស៊ុយអេ ។

គ). អាណត្តិ, គឺពេលដែលរដ្ឋមន្ត្រីនៅកាន់មុខតំណែង ឬកិរដ្ឋមន្ត្រីមណ្ឌល (Fonction de ministre; temps pendant lequel on l'exerce)

។ កន្លងអាណត្តិគណៈរដ្ឋមន្ត្រីលោក យ៉ែម-សម្បូរ ពជការបានចំណាយច្រើន នៅភ្នាត្រហឹម ស្រុកកំពង់ត្រឡាច ។

ឃ)- ទីស្តីការនៃរដ្ឋមន្ត្រី (Département d'un Ministre)

ង) – ចៅក្រមមួយផ្នែក ក្នុងក្រុមតុលាការដែលសម្រាប់ចោទប្រកាន់ ជនអ្នកប្រព្រឹត្តល្មើសនឹងច្បាប់សម្រាប់សង្គម (Ministère public) ។

សេចក្តីអធិប្បាយ ដោយសង្កេតអំពីន័យរបស់ពាក្យថាកំងថា (Ministère)នេះ សឲ្យយើញច្បាស់ថា ពាក្យនេះមានន័យវែងឆ្ងាយជួលយជាងពាក្យខ្មែរយើងថាក្រសួង តែតាមនៃពាក្យក្រសួងនេះ គណៈកម្មការបានតម្រូវនឹងពាក្យថាកំងថា (Ministère) ប៉ុន្តែមានន័យមិនប៉ុនគ្នានឹងពាក្យថា (Ministère) នោះទេ គឺបានន័យប៉ុនគ្នានឹងមួយចំរៀកនៃពាក្យថាកំងថា (Ministère) ប៉ុណ្ណោះ ។

កាលបើយោលទៅរកបែបសម័យបុរាណវិញ ពាក្យថាក្រសួងដែលគណៈកម្មការបានសម្រេចឲ្យប្រើប្រាស់នេះ យើញស្របគ្នាលំនាំពីបុរាណរាយជាក់ស្តែង ដ្បិតយើងបានសង្កេតយើញបុរាណតែងចារឬសរសេរថា: " ក្រសួងត្បូងការ " បានន័យថា ក្រសួងជាអង្គការរដ្ឋធំបំផុតនៅលើក្រុមរាជការនានា ជាលំដាប់តាមផ្នែកការរបស់រដ្ឋ គឺថាក្រសួងសំដៅយកទីស្តីការរាជការ ដែលជាធំលើក្រុមរាជការនានា ។

ផ្នែកកំណត់ធនធនប្រវត្តិសាស្ត្រ

ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

អំពីការតាំងមន្ត្រីសង្ឃ

-បានតាំងលោកចៅអធិការ ង៉ី-អឿយ ជន្មាយុ ៦៧ ឆ្នាំ វស្សា ៤៦ នៅវត្តពោធិវាល (ថ្មពួក) ឃុំថ្មពួក ជាទីព្រះគ្រូធម្មានុបាវ័ អនុគណស្រុកបន្ទាយឆ្មារ ខែត្រកំពត ។

-បានតាំងលោកចៅអធិការ ទៀ-ឈុម ជន្មាយុ ៦៦ ឆ្នាំ វស្សា ២៣ នៅវត្តវៀរវ័នទេវាន ឃុំស្វាយចេក ជាទីព្រះវិន័យធរ អនុគណស្រុកបន្ទាយឆ្មារ ខែត្រកំពត ។

-បានតាំងលោកគ្រូ ខេត-ប៊ុយ ជន្មាយុ ៤៥ ឆ្នាំ វស្សា ២២ នៅវត្តពោធិវាល (ថ្មពួក) ឃុំថ្មពួក ជាទីព្រះសមុហ៍អនុគណ ស្រុកបន្ទាយឆ្មារ ខែត្រកំពត ។

-បានតាំងកិ៏ ចន្ធ.ស៊ួន ជន្មាយុ ២៣ ឆ្នាំ វស្សា ៣ នៅវត្តពោធិវាល (ថ្មពួក) ឃុំថ្មពួក ជាអនុលេខាធិការអនុគណ ស្រុកបន្ទាយឆ្មារ ខែត្រកំពត ។

-ចាន់តាំងលោកចៅអធិការ ឆន្ទ-ហែម ជន្មាយុ ៧១ ឆ្នាំ វស្សា ៣៧ នៅវត្តទត្តមរត្យាកម ឃុំចោ៉ងយា ជាព្រះគ្រូបវត្តមេធា អនុគណ ស្រុកកំភ្នំស្រុក ខេត្តក្រចាត់ដំបង ។

-ចាន់តាំងលោកគ្រូ ថង-ឡាំង ជន្មាយុ ៤៦ ឆ្នាំ វស្សា ២៥ នៅវត្ត ទត្តមរត្យាកម ឃុំចោ៉ងយា ជាទីព្រះវិន័យធរអនុគណ ស្រុកកំភ្នំស្រុក ខេត្តក្រចាត់ដំបង ។

-ចាន់តាំងលោកចៅអធិការ ខេវ វ៉ាត្ថន ជន្មាយុ ៣៤ ឆ្នាំ វស្សា ១៣ នៅវត្តមុនីហេមវ័ន ឃុំពាខ្ញូ ជាទីព្រះសមុហ៍អនុគណ ស្រុកកំភ្នំស្រុក ខេត្តក្រចាត់ដំបង ។

-ចាន់តាំងលោកគ្រូ ម៉ុយ-ស៊ុន ជន្មាយុ ៤១ ឆ្នាំ វស្សា ១៨ នៅវត្ត ទត្តមរត្យាកម ឃុំចោ៉ងយា ជាទីអនុលេខាធិការអនុគណ ស្រុកកំភ្នំស្រុក ខេត្តក្រចាត់ដំបង ។

-ចាន់តាំងលោកចៅអធិការ សិង្ហ ខាទ-សួង ជន្មាយុ ៤៨ ឆ្នាំ វស្សា ២៧ នៅវត្តឯកវង្ស៍ ឃុំព្រៃកនរ៉ង្គ ជាទីព្រះគ្រូសីរីធម្មគុណ ជាសហ-ការីព្រះវិន័ត្ថ មេគណខេត្តក្រចាត់ដំបង ។

-ចាន់តាំងលោកគ្រូ ចក់-គង់ ជន្មាយុ ៥៧ ឆ្នាំ វស្សា ៣៥ នៅវត្ត

ចមសុគ្គវាស ឃុំកំពង់ស្វាយ ជាព្រះគ្រូចរិយាសោភ័ណ ជាសហការី អនុគណ ស្រុកស៊ីរីសោភ័ណ ខែត្រកំពត់ដំបង ។

-បានតាំងលោកគ្រូ កួន លិន ជន្មាយុ ៤៤ ឆ្នាំ វស្សា ២៤ នៅវត្តចមសុគ្គវាស ឃុំកំពង់ស្វាយ ជាព្រះសមុហ៍អនុគណ ស្រុកស៊ីរីសោភ័ណ ខែត្រកំពត់ដំបង ។

-បានតាំងកិត្តិ គង់-ប្រម ជន្មាយុ ២៦ឆ្នាំ វស្សា ២ នៅវត្តចមសុគ្គវាស ឃុំកំពង់ស្វាយ ជាអនុលេខាធិការអនុគណ ស្រុកស៊ីរីសោភ័ណ ខែត្រកំពត់ដំបង ។

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិឆ្លួន្ត គុ. ដែលស្រេកឃ្លានក្រៃពេក ។-ឆ្លួន្ត ស្ត្រី. សេចក្តីប្រាថ្នាក្រៃលែង ។

អតិឆ្លួ ជាគុ ធ្វង គេចខ្លួន, ងល់ ។

អតិជេជិលិ គុ. ដែលមានតេជៈក្រៃលែង, ដែលភ្លឺក្រៃលែង ។ -តេជស្វិន៑ គុ. ដែលមានតេជៈក្រៃលែង ។

អតិឆ្ងាវ៑ ជាគុ. ប្រញាប់ក្រៃពេក ។

អតិបិ ប៉ុំ. ភ្ញៀវ ។ អតិថិន៑ ប៉ុំ. ភ្ញៀវ ។ តាមព្រះរាជា ឯ- ឆ្ងួ ន ប៉ុំ. ភាវៈនៃជនជាភ្ញៀវ ។ -ក្រិយា ស្ត្រី. កិរិយាទទួលទូរភ្ញៀវ ។- ទេវ គុ ដែលមានភ្ញៀវទុកជាទេវតា ។-ធម៌ ប៉ុំ. អតិថិធម៌,ធម៌របស់ភ្ញៀវ, ការទទួលភ្ញៀវដោយល្អ ។ -ធម៌ិន៑ គុ. ដែលមានការទទួលភ្ញៀវជាប្រក្រតី, ដែលទទួលភ្ញៀវដោយប្រពៃ ។ -ឆូជន ន ប៉ុំ កិរិយាឆូជនជាងភ្ញៀវ ។ - ឆូជា ស្ត្រី. កិរិយាឆូជនជាងភ្ញៀវ ។ - ស្រ៊ែត គុ ដែលមានការទទួលភ្ញៀវជាប្រក្រត ឬជាវត្ត' - ស្រ៊ែតិន៑ គុ. ដែលមានការទទួលភ្ញៀវជាប្រក្រត ឬជាវត្ត ។ - សត្ការ ប៉ុំ. គ្រឿងសក្ការៈដល់ភ្ញៀវ ។

អតិទុបិ ប៉ុំ. កិរិយាប្រវាត់ដំក្រៃលែង ។ ឈ្មោះនាគ ។

(នៅមានត)

ភក្តីសទ្ធា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣២ លេខ ៨ ខែសីហា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ



ពុទ្ធសាសនា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ចរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង	ទំព័រ
ផ្នែកសាសនា	
- ពុទ្ធដីវប្បវត្តិ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	៨៤១
- សេចក្តីបរិសុទ្ធនៅឯណា ? របស់ព្រះពុទ្ធវចន៍ កឹម-ភ្ជួរ	៨៥១
- ព្រះអភិធម្មបិដក (គម្ពីរព្រះពុទ្ធវចន៍) (តមក) លោក ប៊ូ-ប៊ូ រៀបរៀង	៨៦១
- មធុរសារាហិណី (តមក) សម្តេចព្រះធម្មលិខិត ល្វី - ឯម ប្រែរៀបរៀង	១៧០
- មហោសធជាតក (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវចន៍ កឹម-ភ្ជួរ ពិនិត្យ	៨៨១
ផ្នែកអក្សរសាស្ត្រ	
- រឿងមរណមាន (តមក) លោក ប៊ី - សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត	៨៩៥
- រឿងព្រេងភាក់ទងនឹងទំនៀមធ្វើពិធីសម្រាប់មនុស្សដើម្បីផ្តាច់បេតុះ លោក ជង-ឯង រៀបរៀង ៣មឯកសារបស់ក្រុមដំបុំទំនៀមទម្លាប់	៩០១
- រឿងព្រេងនឹងរឿងបុរាណដ៏ប៉ុនប្លុងនៅឥឡូមសម័យ(តមក) លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង	៩២៩
- រឿងសាមកុក (តមក) ឧកញ៉ា ខ្ជ - ពន ប្រែ	៩៣៧
- ពាក្យវិឃ្ឃ ចម្រើ លោក ឆាង-ហ្ស៊ី រៀបរៀង លោក សម-ភ័ង ពិនិត្យ	៩៤៣
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
- ការធ្វើសន្ធិសីទ លោក អៀង-គុណ-សាគី រៀបរៀង	៩៥២
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	៩៥៨

មួយឆ្នាំ មាន ១២ លេខ តម្លៃ ៣០ រៀល

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

sommaire

Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT. . . 841
— La pureté par le Vén. KEM-TO 851
— Prah Abhidhammapitaka (Prah Kathavathu) (suite) par M. BOU-PO 861
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN 870
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 881

Partie littéraire :

— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 895
— Tradition khmère selon laquelle on simule la décapitation d'un homme pour le délivrer d'une mort fatale par M. THANG VONG. . 921
— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC 929
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 937
— Activités de la Commission Culturelle par M NEANG-HOU revues par M. SAM THANG. . . . 943

Notes et Chroniques :

— L'Art de faire la conférence par M. IENG-KOUN-SAKY . 952
— Dictionnaire Sanscrit-khmer (suite) par le Vén. PANG-KHAT 958

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ពុទ្ធដីវប្បវត្តិ

(តមក)

ព្រះមហា ជ៉ាន-ខាត់ រៀបរៀង

អរិន្ទមរេធិទាន រាជាភិៈសេកកប៉ាទី ៤

១– ការបែរក្បួ ព្រះពោធិសត្វ ២- វិប្បមង្គល ៣- ពោធិសត្វប្រកបដោយកាមសុខគ្រប់យ៉ាង ៤- ពោធិសត្វទ្រង់សំដែងសិល្បៈ ៥- ទ្រង់អភិសេកតំណែងព្រះនាងយសោធរា ។

១– ការបែរក្បួព្រះពោធិសត្វ

លុះព្រាហ្មណ៍ទាំង ៨ នាក់ចាន់ថ្វាយទំនាយរួចស្រេចហើយ ព្រះបាទសុទ្ធោទនៈត្រាស់សួរថា ព្រះកជបុត្រយេសយើងដែលទំនឹងចេញទៅសាងព្រះផ្នួសនោះ តើដោយហេតុដូចម្តេច ? ។ ពួកព្រាហ្មណ៍នោះក្រាបទូលថា ព្រោះព្រះកជបុត្រស្តេចឧត្តមើញទេវទូតទាំង ៤ បែបគឺ មនុស្សឆក ១ មនុស្សព្យាធិ ១ មនុស្សស្លាប់ ១ បព្វជិត ១ ។ ស្តេចទ្រង់ព្រះសណ្តាប់ហើយ ទ្រង់មានសេចក្តីទុក្ខព្រួយខ្លាំង ទើបត្រាស់បង្គាប់ឲ្យពួកជបុរសថែរក្សាព្រះកជបុត្រដោយម៉ឺងម៉ាត់ ប្រយ័ត្នមិនឲ្យើញ ទេវទូតទាំង ៤ នោះឡើយ ហើយទំនុកបំរុងព្រះកជបុត្រក្នុងកាមសុខគ្រប់ប្រការ ព្រោះទ្រង់សព្វព្រះទ័យ

១- ព្រះគន្ថរចនាចារ្យសំដែងសរសើរសេចក្តីអស្ចារ្យនៃព្រះពោធិសត្វ ដាអនេកប្បការ ពុកក្នុងគម្ពីរផ្សេង ។ ទាំងគម្ពីរបើរវាទនឹងគម្ពីរមហាយាន, ក្នុងគម្ពីរលលិតវិស្តារះលង្កមហាយាន មានសេចក្តីអស្ចារ្យច្បែកខ្លះ ។ ដោយសង្កេចនិយាយ តឹ

ក) ព្រះរាជកុមារស្ថិតនៅក្នុង-ឋមវ័យនៅឡើយ ព្រះវរបិតាស្តេចប្រទានរូបតួច ។ដាគ្រឿងក្រសាលគ្រប់យ៉ាង សុទ្ធតែជាវិការនៃមាសនឹងពេជ្រ មានរូបម្រឹគ, រូបដំរី, រូបសេះ, រូបគោ, ឬរូបបក្សី, រូបរទេះតួចដាដើម, ថ្ងៃមួយ ព្រះនាងបជាបតីគោតមីយកកស្ងាលថ្វាយព្រះពោធិ-សត្វឲ្យប្រដាប់ព្រះស្មរង្គនឹងព្រះហស្ត, មាសពេជ្រនោះអាប់រស្មីជាក់រស្មីព្រះពោធិសត្វ, តាង ទេពធីតាម្នាក់អាស្រ័យនៅក្នុងវិមានោះបង្ហាប់ឲ្យដោះចេញ ហើយតំយាយថា បើនែនឹងទាំង អស់ដាមាសដាពេជ្រនោះទើបអាចនឹងមានតម្លៃប្រសើរជាងភាន, ម្យ៉ាងទៀតព្រះសិទ្ធត្ថកុមារនេះ សូម្បីពន្លឺថ្លាយ, ព្រះចន្ទ, ព្រះអាទិត្យក៏មិនអាចកន្ទងរស្មីព្រះពោធិសត្វបានឡើយ តំងតំយាយ ថ្វីត្រឹមរស្មីមាសពេជ្រប៉ុណ្ណោះនេះ ។

ខ) ព្រះរាជបិតាស្តេចនាំព្រះរាជកុមារទៅនមស្ការទេវរូបដៅមគ្គឹរទេវរូប លុះព្រះរាជកុមារ ស្តេចទៅដិតសំទ្ធាទេវរូប ទេវរូបរង្វេង ។ ដ្ឋិចរូបព្រះឥស្សរ, រូបស្កន្ទកុមារ, រូបព្រះវិស្ណុ, រូបកុវេរៈ រូបព្រះឥន្ទ្រ, រូបព្រះព្រហ្មដាដើមឥឡូវលំ ខ្លះទៀតក្រោកឡើងក្តួលឥតថ្វាយបង្គំទៀតព្រះជាទ រាជខរសហើយតោលសរសើរថា ភ្នំព្រះសុមេរុ មិនគួរនមស្ការគ្រាប់ស្រូវទេ, ឧទ្ធមហាសមុទ្រមិន គួរនមស្ការទឹកដុំកទេ ព្រះអាទិត្យមិនគួរនមស្ការអ័ព្ទលអំពែកទេ . . . ។

គ) កាលព្រះពោធិសត្វមានវ័យធំបន្តិចឡើង ព្រះវរាជបិតាស្តេចឲ្យទៅរៀនអក្សរនៅក្នុង សំណាក់ព្រាហ្មណ៍វិស្វមិត្រ, ព្រះពោធិសត្វទ្រាស់សួរថា «បពិត្រវិស្វមិត្រ! លោកបង្រៀនអក្សរ សាស្ត្រខ្លីចម្ងែច ? ព្រាហ្មណ៍វិស្វមិត្រក៏រាប់អក្សរ ៦៤ ត្វថ្វាយ តែមិត្តតែព្រាហ្មណ៍រាប់ចប់ ព្រះ ពោធិសត្វក៏រៀនចប់ ធ្វើវិទ្វាសដាងក្នុងទៅទៀត, ព្រះពោធិសត្វទ្រាស់សួរទៅទៀតថា «ពេលក ត្រូវបង្រៀនអក្សរសាស្ត្រអីតទៅទៀត ? » ព្រាហ្មណ៍វិស្វមិត្រទាល់ចំណេះ ទៅស្ងៀមរកថ្វើយ មិនកើត ចែះទៅដាសូមរៀនពីព្រះពោធិសត្វវិញ ។

២. រឿងប្បមង្គល

តំណរឿងប្បមង្គល (ច្រត់ព្រះខន្ធ៌ីល) ជានក្តីត្តិឋកសម្រាប់ព្រះនគរ គេបានតាក់តែងព្រះនគរល្អាងរឿងហាក់ដូចជានគរនៃទេវតា ព្រះបាទសុត្ថេខន:មហារាជ ស្តេចត្រមង់យចតុរង្គសេនាពលរាំរ៉ា ឃាត្រាទៅតាន់ស្រែជាទីច្រត់ព្រះខន្ធ៌ីល ទ្រង់ព្រះពលាមុញ្ញាតឲ្យត្រុះពលកុមារស្តេចទៅតាមផង ហើយទ្រង់ចាត់ចែងពលដ្ឋានក្រោមដើមជម្ពូព្រឹក្សថ្វាយប្រថាប់ដល់តេលច្រត់ព្រះខន្ធ៌ីល ពួកស្រីស្នំដែលជាបរិចារ បបួលគ្នាចេញទៅមើលតំណរច្រត់ព្រះខន្ធ៌ីលអស់ ព្រះភោជិសត្វស្តេចទៅតែមួយព្រះអង្គ ឥតមើលមិនឃើញព្រះពលបរិវារទៅដឹតទាន់ កំស្តេចតាំងផ្តត់ព្រះភ្នែកទៅនព្រះបាទចំរើនអានាបានសត្រឹតកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចបឋមជ្ឈាន ។ គ្រានោះ សេចក្តីអស្ចារ្យថ្លែកចំឡែកកើតឡើង តំបណ្តាដើមឈើតាំងអស់ សុទ្ធតែរស្រែមោលចោលទៅតាមវិថីនៃមណ្ឌលព្រះអាទិត្យ ថ្លែកតែស្រមោលដើមជម្ពូព្រឹក្សមួយប៉ុណ្ណោះ ដែលព្រះភោជិសត្វស្តេចប្រថាប់នៅ មិនរស្រែមោលចោលទៅតាមដូចឈើតាំងពួនទេ ស្រមោលនោះតាំងនៅឥដ្ឋដែល ដើម្បីទំនឹកការពារព្រះភោជិសត្វហាក់ដូចជាមានវិញ្ញាណ, ឯពួកស្រីស្នំពលបរិវារត្រឡប់មកពីមើលតំណរច្រត់ព្រះខន្ធ៌ីលវិញ ឃើញសេចក្តីអស្ចារ្យថ្លែកដូច្នោះ កំយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះបាទសុត្ថេខន: ស្តេចទ្រង់ព្រះសណ្តាប់ហើយ ស្តេចចេញមកទស្សនា

ខតរយើញប្រាកដដូច្នោះ ទើបលើកព្រះហស្តប្រណម្យព្រះពោធិសត្វជា
ព្រះកត្តិយស ។ ការលើកព្រះហស្តប្រណម្យនេះ ជាលើកទី ២ ។

៣ ពោធិសត្វប្រកបដោយកាមសុខគ្រប់យ៉ាង

ព្រះសិទ្ធត្ថកុមារទ្រង់មានវ័យចំរើនឡើងដោយលំដាប់ មានព្រះជន្មាយុ
ចាន់ ៧ឆ្នាំ ព្រះរាជបិតាស្តេចត្រាស់ឲ្យដឹកស្រះ ៣ ជាំឈូករៀងៗខ្លួន ឲ្យ
តាក់តែងគ្រឿងមណ្ឌនយ៉ាងប្រណីតគ្រប់ប្រការ សុទ្ធតែយកមកពីដែន
កាសីដែលគេសន្មតថាប្រសើរក្នុងកាលនោះមកថ្វាយ ព្រមទាំងឲ្យសាង
ប្រាសាទ ៣ គឺ រមយប្រាសាទ ១ សុរមយប្រាសាទ ១ សុភប្រាសាទ ១
សម្រាប់ដូវទាំង ៣ ថ្វាយព្រះរាជទ្រព្យសេវិត ដូចការសំតែងដែលទ្រង់ត្រាស់
ចំពោះកិត្តិទាំងឡាយថា (១)

"ម្នាលភិក្ខុទាំងឡាយ! តថាគតជាខត្តិយសុខុមាលបុគ្គល
ជាខត្តិយសុខុមាលបុគ្គលដ៏ក្រៃលែង ជាខត្តិយសុខុមាលបុគ្គល
យ៉ាងប្រសើរជាទីបំផុត, គេដឹកស្រះ ៣ ក្នុងភាំងនៃបិតាតថាគត
ស្រះមួយដាំឧប្បល (លំពង) ស្រះមួយដាំបទុម (ឈូកក្រហម)
ស្រះមួយទៀតដាំបុណ្ឌរីក (ឈូកស) ដើម្បីប្រយោជន៍ដល់
តថាគត, មិនមែនត្រឹមតែក្លិនបន្ទន់ដៃលតថាគតសម្រាប់ប្រើ

១-បឋមបណ្ណាសក ទេវទូតវគ្គ, ឥក. អ. សៀវ. ទំព័រ ១០៧ ។

ដែលយកមកពីដែនកាសីប៉ុណ្ណោះទេ សូម្បីសំពត់សម្រាប់ជូតក្បាល, អាវ, សំពត់ស្លៀក, សំពត់ដណ្តប់ ក៏សុទ្ធតែយកមកពីដែនកាសីទាំងអស់ គេបាំងស្មៅតបត្រឲ្យតថាគត ដោយបំណងនឹងការពារខ្យល់ត្រជាក់, ក្តៅ, លំអងធូលី, ស្មៅឬទឹកសន្សើម កុំឲ្យប៉ះពាល់កាយតថាគត មានប្រាសាទ ៣ ខ្នង សម្រាប់តថាគត ប្រាសាទ ១ សម្រាប់ហែមន្តរដ្ឋវៃ ប្រាសាទ ១ សម្រាប់គិម្ហរដ្ឋវៃ ប្រាសាទ ១ ទៀតសម្រាប់វិស្សន្តរដ្ឋវៃ តថាគតនៅលើប្រាសាទ សម្រាប់វិស្សន្តរដ្ឋវៃ អស់ ៤ ខែ មិនបុះពីប្រាសាទឡើយ ឲ្យគេបំរើដោយភ្លក្សត្រឡើ សុទ្ធតែស្រីតែមានបុរសសោយឡើយទេ ។

ម្នាលភិក្ខុទាំងឡាយ ! នៅក្នុងវាំងរតោតថាគត គេឲ្យសុទ្ធតែបាយនៃអង្ករស្រូវសាលី លាយដោយសាច់ ដល់ទាសកម្មករ (ពោរពោសតែខ្លះៗតែ) ម៉ិនមែនដូចទីដទៃទេ ដែលគេឲ្យតែបាយបុងអង្ករឆីងទឹកជ្រក់ដល់ទាសកម្មករ " ។

មួយទៀត ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះមាគណ្ឌិយព្រាហ្មណ៍ថា (១)

---

១ មាគណ្ឌិយសូត្រ, បរិភោជនវគ្គ ម. ម. សៀវ. ២៤, ទំព័រ ៦៨ ។

"ម្នាលមាគណ្ឌិយ! កាលពីដើម តថាគតនៅជាគ្រហស្ថ ក៏ផ្គាប់ឆ្នែតឆ្នន់ ប្ដូរបិតុឱ្យគេបម្រើដោយកាមគុណទាំង ៥ គឺ

១-រូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

២-សំឡេងដែលគប្បីដឹងដោយត្រចៀក ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៣-ក្លិនដែលគប្បីដឹងដោយច្រមុះ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៤-រសដែលគប្បីដឹងដោយអណ្ដាត ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៥-ដោដ្ឋ ដៃលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ. ។

ម្នាលមាគណ្ឌិយ! តថាគតនោះ មានប្រាសាទ ៣ ខ្នង ប្រាសាទមួយសម្រាប់ដូវភ្លៀង ប្រាសាទមួយសម្រាប់រដូវងា ប្រាសាទមួយសម្រាប់រដូវក្តៅ ។ តថាគតឲ្យគេបម្រើដោយតន្ត្រីដៃលឥតបុរស លើប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀងអស់ ៤ ខែ មិនដៃលចុះមកខាងក្រោមសោះ ។ លុះក្រោយមក តថាគតដឹងច្បាស់ នូវហេតុដៃលនាំកើតទ្បើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌សម្រាប់រលាស់ចោលផង ដៃលសុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្តីពិតហើយ ក៏ឃើនូវសេចក្តីប្រាថ្នាក្នុងកាម បន្ទោរបង់នូវសេចក្តីក្តៅក្រហាយក្នុងកាម ប្រាសចាកសេចក្តីស្រេកឃ្លានមានចិត្តស្ងប់រម្ងាប់នៅក្នុងសន្តានសម្រាន្តនៅ ។ តថាគត

ឃើញសត្វឯទៀត ដែលមិនទាន់ប្រាសចាកតម្រេក ក្នុងកាម ទាំងឡាយ ដែលតម្រេកក្នុងកាមកំពុងទំពាស៊ី ជាអ្នកក្តៅ ក្រហាយព្រោះកាម កំពុងសេពនូវកាមទាំងឡាយ តថាគតមិន ប្រាថ្នានូវឦកជនទាំងនោះ មិនរីករាយក្នុងការសេពកាមនោះ សេចក្តីនោះ ព្រោះហេតុអ្វី ?

ម្នាលមាគណ្ឌិយ! ព្រោះថា កាលបុគ្គលត្រេកអរដោយសេចក្តី ត្រេកអរ រៀរលែងចាកកាមទាំងឡាយ រៀរលែងចាកអកុសល ធម៌ទាំងឡាយក៏នៅជាអ្នកចៀកចរយ ព្រោះហេតុដូច្នោះ តថាគត ទើបមិនប្រាថ្នា មិនរីករាយក្នុងការសេពកាមនោះទេ" ។

៤-ពោធិសត្វសំដែងសិល្បធ្នូ

កាលព្រះពោធិសត្វមានព្រះជន្មាយុ ១៦ វស្សា គួរមានអគ្គមហេសី ព្រះពជបិតាត្រាស់បង្គាប់ពួកព្រះញាតិសក្យពជត្រកូល ឲ្យនាំព្រះពជធីតា មកថ្វាយពោធិសត្វ ពួកសក្យពជត្រកូល បដិសេធមិនព្រមថ្វាយ ហើយ ពោលទោសថា ព្រះពជកុមារស្តេចប្រកបដោយរូបសម្បត្តិល្អ ស្ទាត់ជំនាញ ក្នុងការក៏ឡា តែព្រះអង្គមិនឈ្នះសង្រ្គាមក្នុងជម្ពូទ្វីប ស្រួលឲ្យសមតាមទត្តិយ

ត្រកូលសោះ ព្រះវរពោធិសត្វទ្រង់ព្រះសណ្តាប់ពាក្យនេះហើយ ទើបមានព្រះបន្ទូលចំពោះព្រះពោធិសត្វ ព្រះពោធិសត្វក្រាបទូលតបថា "បពិត្រព្រះអង្គ! តអំពីថ្ងៃនេះ ៧ ថ្ងៃ សូមទ្រង់ព្រះមេត្តាប្រោសឲ្យប៉ាវែនធូនកែវ ខ្ញុំព្រះអង្គនឹងសំដែងសិល្បសាស្ត្រ ចំពោះព្រះភ័ក្ត្រ នៃព្រះញាតិទាំងឡាយ" ។

លុះដល់ថ្ងៃទី ៧ ព្រះពោធិសត្វស្តេចចេញសំដែងវិជ្ជាចេស្តាឲ្យឃើញប្រចក្សត្រង់គ្នា ស្តេចឲ្យប្រជុំញាន់ធ្នូ ៤ ទាក់ ដែលធ្លាប់ស្ទាត់ជំនាញតឹអក្ខណាវេធី ១ វាលវេធី ១ សរវេធី ១ ទឹងសទ្ទវេធី ១ ហើយស្តេចសំដែងសិល្បធ្នូ ១៦ ប្រការ(១) ដែលតតមានញាន់ធ្នូណាមួយប្រឡងចេស្តាទឹងព្រះអង្គបាននៅកណ្តាលទីប្រជុំមហាជនក្នុងក្រុងកបិលព័ស្តុ ចំពោះមុខព្រះញាតិសក្យពង្សត្រកូលទាំងឡាយ ។

៥-ទ្រង់អភិសេកនឹងនាងបរសោធរា

លុះដល់ពេលនោះ ពួកសក្យពង្សត្រកូលឃើញសេចក្តីអស្ចារ្យដូច្នោះហើយ អស់សេចក្តីសង្ស័យ ទើបព្រមព្រៀងគ្នានាំយកទង្គិយកញ្ញាមកថ្វាយពោធិ-

---

១-ក្នុងចម្រុមសម្ភោធកថា ម៉ាងឃើញមានរាយឈ្មោះវិជ្ជាធ្នូទេ, គ្រាន់តែមានសេចក្តីថា ពោធិសត្វបានញ៉ាំងភ្នែកឲ្យដែលបិតនៅទីធ្វើយក្នុងទីចំនួន ១ យោជនបាន ។ តម្លើរខ្លះថា វិជ្ជាធ្នូមាន ១២ ប្រការ ។

សត្វត្រូប ។ ព្រះអង្គ(១) ។ ព្រះបាទសុទ្ធោទនៈ ស្តេចទ្រង់អភិសេក ព្រះរាជបុត្រនឹងព្រះនាងមាយាទេវី ជាព្រះរាជបុត្រីព្រះបាទសុប្បពុទ្ធ នឹងនាងអមិតា ដែលជាកនិដ្ឋភគិនីព្រះអង្គឲ្យជាព្រះអគ្គមហេសី, ព្រះពោធិសត្វស្តេចនៅក្នុងគ្រាសាទទាំងបី ៣ នោះ តាមរដូវទាំង ៣ មានស្ត្រីរាំប្រឹងរាំប្រគំដេញដំកូរឫតន្ត្រីថ្វាយទាំងយប់ទាំងថ្ងៃ ឥតមានបុរសម្នាក់នៅលាយឡំជាមួយឡើយ ហាក់ដូចជាទេវបុត្រដែលស្ថិតនៅស្ថានសួគ៌ទេវលោក រហូតដល់ព្រះជន្មាយុបាន ២៩ ព្រះវស្សា ។

១- សេចក្តីខេះ សូម្បីតម្លើរយើងបើរវិទក៏មានសេចក្តីប្លែកគ្នា, ក្នុងបរមសម្ពោធិកថាថា កាលព្រះបាទសុទ្ធោទនៈ ត្រាស់ឲ្យយកទន្លីយកញ្ញាមកថ្វាយ ឯពួកព្រះញាតិមិនទាន់ព្រមថ្វាយដោយអាងហេតុថា ព្រះពោធិសត្វមិនបានវិន្ធាសម្រាប់ត្រួតត្រាលើប្រទេស, តៅក្នុងអរិយវង្សាន ឯកនិបាតវណ្ណនា បរមភាគថា ព្រះពោធិសត្វបានអភិសេកនឹងនាងយសោធរាបួចហើយ បានពួកព្រះញាតិលើកទោសព្រះពោធិសត្វថាមិនបានវិន្ធាអ្វី ។ ក្នុងគម្ពីរលលិតវិស្តារខាងមហាយានធ្វើយត្រូវនឹងខាងបរមសម្ពោធិកថាដែរ ហើយមានន័យលំអិតពីការប្រឡងប្លែកៗ តៅទៀត ក្នុងគម្ពីរបរមសម្ពោធិកថា ត្រាន់តែប្រាប់ថា ១២ ប្រការ, ក្នុងគម្ពីរលលិតវិស្តារនេះ មានសេចក្តីថា ក្នុងទីប្រជុំនោះ មានបុរសម្នាក់បានអង្ករសាស្តាចចម៉ាងជ្រើរជ្រើរចូលមកប្រឡង, អាចារ្យវិស្វមិត្រចេញមកប្រាប់បុរសនោះថា ឥតអំពើទេ ព្រះរាជកុមារនេះជាអ្នកប្រាជ្ញជាងទុំ តៅទៀត និយាយថ្វី ក្តីមអ្នកប៉ុណ្ណោះ. សក្យរាជឈ្មោះអង្គុនៈ ចូលមកប្រឡងគណិតសាស្ត្រ (រឿងលេខ) នឹងពោធិសត្វ យកចំណោទដែលពិបាកទីចំផុតយ៉ាងច្រើនមកសួរពោធិសត្វ ។

(តៅមានត)

សេចក្តីបរិសុទ្ធិនៅឯណា?

របស់ព្រះពុទ្ធវង្ស កាម-ភូរ

សេចក្តីបរិសុទ្ធិជាគួរនឹងសេចក្តីមិនបរិសុទ្ធិ ។ សេចក្តីបរិសុទ្ធិគឺអ្វី? សេចក្តីបរិសុទ្ធិគឺស្អាតកាយ, ស្អាតវាចា, ស្អាតចិត្ត, មិនសៅហ្មងដោយអំពើអាក្រក់ណាមួយ ដែលគួរឲ្យអ្នកផងតិះដៀលបាន ។ សេចក្តីមិនបរិសុទ្ធគឺអ្វី? សេចក្តីមិនបរិសុទ្ធិ មានដំណើរផ្ទុយគ្នានឹងសេចក្តីបរិសុទ្ធិដូចបានឧទ្ទេសមកហើយខាងមុខ ។

មនុស្សប្រកបណាក៏ដោយ ពោះជាខ្ពស់ក្តី ជាទាប់កណ្តាលក្តី ជាទាបក្តី ជាអ្នកចេះលែលកវៀបចំពុកជាក់កាយឲ្យសមរម្យទៅតាមឋានៈរបស់ខ្លួន មិនប្រព្រឹត្តប្រឡែសប៉ើស ជាអនុលោមតាមច្បាប់សម្រាប់ផ្លូវលោក ឧទ្ទេសច្បាប់សម្រាប់ផ្លូវធម៌ គាំងកងខ្ចីចំពោះមុខ គាំងកងខ្ចីកំបាំងមុខ មិនប្រើកម្លាំងកាយរំលោភឲ្យប្រព្រឹត្តទៅហួសហេតុហួសខ្នាត មានការប្រហារជីវិតសត្វនឹងការលាក់លួចឆក់ដណ្តើមរឺ ជាន់ យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអយុត្តិធម៌ជាដើម, ជាអ្នកមានឫកពាសុភាពរាបសាល្អ គាំងមានចរិយាធម៌នឹងអប្បាយខធម៌ចំពោះអ្នកដទៃមិនរើសមុខយ៉ាងនេះជាដើមហៅថា កាយបរិសុទ្ធិ បរិសុទ្ធស្អាតដោយកាយ ។

មនុស្សណាមួយ តែងមើលឃ្លាតឃ្លាំងនិយាយពីអ្នក ថាពាក្យនេះឯងមិនដែលបៀតបៀន ឲ្យកើតសេចក្តីរង្គើសដល់អ្នកដទៃ ច្រើនតែនិយាយពាក្យណាដែលទាំងឲ្យមានប្រយោជន៍ ជាវាចាសុភាពបសាស័ពោះមិនខ្វះគោះចោះចោក ប្រមាថមើលងាយអ្នកដទៃ, ជាសំដីគួរគេជ្រះថ្លា គួរគេចង់ស្តាប់ ។ ឯងផ្តុតព័ទ្ធចិត្តនៃគាំង ៤ យ៉ាង មិនទាំងឲ្យចំពាល់ខ្លួចសេចក្តីអ្នកដទៃ យ៉ាងនេះជាដើមហៅថា កាយសុចរិតសុទ្ធិ បរិសុទ្ធិស្អាតដោយកាយ ។

មនុស្សណាមួយ ចាន់សង្រ្គមប្រុងប្រយ័ត្នសំអាតចិត្តរបស់ខ្លួន ឲ្យបរិសុទ្ធ ឲ្យតាំងនៅក្នុងកុសលធម៌ ច្រាសចាកមនោទុច្ចរិតគាំង ៣ យ៉ាង មិនបណ្តាយឲ្យចិត្តក្រេវក្រាធលោភលន់ឈ្នានីសច្រណែនខ្ជិលគេ យ៉ាងនេះជាដើមហៅថា ចិត្តសុចរិតសុទ្ធិ បរិសុទ្ធិស្អាតដោយចិត្ត ។

អ្នកដែលចាន់តើតមកមានជីវិតរស់នៅក្នុងលោកនេះ មានសញ្ញាតជាមនុស្សទ័មួយៗគប្បីញុំាងកាយ វាចា ចិត្ត ឲ្យស្ងប់រៀបរយល្អទៅតាមច្បាប់លោកទំនៀមច្បាប់ធម៌ដែលមានគំរើតពុកមក ពុំគួរបើកអំណាចបណ្តោយឲ្យកាយ វាចា ចិត្ត ប្រព្រឹត្តភាយងាយតាំងនៅខាងក្រៅច្បាប់ឡើយ ព្រោះថាការដែលចាន់ទទួលសុខភាព, វឌ្ឍនភាពទំនើងដោតជ័យគ្រប់ជំពូករបស់មនុស្សសត្វទ័មួយៗ រមែងតើតអំពីកាយ វាចា ចិត្តដ៏បរិសុទ្ធល្អ,

ឯការដែលបានខ្ជួលខ្ពុតខ្ពោសគ្រែះថ្នាក់អាចមង្គលត្រប់ដំពូក កំរែងកើតមកអំពីកាយ វាចា ចិត្ត មិនបរិសុទ្ធល្អដែរ ព្រោះកាយ វាចា ចិត្ត ទាំង ៣ នេះ ពុកដូចជាគ្រាស្រម៉ាប់បើកទុកាសឲ្យសុខទីឯពុកហូរចូលមកប្តូចាជាប្រជាទជាទាមុខក្រសួង ជាអ្នកបង្កហេតុឲ្យកើតសុខ ទីឯពុកកំបាន ។ ព្រោះហេតុនោះ សេចក្តីបរិសុទ្ធិទីឯសេចក្តីមិនបរិសុទ្ធិទាំងពីរនេះ ដែលកើតឡើងហើយរមែងឲ្យផលដល់បុគ្គលអ្នកធ្វើចំពោះខ្លួនឯង លោកនិយាយតាមសាមញ្ញពោលថា អ្នកណាធ្វើកំណាបស់អ្នកនោះ ឥតមានអ្នកណាធ្វើឲ្យអ្នកណាបរិសុទ្ធិឬស្អាតហ្មងបានឡើយ ។ ប៉ែកខាងលទ្ធិព្រាហ្មណ៍មានសេចក្តីប្រកាន់ថា អំពើបាបណាមួយដែលបុគ្គលធ្វើហើយ គេអាចលាងជំរះបណ្តែតបង្ហូតបង្ហាត់ចោលបានដោយធ្វើពិធីមានងូតទឹកជាដើម តែពេលដែលកំពុងងូតទឹកជំរះមនុស្សកាយ ចាបោះឯងក៏ជ្រះស្អាតរលែតរលាត់ទៅតាមទៀរទឹកជាមួយនឹងមនុស្សកាយដែរ ។ មានលទ្ធិដទៃខ្លះទៀតប្រកាន់ថា អំពើបាបណាមួយ ទោះបីក្លំនក្តីស្រាលក្តី ដែលបុគ្គលធ្វើហើយ គេអាចទៅលន់តួអង្វែរសូមទាមាសចំពោះព្រះម្ចាស់សួគ៌ ដើម្បីឲ្យព្រះម្ចាស់សួគ៌នោះប្រោសប្រាណាត្រាប្រណីលើកទោសកំហុសរបស់ខ្លួនចោលចេញបាន ដូចគ្នាទីឯព្រះមហាក្សត្រម្ចាស់ផែនដីទ្រង់ប្រោសប្រាណាលើកទោសព្រះពជ្ឈាឃាដដល់អ្នក

ធ្វើខុស ឲ្យផុតចាកព្រះពុទ្ធសាសនាជាដែរ យ៉ាងនេះជាដើម ។

ចំណែកខាងព្រះពុទ្ធសាសនា មានសេចក្តីផ្ចាយគ្នាទីដ៏លម្អិតថា នោះថា អំពើបាបដែលបុគ្គលធ្វើដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង, មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធ ជាយខ្លួនឯង ។ សេចក្តីបរិសុទ្ធិទីនេះសេចក្តីសៅហ្មង រមែងកើតចំពោះខ្លួនអ្នកធ្វើតែម្យ៉ាងប៉ុណ្ណោះ មិនមែនកើតចំពោះហេតុដទៃឡើយ ។ បុគ្គលដែលសៅហ្មងព្រោះអកុសលកម្ម ដែលបរិសុទ្ធចាកសេចក្តីសៅហ្មង ព្រោះកុសលកម្មប្រកបដោយប្រាជ្ញាដែលយល់ត្រូវ ។ អ្នកណាពិចារណាឃើញច្បាស់ដោយប្រាជ្ញាថា ការប្រព្រឹត្តធ្វើអកុសលកម្មគឺអំពើជាអកុសលផ្សេងៗ មានសម្ងាប់សត្វ ទីឆ្លួចលាក់ឆក់ដណ្តើមកំហែងប្លន់ប្រវ័ញ្ចយកទ្រព្យសម្បត្តិរបស់គេដោយអយុត្តិធម៌ជាដើម អំពើទាំងនេះសុទ្ធតែជាកម្មមានទោសជាផ្លូវអបាយ មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ខ្លួនទីនឹងអ្នកដទៃហើយគឺលះបង់គឺមិនធ្វើអកុសលកម្មនោះតទៅទៀត អ្នកនោះឈ្មោះថាជាអ្នកបរិសុទ្ធស្អាត សូម្បីជាអ្នកមានសេចក្តីសៅហ្មងជិតជាមជាប់មកអំពីមុនខ្លះ ព្រោះអកុសលកម្មដែលខ្លួនធ្វើដោយសេចក្តីប្រហែសធ្វេសល្អង់ខ្វៅ កំតែងតាំត្រឡប់ទៅជាអ្នកបរិសុទ្ធស្អាតដោយកុសលកម្ម ដែលធ្វើក្នុងកាលជាខាងក្រោយដោយពិត សមដូចព្រះពុទ្ធភាសិតថា :

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា។

អ្នកណាធ្វេសប្រហែសក្នុងកាលពីមុន លុះកាលជាខាងក្រោយមក
កំដរតែមេរៀងមិនធ្វេសប្រហែសវិញ អ្នកនោះទើបឈ្មោះថា ធ្វើលោក
ឲ្យភ្លឺស្វាងរុងរឿង ដូចជាព្រះចន្ទដែលចេញផុតពីពពក ។

អធិប្បាយបញ្ជាក់តុទ្ធកាសិតនេះថា ជនណាមួយកាលពីពេលមុន
មក ជាអ្នកមានសេចក្តីធ្វេសប្រហែសរវើរវាយ ធ្វើអំពើអាក្រក់ណា
មួយ ដោយកាយ វាចា ចិត្ត ដែលអ្នកប្រាជ្ញលោកនៅគន់ថាជាអំពើ
លាមកក្រទុំក់សៅហ្មងមិនស្អាត លុះកាលជាខាងក្រោយមក គំរៃជា
ក្លាក់គំនិតដ៏ខ្ជួនជាខុស ហើយលះបង់សេចក្តីធ្វេសប្រហែសរវើរវាយដែល
ធ្លាប់តែប្រព្រឹត្តធ្វើអំពើអាក្រក់នោះៗចោលចេញ ហើយប្រព្រឹត្តធ្វើតែអំពើ
ល្អដោយកាយ វាចា ចិត្ត មានឲ្យទានក្សាសីលជាដើម ជននោះឯង
ឈ្មោះថាធ្វើខ្លួនឲ្យមានតន្ទីភ្លឺឲ្យឋិតស្ងួនស្អាត ទាំងកេរ្តិ៍ឈ្មោះរបស់ជននោះ
សោត កំក្រអួលផ្សាយទៅកាន់ទិសទីទាំងពួងដោយសេចក្តីរុងរឿងក្នុង
លោកនេះ ប្រៀបដូចជាព្រះចន្ទពេញវង់ដែលលឿនឃ្លាតចេញផុតពី
មន្ទិល មានពពកជាដើម ជ្រួតជ្រាបឯង ។ សេចក្តីដែលតណានាមក
ប៉ុណ្ណេះនេះ ដើម្បីបញ្ជាក់ឲ្យឃើញថា ក្រៅអំពីខ្លួនរបស់ខ្លួនឯង អ្នក

ណានឹងអាចធ្វើអ្នកណាឲ្យបរិសុទ្ធឬសៅហ្មងនោះពុំបានឡើយ ។

មានជនពួកខ្លះក្នុងលោកនេះមានសេចក្តីយល់ថា សេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិសម្រេចមកតែអំពីចិត្ត សូម្បីកុសលក្តី អកុសលក្តី ក៏សម្រេចមកអំពីចិត្តដែរ ឬដំណើរទៅកាន់សុគតិក្តី ទៅកាន់ទុគ្គតិក្តី ក៏សម្រេចមកតែអំពីចិត្តដែរ ហេតុនោះយើងមិនចាំបាច់ធ្វើទេ ដូចជាបុណ្យកុសលអ្វីផ្សេង ។ យើងកុំចាំបាច់ធ្វើ ឬកុំចាំបាច់ហាត់គិតពុកជាមុន ទាំងឲ្យនាគទ្រព្យឬទាំងឲ្យវេលាទាន វេលាទេ ចាំដល់ពេលណាដែលយើងត្រូវការសេចក្តីល្អគឺបុណ្យ ឬកើតក្នុងពេលជិតស្លាប់ សឹមយើងតាំងចិត្តឲ្យបរិសុទ្ធស្អាតល្អ ដើម្បីឈានចាប់យកសុគតិតែម្តង ។ អ្នកមានគំនិតយល់ដូច្នេះ ប្រហែលជាស្មានថាចិត្តនេះជាធម្មជាតដ៏ឃ្លាតឆ្ងាយស្រួលអាចប្រដៅហ្វឹកហាត់តត់តម្រង់ទៅយ៉ាងណា ។ កិច្ចនៃបវេបវត្តក្នុង ។ យ៉ាងនោះតាមបំណងខ្លួនទេដឹង ? ការយល់ដូច្នេះ មិនត្រូវទៃប មិនត្រូវទំនង មិនសមហេតុផលសោះឡើយ ។ បើតាមពិតនោះ ធម្មជាតិទាំង ៣ យ៉ាងគឺ កាយ វាចា ចិត្តនេះមានលក្ខណៈពិបាកបង្ហាត់ខ្លួនឲ្យប្រឿនប្រដៅឲ្យបានទៃបបវេដោយអាការផ្សេងគ្នាយ៉ាងនេះ ឯកាយដែលអាចធ្វើអ្វីទៅបានត្រប់យ៉ាង ដូចជាចេះសរសេរកម្សាន្តក្តី ចេះធ្វើគ្រឿងអលង្ការអំពីមាសទឹងប្រាក់សំពាប់តាក់តែងកាយនៃបុរសទឹងស្ត្រីឲ្យមានក្សាច់ក្សត្រកិរិយាល្អក្តី ចេះ

គួរបូកគំនូរដ៏វិចិត្រល្អក្តី ដូច្នេះដាដើម លុះណាតែបានរៀនបានហាត់ឲ្យ
ស្ទាត់ពុកជាមុន ទើបកាយនោះឯងអាចប្រើការឲ្យសម្រេចប្រយោជន៍ទៅ
បាន ។ ចំណែកខាងវាចាគឺសំដីសោតវៀតកំប្រហែលគ្នា ដូចជាចេះ
និយាយការអ្វីឲ្យតេស្តាប់ ឬក៏ចេះថ្លែងសុន្ទរកថាជាដើម ក្នុងទីប្រជុំជនមិន
មានការខាស់ឆ្គងទៅបាន លុះណាតែបានគិតហាត់អានឲ្យស្ទាត់ពុកជា
មុនសិនដែរ ទើបវាចានោះឯងជាសំដីពីពេះចាប់ចិត្តដល់អ្នកស្តាប់គួរតេ
យកតម្រាប់តាម ។ កាយនឹងវាចាពីរនេះជាធម្មជាតមើលឃើញច្បាស់
ដោយភ្នែក ស្តាប់ឮច្បាស់ដោយត្រចៀកម៉ិចគឺពិបាកបង្ហាត់ខ្លួនាន់ម៉ុះ
ទៅហើយ ចំណែកបើចិត្តជាអតិសុខុមជាតល្អិតក្រៃលែង គ្មានបុគ្គលិ
សណាខ្លាចគ្រាយអ្វីជាគ្រឿងក្រាកដល់សោះផង សមនឹងពិបាកខ្លួនាន
ឃើងណាទៅវៀត, ហេតុនោះការខ្លួនាន់ហាត់ចិត្តឲ្យបានបែបបទបរិសុទ្ធ
ស្អាតនោះ មិនមែនជាការងាយទេក្រជាទីបំផុត ព្រោះចិត្តនោះជាធម្មជាត
ល្អិតឆាប់ហួសវិស័យនឹងប្រដូច មានសន្ទុះលឿនហើសក្រៃលែងនឹងអ្វី
មកប្រៀបឲ្យស្មើពុំបាន ជាធម្មជាតឆាប់ប្រែប្រួល, ឆាប់ញាប់ញ័រ, ឆាប់
ឃ្លេងឃ្លាង, ឆាប់ធ្វេធ្វា ម្ល៉ងដូច្នេះម្ល៉ងដូច្នោះទីឯចាប់ពត់តម្រង់ឲ្យត្រង់ល្អ
តាមចំណង់របស់ខ្លួនគ្រាម ។ នោះ បានដោយក្រពេកណាស់, មិនមែន
ជាការងាយស្រួល ដូចជនខ្លះដែលមានសេចក្តីឃល់ធ្វេឯដូចបានពោល

មកហើយនោះទេ ។

ម្យ៉ាងទៀត មានជនពួកខ្លះយល់ថា សេចក្តីបរិសុទ្ធក្នុងជីវិតរបស់មនុស្សម្នាក់ៗដែលកើតឡើងក្នុងលោកនេះ គឺមកអំពីមានជាតិគោត្រត្រកូលពូជតង្ស៊ីដ៏ខ្ពង់ខ្ពស់ ឬមកអំពីមានទ្រព្យសម្បត្តិច្រើន ទើបឈ្មោះថាជាសេចក្តីបរិសុទ្ធិស្អាតរបស់មនុស្ស , ការយល់ដូច្នេះពុំជាគំនិតយល់ត្រូវទុស្ដុយគ្នាទេឯសេចក្តីពិត ដ្បិតាមពិតមែននោះ គឺសេចក្តីបរិសុទ្ធិស្អាតនៅត្រង់កាយ វាចា ចិត្ត ដែលមិនប្រព្រឹត្តធ្វើអកុសលកម្មណាមួយ ទើបចាត់ឲ្យឈ្មោះថាជាសេចក្តីបរិសុទ្ធិស្អាតរបស់មនុស្សក្នុងជីវិតនេះបានមិនមែនបរិសុទ្ធព្រោះតែមានជាតិគោត្រត្រកូលពូជតង្ស៊ីដ៏ខ្ពង់ខ្ពស់នោះទេ , មិនមែនបរិសុទ្ធព្រោះតែមានទ្រព្យសម្បត្តិច្រើននោះទេ សមដូចព្រះពុទ្ធភាសិតថា :

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ

ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន ច

សត្តូតំ ឯត្ថាយ រមែងបរិសុទ្ធស្អាតដោយគុណធម៌៥យ៉ាង[1]នេះគឺ: កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធដោយសារគោត្រត្រកូលឬដោយសារទ្រព្យសម្បត្តិទេ ។ គុណធម៌ទាំង៥យ៉ាង

១- ធម៌ ៥ យ៉ាងនេះ មានសេចក្តីអធិប្បាយក្នុងគម្ពីរបរមត្ថទីបនីសាដកាវិសុទ្ធិមគ្គព្រះសីលនិទ្ទេស ។

នេះ ជាសេចក្តីប្រតិបត្តិដ្ឋសទាត់ទាន់ផ្លូវ កាយ វាចា ចិត្ត របស់សត្វឲ្យ
បរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មិនមែនបរិសុទ្ធដោយហេតុ
ដទៃឡើយ ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជនគួរជ្រាបថា បើប្រថ្នា
សេចក្តីបរិសុទ្ធិឲ្យកើតឡើងចំពោះខ្លួន ត្រូវតែខ្លួនយើងប្រតិបត្តិធ្វើបំពេញ
កិច្ចការដោយខ្លួនយើង ឬសេចក្តីសៅហ្មងកើតឡើងដល់ខ្លួនហើយ ត្រូវ
តែខ្លួនយើងលាងជំរះសំអាតផ្លាស់ដោយខ្លួនយើង ទីឆ៏ទៅភិនភាក់ទេម្នាក
ដទៃឲ្យគេធ្វើជំនួសខ្លួនពុំបានឡើយ , សេចក្តីនេះប្រៀបដូចជនភិនោក
ជនម្នាក់បរិភោគអាហារស្កប់ស្កល់ហើយ ឃើញជនម្នាក់ទៀតមិនទាន់
បរិភោគអាហារសោះ តំពុងមានសេចក្តីស្រេកឃ្លាន ហើយចង់ចែក
ផ្លែតបេស់ខ្លួនឲ្យទៅអ្នកដែលកំពុងឃ្លានទោះបានផ្លែតដូចខ្លួនផង តើជន
ផ្លែតនោះ អាចបេះរំលែកផ្លែតចែកទៅជនឃ្លានទោះខ្លះផង បានឬទេ ? ។
មួយទៀតប្រៀបដូចជនម្នាក់កំពុងអន្ទះអន្ទែង ដោយសេចក្តីស្រេកឃ្លាន
បានឃើញជនម្នាក់ចូលមកជិត ហើយចង់ចែកឃ្លានបេស់ខ្លួនឲ្យទៅជន
ម្នាក់នោះ ឲ្យគេដួយឃ្លានដូចខ្លួនផង តើជនឃ្លានទោះទឹឆ៏អាចបេះរំលែក
ឃ្លានចែកឲ្យទៅជនឯទៀត ឲ្យគេដួយឃ្លានខ្លះផង បានដែរឬទេ ? ។ តាម
ពិតជនពាលពីរនាក់គឺជនផ្លែតទឹឆ៏ជនឃ្លាន ទឹឆ៏បេះរំលែកផ្លែតទឹឆ៏ឃ្លានឲ្យ
ដល់គ្នាទឹឆ៏គ្នាទៅវិញទៅមកពុំបានសោះឡើយ មានឧបមាយ៉ាងណា ,

ឯសេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិនេះ រមែងកើតឡើងអំពីខ្លួនឯងផ្ទាល់ខ្លួនឯង អ្នកណាមួយនឹងអាចបេះរំលែកសេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិ ឲ្យដល់គ្នានឹងគ្នាទៅវិញទៅមកពុំបាននោះឡើយ ក៏មានន័យដូច្នោះឯង ។

ផលល្អនឹងផលអាក្រក់ ដែលលេចចេញមកពីសេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិនៃកាយ ឬចិត្តនោះ អាចបង្ហាញឲ្យឃើញជាក់ស្តែងក្នុងបច្ចុប្បន្ននេះ ដែលត្រូវទទួលសុខទុក្ខផ្សេងៗគ្នានោះ មិនចាំបាច់ពាក្យស្ទាំងមកបង្អើលប្រាប់ក្នុងទីនេះទេ សូមតែពិចារណាពិនិត្យសង្កេតមើលដោយប្រាជ្ញាដ៏ប្រសើរនៅដុំវិញខ្លួនក៏គង់ឃើញបានដោយមិនលំបាក។

ហេតុនោះ ពុទ្ធសាសនិកជាអ្នកចង់បានសេចក្តីសុខនឹងសេចក្តីចំរើនឲ្យកើតមានដល់ខ្លួនគ្រប់វេលានេះ ត្រូវតែតាំងសតិគឺស្មារតីឲ្យយាមល្បាតប្រចាំនៅនឹងទ្វារកាយ ឬចិត្តជានិច្ច ដើម្បីខប់កាំងអកុសលផ្សេងៗមានអភិជ្ឈានឹងទោមនស្សជាដើម កុំឲ្យចូលមកបៀតបៀនបាន, បើពុំដូច្នោះទេ មុខជានឹងត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ណាមួយតាមគួរដល់ឃើញជាក់ក្នុងបច្ចុប្បន្ននឹងបរលោក ព្រោះតែសេចក្តីមិនបរិសុទ្ធិនៃកាយ ឬចិត្តនោះឯងជាហេតុ ។

ពាក្យនេះអំពីសេចក្តីបរិសុទ្ធិ ជាគូនឹងសេចក្តីមិនបរិសុទ្ធិចប់ដោយសង្ខេប។

អត្ថន័យនេះមានក្នុងគម្ពីរធម្មបទដូចគ្នា ខុទ្ទកនិកាយ ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះកថាវត្ថុ)

(តមក)

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

បរវាទី– គ្រហស្ថបានសម្រេចព្រះអរហត្តនោះតំមាន ។

សកវាទី– គ្រហស្ថដែលបានសម្រេចព្រះអរហត្តនោះ ប្រាកដជាមានមកមែនហើយ តើបុគ្គលណាដែលបានសម្រេចព្រះអរហត្តកន្លងកេះជាគ្រហស្ថមិនបានបព្វជ្ជា ?

បរវាទី - ដូចសន្តតិមហាមាត្យ ជាអាមាត្យធំរបស់ព្រះបាទឧសេនទិគោសល ។

សកវាទី - សន្តតិមហាមាត្យនោះ ជាមនុស្សសេតសុកមែនឬទេ ?

បរវាទី - មែនហើយ សន្តតិមហាមាត្យជាមនុស្សសេតសុក ។

សកវាទី - បើដូច្នោះ គ្រហស្ថដែលបានសម្រេចព្រះអរហត្តជាអ្នកសេតសុកមែនឬទេ ?

បរវាទី - ឯ មោរំ វត្តព្វេ អ្នកកុំគប្បីនិយាយយ៉ាងនេះ ព្រះអរហត្តមិនដែលសេតសុកទេ សន្តតិមហាមាត្យនោះសេតសុកមែន ប៉ុន្តែ

តាំងពីនៅមិនទាន់ចាន់ព្រះអរហន្ត លុះចាន់ព្រះអរហន្តហើយមិនចាន់សេត
សុភនេ ដែលសេតសភកន្លងថ្ងៃនោះ លុះចុងក្នុងថាស្ត្រីចាំក្រយដ៏តែហើយ
ក៏ស្វាន់សុភចាត់ស្រីងឹងអស់លើងៗ ដូចជាអម្បែនដែលបុគ្គលដុតដោយ
រងើកភ្លើង មានបុគ្គលយកទឹកមកស្រោច ទឹកនោះក៏មិនអាចនឹងតាំងនៅ
ចាន់ អ្នកគប្បីចូលចិត្តដូច្នេះចុះ ។

រឿងសន្តតិមហាមាត្យ

សូមនាំយកហារណ៍នៃសន្តតិមហាមាត្យមកសំដែងក្នុងទីនេះ ជា
សេចក្តីសង្ខេបថា សន្តតិមហាមាត្យនោះ ជាអាមាត្យចំរបស់ព្រះចុល
ចសេនទិកោសលនៅបង្ក្រាបបច្ចន្តជនបទដែលបះបោរឲ្យតចហើយលើក
ទ័ពត្រឡប់មកវិញ ។ គ្រានោះ ព្រះចុលចសេនទិកោសលឲ្យសោយភជ-
សម្បត្តិ ៧ ថ្ងៃ ព្រះភជាតន្ត្រីស្ទើម្នាក់ជាស្ត្រីចុងប្រុសចប់ខាងការច្រៀងនឹង
ភ្នំណាស់ ដើម្បីនឹងឲ្យចម្រើនតិមហាមាត្យ។ នោះក៏សោយភជសម្បត្តិ
សេតសុភស្រីងឹងជ្រប់គ្រប់ចាំង ៧ ថ្ងៃ សេតសុភស្រីងហើយឡើងដំរ
ចរនៅឯកំពង់ទឹកស្ទឹង កាលកំពុងនៅនោះ ចាន់ជួបនឹងសម្តេចព្រះសម្ម
សម្ពុទ្ធនៅកណ្តាលមាគ៌ាកំពុងយចង្កឹមសក្យការងក់ក្បាលហើយហួសទៅ ។

សិនតំ តទា សម្តេចព្រះបរមសាស្តាទ្រង់ធ្វើព្រះអាការញញឹម
ព្រះទន្តឲ្យប្រាកដ ។ ព្រះអានន្ទក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន!

ព្រះអង្គទ្រង់ញាញីមឲ្យច្រាជកនោះតើ អាស្រ័យហេតុបច្ច័យអ្វី ? ទើបទ្រង់ត្រាស់ថា បស្ស អានន្ទ នែអានន្ទ ! អ្នកចូរក្រឡេកមើលភៀសន្តតិ-មហាមាត្យ មានសរីរៈប្រដាប់តាក់តែងហើយមកកាន់សំណាក់តថាគត ខឹងបានសម្រេចព្រះអរហត្ត ហេតុតែបានស្តាប់ព្រះធម្មទេសនាមួយគាថា ត្រឹមប្លងបទប៉ុណ្ណោះក្នុងថ្ងៃនេះ ខឹងហោះទៅកន្លងអាកាសកំពស់ ៧ ជួរភ្នំតហើយខឹងនិព្វានក្នុងថ្ងៃនេះ ។

ឯនគរឆ្ងាយបានឮព្រះពុទ្ធដីកាដូច្នោះ អ្នកដែលជាមិច្ឆាទិដ្ឋិគតថា អ្នកកល់ភ្នែកចូរមើលកិរិយាបស់ព្រះសមណគោតមចុះ ព្រះអង្គត្រាស់ថា សន្តតិមហាមាត្យនេះស្រវឹងស្រាខ្លាំងជាត់ស្មារតី មានសរីរៈតន្ត្រីយភាក់តែងហើយ ខឹងមកស្តាប់ព្រះធម្មទេសនា ហើយខឹងបានសម្រេចព្រះអរហត្តដោយគេចយកវាស ពួកយើងខឹងចាំផ្លាញផ្ទាំងព្រះសមណគោតមដោយមុសាវាទក្នុងថ្ងៃនេះ ។

សម្មាទិដ្ឋិកា ចំណែកជនទាំងឡាយដែលជាសម្មាទិដ្ឋិគតថា ព្រះពុទ្ធគុណាភនេះជាគាអស្ចារ្យខ្លាំងណាស់ ពួកយើងខឹងបានឃើញព្រះពុទ្ធលីលាខឹងលីលានៃសន្តតិមហាមាត្យក្នុងថ្ងៃនេះ ។ សម្តេចព្រះជិនស្រីត្រាស់ដូច្នោះហើយ កំសត្តចតុក្កាចារ្យចេះស្រេចយាងត្រឡប់មកព្រះជេតពនមហាវិហារវិញ ។

ឯវិសាខាគឺ តាំងឆ្ងៃត្រា ចំណែកសន្តតិមហាមាត្យលេងរាំក្នុងមហានទីអស់ពេលមួយត្រឹមជល់ថ្ងៃត្រង់ ហើយក៏ទៅឯសួនទឹកអង្គុយក្នុងទីស្នាមសេពសុខយ៉ាងក្សាយ ។ ចំណែកស្រីនោះគឺតាក់តែងកាយស្រស់បស់ចូលទៅក្នុងស្នាមព្រឿងគំ សំដែងអាការព្រឿងកំបម្រើខ្លួនសន្តតិមហាមាត្យ ស្រាប់ឈ្លោះសត្តកវាតកើតឡើងក្នុងខ្លួនពុះដួងហឫទ័យរបស់ស្ត្រីនោះឲ្យជាច់ ដ្បិតស្ត្រីនោះព្រឿងរាំអស់ ៧ ថ្ងៃ ទឹងបរិភោគអាហារតិចផង ដោយឲ្យការព្រឿងរាំបានពីរោះស្តាប់ល្អមើល។ ស្ត្រីនោះក៏ធ្វើការលក់រាយស្តាប់ទៅចិនមានឆ្នេចក្អែកក្នុងខណៈនោះ ។ សន្តតិមហាមាត្យសួរបុរសតាំងឲ្យយថា ស្ត្រីនោះដូចម្តេចទៅ ? ។ បុរសតាំងនោះដំកឲ្យថា ស្ត្រីនោះស្ងួយដាំតែហើយ ។ សន្តតិមហាមាត្យគ្រាន់តែឮគេច្រាប់ថា ស្ត្រីនោះស្ងាប់ទៅហើយភ្លាម ដោយចិត្តប្រតិពទ្ធស្នេហាស្រឡាញ់ខាងនោះខ្លាំងពេក ស្រាប់ដែលសន្តតិមហាមាត្យដឹកគេញ ៧ ថ្ងៃមកហើយ ក៏រើងស្ងួតហួតហែងអស់ទៅក្នុងខណៈនោះភ្លាម ។ សន្តតិមហាមាត្យស្វាន់លែងស្រវឹងស្រាហើយគិតថា ស្រីពីព្រះបរមសាស្តាមួយអង្គចេញ គ្មានអ្នកណាអាចនឹងរំលត់ទុក្ខសោកបស់អាត្មាអញបានទេ គិតយើញដូច្នេះហើយ ក៏ទៅកាន់សំណាក់នៃព្រះបរមសាស្តាក្នុងសាយណ្ហសម័យ លុះដល់ហើយថ្វាយបង្គំនមស្សការរួចអង្គុយ

ក្នុងទីដ៏សមគួរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ! ខ្ញុំព្រះអង្គមកគាល់ពេលនេះដោយយល់ឃើញថា ព្រះអង្គអាចរំលត់សេចក្តីសោករបស់ខ្ញុំព្រះអង្គបាន សេចក្តីសោកដែលកើតមានដល់ខ្ញុំព្រះអង្គនោះអាស្រ័យហេតុយ៉ាងនេះ, ខ្ញុំលះចិត្តស្រឡាញ់ស្ត្រីនោះសព្វគ្រប់ ព្រះមានព្រះភាគសូមជាទីពឹងរបស់ខ្ញុំព្រះអង្គ ។

សម្តេចព្រះតថាគតទ្រង់ត្រាស់ថា ម្នាលមកគាន់សំណាក់តថាគតដែលជាអ្នកអាចរំលត់សេចក្តីសោកបានដោយសោកបរិវេទាការបាន តិតណាស់ហើយ ការធ្វើកំណាត់អស្ថិដែលជាកដែលអ្នកទួញយំស្តាយព្រោះហេតុតែស្ត្រីតាមនេះក្រៃជាងតែ សូម្បីប្រៀបធ្លាមទឹកក្នុងមហាសមុទ្រភាំងបួន ក៏ទឹកមហាសមុទ្រភាំងបួននោះ នោតិចជាងទឹកភ្នែករបស់អ្នកដែលទួញយំសោកស្តាយស្ត្រីនោះដែរ ទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់សំដែងនូវព្រះគាថាថា៖

យំ ភុញ្ជេ តំ វិសោសេហិ បច្ឆា តេ មាហុ តិញ្ចនំ
មជ្ឈេ ច នោ តមោសុស្សិ ឧបសន្តោ ចរិស្សសិ ។

សេចក្តីថា សេចក្តីកង្វល់ណារបស់អ្នកមានក្នុងកាលមុន អ្នកចូរញុំាងសេចក្តីកង្វល់នោះឲ្យរីងស្ងួតហួតហែងទៅចុះ, សេចក្តីកង្វល់ណាមានក្នុងកាលខាងក្រោយ អ្នកចូរញុំាងសេចក្តីកង្វល់នោះឲ្យរីងស្ងួតហួត

វិហរតីតុ, សេចក្តីកង្វល់ណាមានក្នុងបច្ចុប្បន្នកាលនេះ ចើអ្នកមិនទាន
ប្រកាន់យកទេ អ្នកនឹងនៅជាមនុស្សមានចិត្តដ៏ស្ងប់រម្ងាប់ ចាកពាធិ-
កិលេស ។

កាលសន្តតិមហាមាត្យបានស្តាប់ព្រះធម្មទេសនាក្នុងខណៈនោះចប់
ហើយ ក៏បានសម្រេចព្រះអរហត្ត ជាអង្គព្រះអរហន្តកប់ចូលក្នុងទិព្វា-
ភិញ្ញា ។ សន្តតិមហាមាត្យនោះ លុះបានសម្រេចព្រះអរហត្តហើយ
ទើបពិចារណាមើលនូវខន្ធប្រវត្តិនៃខ្លួន ក៏ឃើញថាអាយុសង្ខារបស់ខ្លួន
មិនបានតាំងនៅយូរអង្វែងទៅមុខទៀតទេ ទើបក្រាបទូលព្រះបរមគ្រូថា
បពិត្រព្រះអង្គ! សូមព្រះអង្គទ្រង់អនុញ្ញាតនូវបរិនិព្វានដល់ខ្ញុំព្រះអង្គ ។
សូមថ្វាយបង្គំលាចូលកាន់ព្រះបរិនិព្វាន ។

ជានដ្ឋានបិ អង្គសម្តេចព្រះសុគតទ្រង់ជ្រាបដោយព្រះញាណ
នូវបុព្វកុសលនៃសន្តតិមហាមាត្យ ប៉ុន្តែទីធ្លាញ់ផ្លាសពាក្យបរប្បវាទ
ក្លួកអ្នកមិច្ឆាទិដ្ឋិ ប្រការមួយទៀត ទ្រង់ឃើញថាពួកអ្នកសម្មាទិដ្ឋិបាន
ស្តាប់បុព្វកុសលនៃសន្តតិមហាមាត្យនោះហើយ នឹងកើតមានសេចក្តីខ្វល់
ខ្វាយក្នុងការកុសល សម្តេចព្រះបរមទេសនាទ្រង់ជ្រាបយ៉ាងនេះហើយ
ទ្រង់ជួនជាសន្តតិមហាមាត្យក្រាបទូលថា ខ្ញុំព្រះអង្គនឹងចូលកាន់ព្រះ
និព្វាន សម្តេចព្រះអនុត្តញាណទ្រាប់ថា បើអ្នកនឹងបរិនិព្វាន ក៏ចូរ

មើលការដ៏សមគួរដល់អ្នកចុះ អ្នកចូរសំដែងនូវបុព្វកុសលដែលអ្នកត្រូវធ្វើ
ឲ្យល្អាស់ប្រាកដចំពោះតថាគតមុននឹងចរនិព្វាន ពាលសំដែងនោះ ចូរកុំ
សំដែងលើប្រថព្វ ចូរទៅសំដែងឲ្យដំណាលអាកាសវិថីឲ្យបានកំពស់ ៧ ជួរត្នោតៗ
បន្តតិមហាមាត្យទទួលព្រះតុទ្ធដីកា សាធុ ៗ រួចហើយ ក៏
ថ្វាយបង្គំនមស្សការ ហោះឡើងទៅឲ្យដំណាលអាកាសបានកំពស់មួយជួរត្នោត
ហើយត្រឡប់ចុះមកថ្វាយបង្គំម្តង ហោះទៅទៀតបានកំពស់ពីរជួរត្នោត
ត្រឡប់ចុះមកថ្វាយបង្គំម្តង ហើយហោះឡើងទៅឯអាកាសទៀត ធ្វើតាម
ចំនងនេះរហូតដល់ ៧ ជួរត្នោត ចុះមកក្រាបថ្វាយបង្គំគ្រប់ ៧ ដង ស្រេច
ហើយក៏អង្គុយឲ្យដំណាលអាកាសវិថី ពេលនោះលុះប្រណម្យក្រាបទូលសំដែង
នូវបុព្វកុសលគឺកុសលដែលខ្លួនបានកសាងពីកាលមុនតទៅមុខថា:

វិបស្សីសម្មាសម្ពុទ្ធកាលេ ក្នុងកាលដ៏ជាព្រះបវរពុទ្ធសាស-
នានៃព្រះសម្ពុទ្ធទ្រង់ព្រះនាម វិបស្សី ខ្ញុំព្រះអង្គកើតក្នុងព្រះនគរពន្ធុមតី-
តិតនឹងធ្វើកុសលកុសិដែលមិនបានបៀតបៀនខ្លួនឯងបុគ្គលដទៃ កំរៃល់
ឃើញថា ការប៉ាវតែងខ្លួនកើរប្រកាសប្រាប់គេឲ្យធ្វើកងការកុសលនោះឯង
មិនបានបៀតបៀនខ្លួនឯងអ្នកដទៃ លុះតែឃើញយ៉ាងនេះហើយ ក៏ដើរ
ឃោសនាបបួលឲ្យអ្នកនគរធ្វើការកុសលចំពោះមាន, ស្តាប់ព្រះសទ្ធម្ម
ទេសនា, រក្សាព្រះវិន្ត្រសរណាគមន៍នឹងសីល ។

គ្រានោះ ព្រះបាទពន្ធុមតីជាព្រះពុទ្ធបិតានៃព្រះវិបស្សីបរមពុទ្ធ
តាលគ្រាស់ហៅឲ្យចូលគាល់ហើយទ្រង់សួរថា អ្នកឯងធ្វើការអ្វី បាន
ដារចេះតែដើរទៅដើរមកតាមមុខព្រះលាន ។ ខ្ញុំព្រះអង្គក្រាបទូលថា ខ្ញុំដើរ
ប្រកាសយោសនាឲ្យអ្នកនគរធ្វើបុណ្យកុសល ។ ព្រះបាទពន្ធុមតីទ្រង់
ព្រះរាជទានខ្លួរកែវមុក្តាហារសម្រាប់ប្រដាប់តាក់តែងខ្លួនមួយភួង គ្រាមួយ
ទៀត ទ្រង់ព្រះរាជទានអស្សរាជសម្រាប់ជិះ គ្រាយមកទៀត ព្រះរាជទាន
រាជវេទ័មដោយសេះសិន្ធពបួន គ្រាយមកទៀត ព្រះរាជទានគ្រឿងទុប.
គោគនីងបរិភោគជាច្រើន នឹងគ្រឿងប្រដាប់សម្រាប់អ្នកធំ ហើយព្រះរាជ
ទានគជសារសម្លុយសម្រាប់ជិះទៅប្រកាសកងការកុសល ខ្ញុំព្រះអង្គតាក់
តែងខ្លួនប្រាណបានស្អាតបាតល្អ ឡើងជិះដំរីចេះទៅប្រកាសយោសនាឲ្យ
អ្នកឯងធ្វើកងការកុសលតាំងពួនប្រមាណប្រាំបីមុខទាំ ក្លិនកាយនៃខ្ញុំព្រះ
អង្គក្រអូបឈ្ងុយឈ្ងប់ ប្រៀបដូចក្លិនខ្លឹមចន្ទន៍, ក្លិនកេសរនៃផ្កាទប្បល
ធំក្រអូបឈ្ងុយចេញពីមាត់នៃខ្ញុំព្រះអង្គ ដោយកងការកុសល គឺដើរ
ប្រកាសយោសនាឲ្យមហាជនធ្វើបុណ្យ តាំងពីក្មេងរហូតដល់ចាស់ជក
ស្ងួយជីវិត នេះជាបុព្វកុសលនៃខ្ញុំព្រះអង្គ ។

សន្ធតិមហាមាត្យក្រាបទូលព្រះពុទ្ធអង្គ អំពីបុព្វកុសលរបស់ខ្លួនចប់
ហើយ ក៏ចូលគេជាកសិណសមាបត្តិហើយរលត់ខន្ធចូលកាន់ព្រះនិព្វាន

នៅវេលានោះឯង ។

ក្នុកប្រាជ្ញតម្បីសន្និដ្ឋានថា - សន្តតិមហាមាត្យនេះ បានសម្រេច
ព្រះអរហត្តកងឹកេនជាគ្រហស្ថ ចាត់ចូលកងឹតីហិអរហកថាដូចវិសជ្ជនា
មកហើយនេះ ។

រឿងសន្តតិមហាមាត្យ ចប់តែប៉ុណ្ណេះ ។

រឿងពាហិយប្បុរស

ធារុចិរិកោ ពាហិយោ ច តីហិ សមាធោ អរ-
ហន្តំ បត្តោតិ ។ សោ ច ធារុចិរិកោ អហិរិកោ
អត្តានំ លោកសន្ទហាបេត្តោ លោកំ វញ្ចេសីតិ អា-
មន្តា តេច វត្តវេ វត្តព្វេ អវហ ហិរិកោតិ វត្តព្វោតិ ។

វារៈនេះ មឹងបានវិសជ្ជនាកងឹតីហិអរហកថាតទៅ ដំណើរសេចក្តី
ថា តីហិ សមាធោ បុគ្គលជាគ្រហស្ថបានសម្រេចអរហត្តនោះមាន
តាំរ ដូចបានឮមក ឯកស្មឹ សមយេ សម័យមួយ ជនជាច្រើន
នាំគ្នាជិះសំពៅបឹកៈទៅកងឹមហាសមុទ្រ ដើម្បីទៅធ្វើពាណិជ្ជកម្មការលក់
ដូរ បើកសំពៅទៅបាន៥ច្រើនទិវាកត្រៃ សំពៅនោះបែកខ្ទាយលិចលង់
កណ្តាលសមុទ្រ ។

(នៅមានត)

មង្គុរសរីហ៍ណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ចាប់ដើមតាំងតែអំពីកាលនោះមក ព្រះបាទមន្ធាតុព្រះបរមចក្រ ព្រះអង្គបានសោយរាជសម្បត្តិជាសុខក្សេមក្សាន្ត ឥតមានសេចក្តីរង្គៀសឡើយ ។

លុះដល់កាលកន្លងទៅយូរអង្វែងយ៉ាងនេះហើយ, សក្តទេវរាជនោះបានសោយសម្បត្តិពិភពតាត់តណ្តាល កំណត់អាយុបានបីកោដិជ្រុំមួយលានឆ្នាំមនុស្សកុំប្បតទៅ មានព្រះឥន្ទ្រាធិរាជដទៃទៀតទៅកើតក្នុងហានតាវតីសទេវលោកនោះទៀត ព្រះឥន្ទ្រាធិរាជនោះបានសោយរាជសម្បត្តិពិភពក្នុងហានតាតីសទេវលោកនោះឯង ដល់កំណត់អស់អាយុកំប្បតចុះមកទៀត ដរាបដល់ព្រះឥន្ទ្រាតាំងខ្សាយ ៣៦ ព្រះអង្គតែងទៅទៀតទៅកើតកំណត់អស់អាយុ ហើយច្យុតដោយហេតុដូចបានអធិប្បាយមកខាងដើមនេះឯង ។

ចំណែកឯព្រះបាទមន្ធាតុព្រះបរមចក្រ បានសោយរាជសម្បត្តិជាស្តេចនៃទេវតា កំណត់អាយុព្រះឥន្ទ្រាធិរាជ ៣៦ ដំណា ដោយរាជ

កាយជាមនុស្សយ៉ាងនេះហើយ កំព្រាអង្គមានកាមតណ្ហាសេចក្តីប្រាថ្នាក្នុងកាមគុណមិនចេះពេញ ចេះតែខ្វះជានិច្ច រឹងតែតែមានកាមតណ្ហាចំរើនកើតធំក្រៃលែងឡើងទៀត, ហើយទ្រង់ព្រះចិន្តាពិចារណាថា ពុទ្ធសម្បត្តិពិបាកតាក់តែងណាស់នេះ មិនជាប្រយោជន៍អ្វីដល់អញ្ជាឡើយ ។ ត្រូវតែអញសម្លាប់ព្រះឥន្ទ្រាធិរាជនេះចោល ហើយសោយរាជសម្បត្តិក្នុងឋានតាវតឹង្សទេវលោកនេះតែម្នាក់ឯង ទើបល្មមនឹងបុណ្យអញជាមួយពិត ។ ព្រះបាទមន្ធាតុព្រះបរមចក្រទ្រង់គិតដូច្នេះហើយ កំពុងតែចំរើនសម្លាប់នូវសត្វទេវរាជនោះបានឡើយ ។ ឯកាមតណ្ហាដែលកើតឡើងយ៉ាងនេះគ្រាន់តែជាឫសគល់ នៃសេចក្តីវិបត្តិ ច្រើនភាគប្រយោជន៍ច្រើនតែមួយនឹង ។ សេចក្តីពិតដូច្នេះ បានជាព្រះអរហន្តចាំងវ្បាយលោកពោលជាឧទានថាចាំងវ្បាយថា :

វរមតិសុខន្តិ្រកា អតិច្ឆាវិហាតោ ឯកោ
ឥធ ឋ បរត្ថ កតិញ្ជ្ជ ឯ សោ តំ វន្ទតេ សជា ។

សេចក្តីសុខដ៏ប្រសើរក្រៃលែង ទើបអាចធ្វើឲ្យផុតចាកកងទុក្ខទាំងពួងបាន ឯនរជនតែបណ្តោយបណ្តោយឲ្យសេចក្តីឥច្ឆាប្រាថ្នាលោភច្រើនដ៏ក្រៃលែងគ្របសង្កត់ខ្លួនបានហើយ សេចក្តីឥច្ឆាប្រាថ្នាដ៏ក្រៃលែងនោះពុំបានញាំងនរជននោះ ឲ្យបានទៅរកសេចក្តីសុខដ៏ប្រសើរនោះតិចតួច ក្នុងលោកនេះ ឬលោកខាងមុខ ក្នុងកាលទាំងពួងឡើយ ។

តណ្ហាយ ជាយតេ សោ តោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោ តោ កុតោ ភយំ

សេចក្តីសោកស្រណោះអាឡោះអាល័យក្តៅក្រហាយដែលខឹងកើតឡើង កំកើតមកតែពីសេចក្តីប្រាថ្នាក្នុងកាមគុណពិត សេចក្តីភ័យអន្តរាយកំកើតតែពីសេចក្តីប្រាថ្នាក្នុងកាមគុណពិត កាលបើបុគ្គលមានចិត្តរួចស្រឡះចេញចាកតណ្ហាហើយ សេចក្តីសោកក្តៅក្រហាយ ខឹងភយន្តរាយកើតមានមកពីខ្លួនឯណា ។

តណ្ហា ជាយតេ សោ នរោ ឯត្ថ ភយំ ជាតោ ឥធ លោកេ
ហិត្វា តណ្ហំ ន ជាយតិ កុតោ តត្ថ ភយំ ភវិស្សតិ ។

ខន្ធជនដែលលុះអំណាចនៃតណ្ហាជាខ្ញុំបំរើតណ្ហាហើយ តែងលំបាកដល់ខ្លួនវិសេចក្តីទុក្ខជាមិនខ្លះទេ ត្រូវសោកតាក់តែងជាដើម កើតឡើងព្រមអំពីសត្រូវមានស្តេចជាដើមក្នុងលោកនេះ ។

យេន លោកេន ជាយេថ លព្ភា ជាយន្តិ តាទិសា
ខេត្តវត្ថុហិរញ្ញំ ភ គវាស្សជាសុវោរិសំ
សព្វមេត សោ លោកោ បហាតព្ពោ ច វិញ្ញុនា ។

សត្វជាតិឆ្កួយដែលបានស្រែចំការខឹងមាសប្រាក់ច្រើនក្តី បានគោសេះខឹងប្រុសជាខ្ញុំបំរើច្រើនក្តី ហើយទំនងខឹងវិនាសទៅវិញដោយសេចក្តី

លោភតណ្ហាឯណា ដែលកើតឡើង ហើយស្ទេចក្តីលោភតណ្ហានោះគឺ
អ្នកប្រាជ្ញដែលចេះដឹងពិត ត្រូវប្រព្រឹត្តលះបង់ចោលចេញឲ្យធាប់ ដោយ
កម្លាំងនៃញាណ ដែលមានកម្លាំងដោយប្រការពិតពិត ។

ឯអាយុសង្ខារនៃព្រះបរមគោតមសាស្តា ដែលមានសេចក្តីឥតប្រាថ្នា
ច្រើនក្រៃពេក ត្រូវសង្កត់ចិត្តហើយ កំសាបសូន្យថយចុះទៅក្នុងកាលនោះ
ឯង សេចក្តីចាស់ជរាកំប្រហាន្ទូវសរីរៈឲ្យខ្ទុះខ្ទេរមគ្រាំគ្រាទៅមួយ
រំពេច ឯសរីរៈបង់មានុស្សកំប្រាកជឡើង ពុំបានលាយប្រឡាំងដោយ
សរីរៈនៃទេវតាក្នុងឋានទេវលោកឡើយ ។

គ្រាកាលនោះ ព្រះចាតុមន្ទាតុព្រះបរមេចត្រូតត្រាធិរាជ ទ្រង់
របួតភ្នាក់ចុះមកចាកឋានទេវលោក ឋានមកបិតទៅក្នុងព្រៃទ្យានបេស់
ព្រះអគ្គជួចកាលមុនវិញ ។

ឯបុរសដែលជាអ្នករក្សាទ្វារទ្យាន ឋានដឹងហើយ កំទាំយកសេចក្តី
ដែលព្រះចាតុមន្ទាតុព្រះបរមេចក្រនោះ ស្តេចត្រឡប់មកព័ស្ថានសួគ៌វិញ
ហើយ ចូលទៅក្រាបទូលក្នុងរាជត្រកូលចាំងអស់ ឲ្យឋានជ្រាបសព្វ
គ្រប់ក្នុងវេលានោះឯង ។ ឯស្តេចដែលជាធំក្នុងរាជត្រកូល កំឋានចេញ
មកអំពីរាជត្រកូលហើយ ចាត់ចែងសេវាមាត្យចាំងឡាយឲ្យក្រាលរាជ-
សនៈជាប្រសើរក្នុងសួនទ្យាននោះ ។

លំដាប់នោះ ព្រះបាទមន្ធាតុព្រះបរមចក្រព្រះអង្គក៏ឡើងផ្ទំលើកជាសន្ទះដ៏ប្រសើរ ដែលសេវាមាត្យក្រាលថ្វាយហើយ ព្រះអង្គផ្ទំសម្រេចជាអនុជ្ញានសេចក្តីធំពុំបាននក្រោកឡើងវិញឡើយ ។ វេលានោះ អាមាត្យទាំងឡាយក៏បាននចូលមកជួបជុំ ហើយថ្វាយបង្គំក្រាបទូលសួរថា ៖ បពិត្រព្រះសម្មតិទេព! តាំងកាលមុនរៀងមកយើងទាំងឡាយត្រូវគោលដួចម្តេចខ្លះ ? ឯព្រះបាទមន្ធាតុព្រះបរមចក្រ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយក៏ត្រាស់ថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! អ្នកត្រូវសម្តែងច្បាប់តាក្យបណ្តាំរបស់អញពីកាលមុនរៀងមកថា ព្រះបាទមន្ធាតុជាស្តេចធំដ៏ប្រសើរ ព្រះអង្គបាននសោយរាជសម្បត្តិជាស្តេចចក្រពត្តិក្នុងទ្វីបធំទាំងបួនមានទ្វីបតូចពីរពាន់ជាបរិវារ ជាអស្ចារ្យពន់ពេកណាស់ មិនតែប៉ុណ្ណោះ ព្រះអង្គបានឡើងទៅសោយសម្បត្តិទិព្យ ក្នុងឋានចាតុមហារាជិកាកំណត់បានច្រើនរាប់មួយពាន់ឆ្នាំមនុស្ស ហើយស្តេចបានឡើងទៅសោយរាជសម្បត្តិទិព្យ ក្នុងឋានតាវតឹង្សទេវលោក អស់កាលជាអម្ចាស់ឃើញរាប់ពន់ពេក ដោយកំណត់នៃអាយុព្រះអង្គទាំងឡាយ ៣៦ ត ទើបព្រះអង្គបានធ្វើមរណកាលក្សីណក្សយព្រះជន្មទៅ ។

ឯព្រះបាទមន្ធាតុព្រះបរមពោធិសត្វនោះ ព្រះអង្គមានព្រះបន្ទូលតែប៉ុណ្ណោះហើយ ក៏ទ្រង់សោយព្រះទិវង្គតទៅ ហើយបានទៅកើតក្នុង

ហានសួនិសោយសម្បត្តិទៀត ដោយសមគួរតាមបុញ្ញកម្មរបស់ព្រះអង្គ
ហោង ។

បពិត្រអើយ ! អង្គសម្តេចព្រះលោកុត្តមាចារ្យជាម្ចាស់ ព្រះអង្គទ្រង់
ត្រាស់សម្តែងរឿងនេះចប់ស្រេចហើយ កំពោលថាបទព្រះគាថាទាំង-
ឡាយថា :

យាវតា ចន្ទិមសុរិយា ទិសា ភន្តិ វិរោចនា
សព្ពេ ជានា មត្ថកតុស្ស យេ ច ទាណា ឧបវិសិតា ។

សេចក្តីថា ព្រះអាទិត្យទាំងព្រះចន្ទទាំងឡាយ ដែលភ្លឺស្វាងរុង-
រឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺច្បាស់ ឆ្លុះមកក្នុងទីមានប្រមាណត្រឹម
ណា សត្វទាំងឡាយណា ដែលនៅអាស្រ័យនឹងផែនដី ក្នុងទីមាន
ប្រមាណប៉ុណ្ណោះ សត្វទាំងនោះសុទ្ធតែជាទាសីទាសាជាខ្ញុំបំរើព្រះបាទ
មន្ធាតុព្រះបរមចក្រទាំងអស់ ដោយពិត ។

ន ភាហាបណវំសេន តិត្តិ ភាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខាភាមា ឥតិ វិញ្ញាយ បណ្ឌិតោ ។

បណ្ឌិតជាតិជាអ្នកប្រាជ្ញអាចមានបញ្ញា ត្រូវពិចារណាឲ្យដឹងដូច្នេះថា
សេចក្តីឆ្អែតពេញប្រាថ្នាក្នុងកាមគុណទាំងឡាយ ដោយអំណាចតែភោ-
បណៈមានប្រមាណប្រើនក៏ពុំមានឡើយ កាមគុណទាំងឡាយរមែងទាំមក

ខ្លួវសេចក្តីខ្ពុលចិត្ត មានសេចក្តីក្រេវក្រាតចង្អុចស្តីដំណាស់ ។

អបិ ធិព្វេសុ កាមេសុ រត្តិំ សោ ជាតិកច្ឆតិ

តណ្ហាក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ចំណែកឯព្រះចុទមន្ទាតុព្រះបរមចក្រនោះព្រះអង្គពុំបានសម្រេចខ្លួវ សេចក្តីដំរេកត្រេកអរក្នុងកាមគុណដំដាំតិច្បាឡើយ ។ ព្រោះហេតុដូច្នោះ ជាន់ជាសម្មាសម្ពុទ្ធសាវ័ក លោកមានតែដំរេកត្រេកអរក្នុងកិច្ចដែលអស់សូន្យពីតណ្ហា ដោយចំណែកមួយដោយពិត ។

មហាជនតាំងពាន់ ជានស្តាប់ខ្លួវព្រះគាថានោះហើយកំជានសំរេច ខ្លួវមគ្គនិងផលមានសោតាបត្តិមគ្គជាដើម ក្នុងកាលនោះឯង ។

ព្រោះហេតុដូច្នេះ ជានជាព្រះអរហន្តតាំងពាន់លោកសំដែងបទ គាថាដូច្នេះថា:

ឥតិ ឯយតកតិំ ពោធិយាធិមត្តាំ

សកាវសមុបនេត្វា នេតិ ទុក្ខាធិ តណ្ហា

អធិយតកតិកាំ កា កថា មាធិសាំ

បជហាថ ឥតិ មត្វា កោ កវេ តន្តិ វត្តុំ ។

សេចក្តីថា តណ្ហាអាចប្រមូលជំកនាំមហាបុរសតាំងពាន់ដែលមានព្យាយាមមាំក្នុងពោធិញ្ញាណ មានគតិដឿងតាន់នេះឲ្យចូលទៅជិត

គាន់អំណាចរបស់ខ្លួនបាន ហើយប្រគល់ឲ្យនូវសេចក្តីទុក្ខលំបាកឥត
គណនាយ៉ាងដូច្នេះ, ចាំបាច់និយាយទៅថ្វីដល់បុគ្គលប្រាកដស្មើដោយ
យើងតាំងឲ្យ ដែលប្រកបដោយគតិមិនឲ្យងាយយ៉ាងនេះ ម្នាលអ្នក
តាំងឲ្យដ៏ចំរើន ! បើអ្នកបានតិចារណាដឹងច្បាស់យ៉ាងនេះហើយ, ត្រូវ
តែលះបង់ចោលនូវតណ្ហានោះ ដែលជាវត្ថុជាគ្រឿងត្រេកអរក្នុងភពឲ្យ
ស្រឡះចេញ ទើបបានសេចក្តីសុខក្សេមក្សាន្តពិតហោង ។

សំដែងរឿងព្រះមហាមន្ធាតុបរមេចក្រជាតំបន់ ៨ ក្នុងវគ្គទីមួយ កំចប់
សេចក្តីដោយសង្ខេបតែប៉ុណ្ណេះឯង ។

៩ ពុទ្ធវម្សាណិជវត្ថុកថា

សំដែងរឿងទិតានុភាណិជឈ្មោះ ភុទ្ធវម្ស តទៅទៀត ដោយបទ
ចុងថា ជម្ពុទីបេ តិរ ចាតលិបុត្តនគរេ ដូច្នេះជាដើម
អធិប្បាយជាសេចក្តីថា តិរ ចាន្តរវារៀត ។ មកថា, មានឈ្មួញ
ម្នាក់ ឈ្មោះពុទ្ធវម្សាណិជ តែងរកស៊ីចិញ្ចឹមជីវិតដោយណិជ្ជកម្ម
ជំនួញដើរទេះ គាត់ទៅអាស្រ័យក្នុងនគរបាតលិបុត្តក្នុង ជម្ពូទ្វីប ។

លុះដល់ចំណោមកជាខាងក្រោយ ពុទ្ធវម្សាណិជនោះបានប្រកប
នូវការជំនួញក្នុងប្រទេសទាំងឡាយមានជនបទនីគមជានីជាដើម កំយក
ទំនិញជាកង្កុនទឹងរទេះ ហើយបរចេញទៅអំពីក្រុងបាតលិបុត្តជាមួយនឹង

ខាងឈ្នួញរទេះដទៃជារច្រើន ដើម្បីនឹងចេញទៅដួញកងប្រទេសផ្សេងៗ ។

សម័យនោះ ព្រះមានព្រះភាគព្រះគន្ធីបានទាំព្រះភិក្ខុសង្ឃច្រើនឆាងពាន់អង្គ ចោមរោមជាបរិវារគ្រាចំទៅកាន់ចារិកនៃជនបទហើយ ព្រះអង្គបានសំដែងធម៌ទេសនាប្រោសមនុស្សនឹងទៅតា ឲ្យបានខលួលអម្រិតសេ ឲ្យបានធ្លឹងផុតចាកផ្លូវឆ្ងាយគឺសង្សារវដ្តចាកខុទ្ធំពាំនពួន ។

កាលនោះ ពុទ្ធម្ចាស់ជាណាថ បានជួបប្រទះនឹងព្រះមានព្រះភាគដែលមប្រកបដោយមហាបុរិសលក្ខណៈ ៣២ ទាំងប្រដាប់ដោយអនុព្យញ្ជនៈ ថ្លៃតសិបតត់ ជាក្លិស្មាន់ឆ្ងរឿងចាំដូចរូបមាសដែលមានព្រះភិក្ខុសង្ឃច្រើនចោមរោមជាបរិវារគ្រាចំទៅតាមផ្លូវនោះដែរ លុះបានឃើញហើយក៏មានចិត្តាល់ត្រេកត្រសែតូសពាំងគ្មាយ ហើយដើរចូលទៅកាន់សំណាក់ព្រះមានព្រះភាគលើកអញ្ជលីថ្វាយបង្គំដោយគោរព ត្រមទាំងបានស្តាប់ធម៌ទេសនាផង ក៏រីឯរតែមានសេចក្តីជ្រះថ្លាខ្លាំងឡើងទៀត លុះចប់ធម៌ទេសនាហើយក៏បានទៅមក្តព្រះមានព្រះភាគ ត្រមទាំងភិក្ខុសង្ឃឲ្យខលួលបង្ហាន់កងសាយណ្ហសម័យថ្ងៃរសៀលនោះឯង ត្រោះខ្លួនទើបតែបានជួបនឹងព្រះពុទ្ធជាដំបូង ពុំខានខេះដឹងកិច្ចកងព្រះពុទ្ធសាសនាទៅឡើយ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាណិជ ! តថាគតទាំងឡាយពីមុនរៀងៗមក ព្រះអង្គតែងរៀរលែងវិតាលកោជន ពុំ

វដ្តលះបរិភោគជាយវេលាថ្ងៃរសៀលទៀយ ។

ចំណែកឯតុទ្ធវម្មតាណិជនោះ លុះបានស្តាប់ព្រះពុទ្ធដីកាដូច្នោះ ហើយ ក៏ក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចំរើន ! ព្រះមានព្រះភាគទាំងឡាយ ព្រះមគ្គនីឯងសោយតែម្តងខ្លះ ទើបគួរកន្លងវេលាថ្ងៃល្ងាចអម្ងាស់ ? ។

កាលនោះ ព្រះមានព្រះភាគព្រះអង្គបានអនុញ្ញាតទឹកបាន ៨ យ៉ាងចំពោះនឹងតុទ្ធវម្មតាណិជនោះថា ម្នាលតាណិជ ? ក្នុងវេលាកាលព្រះតថាគតគួរឆាន់បានចំពោះតែទឹកទាំង ៨ យ៉ាង ឯទឹកទាំង ៨ យ៉ាងនោះគឺ អម្ពបានំ ទឹកស្វាយ ១ ប្តស្វាយ ១ ក្នុងមួយ ជម្ពុបានំ ទឹកផ្លែត្រឹងមួយ ចោចបានំ ទឹកផ្លែចេកមានគ្រាប់មួយ, មោចបានំ ទឹកផ្លែចេកឥតគ្រាប់មួយ, ឧទ្ទបានំ ទឹកអំពៅមួយ, ដារុសកបានំ ទឹកផ្លែមាក់ព្រាងមួយ, មធុកបានំ ទឹកផ្លែស្រគំមួយ, មុទ្ទិកបានំ ទឹកផ្លែចន្ទនមួយ, ត្រូវជាទឹក ៨ យ៉ាង ទឹកទាំងនេះគួរដល់សមណៈនឹងព្រាហ្មណ៍ឆាន់កន្លងវេលាវិកាលបានដោយពិត ។

ឯតាណិជបានស្តាប់ហើយ ក៏មានចិត្តជ្រះថ្លាចាត់ចែងយកផ្លែចន្ទនុំមកប្រចាប់លាយទឹងទឹក ហើយត្រង ១ ឲ្យស្អាតផ្សំលាយដោយសេចក្តីឡាយមានរសស្អុះជាដើម, ស្រេចហើយយកទៅប្រគេនព្រះកិកុសង្ឃមានព

ព្រះសង្ឃសម្ពុទ្ធជាប្រធានក្នុងកាលនោះឯង ។

លុះព្រះបរមសាស្តាចារ្យព្រមទាំងព្រះភិក្ខុសង្ឃបានឧបត្ថម្ភចុះកុបានៈនាន់ស្រេចហើយ ក៏ព្រះអង្គទ្រង់សំដែងធម្មទេសនាដល់តុន្នវម្មណិជនោះ លុះព្រះអង្គសំដែងព្រះធម្មចប់ហើយ ក៏នាំភិក្ខុសង្ឃចេញទៅកាន់ចារិកនៃជនបទក្នុងកាលនោះឯង ។

ចំណែកឯតុណិជវិញក៏មានចិត្តជ្រះថ្លាក្នុងការថ្វាយបានៈនោះពុំមានក្តៅចិត្តមួរទេះបរចេញទៅ ប្រកបការដំនួញក្នុងស្រុកជនបទនានា ជាមួយនឹងឈ្មួញរទេះទាំងឡាយ លុះបានបរទៅដល់ផ្លូវធ្លាយធំធេងមានសុទ្ធតែដីខ្សាច់ ឥតមានទឹកក្នុងព្រៃធំឡើយ ។

ឯទឹកសម្រាប់ផឹកក្នុងរទេះទាំងឡាយ របស់តុណិជនោះក៏អស់ទៅពុំមានសេសសល់តិចតួច ទាំងទឹកសម្រាប់មនុស្សក្តី សម្រាប់តុបានៈក្តី ក៏ពុំមានសេសសល់ក្នុងវេលានោះឯង ។

ឯតុន្នវម្មណិជនោះស្រេក ពេលបើដាច់ទឹកសោះដូច្នោះហើយ ក៏ស្រែកទឹកជាខ្លាំង អត់ទ្រាំពុំបាន ទើបដើរស្វែងរកទឹកក្នុងរទេះទាំងឡាយនោះ សូម្បីគ្រាប់ទៅគ្រាប់មកតាមលំដាប់រទេះនោះ ក៏ពុំបានទឹកផឹកដល់តិចឡើយ ។

(នៅមានត)

(តមក)

លោក អ៊ឹម.កន ចម្លងពីសារស្ក្រាស្ក្រឹតតែ

ព្រះភុទ្ធវង្ស កឹម-គួរ ពិនិត្យ

រីឯអ្នកទាំង ២ នោះមិញ កាន់តែខ្សែរខេះរត់ទៅ, រីឯសម្ដេចរាខេះរត់បានបន្តិចហើយ លែងរាខេះឈប់នៅហោង ។ រីឯព្រះឥន្ទ្រមិញ រត់ទៅដល់តម្ងួយរំពេច ម្ងួយអន្ទើនដែរាខេះនោះហោង សូមព្រួញសម្ងួយតំណាក់ កំពុងចេញអំពីសរីរកាយឡើយ, ហើយតុំហត់ដង្ហើមចេញចូលឡើយ ហើយមិនខ្ចក ក្អែកតុំប៉ប្រិច, រីឯសេនេះឈ្មោះព្រះឥន្ទ្រាធិរាជ ជាស្ដេចទេវតាហោង ។ រីឯសេបរាខេះដល់ថាថា អ្នកជាព្រះឥន្ទ្រពិត ហ៎ះ ? ព្រះឥន្ទ្រថា អើអញជាព្រះឥន្ទ្រពិត ។ កាលបើតាស្ស ព្រះឥន្ទ្រជាដូច្នោះហើយ, រីឯមហាសត្វអ្នកដល់ថាថា ថ្វីកំអ្នកមកធ្វើអំពើដូច្នេះ, ព្រះឥន្ទ្រថា ដែរចៅអ្នកប្រាជ្ញអើយ តែអញមកនេះប្រយោជន៍ធំធេងសំដែងល្បងប្រាជ្ញានៃអ្នក ឲ្យឃល់ជាក់ច្បាស់ប្រាកដហោង ។ ព្រះមហាសត្វថា អំពីនេះទៅ កុំបីអ្នកធ្វើអំពើដូច្នេះទៀតឡើយ ។ រីឯព្រះឥន្ទ្រាធិរាជ

សំដែងអានុភាពអាត្មាជាព្រះឥន្ទ្រស្រេចហើយ អ្នកទៅបិតនៅកណ្តាលអាកាស ដំមានតណិតខ្ទីរស្មីបំភ្លឺដូចព្រះអាទិត្យតេញកំលោះ ន្លោះសរសើរក្រាបថ្វាយនៃព្រះមហាសត្វអ្នកក្រាបថា ម៉ៃហៅមហាសត្វអ្នកក្រាបប្រសើរអើយ, រីអាថ៍សេចក្តីក្រាបថ្វាយពៅពិចារណានេះ តាប់ប្រពៃដោយខ្លួវសុចរិតធម៌ពេកហោង ។ ព្រះឥន្ទ្រាធិរាជសរសើរព្រះមហាសត្វស្រេចហើយ អ្នកក៏ហោះទៅកាន់ឋានអាត្មាវិញហោង ។ ឮដំកាលខោះ រីអាមាត្យដែលចាំទៅខោះម៉ាញ ខ្លួនឯងមើលឃើញដូច្នោះ កំចូលទៅថ្វាយបង្គំព្រះថ្នាទ្រីទេហាពជហើយទូលថា បពិត្រមហាពជអើយ រីសេចក្តីដែលពៅអ្នកក្រាបបង្គាប់ជាក្តាត់ហោង សូមឲ្យព្រះឥន្ទ្រាធិរាជក្តី កំតង់ថាញ៉ាក្រាបថ្វាយនៃពៅអ្នកក្រាបដែរ ហេតុម៉្លេះក៏ព្រះថ្នាទ្រីអម្ចាស់មិនទ្រង់ត្រាប់ថា ពៅអ្នកក្រាបជាមហាបុរសវ័ន្តន៍វិសេស ស្តេចស្តាប់ជាក់ហើយមានបន្ទូលដល់ឯអាចារ្យសេនកថាម្នាលអាចារ្យសេនកអើយ យើងនឹងឲ្យពៅនាំពៅអ្នកក្រាបនោះមកឬម្តេច? រីអាចារ្យសេនកហេតុតែជាអ្នកកំណាញ់លាភសក្ការៈនោះមិញក៏ទូលថាស់ថាបពិត្រអើយ នាមីហៅថាអ្នកក្រាប ទៅប្រមាណមានចំណេះតែអម្បាលនេះក៏ហៅចំណេះតិចក្តាត់ណាមហាពជ! តុំថាន់ជាអ្នកក្រាបឡើយ សូមអម្ចាស់ឈប់ស្ទើរសិន ហើយយើងលួងក្រាបឲ្យអស់ចិត្តតំនិតហោង ។

រត្រៃចាវរៀងហាក់ដ សេដ្ឋចស្តាប់ហើយគន់ស្ងៀមវិញហោង ។

សន្តនារកបញ្ហា ដ៏ដ្ឋិតោ រំយើងបានស្រដីពីប្រស្នាក្មេងអាយុ ៧ ឆ្នាំមិញ ក៏ស្រេចខ្ញុំប្រកាអម្បាលនេះហោង ។

ឧណ្ហោតិ រីការល្បងកំណាត់ឈើតគីរនោះមិញ មានដូចតទៅនេះ អាថ៌កំបាំងសំ ភដា បណ្ឌិតំ រីមិស័ស្សាមាតិបតិត្រអើយ មានការសម័យថ្ងៃមួយ, មហាក្សត្រាធិរាជ ដ៏ខ្ពង់តេតនឹងអស់អ្នកប្រាជ្ញទាំង ៤ ថា យើងខ្ញុំចង់ល្បងលព្រះមហាសក្តអ្នកប្រាជ្ញនោះណ្ហ ហើយស្តេចឲ្យយកកំណាត់គគីរមួយកំណាត់តាត់ចេញនៅតែប្រវែងមួយចំអាម ហើយឲ្យឆកជាងមកក្រឡឹងឲ្យស្មើ ធ្វើមិនឲ្យដឹងជាចុង ជាដើមស្រេចហើយ ស្តេចឲ្យអាមាត្យនាំទៅកាន់សំរីវឹ្ឍកសេដ្ឋី នៅស្រុកជាច័ន្ទយាមជ្រុតាមនោះមកដល់ខ្ញុំពិចារណាទិដ្ឋន្តា ពុំអាចដើម្បីទឹងដឹងកំណាត់ឈើតគីរនោះថា ខាងណាចុង ខាងណាដើមបានឡើយ, ទើបថាជ្រុតមានព្រះបន្ទូលត្រាស់ឲ្យមកដល់អ្នកឯកល់គ្នា ឲ្យយកកំណាត់ឈើតគីរនេះ ឲ្យដឹងជាខាងណាចុង ខាងណាដើម, បើដឹងហើយ អើនោះក៏ជាការតេតទោសតែប៉ុណ្ណឡើយ, ថាបើមិនដឹងហើយ ព្រះអង្គទិដ្ឋន្តាឲ្យត្រូវទោសដំណាំងដល់អ្នកឯងឯកល់គ្នាបាន ១០០ ដង ។ រីសំរីវឹ្ឍក-

សេដ្ឋី ខ្ញុំអស់អ្នកស្រុកជាច្រើនយកមជ្ឈត្រាមនោះមកជំនុំគ្នា ពិចារណាក៏ពុំអាចដើម្បីនឹងដឹងជាចុងជាដើមបានឡើយ ទើបសំរឹងឡកសេដ្ឋីតពិចារណាឯងថា មានតែចៅមហាសថក្នុងអញនេះមានប្រាជ្ញា កំអាចដឹងកំណាត់ឈើតគីរនេះជាចុងជាដើមមិនខេឡើយ, បើដូច្នោះ ចូរគ្នាយើងទៅហៅមកជណ្តើងល្បងម៉ែល ។ ទើបសំរឹងឡកសេដ្ឋីឲ្យទៅហៅព្រះមហាសថ អំពីបរមសាលាក្រឡាល្បែងនោះមកកំជណ្តើងថា ម្នាលចុមមហាសថក្នុងសំឡាញ់អាតុកអើយ! ឥឡូវនេះ មហាក្សត្រឲ្យយកកំណាត់ឈើតគីរដួនមកអាតុក ខ្ញុំអស់អ្នកស្រុកជាច្រើនយកមជ្ឈត្រាមប្រើគាយឲ្យដឹងជាចុងជាដើម អស់យើងទាំងនេះ ពុំអាចដើម្បីនឹងគាយដឹងបានឡើយ ឯបាទើបមានប្រាជ្ញាអាចដឹងបាន, រីព្រះមហាសថអ្នកប្រាជ្ញស្តាប់ហើយ ទ្រង់ចិន្តាពិចារណាថា នាមហាក្សត្រាធិរាជ ស្តេចឲ្យដួនកំណាត់ឈើតគីរនេះមក ដើម្បីឲ្យគាយនឹងធ្វើជាប្រយោជន៍ឲ្យអញឯងហោង, ហើយថា បើដូច្នោះ ចូរអ្នកឲ្យនាំមកខ្ញុំនឹងមើលអេះ, ទើបសំរឹងឡកសេដ្ឋី ឲ្យនាំកំណាត់ឈើតគីរនោះមកឲ្យព្រះមហាសត្វអ្នកប្រាជ្ញ។ ទើបព្រះមហាសថ អ្នកកាន់កំណាត់ឈើតគីរនោះលើកឡើងហើយ កំព្រះអង្គស្គាល់ដួងរំពេចនោះឯងថា ឯនេះចុង ឯនេះដើម, តែពោះបី

ព្រះអង្គដ៏ឯប៉ុន្មានទាំង្កើ កំឡើងជាមិនដឹងឡើយ, ហេតុនឹងចង់យកចិត្តអ្នកផង
ទាំងឡាយឲ្យដឹងផង ទើបព្រះអង្គឲ្យភៀយកកាជន៍មួយមកចាក់បំពេញ
ខ្លួរឹតហើយឲ្យយកខ្សែអម្បោះមកចងភាក់កណ្តាលកំណាត់ឈើតតីរនោះ
ហើយជាក់តងឹតកាជន៍នោះ ហើយកាន់តែចុងខ្សែបណ្តែត, រីឯដើម
សកាពជាធ្ងន់លិចចុះក្នុងទឹកកាជន៍នោះ ហើយអណ្តែតឯកុងឡើងវិញ
ហោង ។ លំដាប់នោះ ទើបព្រះមហោសថឆ្លើយជាមិនដឹងកំសួរ អស់មហា
ជនទាំងឡាយថា ម្នាលអ្នកទាំងឡាយអើយ, ឱឈើផងទាំងឡាយ
នោះ តើធ្ងន់ឯដើមលើសឬធ្ងន់ឯចុងលើសហឹង ? អស់មហាជន
ទាំងពួងឆ្លើយថា បពិត្រព្រះមហោសថអើយ ឱឈើទាំងឡាយធ្ងន់ឯដើម
លើស, ទើបព្រះមហោសថប្រាប់ថា ម្នាលអ្នកទាំងឡាយអើយបើដូច្នោះ
លិចមុខនោះឯងជាខាងដើមឈើ. ដ្បិតសកាពធ្ងន់លើស ទើបលិច
ចុះ, ឯម្ខាងទេះសកាពស្រាលជាចុងឈើហោង, ម្ល៉ោះហើយព្រះអង្គឲ្យ
កត់សំគាល់ជាចុងជាដើមស្រេចហើយ ឲ្យទាំងឆ្លើយព្រះមហាសត្វត្រាច់-
រាជនោះវិញហោង ។ ព្រះមហាសត្វត្រាធិរាជស្តេចជ្រាបហើយ កំមានព្រះ
រាជហឫទ័យនោះពេញខ្លួរព្រះអំណរអរក្រៃពេក មានព្រះបន្ទូលជណ្តើងថា
អ្នកណាដឹងជាចុងជាដើមហឹង ? អស់មហាជនទាំងឡាយ ក្រាប

ថ្វាយចង្ហុំប្រណាមខ្លួលថា សូមទានព្រោស ព្រះមហោសថកូនសំរឹទ្ធក-
សេដ្ឋីនោះឯងអាចដឹងជាបុងជាដើមហោង ។ ព្រះមហាសត្វគ្រាធ៌ាជ
ស្តាប់ហើយ មានព្រះបន្ទូលដណ្តឹងទៅកាន់អាចារ្យសេនកថា អើអាចារ្យ
គួរហើយ អញនឹងឲ្យទៅនាំយកមកពុកជាអ្នកប្រាជ្ញប្រដូចម្តេចហឹង ។ ឯ
អាចារ្យសេនកទូលតាស់ទៀតថា មហាកជ បពិត្រមហាកជអើយ សូម
ទានឈប់សែ្ទះសិន រង់ចាំយើងខ្ញុំនឹងល្បងដោយខ្លួនៗថ្វាយគលឲ្យអស់ចិត្ត
ហោង ។ ព្រះមហាសត្វស្តាប់ហើយមានព្រះបន្ទូលថា ហៃអាចារ្យសេនក
អ្នកគិតនោះនាំប់ហោង ។

សីសន្តិ នេះនឹងស្រដីពីការល្បងក្បាលខ្មោចដូចតទៅនេះ ។
អថេកធិវាសំ ឥត្ថិយា ច សីសំ បុរិសស្ស ច សីសន្តិ
។ ល ។ មានកាលសម័យកាលមួយ ព្រះមហាសត្វគ្រាធ៌ាជនូវអ្នកប្រាជ្ញ
ចាំង ៤ ជំនុំរៃគិតស្រេច ស្តេចឲ្យល្បងលងអ្នកប្រាជ្ញ ទើបឲ្យទៅយក
ក្បាលខ្មោចចាំង ២ មួយគឺក្បាលខ្មោចស្រី មួយគឺក្បាលខ្មោចប្រុស
ហើយទើបឲ្យនាំទៅកាន់សំរឹទ្ធក្រសេដ្ឋី នូវអស់អ្នកស្រុកចាំនួយមេជ្ឈ-
ត្រាមថា ដ្បិតមានព្រះបន្ទូលតិះសែស ត្រាស់ឲ្យយើងនាំក្បាលខ្មោចស្រីមួយ
ក្បាលខ្មោចប្រុសមួយ ចាំង ២ មកកាន់អ្នកឯង, ឲ្យយកឯណាក្បាល

ខ្មោចស្រី ឯណាកាលខ្មោចប្រុស ថាបើអ្នកតាយត្រូវ អើតំណាកា
ឥតទោសទេឬយ, ថាបើមិនដឹងហើយ ព្រះអង្គទំនឹងឲ្យត្រូវព្រះពជ្ឈដំណាំង
តាន់ដង ។ កាលនោះសិរីវឌ្ឍកសេដ្ឋី ទូរអស់អ្នកស្រុកជាចំនួយរាមជ្ឈគ្រាម
នោះ រមិលមើលកាលខ្មោចទាំង ៦ នោះហើយ សឹងតែមិនដឹងពល់គ្នា,
លុះទៅដល់ពឹងព្រះមហាសថអ្នកប្រាជ្ញ ទើបព្រះអង្គរមិលមើលទៅយល់
ហើយ ព្រះអង្គស្គាល់ជាកាលខ្មោចស្រី ជាកាលខ្មោចប្រុសនោះមួយ
រំពេចហោង ។ បតិត្រេសប្បុរសឥឡូវទាំងឡាយអើយ នាព្រះមហាសថ
ព្រះអង្គដឹងជាស្រីជាប្រុសនោះ តើហេតុដូចម្តេច ? ថាដ្បិតកាលខ្មោច
ប្រុសមានសង្រែកត្រង់ ឯកាលខ្មោចស្រីមានសង្រែកវៀចក្រឡាចន្ទិច
ហើយជាច់ចេញវិញ, ដ្បិតហេតុនោះហាង៎ទើបព្រះអង្គដឹង ហើយព្រះ
អង្គប្រាប់អស់អ្នកទាំងឡាយថា នែនេះឯងជាកាលខ្មោចស្រី នេះជា
កាលខ្មោចប្រុសហោង ។ រីសិរីវឌ្ឍកសេដ្ឋី មួយអន្ទើទូរអស់អ្នកស្រុក
ជាចំនួយរាមជ្ឈគ្រាមនោះ ឲ្យនាំកាលខ្មោចនោះទៅថ្វាយព្រះមហាសត្ត-
ធិកជវិញហោង ។ កាលណាបើស្តេចជ្រាបសុភាពអស់អាថិរសេចក្តីនោះ
ហើយ កំមានព្រះពជ្ឈហឫទ័យនោះ ជាពេញទូរព្រះអំណាអរក្រៃពេក
ហោង ។

អហំតំ នេះឯងនឹងស្រដីពីការល្បងពស់នោះមិញ ។ អថេ-
កឯវំសំ សប្បញ្ញូ សប្បិនញ្ញូ អាហារបេត្វា អយំ
សប្បោ អយំ សប្បិនីតំ ជានន្តូ អជានន្តានំ សហ-
ស្សន្តេន្តោតំ បហាណីសុ ។ បពិត្រអើយ មានកាលសម័យ
ថ្ងៃមួយវិញទៀតក្រូវ ស្តេចឲ្យពួកជអាមាត្យយកពស់ឈ្មោលនូវពស់ញី
ឲ្យនាំ ៧កាន់សិរីវឌ្ឍកសេដ្ឋី នូវអ្នកស្រុកថាចនយវមជ្ឈគ្រាមថា ស្តេច
មានព្រះបន្ទូលគ្រាស់ឲ្យយើងនាំពស់ទាំង ២ មកកាន់អ្នក ឲ្យអ្នកចាយ
ពស់ទាំង ២ នេះ ឲ្យដឹងជាឈ្មោលជាញី ថាបើមិនដឹងហើយ ព្រះ
មហាក្សត្រាធិរាជឲ្យត្រូវព្រះពាជតំណាំងពាន់ដងពុំលែងឡើយ ។ រីសិរី-
វឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកថាចនយវមជ្ឈគ្រាមនោះ ពុំអាចដឹងថាន
ឡើយ កំទាំពស់នោះទៅដណ្តើងគោធំសត្វអ្នកច្រាំង ព្រះអង្គឃល់ពស់
នោះហើយ ទ្រង់ស្គាល់មួយរំពេចនោះហោង ។ ថានាព្រះអង្គស្គាល់នោះ
តើដោយហេតុដូចម្តេច ថាធម្មតាពស់ឈ្មោលនោះ វាមានកន្ទុយនោះ
ធំរលោងហើយមានក្បាលនោះធំសមនឹងក្អែក មានផ្តែកនោះជុំវិញ ។ រីឯ
ពស់ញីនោះសោត មានកន្ទុយនោះស្តួចក្តាត់ ហើយមានផ្តែកនោះតិច។
មិនជុំវិញឡើយ, ហេតុនោះហោង ទើបព្រះអង្គដឹង ហើយព្រះអង្គច្រាប់

អស់អ្នកផងថា ម្នាលអ្នកទាំងឡាយអើយ នេះឯងជាពស់ឈ្មោល នេះឯងជាពស់ញីហោង ។ អធិប្បាយសេចក្តីនេះ ដូចយើងបានស្រដែមកអំពីខាងដើមនោះឯងហោង ។

ក្កុក្កាដោតិ នេះឯង ទំនស្រដីពីការល្បងមាន់នោះម៉ិញ ។ អថេកទិវសំ ចាតិយរមជ្ឈគាមកសិនោ អម្ហាកំ សត្ថុសេតំ ចាឧំសាណំ សីសក្ខន្ធំ តយោ ឥមាលេ អឧតក្កមិត្វា ឧទ្ធុំ មច្ឆលទ្ធសតំ បេសេត្វា នោ ចេ បេសេន្តិ សហស្សុទ្ធម្ពោតិ សាសនំ បហិណិសុ ។

មានកាលសម័យថ្ងៃមួយ, ព្រះមហាកស្សបត្រាធាតុ នូវគាថាបាទទាំង ៤ ប្រើភជនូតមួយទាំពាតិមានទៅសិរីវឌ្ឍកសេដ្ឋី មួយអន្លើនូវអ្នកស្រុកជាតិនយរមជ្ឈគ្រាមថា ព្រះបន្ទូលពាសេសត្រាស់ឲ្យមកកាន់អ្នក ឲ្យអ្នកកេតាមន្តិលទ្ធសតកាជ ឲ្យបាននាំទៅថ្វាយព្រះជាតដ៏ជាអម្ចាស់, រីឯគោនោះសោត ឲ្យមានទ្វូនោះសល្លបិសុទ្ធអស់ទាំងទ្វូនគោនោះហោង ។ រីគោសោត មិនរិស័យដូចគោទាំងឡាយឡើយ ឲ្យមានស្នែងនោះជុះឯជើង ប្លុះនោះមានឯក្បាល ហើយឲ្យបានស្រែកពេទ្យមួយកក្រើ ៣ ដង មិនកន្ទុចលែងនូវគាលទាំង ៣ នោះឡើយ បើអ្នកបានគោដូច្នោះនាំទៅ

ថ្វាយនោះ [illegible] ដូចន័យព្រះបន្ទូល កំ
ព្រះអង្គពុំអត់ទេតើយ, ហើយទឹងត្រូវតំណាងមួយតាន់ដងពុំខាន
ឡើយ ។ រីឯ[illegible]ស្ដេច មួយសន្ធឹងនូវអ្នកស្រុកធងំតាំងឡាយ មក
ជំទុំពិចារណាតំណាចយល់អាថិសេចក្ដីប្រស្នានោះបានឡើយ ហើយមក
ដល់ពឹងព្រះមហោសថអ្នកប្រាជ្ញ, រីព្រះមហោសថ ព្រះអង្គដឹងពិចារ-
ណាប្រស្នាដោយនូវព្រះប្រាជ្ញាទ្រឹង ឈ្វេងយល់មួយរំពេច ទើបមាន
ព្រះបន្ទូលថា ម្នាលគ្នាយើងតាំងឡាយអើយ, ចូរអ្នកតាំងឡាយដ្រើស
រើសរកមាន់សមរិសុទ្ធបានមួយឲ្យនាំទៅថ្វាយ. ដ្បិតមាន់នោះមានឆ្នាល់
ឯដើងហោង លោកហៅថា ស្លែងឯដើងវិញ; ឯមាន់នោះសោត វា
មានសំរឯក្បាលនោះហោង លោកហៅថា ជួរឯក្បាលនោះវិញ, ឯ
មាន់នោះ វាតែងរងាវមួយយប់ ៣ ដង មិនកន្ធឹងនូវកាលតាំង ៣ នោះ
ឡើយ, ហេតុនោះឯង លោកថាជាគោកេទ័ស្រែក ៣ ដងមួយយប់
វិញហោង ។ រីអស់អ្នកធងំ ក្រាបទូលព្រះមហោសថថាដូច្នោះ ក៏រក
មាន់សល្អចរំសុទ្ធនាំទៅថ្វាយព្រះមហាក្សត្រាធិរាជ ព្រះអង្គជ្រាបហើយ
មានព្រះរាជហឫទ័យជំពេញនូវព្រះអំណរក្រៃពេក ដូចន័យដែលយើង
ស្រដីអំពីមុននោះហោង ។

មណិតំ នេះទំនឹស្រដីតាសល្បង់មណីតេន ។ សង្កេច
កុសរញ្ញោ ធំដ្ឋោតិ មណិកុដ្ឋោ អត្ថិ ។ សោ
អដ្ឋសុ ឋានេសុ វង្កោ ហោតិ អស្ស បុរាណសុត្តំ
ឯត្ថ ។ បតិត្រអើយ, កាលនោះ មានតែមណីរតនមួយអំពីសម្តេច
ឥន្ទ្រាធិរាជ យកមកថ្វាយព្រះបាទកុសរាជ, រីឯតែមណីរតនៈនោះសោត
មានវន្ទនោះរឿង ៨ ស្លាន, មានតន្ទីស្មើនោះគ្នីរុងរឿងល្អឆ្អែតត្រចះត្រចង់
មហិមាក្រៃពេក, ឮដំកាលនោះ រីឯព្រះចស់អំពីបុរាណជាច់បងនឹងវង្សឯង
ឃ្លាហើយ ឥតអ្នកឯណាមួយកំនឹងកាចឆ្លើះខ្សែស្រួតព្រះចស់អំពីបុរាណនោះ
បានឡើយ ដ្បិតវន្ទមណីរតនៈរឿងច្រើនអង្វែ ហើយទឹនឹងម្ចាំខ្សែស្រួតថ្មី
ដើម្បីទឹនឹងបញ្ចូលទៅក្នុងវន្ទបោះមណីរតនៈនោះបានឡើយ ។ មួយសោត
មានសម័យថ្ងៃមួយនោះហាង ព្រះមហាក្សត្រចង់ល្បងប្រាជ្ញាព្រះ
មហោសថអ្នកប្រាជ្ញ ក៏ព្រះអង្គប្រើកដអាមាត្យនោះនាំតែមណីរតនៈនោះ
ទៅកាន់សីវីខ្លាក្រសេដ្ឋីប្រាប់ថា ព្រះបន្ទូលពាសេសត្រាស់ឱ្យយើងនាំតែ
មណីរតនៈនេះមកកាន់អ្នក ឱ្យឆ្លើះខ្សែមណីរតនៈអំពីបុរាណចេញ ហើយ
ឱ្យយកខ្សែស្រួតថ្មីបញ្ចូលកងបោះវន្ទមណីរតនៈវិញបាន ថាបើបញ្ចូល
ពុំបានទេ ព្រះអង្គនឹងឱ្យត្រូវព្រះតំណាំងមួយពាន់ដង ។ សីវីខ្លាក្រសេដ្ឋី

ខ្ញុំវិអស់អ្នកផងទាំងឡាយ សឹងតុំអាចដើម្បីនឹងយកខ្សែសូត្រចាស់ នឹង
ផ្ទាស់យកថ្មីបញ្ចូលតុំបានឡើយ ទើបអស់អ្នកផងទាំងឡាយ សឹងតែ
បបួលគ្នាទៅកាន់សំណាក់ពោធិសត្វ ក្រុងប៉ារ៉ាណាសី ក្រាបបង្គំទូលដោយដំណើរសេចក្តីត្រង់ហើយ
ព្រះអង្គតិចារណាទូវព្រះក្រែងជ្ញាទិព្វវិសេស យល់ដោយទូវកិច្ចបញ្ចូលខ្សែ
កងច្បាប់មណីរ័តន៍នោះឲ្យបានទាំងងាយប្រាកដក្តាត់ហោង ។ ទើបព្រះ
មហាសត្វ ព្រះអង្គមានព្រះបន្ទូលថា ម្នាលគ្នាយើងទាំងឡាយអើយ,
កុំបីអស់គ្នាយើងគិតឡើយ ចូរឲ្យអញឯងនឹងបញ្ចូលខ្សែមណីរ័តន៍នេះ
ឯង កុំបីឲ្យគ្នាយើងព្រួយបារម្ភអ្វីឡើយ ទើបព្រះអង្គឲ្យទឹកឃ្មុំមកលាប
ស្រាលបន្ទូវខ្នាច្បាប់មណីរ័តន៍ទាំងសងខាងស្រួចហើយ ព្រះអង្គឲ្យវៀញ
ខ្សែច្រាលរួចល្អ, ហើយឲ្យយកទឹកឃ្មុំមកលាបឯចុងខ្សែសូត្រនោះ
ហើយបញ្ចូលខ្សែនោះត្រង់ខ្នមណីរ័តន៍ស្រួចហើយ ឲ្យទាំងៗដំកល់ឲ្យដ៏
រឹងស្រួចមោចតែនឹងវ៉ារចេញចូល, រីឯស្រួចមោចផងទាំងឡាយ កាលណា
បើវ៉ាងុំក្នុងទឹកឃ្មុំ វ៉ាវ៉ារចេញមកទាំងទាំងខ្សែសូត្រចាស់អំពីបុកណានោះ
រួចចេញអំពីក្នុងរន្ធនោះស្រឡះហើយ វ៉ាមកតាំងាំខ្សែសូត្រថ្មីនោះ ក
ខង់ចាញត្រង់ចូលមួលទៅក្នុងរន្ធនោះ លេចចុងខ្សែចេញមកឯខាង
ម្ខាងវិញហោង ។ កាលនោះ ព្រះមហាសត្វអ្នកប្រាជ្ញដ៏ធំថា

ស្រេចទាំងពាំនាំខ្សែលចេញដូច្នោះហើយ ព្រះអង្គចាប់យកមណីរតន៍
នោះមក ហើយទើបឲ្យទាំងទៅថ្វាយព្រះមហាក្សត្រាធិរាជនោះវិញ។ ហាន
មើបស្តេចស្រែបថា ព្រះមហាសព៌ជ្ញកង្ហាដ្ឋ អាចបញ្ចូលខ្សែក្នុងច្បាស់
មណីរតន៍បានដូច្នោះហើយ ក៏មានព្រះហឫទ័យនោះដឹងខ្លួនព្រះអាំ
ណាអស់ក្រៃពេកហាន ។

វិជាយនដ្ឋិ នេះទីឆ្នាំស្រដីពីការល្បងប្រសូតកូននោះមិញ ។
ឯកធិវសំ កាល រញ្ញោ មង្គលឧសភំ តម្ប កុម្ភា-
សេ ទាសាបេត្វា មហោទរំ កត្វា វិសាលាយ ណោ-
វិត្វា តេលេន មក្ខេត្វា ហាលិទ្ទិយា នហាបេត្វា
តាមកាសីនំ បេសយឹសុ ។ ល ។ បពិត្រអើយ យើង
ខ្ញុំនឹងរៀបរាប់មកថា មានកាលសម័យថ្ងៃមួយ ព្រះមហាក្សត្រាធិរាជ
ស្តេចឲ្យយកគោមង្គលឧសភាជ ចងក្បាលវិធីផ្ទៃសណ្តែកច្រើន ធ្វើឲ្យ
វាហើមផ្ទៃពោះធំក្រៃ ហើយឲ្យពួតប្តែងគោនោះឲ្យលើង ហើយយក
ប្រេងលាបរលោងបំព្រងឆ្អឹង ហើយទើបយកមេគន្ធតជូតអស់ពាំងខ្លួន
គោ ឲ្យមានសម្បុរលឿងល្អ ហើយស្តេចឲ្យទាំងទៅកាន់សំរីរាង្គក្រសែដ្ឋ
ទូរអស់អ្នកស្រុកជាច័ទយវាទជ្ឈាមថា មានព្រះបន្ទូលពាសេសត្រាស់

ប្រើឲ្យយើងនាំគោនេះមកកាន់អ្នក ដ្បិតគោនោះមានគតិថាស់ឆ្អែហើយ
ស្មមន៏ឯងប្រសូតកូន ចូរអ្នកឲ្យក្សាគោនេះឲ្យប្រសូតកូនចេញឲ្យល្អ ហើយ
ឲ្យនាំទៅថ្វាយចាំងជាចាំងកូនគោនោះឯង, បើអ្នកឲ្យគោនេះប្រសូតកូន
ចេញបាននាំទៅថ្វាយ កំជាការឥតខោស, បើប្រសូតកូនពុំបាន ខ
ព្រះអង្គន៏ឯងឲ្យត្រូវព្រះរាជទណ្ឌជាដំណាំងមួយពាន់ដង ពុំមានឡើយ ។
សិរីវឌ្ឍកសេដ្ឋី ខ្លាអស់អ្នកស្រុកជាច្រើនយ៉ាមជ្រាមដំនុំគិតពិចារណា
ថា យើងឯងឡូវនេះ មហាក្សត្រាធិរាជ ព្រះអង្គឲ្យយកគោឈ្មោល
មកឲ្យយើងរក្សាឲ្យមានកូន ធ្វើម្តេចនឹងបានកូន ខ្លះថា អើអញឆ្លៀវដែរ
ហ៎ះ ខ្លះថា បើខ្លួនឯងនៅឯណាស់ហើយ តើហេតុអ្វីកំមិនទៅរក
លោកអ្នកជ្រាបវិញ ? ទើបសិរីវឌ្ឍកសេដ្ឋីឮ ហើយ ស្រដីប្រើប៉ើរឲ្យទៅ
ហៅព្រះមហាសត្វអ្នកជ្រាប មកនឹងដណ្តើនហេតុអាថ៌សេចក្តីនោះហោង
ទើបអស់អ្នកភាំងឡាយស្តាប់ហើយ ម្នីម្នាលេះរលាំងទៅកាន់សំណាក់
ពោធិសត្វ ហើយដំណាលដំណើររឿងថ្លាប់សព្វគ្រប់ ទើបពោធិសត្វអ្នក
ទៅយល់គោនោះហើយ ព្រះអង្គពិចារណាអាថ៌ប្រស្នាដូច្នេះហើយក៏រៃគិត
តបជាអាថ៌ប្រស្នាទៅវិញទើបបានអេះ ។

(នៅមានត)

រឿងមរណាមតា

(តមក)

លោក ប៉ែ សុវណ្ណ ចម្លងពីសាស្ត្រាស្ទឹកតែ

សុភមេរយ មជ្ឈប្បមាទដ្ឋានា ឲ្យវៀរចាកតិរិយា គឺធឹកស្រាទឹកស្រវឹង ។ ភនាំឲ្យចិត្តហ៊ាន ឫតវិញ្ញាណសោះសូន្យឈឹង ប្រមាទឃ្លាតចិត្តឹង ខឹងវង្វើងចិត្តតិរ្ថិយ ។ កុដុម្ពីក៍ទទួលសីល ឥតមន្ទិលពីសីល ថាចាំគ្រប់ ឫសី សេចក្តីប្រែមិនមានសល់ ។ ស្រេចហើយព្រះឥសី ប្រើកុដុម្ពីក៍ ជ្រួចទឹកទស· ស្នោកជម្រះអស់ កម្មវេរជាបច្ច័យ ។ ចូរឲ្យាម តាំងបីខាក់ ចាំឲ្យជាក់តែសព្វថ្ងៃ តាំងចិត្តឲ្យប្រពៃ ឲ្យបរិសុទ្ធក្នុងអាត្ម ។ តាបសឥសីសិទ្ធ តាំងប្រព្រឹត្តឲ្យសីល ស្រេចហើយលោកគត្តា ថាអាត្មាចំរើនពរ ។ លាឲ្យាមទាំងបីទៅ ទីលំនៅព្រឹក្សាករ ថាហើយអ្នកក្រោកឈរ ប្រែព្រះក៍ក្តៃព្រៃហិមពាន្ត ។ ដំណើរដើរស្រេតតំ តំយោបថល្អកគ្នាន ស្រេចចរចេញចាកឋាន ចូលព្រឹក្សព្រៃទីបព្វត ។ ក្រោយព្រះឥសីទៅ ទីលំនៅព្រៃព្រឹក្ស កុដុម្ពីក៍ចងចិត្តា ចាំសីល ៥ មិនផ្សេងភ្លេច ។ ជាស់ខឿនកូនប្រពន្ធ ឲ្យទឹកគុណសីលកុំជាប់ សព្វថ្ងៃ

មិនមានភ្លេច ចិត្តគាចខ្ចប់ចោលស្រឡះ ។ កុដុម្ពីក៍ចានសាន៍ផល
សីលកុសលពីមុនក្រាស់ ទើបចានជួបប្រទះ ព្រះឥសីមកខ្ចាន ។ ឲ្យ
តាំងកន៍សីល ៥ ខ្ចាប់ចន៍ចាំដឿក្នុងក្រាណ មិនចាត់បន៍វិញ្ញាណ ជា
ប្រក្រតីសព្វទំវាំ ។ ទើបកុដុម្ពីក៍កាលី នាំកូនស្រីបរិភោក្តា ស្រេចកាប់
ឈើធ្វើជា ខួមអាស្រ័យនៅទំនោះ ។ ហើយកាប់ចំការដាំ យកពូជ
ត្រាំជាំជាក់ដុះ ម្ហូស្ងូវីជាំបុះ ដើមល្អណាស់ដោយជាតទឹក ។ ជាំស្រូវ
ស្លែឃ្លោកល្ង សណ្តែកត្រសក់ឥឡឹក ប្រៃកូនឱ្យស្រោចទឹក ជាំត្រ
ឡាចស្លាស្លែ ។ កាលីដើរទៅលក់ សព្វភូមិស្រុកត្រាន់អាស្រ័យ
កុដុម្ពីក៍នៅចាំដៃ ដំរេះស្មៅដំណាំផន ។ ដំណាំផ្លែពុំខ្វះ នោះកាលី
រឿចផ្គុផ្គង ខួលៈទៅលក់សព្វជន ចានជាច្រាកទិញគោក្តា ។ រីឯអស់
អ្នកស្រុក ចូលតគ្រុកច្រើនត្រៀបត្រា សុំទិញអស់ផលា ផ្លែត្រសក់ឥឡឹក
ស្លែ ។ លុះចានឃើញកាលី មានកូនស្រីរូបល្មមស្មៃ កត្តាស្រស់ប៉ៃប្រៃ
ថ្លាត្រចង់ដួចវង់ខែ ។ មានចិត្តចាប់ស្រឡាញ់ អរអស់អញ្ជាតិតបៀត
ចែរ សាកសួរកន្ទាំខែ ចង់ចងតន្ធមួលមេត្រី ។ អ្នកស្រុកមានកូន
ប្រុស ពាលកម្ងោះស្រស់ច្រមប្រិយ កុដុម្ពីក៍មានកូនស្រី រូបល្អល្អះសាក់
សមគ្នា ។ ដណ្តឹងចានដួចចិត្ត ព្រមគ្នាតិតរកវេលា សង់ផ្ទះការ
បុត្រក្ងា ចានពេលក្រាចសំពះ ។ សន្ធានញាតិខាងប្រុស ច្រើនច្រួន

ប្រុះចង្រៀតផ្ទះ ប្រុសស្រីតាលក្មេងចាស់ មកជួយការជុំកុះករ ។ រួចលើកចំណងដៃ ទ្រព្យថោកថ្លៃមកឈូសឆាយ ញាតិខ្វះជាអ្នកក្រ គ្មានទ្រព្យអ្វីនឹងចងដៃ ។ យកដើមស្វាយដូងគ្នោត ញាតិខ្វះសោតកំមានដៃ ឈើតាលមកចងដៃ គ្រាន់ទុកជាធ្វើចន្ទុះ ។ ខ្វះចង្កឹះបីគោ សេះដំរីកិនចង្រិះ ញាតិខ្វះតាបច័ល្លតុះ យកតន្ទុងលបចងដៃ ។ ញាតិខ្វះនៅស្រុកលើ ទំស្រួតដើរនឿយល្ហិតល្ហៃ យកកេរចងដៃ ឃ្លានពីលើកគ្នាដប់នាក់ ។ រួចលើកស្តុកមកវៀប ដង្កែត្រៀបតាមយស ស័ក្តិ នាម៉ឺនរៀបតុង្រាក់ ចំណីខ្វែមសិនង្រាំដាន់ ។ គ្រៀកពស្ត្រ អ្នកគ្រាន់បើ សិនយាំងស្ទើរដាក់តុស្តាន់ រៀបសិនជាបីដាន់ តាមសណ្តាប់ស៊ីថ្នាក់ក្រោម ។ ញាតិឡាយអ្នកតាល់តាប ទុំវិលការរៀបយ៉ាងល្អម តុស្តាន់ទីឆាទនតោម ង្រ្កាំមួយស្តុកជួប ។ គ្នា ។ អស់ញាតិតាំងប្រុសស្រី តាស់ក្មេងក្តីន្ទ្រព្រះតញ្ជា អ្នកមុខអ្នកមានដារ រៀបស៊ីផឹកត្រេកអរលន់ ។ ស្រេចហើយវិលលាទៅ ទីលំនៅស្រុកជំបន់ កុដ្ឋម្ចាស់ការក្មេងតន់ ស្រេចសុរោមង្គលការ ។ កុដ្ឋម្ចាស់ជាទន្ទុះថ្មី នៅប្រក្រតីជួរចិន្តា ជាទាំងកូនប្រសារ ជា ៤ នាក់គ្រាន់តក់ក្តៅ ។ តាំងតែពីថ្ងៃនោះ ឥតមានមោះឥតហ្មងសៅ កុដ្ឋម្ចាស់កាលីនៅ ជាស្រុកខេសក្តែអាត្មា ។

ន័យនេះនៅនី- ពាន្យៅអំពី បរមត្ថត្រា វិមលបពិត្រ ព្រ
ះពុទ្ធត្រៃវិត្រា កាលប្រើអាជ្ញា តំឃាដជីវិត ។ ឱាឯចន្លុណី ស្រេចព្រះ
ចក្រី បរមបពិត្រ ត្រាស់ហៅអាមាត្យ មួយមានតំនិត តំនាប់
តាប់តិត ល្អល្អះចិត្តា ។ ជាចៅក្រមធំ ពុកតែងជំនុំ ក្តីកងនគរ
អស់រាស្ត្រតាំងឡាយ សប្បាយគ្រប់គ្នា ព្រោះចៅក្រមជា ជំនុំក្តី
ស្អាត ។ ទើបស្តេចត្រាស់ប្រើ បង្គាប់ចៅលើ អនុជិតអាមាត្យ
ឲ្យជាចៅក្រម ជំនុំតាមខ្នាត តិនិត្យឲ្យស្អាត កុំពោសអគ៌យាយ ។
ខ្លួវពោសកុដ្ឋិក៏ កាលិទ្ធិ ជាអាពុកម្តាយ មេចន្លុណី អប្រិយ
អន្ធពាយ អាមាត្យនេនាយ ខ្លួលនង្ហែរ ។ ក្រាបលាវរចុះ ដើរចៅ
ចំពោះ ឡើងលើសាលា នាហ៊ឺនធំតូច ដួបជុំគ្រឿបគ្រា ទើប
អាមាត្យ ប្រើឲ្យចៅកោះ ។ អ្នកអគ៌ជាធំ យកមកជំនុំ បម្រើ
លាចុះ ដើរដល់ពោះនាថ់ ប្រញាប់កាលខោះ អ្នកអគ៌រត្រាកចុះ
ពីផ្ទះយាត្រា ។ ស្រីឆ្នាំរតាំងឡាយ ដែលហែអគ៌យាយ ក័យស្តុត
ពាល់គ្នា អ្នកអគ៌ដើរដេរ់ មណ្ឌលហើយណា ឡើងលើសា.ហ
អង្គុយនៅនី ។ អាមាត្យសួរថា អ្នកអើយក្សត្រា ជាម្ចាស់សិរស
ស្តេចឲ្យបុណ្យសិក្តិ ពិភ័ក្ត្រនារី រក្សាទេវី វរទត្តិយា ។ មេចយាយ

ប្រហែស ត្រងើយធ្វើធ្វេស ព្រះកដឹតា អង្គអគ្គមហេសី សិរីទត្តិយា
មណាមាតា បរមបពិត្រ ។ ទាំងឆកទៅ ទីណាហ្នឹងសៅ ដល់
ក្បែយដីវិត ចេះចូរអ្នកអស់ ធ្វើយមកដោយពិត អញទឹងពិនិត្យ តាម
ពេសនោះណា ។ អ្នកទាស់កិតភ័យ សំពះញ៉ែដៃ ជម្រាបភៅថា
តាមដោយតន្ទឹង ខំឯអតីតា ជួបជុំនតណិនា ពីមុខមកស្រាប់ ។
អនុដឹតអាមាត្យ ជំទុំគិតស្ងាត ឃើញហើយថ្ងៃឆ្ងាប់ ថាតាមមាត្រា
ទង្គារប្រញាប់ អស់ឯងពុំគាប់ ពុំគួរទៅជ្រុលណា ។ ទាំអគ្គមហេសី
ចេញចាកបុរី បរមក្សត្រក្សត្តិ ស្តេចវិលមកដល់ មណ្ឌលកដហាន
អស់ឯងពុំជុនន រៀងខ្លួលក្សត្រថ្ងៃ ។ ពេសនោះជួនក្តាត់ ឮប្រត្រាំ
កាត់មាត់ កាត់ដើងកាត់ដៃ ពេសមួយទៀតជួន ពេតពាន់ក្រៃក្រ ទាំ
មហេសីថ្ងៃ ចេញពីកដកំង ។ ឥតតិចាណា ពុំជុនក្សា ប្រហែសក្តេច
ភ្លាំង បះណ្តាយមហេសី លុះក្តីមណាំ ពេសនោះហៅភ្លាំង តាមដោយ
មាត្រា ។ ត្រូវឲ្យតិយាជ បំបាត់ជន្មជាតិ ចេញចោលអសារ អ្នកទាស់
កិតភ័យ ពេតក្រែមហិមា ទឹកមុខស្រាប់ជា ខ្លួនហាស់ម្ល៉ះហើយ ។
ទើបលាទៅផ្ទះ តាំងចិត្តជម្រះ ខុទ្ទកោកជានស្បើយ រក្សាសីលសុទ្ធ
ស្រគត់ត្រងើយ យកសីលជាត្រើយ ទីតំងអាត្ម ។ ហើយចាយទ្រព្យ
ជន ឲ្យទានធ្វើបុណ្យ សព្វទិនទីពាំ កូនស្រីអស់នោះ នាមឈ្មោះ

ធម្មា ខេវីជាតិជា សៅឡឹកក្សត្រថ្នៃ ។ ចានដ៏ងាម្ដាយ តិតពុំសប្បាយ
មានទោសដល់ក្សីយ ព្រោះខាងសាវិកា ធម្មាទីងក្រៃ គុំគួន
សព្វថ្ងៃ ព្យាបាទពុំស្បើយ ។ អនុជិតអាមាត្យ រកទោសមួយស្អាត
ទោសមួយទៅឡើយ គឺទោសកុដ្ឋម្ដិក កាលឥតត្រើយ ដំនុំឃើញហើយ
ឡើងខួលក្សត្រា ។ ដល់ហើយចង្កឹំ ខនអង្គប្រណម្យ ក្រាបខួល
ទៅថា ត្រាស់ប្រើយើងខ្ញុំ ដំនុំកាក្យ ទោសទាំងខ្ញុហា ពុំចេរ
ក្សត្រថ្នៃ ។ រីទោសអ្នកអកំរ ចានឲ្យហៅមក ដំនុំវិនិច្ឆ័យ តាម
ច្បាប់ត្រូវកាត់ ខ្លួមាត់ដើងដៃ ទោសមួយធ្ងន់ក្រៃ លុះដល់ជន្មា ។
កុដ្ឋម្ដិក—កាលី បញ្ជោតមហេសី ព្រះចានពកជា យកទៅសម្លាប់
តាមច្បាប់ត្រូវជា ពិយោជជន្មា ច្រាំពីរសន្ដាន ។ ស្ដេចស្ដាប់ត្រាស់ថា
អើទោសម្ដេចម្ចា ធ្ងន់ស្រាលប៉ុន្មាន ចូរធ្វើតាមទោស សន្ដោស
ពុំចាន ដំនុំរ៉ះធ្ងាន ឲ្យត្រូវមាត្រា ។ អនុជិតអាមាត្យ ក្រួញក្រាច
បខច្ចេ ខខួលខង្ការ ស្រេចហើយចង្កឹំ ប្រណម្យក្សត្រា លាវិល
សាលា ដំនុំប្រក្រតី ។ ដល់ហើយអាមាត្យ បង្គាប់ពេជ្ឈឃាត
ខ្លួមុខមន្ត្រី ទៅចាប់កុដ្ឋម្ដិក ចងខ្លី កាលី ខ្លួញាតប្រុសស្រី ច្រាំពីរ
សន្ដាន ។ កោះទាំងមេស្រុក ស្ងងាសកុំខុក ភ្នាក់ងារប៉ុន្មាន
កងឆ្មាំពេញានក កោះយកឲ្យចាន ទាំងអស់កុំខាន នាំមកឲ្យទាប់ ។

រីឯកុដុម្ពីក៍ កាលិចន្ទី ជាក់ក្តីឲ្យជាប់ តាមព្រះទង្វើរ ក្សត្រាបង្គាប់ ថ្វីរៀបប្រញាប់ កុំធ្វើរេរ ។ ហើយគោះចៅហ្វាយ ស្រុកខ្លួន អន្តរាយ ចាំងស្មៀនភ្នាក់ងារ យកមកដំនុំ ទិតទំស្រាវ តាមព្រះទង្វើរ ក្សត្រក្បាន្តចមចៅ ។ អាជ្ញាចុងស្តាប់ ខន្ធួលបង្គាប់ លុតលាចេញ ស្រាវ ភ្លាចព្រះបម្រើ ទំដើរលឿនស្ទាវ តាត់ប្រតស្រួតចៅ តាសិកវដ្ឋា ។ កាលីកុដុម្ពីក៍ ត្រង់ចេញចោលទី ចោលស្រុកអាត្មា ត្រាយញាតិសន្តាន ត្រឿងលានបណ្តា - ពស្តើរក្សេពល់គ្នា មិនដឹងខ្លួនសោះ ។ ត្រឹកត្រាងស្តួច ភ្លាក្លាក់ចុះដី ចុះដើរចៅឆ្ពោះ ដល់ផ្ទះកុដុម្ពីក៍ ឃើញទីផ្ទះនោះ ផ្ទះចៅស្ងាត់សោះ តុំឃើញតុំឃល់ ។ អ្នកស្រុកតិយតិត បបួលគ្នាគិត ជំនុំរេលំ ខ្លះថាទេអញ តិតពេញហៅទួល ហេតុម្តេចក៏យល់ ក្បាលភ្នេចទៅនោះ ។ ភ្នេចប្រុសឬស្រី ទោសនោះពីអ្វី តំស្ទាប់ដូច្នោះ កុដុម្ពីក៍ត្រង់ចាត់ ចោលផ្ទះស្ងាត់សោះ ខ្លះស្តាប់ជាទុះ មិនដឹងទេអ្វី ។ ខែអញស្គាល់ជាក់ ពិនិត្យជាក់លាក់ ភ្នេចភ្លេចកាលី ភ្លេចឫងគាត់នោះ ឈ្មោះចន្ទលី ហើយចុះកុំស្តី យើងទៅមិនជា ។ រកវៀបត់ចេញ ពីស្រុកនោះវិញ ចាកចោលគ្រឹហា ស្រីខ្លះរៀបខ្សៀវ កិះកៀវច្រាប់គ្នា កុំឲ្យរេរៀបត់រីរើយ ។ ឯកាលិណី ជាបងកាលី ទៅស្ងៀមកន្តើយ ទើបភ្លាក់

តាដេក ក្រខ្លែកមើលហើយ សួរថាអ្នកមើយ រៀបរត់ទៅណា ។ គេឆ្លើយប្រាប់មក ថាយាយទៅរក មើលផ្ទះលោកតា កុដុម្ពីន៍ជិតជិត ដំណឹងកិច្ចការ កាលណាយា ក្រោកក្រែះដើរទៅ ។ ដល់ផ្ទះកុដុម្ពីក មើលមិញយើញទី ស្ងាត់សូន្យហ្មងសៅ ដើរដល់ចូលជិត តាមិត្យ មើលទៅ យើញក្បាលខ្មោចនៅ លើផ្ទះគាលី ។ ខើបកាលណា ស្គាល់ជាក្មេងស្រី ភ្លាត់មាត់ថាយ៉ា មេចនូណា ម្តេចក្បុយជីវ៉ តិត យើញថាយ៉ា អញនៅមិនបាន ។ ម្ហូរវិលមកផ្ទះ យកសំពត់ផ្ទាស់ ស្បៃកខ្លាប់ប្រុងប្រាណ រៀបវេចរបស់ អម្រស់ធនធាន ស្បៀងតិចតួចបាន តញ្ជើជាក់ខុក ។ ហើយចូលកន្លឹយក ហិបស្វាបានមក អង្រែត្បាល់ប្រុក រៀបហើយជាក់ស្រេច អំបិលប្រហុក លើកចេញមកខុក ពានហាលនោះកូវ ។ ចាប់យកតញ្ជើ អង្គុលលើ រត់តាមគេទៅ ពាក្យចសំពាយ អន្តរាយចោលនៅ រត់តាមគេទៅ ខើបតិតអនិច្ចា ។ ថាឧកាលី រត់ចោលឯស្រី ឲ្យស្វាប់អសារ ហន រត់តែខ្លួន ទៅតួនឪណា តិតដើមតិតថា ស្វាប់ផងសៅផង ។ អញ ស្មានជាពិត ម្តេចឡើយប្រែចិត្ត ប្រែចេញចោលឯង ឲ្យស្វាប់តែឯង កន្ទែងកន្ទង ស្តីហើយយំឯង តេច ។ ដើរទៅ ។ គេរត់ចោលចាត់ ម្នាក់ឯងស្ងប់ស្ងាត់ រង្វើងសៅដៅ ភ្នែតមាត់ក្អែក សម្រែកតាវៅ

ស្មានជាគេហៅ ចំរត់ម៉ឺម្ចា ។ ឯអស់កម្លាំង ទៀកស្លុតគាំង មាត់តែ
ខំតា ជញ្ជក់ជញ្ជប់ តែមាត់ទទេ ជំងឺជាគ្មានស្លុះ ទើបរកពុទ្ធា ។
ដោយចាស់ហើយវត់ កម្លាំងតិចហត់ អត្តិយជ្រងោ ជង្ហើមតិចណាស់
ហេតុចាស់ខ្ទុំជោរ គិតឃើញថាខ្ញុ អញក្មេចសំភាយ ។ ក្មេចហិបត្បាល់
បុក ចាន់អ្វីជ្រលក់ ស្លាស៊ីខ្មុកាយ ខុកម្ចាន់ហាន់ តាមចាន់មិនឆ្ងាយ
ក្មេចគាំងសំតាយ សំពត់ដណ្តប់ ។ កាលនៅគ្រឹហា ម៉ើល្ងាចកាល
ណា រដាំចំប្រប់ ឥឡូប្រៃស្រាយ យកព្រៃជាម្ហូប ចាន់អ្វីដណ្តប់ រដាំ
ជាច់ឡាល់ ។ ម៉ើទៅឯផ្ទះ ជួនជាតើបពះ អាជ្ញាមកដល់ វាយកទៅ
កាប់ សម្ងាប់គ្នាខសល់ តែតួនជាច់ឡាល់ ស្លាប់ទឹងរដាំ ។ អត្តិយ
សញ្ជឹង គិតសត្វមិនដឹង ទៅណាមកណា គិតម្តងថាខេះ កុំរិះខេវ
ទៅផ្ទះយើងជា ចាន់ឈ្លួតដណ្តប់ ។ គិតហើយក្រោកដើរ ក្មេចយក
កញ្ជើ ទៅរៀបលាន់លប់ ស្រូតរូតទៅផ្ទះ លលះគ្នាន់ឈប់ ដើរដួល
ជំពប់ តើបទឹងអាជ្ញា ។ តីនាយពេជ្ឈឃាដ ដែលពាដអាមាត្យ
ប្រើមកនោះណា បណ្តើរគ្នាហៅ ចិនខ្មែរយួនភ្លា កាលីណាយ
ឃើញហើយគិតភ័យ ។ តែវិលទៅក្រោយ ហាត់ហេតុព្រោះដោយ អត់
ចាយកាលថ្ងៃ ដើរដល់កញ្ជើ ក្អែកហើរកេងព្រៃ ក្រញ្ជៀវពេញ
ព្រៃ ចឹកស៊ីអង្គរ ។ កំពប់គាល់អស់ គ្មានសល់តិចសោះ ដោយ

ជីកកគរ គាស់ដើរដល់ ឃានយល់ហើយឈរ យកដៃគក់គរ ទ្រូង
យំក្តែង ។ ។ ទុអញសម្លាប់ គិតទៅជាគាប់ ប្រែទុសច្បាស់ខែង ឃ្លាន
ឃាយជាប់ខ្សែ គោះហសម្លាក់ឯង នេះគឺកម្មត្រង់ តាមពាន់ថ្នូ ។ ។
ជាហើយទុនចុះ រើសអង្គរខោះ ពាំដ៏ស្មៅពាំដ៏ ឃានមកមួយក្តាប់
ចាប់ស៊ីពាំដ៏ លើកអកខ្សែដ៏ខ្លី គ្មានឆ្នេញទំពា ។ រៀបលេច
ទឹកមាត់ ឃ្លានឃាយពេកក្តាត់ ស្មើក្រយជន្លា ដើរទៅដើរមក
ជ្រុលជ្រកវេក មិនដឹងទៅណា ឲ្យឃានឃាយស៊ី ។ គេះគំហែល
អស់ មិនឃើញជានសោះ ស្មៅគ្មានវាក់ រ គេទៅផ្លូវណា ពាំដ
ពាក់ពួនខ្លី ណាឃាត់ជានឆ័ នោះខ្មៀតទៅហើយ ។ គាស់ណីយំ
គក់ទ្រូងស្ទើក្រំ ម្នាក់ឯងស្លើយ ។ លន្ទោចខ្ទោចផ្សា ឥតការឥត
ត្រើយ ទំដើរទៅហើយ ឈ្លោកជានគន្លង ។ អង្គរមួយក្តាប់
បៀមគ្រាន់ជញ្ជាំ មាត់លេចម្តង ។ កម្ចាំងតិចតាច ដុនជាបកន្លង
ដើរហើយយំនង គេចថ្បាបអប្រិយ ។ គឺកម្មគាត់ឯង ព្រោះចិត្ត
រាឡង ប្រមាថក្បត្រ៍ មរណាមាតា ព្រះមហាមហេស៊ី តាមពាន់
លោកិយ ឲ្យរងវេទនា ។ ទំដើរមួយថ្ងៃ គោះជាក់សន្ធៃ ដើរ
ដួលច្រើនគ្រា លុះដល់ត្រលាំ មិនឃើញវេក ទើបជានជួបគ្នា ព្រឿង
លានទាំងឡាយ ។ ដើរដល់ដួលដេក ដួលជាបន្ទេចក្តែក ស្ទឹង

ស្ទឹតក្នុងកាយ អស់ព្រឿងសាច់ញាតិ ខ្លីឃ្មាតខ្លាំងក្លាយ ហៅឲ្យហូប
ចាប ផ្អែមហើយដឹកទៅ ។ រីឯភេជ្ជឃាត ចំដើរខ្លីឃ្មាត បាន
ដល់លំទៅ ទៃត្រកូមិកុដុម្ពីក យើញខ្ចីហូនទៅ បាត់មនុស្សអស់ទៅ
ទៅផ្ទះស្ងាត់ឆេង ។ យើញតែគ្នាតក្អែក កន្ត្រៀវស្រៀវស្រែក ចឹក
ឆ្នាំងអំបែង ជ្រូកក្តាន់មាន់ទា ផ្អែមឆ្ងាញ់ព្រុសលូវល្វីយលូវ
ស្រែងស្ងប់មហិមា ។ ភេជ្ជឃាតមើលយល់ ទីតាំងមណ្ឌល តុំមាន
មនុស្សម្នា ប្រើពលដើរកេ ក្រែងជ្រកតួខគា ខ្លះខ្លីឆ្កែហា
យល់ស្ងាត់អស់ក្តី ។ ជម្រាបនាយថា តុំចេរមេត្តា ទើបកេថ្ម ។ ក្តក់
ក្តើឆ្កែគុកក្តៅ រះណ្តៅទៅដី ស្នាមដើងថ្ម ។ ទើបភៅតិចសោះ ។
នាយបើកអំណាច ថារើយកុំភ្លាច រិបរើឲ្យអស់ កុំមានមេត្តា ករុ
ណាវាសោះ ជំណាំតាំងអស់ តាមតែពាល់គ្នា ។ ភេជ្ជឃាតតាំង-
ឡាយ រត់ចូលប្រញាយ ចាប់ជ្រូកមាន់ទា ចាប់គោក្របី ដំរីពាល់គ្នា
ខ្លះខ្លីឆ្កែបេះស្មា បេះដូងដឹកទឹក ។ ខ្លះចូលខៀនចិន យកបានឥដ្ឋឹក
ចាក់ស្រោលើកផឹក គាប់ចេកខ្ទះស្ងោយ ប្រញាប់ប្រញឹក ខ្លះចុះដងទឹន
លានឆ្នាំងដាំចាយ ។ ឆ្កែជ្រូកមាន់ទា ស្ងួតាំងញាំភ្លា លើកជូនចៅ
ហ្វាយ រួចហើយពាល់គ្នា ផឹកស្រាសប្បាយ ឆ្លាដៃនិយាយ ទឹកមាត់
ហូរខ្ជាត់ ។ មិនគិតអនិច្ច កំណើតអ្នកស្រា អ្នកស្រែជួយតិ

មកជួមជួលធ្វើ ចំរើនមាគ្ស ផ្លាប់តែសង្វាត គ្រាន់តែធឹកស្រា ។
នាយធំសម្រេច គោក្តារួចស្រេច ដំនុំពជការ ថាយើងចំរើ លោក
ប្រើអាត្មា ចេញមកចាប់អា អ្នកខេសចាំងអស់ ។ លោកប្រើប្រញាប់
ត្រូវចាប់ឲ្យចាប់ ត្រូវកោះឲ្យកោះ ឥឡូវដឹងខ្លួន រត់ពួនចាំងអស់
យើងគិតពិគ្រោះ ធ្វើម្តេចចាប់បាន ។ នាយមួយឆ្នើយថា យើងតាមកេវ
ទីឯរត់ប៉ុន្មាន ស្លាក់រកបានតិច ៖ តេចចាប់បាន នាយធំឆ្នើយថ្លង់ន
ថាខេមិនជា ។ ស្រុកនេះព្រៃធំ ព្រៃជិតដើងកុំ ឯងដឹងផ្លូវណា វាជាស
ដេញតាប់ ឯងស្លាប់អស្សារ ចោលខ្លួនឯងា ខ្លួចក្តីមិនខាន ។ នាយ
មួយឆ្នើយស្មោះ ថាបើដូច្នោះ ធ្វើម្តេចចាប់បាន រឹលខេទេ ព្រៃធំខុស
ខ្លួនច្រាណ យើងមិនអាចហាន រិះគិតយ៉ាងណា ។ ឯនាយជាធំ ថាខេបើកុំ
ព្រះបាទពជា ស្តេចប្រើយកផ្កក នាំមកឲ្យវា កុំអីយើញជា មិនដឹង
ខ្លួនស្មោះ ។ នាយមួយថាអើ យើងឥតអំតើ ខាតបាតដើងស្មោះ
ខំដើរព្រួយច្រាណ មិនហ៊ានឈប់ស្មោះ ឥតលាភចាំងអស់ ចាំង
លោកចាំងយើង ។ មួយទៀតអាជ្ញា ព្រះបាទក្សត្រា ឥស្សរថ្កុលថ្កើង
ត្រាស់ប្រើចំពោះ លើអស់ចាំងយើង ឥឡូវបង់ដើង តុំបានពជការ ។
ឯនាយជាធំ ថាខេអ្នកកុំ គិតថ្នាំពល់គ្នា ព្រោះតែព្រះអង្គ ស្តេចទ្រង់
ក្រោធ ទើបខ្លួចពជការ យើងធ្វើពុំបាន ។ គួរតែយើងៗ យើង

ខ្ញុលព្រះហៅ ចក្រភត្តិក្សត្រក្សត្ត តាមតែព្រះទ័យ ក្សត្រវៃទ្រង់ធ្យាន
គិតនោះទើបបាន ឃើញស្រួលពាល់គ្នា ។ នាយពាំនោះគិត ស្រួល
ព្រមគំនិត រៀលក្រោយលីលា ដល់ប្តីឯអាមាត្យ ជាអាចវៃឆ្លងថា ដូច
បានពណ៌នា ពីមុនមកនោះ ។ អាមាត្យឡើងទៅ ឡើងខ្ញុលព្រះហៅ
ជ្រាបគ្រាស់ថានុះ ហេតុម្តេចដឹងខ្លួន រត់ពួនដូច្នោះ អាមាត្យក្រាបចុះ
ខ្ញុលស្តេចតុង្គារ ។ ពុំចេះក្សត្រវៃ ទ្រង់ជ្រាបព្រះទ័យ ដោយព្រះអាជ្ញា
ត្រង់នោះតុំដឹង ដំណឹងកិច្ចការ ទ្រង់ព្រះចិន្តា គង់ជ្រាបមិនខាន ។
ស្តេចទ្រង់សណ្ឋិត សន្ធិដ្ឋានរ៉ែគិត ជ្រាបដោយចិត្តញ្ញាណ មានព្រះ
តុង្គារ បរចាស្មោះស្មាន ថាតក់ចាន ដឹងដោយអាជ្ញា ។ អញប្រើ
ឲ្យយក ឲ្យទាំងាដ្ឋក សាច់មនុស្សឲ្យវ៉ា ហេតុនោះឲ្យដឹង ដំណឹង
កិច្ចការ ណ្ហើយចុះពាល់គ្នា អ៊ុតគតកុំភ័យ ។ ឯទោសអក់យោយ ដែល
អ្នកពាំនឲ្យាយ ជំនុំវិនិច្ឆ័យ លែងទោសគាត់ទៅ កុំចៅឲ្យក្រ័យ កុំ
ឲ្យគាត់ភ័យ គាត់កិតកាន់កាំង ។ ប៉ុន្តែឲ្យយាត់ ស័ក្តិយសពីគាត់ កុំ
ឲ្យចូលក់ឆ្ង គោះស្នាំស្នេហា បរិភោគពាំ ខាងគាត់ឲ្យខាំង ឲ្យភាត
ហូតចេញ ។ អាមាត្យបានស្តាប់ ស្តេចត្រាស់បង្គាប់ ក្រាបលាលៀវវិញ
ទ្វើតាមអាជ្ញា ក្សត្រាទោះមិញ អ្នកអក់អែរតេញ ចិត្តសោមនស្ស ។
ហេតុស្តេចទ្រង់ធម៌ ព្រះទ័យស្មោះស មែនមានមេត្តា ស្តេចសាងអ៊ារម៉ី

ជាតុទ្ធចិតា ព្រះខ័យជ្រះថ្លា ដោះទុក្ខសត្វផង ។ ស្រេចហើយក្សត្រៀម
កំសាន្តព្រះខ័យ ពុំមានសៅហ្មង អស់ស្រីស្រឡាំង បរិពារស្ទុះផង ត្រេក
អរកន្ធង ឥតឯទបមា ។ តាំងថ្ងៃខែរ៧ ក្សត្រក្សាន្តបមាថ្ង ត្រេកសោម-
នស្យា ទីឆ៍ទាឆ៍បក្សី សិរីសោភា មិនឲ្យឃ្លាតឃ្លា ឃ្លាតឃ្លៀងមួយថ្ងៃ ។
បើក្សត្រទុក្ខម ចូលទីបន្ទំ បរមសុខសេយ្យ នាំទាឆ៍សោភា ចរចាសុមៃ
ព្រះថ្លាក្សត្រៀម ផ្លៀងព្រះកាមា ។ លុះតើនចាកទី សយនាមុនី
ស្តេចនាំសោភា ចេញស្រង់ទឹកអប់ ត្រឡប់ប៉ុច្ចា ស្រង់ស្រេចក្សត្រា
ធិរាជចក្រី ។ ស្តេចសោយក្រយា ទិព្វរសឆ្ងាញ់ រសរៀនប្រក្រតី
សោយស្រេចក្សត្រក្សាន្ត ប្រទានចំណី ចែកខំផងក្តី ឲ្យទាឆ៍
សោភា ។ ចេញចុងរោងរ៉ែត្ន ព្រះថ្លាទមហាក្សត្រ នាំទាឆ៍សោភា
ឲ្យទំពៀបទាល់ តង់តាល់ក្សត្រា ត្រាស់ប្រើចរចា ស្តេចស្តាប់សំដី ។
សម្តេចក្សត្រា ត្រេកសោមនស្យា ទីឆ៍ទាឆ៍បក្សី ពុំដែលឃ្លាតឃ្លា
ព្រះថ្លាចក្រី រឿងៗប្រក្រតី សព្វទិនទាំង ។ ស្រឡាំងស្ទុះស្ទុំ ស្រោត
សឹងមានចិត្ត ស្រឡាញ់ពាល់គ្នា អញ្ជើញទាឆ៍ទៅ លំនៅត្រីហា លួង-
លោមសន្ធូនា ឲ្យស្តីទីឆ៍ស្តាប់ ។ ឯទាឆ៍សោភា យល់ស្ទុះស្ទុហា
ស្រឡាញ់រកាប់ ទាឆ៍ចង់ចរចា រៀបរាសោសព្វ ស្ទុះស្ទុំស្តែងស្តាប់
ពុំលោះវៀលា ។

ន័យនេះឈប់ស្ទះពណិនា ពោលតាគ្រាមា នាមឈ្មោះព្រះជន្ធជន-
បទ ។ ជាខេត្តស្រុកក្រៅកំណត់ ពស្ត្រផងច្រាកដ កំកើតមានចោរកូយ
ខ្លាំង ។ លើកគ្នាជាទ័ពតតាំង តរល់ចេញប្លាំង ដណ្តើមយកទ្រព្យ
អ្នកស្រុក ។ មហាជនកើតហេតុកលិយុគ ជ្រុតចោរធ្វើទុក្ខ លំបាកលំ
បិនគេកក្រៃ ។ ភូមិតួចផ្ទះតិចតិតភ័យ រត់ទៅព្រៃផ្សៃ ជ្រកទៅផ្ទះ
ប្រើនភូមិធំ ។ នាំគ្នាកាប់ឈើរំលំ ស្ងាក់ច្រកតួចធំ ធ្វើជាទ័ពការ
ពល់ស្រុក ។ ចោរលើកទ័ពចូលតតុក ឥតខ្លាចចូលលុក រុកពន
ខ្ទ្រានបន្ទា ។ ខ្លះពយចែកព័ន្ធគ្រាមា ច្រាំពីជាន់ជា ផ្លូវដើតប្រកិត
ជុំស្រុក ។ អស់ពស្ត្រកងភូមិតើតទុក្ខ តិតភ័យពាកណាមក ស្រែកយំ
ទ្រហឹងអឺងកង ។ ប្រុសខ្លះចេះគុណដំបង ចេញទៅប្រឡង ប្រឡូក
ទីដ៏ចោរការស្រុក ។ ចោរចេះគុនខ្មែលចូលលុក ច្បាំងទីងអ្នកស្រុក
សំរុកសំរុញចូលបាន ។ ចូនវាយយកទ្រព្យជនជាន ជាល់តប់ជាក់ច្រាន
អ្នកស្រុកចាញ់ចោរគ្រាំគ្រា ។ អ្នកស្រុកស្រែកហៅមហិមា ហៅភូមិ
ជិតគ្នា មកជួយមកចូលប្រកាប់ ។ ចោរខ្លះរត់ចាក់ក្រចាប់ ចំរូងដៃកស្រាប់
ពយស្ងាក់ត្រប់ច្រកចាំទៅ ។ ភូមិជិតឮគ្នាស្រែកហៅ ម្ចាស់រត់ទៅ ចំរូង
ក្រចាប់មុតដើង ។ ឈឺធ្មៃបក្តៅផ្សាដូចភ្លើង ដួលស្រួសក្រោកឡើង

ឧដ៏ដើរតុំចាន់ឡើយណា ។ ឯចោរឡើងរើគ្រឿ យកតាមចិត្តវ ចាន
ហើយត្រឡប់លៃទៅ ។ អ្នកស្រុកកើតទុក្ខក្តាត់ក្តៅ ជ្រែតចោរវាយត្រូវ
ដំណាំឈឺក្រំកាយា ។ ខ្លះត្រូវបួសឆ្អឹង ចាក់ដៃចាក់ស្មា ពិការខ្វៀនខ្វិន
ជាទុក្ខ ។ កើតគោលាហលគ្រប់ស្រុក អស់ភស្តុតុំសុខ ពុំសូវសម្បាយ
ទ័យា ។ គ្រប់ខេត្តស្រុកក្រៅនានា នាំគ្នាលាលា ទៅប្តឹងស្តេចត្រាញ់
សម្រេច ។ ចៅមឿងស្តេចត្រាញ់ដឹងស្រេច កេណ្ឌតលំរោច ពលសេន
សុទ្ធសឹងខ្លះខ្លាំង ។ លើកចេញទៅប្រាប់ចោរខ្លាំង ចោរលើកកូយ
ម៉ុង ចេញច្បាំងចៅមឿងធំចាញ់ ។ លើកទ័ពថយត្រាយវិលវិញ
ពលកើតទុក្ខម្ខេញ កំរត់ចោលស្រុកអាត្មា ។ ជ្រកពួនសត្វព្រៃព្រឹក្សា
ចោរមានជយា រុកពនគង្គានដេញដាច ។ ចៅមឿងស្តេចត្រាញ់ក័យកិត
ស្តើរក្សយដ៏វិត កំរត់ទៅប្តឹងមន្ត្រី ។ ជាធំសម្រេចផែនដ៏ ឯអស់មន្ត្រី
កំទាំសេចក្តីនោះទៅ ។ ឡើងខួលក្សត្រាចមទៅ ស្តេចជ្រាបដោយទៅ
ដំណើរត្រាស់ប្រើអម្ចាស់ ។ ឲ្យកេណ្ឌពលពាលសេនា
ត្រប់សាសន៍តាសា ជាក់មេដាក់ទាយកំណាន់ ។ សឹងមានគ្រប់គ្រឿង
ប្រគាន់ កេណ្ឌចាន់រួសពាន់ កំឡើងក្រាបខួលក្សត្រា ។ ស្តេចជ្រាប
សព្វគ្រប់ប្រការ ត្រាស់ប្រើអមច្ច ឲ្យដុំចតុរង្គពាហន ។ ពួកពល
ថ្មើជើងប្រុងប្រាណ ពលសេះក្ងាហាន ពលរថតដន្ទូជើងសឹក ។

រូបពង់ធាត់ធំពន្លឹក ប្រទះច្បាំងសឹក មិនថុចមិនថយរួញរា ។ សឹងមុត
សឹងមានជយោ ធ្វើសឹកច្រើនគ្រា ប្រសព្វប្រសិទ្ធិខ្លាំង ។ សេនា
ថ្មើជើងបើង រូបធំខ្ពស់ស្តើង ក្រអើតក្រអាញស្ងាញស្ងូត ។ សេនា
អាសាស័ក្តិសិទ្ធិ ក្លៀវក្លាតំនិន កំណែរកម្លាំងស្មើឡល់ ។ សេនាវ៉ា
មង្គល បើកបរតទល់ ប្រទូស្តប្រទះឥតភ្លឹក ។ សេនាគជន្ទ្រស័ក្តិ
សឹក ចិត្តមុតជំពន្លឹក សាហាវសៃហ៍សពេកក្រៃ ។ រូបពង់ធាត់ធំស្តើម
ស្គែ ក្លាក្លៀវច្រៀវច្រៃ កំហែងទ្រហឹងអឺងកង ។ ត្រួតត្រាសេនា
តលង់ សូរស័ព្ទរំពង កិញ្ជរន្ធាន់តសុង ។ ជុំស្រែចសម្តែចពាជា
ទ្រង់គ្រឿងសោភា ព្រះមកុដអាភរ័ត្នកយ ។ ភ្លឺប្រុះទ្វាសទ្នុះព្រោង
ព្រាយ ធើតធោមធាធាយ ត្រចង់ត្រចះស្មើ ។ ហាក់ដូចអគ្គិឥន្ទ
កោសិយ ស្រែចព្រះចក្រី ស្តេចយោងចេញចុងរោងរ័ត្ន ។ នាហ្ម៉ឺន
ឡើងគាល់ច្រើនក្តាត់ ទើបព្រះមហាក្សត្រ ស្តេចផ្តាំអគ្គឯកមន្ត្រី ។
ឲ្យប្រុងប្រយ័ត្នបុរី ស្រឹង្គារសៅស្រី ទីតាំងពជកំងរ័ត្នមេរ្យ ។ ប្រាសាទ
ក្រឡាបន្ទំ អក់យោយស្រីស្នំ រក្សាសារីកាឲ្យល្អ ។ ក្រែងមានអន្តរាយ
ភ័យមរណ៍ ផ្តាំស្រែចភូធរ ឡើងគង់ទីតាំងគជសារ ។ បងគ្រឿង
មាលមាសរបទា ភ្លឺតាំងយោធា តព្រោងពព្រាយទ្នុះទ្វាស ។ បរញ្ជោង
ប្រាសាទសឹងមាស រ័ត្នកយដាំជាស ពៃទូរ្យសុរិកាន្តមុត្តា ។ ស្មើហាក់
ដូចសុរិយា ចែងចាំងវៃហាស៍ ខ្នាលប្រទ្រាលពេកក្តាត់ ។ ព្រាហ្មណ៍

ទេសផ្ទុំសាំងស្រងាត់ ដង្ហែមហាក្សត្រ ចេញចាកក្រុងកែវចេតា ។ ពលពង្សចតុរង្គអាសា តាំងហោបីគ្រា ខ្លះខ្លាយភ្ញាប់ញ៉ាំប្រថពី ។ ភ្លេងផងពាតគងតែរ សព្វសូរដន្ត្រី ប្រគោះប្រគំពុំខ្ចាំង ។ ស្គរខ្ពស់ស្គរខ្លួងស្គរតាំង ខ្លែវស្គរពិណតាំង សុភោរហ៊ោពុកមេឌា ។ ខន់ជ័យមាសមៃលាតណា ប្រាស់ប្រាលមហិមា ខង្គីលខង្គើរដោរដាស ។ ស្រែទំនួលខ្ពៅអាកាស ពពកដោរដាស ដោយតេជអានុភាពក្សត្រា ។ ចៅមឿងជាមុខសេនា ទ័ពស្រួចក្សត្រា តាំងផ្លូវតម្រង់ទ័ពចោរ ។ ចាត់ចែងជាបែកគហុលោ សឹងមានតេជោ តេជះតបះរឹងរិទ្ធ ។ បែកស្តាំលលាំពិទិត្យ បែកឆ្វេងជំប្រសិទ្ធ ទ័ពណូនសឹងរិទ្ធីគ្នា ។ ស្តេចលើកចតុរង្គពហុលាជ្រុំពីរទិវ ចានដល់ព្រះចន្ទជនបទ ។ វេលាសុរិយោរលត់ អ័ព្ទអស្តង្គត ព្រលប់ជួបជួលសិទ្ធិយោ ។ ព្រះចន្ទចែងចាំងវេហាស៍ ស្រឡះមេឃាត្រចះត្រចង់ស្មើ ។ ស្តេចឲ្យបញ្ឈប់សេនីយ អាមាត្យមន្ត្រី កំលើកព្រះតន្ទាជ័យ ។ រួចស្រេចរំពេជធាប់រៃ ព្រះបាទក្សត្រថ្កៅ ឡើងគង់ក្រឡាមណ្ឌល ។ អាមាត្យចាត់ចែងរៀបពល ឲ្យបោះទ័ពទល់ ចាបចាយរៀបរាយប្រកិត ។ ជាជួរជ្រុំពីរជាន់ជិត គយល្បាតពិទិត្យ ពន្លឺភ្លើងភ្លឺផ្លេកព្រោងព្រាយ ។ គ្រប់ច្រកគ្រប់ទ្វារទ័ពចាយ ចាំងបាវចាំងនាយ ក្រវែលវង្កាត់ពៅមក ។ កាំភ្លើងមេរៀបគ្រប់ច្រក កាំភ្លើងដៃដក រន្ទុកច្រកគ្រាប់

ដើរល្បាត ។ សេនាហ៊ានរៀនបានខ្លាត ធ្វើការសង្វាត មិនឈប់មួយយប់
ទល់ព្រឹក ។ សូរស័ព្ទសន្ធាសន្ធឹក គគុតគគឹក ដោយនាយសេនាទ័ពធំ។
ស័ព្ទភ្លេងលើយលេងរងុំ ត្រែសង្ខប្រគំ រំពងព្រៃព្រឹក្សអគ្ឃា ។ ឮលាន់
ស្ទើរភ្ញាយពស់ហោ ហៅហៅគ្នីគ្នា សន្ធឹកសន្ធាប់ឮឆ្ងាយ ។ រីឯអស់
ចោរទាំងឡាយ ឮសូរស័ព្ទសាយ កំដរដាទ័ពក្សត្រា ។ ស្តេចលើកចតុរង្គ
សេនា ចំពោះតំក្រា ទៅត្រូវទ័ពវាដូច្នោះ ។ កិតភ័យញាប់ញ័រពុងពោះ
រូតរះចោលអស់ នៃស្បាងសម្បត្តិភ័ស្តុការ : ទាំងគ្រឿងខ្លួនខ្មែរជា ។
រត់ចោលឃ្លាតឃ្លា តុំបានជាប់នៅអាត្មា ។ ចោលទាំងខោអាវតំស្ពាត គជ
កាសតាក ទាំងភ្នកពជ្រះសហឹង ។ រត់ខ្លួនខេមិនជឹង កិតបាត់ព្រលឹង
ដោយតេជស្ត្រាតណ្ហាភយ ។ ខ្លះចេញតាមច្រកបន្ទាយ ខ្លះភ័យពយមាយ
ទំលាយបន្ទាយតុំបាន ។ ខ្លះមុជមមុលជាក់ច្រាន ជាប់ឆើតអស់ប្រាណ ពក
អាចម៍ពកនោមតេញទៅ ។ កិតភ័យអឺងកងនោឡា សុតស្ងន់ស្ងឹងស្ងោ
ប្រាត់បង់វិញ្ញាណសោះសា ។ រៃកត់ជាយលាមកភ្ញាយមូត្រ ពួនសត្វកំពោត
កំភាប់អង្គុតអស់ឆេង ។ រត់ខ្លួនខេរលើង អាវខោចោលឆេង អាក្រាត
អាក្រាសនៅវាល ។ ដងើកងងាកងងាល ខ្លះចាប់បានផាល សំបកខេ
រត់ទៅ ។ រត់ពីរសៀលថ្ងៃនៅ លុះដល់យប់ជ្រៅ ទៅពួននៅគុកគុហា ។
ន័យនេះឈប់ស្ងៀតណា នាលពីកជា រៃលវើងខ្លាំងញ័យ ។

ព្រឹកត្រង់ស្រេចស្រាន់ទម័យ តើខចកសុខសេចក្ស ស្រប់ត័ក្ត្រចេញគង់
ក្រឡា ។ គំនាល់ទិពវិគាសនា ចតុរង្គីអាសា គង់តាល់ជាជួតាប់តាន់ ។
ដោយបែកដោយពួកកំណាន់ ស្តាំឆ្វេងច្រើនជាន់ ជុំជិតប្រកិតត្រៀបត្រា ។
ទើបស្តេចចេីកព្រះខ្សែថា ត្រាស់ប្រើអមច្ចា នូវពួកមហានពាលោ ។
ទៅមើលបន្ទាយទ័ពចោរ តែចោរមោហា វ៉ាតិតប្រការម្តេចម្តា ។ អាមាត្យ
ខ្ញុលខ្ញង្ការ បង្គំលុតលា ផែលទៅនិពាជ័យទៅ ។ ចានដល់ទ័ពចោរ
ឃោរឃៅ ឃើញបន្ទាយនៅ សូន្យស្ងាត់ចង់ចាត់មនុស្សម្នា ។ អាមាត្យ
នូវតែលយោធា ចុះព័អស្ប្ប ចូលកន្លងបន្ទាយមើលជាក់ ។ ឃើញសឹង
ត្រឹមចោរអប្បល់ក្តណ៌ ប្លន់ចានមកជាក់ រៀបពុកពេញតាំងបន្ទុយ ។
ពានតោកថាសតុន្នាំងចាយ មាសប្រាក់រត្នាយ សំពត់ហូលព្រៃគាសា ។
អាមាត្យហៅមេប្រុមសេនា នៅពលអាសា កុំឲ្យឃកត្រឹមនោះនៃ ។
ចាំខ្ញុលក្សត្រាជៀស្តេជ័យ តាមតែព្រះទ័យ ត្រង់ឈ្នេងប្រការម្តេចមិញ ។
ថាហើយទាំងគ្នាវិលវិញ បរសេះចរចេញ ដល់ហ៊ោយឡើងខ្ញុលក្សត្រ
ថ្កុំ ។ ស្តេចបន្ទូលទៅថាហៃ អាមាត្យវ៉ៃ ចូលធាប់ប្រញាប់ម្ន៉ាម្ន៉ា ។
ទៅប្រាប់អស់ពស្តេប្រជា ឲ្យវាទាំងគ្នា មកតិតជញ្ជូនយកត្រឹម ។
រថសន្ធរណាស្គាល់ស្រាប់ កុំឲ្យសាប់ឡាប់ ទៅយករថសន្ធវិញ ។
អាមាត្យលុតលាចរចេញ រួតរត់ត្រចាញ់ ប្រាប់អស់ពស្តេនានា ។

អស់ពស្ត្រត្រេកអរមហិមា បបួលគ្នាគ្នា មកដឹកជញ្ជូនទ្រព្យធន ។ ត្រេកអរពេលគ្នាគេកពន់ ចានទ្រព្យចរបុណ្យ ក្សត្រក្សត្តិទ្រើសទ្រង់ករុណា ។ សឹងថ្វាយស័ព្ទសាធុការ កល់មាត់ពល់គ្នា នោះឡាទ្រហឹងអឺងកង ។

បទព្រហ្មគីតិ

ព្រះជាទម្រៃលធម្ម ពជទត្តមលើសលោកផង ស្តេចប្រាប់សឹកយង់ឃ្នង ចានចាក់បបះដោយចេស្តា ។ ស្រេចហើយក្សត្រឡាស់ឲ្យឆាប់ប្រាប់ពស្ត្រផងស្រែចំការ ឲ្យចេញពីព្រឹក្សា មកនៅភូមិស្រុកទីទៃ ។ កាលណោះពួកអ្នកស្រុក មិនគួរកុកច្រើនក្រាស់ក្រៃ ចរចេញពីកុងព្រៃ មកនៅភូមិគ្រប់អាគ្នា ។ ឯអង្គក្សត្រកូនាថ ស្តេចប្រកាតព្រៃព្រឹក្សាចតុរង្គអង្គសេនា ហៅក្សត្រក្សត្តិចរចូលព្រៃ ។ ចរចាប់សត្វម្រឹគាព្រះពជាក្សត្តិព្រះទ័យ សេនាតលទ័តជ័យ សឹងសប្បាយឥតភ័យា ។ ឯអស់ចោរចាំងឡាយ រត់ទៅធ្វាយភ័យមហិមា ឮស្តេចលើកយោធាប្រកាតព្រៃចាប់ម្រឹគា ។ ស័ព្ទសូរអស់កងពល រត់ចលំរកហៅគ្នាញាប់ញ័រចាំងព្រឹក្សា ស្មានជាស្តេចដេញអាគ្នា ។ នាំគ្នារត់ទៀតទៅចោលភោគាវ សឿងកោតា រត់ជាត់មត់អាហារ ជាប់តោះស្ងាប់កងព្រឹក្សាព្រៃ ។ ខ្លះពួនក្នុងរូងភ្នំ គ្រុនសន្ធំស្គមសន្ធៃ ស្ងាប់

ចោលខ្មោចក្នុងព្រៃ ច្រែនអន្ទេកពេកត្រៀបត្រា ។ ស្ងាប់អស់គ្នាន
សល់ម្នាក់ ដោយជួរច្រែនប្រការ ខ្លះពួនតានលើខ្នា ខ្លាំស្ងាប់
តាំយកទៅ ។ ខ្លះតត់តានលើពស់ លេបតាំងរស់គ្នានសល់នៅ
ហេតុកម្មចោរយោរយៅ ឲ្យស្ងាប់អស់ដោយវេក ។ និតានតតាំខ្មែ
ប្លួនប្រៀបប្រែពាលតណិតា តាលស្តេចលើកយោធា ចេញទៅច្រាប់
ចោរក្នុយភ្នំង ។ ចាត់បបដោយថ្នាមើ ព្រះចក្រីខ្ជីភ្នំង ដល់ស្តេច
លើកកួយហាំង ចូលប្រពាតព្រៃព្រឹក្សា ។ ដំណើរទំនង់តាត្យ កិច្ច
សុភាពតិសត្យា សុរេចដួបចូលជា ខ្មែរច្រាំច្រកដមែនមាន ។

បទភាពតិ

នេះនៅរៀបភប់ រៀបរៀងសាសត្ត សាសង៌ដោយជាន តែងតតាំខ្មែ ច្រាំប្រែទំនាន តិតតីក្សក្រក្សាន្ត រំមលចេស្ត ។ តាលក្សត្រ
ប្រពាត ព្រឹកព្រៃក្នុងជាតិ ឈប់ស្នេះចរចា នេះទំនង់ទាំនិ-តានតិសា-
រីតា តាលក្រោយក្សត្រា ស្តេចលើតទំពាទៅ ។ ទាង៌នាថនៅទិត្យ ក្នុង
ភំនស្នេហ៍ស្និទ្ធ ឯកតតហ្នង៌សៅ អស់ស្នំស្នេហា បរិវារក្នុងក្រៅ
អញ្ជើញនាង៌ទៅ លួង៌លោមចរចា ។ ហើយថ្វាយចំណី ចេកទំនំក្តី
ខ្លូវអស់ផលា ខ្លូវនេមង្ឃុត ទង៌ល្មុតសេដា ទឹកឃ្មុំផលា ប្រឡំខ្លូវលាជ។
រៀបជូនសារិកា ឲ្យបរិភោគា សព្វថ្ងៃព្រឹកល្ងាច ឯនាង៌សារិកា រៀបហារ
ច្រាសច្រាជ្ញ អស់ស្នំគោតខ្លាច ស្រឡាញ់ភល់គ្នា ។ មិនហ៊ានឲ្យអាក់

ឲ្យគន់ថ្នាំដ៏ថ្លាត់ ចិត្តនាងឡើយណា បើនាងក្អកទឹក រលឹកក្សត្រា
ស្រីខ្លះចរចា លួងលោមឲ្យសើច ។ ថាអ្នកម្ចាស់ថ្លៃ អាញើញខតចៃ
ច្បាំងទឹងសង្កើច ចៃចោលហើស ក្រឡះចៃសើច លោតទាំសង្កើច
ដួលផ្ងារស្រាងឆ ។ ខ្លះថាអ្នកម្ចាស់ មើលមួសធំណាស់ ខ្លួនប៉ុនតីឆ្កាង
ខ្ញុំនេះក្លាក់ ក៏ធាក់ខ្ញុំក្តាង ខ្ញុំដួលស្រាងឆ ក៏ហើរគត់ចាត់ ។ សារិកា
ទើតនោម ស្តាប់តីលៀងលោម លួងសើចច្រើនក្តាត់ ខាងធ្វើរួសកយ
ចៃកចាយសារសត្យ តីលៀងអត្តាត់ សើចសាំនកល់គ្នា ។ ស្រីស្នំ
អកំយោយ សោតសំដីសម្បាយ រឿងកាលំវេលា លុះល្ងាចត្រលប់
យប់សន្ធិយា ខាំនាងសារិកា ចូលទ្រូងមាសថ្លៃ ។ កាលំពេលវេលា
ទៅតគៀរវែក សារិកាខេះនៃ ពីត្រូងតេកតន់ កម្មធន់ក្រៃសង្កៃ
តមកាន់ស្រីថ្លៃ ឲ្យកើតទុក្ខម្ខាញ ។

ឧទព្រហ្មគីតិ

មានតាសមួយទិក ហេតុវែកពីមុនមិញ មានស្ងំដង្កៃវិញ ឈ្មោះ
នាងនន្ទាវេរី ។ ជាកូនអ្នកអកំមួយ ដែលស្តេចឲ្យថាណ្តាញ់ ក្នុង
កំនើតឱញាតតី ទៅកេស៊ីជោយទម្ងន់ ។ ជាក់ផ្ងារស្ងាចារ លក់
ប្រក្រតីតម្លៃតេតន់ មិនដែលគ្នើការធ្ងន់ ជាពូជនឡត់តុះតប ។
នន្ទាបានមើញខ្ចាយ ពុំសប្បាយទុក្ខលង្គាត រកស៊ីយល់ថាតប

លក់ដូរនៅដោយពាណិជ្ជ ។ ឆន្នាចង់អាយាត ចង់ឮក្បាច្រៀងនាង
សារិកា តែតថាអ្នកមាតា កាលដើមឡើយមានបុណ្យស័ក្តិ ។
ឥឡូវប្រែជាខ្សត្រ យាងខុតតែតមាសប្រាក់ រកស៊ីឡើយសស្រាក់
ចាស់ម្ល៉េះហើយមកលំបាក ព្រោះតែមេសារិកា ខើបមាតអញ
គោកយ៉ាក ម្ល៉េះហើយហានលំបាក នឹងដៃអញនេះមិនភាន ។
ឆន្នាតែតដូច្នោះ ហើយក៏ដើរចុះចាកហាន ទៅដល់លើពពងមាន
ចូលបន្ទំមហាក្សត្រា ។ ថ្ងៃនោះជួនអស់ស្មុំ ខ្លួចាស់ខ្ចុំក្មេងសារិកា
តុំបាននៅរក្សា ជាប្រក្រតីដូចសព្វដង ។ ហេតុកម្មនាងស្រីថ្ងៃ ពីព្រឹង
ទៃនាងមានហ្មង បញ្ចូលចិត្តស្មុំផង ឲ្យក្មេងភ្ញាំងគ្រប់ ។ គ្នា ។
ឆន្នាចូលដល់ក្នុង ទៀបទៅទ្រូងនាងសារិកា ឆន្នាឆ្មៀងនេត្រា មើល
ឆ្វេងស្តាំឃើញស្ងាត់ល្អ ។ ចើកឆ្នាសុវណ្ណា លួចហត្ថាហើយថ្នមទ្រូ
លើកយកសារិកាមក់ ជាក់ដល់ជិតដិតទុក ។ ដណ្តប់ឈ្នួតជាហ៊ុម
ពីក្រៅពុំតាំងសារិកា ហើយចុះចរយោគ្រា រួលអាត្មាទៅភូមិហាន ។
រីឯនាងសារិកា កាលឆន្នាវាចាប់បាន រួលទៅលំនៅហាន ឲ្យនាងស្តីវ
ន័ងស្តាប់ ។ ហេតុនេះនាងសារិកា តុំចរចារចែងសាសព្វ តុំហៅតុំស្រែក
ច្រាប់ អ្នកដទៃឲ្យដឹងនាង ។ សម្ងំឲ្យឆន្នា ថ្នមកាយាសព្វសាង្គ ឆន្នា
ដើរចំភ្លាង ហុចសារិកាឲ្យទាស ។ ដោយខឹកក្តីចិត្តា មានវាចាមិន

មេត្រី បង្គាប់ដល់ពាសី ថាហាឯយតសារិកាទៅ ។ ចោចក្រមស្លាបបំ
អេង ផ្សេរលើងកុំឲ្យទៅ ចោចស្រែចហាឯយកទៅ កាម់ចិញ្ជាំសាច់ឆ្ងិន
វ ។ ផ្សេរស្លិតហើយខ្លួ ឆ្ងិនយកមកអញ្ជេកាត្តា សងសឹតនឹងខ្លួនអ
ក្នងវៃលានេះប្រញាប់ ។ ពាសីស្តាប់ពាថា ដែលធន្លាបានបង្គាប់ ទើប
ធ្វើយ៉ាងប្រញាប់ ចាប់សារិកាមិនប្រណី ។ ឯនាងសារិកាសោត ឮ
គេក្រោធពុំប្រណី នាងក្មេចក្លាំងស្មាតី បន្តិចមកក្បាកាយ ។ តែតថា
ខ្លួនអញអើយ ទុក្ខទៀតហើយគួរអនិច្ចា ម្តងនេះស្លាប់អសារ រកអ្នក
ណាជួយពុំបាន ។ រកេស្តេចៗពុំនៅ លើកទ័ពទៅធ្វាយទីហាន ទឹងហៅស្តេ
ត្រប់ក្រុាណ សឹងនៅធ្លាយហៅពុំឮ ។ ពាសីបោចបក្ខា នាងសារិកា
ភ្ញាក់ព្រឺតព្រឺ សាច់ស្បែកតើតធៀបឈើ ស្មើរសេន្ធប់កាលនោះនៃ ។
ចោចប្រិបព្រឺតព្រឺអង្គ ឈឺស្រយង់ត្រប់សរសៃ ជលនេត្រនាងស្រីថ្លៃ
ស្រក់សស្រាក់ពុំស្រាកស្រាន្ត ។ ឈឺធៀបផ្សាអស់អង្គ ឮប់ឮនឮធ់
ខប់ពុំបាន លេងលើយក្មេចក្នងក្រាណ សន្ធប់តឹកក្មេចអាត្មា ។ កម្ម-
ត្រេងមកដល់មុន ក្រោយនោះបុណ្យតិព្វាស្មា មកជួយនាងសារិកា
បង្វែចិត្តមេពាសី ។ ចោចរួចទុកប្រហែស ដើរក្រែអែសចុះទៅដី រក
បេះស្លឹកខ្ចីមួខ្ចី ធ្វើជាខ្លួនញ៉ាំក្ងា ។ សារិកាកែវតែសី តាលពាសីវ
ជាក់នា ខាងអាងទឹកនោះណា នាងត្រជាក់ភ្លាក់ដឹងក្រាណ ។ ប្រឹង

ប្រែប្រែគាយា បើកនេត្រាមើលសព្វហាន ឆ្វេងស្តាំស្វាត់ពុំមាន មនុស្ស
ម្នាម្នាក់នៅទីនោះ ។ នាងប្រឹងក្រោកឈរបាន ប្រែប្រឹងប្រាណ
ឈោងចំពុះ ចឹកជាប់នោចនោះ ខំដួនដើរលើត្រីហា ។ ឈាន
ម្ខងបានមួយដង្ហាប់ ឈឺញ៉ាញ្ជាប់អស់អង្គា, សាច់ស្បែកផ្សាត្រាំត្រា ក្រំ
គាយាយ៉ាំងអនេក ។ កកិលមួយដង្ហាប់ម្តង ឃើញប្រហោងរនាបញ្ចេក
ប្រហដូចតែវែក នាងខំលាក់ខ្លួនចុះទៅ ។ ដល់ដើរហ៊ាមេនាងដើរ
ឈានទីទើរតិចៗទៅ ឃុនឃើញរូងមួយជ្រៅ ជារូងស្តេចកណ្តុរស ។
នាងចូលទៅលាក់ខ្លួន ជ្រកពីឯពួនកំចាំងស្ម័ស្រេចហ៊ាយនាងបវរ
ក្រាបសម្រាន្តអង្គកាយ ។

គជាម្ខាសិកៈ កាលបើនិស្សា គាប់កាលនោះសេតណា
រីឯស្តេចកណ្តុរស ។ ភ្ញាក់ពីនិទ្រា ក្រោកលីលាត្រចេញចរ
នាំពលពាលស្មោះសរ ហែដើរលេងក្នុងរូងខ្លួន ។ បរិពារតាំង-
ឈ្មោលញី -ដើរហែមមរច្រៃពេកពន់ កណ្តុរសតយតន់ មៀងមើល
ទៅយល់សាវតា ។ សំកុតស់ក់ងក្រាប រកកេមស្ងាបគ្នាខ្លះណា
រលើងគេងគាយា ជ្រកក្នុងរូងខ្លួនដូច្នោះ ។ ទើបស្តេចកណ្តុរស
រោលឃើញនៅទីនោះ ឥណ្ឌឹងសួរកេណ្ហោះ ថាអ្នកនាងតើណ្ហោះអ្វី ? ។

(នៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

រឿងត្រូវដាក់ឧបនិស័យទំនៀមទៀងទាត់

សម្រាប់មនុស្សដើម្បីផ្តាច់គ្រោះ

លោក ឋន-វង្ស រៀបរៀង

តាមឯកសារនៃក្រុមជំនុំទំនៀមទម្លាប់

មានសេចក្តីដំណាលថា មានលោកគ្រូចៅអធិការមួយអង្គគង់នៅវត្តមួយ ជាអ្នកចេះចាំស្ទាត់ខ្លួវិស្ឋនតម្រាផ្សេងៗគ្មានបន្ទោះ ។ នៅកន្លែកុដិលោកមានខ្លួជាច្រើន សម្រាប់ដំកល់ខុនខ្លួវិស្ឋនតម្រាគ្រប់មុខ ។ បណ្តាសិស្សរបស់លោកចាំងអស់ មានសាមណេរមួយរូប ជាសិស្សជំនិត, លោកមានសេចក្តីពេញចិត្តអានសាមណេរនេះជាងសិស្សឯទៀត ។ ថ្ងៃមួយ លោកបង្រៀបថា តើសាមណេរនេះ មានគំនូរសនាដូចម្តេច? លោកគិតាំងរាយលេខតាមវិធីក្បួនតម្រាផ្សេងៗទៅ ឃើញថាសាមណេរនេះនៅ ៧ ថ្ងៃទៀតត្រូវស្លាប់ទើបត្រូវយក ។ កាលឃើញដូច្នោះ លោកគ្រូមានសេចក្តីតូចព្រះទ័យតន់ពេក ដោយនឹកអាណិតដល់សាមណេរជាសិស្សនោះខ្លាំងណាស់ រួចហើយលោកហៅសាមណេរនោះមកប្រាប់គាំងខ្សឹកខ្សួលថា នែខេន! ឥឡូវអញបើកមើលក្បួនតម្រាផ្សេងៗ

ទៅ ឃើញមានតំណាយថា នេនឯងនេះ ត្រូវស្លាប់ទឹងម្រឹត្យវៃយកក្នុងរវាង ៧ ថ្ងៃទៀត តើនេនឯងគិតដូចម្តេច ? ។ សាមណេរនោះក៏ដាក់មុខជ្រប់ ដោយគិតថា តួនតម្រាបសំលោកគ្រូអញ្ជេនេះខាងតិចណាស់ បើឃើញ ទំនាយយ៉ាងណា ទឹងប្រាកដដូច្នោះចៀសពុំរួចទេ ហើយក៏ធ្វើយតបទៅ លោកគ្រូវិញថា ខ្ញុំព្រះករុណាពុំដឹងគិតដូចម្តេចទេ ព្រោះចៀសពុំរួច ជាដែល, ប៉ុន្តែឥឡូវចុះខ្ញុំព្រះករុណាសូមលាព្រះគេជព្រះគុណដើរចេញ ពីវត្តនេះទៅ បើជួបទឹងម្រឹត្យវៃវាយកត្រឹមណា ក៏ស្លាប់ត្រឹមនោះទៅចុះកុំ ឲ្យព្រះគេជព្រះគុណឃើញមុខ ព្រោះបើទុកជានៅក៏ស្លាប់ទៅក៏ស្លាប់ ។ លោកគ្រូមានពុទ្ធដីកាតាំងត្រឿមក្រំ ថា អើ ! តាមតែនេនឯងចុះ ។ រួចហើយ សាមណេរនោះ ក៏ថ្វាយបង្គំលាលោកគ្រូចេញពីវត្តទៅ ។

លុះសាមណេរចេញទៅដល់តាក់កណ្តាលផ្លូវក្នុងរវាងក្នុងថ្ងៃ ទី ៧ ម្រឹត្យវៃក៏មកស្រូបកាត់យកព្រះកេសសាមណេរនោះទៅ ។

ជួនជាក្នុងពេលនោះ មានព្រះឥសីមួយអង្គ ទើបចេញមកពីចង្រ្កម ការនា ទំមន្តមកជួបម្រឹត្យវៃបានក្បាលសាមណេរ ១ ជួច្នោះក៏សួមចំណូលបាត យកពីម្រឹត្យវៃ ។ ក៏ប្រគេនក្បាលសាមណេរនោះទៅព្រះឥសី ។ ព្រះឥសី កាលបើបានក្បាលហើយ ក៏រើសយកតាំងខ្លួនសាមណេរនោះមកផ្តុំ សែក មន្តប្រោះឲ្យរស់ឡើងវិញ ហើយនាំយកសាមណេរនោះ ទៅនៅឯ

គាស្រមវេស់លោក ។

ថ្ងៃក្រោយមក សាមណេរនោះមានសេចក្តីពិការលើកដល់លោកគ្រូ ព្រមទាំងញាតិញោមវេស់លោក គំសុំលាព្រះឥសីត្រឡប់មកវិញ ។ ព្រះឥសីក៏យល់ព្រម តែមុខនឹងត្រឡប់មកវិញ ព្រះឥសីបានបង្ហាត់មន្តមួយសម្រាប់ប្រោះ ហើយផ្តាំថា "ត្រូវទៅមើលដើមទ្រូងលំវិតតែម្តង កុំបង្អែបង្អង់ឡើយ ហើយវិធានេះកុំប្រើក្តៅសង្កាស បើខុសជាឃើញសត្វប្តូរអ្វីស្វាប់ក៏ដោយ " ។ លុះសាមណេរនោះ លាព្រះឥសីចេញតាមមកដល់ពាក់កណ្តាលព្រៃ បានឃើញសាកឥសុកខ្លា១ស្វាប់ផុយរលួយអស់ នៅតែរាងធ្ងន់ នៅត្រង់មាត់រូងនៃនាគមួយ ។ ដោយការចង់លឿនមើលវិធាសាមណេរនោះក៏សែកមន្តប្រោះខ្លានោះបានរស់ឡើង ។ កាលខ្លានោះរស់ឡើងវិញហើយ វាក៏រឿចចង់ស៊ីសាមណេរនោះវិញ ដោយពាំនឹងថាសាមណេរនេះ មកជាស់ពញាក់ពាំពុងដេកលក់ ។ សាមណេរថាអត្តាមិនមែនពញាក់ទេ តាមការពិត គឺបងឯងស្វាប់ផុយរលួយអស់ទៅហើយ អត្តាបានសង្គ្រោះប្រោះឲ្យរស់ឡើងវិញដោយការណាតបងឯងទេ ហេតុដូចម្តេចក៏តិតចង់ស៊ីអត្តាដែលជាអ្នកមានគុណលើខ្លួនវិញ ? ។ ខ្លាថា យើងមិនមែនស្វាប់ទេ យើងកំពុងដេកលក់ស្តាប់ស្តល់តែស្រមណ៌ចង្រៃឯងទេតើ ដែលមកពញាក់យើង រឿងនេះ យើងត្រូវតែ

ស៊ីស្រមណ៌ឯង ។ ក្រោយដែលបានដឹកគ្នាយ៉ាងយូរបួចហើយ, សាមណេរថា ចើដូច្នោះ ត្រូវទៅរកចៅក្រមកាត់សេចក្តីឲ្យបានដឹងខុសត្រូវសិន ទើបអាត្មាសុខចិត្ត ។ ខ្លាន់ឯសាមណេរនាំគ្នាដើរកាត់ព្រៃដើម្បីរកចៅក្រម ។

ចំណែកខាងព្រះឥសី ក្រោយដែលសាមណេរខោះចេញផុតមកសោកចេះតែពិការម៉ៅក្នុងចិត្តជាខ្លាំង លុះពិចារណាមើលទៅឃើញថា សាមណេរនឹងខ្លាកំពុងមានវិវាទនឹងគ្នាយ៉ាងសម្បើម រួចហើយព្រះឥសីក៏ខំមន្តដោយឫទ្ធិមកភ្លាម ទៅគង់ចាំនៅក្រោមដើមជ្រៃមួយដើម ដើម្បីជួយសង្គ្រោះសាមណេរ ។ ប្រហែលជាមួយសន្ទុះ បានឃើញសាមណេរនឹងខ្លាមកដល់ ។ អ្នកទាំងពីរក៏ថ្វាយបង្គំព្រះឥសីតួលតាមហេតុរឿងៗខ្លួន ។ ក្រោយដែលបានយល់ហេតុសព្វគ្រប់ហើយ ព្រះឥសីក៏មានវាចាថា ដើម្បីឲ្យច្បាស់រឿងនេះត្រូវយើងទៅពិនិត្យមើលដល់ទីកន្លែង ។ ខ្លាន់ឯសាមណេរក៏នាំព្រះឥសីត្រឡប់ទៅកន្លែងខោះវិញ ។ ព្រះឥសីក៏មានវាចាថា អើ! ចៅខ្លាឯងធ្លាប់ទៅមើល ! ដំណើរដួចម្តេចមុនដំបូង ? ។ ខ្លាក៏លួនចូលទៅដេកស្បែរមាត់រូងនាគខោះ ដើម្បីបង្ហាញព្រះឥសី ។ ឯនាគកាលបើដឹងថា ខ្លាចូលទៅជិតកន្លែងខ្លួនហើយ ក៏ព្រួសពិសមកចំលើខ្លាខោះស្លាប់ពុកផុយរលួយដួចដើមវិញហោង ។

ព្រះឥសីបានស្តីបន្ទោសសាមណេរនោះជាច្រើន ព្រោះមិនព្រមស្តាប់បណ្តាំរបស់លោក រួចហើយ ព្រះឥសីបានទាំសាមណេរនេះដោយឫទ្ធិមកដាក់ស្បែវត្ត ហើយត្រឡប់ទៅតាន់អាស្រមវិញ ។

ឯលោកគ្រូបៅអធិការ តាំងអំពីសាមណេរជាសិស្សលាចេញទៅពេលណា លោកមានព្រះទ័យព្រួយជាខ្លាំង ដោយនឹកអាណិតដល់សាមណេរជាសិស្សនោះ ចេះតែនឹកមកមែកល់ថ្ងៃមិនដែលដាច់សោះ ។

ពេលរសៀលថ្ងៃមួយ លោកចេញមកតង់ទៅពនហាលខាងមុខកុដើម្បីលំហើយការគាន់តែងកន្ទ្រឹងព្រះទ័យរបស់លោក, កំពុងតែខ្ជិលស្រាប់តែឃើញសាមណេរនោះទិមុខមកដល់ខ្ទោងទ្វារវត្ត, ដោយសេចក្តីទឹកភ្នែកជោក លោកក៏ស្ទុះចុះតត់ទៅទទួលសាមណេរនោះយ៉ាងរួសរាន់ត្រមតាំងសួរយ៉ាងប្រញាប់ប្រញាល់ថា ចុះថាម្រឹត្យយកម៉ោចកំមកវិញ ? ។

ខ្ញុំព្រះករុណាមិនស្លាប់ទេ ! (សាមណេរឆ្លើយ) ។

លោកគ្រូភ្ញាល់ណាស់មានពុទ្ធដីកាថា អាក្បួនតម្រានេះយកជាការមិនបានទេ មើលឃើញថាត្រូវស្លាប់ ឥឡូវបែជានៅរស់ទៅវិញ អ្នកណាទាំងធ្វើក្បួនតម្រានេះសុទ្ធតែកុហកតាំងអស់ ហើយលោកឲ្យយកក្បួនតម្រានោះទៅដុតភ្លើងចោល ។

សាមណេរឃើញដូច្នោះ ក៏ទូលលោកគ្រូបៅអធិការថា តម្រានេះ

មិនខុសទេ ស្លួមឈប់សិនកុំអាលជុត ខ្ញុំព្រះករុណាត្រូវម្រើត្បូរយកមែន ដែលរស់មកវិញនេះ ដោយសារព្រះឥសីលោកប្រោះឲ្យរស់ , បន្ទាប់មក សាមណេរនោះក៏រៀបចាប់តាមដំណើរ ។

លោកគ្រូក៏ប្រើក្មេងឲ្យទៅយកតម្ពឺពីក្នុងភ្លើងមកវិញ មានឆេះខ្លះ នៅសល់ខ្លះ រួចហើយលោកចាត់ឲ្យចម្លងជាថ្មើងវិញ ទុកតមកដល់ សព្វថ្ងៃនេះ ។

ដោយហេតុនេះទើបស្លួនតម្រាសព្វថ្ងៃនេះថាយពុំសូវខឿនចាត់ដូច កាលមុនគ្រោះមានហេតុដូចរៀបចាប់មកនេះ ។

មានចំនៀមមួយទៀត អំពីវិធីចាប់មនុស្សយកទៅសម្ងាប់ (១) ធ្វើ ឧបទេសដើម្បីផ្តាច់គ្រោះ កំមានជាប់មកដោយអនុលោមតាមរឿងព្រេង នេះដែរ (ត្រង់ព្រះឥសីសុំចិញ្ចៀនបាតក្បាលសាមណេរអំពីម្រើត្បូរយក មកប្រោះឲ្យរស់ឡើងវិញ) ប៉ុន្តែកាលណាបើមនុស្សណាម្នាក់ នៅសុទ្ធ តែគេមើលទៅឃើញដូចជាកំបុតក្បាល ។ គេត្រូវមត់គ្នាធ្វើពិធីចាប់ មនុស្សនោះយកទៅសម្ងាប់ដើម្បីផ្តាច់គ្រោះ , បើពុំធ្វើដូច្នោះទេ , ខ្លឹង

១- តាមសេចក្តីឧក្រាស៍តីលោក ជឹម-ឈុំ សមាជិកធ្វើយធ្វងនៅឃុំឫស្សីព្រៃ ស្រុក សណ្តាន់ កំពង់ធំថា: បើមិនបានជិលទៅរៀបចំធ្វើពិធីសម្ងាប់ទេ គ្រាន់តែក្លែងចោទឲ្យភ័យ ដោយហេតុអ្វីមួយ ក៏សន្មតថាផ្តាច់គ្រោះដែរ ។

ឫណ្ណាលឲ្យមានគ្រោះថ្នាក់ ដូចជាអ្នកខាំ ពស់ចឹក ខ្ទេះចាញ់ ទឹងធ្លាក់ពី
ចុងឈើជាដើម ។

ឯពិធីនោះ គឺ បើឃើញឮស្រាប់ថា មនុស្សនោះកំពុងស្លាលហើយ
គេត្រូវប្រជុំអ្នកស្រុកទៅចោមចាប់ ដោយក្លែងយកហេតុអ្វីមួយទៅបំភ័យ,
រីឯមនុស្សដែលនៅជាមួយមនុស្សនោះតាំងប៉ុន្មាន ក៏គេឥតប្រាប់ឲ្យដឹង
ដែរ ។ កាលណាគេចាប់បានហើយ គេនាំសំដៅទៅកន្លែងចាំធា ហើយ
គេនិយាយពាក្យគំហកគំហែងផ្សេងៗ ថា ទឹងយកទៅសម្លាប់ក្នុងកន្លែងចាំធា,
ត្រូវចាត់មនុស្សខ្លះទៅនិមន្តព្រះសង្ឃចំនួន ៤ ៥អង្គ ឬតែ ១អង្គ ២អង្គក៏
បាន ឲ្យទៅតាំងនៅកន្លែងចាំធាឯណោះមុន (បើគ្មានព្រះសង្ឃត្រូវកេអាចារ្យ
ណាម្នាក់ក៏បាន) កាលណាគេនាំមនុស្សនោះទៅដល់ហើយ គេឲ្យអង្គុយ
បែរមុខទៅទិសបូព៌ាប្រាប់ឲ្យតាំនាធម៌ (ពុទ្ធគុណត្រង់បទណាមួយក៏បាន)
ហើយគេយកដើមចេកប្រវែងល្មមលើសពីស្មាលអ្នកទៅស ដែលអង្គុយ
នោះប្រហែលមួយហត្ថ ជាក់បញ្ឈរតែក្រោយខ្នង ហើយគេស្រែកហៅ
ឲ្យជនរួចហើយ គេយកជាវតាប់ផ្តាច់ដើមចេកពីលើក្បាលមនុស្ស
នោះបន្តិចចេញទៅ ហើយគេប្រាន់ផ្លែមនុស្សនោះឲ្យផ្តាច់មុខបន្តិច
ទៅដែរ ដោយគេនិយាយទៅបកិច្ចថា " សម្លាប់ចេហើយ ! ស្លាប់
ហើយ ! " ។ ឯព្រះសង្ឃឬអាចារ្យដែលនៅកន្លែងនោះ កាលបើឮគេ

និយាយពាក្យទុបកំប្ចុ ឬទុបទេសយ៉ាងនេះហើយ ត្រូវសួរគេ។ (១)ឱ្យច្បាស់តាមដំណើរបួបហើយ ត្រូវសុំចំណាំថាតយកសាកសពមនុស្សដែលគេសម្លាប់នោះ ។ អ្នកសម្លាប់ត្រូវតែប្រគេនទៅព្រះសង្ឃឬអាចារ្យនោះកុំខាន ។ ឯអ្នកដែលត្រូវគេសម្លាប់ ត្រូវឆើបឆៃថ្លៃដង្ហាយបង្គំព្រះសង្ឃឬអាចារ្យទទួលស័ល្យរួចហើយ ព្រះសង្ឃឬអាចារ្យត្រូវសូត្រកវត្តុ ថាបពីតឱ្យហើយឱ្យឈ្មោះ (២)ជាថ្មីទៀត ។

ឯវត្ថុដែលត្រូវមានកន្លែងធ្វើពិធីនោះ គឺ ស្វាធម៌១គូ ទៀន ធូបថ្ការី ស្វា សម្រាប់ប្រគេនលោកឬដូនអាចារ្យ, ដើមចេកមួយកំណាត់សម្រាប់ធ្វើប្រដាន, ពីកមួយផ្តិលសំរាប់ព្រះសង្ឃសូត្រថាបពីក ន័ងជាវ១ សម្រាប់កាប់ ។

ពេលដែលត្រូវធ្វើគឺ ពេលព្រលប់ជាដើមទៅ ។

ឯពិធីទាំងនេះ លោក ជ័ម-ឈុំ បានឱ្យការណែ៎ថា លោកបានឃើញគេធ្វើផង ធ្លាប់ធ្វើផ្ទាល់ខ្លួនលោកជាមួយនឹងអ្នកស្រុកនៅភូមិជាមួយគ្នាផង ។

---

១ សួរថា ជុះអស់លោកមកទីនេះទាំងយប់អង្រួតអង្រាមានការអ្វី ?, យើងខ្ញុំតាំមនុស្សនេះមកសម្លាប់, – សុំនាងកុំឱ្យសម្លាប់, ជានាងម្តេចបានបើសម្លាប់រួចទៅហើយ (និយាយពាក្យទុបទេស) ។

២ ខ្លួចជាមនុស្សឈ្មោះសុខ ដល់គេធ្វើពិធីសម្លាប់រួចហើយ គេដាក់ឈ្មោះសៅទៅវិញជាដើម ដោយគេបបទេសថា រួចនឹងឈ្មោះមុនតោះ ទុកឱ្យចាស្លាប់ជាតិបង់ទៅហើយ ឯរួចនឹងឈ្មោះក្រោយនេះ ទើបនឹងកើតថ្មី ។

រឿងព្រេងនិងរឿងបុរាណជប៉ុនក្នុងមធ្យមសម័យ

(តមក)

លោក ង៉យ-ប៊ុក ប្រែរៀបរៀង

រឿងលោកវ៉ាតាណាបេណ្ឌស៊ុណា និងនាងអាប

សម័យមួយ ពលរដ្ឋកងក្រុងតូយ៉ូតូ (ប្រទេសជប៉ុន) បានទាំគ្នាតស៊ូទំស្មោកយតក់ស្ទុតឥតឧបមា ដោយបានឮដំណឹងថា មានឥសីអាបមួយបានតំយាជមនុស្សម្នាក់ពីពេលព្រឹក ។ មានមនុស្សជាច្រើន ប្រជុំគ្នាតាមវិថីពាំនឡាយ ជជែកគ្នាពីព្រឹត្តិការណ៍នេះ ដោយគោលថា :

"គួឲ្យខ្លាច គួឲ្យតក់ស្ទុត . . . . ពលំថ្ងៃនាងអាបតែងសម្លាប់មនុស្ស .., ក្នុងកាលកន្លងមកបីខែហើយ -- តើនាងអាបសម្លាប់មនុស្សប៉ុន្មាននាក់ហើយ . . . . នាងអាបនេះ ពំនៅកងស៊ើនដ៏តមាត់ភ្នំក្រុងតូយ៉ូតូ ។

មនុស្សម្នាក់សួរថា តើអ្នកឯងធ្លាប់បានឃើញរូបនាងអាបនោះទេ?។

-ខ្ញុំមិនដែលបានឃើញទេ , តែកូយខ្ញុំម្នាក់បានឃើញ ហើយវាបានប្រាប់ខ្ញុំថា :

«នាងអាបនេះ មានមាឌគួរស្បើមពេកណាស់, មុខវាពណិប្រផេះដូចពណិដី សក់កន្ត្រើនស៊ើៗមម៉ើង ភ្នែកស្តាំធំសំឡឹងទៅលើ ភ្នែកឆ្វេងតូចសំឡឹងមកក្រោម , ប្រមុះធំមួរមួលគ្នា មាត់ធំប្រកាប បបូរមាត់

ក្រាស់ក្រហមដូចប្រឡាក់ឈាម ; កាលណាមានមនុស្សដើរទៅជិតសេះ
នោះ ចង់ចូលឬចេញពីទីក្រុង . នាងអាបនោះយារដាវគ្រវីលោតទៅ
សង្កត់កាច់មនុស្សនោះ ឲ្យបួសឬស្លាប់មួយរំពេច, ជួនកាលវាហោះ
ទៅលើអាកាស ស្មែងរកពាក្យបង់វាដែលវាកាប់ឲ្យបួស បើឃើញទៅ
ទីកន្លែងណា វាលោតចុះទៅសង្កត់ពីលើ ចាប់យកមកជាអាហារដូច
គ្នាត..,ហើយរឿងនេះខ្ញុំបានសួរអ្នកជិតខាងម្នាក់ថា «តើអ្នកឯងដឹងដំណើរ
ហេតុអ្វីបានជានាងអាបនេះស្អប់មនុស្សខ្លាំងម៉្លេះ?» ។ អ្នកនោះបានឆ្លើយ
ថា បានជាវាស្អប់មនុស្ស ព្រោះវាមានចិត្តលំបាកជាខ្លាំង ដោយសារតែ
មានរូបអាក្រក់, ហើយមនុស្សតែងចុះបង់ចោលវា ជួនកាលមានមនុស្ស
និយាយពាក្យចំអកឡកឡឺយឲ្យវាឈឺចិត្ត វាមានបំណងចង់បានបុរសជា
ស្វាមី ប៉ុន្តែ គ្មានបុរសណាអាចហ៊ានចូលមកជិតវាសោះ ។ ម៉្យាងទៀត
នាងអាបនេះវាអាចកាឡាខ្លួនជាស្ត្រីមានរូបស្អាតគួរពិស្ម័យក៏បាន ប៉ុន្តែ
វាមិនកាឡាខ្លួន ព្រោះមានបំណងចង់ឲ្យគេស្គាល់ខ្លួនវាដោយរូបកាយ
ធម្មជាតដូច្នេះ ហើយមិនបានសម្រេចដូចបំណង ទើបវាធ្វើអំពើកាច
សាហាវចំពោះមនុស្ស ដែលព្រោះតែយកន្ត្តើយចំពោះខ្លួនវា " ។

មនុស្សពាលនោះ ក៏ពាក្យគ្នាដោយត្រួយថាវម្តងថា: តើអ្នកណាហ្ន៎
អាចជួយស្រោចស្រង់យើង ឲ្យរួចពីកណ្តាប់ដៃរបស់នាងអាបនោះបាន ។

ថ្ងៃក្រោយមក ស្តេចត្រាញ់ទៅក្នុងក្រុងតិយ៉ូតូ ទ្រង់ជ្រាបប្រមូលពួកយោធាចាំធ្វើយ ហើយទ្រង់មានបន្ទូលថា: លោកអ្នកបានដឹងហើយថា មានទាំងអាបមួយនៅខាងមុខភ្នំងគ្រាក្រុងតាំងពីយូរមកហើយបានសម្លាប់មនុស្សក្នុងទីក្រុងជាច្រើន ក៏មិនឲ្យអ្នកណាចេញពីទីក្រុងឬចូលមកក្នុងក្រុងបានឡើយ ក៏តែងតាន់ជាវត្ថុរបស់លោតទៅតាមមនុស្សឲ្យប្រុងប្រយ័ត្នស្មាប់មិនខាន, យើងមិនអាចខុកស្ងាតការណ៍បែបនេះឲ្យបិតនៅតទៅទៀតទេ ត្រូវតែកំចាត់វាចេញ. ខ្ញុំមានចំណងចង់កេរយោធាក្លាហានម្នាក់ ដែលអាចតយុទ្ធនឹងវាបាន បណ្តាលោកអ្នកជាមេរយោធាចាំធ្វើយតើអ្នកណាអាចនឹងការៈបែបនេះបាន ? ។

ក្រោយដែលមានការស្ងប់ស្ងៀមមួយស្របក់ មានមេរយោធាម្នាក់ទ្រើយថា " ខ្ញុំបង្គំ ! " ។ មេរយោធាចាំធ្វើអស់ក៏ក្រេឡេកមើលទៅបុរសយុវនែ ដែលទើបនឹងក្រាបបង្គំទូលតបព្រះអង្គ ។

បុរសនេះ ជាមេរយោធាមានឈ្មោះល្បីល្បាញថាជាម្ចាស់ក្លាហានមានទាមថា លោកព៌តាណាបេណូស៊ុណា ។

ស្តេចត្រាញ់ ទ្រង់មានព្រះបន្ទូលតបទៅលោកព៌តាណាបេណូស៊ុណាថា « យើងអត្តុណាជាអនេកប្បការ, ព្រឹកស្អែក អ្នកត្រូវចូលទៅតយុទ្ធនឹងទាំងអាបកុំខាន» ។

លុះពេលព្រឹក លោកវ៉ាតាណាបេណូស៊ុណា ក៏ចេញទៅតាម
ខ្នាងទ្វារខាងជើងនៃទីក្រុងតិយ៉ូតូ ។

មេយោធានេះ មានមាឌធំ ស្គម មុខមានសម្បុរដូចលង្ហិន ភ្នែក
ចោលស្មើខ្ញាំងណាបន្តេះ ចិញ្ចើមញាក់ម្ខង ។ ដៃញាស្រឡឹតរលាំគ្នា,
ពាក់គ្រឿងក្រោះធ្វើពីដែកថែប ពាក់ស្រោមដៃធ្វើពីស្បែកមានពាសដែក
ពាក់ម្ខាងដែលកាំភ្លើងកាន់ជាប់, កាន់ដាវវែងមួយទៅដៃ, ពេលនោះ គាត់ក៏គិត
មកដល់កូនប្រុសដែលមានអាយុ ៨ ឆ្នាំថា អញប្រហែលជាលែងឃើញ
មុខកូនហើយ ប្រសិនបើអញត្រូវស្លាប់ក្នុងពេលតស៊ូនឹងខាងអាបនេះ,
ប៉ុន្តែ អញអាចពុកអនុម្បាវ័យមួយដ៏ត្រកាល ប្រកបដោយការល្បី
ល្បាញទៅក្នុងចិត្តនៃកូនអញដែរ ។

ពេលនោះ ខាងអាប លុះក្រឡេកឃើញមេយោធាកំពុងដើរមក
ចំមុខខ្លួនដូច្នោះ មានចិត្តត្រេកអរឥតឧបមា ដោយនឹកក្នុងចិត្តថា «បុរស
នេះ ត្រូវបានជាចំណីអញឥឡូវនេះហើយ” តែនស្រេច ខាងអាបបើក
ទ្វារស៊ើន កាន់ដាវត្រៀមដោយសេចក្តីក្លាហាន រង់ចាំមេយោធានោះ,
ខាងអាប ធ្វាប់តែត្រៀមជាស្រេចហើយ មនុស្សដែលដើរមកកាន់ទីនោះភ័យ
តក់ស្លុតរត់ខ្ចាត់ខ្ចាយ ។ ផ្ទុយទៅវិញ លោកវ៉ាតាណាបេណូស៊ុណា
នេះឥតតក់ស្លុតសោះ ស្រាប់តែលោតដោយការបញ្ចេញស្នៀតយ៉ាង

រហ័សដូចព្រួញទៅតាមណាស្ត្រដ៏ឆ្នើម គេចផុតពីមុខឯវាទាន
គាប ហើយសុំទៅកាប់ដៃស្តាំទានគាបជាប់ភ្លាក់ពុះ ហូរឈាមស្រោក
មួយរំពេច ។

ទានគាបឈឺឈួលខ្លាំង រត់ចូលទៅកន្លែងស៊ីនវៃស្រែកទ្រហោយំ។
លោកវ៉ាតាណាបេណូស៊ុណា ឧទរើសកំណាត់ដៃស្តាំទានគាប
យកសំពត់ព្រែរុំខ្ចប់ឲ្យស្អាត រួចមកផ្ទះវិញ ហើយលោកនឹកក្នុងចិត្តថា
« តើកូនប្រុសរបស់អញមានចិត្តសប្បាយយ៉ាំងណាទៅ ដល់វាដឹងថា
ឪពុកវាមានសេចក្តីក្សាហាន កាប់បានដៃទានគាបនោះ! ប្រហែលជាវា
បន់ដឹងទូវាតេស៊ូឪពុកវាចំពោះទានគាបទេដឹង ! " ។

លុះមកដល់ផ្ទះក្នុង, កូនប្រុសទីឯកូនស្រីរបស់លោក នាំគ្នារត់
ត្រសែងទៅទទួលឪពុក មានចិត្តត្រេកអរយ៉ាំងខ្លាំងអង្វរឪពុកថា សូមប៉ា
បង្ហាញដៃស្តាំទានគាបឲ្យកូនឃើញផង កូនចង់ឃើញណាស់! ហើយ
សូមប៉ាបង្ហាញឲ្យប្អូនស្រីឃើញផង ព្រោះអូនចង់ឃើញណាស់ដែរ ។

លោកវ៉ាតាណាបេណូស៊ុណាញាក់ចិញ្ចើម ហើយតបទៅកូនលោក
វិញថា ទេ, កូន! ឪពុកបានប្តេជ្ញាកន្លែចិត្តថា មិនបង្ហាញដៃអាបឲ្យនរ-
ណាឃើញឡើយ ។

បន្តិចមក តាំយោលោកក៏ចូលមកដល់ ឃើញស្វាមីនៅម្នាក់ឯងគិ

អង្គរស្វាមីថា សូមបងមេត្តាបង្ហាញដៃអាបខ្ញុំឲ្យឃើញផង ដែលជាកស្តុតាងនៃសេចក្តីក្លាហានរបស់បង ។ ខាងឯការ ចើទុកជាខ្លួចអង្គរស្វាមី ដោយពាក្យផ្អែមល្ហែមយ៉ាងណា, ក៏ស្វាមីខាងមិនព្រមបង្ហាញដៃខាងអាបជាដាច់ខាត ។

✓ លុះពេលរសៀល មានយាយចាស់ម្នាក់មកសុំជួបនឹងលោកព្រាហ្មណាបេណ្ឌសុំណា ។ យាយចាស់នេះ គឺជាម្តាយមីង ដែលបានថែរក្សាលោកតាំងពីតូច ព្រោះលោកជាកូនកំព្រាតាំងពីនៅជាទារកទៅឡើយ, គាត់ពាក់អាវវែងមានសម្បុរស្រអាប់ មានមុខសក្តិដូចក្តុក ទឹកមុខស្លូតបូត តែជួចជាព្រួយចិត្តបន្តិច, លុះបានជួបនឹងលោកព្រាហ្មណាបេណ្ឌសុំណា គាត់ទៅជាមានទឹកមុខរីករាយទៅវិញ ដោយបានជួបនឹងកូយគាត់ ហើយក៏សរសើរថា:-

មីងបានដឹងថា ឯងខ្លួនឯងជាគជ្ជយាំងប្រសើរ ពីរបីថ្ងៃមុនៗមកនេះ មនុស្សដែលនៅក្នុងសង្កាត់ភូមិមីង បានសរសើរតែពីសេចក្តីក្លាហានរបស់កូយ, ឯមីងមកសួរសរសើរសេចក្តីក្លាហានរបស់កូយ សរសើរដោយស្មោះស្ម័គ្រ, មីងមានសេចក្តីត្រេកអរចំពោះកូយ ដែលបានសម្រេចនូវកលល្បាណកិច្ចដ៏ប្រសើរនេះ ។

លោកព្រាហ្មណាបេណ្ឌសុំណា កំពុងតែស្តាប់តាមពាក្យម្តាយមីងដែលលោកទុកដូចជាមាតាបង្កើត ហើយតបទៅម្តាយមីងថា:-

ឯមីងអើយ ! មីងចិត្តល្អនឹងខ្ញុំណាស់ ពិតមែនតែគ្មានពេលទំនេរមកលេងនឹងខ្ញុំ ប៉ុន្តែ មីងទំធ្វើតទុកាសមកជួបនឹងខ្ញុំៗ មានសេចក្តីត្រេកអរណាស់ ។

ម្ចាយមីងក៏ពោលថា នែកញ្ញា ! កញ្ញាអាណិតមេត្តាមីង ... មីងសូមឲ្យកញ្ញាបង្ហាញខ្លួរដៃនាងអាបនោះ តើមានសភាពបែបណាទៅ ! មីងចង់ពាល់ដៃនាងអាបនេះ សូមកញ្ញាកុំប្រកាន់ទីង ។

លោកព្រាហ្មណ៍បេលូស៊ីណា មានចិត្តរួញរា ហើយពោលតបថា លោកម៉ែ ! ខ្ញុំបាទមិនត្រូវបង្ហាញដៃនាងអាបនេះឲ្យកើយាបុត្រាបុត្រីខ្ញុំឃើញសោះ, ខ្ញុំបានប្តេជ្ញាថា នឹងមិនបង្ហាញដៃនាងអាបនេះឲ្យនរណាឃើញសោះ តែចំពោះលោកម៉ែជាម្តាយរបស់កញ្ញា ខ្ញុំពុំកលោកម៉ែដូចជាមាតារបស់ខ្ញុំ ព្រោះលោកម៉ែបានបីបាច់រក្សាខ្ញុំតាំងពីតូចមក ។ ខ្ញុំមិនអាចនឹងមិនឲ្យលោកម៉ែ ឃើញដៃនាងអាបនោះសោះឡើយ, ករណីយកនេះ គឺត្រូវតែខ្ញុំបង្ហាញឲ្យលោកម៉ែឃើញដោយមិនបាច់ ... ។

លោកព្រាហ្មណ៍បេលូស៊ីណាបាននិយាយថា កុំឲ្យអ្នកណាចូលក្នុងបន្ទប់នេះជាដាច់ខាត រួចលោកដើរទៅយកដៃនាងអាបមកស្រាយកំណាត់សំពត់សូត្រដែលរុំនោះចេញ ។

គេលនោះ ម្ចាយមីងលោកយកដៃធ្វើឈោងចាប់ដៃអាប កំព្រីកេម ព្រីស្បែក ជាខ្លាំង ហើយពោលថា:-

ម៉ឺងមានចិត្តត្រេកអរពន់ពេក ដោយបានឃើញដៃគាបនេះ ។

លោកវ៉ាគាណាបេណ្ឌាស៊ុណា បើកភ្នែកធំមើលចំមុខម្ចាយម៉ឺង លោក ។ បានឮសូរសម្លេងអំបាញ់មិញនេះ ហាក់ដូចជាមិនមែនសូរសម្លេងម្ចាយម៉ឺងលោក ព្រោះសម្លេងនេះមានសភាពប្លែកពីធម្មតា ។

ក្នុងពេលមួយរំពេចនោះ មុខម្ចាយម៉ឺងលោក ក៏ពេជ្រាមុនប្រផេះ មានឆ្នូត គគ្រាតគគ្រើមគួរឲ្យស្អប់ខ្ពើម ច្រមុះយឺតវែងរមួលគ្នា ភ្នែកស្តាំរីកធំបើកចាញ់ចេញលើ ភ្នែកឆ្វេងតូចបើកចាញ់ចេញក្រោម... ។

លោកវ៉ាគាណាបេណ្ឌាស៊ុណា កំសត់ក្រៃ ហើយដឹងច្បាស់ថា ស្រីនេះ មិនមែនជាម្ចាយម៉ឺងលោកទេ គឺនាងអាបនោះឯង... នេះគឺជាឧបាយបន់នាងអាប ដើម្បីឲ្យបានដៃយកទៅវិញប៉ុណ្ណោះ ។ លោកមេយោធាឥតនិយាយអ្វីមួយម៉ាត់ឡើយ លោកក៏ស្ទុះចេញទៅយកដាវ ដល់លោកវិលត្រឡប់មកវិញ, ស្រីនោះកំបាត់ពីនោះទៅ ទ្វារផ្ទះរបស់លោកចំហ លោកស្ទុះទៅមើលតាមទ្វារនោះ ស្រាប់តែឃើញនាងអាបហោះយ៉ាងលឿនកណ្តាលអាកាស មានដៃតែមួយ ហើយកាន់ដៃស្តាំរបស់វ៉ាមានពណ៌ក្រហម, ខ្លួនវ៉ាគាក់អាវវែងមានពណ៌ប្រផេះ ។

ចប់រឿងវ៉ាគាណាបេណ្ឌាស៊ុណានឹងនាងអាប

(នៅមានត)

កណ្ឌទី ៤១

ទេសកថាវិបុលពាជសេនា ឆ្លងកន្ទួល ប្រៃរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះខួបយកលបំណាន
> ទាំងមានសន្ធានស្នេហាជាតិ។

ចាំនឹងថនឹងធ្វើយេថា ខ្ញុំចូរមកកែលោកនេះ មិនមែននឹកឃើញដល់បណ្ដាស័ក្តិទេ ព្រោះអាណិតអាណាប្រជាពុកស្ត្រីនឹងឲ្យជាសុខ ប្រសិនបើលោកបានស្រុកតាំងតាំងហើយ សុំកុំសម្លាប់ញាតិបងប្អូនខ្ញុំបាទដែលនៅក្នុងស្រុកនោះឡើយ ។

ចូរឆ្លើយថា ខ្ញុំធ្វើការសឹកសង្គ្រាមនៅណាដំបន់ណាក្តី មិនមែននឹងឲ្យពាស្ត្រីបានសេចក្តីក្តៅក្រហាយសោះឡើយ គឺតែតែបំរុងឲ្យបានសេចក្តីសុខថែមទៀត ដែលខ្ញុំឲ្យគាប់សម្លាប់ខ្លះនោះ ព្រោះតែមនុស្សនោះកំណត់ទុំដំ បើប្រសិនជាអ្នកខ្លាចក្រែងញាតិបងប្អូនអន្តរាយ ខ្ញុំនឹងធ្វើសំបុត្រទៅ

ឃុំក្បាទុកជាសំគាល់ ។ ជាំងថងធ្វើជាគ្រែកអានុនគំនាប់ហើយថា បើ
មហាទេពជាណាតមេគ្លាឲ្យសំបុត្រទៅឃុំក្បាទុក ខ្ញុំបានកំអស់សេចក្តី
វិតក្កទុក្ខព្រួយ ។ ចូរឆ្លើតែងសំបុត្រឲ្យ ។ ជាំងថងកំពុលយកសំបុត្រ
ហើយផ្តាំទីងចូរឆ្លុកថា បើខ្ញុំបានទៅហើយឲ្យមហាទេពជាំប្រញាប់ចាត់
ចែងកងទ័ពទៅច្បាំងទីងដីវាយជាមុន កុំចាំឲ្យដីវាយមកទាន់ ហើយចាំងថង
តំលាចូរឆ្លេញមកចុះខ្លួក ។

ខណៈនោះឈើស៊ុដែលទៅដំតទ័នោះ តំស្ទុះទៅចាប់ជាយអាវចាំង-
ថងទុកហើយនិយាយថា ខ្លួនអ្នកនេះអង់អាចណាស់ ខ្លាចជាក្តើងនោះនេះ
មិនអស់តាហានចូរឆ្លុយ ចានជាក្តែងតំតជាកលទាយមកបញ្ឆោតចូរឆ្លុយចង
ក្បួនខ្លួកចម្បាំងទុកទៀត ប្រាថ្នាទីងឲ្យដុតតាហានទីងខ្លួកចម្បាំងចេញឲ្យ
អស់រលីងតែម្តងឬ ដែលជាម្រេះរិះគិតរបស់អ្នកនោះនីងមិនយល់ច្នុះចានតែ
ចូរឆ្លុ ឯខ្លួនខ្ញុំអាចជំនីងដល់តាំងអស់ ។ ជាំងថងឮដូច្នោះតំតក់ស្លុតតក់ឃ
រន្ធត់ស្មារតី ក្រឡេកមើលមកក្រោយកំយើញឈើស៊ុតែម្នាក់ឯងកំដួចជាឆ្លូ
ខ្លួលយកក្នុងចិត្ត ព្រោះឈើស៊ុជាក្មេងសម្លាញ់ស្និទ្ធនីងគ្នាមកពីក្មេងហើយ
ជាដែលខ្ញុំរិះគិតមកនិយាយនីងចូរនេះ ព្រោះស្តាយស្រុកកាំនតាំងជាខែត្រ
ឯក ហើយមានខែត្រឡើងដល់ ៨១ មណ្ឌល ក្រែងមានអន្តរាយ តាំង
ប្រជានុកស្តែចំណុះស្រុកកំនីងដល់ខ្លួរសេចក្តីស្លាប់តាំងអស់គ្នា ចានជាខ្ញុំ

មកបញ្ឆោតចូនូ ប្រាប់ថានឹងជួយជីវិតអ្នកស្រុកតាំងអស់ទៀៅ ។ ឈើស៊ី
កំធ្វើជាតបថា ខ្ញុំអ្នកមានចិត្តអាណិតស្តាយពួកស្រុកតាំងតាំងខ្លាចអន្តរាយ
ទើបមកប្រាប់ឲ្យចំរើនគិតឲ្យបានការយ៉ាងនេះ ចុះគាបានចូនូដល់ ៨៣
ម៉ឺនទោះ អ្នកគ្មានចិត្តអាណិតថានឹងដល់ទូរសេចក្តីស្លាប់តាំងអស់ទេឬ ? ។

ចាំងឋងថា ការតាំងអម្បាលនេះ មិនមែនជាការបង់ស៊ុនតួនតែ
ម្នាក់ឯងទេ គឺជាការបង់ទៀតពីចៅហ្វាយចាស់អ្នកខោះដែរ ដែលអ្នកថា
ដូច្នេះមុនជាយកសេចក្តីដែលខ្ញុំគិតនេះ ទៅប្រាប់ចូនូឲ្យដឹងម៉ឺងឬ ? ។ ឈើ
ស៊ីតបថា ដែលខ្ញុំបានផុងខ្លួនមកនៅនឹងចូនូដូច្នេះ គឺមកដោយសេចក្តីថា
ចិត្ត លុះមានាខ្ញុំស្លាប់ទៅ ខ្ញុំក៏មានចិត្តនឹកខឹងនឹងចូនូជាបងសព្វថ្ងៃនេះ
ខ្ញុំក៏មានចិត្តលើកគាល់យកទៀតមិនក្រែងសោះ ព្រោះគិតដល់គុណទៀត
ដែលមានមកពីដើម កាលដែលនឹងឃ្លាតចាកមកក៏បានស្បថស្បែងគ្នានឹង
ទៀតថា ខោះបើមកនៅទីតនេះក្តី ក៏មិនបានប្រាប់កលសឹកអ្វីនឹមួយឲ្យ
ចូនូដឹង ឥឡូវខ្លួនអ្នកក៏បានរំគិតនឹងដុតទីតចូនូឲ្យអស់ ហើយនឹងចង់ដុត
តាំងខ្លួនខ្ញុំផងទៀតឬ ? ។ ចាំងឋងថា ហេតុម្តេចអ្នកមកចរចាដូច្នេះ ឯជម្ង-
តាអ្នកមានជម្រះប្រាជ្ញា ថើមានតំយាមកដល់ខ្លួនហើយ មិនគិតនឹងយក
ខ្លួនឲ្យរួចក៏មិនហៅថាជាអ្នកមានប្រាជ្ញាបាន ហើយចាំងឋងក៏លាចុះ
ទូកទៅ ។

ឯឈ័ស៊ុ លុះចាំដ៏ថង់ទៅហើយក៏គិតថា បើយើងនៅក្នុងខ័ពបួនតទៅ គឺតងំនឹងបាននេចក្តីលំបាកវេទនា គួរតែម៉ូមាប្រែប្រួលគិតឲ្យរួចភ័យ ទើបប្រើមនុស្សស្និទ្ធស្នាលឲ្យដើរទៅនិយាយឮលឺថា មានអ្នកជំនួញមកច្រាប់ដំណឹងថា ម៉ាថេនឹងហ៊ានស៊ុយដែលនៅស្រុកសេលៀនខោះ ទឹងលើកកងខ័ពមកវាយយកស្រុកហ៊ូតោ ។ បណ្តាគហានបួនដ៏ឮលឺថា មានអ្នកជំនួញមកច្រាប់ដំណឹងថា ម៉ាថេនឹងហ៊ានស៊ុយដែលនៅស្រុកសេលៀនខោះ ទឹងលើកកងខ័ពមកវាយយកស្រុកហ៊ូតោ បណ្តាគហានបួនដ៏ឮដូច្នោះក៏ព្រួយចិត្ត គិតភ័យគិតដល់គ្រប់គ្រួ ទើបនាំគ្នាចូលទៅច្រាប់បួនតាមគិត្តិសព្ទដែលឮខោះ ។ បួនដ៏ដូច្នោះទើបប្រឹក្សាសេនាគហានទាំងឮថាការយើងនឹងលើកកងខ័ពមកច្រាប់ច្រាមអាណាខ្ញុំគ្រមាត់ខ្ញុំ ក៏គិតភ្ញាក់តែម៉ាថេនឹងហ៊ានស៊ុយប៉ុណ្ណោះ ឥឡូវឮដំណឹងមកថា ម៉ាថេនឹងហ៊ានស៊ុយលើកកងខ័ពមកវាយស្រុកហ៊ូតោហើយ គួរនឹងឲ្យនរណាដែលមានថ្លៃដៃទាំងតួតែខ្លួលអាសាចេញទៅការពារបាន ។

ឈ័ស៊ុឆ្លើយថា ខ្ញុំបាទមកនៅទីនេះគំមិនខាន់បាននេធ្វើការអ្វីឲ្យជាគុណបំណាច់ឡើយ ឥឡូវមានសត្រូវមកចំងាំហើយ ខ្ញុំបាទនឹងសុំអាសាលើកគហាន ៣ ពាន់ទៅចាត់ចែងជាក់តយល្បាតប្រុងប្រយ័ត្នស្កាត់តាមច្រកផ្លូវដែលទៅត្រូវលើស្រុកហ៊ូតោជាមុន បើសិនណាសឹកសត្រូវ

មកលើសលប់ទីធំខប់ពុំបាន ខ្ញុំបាទទីធ្វើមានសំបុត្រប្តឹងមកលោកឱ្យបាន
ជ្រាប ។ បួងួចបានឮថា ឈើស៊ីសុំគាសាភៅកំមានចិត្តត្រេកអរថា ដែល
អ្នកខ្លួលភៅនោះយើងគាប់ចិត្តណាស់ ព្រោះគាហានខាងណោះកំសល់
ភៅជាច្រើន បួងអ្នកចាត់ចែងចែងរំលែកយកភៅចុះ ហើយកំប្រមូល
គាហាន ៣ តាន់ឡើងចាប៉ាជាខ័ងស្រួច ឈើស៊ីទីធំងចាប៉ាកំណាបួងួចចេញ
ភៅដល់ស្រុកហ៊ូតោ ។

ឯបួងួលុះវេលាព្រឹកកើរឿងសេះនាំគាហានដើរត្រួតមើលបន្តាយដើង
គោកឃើញមាំមួនទាំងអស់ហើយកំត្រឡប់មកវិញ លុះវេលាល្ងាចគំចុះ
ទូកចេញភៅត្រួតកងខ័ងកើត ដែលអ៊ីតិម ម៉ាយរៀបចំឱ្យចងជាក្បួន
ទុកជាកង ។ ហើយបង្គាប់ឱ្យគាហានចាត់ចែងគ្រឿងសស្ត្រាវុធទីធ្ងន់ទុក
តាមសើនបន្តាយ ហើយតែងតុលៀងសេនាគាហានទាំងពួង ។ ក្នុង
ខណៈនោះព្រះចៅហៀនគេសោយរាជសម្បត្តិបាន ១២ ឆ្នាំ (ព.ស.
៧៤៤) ។ គាលបួងួចុះមកត្រួតកងខ័ងទូកនោះជាវៃបុស្ស ១៥ តើត
ព្រះចន្ទ្រពេញវង្សត្រួចធ្លាក់ត្រចះជ្រះថ្លា ឥតាកំស្ងប់ស្ងាត់ឈឹង សមុទ្រធំ
ល្វឹងល្វើយគ្មានលេកសោះ ទូកខ្លានទាំងអស់ទីធ្លាប់ជួបផែនដី តោះប៉ីទីធ
មានលេកឡល់ចក់ដោកមកធំយ៉ាងណា បណ្តាទូកបម្បាំងទាំងអស់នោះ
កំមិនរំតើបទីធ្លាប្រែប្រួលភៅណា ទាំងបណ្តាគាហានកំមិនមានពុលរលេក។

ឯចៅក្នាក់ងារគ្រឿងលេងក្មេងតូរ្យតន្ត្រី កំនាំគ្នាដេញចាប៉ីកូតទ្រូស្ទូរ
ទ្រហឹងអឺងអាច ។ ចូនឆ្លើយញាតហានស៊ុលឿងតាមរបៀបថៃរន្ធាន់ខ្លាប់
ម៉ើលប្រហែល ៣០០ ប៉ាយ នាំគ្នានិយាយតិការសង្គ្រាមទៅវិញទៅមក
ខណៈដែលចូនឆ្លូកំតុងសេពសុពនៅជាកណ្តាលចូកដែ ជាមួយសេនា
ញាតហានទាំងពួងនោះ ក៏ក្រឡេកមើលទៅលើអាកាស ឃើញខាងស្រុក
កាំងតាំងនៅទិសបូព៌ា ទឹងស្រុកកាំងហៅក្បែរមោត់ទន្លេខាងទិសបស្ចឹម
មើលទៅទិសទក្តរ ទិសទក្សិណក៏ភ្លឺដោយពន្លឺព្រះចន្ទ្រ ចូនឆ្លូកំមានសេចក្តី
សោមនស្សរីករាយ ហើយនិយាយទឹងញាតហានទាំងពួងថា ពីដើមយើង
គិតថា ទឹងទំនុកបំរុងផែនដីឲ្យជាសុខ យើងក៏បានធ្វើការច្រាប់ច្រាម
សត្រូវរៀងមកជាច្រើនដំបន់ហើយ ឥឡូវនៅសល់តែស្រុកកាំងតាំង ១
ខ្លាំងពូកែជាងគេ ឲ្យអ្នកទាំងពួងរួមប្រមូលឲ្យមូលចិត្តគំនិតគ្នាជួយយើងឲ្យ
បាន ទឹងកំចាត់ស៊ុនតួន, ដើរយើចេញ ហើយស្រុកខេសក៏ទឹងនៅជាសុខ
យើងទាំងឡាយក៏ទឹងបានឃើញមុខគ្នាជាទីសប្បាយ ។ ទីប្រឹក្សាទឹងសេនា
ញាតហានទាំងឡាយបានឮចូនឆ្លូថាដូច្នោះ កំនាំគ្នាតំនាប់ហើយថា សូមឲ្យ
ទេវតាជួយឲ្យបានសម្រេចដូចសេចក្តីប្រាថ្នាចុះ យើងខ្ញុំទាំងឡាយទឹង
បានជាទីពឹងតទៅ ។ (នោមានត)

ពាក្យវិប្បដិសារ

លោក ខាង-ហ៊ូ រៀបរៀង

លោក សម-ចាំង ពិនិត្យ

អស់លោកអ្នកអានភិតភិញ្ជាយ !

ក្នុងពេលនេះគណៈកម្មការវិប្បដិសារូមជូនការកែតង់ ចំពោះពាក្យ ឥរិយាបថ ម៉ាត់ខ្មែរ ហើយដល់ទៅពេលខាងមុខ ទើបលើកយកពាក្យខ្លះដែលបានបង្កើតថ្មី មកធ្វើអត្ថាធិប្បាយពន្យល់អស់លោកអ្នកអាន ឲ្យបានស្រាលច្បាស់ ដើម្បីងាយស្រួលចំពោះលោកអ្នក ដែលត្រូវការប្រើប្រាស់ នូវពាក្យនីមួយ ៗ តាមគួរដល់ការណ៍ ។

ចំពោះពាក្យឥរិយាបថ ដែលត្រូវលើកយកមកកែតង់ក្នុងពេលនេះគឺ:

១- អធិបតេយ្យភាព,

២- ឯកភាជ្យភាព,

៣- អយស្ម័យយោគ, ។

១- អធិបតេយ្យភាព សព្ទនេះយើងគ្រាប់ប្រើមកខ្លះ ពាំងនូវការខ្វែងនូវសារតម្លាទថា : អធិបតេយ្យភាព។ រត់ដៃ រត់មាត់ឥស់ទៅហើយ ។ សព្ទនេះបើសង្កេតរកឫសគល់ដើម គឺជាពាក្យបាលី ។ តាមវេយ្យាករណ៍បាលីលោកហៅថា តទ្ធិត (Adjectif dérivée) បានជា

ឯកសទ្ធតហៅថា តទ្ធិត ព្រោះអធិបតេយ្យនេះសំរេចមកពីសព្ទពីរគឺ : "អធិបតិ" មួយសព្ទនឹង "ភាវៈ" ដែលត្រាយមកជាភាគមួយសព្ទ ។ ដល់ចុះណេយ្យបច្ចយ ក្នុងពួកភាវតទ្ធិតមកផ្សំផង បច្ចយនេះមានអំណាចឈរឈ្មោះជាជំនួសសព្ទថា ភាវៈ ឬ ភាព ជាន់ពេញថាវិបូណិ, អធិបតិ+ភាវៈ+អេយ្យៈសម្រេចរូបទៅជា អធិបតេយ្យ ។ ប៉ោចង៏បទវិគ្រោះ តាមវេយ្យាករណ៍ហ៊ាលីសម្រាប់បទតទ្ធិតថា អធិបតិនោ-ភាវោ=អធិបតេយ្យំ ប្រែថា ភាពនៃបុគ្គលជាធំ ឬថា ភាពនៃអ្នកធំ (:ហៅថាភាវតទ្ធិត) ។ ដូច្នេះបញ្ជាក់ឲ្យឃើញច្បាស់ថា អធិបតេយ្យនេះ បើត្រូវការចង៏និយាយ មិនចាំបាច់យកសព្ទថា "ភាព" មកជាក់ផ្តឹតខាងមុខថា "អធិបតេយ្យភាព" ផងទេ ព្រោះស័ព្ទថា អេយ្យៈនេះ ចេញមកជាជំនួសសព្ទថាភាវៈ ឬ ភាព ទៅហើយ ។ តាលបើយើង៏និយាយថា "អធិបតេយ្យភាព" ។ ដូច្នេះនោះតាមតិតឃើញមានសព្ទថា "ភាព" ទៅក្នុង៏នេះដល់ពីរដង៏ទៅហើយ ។ តីអធិបតេយ្យភាពត្រូវប្រែថា «ភាព-ភាពនៃបុគ្គលជាធំ» ស្មើគ្នានឹង៏ពាក្យថា «អធិបតិភាព.ភាព» ដែរ ដោយហេតុនេះ បើយើង៏ចង់ប្រើពាក្យផ្លាស់ប្តូរគ្នា ត្រូវប្រើថា អធិបតិភាព ដែលមានន័យប្លែកគ្នានឹង៏ អធិបតេយ្យដែរ តីថាអធិបតិភាព កំតីអធិបតេយ្យ ។ កំតីអធិបតិភាពប្រែថា ភាពនៃបុគ្គលជាធំដូចគ្នាទាំង៏ពីរសព្ទនេះ ។ ដូច្នេះ បើមែរទៅរកការត្រូវ,

យើងចង់និយាយថា "តាតនៃបុគ្គលជាធំ" សូមនិយាយតែត្រឹម «អធិបតេយ្យ» ប៉ុណ្ណោះបានហើយ ព្រោះត្រង់ស័ព្ទថា "តាត" នេះ មាន នៅក្នុងបច្ច័យអេយ្យៈស្រាប់ទៅហើយ ។

ឧទាហរណ៍តែមួយ ដែលបានលើកយកមកអធិប្បាយ បញ្ជាក់ជូននេះ សូមលោកអ្នកអានគិតឲ្យ បណ្តោយស្មារតីទៅកាន់ស័ព្ទជាតិខ្មែរ ដែលជាពួកតាតទ្វិត ចុះបច្ច័យដូចគ្នាតែមួយនេះផងចុះ ដូចជាស័ព្ទថា "ប្រជាធិបតេយ្យ ពាជាធិបតេយ្យ, ឯកាធិបតេយ្យ, អនាធិបតេយ្យ រាជាធិបតេយ្យ" ជាដើម ។ ស័ព្ទទាំងនេះក៏ដូចគ្នាទៃឯស័ព្ទថា «អធិប-តេយ្យ» ដែលបានអធិប្បាយខាងលើនេះដែរ ។ បើត្រូវតាមនិយាយ មិនចាំបាច់យកស័ព្ទថា «តាត» មកដាក់ពីខាងមុខទៀតឡើយ ព្រោះ ពាក្យតាតមានតប់នៅក្នុងនោះស្រាប់ហើយ ។

សុំបញ្ជាក់ជូនទៀតថា ប្រសិនបើចង់និយាយ ឬ សរសេរ ខ្លួសស័ព្ទ ថា "អធិបតិ" ហើយទើបតាតផងថា "អធិបតិតាត" ហើយអានទៅ តាមទម្លាប់ថា «អធិបតីតាត» ដូច្នេះវិញក៏ឥតមានខុសខ្លួសអ្វីទេ គ្រាន់ តែមានសូរសំឡេងខ្លួសគ្នា គឺស័ព្ទមួយថា "អធិបតេយ្យ" មួយថា «អធិ-បតីតាត» ប៉ុណ្ណោះ ។ ប៉ុន្តែចំពោះពាក្យ "អធិបតីតាត, គណៈ កម្មការប្រែថា "នៅក្រោមអធិបតីតាត" ដូច្នេះទេ ។

២-ឯកកជ្ឈភាវ៣ សព្ទនេះជាពាក្យសំស្ក្រឹតដែរ ។ កាលណាបើសរសេរថា "ឯកកជភាព" តើសរសេរ : ឯ-ក-រ ស្រៈអ-ជ-ភ-ស្រៈ អ ហើយទំនឹង- ដោយមិនមានជាក់ដើម.ច- ផ្ទើទំនឹងតួ ជ.ផងទេ។ ពាក្យថា "ឯកកជភាព" នេះ ទៅជាសមាសនាម ព្រោះរួមមកពីសព្ទពីរ គឺ:ឯកក ១ ន័ងភាព ១ ។ បើយើងច្រើជា "ឯកកជភាព" ដូច្នេះ កំបាន ឥតខាស់ទេ ។

ប៉ុន្តែបើសរសេរជា "ឯកកជ្ឈភាព" ដោយមានជាក់ដើម.ច-ផ្ទើទំនឹងឥក្សរ ជ ផង សព្ទថាឯកកជ្ឈៈនេះទៅជាតទ្ធិតទៅវិញ ។ ដូច្នេះ កាលបើសរសេរមិនចាំបាច់ឲ្យមានសព្ទថា "ភាព" នៅភ្ជាប់ឥតខាងមុខទៀតទេ "ឯកកជ្ឈភាព" នេះទំនឹងទៅជាមាន «ភាព» ដល់ទៅពីរដងនៅក្នុងនោះទៅហើយ ។ បានជាហ៊ានអះអាងដូច្នេះ ដោយហេតុសព្ទថា "ឯកកជ្ឈ" នេះ តាមវេយ្យាករណ៍សំស្ក្រឹត ជាភាវៈតទ្ធិត, ចុះណាឃ្យ-បច្ច័យ ។ បើចង់ជាបទវិគ្រោះបាលីថា ឯកកជស្ស ភាវោ=ឯកភ្លុំ, ប្រែថា ភាពនៃស្តេចឯក ។ វិគ្រោះជាសំស្ក្រឹតថា «ឯកកជស្ស ភាវ ឯក.កជ្ឈំ ខ្មែរយើងថា «ឯកកជ្ឈ» ។ ឯ ណ្យៈ បច្ច័យក្នុងភាវតទ្ធិតដែលចុះមកដូច្នេះ អាចផ្ទាស់ប្តូរជំនួសសព្ទមួយថា "ភាព" បាន ។ ដូច្នេះសឲ្យយើញថា «ឯកកជ្ឈ» នេះគឺមានសព្ទថា "ភាព" កប់នៅខាងក្នុង

ស្រាប់ហើយ, បើត្រូវតាមសេរីភាពនិយាយមិនចាំបាច់ជាក់ «ភាព» ពីខាងមុខទៀតឡើយ ។

សេចក្តីអធិប្បាយ ជាសង្ខេបដូចបានរៀបរាប់មកខាងលើនេះ ជាសេចក្តីល្អិតតិចបាតយល់បន្តិចបំពោះអស់លោកអ្នកអានខ្លះ ដែលពុំសូវបានសង្កេតពិនិត្យវេយ្យាករណ៍ជាលំនឹងសំស្លឹត ។ តែប៉ុន្តែជាការចាំបាច់ត្រូវតែរកតាយយកមកនិយាយ ព្រោះដើម្បីជាគ្រឿងបញ្ជាក់ដូនលោកអ្នកអានឲ្យយើញច្បាស់ថា បានជាគណៈកម្មការវប្បធម៌ហ៊ានតោលរិះគន់ ចំពោះសព្ទថា «អធិបតេយ្យភាព» និង «ឯកភជ្យភាព» ថាខុស ព្រោះអាងទៅលើគោលចារិកដូចបានរៀបរាប់ដោយសង្ខេបខាងលើនេះឯង ។

តាមការសង្កេតរបស់យើងសព្ទថា "ឯកភជ្យភាព" នេះប្រហែលជាអស់លោកអ្នកដែលចាប់សរសេរ ឬ និយាយនោះ ផ្គូផ្គងទៅនឹងពាក្យបារាំងថា Indépendance ទេដឹង ? ប្រសិនបើការស្មានរបស់យើងនេះ ត្រូវតាមចំណាំរបស់អស់លោកទាំងនោះពិតមែន យើងសូមបញ្ជាក់ដូនថា ពាក្យ Indépendance នេះគណៈកម្មការវប្បធម៌ បានផ្គូទៅនឹងពាក្យខ្មែរយើងថា «ឥស្សរភាព» ដែលបានសេចក្តីថាភាពជាធំឬភាពដែលស្រេចតែនឹងចិត្តទៅវិញទេ ព្រោះ Indépendance បារាំងគេ

ពាក្យសំដីថា Etats d'une personne indépendante ។

ដូច្នេះ បើអស់លោកត្រូវការបកប្រែពាក្យ Indépendance នេះ មកជាសេចក្តីខ្មែរ សុំកុំសរសេរថា "ឯកកជ្ឈភាព" សុំឲ្យប្រើថា "ឥស្សរភាព" ឬឯកកជ្ឈភៅវិញ ព្រោះពាក្យនេះគណៈកម្មការវៀតមិញបានផ្សាយជាផ្លូវការរួចទៅហើយ ។

៣-ពាក្យថា "អយស្ម័យយាន" ត្រូវអានថា «អៈយ៉ុស.ស្មៃយាន» កុំអានថា "អៈយៈស្មៃយាន» ឬអៈយ៉ុស.ស្មៃយៈយាន« ឡើយ ។

ពាក្យនេះ គណៈកម្មការវៀតមិញ បានចងក្តីតឡើងព្រមទាំងបានផ្សាយតាមផ្លូវការជាយូរមកហើយ ។ តាមការសង្កេតយើញថាជនជាតិយើងខ្មាប់ប្រើពាក្យនេះតាមផ្លូវការស្រួលមាត់ ស្រួលត្រចៀក លែងងាស់លែងតស៊ូឆ្ងល់ទៅហើយ ។ ពាំនឹកថាអ្នកជាការផ្នែកខាងក្រុមត្រួតត្រាពជអយស្ម័យយានរបស់ប្រទេសយើង ក៏បានយកពាក្យនេះ ទៅប្រើប្រាស់តេញលក្ខណៈដែរ ។ នេះតែងយើញសរសេរចារឹកទៅតាមតេញតែគន្លឹងទៅក្នុងដីក្រមោះ ។ ក៏ប៉ុន្តែ ពាក្យចចាមអាចមចេះតែឮសួរពោលរិះគន់ថា តណៈកម្មការវៀតមិញ ចេះតែប្រើសរកតែពាក្យណាដែលលំបាក ដែលរតមិនឆ្ងាប់ដឹង, មិនឆ្ងាប់និយាយ យកមកជាក់ឲ្យគេ

ប្រើ, ឲ្យគេនិយាយ នាំឲ្យតែសំបាតប្រើ ។ ដូចពាក្យអយស្មុយយានេះ ចាំបាច់ឯងឆ្កើតមតធ្វើអ្វី បើមានពាក្យខ្មែរសម្រាប់ប្រើហើយថា រវៃ-ភ្លើង, រវេះភ្លើងស្រាប់មកហើយ ។

ការពោលរិះគន់ដូច្នេះ ក៏ជាការមួយគួរឲ្យចាប់អារម្មណ៍ដែរ ។ តណៈកម្មការវៀរធម៌ មានសេចក្តីត្រេកអរក្រៃលែង ចំពោះការរិះគន់នេះព្រោះជាការណ៍មួយនាំឲ្យតណៈកម្មការ ចានខ្លះចំណុចនឹងធ្វើអធិប្បាយជូនអស់លោកអ្នកអាន ឲ្យចាយល់ច្បាស់ អំពីពាក្យអយស្មុយយានោះ ។

អស់លោកអ្នកអានទាំងឡាយ ! ចំពោះពាក្យថា អយស្មុយយានេះ សូមលោកអ្នកជ្រាបដូចតទៅ ៖

ហេតុខាងដើម ពាក្យនេះពុំមែនតណៈកម្មការវៀរធម៌ ជ្រើសរើសតែដោយឯង ។ ទេ ។ តាមពិត មុនដំបូងលោកអ្នកត្រួតត្រាកិច្ចការ ខាងក្រុមអយស្មុយយាន ចានស្រង់យកពាក្យតិកនិកជាសាសាច់ធំ ជាច្រើនពាក្យ សម្រាប់ប្រើការខាងមុខក្រសួងខ្លួនោះ ផ្ញើទៅឲ្យតណៈកម្មការវៀរធម៌ ដើម្បីជ្រើសរើសតែពាក្យដែលមានស្ងួរស័ព្ទជាខ្មែរយកមកផ្តួ ហើយមានបញ្ជាក់ថា សុំតណៈកម្មការជ្រើសរើសតែពាក្យខ្មែរ យកមកផ្តួនោះ ឲ្យមានចំហាំប៉ុន ។ គ្មានឯពាក្យចាក់ឯង កុំឲ្យខ្លះកុំឲ្យលើស ។ ព្រោះហេតុនេះហើយ ចានជាតណៈកម្មការវៀរធម៌ ជ្រើសរើសចានពាក្យ

ថា អយស្ទ័យយានេះ យកមកផ្គូនឹងពាក្យថាភាំងថា «Chemin de fer» សព្ទថា "អយស្ទ័យ" នេះជាគុណនាម សម្រេចមកពីពាក្យសំស្ក្រឹត "អយសិ នឹង មយ:" យកតួ «ស»តម្រួតលើតួ «ម» ក្លាយជា អយស្ទយ: ឬអយស្ទ័យ, បើជាពាក្យបាលីវិញថា "អយោមយ: ឬ អយោម័យ" អាស្រ័យប្រែថា «ដែក," "មយ: » ប្រែថា « ផ្សំមក, សម្រេចមក, » រួមគ្នាទៀថា ដែលធ្វើដោយដែក, ដែលយកដែកធ្វើ (តាំមែនធ្វើអំពីដែកទេ ព្រោះដែកទៅជាដែកជាដែល) ។ យាន: ឬយាន ជាពាក្យសំស្ក្រឹត នឹងបាលី ប្រែថា :គ្រឿងដឹកនាំ, គ្រឿងនាំបន្ទុកទៅមក គ្រឿងសម្រាប់ដំរះ ។ អយស្ទ័យយាន ប្រែថា «គ្រឿងសម្រាប់ដំរះ ដែលធ្វើដោយដែក» ឬថាដែលលឿនទៅតាមផ្លូវដែក ។

Chemin de fer គណៈកម្មការវៀរឆ្ងាមិ បានផ្គូពាក្យថា អយស្ទ័យមាគ៌ាយាន, ប៉ុន្តែដោយយល់ឃើញថាវែងណាស់តាំបាកហៅ តែកាត់ពាក្យមាគ៌ាចេញ ទុកឲ្យនៅត្រឹមតែអយស្ទ័យយាន ។ សុំបញ្ជាក់ម្តងថែមទៀតត្រូវអានថា អៈយ៉ុស-ស្ទៃ-យាន តាំមែនអានថា អៈ យៈ-ស្ទៃ យាន ឬអ, យ៉ុសស្ទៃយៈយានទេ ។ ដូច្នេះអាចបញ្ជាក់ឲ្យឃើញថា ឈ្មោះនេះតាំយ៉ាងនេះតាំសមហេតុសមផលឡើយ, ព្រោះពាក្យដែលគណៈកម្មការវៀរឆ្ងាមិ បានបង្កើតឲ្យមានឡើងនេះ សុទ្ធសឹងតែខំប្រឹងរិះរកដោយហ្មត់ចត់ ផ្គូផ្សំ

ឧដ៏ពាក្យថាកាំង់ថា Chemin de fer តុំមែនជួរឡែស្មើនឹងពាក្យថា (Voiture de fer) ឬ Charrette de fer ទេ។ ពាក្យថាអយស្ម័យយាន Chemin de fer នេះ សម្រាប់ប្រើជា ចោរីកាសា ឬចោរីកាព សម្រាប់ប្រទេសឯកពាជ្យប៉ុណ្ណោះ ។ ឯពាក្យថារថភ្លើងក្តី, រទេះភ្លើងក្តី បើនឹងថាត់ថាជាគ្រាមកាសា ឬកាសាសាមញ្ញ សម្រាប់ជាតំរែរយើងកំបាន តែយើងអាចប្រើជាកាសាសាមញ្ញ និយាយស្តីប្រាស្រ័យគ្នាបានតាមធម្មតា ឥតមានទោសកំហុសអ្វីទេ ដូចជារថយន្ត, ទោចក្រយាន, ត្រីចក្រយាន ជាដើមដូច្នោះដែរ យើងចង់ហៅថាឡាន, កង់ ស៊ីក្លូ តាមទម្លាប់កំបាន ។ល។ សូមអស់លោកអ្នកជ្រាប ។

នៅទីបំផុតនេះ យើងសុំអស់លោកអ្នកអាន ចំបែរយោបល់ទៅកពាក្យបាកាំងវិញមើល ? លោកអ្នកគង់នឹងយើញថា ត្រង់ពាក្យសម្រាប់ហៅយានប្រភេទនេះ បាកាំងគេមានពាក្យប្រើនគឺ Rail, Locomotive chemin de fer ដែរ តុំមែនមានពាក្យតែ ១ ម៉ាត់នោះទេ ។

ត្រង់ពាក្យថា ពាជអយស្ម័យយាននេះ ប្រសិនបើគណៈកម្មការវប្បធម៌បង្កើតវិញ យើងគេញចិត្តថា ពាជាយស្ម័យយាន ។ គឺមកពីពាជៈនឹងអយស្ម័យយានស្រួលមាត់ហៅជាង ពាជអយស្ម័យយាន ។

ផ្នែកគំណត់ធំនៃប្រវត្តិការណ៍

ការធ្វើសន្និសីទ

អំពីការសិក្សាខាងព្រះពុទ្ធសាសនា

នៅសហរដ្ឋអាមេរិក

ដោយលោកបណ្ឌិត វិស្សា ឯ គារ័ត

ចំពោះសមាជិកសង្ឃ និង សាស្ត្រាចារ្យទាំងឆ្នាយ

នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ និង

ពុទ្ធិកវិទ្យាល័យ ព្រះសុភទ្រិត

លោក អៀង-គុណ-សាធី

អគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ រៀបរៀង

មុនដំបូង យើងសូមថ្លែងអំពីបុព្វហេតុ ដែលនាំឲ្យលោកបណ្ឌិត វិស្សា ឯ គារ័ត បានអញ្ជើញមកធ្វើសន្និសីទ ដូចសេចក្តីតទៅនេះ ៖

លោកបណ្ឌិត វិស្សា ឯ គារ័ត ជាតិអាមេរិកាំង ជាទីប្រឹក្សានៃមូលនិធិអាស៊ីធង ជាសាស្ត្រាចារ្យបង្រៀនវិជ្ជាខាងព្រះពុទ្ធសាសនា នៅសាកលវិទ្យាល័យយ៉ែល ក្នុងសហរដ្ឋអាមេរិកផង ។ លោកបណ្ឌិតនេះជាអ្នកត្រិះរិះពិចារណារឿងរ៉ាវខាងព្រះពុទ្ធសាសនា លោកបានចេះដឹងលម្អិតព្រះពុទ្ធសាសនាទាំងពីរយ៉ាង គឺលទ្ធិខាងថេរវាទ និងមហាយាន ។ លោក

ភ្ជាប់ជាមួយអញ្ជើញមកប្រទេសកម្ពុជាយើងនេះ ជាច្រើនដងហើយ ។ កាលពីឆ្នាំ ១៩៥៨ លោកបានអញ្ជើញមកធ្វើសន្និសីទ អំពីរឿងព្រះពុទ្ធសាសនាមួយដងហើយ នៅក្នុងបរិវេណនៃពុទ្ធិកវិទ្យាល័យ ព្រះសុពម្រឹតចំពោះសាធារណៈជន ជាពិសេសចំពោះសមណនិស្សិត ។

កាលពីថ្ងៃទី ២៦ កក្កដានេះ លោកបណ្ឌិតវិស្សុ ឯ គារ៉ែ បានអញ្ជើញមកដល់ក្រុងភ្នំពេញ ហើយលោកអញ្ជើញទៅថ្វាយបង្គំសម្តេចព្រះសង្ឃនាយក បានទៅសន្ទនាជាមួយសមាគមព្រះពុទ្ធសាសនា ជាមួយនឹងព្រះសង្ឃព្រមទាំងពុទ្ធបរិស័ទខ្លះ ។

ព្រះតេជព្រះគុណព្រះពោធិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សា ដោយលោកភ្ជាប់បានស្គាល់លោកបណ្ឌិតនេះ តាំងពីកន្លងកាលដែលលោកបានធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិកពីឆ្នាំ ១៩៥៦ ទើបលោកធ្វើតយកឱកាសនេះ អញ្ជើញលោកបណ្ឌិត គារ៉ែ ឲ្យធ្វើសន្និសីទអំពីការសិក្សាខាងព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក ចំពោះសមណនិស្សិតទាំងឡាយដែលកំពុងសិក្សាសព្វថ្ងៃ ក្នុងពុទ្ធិកមហាវិទ្យាល័យ នឹង ពុទ្ធិកវិទ្យាល័យ ដើម្បីឲ្យសមណនិស្សិតទាំងឡាយនោះបានជ្រាបយល់ថា ការសិក្សាខាងព្រះពុទ្ធសាសនា មិនមែនមានតែក្នុងប្រទេសយើងដែលជាប្រទេសភ្ជាប់មានព្រះពុទ្ធសាសនាពាក់ព័ន្ធមកហើយនោះទេ សូម្បីប្រទេស

ចាំងឡាយដែលមិនធ្លាប់មានព្រះពុទ្ធសាសនា គឺគង់តែនៅបង្កើតឲ្យមានការសិក្សាខាងព្រះពុទ្ធសាសនាដែរ ព្រោះថាព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយហេតុផល មនុស្សគ្រប់ប្រទេសក្នុងសាកលលោកមានសហវដ្ឋអាមេរិកជាដើម ទោះបីគេមិនប្រាថ្នាកាន់តាមក៏ដោយគង់តែត្រូវការចង់ចេះចង់ដឹងដែរ ។

អាស្រ័យហេតុដូចខាងលើនេះ ទើបព្រះតេជព្រះគុណព្រះពោធិវង្ស ចាន់អញ្ជើញលោកដុកទ័រ គ្រាវ៉ែ ឲ្យធ្វើសន្និសីទដោយក្រសួងធម្មការចាន់យល់ព្រមផង ដូចចាន់រៀបរាប់រួចមកហើយ ។ លោកដុកទ័រ គ្រាវ៉ែ ក៏ចាន់ខ្លួលដោយរីករាយ ។

ដូច្នេះ ចាន់ជាកាលពីថ្ងៃអាទិត្យទី ២៤ កក្កដា ១៩៦០ ពេលម៉ោង ១៦ លោកបណ្ឌិតវិស្ស ឯ គ្រាវ៉ែ ចាន់អញ្ជើញទៅកាន់បណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុកជ ដោយមានលោកដុកទ័រ ហ្វាកាំរ ជាតំណាងនៃមូលនិធិអាស៊ីដូនទៅផង ។ ក្នុងបណ្ណាល័យនោះ មានការជួបជុំសមណៈនិស្សិត ទីឯសាស្ត្រាចារ្យព្រមទាំងបុគ្គលិកក្នុងពុទ្ធិកវិទ្យាល័យ មួយអន្ទឹរដោយលោកនាយការិយាល័យ ក្រសួងធម្មការតំណាងលោកវដ្ឋមន្ត្រី រួមទាំងអស់ប្រមាណ ៤០០ នាក់ ។

មុននឹងធ្វើសន្និសីទនោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ចាន់រៀប

ពាក់ព័ន្ធបំពីប្រវត្តិនៃលោកបណ្ឌិត គ្រីវ៉ែ ទើបហេតុដែលត្រូវធ្វើសន្និសីទ
រួចបានជូនទូកាសដល់លោកដុកទ័រ ។

លោកដុកទ័រគ្រីវ៉ែ បានធ្វើសន្និសីទក្នុងពេលនោះអស់រយៈកាលជាង
១ ម៉ោងទើបចប់ ។ លោកថ្លែងជាភាសាអង់គ្លេស ហើយលោកជា-ខន់
សាស្ត្រាចារ្យបង្រៀនភាសាអង់គ្លេសនៅពុទ្ធិកវិទ្យាល័យ ជាអ្នកប្រែមក
ជាភាសាខ្មែរ ។

យើងសូមដកស្រង់យកតែត្រង់គោលចំណុចខ្លះ ។ នៃសន្និសីទ
នោះមកថ្លែងជូនដូចតទៅនេះ :

លោកដុកទ័រ គ្រីវ៉ែ បានថ្លែងថា :

-ក្នុងសហរដ្ឋអាមេរិក មានសាកលវិទ្យាល័យជាច្រើន មានសា-
កលវិទ្យាល័យ យ៉េល ជាដើម ដែលមានសិក្សាខាងព្រះពុទ្ធសាសនា ,

-ពួកនិស្សិតដែលទទួលការសិក្សាខាងព្រះពុទ្ធសាសនា គឺសិក្សា
ដោយយកចិត្តទុកដាក់ណាស់ ,

-សាស្ត្រាចារ្យដែលបង្រៀនព្រះពុទ្ធសាសនា ច្រើនតែជាតិជប៉ុន
ដែលមានការចេះដឹងច្រើន ,

-ក្រៅពីជាតិជប៉ុន មានសាស្ត្រាចារ្យជាតិអាមេរិកាំងខ្លះ ជាតិ
បារាំងសែសខ្លះ ,

-ចំពោះការសិក្សាព្រះពុទ្ធសាសនា បើអ្នកសិក្សាបានចេះដឹងវិជ្ជាច្រើនយ៉ាង វិជ្ជានោះអាចនឹងធ្វើជំនួយជួយឲ្យអ្នកសិក្សាមានការភ្ញីស្វាង ច្រើន ហើយនឹងនាំឲ្យកាន់តែបានចេះដឹងយល់ផ្លូវព្រះពុទ្ធសាសនា ជាក់ច្បាស់ឡើងទៀត ។

-ចំពោះភាសា បើអ្នកសិក្សាបានចេះភាសាឲ្យច្រើនដូចជាភាសាអង់គ្លេស ភាសាបារាំងសែស ភាសាចិន-ទីបេត ជាដើម ផ្សំជាមួយនឹងភាសាជាតិរបស់ខ្លួន នឹងនាំអ្នកសិក្សាខាងព្រះពុទ្ធសាសនា ងាយយល់ខ្លួលំខូលាយក្នុងរឿងព្រះពុទ្ធសាសនា ដោយបានយកសៀវភៅដែលនិយាយពីព្រះពុទ្ធសាសនា ជាភាសាផ្សេងៗ មកនិពន្ធប្រៀបធៀប ។

-ចំពោះសហរដ្ឋអាមេរិក ដែលសព្វថ្ងៃនេះកំពុងមានការសិក្សាខាងព្រះពុទ្ធសាសនាមែនហើយ ប៉ុន្តែពុំទាន់មានអង្គការនៃព្រះពុទ្ធសាសនាឲ្យដូចជានៅក្នុងប្រទេសកម្ពុជាយើងនេះទៅឡើយ គឺពុំទាន់មានវត្តអារាម ពុំទាន់មានព្រះសង្ឃ ពុំទាន់មានអ្នកគោរពប្រតិបត្តិកាន់ឲ្យបានបរិបូណ៌ទៅឡើយ ។ ប៉ុន្តែមានសង្ឃឹមថា តទៅក្នុងអនាគត ប្រសិនបើមានការសិក្សាចំរើនឡើង អ្នកសិក្សាក៏យកចិត្តទុកដាក់ ហើយមានជំនឿ គង់តែនឹងមានព្រះសង្ឃ មានពុទ្ធបរិស័ទពុំខាន ។

កាលដែលលោក ដុកទ័រ តារ៉ែ បញ្ចប់សន្ទិសីរួចហើយ មាន
សមណាទិស្សតច្រើនរូបបានសួរលោកដុកទ័រនោះ អំពីបញ្ហាផ្សេងៗ ខាង
ការសិក្សាព្រះពុទ្ធសាសនា សួរជាភាសាអង់គ្លេស លោកដុកទ័រក៏បាន
ឆ្លើយតបវិញរហូតដល់ម៉ោង ១៧ កន្លះទើបចប់ ។ កាលដែលចប់ហើយ
ព្រះតេជព្រះគុណ ព្រះសោធិវង្ស បានថ្លែងអំណរគុណចំពោះលោកដុកទ័រ
ដែលបានធ្វើសន្ទិសីខ អំពីការសិក្សាព្រះពុទ្ធសាសនា ទាំងឲ្យសមណ-
ទិស្សតទាំងឡាយមានការចាប់អារម្មណ៍ជាច្រើន ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទុប៌ិតិ គុ. ដែលកោង, ដែលក្រអឺត ។

អតិទុគ៌ិដ៌ គុ. ដែលមើលឃើញឆ្ងាយ ។

អតិទុហ៌ិ ឆាគុ. ឆេះក្រៃលែង; ធ្វើឲ្យទំនាស់ ។

អតិទុហ៌សាង្ឃ៌ិ គុ. ដែលមានអត្ថាស្តៅក្រហាយក្រៃពេក ។

អតិទ៌ាត្ត្រ ន. ន. អ្នកឲ្យទានក្រៃលែង ។

អតិទ៌ាន ឧបុ អតិទាន, ការឲ្យទ្យក្រៃលែង ។

អតិទ៌ារុណ គុ. ទារុណក្រៃលែង ។

អតិទ៌ាហ៌ ចុំ. ការឲ្យឆេះក្រៃលែង; ការឲ្យរលាកក្រៃលែង ។

អតិទ៌ិគ្ឃ ឆាគុ. បង្គួលក្រៃ ពក, កំណត់, បញ្ជូន ។

អតិទ៌ីទ្ឃ៌ គុ. ដែលឆេះសន្ធៅ, ដែលភ្ញាក្រៃលែង ។

អតិទ៌ីទ្ឃ៌ិ ស្ត្រី. ពន្ធូក្រៃលែង ។

អតិទ៌ីឃ៌ិ គុ. វែងក្រៃពេក ។

អតិទ៌ីទ្រ៌ ឆាគុ. លេងក្រៃពេក; ភ្ញាក្រៃលែង ។

(នៅមានត)

តម្លៃជសទិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣២ លេខ ៩ ខែកញ្ញា

ព. ស. ២៥០៣ គ. ស. ១៩៦០

ក្នុង ១ ភ្ញ





ភ្នំពេញសន្ទេយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញវាល់ខែពុទ្ធសាសនបណ្ឌិត្យ

	ប ញ្ជី រឿ ង	ទំព័រ
	ផ្នែកសាសនា	
-	ពុទ្ធដីវិប្បវត្តិ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	៨៦១
-	គោលព្រះនិព្វាន ព្រះឧបាលីវង្ស សួរ-ហាយ រៀបរៀង	៨៨១
-	ព្រះអភិធម្មបិដក (គម្ពីរកថាវត្ថុ) (តទក) លោក ប៊ូ-ប៊ូ រៀបរៀង	៨៩៩
-	មធុរសរិហិណី (តមក) សម្តេចព្រះធម្មលិខិត ល្វី - ឯម ប្រែរៀបរៀង	១០០៨
-	មហោសថជាតក (តមក) លោក អឹម-កន បម្លងពីសាស្ត្រាស្ងឹកវែត ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ	១០១៧
	ផ្នែកអក្សរសាស្ត្រ	
-	រឿងមារណមាគ (តមក) លោក ប៊ី-សុវណ្ណ បម្លងពីសាស្ត្រាស្ងឹកវែត	១០២៧
-	រឿងព្រេងប្រទេសអារ៉ាប់ ភិក្ខុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស	១០៤២
-	រឿងព្រេងនិងរឿងបុរាណជាប៉ុនប្អូនក្នុងមធ្យមសម័យ(តមក)លោក រ៉ាយ-ប៊ុក ប្រែរៀបរៀង	១០៥១
-	រឿងសាមកុក (តមក) ឧកញ៉ា ខ្ទូ - កន ប្រែ	១០៦១
-	ពាក្យវប្បធម៌ លោក ខាង-ហ្ស៊ី រៀបរៀង លោក សង-ចាំង ពិនិត្យ	១០៦៩
	ផ្នែកកំណាត់ទំនឹងប្រវត្តិការណ៍	
-	ពតិមាន៍ផ្សេងៗ របស់ក្រសួងធម្មការ	១០៧៦
-	វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	១០៧៨

មួយឆ្នាំ មាន ១២ សៀវភៅ តំលៃជាវ ៤៣០០

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom Penh

sommaire

Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT. . . 961
— Le Nirvana par le Vén. SOR-HAY. 981
— Prah Abhidhammapitaka(Kathavathu) (suite) par M. BOU-PO 999
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN 1008
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 1017

Partie littéraire :

— Légende de Marana Mâtâ(suite)relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1027
— Contes et Légendes arabes traduits par Bhikhhu MEN-REAM 1042
— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC 1051
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1061
— Activités de la Commission Culturelle par M. NEANG HOU revues par M. SAM-THANG. . . . 1069

Notes et Chroniques :

— Nouvelles diverses du Ministère des Cultes 1076
— Dictionnaire Sanscrit-khmer (suite) par le Vén.PANG-KHAT 1078

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

តុន្ដិឝប្បវត្ថិ

(តមក)

ព្រះមហា ជ៉ាន-ខាត់ រៀបរៀង

អវិទូរេនិទាន មហោភិនិក្ខមនកថាទី ៥

១-ទ្រង់ប្រកាតនឡ្ហាន, ២-ទ្រង់ទតឃើញទេវទូត៣ខាងដើម, ៣- ទ្រង់ទតឃើញទេវទូតទី៤, ៤- កាលកំពុងប្រកាតនឡ្ហាន, ៥. ព្រះរាហុលកុមារប្រសូត, ៦- ពោធិសត្វកើតសង្វេត ៧- ទ្រង់រួចស្រឡះពាកកាម, ៨- ទ្រង់មានតម្រិះក្នុងថ្ងៃសុ, ៩-ពោធិសត្វស្តេចចេញសាងមហាភិនេស្ក្រមណ៍, ១០ ទ្រង់កាន់យកនវគ្គមភេទ ។

ឆ្ងើយចំណោទយ៉ាងធ្ងន់ឥតទើសទាល់អ្វីសោះ, គេយកធម្មមកថ្វាយព្រះពោធិសត្វ។ ចាប់យឹត ជាញាប់ញាក់តស់ ទើបព្រះបាទសុទ្ធោទនៈ ត្រាស់ឲ្យយកធម្មប្អូរាណ (សហស្សជាតធនុ) ពោធិសត្វលើកឡើងជាភ្ញាយ៉ាងស្រួល ក្លនសរទៅមុខដើមឈើធ្នុះហើយលិចទៅក្នុងដែនដី ត្រង់ទីនេះ គេឲ្យឈ្មោះថាអណ្តូងក្លនសរ, ទេវតាត្រណែតជាលំដាប់ ១ ដៃស្មាច់, ពោធិសត្វយកព្រះហស្តទៅពាល់ដំរីសោះ។ដើរឡើងហើយនមស្ការព្រះពោធិសត្វ ។ ឯឈ្មោះអគ្គមហេសីព្រះពោធិសត្វនេះ មានឈ្មោះច្រើនទៅទៀត, ក្នុងគម្ពីរយើងដាស៊ើរវៅទថាពេលោះ យសោធរា ជាបុត្រីព្រះបាទសុប្បពុទ្ធ ឱងនាងអមិតា, ឈ្មោះរាហុលមាតា ឬ ពិម្ពា ឈ្មោះតាំង៣ នេះផ្ទុចគ្នាទេគម្ពីរលលិតវិស្តារនមហាយានថា ឈ្មោះគោបា ជាបុត្រីសក្យទណ្ឌបាណិ ។ ទណ្ឌបាណិ កាលប្រឡងធ្នូបានតាំយកនាងគោបាទៅឱងនែរ ហើយនិយាយថា អ្នកណាមានដំឃងនឹងលើកនាងគោបាឲ្យដល់អ្នកនោះ(នេះតាមទំនៀមប្រទេសភ្ញៀសម័យនោះ) ។ គម្ពីរមហាវស្តុថា អគ្គមហេសីព្រះពោធិសត្វឈ្មោះនាងយសោធរា ដែរ តែជាបុត្រីមហាតាម, តាមសិលាចារឹកផ្សេងៗ ទាងខ្មែរតែកាយថា ព្រះពោធិសត្វមាខគ្គមហេសី ៣ អង្គគឺនាង គោបា១ ជាបុត្រ, នាងយសោធរា១ ជារាហុលមាតា ឱងនាងត្រីតា ។

១-ទ្រង់ប្រពាតទុទ្ទាន

ថ្ងៃមួយ ព្រះមរមពោធិសត្វទ្រង់ព្រះសណ្តាប់ពាក្យនេដំណាលថ្វាយ ថាឱកងឆមង្គលទុទ្ទាន មានរុក្ខាវតាជាតិដុះលូតលាស់សន្ធឹកខៀវខ្ចី មានឦមាត់សត្វបក្សីយាសយំពិរោះរងំអឺងអាប់ ឯស្រះបុក្ខរណីពេញដោយផ្កាឈូកកម្មុទនីល មានផ្កាឥតស្ទុះស្គាយរំលេចពណ៌ឆ្វាស់គ្នា ចោលភ្ញៀនក្រអូបឈ្ងុយឈ្ងប់ កាលនោះស្តេចទ្រង់ទឹកក្នុកព្រះទ័យចង់ទៅប្រពាតទុទ្ទាន ទើបស្តេចត្រាស់បង្គាប់ឲ្យសារថីរៀបចំព្រះរាជរថភ្លូន ព្រះរាជដំណើរ(១) សារថីទទួលព្រះរាជបង្គាប់ហើយ ក៏រៀបតាក់តែងព្រះរាជរថដ៏វិចិត្រ ទីមរោយសេះសិន្ធវៈ ៤ មានពណ៌ដូចស្លឹកកុមុទជាតិ រៀបស្រេចហើយ ចូលទៅក្រាបបង្គំអញ្ជើញស្តេច ។ ព្រះមរមពោធិសត្វស្តេចឡើងលើព្រះទីទាំងមង្គលរាជរថ ហែហមដោយរាជបរិពាររចេញពីព្រះនគរឆ្ពោះព្រះភ័ក្ត្រទៅកាន់ទុទ្ទានប្រទេស ដាច់តំបន្តព្រះទ័យ ។

២- ទ្រង់ទតឃើញទេវទូតបីខាងដើម

កាលនោះ ពួកទេវតាដ៏ធំថា ព្រះសិទ្ធត្ថកុមារស្តេចដល់គេលន៍ធំ

១- គម្ពីរលលិតវិស្តារនិងពុទ្ធចរិតអស្សឃោសៈថា ព្រះពោធិសត្វទៅសួរអនុញ្ញាតអំពីព្រះវររាជបិតាទ្រង់មិនបារម្ភឃាត់ ទ្វាបទាស់ព្រះទ័យព្រះរាជបុត្រ ទើបបានបង្គាប់ឲ្យរៀបតាក់តែងភ្លូល ឲ្យដើរញុះញង់ពួកលាមការ អ្នកកំសត់ទុគ៌តចេញពីផ្លូវ ដើម្បីកុំឲ្យពោធិសត្វស្តេចទតឃើញ ។

ត្រាស់ដឹងជាព្រះពុទ្ធហើយ គិតគ្នាថាទំនិសំដែងទូវបុព្វនិមិត្តហ្វាយ ទើប
បង្គាប់ទៅបុត្រមួយអង្គឲ្យនិមិត្តជាមនុស្សជក ទេញថាក់ត្រហុប សក់
ស្កូវព្រោង ខ្លាំងកោងក្ងក់ កាយរតីមរតាមដោយធ្មេញដំទីរជូចជាបង្គីង
ដៃកាន់ឈើច្រត់ញ៉ាទេច្រើក ។ ដើរមកកាន់មគ្គវិថី មានអាការមុខតួរឲ្យ
សង្វេគពេក ពេលនោះ ព្រះបរមពោធិសត្វទីឆ៏សារថីបានឃើញទូវ
មនុស្សជកនោះ ឯអ្នកដទៃមិនបានឃើញមនុស្សជកនោះទេ ដោយទេ-
វានុភាព ព្រះបរមពោធិសត្វ និមិត្តតែបានឧតឃើញមនុស្សជកនោះ
ហើយ ទើបស្តេចត្រាស់សួរសារថីថា នែសារថី ហ្ន៎ មើលមនុស្សខ្ទុះ
ដែលមានសក់ស្កូវព្រោង ខ្លាំងកោង សាច់ឃុយឃោរ ឃើញតែគ្រោងឆ្អឹង
រគឹង ដៃកាន់ឈើច្រត់ខាប់ខ្លួនញ៉ាទេច្រើក ក្អែកខ្លងរួងជ្រៅគ្រប់ដោយ
កេមចំញើម មនុស្សប្លែកនេះជាធម្មតាប្រក្រតីគ្នាទេឬជូចម្តេចខ្លះ ពេលនោះ
ទេពតាដែលជ្រែកចូលក្នុងកាយសារថី នាំសារថីឲ្យក្រាបទូលដោយតាក្យ
សត្យថា មនុស្សនេះ កាលពីដើមនៅក្មេង ល្អៅទឹកដោះ ហើយកំចំរើន
ធំឡើងជាលំដាប់ ចេះរាំ ចេះដើរ ទៅជាមនុស្សតម្ងោះ មានរូបស័ក្តិសម
តទៅទៀត ដល់ទូវជកកាត ជកនេះជាសត្រូវមេចំផ្ទេចចំផ្លាញកំឡាំង
សតិបញ្ញា ជាមេកំណើតឲ្យកើតសេចក្តីសោកស្តាយយំសង្រែងសង្រៃ ។
ព្រះពោធិសត្វ ទ្រង់ព្រះសណ្តាប់តាក្យសារថីក្រាបទូលដូច្នោះហើយ កំ
ញាប់ញ័រចំប្រប់ក្នុងព្រះទ័យ ទើបស្តេចត្រាស់សួរសារថីតទៅទៀតថា

ទោសនេះ ទំនងមានជល់អាត្មាអញដែរឬដូចម្តេច ? សារថីក្រាបទូលថា ទោសនេះទំនងមានជល់ព្រះអង្គដែរ លុះកាលណាទ្រង់មានរំយោចំរើនធំឡើង ឬទ្រង់មានរំយោចំរើនច្រើនជ្រុលទៅមុខ ឯសត្វលោក ចើទុកជាដឹងថា ជារានេះជាអ្នកចំផ្លាញនូវរូបដូច្នេះ ក៏នៅតែជ្រុលភ្នាក់ពេញចិត្ត ។ ព្រះពោធិសត្វទ្រង់ព្រះសណ្តាប់ពាក្យថា ជក។ដូច្នេះ ក៏ស្តុតព្រះទ័យដូចជាមេគាឮនូវសម្លេងខ្ទេះដ៏គគងយ៉ាងខ្លាំង ទ្រង់ដកដង្ហើមធំវែង ។ គ្រានោះ ព្រះសិរ្សបែបដូចជាមានភ័យធំណាស់ ជ្រប់ស្តុតស្ងប់ព្រះភ័ក្ត្រ ទ្រង់ខតតម្រង់ឆ្ពោះទៅមនុស្សជកនោះ ហើយឃើញមានប្រជាជនដទៃទៀត នៅមានសេចក្តីរីករាយ ទើបទ្រង់ត្រាស់ដោយសង្វេគថា ជកនេះ សម្លាប់បំផ្លាញនូវស្មារតីផង នូវរូបផង នូវសេចក្តីប្រឹងប្រែងផង ឥតសេសសល់ទេ សត្វលោកតុំឃើញអំណាចជកប្រាកដដាក់ច្បាស់ដូច្នេះទេ ឬនជាមិនមានសេចក្តីស្តុត , នែសារថី! កាលបើដូច្នេះ អ្នកចូលញ៉ាំងរទេះឲ្យត្រឡប់ទៅផ្ទះវិញឆាប់ ។ ព្រោះចិត្តអាត្មាអញកំពុងជាប់ជាន់ក្នុងពាក្យថាជក ។ សេចក្តីរីករាយនឹងមានក្នុងទីណាទៀតក្នុងលើដូចម្តេចកើត? ព្រះពោធិសត្វស្តេចមានតម្រិះសុទ្ធតែទៅក្នុងជក ស្តេចយាងចូលទៅកាន់ព្រះពុទ្ធកំពង់ហាក់ដូចជាចូលទៅកាន់ទីសូន្យទទេ , ម្យ៉ាងទៀត កាលដែលព្រះអង្គកំពុងតែរំពឹងគិតថាជក ។ ដូច្នេះ ទ្រង់មិនបានសុខស្រួលក្នុងព្រះទ័យសោះ ។ ព្រះវរកដបិតាស្តេចជ្រាបដំណឹងនេះ ស្តេចត្រាស់បង្គាប់ឲ្យពួកស្រីស្នំក្រម

គាគៅក់តែងឱកឆគាយដោយរត្រឿងអលង្ការដើរចិត្រមកប្រលោមពោធិសត្វ ដោយនាប់រួសកន់(១) ។ លើកទី ២ ស្តេចទតឃើញមនុស្សព្យាធិ, លើកទី ៣ ទ្រង់ទតឃើញមនុស្សស្លាប់ ។

៣-ទ្រង់ទតឃើញទេវទូតទី ៤

ថ្ងៃមួយតមកទៀត ព្រះមហាបុរសត្ន ប្រថាប់លើព្រះរាជរថ ទឹមដោយសេះសិន្ធព ៤ ចេញទៅប្រពាតឧទ្យានលើកទី ៤ ព្រះវរាជបិតាទ្រង់បានតាក់តាងឱ្យអ្នកត្រួតត្រាថ្នូរវៃរក្សាត្រួតត្រាចំនួនក្រៃលែង ជាងលើកទី ៣ ទៅទៀត, ដូចនោះ ស្តេចទតឃើញរូបបុរសម្នាក់ មានកេសជាសមណៈ ស្លៀកដណ្តប់សម្លៀកបាសាវពស្ត្រ មានឥន្ទ្រិយស្រពិតស្រពិនគួរឱ្យកើតសេចក្តីជ្រះថ្លា ជារូបដែលខេតតាជាន់សុទ្ធាវាសដដែលនោះមកនិម្មិតថ្លាយ ដើរមកកាន់មគ្គវិថីនៃព្រះរាជដំណើរ, ទ្រង់សួរសារថីថា ម្នាលសម្លាញ់ ! មនុស្សនោះឈ្មោះអ្វី ? គ្រានោះជាសម័យមុនពុទ្ធកាល សារថីក៏មិនស្គាល់កេរបព្វជិត ហើយមិនដឹងជាបព្វជិតមានគុណដូចម្តេចផង តែដោយអំណាចទេវតានុភាពដែលត្រែកចូលក្នុងកាយ នាំសារថីឱ្យ

១- សេចក្តីត្រង់ពោធិសត្វប្រពាតឧទ្យានហើយទតឃើញទេវទូតទាំង ៤ នេះ មានសេចក្តីពិស្តារត្រង់លើកទី ១ និងលើកទី ៤ ឯលើកទី ២ និងទី ៣ មិនមានពិស្តារទេ គ្រាន់តែនិយាយថាពោធិសត្វ ស្តេចចេញទៅទៀតលើកទី ២ ឃើញមនុស្សព្យាធិ, លើកទី ៣ ឃើញមនុស្សស្លាប់ ។ ក្នុងគម្ពីរពុទ្ធចរិតអស្សឃោសៈមានសេចក្តីពិស្តារពីពេះគ្នាចាប់ចិត្តត្រួតទាំង ៤ លើក។ក្នុងអរិទ្ធបរិនិទាន ឯកនិបាតវណ្ណនា បឋមភាគថា ឃើញទេវទូតទាំង ៤ នេះ តែក្នុងមួយថ្ងៃ ។

ក្រាបទូលដោយពាក្យសត្យថា បពិត្រព្រះសម្មតិទេព មនុស្សនេះឈ្មោះ បព្វជិត ហើយពណិនារឿងបព្វជិតដោយអនេកបរិយាយ ។ ព្រះពោធិ-សត្វទ្រង់ព្រះសណ្តាប់ហើយ ទេញព្រះទ័យនឹងកេរបព្វជិត ទ្រង់ព្រះតម្រិះថា ការប្រព្រឹត្តិជាសមណៈកេរនេះ ជាកុសលដ៏ប្រសើរណាស់ គួរអាត្មាអញកំណត់កាន់យកធ្វើតមកេរនេះ, ថ្ងៃនោះ ព្រះពោធិសត្វស្តេចហួសទៅកាន់ទន្សាយប្រសេស ដើម្បីកំសាន្តព្រះទ័យ ។

៤- កាលទ្រង់ប្រពាតទន្សាយ

ពួកស្ត្រីសំក្រមការមានរូបល្អប្រិមប្រិយ ហាក់ដូចស្ត្រីទេពអប្សរបរិ-ភោគ ប្រដាប់ដោយសំពត់កោសេយ្យពស្ត្រ រំលេចពណិច្រាលផ្លេទឹងក្តី ផ្កា ព្រមទាំងគម្រងគ្រឿងក្រអូបគ្រឿងលាប គួរឲ្យកើតសេចក្តីភោគយ សាទរក្រៃលែង បបួលគ្នាស្រុតចូលទៅហែហមព្រះពោធិសត្វ ប្រៀនកំលួង លោមប្រលោមបំរើដោយកាមគុណ ។ ព្រះពោធិសត្វស្តេចប្រពាតទន្សាន ជាទីមណ្ឌិយដ្ឋានកំសាន្តព្រះទ័យ ត្រង់ទីតំបន់ ស្តេចទតឃើញភូមិភាន មានរុក្ខជាតិលូតលាស់លំពង់សន្ធឹកពេរពិន្ធ មានផ្កាចោលក្នុងក្រអូបឈ្ងុយ ឈ្ងប់, ទឹងគន់មើលឯសត្វសកុណាបក្សាសោតកំយោះយំពីពេះរងឹដូចស័ព្ទ តូរ្យតន្ត្រីឯស្រះចោកទូរណីក៏ប្រដាប់ដោយបញ្ចបទុមជាតិកុមុទនឹលលំចង់ សត្តបង្គ៌ជ ចោលក្នុងទូទៅទាំងសកលទន្សាយប្រសេស ។ ព្រះពោធិសត្វ

ស្តេចប្រពាតអស់ទៀងកាតសម័យទៀបសាយ័ណ្ហហើយ ទ្រង់ហែហម
ដោយអនេកនិករសុកង្គ្នាជ ចុះស្រង់ជម្រះព្រះកាយក្នុងស្រះបុក្ខរណី
លុះទៅកអស្តង្គត ទើបស្តេចបរចរចាកមង្គលស្រះ ទ្រង់និសីទនាការលើ
ផែនថ្មសិលាអាសន៍ ទ្រង់មានចំណងចង់ព្រះសារ្យដោយគ្រឿងពាជ
វិកូសនាលង្ការ ពួកស្រីស្នំក្រមការពាជបរិពារមានខ្នាន់ព្រះកេសជាដើម
អញ្ជើញគ្រឿងប្រដាប់តីរាលង្ការ នឹងគ្រឿងប្រស់ព្រំមកថ្វាយ ។

ខណៈនោះ ក្តៅដល់អាសនៈអមរិន្ទ្រាធិរាជ ស្តេចបើកទ្វារចក្ខុ
ក្រឡេកមកឃើញដូច្នោះ ទ្រង់ត្រាស់បង្គាប់វិស្សកម្មទេវបុត្រថា ម៉ៃ
សម្លាញ់! ក្នុងពាក់កណ្តាលអង្រាត្រយប់នេះ ព្រះសិទ្ធត្ថកុមារ ស្តេច
ទីនចេញសាងមហាភិនេស្ក្រមណ៍, ពេលនេះ ជាបច្ចុមាលង្ការនៃព្រះមហា
បុរស ចូរអ្នកទៅប្រដាប់ថ្វាយព្រះមហាបុរសត្តេឥឡូវនេះ ។ វិស្សកម្ម
ទេវបុត្រយកកេរឹងជាខ្នាន់ព្រះកេស ចាប់វេជ្ជនពស្ត្រអំពីដៃមនុស្សមក
ព័ទ្ធព្រះសិរ្សថ្វាយ រួចប្រដាប់ដោយចិលន្ធនាការណៈល្អដូចមហាព្រហ្ម ។
ព្រះពោធិសត្វស្តេចឡើងគាន់ព្រះពាជវរទីវត្តចាកទ្យានប្រទេស ហែហម
ដោយពួកពលសកលយោធានឹងពួកអនេកបរិពារទត្តិយកញ្ញា ។

៥- ព្រះរាហុលកុមារប្រសូត

គ្រានោះ ព្រះនាងពិម្ពាប្រសូតពហុលកុមារ, ព្រះបាទសុទ្ធោទនៈ

ទ្រង់ត្រាបដូច្នោះ ទើបត្រាស់ឱ្យប្រើភជបុរសម្នាក់នាំសារទៅក្រាបទូលព្រះបរមពោធិសត្វ, ឯព្រះបរមពោធិសត្វ ទ្រង់សណ្តាប់ពាក្យនេះហើយ ទ្រង់មានព្រះបន្ទូលថា ឧបាសកអញហើយតើ! ចំណងកើតហើយតើ! ។ ឯព្រះថេរសុត្តោនេះត្រាស់សួរភជបុរសថា កូនអាត្មាអញនិយាយដូចម្តេចខ្លះ? ភជបុរសក៏ក្រាបទូលតាមពាក្យព្រះពោធិសត្វ ហើយទ្រង់ថ្វាយព្រះនាមព្រះភជនត្តាថា "ភហុលកុមារ(១)" ។ ចំណែកខាងព្រះបរមពោធិសត្វស្ថិតលើភជវេ ហែហមដោយភជបរិវារ ស្តេចផ្ញើះព្រះកំឡាំងទៅកាន់ព្រះភជនគរ ជល់ហើយ ប្រទក្សិណប្រាំដង្គប្រាសាទភជនិវេសន៍ ៣ ជុំ, កាលនោះ ព្រះនាងវត្តិយកញ្ញាមួយព្រះអង្គ ព្រះនាមកិសាគោតមី ស្តេចឡើងទៅលើហាបញ្ជរព្វជិតូមិតលដ្ឋានខែប្រាសាទ ឃើញព្រះមហាបុរសគ្មានសោកាដោយរូបសម្បត្តិ គិតមានព្រះទ័យត្រេកអរសោមនស្ស ទើបត្រាស់សរសើរដោយបទគាថាដូច្នេះ ៖

ធិត្ថុ តា ឥទ សោ មាតា ធិត្ថុ សោ ឥទ សោ បិតា
ធិត្ថុ តា ឥទ សោ ជារ យស្ស ឯសិ ឥទិសោ បតិ ។

ព្រះអង្គីរសកុមារ មានរូបសម្បត្តិល្អប្រាកដដូច្នេះ បើព្រះអង្គជាព្រះរាជបុត្រព្រះមាតាអង្គណា ព្រះមាតាអង្គនោះគឺនឹងអាចរំលត់ទុក្ខបាន, បើ

១- ភហុល < ភហុ + ល = ភហូចាប់ ។

ព្រះអង្គជាព្រះរាជបុត្រព្រះបិតាអង្គណា ព្រះបិតាអង្គនោះក៏នឹងអាចរំលត់ទុក្ខបាន, បើព្រះអង្គជាព្រះភស្តាទៃនាងរាជនារីអង្គណា ព្រះនាងរាជនារីអង្គនោះក៏នឹងអាចរំលត់ទុក្ខបាន ។

កាលព្រះបរមពោធិសត្វ ទ្រង់ព្រះសណ្តាប់ពាក្យនេះហើយ ទើបទ្រង់ព្រះចិន្តាថា ព្រះនាងនេះ ឥតយើញនូវរូបសិរីសម្បត្តិនៃអាត្មាអញ ហើយពោលថា អាចនឹងរំលត់នូវទុក្ខនៃមាតាបិតានឹងកន្លាបានដូច្នេះ ក្នុងកាលណាហ៎! ទើបអាត្មាអញនឹងរំលត់ទុក្ខនេះបាន? ទ្រង់ពិចារណាដោយព្រះប្រាជ្ញាញាណ ដែលប្រាសចាកសេចក្តីត្រេកអរក្នុងកិលេសកាមគុណហើយ ទ្រង់ឥតយើញប្រាថ្នាថា កាលណា បើកូនឯងគឺរាគគ្គិ ទោសគ្គិ មោហគ្គិដាដើមរលត់សូន្យហើយ កាលនោះ ទើបឈ្មោះថាទុក្ខនោះរលត់សូន្យអន្តរធានអស់ទៅវិញពិត, ព្រះនាងនោះពោលនូវពាក្យដ៏ពីរោះទៀតាត្មាអញស្តាប់ បើដូច្នេះ អាត្មាអញនឹងប្រព្រឹត្តស្មើនឹងកន្លងនូវធម៌តែព្រះនិញ្ញទក្នុងថ្ងៃនេះ , អាត្មាអញគួរនឹងធ្វើគ្រឿងសក្ការបូជាស្មើនឹងព្រះនាងអង្គនេះទើបគួរ ហើយទ្រង់ដោះនូវគ្រឿងប្រដាប់ពីព្រះសុរន្ធដ៏វិចិត្រដោយតែមុក្តាមានតម្លៃមួយសែនកហាបណៈ ឲ្យរាជបុរសនាំយកទៅថ្វាយព្រះនាងកិសាគោតមី ។ ព្រះនាងយល់ថា ព្រះសិទ្ធត្ថកុមារមានព្រះទ័យប្រតិព័ទ្ធស្នេហាចំពោះខ្លួន ក៏ទទួលគ្រឿងបណ្ណាការនោះ

ដោយចិត្តសោមនស្សយ៉ាំងក្រៃលែង ។ ព្រះបរមពោធិសត្វប្រកបដោយ
សិរីដ៏ទុត្តម ស្តេចឡើងកាន់មហាប្រាសាទ ដ្ឋលើខែនចិត្តសេយ្យាសន៍ រុង
រឿងដោយពន្លឺប្រទីបជ្វាលាភ្លឺព្រោងព្រាតពួរ៧ ជាន់ផ្ទៃព្រះរាជនិវេសន-
ដ្ឋាន , ឯកន្ត្រីយកញ្ញាប្រដាប់កាយដោយគ្រឿងអលង្ការដ៏វិចិត្រ មាន
រូបឆោមលោមពណ៌សក្តិសម សុទ្ធសឹងល្អ ៗដូចស្រីទេពអប្សរបរិវារកញ្ញា
ប្រគំដេញជំពិណពាទ្យតូរ្យតន្ត្រី ច្រៀងកំពុងសូរសព្ទសំឡេងពីរោះរំងឹមុខតួ
រីករាយសប្បាយក្រៃលែង បបួលគ្នាប្រលោមព្រះពោធិសត្វឲ្យស្តេចត្រេក
អរក្រសាលក្នុងឥរិយាបថកាមគុណ ។

៦_ពោធិសត្វកើតសង្វៃគ

ព្រះពោធិសត្វគ្រាន់តែធ្វើនព្រះនេត្រឧតមហោស្រព ផ្តើនព្រះ
សោតស្តាប់ចម្រៀងបន្តិច កំទ្រេនិងទ្រាលក់៧, ឯពួកនាដកន្តីស្ត្រីរបាំ
ឃើញព្រះបរមពោធិសត្វស្តេចផ្ទំលក់ដូច្នោះ ក៏បបួលគ្នាដេកលន់លក់អស់
ទៅ ។ លំដាប់នោះ ព្រះពោធិសត្វស្តេចទ្រង់តើនឡើង ឧតព្រះនេត្រ
ឃើញពួកស្រីរត្តិយកញ្ញាដេកលក់មានអាការៈផ្សេង ៗគ្នាឲ្យសង្វេគដោយ
ខោរវទុកាតបណ្តាល ស្ត្រីខ្លះ ដេកចោលគ្រឿងប្រដាប់តូរ្យតន្ត្រី ស្ត្រីខ្លះ
ទៀតអាក្រាតសំលៀកបំពាក់ហៀរហូរទឹកមាត់ត្រជាក់ សង្វេគដួញស្រ
មុកខ្លួនមុខតួរខ្ជាប មានដៃជើងបត់បែនច្របេងច្របាង ព័ទ្ធព័ន្ធគឺគាក់

លើគ្នា មានអាការដូចជាសាកសពច្រើនច្រដាននៃដែលគេចោលក្នុងព្រៃស្មសានហាន់ស្ងាត់គួឲ្យខ្លឹមរអើមក្រៃពេក, សូម្បីផ្ទៃមហាប្រាសាទ ដែលតាក់តែងវិចិត្រដោយប្រទីបផ្កាលា ដុតដោយប្រេងក្រអូប ផ្សាយក្លិនសុគន្ធពិរោះឈ្ងុយឈ្ងប់ក្តីព្រោងព្រាយ ចោលរស្មីច្រះទៅចាប់តំរង់ផ្កា លេចពណ៌ល្អស្រស់ខួងភ្នែនផ្ទៃប្រាសាទល្អដូចលំទៅអមរន្ទ្រោងពាជកំដោយ ព្រះពោធិសត្វមានព្រះទ័យតក់ស្លុតខ្លាច ហាក់ដូចជាទ្រង់ប្រថាប់ទៅកណ្តាលទ្រនៃព្រៃស្មសានហាន់ស្ងាត់ ដែលពាសពេញដោយខ្មោចស្រស់ មានក្លិនអសោចក្រៃពេក, កពតាំង ៣ កំប្លុកជហាក់ដូចជាគេហដ្ឋាន ដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ, ទ្រង់ខឿយណាយចាកកាមគុណា ទើបទ្រង់លាន់ព្រះឧស្សាសថា « ទុក្ខតំ វត កោ! ទុក្ខសគ្គំ វត កោ! យោទុក្ខ ទ្រពណាស់តើ! យោទុក្ខសសគ្គទើសថាស់ណាស់តើ!" ដូច្នេះ ។

៣-ទ្រង់រួបស្រឡះចាកកាម

ព្រះមហាបុរសត្ន ទ្រង់ពិចារណាឃើញទោសកាមដូច្នេះហើយ ទ្រង់មានព្រះតម្រិះនឹងចេញចាកកាម ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះមហានាមសក្យៈថា [1] ៖

"កាលតថាគតនៅដាំពោធិសត្វ មុនអំពីការត្រាស់ដឹង

---

១ ព្រះឧបរិបណ្ណាសជាតក ឥសិគណវគ្គ ម. ម., សៀវ. ២០ ទំព័រ ៣៣៧ ។

តថាគតបានឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃថា កាម
ទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តី
បង្អៀតបង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនក្រៃ
ពេក, បើតថាគត វៀរចាកកាមទាំងឡាយហើយ វៀរចាក
អកុសលធម៌ទាំងឡាយហើយ តែមិនទាន់បានឆ្លងបីតិនឹងសុខៈ
ឬគុណជាតិដទៃល្អិតលើសជាងបីតិនឹងសុខៈនោះទេ ក៏តថាគត
ដឹងប្រាកដថា ត្រូវត្រឡប់មករកកាមទាំងឡាយវិញ ដោយ
ពិត ។ លុះតថាគត បានវៀរចាកកាមទាំងឡាយហើយ បាន
វៀរចាកអកុសលទាំងឡាយហើយ បានឆ្លងបីតិនឹងសុខៈផង
នឹងគុណជាតិដទៃដ៏ល្អិតលើសជាងបីតិនឹងសុខៈនោះផង ទើប
តថាគតដឹងប្រាកដថា មិនវិលត្រឡប់ មករកកាមទាំងឡាយ
វិញឡើយ” ។

៨- ទ្រង់មានតម្រិះក្នុងចិត្ត

សេចក្តីមួយទៀតថា កាលដែលទ្រង់ឆ្លងគ្រាស់ដឹងហើយ កំទ្រង់

ជាទត្រាស់បញ្ជាក់ទោសកាមនោះចំពោះភារទ្វាជៈថា (១)

«ម្នាលភារទ្វាជៈ! កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ តថាគតត្រិះរិះថា ឃរាវាសបង្អៀតពេកណាស់ ជាផ្លូវនៃធូលី ឯបព្វជ្ជាទើបទំនេរ បើអាត្មាអញនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ក្រៃលែង ឲ្យបរិសុទ្ធក្រៃលែង ឲ្យផ្លូវដែងដូចជាសង្ខដែលគេដុះខាត់បានឡើយ បើដូច្នោះ គួរតែអាត្មាអញកោរសក់ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ហើយចេញចាកផ្ទះបួសទៅកាន់ផ្លូវវិញ» ។

កន្លះណៈនោះ ព្រះពោធិសត្វមានព្រះភ័ព្វនឹងគោរពនឹងទៅកាសមណាកោ ទ្រង់ព្រះតម្រិះថា - អាត្មាអញនឹងចេញកាសាវមហាភិនិស្ក្រមណ៍កន្លះត្រីនេះ, ទើបទ្រង់ក្រោកចាកព្រះទីនេសេយ្យាសន៍ បទចរទៅដាស់ធន្នាមាត្យ ។ ធន្នាមាត្យ ដេកដាក់ក្បាលលើឥណ្ឌីគូរ ជាទម្រាំព្រះសូរសៀងត្រាស់ស្តួចដូច្នោះ ក៏ក្រោចទូលថា ខ្ញុំព្រះអង្គឈ្មោះធន្នៈ ជាអ្នកក្បាព្រះអង្គ ។ ព្រះពោធិសត្វមានព្រះបន្ទូលថា ធន្នៈ! អាត្មាអញ

១-សង្ខារសូត្រ ព្រហ្មណវគ្គ សៀវ. ២៥ ទំព័រ ២៦៤ ។

ទីឯចេញកសាងមហាកឋិនទេស្រុកណ៌កន្លងកន្រ្តៃនេះ អ្នកចូរទៅរៀបចំសេះមួយឲ្យយើងឆាប់ ។ ។ ឆន្ទអាមាត្យទទួលព្រះពាជបង្គាប់ហើយ យកគ្រឿងអស្សបរណ៍ ដើរទៅកាន់ពេធិសេះកណ្ឌកពាជ(១) រៀបចំបានគ្រឿងអស្សកណ្ឌដ៏វិចិត្រដោយអលង្ការផ្សេង ។ ។ ឯព្រះពោធិសត្វ កាលទ្រង់ត្រាស់បង្គាប់ឲ្យឆន្ទអាមាត្យទៅរៀបចំសេះ ស្តេចគំនានព្រះតម្រិះថា អាត្មាអញគួរទៅមើលតក្រុងសេអាត្មាអញសិន , ទើបស្តេចបរទរចូលទៅកាន់សិរីតក្កដ្ឋានៃព្រះមាតាពិម្ពាពាជទេវី ទ្រង់ប៉ោកបន្ទូបដៃលរុងរឿងដោយពន្លឺប្រទីប ទតឃើញព្រះអគ្គមហេសី ផ្ទំលក់ស្ងំខ្ពស់លើព្រះខែនសេយ្យាសន៍ យកព្រះករប្រតិស្ថានលើព្រះសិរីព្រះពាជទេសេតដ៏ព្រះអង្គ, ព្រះពោធិសត្វទ្រង់ព្រះសណ្តែកឈរសើចរណ៉ាំរាវ ស៊ប់ព្រឹងមើលព្រះពាជបុត្រនីព្រះពាជទេវី ហើយទ្រង់ព្រះតម្រិះថា បើអាត្មាអញលើកព្រះហស្តព្រះពាជទេវីចេញ ហើយលើកពរព្រះពាជទេស ខ្ចាចក្រែងព្រះពាជទេវីតើនចាកនិទ្រាមុណ្ណ៍ ទីឯធ្វើឲ្យអន្តរាយដំណើរចេញកសាងមហាកឋិនទេស្រុកណ៌នៃអាត្មាអញមិនខាន, ល្អើយចុះ កាលណាបើអាត្មា

---

១ សេះកណ្ឌកៈនេះ (ប-កន្ថក,សំ កណ្ឋក) បណ្តាយ៨ហត្ថ ពិសាលតាំងពីកងសៀកខ្នុយ, កំពស់សមនឹងទ្រង់ទ្រាយ សម្បុរសសុទ្ធដូចសង្ខ៍ដែលគេខាត់ថ្មីៗ ក្បាលម្ចើដូចចំពុះក្អែក, មុខប្រទេសដូចបណ្តូលស្មៅយ៉ាងក្លាង, មានកំឡាំងខ្លាំងក្រៃ ក្នុងជាព្រះទីតាំងស្តេចបក្រតព្រាធិរាជ,។

អញ្ជាំងនេះត្រាស់ដឹងជាព្រះពុទ្ធច្បាកដហើយ សឹមអាត្មាអញនឹងវិលត្រឡប់មកមើលតំណែកូនវិញ, ទ្រង់ព្រះតម្រិះដូច្នេះស្រេចហើយ ទើបស្តេចចេញចុះចាកប្រាសាទទៅកាន់កណ្តាលមនោម័យ ទ្រង់មានព្រះបន្ទូលនឹងកណ្តកៈថា ម្នាលកណ្តកៈ! អ្នកចូរចម្ងល់យើងឲ្យទូន្មរួចក្នុងមួយភាត្រីនេះ យើងអាស្រ័យអ្នកជាយាន នឹងបានត្រាស់ជាព្រះពុទ្ធ ហើយចម្ងល់សត្វលោកត្រមាំងទេវលោកជាក់លើថ្កល់ត្រើយត្រាណាបានអមតនិព្វាន ។ កណ្តកជមនោម័យ ឱនទទួលស្តាប់ព្រះបន្ទូលប៉ុណ្ណោះហើយ មានចិត្តត្រេកអរក្រៃពេក បន្ទូរបូហសិតាការដ៏លាន់ឮគឹកកងរំពងឡើង ។

៩- ពោធិសត្វស្តេចចេញសាងមហាភិនេស្ក្រមណ៍

គ្រានោះ ព្រះបរមពោធិសត្វទ្រង់សេះកណ្តកជ ចេញចាកជនវៃសន៍ក្នុងកណ្តាលភត្រី ដូចសេចក្តីដែលទ្រង់មានព្រះពុទ្ធដីកាចំពោះពោធិជដកុមារថា(១)

“ម្នាលរាជកុមារ! កាលតថាគតនៅជាពោធិសត្វនៅឡើយ មានសេចក្តីត្រិះរិះថា សេចក្តីសុខ បុគ្គលមិនគប្បីបានដោយសេចក្តីសុខទេ, សេចក្តីសុខ បុគ្គលត្រូវបានដោយសេចក្តីទុក្ខ។

---

១ - ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ. ២៤ ទំព័រ ៣៥៩ ។

ម្នាលរាជកុមារ! សម័យក្រោយមក តថាគតនៅកម្លោះ មានសក់ខ្មៅស្រិល ប្រកបដោយវ័យដ៏ចំរើន គឺនៅក្នុងបឋមវ័យនៅឡើយ តាលមាតាបិតា មិនបង់ឲ្យប្លួស មានមុខទទឹកដោយទឹកភ្នែក កំពុងខ្ជួញយំ ក៏បាននោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ បេញចាកផ្ទះប្លួសមកប្លួស" ។

សេចក្ដីមួយទៀត កាលដែលព្រះអគ្គជិតនឹងចូលបរិនិព្វាន កំទ្រន់បានត្រាស់ចំពោះសុភទ្ធថា (๑)

"ម្នាលសុភទ្ធ! កាលតថាគតមានវ័យ๒๙ឆ្នាំបានប្លួសហើយ ជាអ្នកស្វែងរកគួរកុសល ។ ម្នាលសុភទ្ធ! កាលណា បើតថាគតប្លួសបានដាច់๕๐ឆ្នាំហើយ ញ៉ាំងប្រទេសគឺវិបស្សនាមគ្គឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹងគឺ អរិយមគ្គ, ព្រោះហេតុនោះ (សមណៈ)ខាងក្រៅសាសនាតថាគតនេះ មិនមានឡើយ" ។

ព្រះបរមគោតមសត្ថុស្ដេចឡើងលើទីឥណ្ឌកមនោមយ មានឆន្ន

๑-មហាបរិនិព្វានសូត្រ ទីឃ. សៀ. ๑๖ ទំព័រ ๓๑๓ ។

អាមាត្យជាន់ខ្ពស់ ស្តេចយាងចេញទៅដល់មាត់ទ្វារ(១)ធំ ទ្រង់ព្រះតម្រិះថា បើគ្មានអ្នកណាបើកទ្វារទេ អាត្មាអញទំងន់ជិះលើសេះគាបឲ្យជាប់ដោយក្តៅឲ្យធន្ធះគោងពីក្រោយ ហើយទំងន់លោតរំលងកំពែងកំពស់ ១៤ ហត្ថនេះ ចេញទៅខាងក្រៅឲ្យបាន ។ ឯធនូអាមាត្យទំងន់កណ្តាកអស្សត្រកើមានតំនិតដូចព្រះពោធិសត្វដែរ ។ ទេពតាអ្នកចាំទ្វារ ដឹងហេតុដូច្នោះដោយញាណជាទិព្វ ទឹកខ្លាចដល់អាជ្ញានៃទេពតាមានសក្តិធំ ។ កំបើកទ្វារថ្វាយ ។

កាលនោះ ជាថ្ងៃពេញបូណ៌មីនៃអាសាឡ ប្រកបដោយនក្ខត្តអាឡ្ហានក្ខត្តឫក្ស ព្រះបន្ទូពេញដំក្តីស្រមៃតទៅកណ្តាលពួកតាកដោយអនេកបរិវារលើយតាមនភាល័យ ។ ព្រះពោធិសត្វស្តេចបរតាមអាកាសវិថីរុងរឿងដោយទេវនិករាំងមុខលោកធាតុ ដែលធ្វើគ្រឿងសក្ការបូជាដោយផ្កាកម្រងគ្រឿងក្រអូបផ្សែង ។ ប្រគំដេញដំតូរ្យតន្ត្រីដេរដាសពាសពេញផ្ទៃនភាកាស ព្រះពោធិសត្វស្តេចចេញទៅក្នុងភក្ត្រីមួយប៉ុណ្ណោះ ឆ្លងបាន នគរ ៣ គឺនគរកបិលព័ស្តុ ១ នគរវៃសាលី ១ ទំងន់នគរសាវត្ថី ១ បម្រុយ

១-ទ្វារធំកំពែងក្រៅនេះ គេមិនអាចបើកបានទេ ព្រោះមានកម្លាំងទ្វារពាន់ កន្ធាំងមួយជាន់ៗ មនុស្សមួយពាន់នាក់ទើបបើកបាន, ព្រះបាទសុទ្ធោទនៈបង្គាប់ឲ្យធ្វើដូច្នេះ ដើម្បីការពារព្រះពោធិសត្វកុំឲ្យចេញបាន, តែមានសេចក្តីថា ព្រះពោធិសត្វមានកម្លាំងខ្លាំងណាស់ បើគិតធៀបនឹងកម្លាំងដំរី ខ្លាំងស្មើនឹងដំរីមួយពាន់កោដិ, បើធៀបនឹងកម្លាំងមនុស្ស ខ្លាំងស្មើនឹងមនុស្សមួយសែនកោដិនាក់ ។

ផ្លូវភា្ញ០ យោជន៍ ហើយស្តេចញ៉ាំងសេះឲ្យផ្ងោះឆ្ងាំងស្ទឹងអនោមានទី ដែលមានទទឹង ៨ ១សក ទៅត្រើយខាងនាយ ប្រៀបដូចជាទ្រង់ឆ្លងទឹយសង្សារ ស្តេចចុះចាកកណ្ឌកមនោម័យ ហើយទ្រង់និមិត្តនាការសណ្ឋិតលើផកខ្នាច់ ដែលមានសម្បុរដូចប្រាក់ ទ្រង់មានព្រះបន្ទូលត្រាស់បង្គាប់ឆន្នអាមាត្យ ថា ម្នាលឆន្នសំឡាញ់ ! អ្នកចូរនាំយកគ្រឿងអាភរណៈទាំងឡាយ ព្រមទាំងសេះសិន្ធពនេះវិលទៅនគរវិញចុះ យើងនឹងបួសក្នុងទីនេះ, មានព្រះបន្ទូលដូច្នេះហើយ ទ្រង់ដោះគ្រឿងអាភរណៈទាំងឡាយ ចេញអំពីព្រះអង្គ ហើយប្រគនទៅឆន្នអាមាត្យ ។ ឯឆន្នអាមាត្យ ក្រាបទូលសូមបួសជាមួយផង ព្រះពោធិសត្វស្តេចមិនទ្រង់អនុញ្ញាត ហើយឆន្នអាមាត្យក៏នាំគ្រឿងអាភរណៈព្រមទាំងសេះត្រឡប់ព្រះនគរវិញ ។

១០-ទ្រង់កាត់យកឧត្តមភេទ

ព្រះពោធិសត្វស្តេចទ្រង់ព្រះចិន្តាថា កេសាអាត្មានេះ មិនសមដល់សមណៈភេទទេ ទើបទ្រង់ចាប់ព្រះខ័នដោយព្រះហស្តស្តាំ ចាប់ព្រះកេសាដោយព្រះហស្តឆ្វេង កាត់ព្រះកេសាដោយព្រះអង្គឯង ព្រះកេសា(១)

១-ព្រះកេសាទៅសល់ ២ ឆ្នាប់នេះ មិនល្អតណាស់ទៀត សូម្បីព្រះមស្សុ ក៏ផ្លុំបង្ហាមិនចាប់កោរកាត់ទៀតទេ ទៅតែប៉ុណ្ណោះហួតជាល់បរិមិត្តាន ។

ទៅសល់ប្រហែលតឹងធ្នាប់ តែវិលជាខក្ខិណាវដ្តទាំងអស់ រួចទ្រង់ចាប់ព្រះបូរ្សាមួលីចោះទៅលើអាកាសថ្មឹងថា បើអាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ សូមឲ្យបូរ្សាមួលីនេះ ឋិតនៅលើអាកាស, បើមិនបានត្រាស់ទេ ឲ្យធ្លាក់មកលើផែនដីវិញចុះ ។ កាលណោះ ព្រះឥន្ទ្រាធិរាជ ទតឃើញដោយទិព្វចក្ខុហើយ យកប្រអប់កែវទៅទទួលព្រះបូរ្សាមួលីនោះ យកទៅប្រតិស្ឋាទុកក្នុងឋិបូរ្សាមណីចេតិយ, ព្រះអដ្ឋកថាចារ្យពោលសរសើរដោយព្រះគាថាដូច្នេះ៖

ឯត្ថាន មោលឹ វរគន្ធកំសិតំ
វេហាសយំ ឧក្កិបិ អគ្គបុគ្គលោ
សហស្សរង្សោ សិរសា បដិគ្គហិ
សុវណ្ណចង្កោដវរេន កស្សបោតិ

«ព្រះអគ្គបុគ្គលទ្រង់កាត់ព្រះមោលី ដែលអប់ហើយដោយគ្រឿងក្រអូបដ៏ប្រសើរ ហើយទ្រង់ចោះទៅឯអាកាសវេហាស៍, ព្រះសហស្សរង្សីភ្ជាប់សរ: ស្តេចទទួលព្រះមោលីនោះទុកក្នុងប្រអប់ជាវិការៈនៃមាសដ៏ថ្លៃថ្លាដោយសិរ្សៈខ្លួន" ។

ក្នុងលំដាប់នោះ ព្រះពោធិសត្វទ្រង់ព្រះចិន្តាតទៅទៀតថា តាសិកពស្ត្រនេះ មិនសមគួរដល់សមណកេរទេ; ត្រានោះ ឃដិការមហា-

ព្រហ្មា ជាមិត្រចាស់ព្រះអង្គក្នុងសាសនាកាលព្រះពុទ្ធកស្សបៈ ដ៏ឯហេតុដូច្នេះ កំតែងថា សំឡាញ់អាត្មាអញចេញសាងផ្នួសក្នុងវៃថ្ងៃនេះហើយ ដើដូច្នេះ គួរតែអាត្មាអញនឹងយកគ្រឿងសមណបរិក្ខារ(១) ទៅថ្វាយដល់ព្រះនេះ, តែតដូច្នេះហើយ កំនាំយកគ្រឿងបរិក្ខារ ៨ ទៅថ្វាយព្រះពោធិសត្វ ដូចមានបទព្រះគាថាដែលលោកអ្នកប្រាជ្ញបានចងទុកជាគាថាពន្ធដូច្នេះ ៖

តិចីវរញ្ច បត្តោ ច វាសិ សូចិ ច ពន្ធនំ
បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ ។

"គ្រឿងបរិក្ខារបស់តិក្ខុ អ្នកមានព្យាយាមគួរប្រកប មាន ៨ ប្រការ គឺ ត្រៃចីវរ (សង្ឃាដិ ចីវរ សង្ឃាដិ) ១, ជាត្រ១, កាំបិតកោរ១, ចំពង់ម្ជុល១; កាយពន្ធន៍១, ស្ពាត់ត្រងទឹក១, " ។

ព្រះពោធិសត្វ ទទួលគ្រឿងបរិក្ខារអំព័យដ៏ការមហាព្រហ្មហើយ ទ្រង់ប្រដាប់ត្រៃចីវរកាសាវពស្ត្រ ជាទង់ជ័យព្រះអរហន្ត ដោយបុព្វភាគ-យោគ ដែលទ្រង់ធ្វើជាប់សិក្សាមកអំព័បុរេតព ជាបព្វជិតកេទុត្តម ហើយទ្រង់ប្រគល់ព្រះកូសាតាំងគូដែលទ្រង់ជាគ្រហស្ថ ប្រគនទៅមហាព្រហ្ម។ ទទួលឯកព្រះកូសានោះ ហើយថ្វាយបង្គំលា នាំយកទៅបញ្ចោះនៅកន្លែងទុស្សចេតិយក្នុងព្រហ្មលោក ។

១-លលិតវិស្តរៈថា មហាព្រហ្មក្លែងខ្លួនជាព្រាហ្មណ៍ចាស់ ពោធិសត្វសុំផ្ទុះសំលៀកបំពាក់ព្រាហ្មណ៍នោះ ប្រទានគ្រឿងអំតាវទៅព្រាហ្មណ៍វិញ ។ (ទៅមានត)

គោលព្រះធម្មា ៨

ព្រះឧបាលិវង្ស សួរ-ឋាយ

រៀបរៀង

ព្រះនិព្វានជាគោលដៅមួយដ៏ធំបំផុតរបស់ព្រះពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម៌បញ្ញត្តិនិយ ប្រៀនប្រដៅសាធារណជនក្នុងកាលដែលទ្រង់ប្រតិបត្តិព្រះពុទ្ធកិច្ច ៤៥ ឆ្នាំ រាប់តាំងអំពីថ្ងៃដែលព្រះអង្គបានត្រាស់ដឹងរហូតដល់ថ្ងៃបរិនិព្វានទោះ ពុំមែនដើម្បីអ្វីក្រៅពីការណែនាំសត្វលោកឲ្យស្គាល់ឲ្យចេះដើរដ៏ប្រសើរបំផុតគឺព្រះនិព្វានទោះឡើយ ។

និព្វានជាអត្ថបទ ៤ នៃអភិធម្មត្ថសង្គហៈ, ជាគុណជាតដ៏ល្អិតបំផុតដែលបុថុជ្ជនអាចយើញច្បាស់ដោយចក្ខុ ឬដោយប្រាណស់, និព្វានជាលទ្ធផលនៃពុទ្ធបរិសទ៍ ដែលប្រតិបត្តិដោយសេចក្តីព្យាយាមដ៏ត្រឹមត្រូវតាមមជ្ឈិមបដិបទា ឬ តាមកុសលធម៌ទាំងឡាយមានបុញ្ញកិរិយាវត្ថុ ១០ ជាដើម ។ និព្វានជាឥដ្ឋារម្មណ៍ (អារម្មណ៍ជាទីប្រាថ្នា, ជាទីចាប់ចិត្ត) នៃកល្យាណបុថុជ្ជនទើងអរិយបុគ្គលដោយពិត ប៉ុន្តែជាអនិដ្ឋារម្មណ៍នៃឫបជនឬពាលជន ដែលផ្ទុយស្រឡះអំពីកល្យាណបុថុជ្ជនទើងអរិយបុគ្គល ។ កន្លែងនេះសូមសំដែងចំពោះព្រះនិព្វាន ដើម្បីជាសណ្តាប់នៃពុទ្ធបរិសទ៍ដោយសង្ខេបដូចតទៅនេះ៖

ពាក្យថា "ឯញ្ជាយ" បានដល់សេចក្តីសូម, យើងអាចយល់បាន ដោយបញ្ជាស់ឈ្មោះចំពោះព្រះនិញ្វាន អាស្រ័យមានពុទ្ធភាសិតដូចតទៅ នេះ :-

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះ រមែងជាអ្នកអាចយើញបញ្ជាស់នូវសីតិភាព ។ ធម៌ ៦ យ៉ាងនោះគឺ :

១ ការសង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់បាន

២-ផ្គងចិត្តឡើងក្នុងសម័យដែលគួរផ្គងបាន

៣-ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយបាន

៤-ជាក់ចិត្តត្រង់ឱក្នុងសម័យដែលគួរជាក់ចិត្តបាន

៥-អាធ្យាស្រ័យដំប្រណីតអាចធ្វើបាន

៦-ចិត្តត្រេកអរយ៉ាងខ្លាំងក្នុងព្រះនិញ្វាន ។

ពាក្យថា "ជាអ្នកអាចយើញបញ្ជាស់នូវសីតិភាព" តាមភាសាបាលី ប្រើពាក្យថា កល្យោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ប្រែថា បុគ្គលគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសីតិភាពដ៏ប្រសើរបំផុត ឬជាកំពូល ។ ពាក្យថា សីតិភាព នេះប្រែថា "ត្រជាក់ត្រជុំ" ។ អដ្ឋកថាចេញ សេចក្តីថា ព្រះនិញ្វាន ដែលជាគុណជាតដ៏ត្រជាក់សុខស្ងប់ក្រៃលែង ព្រោះរលត់ភ្លើងកិលេស ភ្លើងទុក្ខអស់ហើយ ។

តាមម្នាណ៍នៃអរិយបុគ្គល ដែលចូលដល់ព្រះនិព្វាន ក្រៅអំពីអត្ថបទ
កន្លងសូត្រនេះ មានអត្ថបទមួយទៀតជាពុទ្ធភាសិតដែលបញ្ជាក់ឲ្យយើងឮ
ថា និព្វាន គឺអ្វី ? មានគុណសម្បត្តិដូចម្តេច ? ពុទ្ធភាសិតនេះ
សំគាល់ត្រង់ការពិពណ៌នាម្នាណ៍ របស់អរិយបុគ្គល ដែលចូលដល់ព្រះ
និព្វានហើយ មានចិត្តប៉ះពាល់នូវព្រះនិព្វានហើយ ក្នុងពេលណា ដែល
ចិត្តបានជួបប្រទះនូវព្រះនិព្វានហើយ ពេលនោះ អរិយបុគ្គលត្រង់ប្លែ
តែងមានការពិពណ៌នាម្នាណ៍ដុះចេញមកថា ៖-

គុណជាតខ្ទុះស្អប់ ខ្ទុះប្រណីត ខ្ទុះឯងជាទីបន្សាត់បង់នូវសេចក្តី
ស្រវឹង ជាទីកំចាត់បង់នូវសេចក្តីស្រេកឃ្លាន ជាទីដកចោលនូវសេចក្តី
អាល័យ ជាទីកាត់បង់នូវវដ្តៈ ជាទីអស់ទៅនៃតណ្ហា ជាទីប្រាស
ចាកតំរេស ជាទីរំលត់តំរេស នេះឯងហៅថា «និព្វាន(១)» ។

អត្ថបទខាងលើនេះ តាមភាសាបាលីថា ៖-

ឯតំ សន្តំ ឯតំ បណីតំ យទិទំ មទនិម្មទនោ
បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដូបច្ឆេទោ
តណ្ហាក្ខយោ វិរាគោ និព្ពានំ និព្វានំ ។ ពាក្យបាលី
ទាំងនេះ អ្នកដែលមិនស្គាត់ជំនាញភាសាបាលី គឺគួរតែព្យាយាមខ្ទេញ

១- មាន ២ យ៉ាងគឺ: សឧបាទិសេសនិព្វាន ១ អនុបាទិសេសនិព្វាន ១ ។

ឱ្យចាំ ព្រោះពាក្យនេះជាគោលសំដៅដ៏ខ្ពង់ខ្ពស់ អត្ថបទ ខ្ញុំដឹងគុណជាតនៃព្រះ
ធម្មានយ៉ាងជាក់លាក់បំផុត, សូមពិនិត្យពាក្យប្រែតទៅនេះ

ឯតំ សន្តំ គុណជាតន្ទុះសូប៌

ឯតំ បណីតំ ន្ទុះប្រណីត

យទិទំ គុណជាតនេះឯងគឺ

មធុធម្មធោ ជាទីបន្សាត់បង់នូវសេចក្តីស្រវឹង

បិបាសវិនយោ ជាទីកំចាត់បង់នូវសេចក្តីស្រេកឃ្លាន

អាលយសមុគ្ឃាតោ ជាទីដកចោលនូវសេចក្តីអាល័យ

វដ្តុបច្ឆេទោ ជាទីកាត់បង់នូវវដ្ដៈ

តណ្ហាក្ខយោ ជាទីអស់ទៅនៃតណ្ហា

វិរាគោ ជាទីរលាយភាគៈ

និរោធោ ជាទីរំលត់កិលេស

និព្ពានំ ជាទីអស់គ្រឿងចាក់ស្រៈ ។

ពុទ្ធភាសិតនេះសំដែងបញ្ជាក់ថា និព្វានគឺសេចក្តីសូប៌ដ៏ប្រសើរ ។
ពាក្យថា "ប្រសើរ" នោះ កថិកដ្ឋកថា អធិប្បាយថា "ខ្ពស់ផុតពីអ្វី
ប្រៀបពុំបាន" ។ កថិកនេះ សេចក្តីសូប៌ដែលហៅថាព្រះ និព្វាន
នោះ សំដៅយកសេចក្តីសូប៌ដ៏ត្រជាក់ត្រជុំប្រសើរខ្ពស់បំផុត ។ បុគ្គលដែល

ចានចូលដល់សេចក្តីស្ងប់ថ្នាក់នេះហើយ មិនចេះធុញទ្រាន់ មិនចេះឆ្អែតឡើយ ចានសេចក្តីថា «តែងខ្ជួលសេចក្តីស្អប់ចិត្ត-ឆ្អែតចិត្ត-រីករាយចិត្តជានិច្ច» ន័យនេះសមដូចពុទ្ធភាសិតមួយកន្លែងទៀតថា:-

បវិវេកំ រសំ បិវិត្វា រសំ ឧបសមស្ស ច

និទ្ទរោ ហោតិ និប្បាបោ ធម្មប្បីតិរសំ បិវំ ។

អ្នកដែលចានផឹកនូវរសនៃសេចក្តីស្ងាត់ចាកកិលេស ចានផឹកនូវរសនៃសេចក្តីស្ងប់ហើយ រមែងជាអ្នកមិនចានសេចក្តីខ្វល់ខ្វាយ ជាអ្នកមិនចានបាប កាលផឹកនូវរសនៃធម្មប្បីតិ ។

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា

អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

អ្នកដែលមានបីតិកើតឡើងដោយធម៌ មានចិត្តថ្លាថ្លាផង តែងនៅជាសុខ បណ្ឌិតតែងរីករាយក្នុងធម៌ដែលព្រះអរិយៈទ្រង់ប្រកាសហើយសព្វ ។ កាល ។

ពុទ្ធភាសិតមួយកន្លែងទៀតមានសេចក្តីស្រដៀងគ្នានឹងពុទ្ធភាសិតខាងលើនេះថា :

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្ពានំ ។

និព្វានន្តុ សុខំ ឧត្តមំ ប្រណីតំ នេះឯងជាធម្មជាតិរម្ងាប់នូវសង្ខារទាំងពួង

ជាទីលះចោលនូវមិច្ចាទិដ្ឋិ ជាទីអស់នៅនៃតណ្ហា ជាទីប្រាសចាក
កិលេស ជាទីរំលត់នូវកិលេស ហៅថា ឯញ្ជាន ។

ឯញ្ជានដែលសំដៅយកសេចក្តីស្ងប់នេះ អាចធ្វើសេចក្តីចូលចិត្តឲ្យ
ប្បាស់ថា «មិនមែនសំដៅយកសេចក្តីស្ងប់ធម្មតា ដែលធ្លាប់តឹងចុនមួយ
ដងម្តងយ៉ាមនោះទេ» គឺសំដៅយកសេចក្តីស្ងប់ជាកំពូលគ្មានអ្វីបង្កបង្កើត
ទៀត មិនមែនកើតមកពីអ្វី ឬ ប្រែប្រួលពីអ្វីទៀតឡើយ ជាសេចក្តីពិត
ដែលមាននៅទាន់លើធម្មជាតិតាំងអស់ តាំងវត្តតាំងនាមធម៌ ។ វត្តតាំង
ឡាយដែលមានបច្ច័យតុបតែង តាលបើអស់ហេតុអស់បច្ច័យហើយ
រមែងរំលិចចូលទៅកន្លែងសេចក្តីស្ងប់ស្ងៀម ដែលអស់ផ្តួសផ្សារនៃសោកល
ចក្រាំឡ, សេចក្តីស្ងប់ចាកកិលេសនោះ ទើបបានតាំងនៅជាស្ថាពរកន្លែ
បំផុតគ្មាន ។

ជឹងប្បាស់ផ្លូវព្រះនិព្វានដូចម្តេច ?

សេចក្តីស្ងប់ដែលហៅថាឯញ្ជាននេះ លោកអ្នកគិតអាចគិតស្ទង់បាន
តាមន័យនៃតក្កៈ (សេចក្តីត្រិះរិះ)ថា វត្តណាដែលអស់នៅនៃហេតុបច្ច័យ
ឬដែលកំចាត់ហេតុបច្ច័យចេញបានអស់ហើយ សល់នៅតែសេចក្តីទេ
ស្អាត ប្រាសចាកខ្លួនប្រាណ ប្រាសចាកចិត្តនោះ ។, ហើយក្នុងសេចក្តី
ទេស្អាតនោះ គ្មានវត្ថុអ្វីក្រៅពីសេចក្តីស្ងប់ស្ងៀមនៃផលញាណទេ ។

សេចក្តីស្ងប់ដែលគោលមកនេះ មានទៅជាទិដ្ឋ មិនចាំបាច់មានទុំតុបតែង
ព្រោះមិនមានរូបកាយក្រាកដូចម្តេចទេ ប៉ុន្តែយើងអាចដឹងបានថា វត្ថុ
ត្រង់យ៉ាងដែលមានក្រាកដនោះ សុទ្ធតែកើតមកពីហេតុបច្ច័យច្រើនយ៉ាង
រួមផ្តុំគ្នាកឡើងជាវត្ថុ ។ ឯទិព្វានមិនមានវត្ថុអ្វីដែលមានខ្លួនក្រាណាតែ
ក្រាកដទេ ។ សេចក្តីអធិប្បាយដែលគោលមកនេះ ហាក់ដូចនឹងចូល
ចិត្តងាយ តែសូមកុំភ្លេចថា ទិព្វានគឺជាផលញាណដែលយើងអាចទទួល
ឯកន្តបរមេសុខបាន គឺការទទួលអារម្មណ៍នៃសេចក្តីស្ងប់ពិត ។ ទើបបាន
ឈ្មោះថា ជាធម្មាស់ក្នុងព្រះទិព្វាន, ព្រោះទិព្វាននោះ មានទៅផល-
ញាណអាចទទួលអារម្មណ៍ជាវិសាលសុខ ដែលផ្សែងចាកសុខក្នុងភព
ទាំង ៣ ។

ពាក្យថា ការធ្វើឲ្យជាក់ច្បាស់នូវព្រះទិព្វាន ក្នុង
គម្ពីរបដិសម្ភិទាមគ្គ ដែលព្រះសារីបុត្តអធិប្បាយថា «បានដល់ការទទួល
នូវបរមសុខប្លែកវិសេស ទើបឈ្មោះថាទិព្វាន" ដោយបាលីថា សច្ឆិ-
កិរិយាបញ្ញា ផស្សនដ្ឋេន ញាណំ ប្រែថា បញ្ញាជាគ្រឿង
ធ្វើឲ្យជាក់ច្បាស់នូវព្រះទិព្វាន, ឈ្មោះថាញាណដោយប៉ះពាល់នូវព្រះ
ទិព្វានអាចប្រៀបនឹងពុទ្ធភាសិតថា ផុសន្តិ ធីរា ឯព្វានំ យោគ-
ក្ខេមំ អនុត្តរំ ប្រែថា អ្នកប្រាជ្ញទាំងឡាយតែងប៉ះពាល់នូវព្រះទិព្វាន

ដែលជាទីក្សេមក្សាន្តចាកគំលេសយ៉ាងប្រសើរចំផុត ។

និព្វានជាទីស្ងប់នៃសង្ខារទាំងពួង

ពាក្យថា «និព្វាន» គឺជាទីស្ងប់នៃសង្ខារទាំងពួង, សង្ខារ ប្រែថា ធម៌ដែលមានបច្ច័យជាគ្រឿងតុបតែង, ក្នុងន័យនេះសង្ខារសំដៅយកនាមរូប។

កាលបើវិញ្ញាណបានតប់ប្រសប់នឹងសេចក្តីសូន្យដ៏ប្រណីតនេះហើយ អរិដ្ឋ តណ្ហា នឹង១បានទេ កំហួតចាកបន្ទិចម្តង។ ដរាបដល់មិនសេសសល់ ។ ក្នុងពេលដែលគំលេសមិនមាននៅក្នុងសន្តានហើយ មិនមានអ្វី ដែលនាំឲ្យមានកម្មថ្មីតទៀតឡើយ កាលបើអស់ចាំងកម្មចាំងគំលេសហើយ ចងសន្ធិវិញ្ញាណនៃជាតិតទៅថ្មីតក៏មិនមាន, កាលបើអស់ចងសន្ធិវិញ្ញាណហើយ នាមរូបក៏មិនមាន ព្រោះហេតុនោះនិព្វាន ទើបឈ្មោះថាជាទីស្ងប់នៃសង្ខារទាំងពួង ។ សេចក្តីអធិប្បាយនេះ យើងអាចយើញបានដោយច្បាស់ចំពោះពាក្យសួរ នឹងពាក្យតបរវៀងអដ្ឋកមាណព នឹងព្រះសម្មាសម្ពុទ្ធដូចតទៅនេះ ៖-

អដ្ឋកមាណពបានក្រាបបង្គំទូលព្រះពុទ្ធបរមគ្រូថា :

បពិត្រព្រះអង្គដ៏ចំរើនទុក្ខ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរថា បញ្ញាសតិ នឹងនាមរូបទាំងនេះ រមែងរលត់អស់ទៅក្នុងទីណា ? សូមព្រះអង្គមេត្តាប្រោសតបឲ្យបាន ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា :

នែអជិតៈ ! អ្នកបានសួរនូវប្រស្នាណាចំពោះតថាគត តថាគតនឹងប្រាប់នូវប្រស្នានោះដល់អ្នក; នាមនឹងរូបតែងរលត់មិនមានសល់ក្នុងទីណា បញ្ញានឹងសតិក៏រលត់បង់ក្នុងទីនោះដែរ ហាងនេះគឺព្រោះវិញ្ញាណរលត់ ។ បញ្ញានឹងសតិជាចំណែកមួយនៃនាមធម៌ក្នុងកងសង្ខារ ។ ចម្ងាយដែលទ្រង់តបទៅកាន់អជិតមាណព ជាទីគួរចាប់ចិត្តយ៉ាងក្រៃលែង ព្រោះបញ្ញានឹងសតិជាសង្ខតធម៌ ជារបស់ត្រូវរលត់ជាមួយនឹងវិញ្ញាណដែរ ។ បញ្ញានឹងសតិនេះជានាមធម៌ ជារបស់មិនទៀងទាត់ខ្លៅឡើយ ប៉ុន្តែផលនៃនាមធម៌ជាច្រើនយ៉ាង មានពោធិបក្ខិយធម៌ជាដើម ដែលអាចនាំចិត្តអ្នកឲ្យចិត្តរួចចាកអាសវក្កិលេសទាំងពួង ប្រមូលកំណាំងឲ្យតើតអរហត្តផលញាណបានដោយពិត ។

ធម្មាធជាទីលះបង់នូវឧបធិទាំងពួង

ពាក្យថា «ឧបធិ» កងទីនេះ សំដៅយកកិលេស ដូចជាពាក្យថា ឧបធិវិវេកោ សេចក្តីស្ងប់ស្ងាត់ចាកឧបធិកំមាន សំដៅយកបញ្ចក្ខន្ធកំមាន ដូចបាលីថា:-

ឧបេ ច សន្ធេ ច អភោ រសេ ច

តណ្ហាមតិត្តិយោ ចាកិរនត្តិ យញ្ញា

ฯลฯ มลฺลิ อุปฺปลานิ ปญฺจ

ตสฺสา จ ยิฏฺเฐ จ ปาโต อาคญฺฉิ

ยញ្ញតាំងឲ្យយតែនពោលសរសើរបូជា សម្តែង នូវ ការមនឹងស្រ្តីតាំងឲ្យយ ខ្ញុំព្រះអង្គយល់ថា នោះជាមន្ទិលក្នុងឧបធិតាំងឲ្យយ ហេតុនោះ ទើបមិនត្រែតត្រអាលក្នុងការសែនព្រេន នឹងការបន់ស្រន់ ។

ឧបធិក្នុងទីនេះ អដ្ឋកថាប្រាប់ថាជាដល់បញ្ចក្ខន្ធ ។ ឯពាក្យថា «ឥញ្ជាឯ» នេះ ជាទីលះបង់តាំងកិលេសតាំងបញ្ចក្ខន្ធ គឺគ្មានសេសសល់ឡើយ ។

និញ្ជាឥជាវីរាគធម៌

ក្នុងទីខ្លះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ហៅនិញ្ជានថា «វីរាគធម៌» ដែលប្រែថា ធម៌ជាទីប្រាសចាកនៃកិលេស គឺសំដៅសេចក្តីថា ចិត្តរបស់បុគ្គលណាមួយ កាលបើបានប្រទះនឹងវីរាគធម៌ហើយ ឈ្មោះថាបានដឹងនូវព្រះនិញ្ជានហើយ ។ កិលេសតាំងឲ្យយរមែងវិនាសចេញពីចិត្ត មិនមានសេសសល់ ។ ពាក្យថា «វីរាគធម៌» ក្នុងទីនេះ ក៏គឺសេចក្តីស្ងប់ដែលប្រាសចាកតម្រេក ដែលយើងអាចយល់បានយ៉ាងច្បាស់ ដោយពុទ្ធភាសិតដូចតទៅនេះ :-

យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា

ภ វិភតោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទ.
នោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដូបច្ឆេទោ
តណ្ហាក្ខយោ វិភតោ និព្ពានំ ។

ម្នាលភិក្ខុទាំងឡាយ សង្ខតធម៌ ឬ អសង្ខតធម៌មានចំនួនប៉ុន្មាន
វិភគធម៌ យើងពោលថា ជាកំពូលនៃសង្ខតធម៌ទាំងអស់
នោះ, វិភគធម៌ គឺធម៌ជាទីបន្លាត់បង់នូវសេចក្តីស្រវឹង ជាគ្រឿងកំចាត់
នូវសេចក្តីស្រេកឃ្លាន ជាគ្រឿងរលាស់នូវសេចក្តីអាល័យ ជាគ្រឿង
រំលត់ទៅនៃកិលេស ហៅថា និព្ពាន ។

និព្វានជាអសង្ខតធម៌

ត្រង់បទថានិព្វានជាអសង្ខតធម៌នេះ យើងអាចយល់បានយ៉ាងជាក់
លាក់ ដោយអាស្រ័យពុទ្ធភាសិត ក្នុងពុទ្ធវគ្គ ខុទ្ទកនិកាយ ដូចត
ទៅនេះ :-

អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ ។
នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ
អសង្ខតំ ។ ឧយិច ជាតស្ស ភូតស្ស កតស្ស សង្ខ.
តស្ស និស្សរណំ បញ្ញាយេថ ។ យស្មា ច ខោ
ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ តស្មា

ជាតិសប្ប ភូតិសប្ប កតិសប្ប សង្ខតិសប្ប ឯសប្បរណំ បញ្ញាយតិ ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈដែលមិនកើត មិនលូតលាស់ ដែលមិនមានបច្ច័យធ្វើ មិនតាក់តែងមានទៅ, ម្នាលភិក្ខុទាំងឡាយ បើអាយតនៈដែលមិនកើត មិនលូតលាស់ មិនមានបច្ច័យធ្វើ មិនតាក់តែងមិនបានមានហើយ ការរលាស់ខ្លួនចេញដែលនាំឲ្យកើត លូតលាស់ ដែលមានបច្ច័យធ្វើ ដែលតាក់តែងក្នុងលោកនេះ មិនត្រូវជាដូចេ ? ម្នាលភិក្ខុទាំងឡាយ អាយតនៈដែលមិនកើត មិនលូតលាស់ មិនមានបច្ច័យធ្វើ មិនតាក់តែង រមែងមានទៅត្រូវជា ព្រោះហេតុណា ហេតុនោះ ការរលាស់ចេញខ្លួនចេញដែលកើត ដែលលូតលាស់ ដែលមានបច្ច័យ ដែលតាក់តែងរមែងត្រូវជា ។

ឥព្វាធជាអាយតនៈ

ព្រះមានព្រះភាគនិកាយ មានបាលីបញ្ជាក់ដូចតទៅនេះ ៖

អត្ថិ ភិក្ខវេ តទាយតនំ ។ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ ។ នាយំ លោកោ ន បរលោកោ ន

ឧកោ ចង្កមសុរិយា ។ តមហំ កិក្ខវេ ឯវំ អាគតំ
ឯធាមិ ន កតឹ ន បិតឹ ន ចុតឹ ន ឧបប្បត្តឹ ។ អប្បតិដ្ឋំ
អប្បវត្តំ អនារម្មណមេវ តំ ។ ឯសេវន្តោ ទុក្ខស្ស ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះរមែងមានទៅ ប៉ុន្តែកន្លែងអាយតនៈ
នោះមិនមានដី មិនមានទឹក មិនមានភ្លើង មិនមានខ្យល់ អាកាសានញ្ចា
យតនៈក៏មិនមែន អាកិញ្ចញ្ញាយតនៈក៏មិនមែន នេវសញ្ញានាសញ្ញាយ-
តនៈក៏មិនមែន លោកនេះក៏មិនមែន លោកដទៃក៏មិនមែន ព្រះចន្ទនិង
ព្រះអាទិត្យក៏មិនមែន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវ
អាយតនៈនោះថាទៅមានដំណើរ តឹការមកទៅ ឈរ ច្យុតិ កើត
ឡើយ ។ អាយតនៈនោះមិនមានទីតាំង មិនប្រព្រឹត្តទៅ មិនមាន
អារម្មណ៍សោះឡើយ នេះហើយជាទីបំផុតនៃសេចក្តីទុក្ខ ។

ពុទ្ធភាសិតនេះហៅនិព្វានថា «អាយតនៈ" ។ ពាក្យថា អាយតនៈ
នេះសំដៅយកធម្មាយតនៈ គឺជាធម្មារម្មណ៍ដែលសុទ្ធចិត្តចាប់តោងតាម
វិឈានឬវិបស្សនាឡើងទៅកាន់លោកុត្តរធម៌ ។ ការដែលនឹងពួលចិត្ត
គោលនិព្វានឲ្យបានជ្រៅជ្រះ ត្រឹមត្រង់តាមសេចក្តីពិតនោះ គួរសិក្សា
ពុទ្ធភាសិតមួយកន្លែងទៀត ក្នុងពុទ្ធទីឃនិកាយដូចតទៅនេះ ៖

និស្សិតស្ស ចលិតំ ។ អនិស្សិតស្ស ចលិតំ

ឧត្តំ ។ ចលំតេ អសតិ បស្សទ្ធិ ។ បស្សទ្ធិយា សតិ វតិ ឧ ហោតិ ។ វតិយា អសតិ អាគតិ កតិ ឧ ហោតិ ។ អាគតិកតិយា អសតិ ចុតូបបាតោ ឧ ហោតិ ។ ចុតូបបាតេ អសតិ នេវ ឧ ហុរំ ឧ ឧភយមន្តរេ ។ ឯសេវន្តោ ទុក្ខស្ស ។ (វត្តិនីវត្តិយា អដ្ឋកថា តែថា ឧតិ ឧតិយា) ។ ការញាប់ញ័រតែងមានដល់បុគ្គលអ្នកអាស្រ័យតណ្ហា ការញាប់ញ័រ មិនមានដល់បុគ្គលដែលមិនអាស្រ័យតណ្ហាទេ, កាលបើសេចក្តីញាប់ញ័រមិនមាន បស្សទ្ធិ សេចក្តីស្ងប់រម្ងាប់មាន; កាលបើបស្សទ្ធិមាន វត្តិគឺសេចក្តីត្រេកអរមិនមាន; កាលបើវត្តិមិនមាន ដំណើរជាទីមកជាទីទៅក៏មិនមាន; កាលបើដំណើរជាទីមកជាទីទៅមិនមាន ការច្យុតនិងការកើតក៏មិនមាន; កាលបើការច្យុតនិងការកើតមិនមាន លោកនេះនិងលោកដទៃក៏មិនមាន; ទីក្នុងចន្លោះនៃលោកទាំងពីរក៏មិនមាន នេះឯងជាទីបំផុតនៃសេចក្តីទុក្ខ ។

និព្វានមិនមែនបិត្តុ

ចិត្តដែលរួចចាកអាសវក្កិលេសហើយ ហៅថា ចិត្តដល់នូវនិព្វាន ដោយពិត ប៉ុន្តែកាលបើចិត្តដល់នូវនិព្វានហើយ លែងហៅថាចិត្តទៀតហើយ ។ ពាក្យថា "និព្វាន" នេះលោកសំដែងយកអនុបាទិសេសនិព្វាន-

ធាតុ ។ សមដូចបាលីកន្លងមកថាធម្មសង្គណីដែលតាំងជាបញ្ហាថា

កតមេ ធម្មា ចិត្តា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោធាតុ មនោវិញ្ញាណធាតុ ឥមេ ធម្មា ចិត្តា ។

កតមេ ធម្មា នោ ចិត្តា វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ចិត្តា ។

ធម្មតាំងឡាយដូចម្តេច ហៅថាចិត្ត ? គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មតាំងនេះហៅថាចិត្ត ។

ធម្មតាំងឡាយដូចម្តេច ហៅថាមិនមែនចិត្ត ? គឺវេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ រូបតាំងអស់ ១ អសង្ខតធាតុ ១ ធម្មតាំងនេះហៅថាមិនមែនចិត្តទេ ។

ពាក្យថា "អសង្ខតធាតុ" បានដល់ធាតុដែលមិនមានបច្ច័យតាក់តែងលោកសំដែងយកនិព្វានដែលបញ្ជាក់ថា និព្វាន ពុំមែនជាចិត្តឡើយ ។

និព្វានមិនមែនសូន្យ

និព្វានជាគុណជាតដែលមានទៅជាស្ថាពរ មិនមានការប្រែប្រួល

ជាលទ្ធផល ដែលកើតមកអំពីចិត្តបរិសុទ្ធនៃពុទ្ធបរិស័ទ ។ ទិញ្ញាន៤ុំមែន
ជាទីរ៉ាំលស្ហាស្លេវដូចអាកាសជាតុទេ ត្រង់ពាក្យដែលថា «ទិញ្ញានសូន្យ
នោះ» មិនមែនសូន្យខ្លួនឯងទេ គឺសូន្យស្ងាត់ចាកកិលេសត្រង់យ៉ាងសូន្យ
ស្ងាត់ចាកជាតិ ជរា ព្យាធិ មរណៈ សមដូចពុទ្ធភាសិតថា «ឯញ្ជាំ
បរមំ សុញ្ញំ» ទិញ្ញាណជាគុណជាតសូន្យដ៏ក្រៃលែង, ឯញ្ជាំ
បរមំ វេទន្តិ ពុទ្ធា ព្រះពុទ្ធទាំងឡាយ តែងពោលថា ទិញ្ញាណជា
គុណជាតប្រសើរក្រៃលែង» ។

ពាក្យថា «ទិញ្ញានសូន្យនោះ» សំដៅយកការស្ងាត់ចាកសង្ខារវិញ្ញ
ត្រឿងវិលវល់ ដូចប្រទេះនឹងការកើតស្លាប់ តុំមែនទិញ្ញានសូន្យទេឯង។
នោះឡើយ ។ ដូចពាក្យថា «តាមោ សុញ្ញោ ឯកំ សុញ្ញំ
កេហំ សុញ្ញំ ប្រែថា ស្រុកសូន្យ, ក្រុងសូន្យ, ផ្ទះសូន្យ» ។
ពាក្យថា «ស្រុកសូន្យ» បានដល់ស្រុកសូន្យចាកមនុស្ស ក្នុងកាលដែល
មានអាសន្នរោគ ឬអហិវាតករោគ មនុស្សក្នុងស្រុកភៀសខ្លួនរត់ចេញ
ពីលស្រុក ស្ងាត់ពីស្រុកសូន្យឈឹង ។ ក្រុងសូន្យ, ផ្ទះសូន្យ ក៏
មានសេចក្តីដូចគ្នា ។ ស្រុកសូន្យ, ក្រុងសូន្យ, ផ្ទះសូន្យនោះគឺសូន្យ
ស្ងាត់តែមនុស្ស ដោយមិនមានមនុស្សនៅក្នុងស្រុក, ក្នុងក្រុង, ក្នុង
ផ្ទះប៉ុណ្ណោះ តុំមែនសូន្យស្រុក សូន្យក្រុង សូន្យផ្ទះ ដោយគ្មាន

ស្រុក គ្មានទីក្រុង គ្មានផ្ទះនោះឡើយ ។

ស្រុកសូន្យ, ទីក្រុងសូន្យ, ផ្ទះសូន្យនោះ គឺស្រុកមាននៅ, ទីក្រុងមាននៅ, ផ្ទះមាននៅដោយពិត ប៉ុន្តែមិនមានមនុស្សនៅ សេចក្តីនេះយ៉ាងណា ទិព្វានមាននៅជាទ្រុកដដូចជាសស្ត្រតែមួយគ្រាន់តែសូន្យស្ងាត់ចាកជាតិជរា ព្យាធិ មរណៈ ប៉ុណ្ណោះគឺយ៉ាងនោះដែរ ។

សំឌួងនៃពាក្យបំភាំទិព្វានត្រមទាំងអធិប្បាយ

ពាក្យថា«ឯព្វាន, មកអំពី ឯ ឧបសគ្គ ប្រែថា «មិនមាន; ចេញ, ឆ៊ាចេញ» ទីឆ ជាតុ ប្រែថា «ចាក់ដោត,ឈឺចាប់,ក្តៅកេលពល រលត់, រំលត់" ទីធ យុ បច្ច័យ; យកឯជាពា យកឯ មកផ្សំទីធ ពាជាឯព្វា យកយុ បច្ច័យជាអនសម្រេចរួបទៅជាឯព្វាន មានសេចក្តីដូចតទៅនេះ

១ ប្រែថា មិនមានគ្រឿងចាក់ដោត ។ ពាក្យថា ចាក់ដោត បានដល់កូនសរគោលគឺតំលៃសមានពគៈ ទោសៈ ជាដើម ដែលគាចចាក់ដោតសត្វសត្វ ឲ្យបានខ្លួលទុក្ខវេទនាក្តីគតវដ្តសង្សារកទីបំផុតបានដោយក្រ ។

២- ប្រែថា មានការឈឺចាប់ដកចេញហើយ ។ ពាក្យថា «ឈឺចាប់» បានដល់សេចក្តីទុក្ខតាំងពួង ដែលកើតឡើងព្រោះជាតិ ជរា ព្យាធិ មរណៈ ។ ដែលហៅថា «ទិព្វាន» បានដល់ការដកចេញបានខ្លួវសេចក្តីទុក្ខតាំងពួងអស់ហើយ ឬថាជាគ្រឿងបញ្ចប់ជាតិ ជរា

ត្បាធ មរណៈអស់ហើយ ។

៣- ប្រែថា មានកាំដៅរលត់ហើយ ។ ពាក្យថា «កំដៅ» ចានដល់សេចក្តីក្តៅ ពេលកាល អន្លះអន្លែនដោយភ្លើងកិលេសនឹងភ្លើងទុក្ខ ។ ដែលហៅថា «និព្វាន» ចានសេចក្តីថា មានភ្លើងកិលេសនឹងភ្លើងទុក្ខរលត់អស់ហើយ ។

៤- ប្រែថា មិនមានគ្រឿងវិលវល់ ។ ពាក្យថា «គ្រឿងវិលវល់» ចានដល់បដិសន្ធិវិញ្ញាណ ដែលអាចគ្រាច់ឆ្អែតចាប់កំណើតទៅកន្លែងផ្សេងៗដោយអំណាចវដ្ត: (គ្រឿងវិល) ៣ យ៉ាងគឺ កិលេសវដ្ត: ការវិលទៅដោយអំណាចកិលេស ១ កម្មវដ្ត: ការវិលទៅដោយអំណាចកម្ម ១ វិបាកវដ្ត: ការវិលទៅដោយអំណាចវិបាក ១ ។ ដែលហៅថា "និព្វាន" ចានដល់ការអស់គ្រឿងវិលវល់ទៅកន្លែងលោកហើយ គឺថាជាគ្រឿងបញ្ចប់ដំណើរ ដែលតែងគ្រាច់ឆ្អែត តែងអន្ទោលទៅកន្លែងតទ ។ ដែលហៅថា និព្វាននោះ ដោយមានកិច្ចការដើម្បីខ្លួន ឬ ដើម្បីលោកបច់ស្រេចហើយ ។

៥- ប្រែថា មិនមានព្រៃគោលគឺកិលេស ។ ពាក្យថា «ព្រៃ» ក្នុងពីរនេះ សំដៅយកព្រៃញាតសញ្ញាតគោលគឺកិលេសមានរាគៈទោសៈមោហៈជាដើម ដែលហៅថា «និព្វាន» នោះ គឺជាគុណជាតដ៏បរិសុទ្ធចេញផុតចាកព្រៃស្មាប់ គឺកិលេសអស់ហើយ ។

ព្រះអភិធម្មបិដក

កម្ពីរព្រះកថាវត្ថុ

(ភាគ)

ណោក ចូ-ប៊ូ ប្រែរៀបរៀង

ពាណិជទាំង៥ឮយ៉ាងដល់ទូរមរណភ័យ ជាអាហារនៃត្រីកន្លឹមមហាសមុទ្រ ដ្ឋលកាំ តមោត្វា បុរសម្នាក់ជាពាណិជមកក្នុងនាវានោះ លុះសំ-ពៅផ្ទុយហើយបានភ្ជាមួយបន្ទះ ទំប្រើនតោងភ្ជាវែលធ្វងទៅដល់កំពង់ឈ្មោះសុបប្បារកៈ ។ មនុស្សទាំង៥ឮយបានឃើញបុរសនោះអាក្រាតគ្មានសំពត់ចំពោះជាំងកាយ ព្រោះសំពត់ស្ទៀកដណ្តប់រលួតទៅតាមទឹកសមុទ្រអស់ ។ បុរសនោះកេអ្វីស្ទៀកពុំបាន កំយកមែកឈើស្ងួតមកចងក្រងធ្វើជាសំពត់ស្ទៀកដណ្តប់ ហើយទៅដល់ពេលទេព្រក្សរើសបានអំបែងមួយបំហៀងកាន់ដើរសូមទានបាយទឹក អ្នកកំពង់សុបប្បារកៈអស្ចារ្យ ។ មនុស្សទាំងពួងបានឃើញបុរសនេះ កំនាំគ្នាសរសើរថាជាព្រះអរហន្ត សោមនស្សជ្រះថ្លាឲ្យបាយបបរនិងចំណីចំណុកផ្សេង ។ ដោយសទ្ធា ហើយយកសំពត់ស្ទៀកដណ្តប់មកឲ្យបុរសនោះទៀតផង ។

ចំណែកបុរសនោះគិតតែក្នុងចិត្តថា គាត្មាអញបានលាភសក្ការៈទាំងអម្បាលនេះ មកពីអញអាក្រាតខ្លួនទេ ឥតស្ទៀកសំពត់ពាក់អាវ

បើអញស្វែកពាក់សំពត់អាវ លាកសក្ការៈទាំងពួងមុខជាលែងកើតមានដល់អញទៀត គិតដូច្នេះហើយ មិនត្រមះខ្លួលយកសំពត់ទាំងពីរដែលគេយកមកឲ្យ ស្វែកតែស្វឹកឈើមែកឈើដើរគ្រាច់គ្រាចរ ។ មនុស្សទាំងឡាយឃើញអាការសន្តោសនៃបុរសនោះ ក៏នាំគ្នាសរសើរថាជាព្រះអរហន្តមួយអង្គ ។ បុរសនោះគិតថា លោកេ អរហាន្តោ ជនទាំងឡាយពួកណាមួយជាព្រះអរហន្តក្តី ជាអ្នកប្រតិបត្តិដើម្បីនឹងឲ្យបានដល់ព្រះអរហន្តក្តី អាត្មាអញនេះ ក៏ពាប់ចូលកន្ងែជនពួកនោះបានម្នាក់ដែរ មិនត្រូវអែញសង្ស័យទៀតឡើយ ។

អថស្ស សាលោហិតា ភ្រាតោ មានព្រហ្មមួយអង្គ ជាបុព្វណសាលោហិតមកពីបុព្វជាតិ ចូលមកដល់សំណាក់នៃតាហិយបុរសហើយ ទើបមានវាចាថា តាហិយ ! អ្នកចូរកុំសំគាល់ខ្លួនដូច្នេះឡើយ ខ្លួនអ្នកមិនមែនជាព្រះអរហន្តទេ មិនមែនជាអ្នកប្រតិបត្តិដើម្បីនឹងឲ្យបានសម្រេចអរហត្តទេ ។

តំ ឯស្សា ចំណែកតាហិយបុរសនោះ លុះក្រឡេកមើលទៅឃើញព្រហ្មស្ថិតនៅឯអាកាស ស្រែកច្រាប់មកខ្លួនដូច្នេះហើយក៏សួរថា អ្នកណាជាព្រះអរហន្ត ហើយអ្នកនោះនៅឯណា ?

កាលតាហិយបុរសបានដឹងសេចក្តីច្បាស់លាស់អំពីព្រហ្មនោះហើយ

កំប្រញាប់ទៅឯនគរសាវត្ថី ឃាតដួចនឹងព្រះបរមសាស្តាកំពុងស្តេចចំណូ-
ឆាត កើតចិត្តជ្រះថ្លា បន្ទន់ខ្លួនចូលទៅជិតហើយចាប់ទុបកត្រះបាទក្រាប
ទូលថា បពិត្រព្រះបរមគ្រូខ្ញុំសីលាទិគុណគួរឲ្យអស្ចារ្យ ! សូមព្រះអង្គ
ទ្រង់ព្រះមេត្តាប្រោសសំដែងធម្មទេសនា ដើម្បីប្រយោជន៍ ទឹងសេចក្តី
សុខដល់ខ្ញុំព្រះអង្គអស់កាលដ៏យូរអង្វែងទៅ ។

សម្តេចព្រះបរមសាស្តាកំទ្រង់ត្រាស់ទេសនានៅកណ្តាលផ្លូវ ។
សោ ឆម្មំ សុត្វា កាលពាហិយបុរសកំពុងតាំងចិត្តស្តាប់ហើយគិត
ពិចារណាទៅតាមក្រសែព្រះធម្មទេសនា ក៏បានសម្រេចអរហត្តផល
ហើយក្រាបទូលសូមបព្វជ្ជាឧបសម្បទា ព្រះពុទ្ធអង្គទ្រង់ត្រាស់អនុញ្ញាតឲ្យ
ពាហិយបុរសទៅកេបាត្រនឹងត្រៃចីវរ កាលពាហិយបុរសកំពុងដើរត្រាច់
រង្គាត់ស្វែងកេបាត្រនឹងត្រៃចីវរតាមផ្លូវ ស្រាប់តែនាងយក្ខិនីម្នាក់ក្រឡា
ខ្លួនជាមេគោមកបុះនឹងស្នែងត្រូវចំកណ្តាលដើមទ្រូងនៃពាហិយបុរសក្សោយ
ជីវិតហើយចាំនិព្វានទៅកន្លែងនោះឯង ។

អ្នកប្រាជ្ញគប្បីជ្រាបថា ពាហិយបុរសេនេះ កំបានសម្រេចអរហត្ត
ភូមិកាលខ្លួនទៅជាគ្រហស្ថដែរ ចាត់ចូលក្នុងគណៈតិរ្ថិអាជីវកថា ដូច
រឿងសច្ចន្តរមកនេះ ឯង ។

រឿងពាហិយបុរសចប់ប៉ុណ្ណេះ ។

រឿងព្រះបាទសុទ្ធោទនមហារាជ

តីហិ អរហា ហោតិ តោ បន អរហា សុទ្ធោ-
ទនោ មហារាជា អរហាតិ សោហិ អជ្ឈាសយំ វសេន្តោ
សោតាបត្តិផលំ បត្តោ បច្ឆា ធម្មទេសនំ សុត្វា អ-
រហត្តំ បត្វា បរិនិព្វាយីតិ ។

ក៏ព្រះនេះនឹងបានវិសជ្ជនាតីហិអរហាតថាគតៗ ដោយតាំងជាពាក្យ
សកវាទី នឹងបរវាទីថា ៖

សកវាទី-បុគ្គលជាគ្រហស្ថ បានសម្រេចអរហត្តហើយ និព្វាន
នោះ មានខ្លះដែរឬទេ ?

បរវាទី-មានខ្លះដែរ គឺព្រះបាទសុទ្ធោទនមហារាជ ជាព្រះពាហិរកត
ក្នុងក្រុងកបិលវត្ថុ បានសម្រេចអរហត្តផល ហើយចូលកាន់ព្រះ
និព្វាន ។

សកវាទី-ព្រះបាទសុទ្ធោទនបរមក្សត្រប្រកបព្រមដោយបញ្ចកាម-
គុណ បើដូច្នោះ ព្រះអរហន្តបុគ្គលគ្រែកអរតែក្នុងបញ្ចកាមគុណដែរឬ ?

បរវាទី-អ្នកកុំនិយាយដូច្នោះ ព្រះបាទសុទ្ធោទនះនោះ តាំងអំពី
បានសម្រេចអរហត្តផល កំពុងតែអាល័យក្នុងរាជសម្បត្តិជាច់អស់រលីង
ហើយ មិនបានគ្រែកអរក្នុងបញ្ចកាមគុណទេ ទើបនាំរឿងនោះមក

ពណ៌នាដោយសង្ខេប ដូចតទៅនេះ ៖

អថ ខោ ភគវា កន្តកាលដែលសម្តេចព្រះមានព្រះភាគស្តេចចូលទៅគាស្រ័យនៅក្នុងកុដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងសាវត្ថី ព្រះបាទស្រីសុទ្ធោទនមហាក្ស ទ្រង់ព្រះកេតាតយ៉ាងច្បាស់ ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបដោយព្រះញាណហើយ ស្តេចយាងទៅសួរដោយព្រះវាចាស្រួលសង្ស្រួលប្រុំយអង្គជាបរាំរ ធ្វើឥទ្ធិបាដិហារ្យស្តេចទៅគាន់ព្រះនគរកបិលភស្តុដោយអាកាស លុះដល់ព្រះនគរកបិលភស្តុហើយ កំពុះចាកវេហាស៍ គាន់ភូមិភាគប្រថព្ធ ស្តេចចូលទៅក្នុងព្រះពាធនិវេសន៍ ចូលទៅដល់ក្រឡាព្រះបន្ទំនៃសម្តេចព្រះបិតា គង់លើបវរបញ្ញត្តាសនៈ ទាងព្រះសិរនៃសម្តេចព្រះពុទ្ធបិតា ហើយត្រាស់សួរព្រះអាការប្រឈួន ។

តំ សុត្វា សម្តេចព្រះពុទ្ធបិតាបានទ្រង់ព្រះសណ្តាប់ ទើបក្រាបទូលថា ខ្ញុំព្រះអង្គនេះមិនអាចនឹងអត់ធន់បានទេ ហួសកំឡាំងដែលនឹងគង់ជីវិតនៅបាន ។ សម្តេចព្រះអនន្តញ្ញាណត្រាស់ថា មហាបពិត្រ! ព្រះអង្គចូរកុំញាំងសេចក្តីបរិតក្កឲ្យតើតខ្លាំងពេក ត្រាស់ដូច្នេះហើយ ទើបលូកព្រះហស្តទាងស្តាំស្ទាបព្រះសិរនៃសម្តេចព្រះពុទ្ធបិតា ធ្វើនូវព្រះពុទ្ធាធិដ្ឋានថា តថាគតបានធ្វើកតញ្ញុតាសាងព្រះបារមីមកបួនអសង្ខេយ្យកប្បៃមួយសែនកប្ប ដោយប្រាថ្នានឹងប្រោសសព្វសត្វឲ្យរួចផុត

ពីសង្ឃវេដ្ឋ ព្រះពោតាពាធខាងព្រះសិរ នៃសម្តេចព្រះបិតា ចូរ
អន្តរធានទៅ ។ ក្នុងទណ្ឌនោះ ព្រះពោតក្នុងព្រះសិរ នៃព្រះបាទ
សុទ្ធោទនមហារាជក៏អន្តរធានបាត់អស់ទៅ ដូចជារាត្រីកន្លងផុតជាតិ
រមៀលភ្លាត់ទៅដូច្នោះ ។

លំដាប់នោះ សម្តេចព្រះបាទសុទ្ធោទនមហារាជ ទើបស្តេច
ឡើងការចាកព្រះទៃនសិរីសេយ្យាសន៍ លើកព្រះករអង្គវាសម្តេចព្រះបរម
ត្រៃលោកនាថសាស្តាចារ្យ ក្រាបទូលនូវគាថានៃទុក្ខវេទនាថា ខ្ញុំព្រះអង្គ
បានស្រែកស្រាន្តចាកពោតាពាធហើយ សម្តេចព្រះបរមត្រៃលោកនាថ
ទ្រង់តិចារណាហើយជ្រាបហ្ន សម្តេចព្រះតុច្ចបិតានឹងបានសម្រេចអរ-
ហត្តផលហើយនឹងបានតង់ព្រះជន្មទៅ ។ កន្លងតាំងថ្ងៃនេះទៅបានតែ ៧ ថ្ងៃ
ទៀតប៉ុណ្ណោះទេ លុះទ្រង់ជ្រាបយ៉ាងនេះហើយ ទើបប្រោសប្រទាន
ព្រះធម្មទេសនាអស់ ៧ ថ្ងៃ តាំងពីវ័នទីពត្រី ជានិច្ចកាលមិនដាច់ សំដែង
ព្រះត្រៃលក្ខណកថា មានអនិច្ចលក្ខណៈជាដើម ហើយត្រាស់ទេសនា
ព្រះអរិយសច្ចតាំងបួនប្រការ ។ សម្តេចព្រះតុច្ចជនកាធិបតីបានទ្រង់ព្រះ
សណ្តាប់ កំបានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាញាណ
ក្នុងថ្ងៃជាគំរប់ ៧ ទើបពិចារណាមើលនូវព្រះជន្មាយុសង្ខារ ទ្រង់ជ្រាបថា
នឹងមិនបានស្ថិតនៅយូរ ក៏ក្រាបទូលសូមអនុញ្ញាតនឹងបរិនិព្វាន ។ សម្តេច
ព្រះទ្រង់ញាណត្រាស់អនុញ្ញាតថា ចូរទ្រង់មើលកាលដ៏ឧត្តមគួរចុះ ហើយ

សម្តេចព្រះជនកាធិបតីលើកព្រះកប្រណម្យសូមទាមទោសថា សូមព្រះអង្គជាទីពឹងរបស់សត្វលោកអត់ទោសដែលខ្ញុំព្រះអង្គភ្លាំងភ្លាត់ប្រមាទតាំងពីកាលមុន ។ រួចមកហើយនោះឲ្យដល់ខ្ញុំព្រះអង្គផង ។ ព្រះមានព្រះភាគទ្រង់អត់ទោសថ្វាយហើយ ព្រះបាទស្រីសុខ្ញាទេមហាពជគំទំរេតព្រះអង្គចុះទៅលើព្រះខែនបវរសេយ្យាសន៍ រលត់ព្រះអស្សាសៈនិងបស្សាសៈអស់ព្រះជន្មាយុសង្ខារស្តេចចូលកាន់ព្រះនិព្វានក្នុងវេលានោះ ។

សម្តេចព្រះទេសតលញ្ញាណមានធម្មសង្វេគត្រាស់សំដែងព្រះធម្មទេសនាមានអរិច្ចលក្ខណៈជាដើម ចប់ហើយទ្រង់ត្រាស់ទីឆ្លើយព្រះអរិយកស្សបមហាថេរដែលជាអ្នកចាស់ជាងព្រះអរិយសង្ឃទាំងពួងថា ម្នាលកស្សប ! តថាគតនឹងធ្វើឈាបនកិច្ចសពព្រះបិតា អ្នកចូរទៅពិចារណារកមើលទីកន្លែងឲ្យសមគួរនឹងធ្វើឈាបនកិច្ចព្រះសរីរៈនៃព្រះបរមបិតា ។

ព្រះមហាកស្សបត្តេរទទួលព្រះពុទ្ធដីកាហើយ មានតិក្ខុសង្ឃជាបរិវារ ព្រមទាំងសក្យជនីឯកជបរិវារជាច្រើន ទៅឯទីឈាបនកិច្ចហើយធ្វើដើងថ្កល ។

អមរតណា ក្នុងខណៈនោះ ពួកអមរទេវតាក្នុងមុខចក្រវាឡមានអគ្គិអមរិន្ទ្រទេវរាជជាប្រធាន មកសមោសសន្និបាតប្រជុំគ្នានាំយកកុងាគារបុស្សកប្រដាប់ដោយកំពូលប្រាំយ ព្រមទាំងគ្រឿងប្រដាប់ព្រះសរីរសពផ្សេង ។ នឹងគ្រឿងក្រអូបទិព្វសំគាងផ្សេង ។ មកថ្វាយ ។

ចំណែកព្រះមហាកស្សបត្ថេរ កាលធ្វើចិត្តការដើរជុំវិញរួចស្រេច
ហើយ ត្រឡប់មកក្រាបថ្វាយសម្តេចព្រះបរមសាស្តា ។ កំលោកទត្តមង្គលភោគ្គម នៃសម្តេចព្រះស្រីសុគន្ធមហាពុទ្ធចិតាហើយ ជុំវិញសំអាតដោយទឹកឆាកសុគន្ធរសវារី ព្រះធម្មសេនាបតីសារីបុត្រជាំជាព្រះអគ្គសាវកខាងស្តាំ ក៏ជួយស្រោចស្រង់ព្រះទឹកឆាកលើព្រះកាយនៃសម្តេចព្រះបរមជនកាធិបតី ។

ខណៈនោះ សម្តេចព្រះជិនស្រីទ្រង់ត្រាស់ទៅកាន់ភិក្ខុសង្ឃទាំងពួងថា អ្នកចូរឃើញនូវព្រះពុទ្ធចិតាបស់តថាគតចុះ ត្រាស់ដូច្នេះហើយទើបមានព្រះពុទ្ធដីកាទៅព្រះសារីបុត្រថា ម្នាលសារីបុត្រ ! បុគ្គលណាប្រព្រឹត្តសុចរិតធម៌ ហើយមានចិត្តជ្រះថ្លាខ្ជិលចំពោះព្រះនិព្វាន បុគ្គលនោះចូរប្រតិបត្តិបូជាមាតាចុះ ត្រាស់រួចហើយទ្រង់លើកសពព្រះបិតាជាក់កំណត់នមញ្ជុស តិចិតកែវហើយដង្ហែទៅឯឈាបនដ្ឋាន ដំកល់កន្លែកុដារគារបុស្សក សម្តេចអមរន្ទ្រធ្វើទ្រង់ភ្លៀងព្រះបរមសព ហើយយកកែវជាតិវេសម្ភយដួងមកបម្រុងទុកថ្វាយព្រះភ្លើង ។ ព្រះបរមសាស្តាឃាត់ថា ព្រះអង្គកុំអាលអុជអគ្គី ទុកឲ្យតថាគតអុជមុន ព្រះឥន្ទ្រកំថ្វាយដួងកែវមណីទៅព្រះសាស្តា ។ ទ្រង់អុជអគ្គីធ្វើឈាបនកិច្ច ។ លំដាប់នោះ ទេវនិករមានសម្តេចអមរន្ទ្រជាដើម ទើបរមក្សត្រសក្យពង្ស, មនុស្សទាំងឡាយ

កំអុជអគ្គីជាលំដាប់ ។

អ្នកប្រាជ្ញទាំងឡាយគប្បីធ្វើមនសិការកំណត់ខុសកុងចិត្តថា សម្តេចព្រះបាទស្រីសុត្ថោទនមហារាជ ជាព្រះតុន្ធបិតា បានសម្រេចអរហត្តផលហើយអស់ព្រះជន្មចូលកាន់និព្វានដោយកេរជាគ្រហស្ថ កំតួរនឹងបានចូលកងគតិហិអរហាកថានេះ ។

រឿងព្រះបាទសុត្ថោទនមហារាជ ចប់ប៉ុណ្ណេះ ។

គតិហិអរហាកថា ចប់ប៉ុណ្ណេះ ។

មធុរសវិហិណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម រៀបរៀងរៀង

(តទៅ)

គ្រានោះ មានពួកមនុស្សដែលនៅក្នុងរះមួយផ្សែងដោយវៀរភ្លាក ឃើញពាណិជនោះស្រែកខឹកខ្ជាំង កំមានសេចក្តីករុណាអណិតពន់ពេកហើយនិយាយប្រាប់ថា នែពាណិជ! អ្នកត្រូវតែរញ្ជើញមកខាងនេះជាមួយនឹងមានទឹកបន្តិចក្នុងអណ្តូងទឹកតូចនេះ ចូរអ្នកទៅមើលឲ្យឃើញច្បាស់ហើយផឹកចុះ ។

ឯពាណិជក៏បានចុះទៅក្នុងអណ្តូងនោះហើយ ដងទឹកផឹកក្នុងខ្លះនោះឯង ។

ឯទឹកនោះ ក៏ប្រែត្រឡប់ទៅជាទឹកមានឧជារសផ្អែម ប្រាកដជាស្មើដោយទឹកផ្ទៃច័ន្ទដោយពិត ។

ឯពុទ្ធវិម្ហពាណិជនោះសោត កាលបើបានដឹងទឹកដ៏មានឧជារសនោះហើយក៏គិតរំពឹងពិចារណាយ៉ាងនេះថា : ឧហ្ន៎! នេះជាផលានិសង្សហូរដួនមកពុំដាច់ នៃទឹកច័ន្ទដែលអាត្មាអញបានថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ព្រមទាំងកិត្តុសង្ឃក្នុងកាលនោះ, ឥឡូវនេះបានឲ្យផលសម្រេចជាទិដ្ឋធម្មកន្លងមកក្នុងថ្ងៃនេះឯង ។ លុះពាណិជគិតយ៉ាងនេះហើយ កំមានចិត្ត

សោមនស្សជ្រះថ្លា ចាន់ទៀងពីអណ្តូងត្រឡប់មកកាន់រនេះវិញចាន ត្រូវ
មើលតាជន់តាងទឹកចាំងអស់កន្លះរនេះរចស់ខ្លួន ។

ឯការជន់ចាំងនោះសឹងពេញបាប្តូណ៍ដោយទឹកច្នូដ៏មានឧត្តារសផ្អែម
តើតប្រាកដក្នុងកាលនោះឯង ។

លុះឯពាណិជនោះបានឃើញទឹកដ៏ជាចិត្យមានឧត្តារសពេញការជន់
ចាំងអស់ ពុំបានស្រេកស្រុតទៀ សឹងនៅពេញដដែល កំកើតជ័ត
ផ្សព្វផ្សាយសព្វកន្លែងការចាំងអស់ ហើយគាត់ឃោសនាប្រាប់មនុស្សចាំង
ឡាយថា: ម្នែអ្នកចាំងឡាយ! ចូរអ្នកចាំងអស់គ្នាផឹកទឹកចិត្យនេះ ឲ្យ
ឆ្អែតចរិប្តូណ៍គ្រប់គ្នាតាមត្រូវការចុះ ។

ពួកមនុស្សចាំងនោះ ឮនស្តាប់ពាក្យឃោសនាហើយក៏មកជួបជុំ
មួយរំពេច ចានឃើញទឹកដ៏ជាចិត្យកើតប្រាកដដូច្នោះហើយ ក៏មានចិត្ត
ស្ងើចតន់ពេក ហើយចប្តូលគ្នាដងទឹកនោះផឹកតាមប្រាថ្នាពុំចេះអស់សឹង
មានឧត្តារសផ្អែមឆ្ងាញ់ជាងទឹកចាំងតួងក្នុងលោកនេះ ឥតមានរសទឹកដទៃ
ប្រៀបផ្ទឹមចានឡើយ ។

ចំណែកឯពាណិជក៏ចានប្រតាសសំដែងសារសើរឧត្តមពុទ្ធគុណក្នុង
កណ្តាលទីប្រជុំនៃមនុស្សចាំងឡាយនេះ ហើយសូត្រជាបទគាថាថា:

ឧស្សវេនំ តវត្តា កោ អាទុភាវំ មហោសិនោ

អថិន្ទនិយមច្ចេរំ សន្ទិដ្ឋកមកាលិកំ . . .

ម្នាលអ្នកគាំនឹងព្យាយដ៏ចំរើនអើយ! ចូរអ្នករំពឹងមើលនូវអានុភាពនៃទានដ៏អស្ចារ្យដែលបណ្ដិតពុំបានស្មានទុកមុន ជាទានឲ្យផលទាន់ក្នែកពុំរង់ចាំកាល ដែលខ្ញុំថ្វាយហើយចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គស្បែនរកនូវគុណដ៏ប្រសើរមានសីលគុណជាដើមដោយពិត ។

បសន្នមានសា ពុទ្ធេ ទិន្នំ ទានិយកំ មយា
វិបច្ចតិ ឥទានេវ តំ ទានំ មុទ្ធិកមហសា ។

ទានប្រកបដោយទឹកចិត្តឯណា ដែលខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយហើយចំពោះព្រះពុទ្ធជាម្ចាស់, ទាននោះមានទឹកច័ន្ទជាទីត្រេកអរមិនឲ្យផលដ៏ជាក់ស្តែងក្នុងបច្ចុប្បន្ននេះឯង ។

ឯវន្តំ សុទ្ធិន្តំ ភ សីតលំ មធុរេនកំ
ទិព្វទានំ នេកវិធំ ជាតអព្ភុតមក្ខយំ
សីលវន្តេសុ តោ ជាម ន ទានេយ្យវិចក្ខណោ
ឥធ លោកេ បរត្ថេសុ សុខំ ទានមុត្តមំ ។

ម្យ៉ាងទៀតទឹកផ្អែមត្រជាក់មានឧជារសដ៏ស្អាត បើដូចទឹកដ៏ជាទិព្យរបស់ទេវតាពាំនឹងព្យាយមិនចេះអស់ទៅ គួរជាទីអស្ចារ្យខ្លាំង (ដល់ខ្ញុំ) អ្នកជ្រាជ្ញណាមិនដែលឲ្យទានដល់បុគ្គលអ្នកមានសីលពាំនឹងព្យាយ ក៏ត្រូវតែ

ទ្បាននេះដោយពិត ។ ឯទានដ៏ឧត្តម ដែលបុគ្គលបានឲ្យហើយ រមែងឲ្យនូវសេចក្តីសុខក្នុងលោកនេះនឹងក្នុងបរលោកតុំបានឡើយ ។

យទិច្ឆតំ គហោត្វាន បិវិត្តា មធុកេឧកំ
កាឧជានិ ច ឫវត្វា យន្តំ សព្ពេ យទិច្ឆតំ ។

មនុស្សទាំងពួងដងយកទឹកផ្អែម ហើយផឹកឲ្យឆ្អែតគួរតាមប្រាថ្នាផង ដងយកដាក់ក្នុងភាជន៍ឲ្យពេញតាមប្រាថ្នាផង ហើយត្រាច់ទៅចុះ ។

លុះព្រះមែ្លាងណាជបានពោលគាថាយ៉ាងនេះហើយ កំបញ្ញាមនុស្សនឹងគោចាំងឡាយ ឲ្យក្រេបផឹកទឹកចន្លុះពិត្យដ៏មានឧជារសផ្អែមពីសាចាំងអស់គ្នា ក្នុងកាលនោះឯង ។

ចំណែកពួកមនុស្សក្តី គោចាំងឡាយក្តី កំបានក្រេបផឹកទឹកផ្អែមជាបដល់ឆ្អែតគ្រប់ៗគ្នា ឯទឹកចន្លុះក្នុងភាជន៍នោះក៏ពុំចេះអស់ សឹងនៅពេញភាជន៍វិញដដែល ដោយបុញ្ញឫទ្ធិនោះគួរជាទីអស្ចារ្យពន់ពេក ។

លុះរាប់តពីនោះ ពាណិជក៏បានប្រកបជំនួញដោយឈ្មួញរេះចាំងឡាយ តែឆ្ងាច់ទៅកាន់ទន្លេតូចធំក្នុងដងផ្លូវ ចាំងអស់ លក់ទំនិញតាមធម្មតា បានទៅដល់ទន្លេរកដ្រីះហើយគិតថា អាត្មាអញនឹងចូលទៅទេវស្ថានថ្វាយបង្គំព្រះមានព្រះភាគ ហើយសន្សឹមធ្វើដំណើរចេញទៅខែបគួរ, លុះពាណិជគិតយ៉ាងនេះហើយ ក៏ចូលទៅកាន់វិហារវៀរ្បុន

ចានថ្វាយបង្គំព្រះសាស្តាចារ្យ ហើយអង្គុយក្នុងទីសមគួរ ។

ចំណែកឯព្រះបរមសាស្តាចារ្យ ព្រះអង្គបានធ្វើបដិសណ្ឋារៈស្រស់ស្រាយជាមួយនឹងពុទ្ធវិម្ហាណាជនោះឯង ។

ឯពាណិជ កំបានយកសេចក្តីដែលជាអស្ចារ្យនោះ ក្រាបបង្គំទូលចំពោះព្រះមានបុណ្យជាម្ចាស់ ដោយសេចក្តីសព្វគ្រប់ដូច្នេះថា: បពិត្រព្រះមានជាតដ៏ចំរើន! ខ្ញុំព្រះអង្គបានឃើញថាជាវិយ៉ោបស់ព្រះអង្គ គួរជាទីអស្ចារ្យ អត់ទ្រាំទុកពុំបាន ទើបចូលមកកាន់សំណាក់ព្រះអង្គនេះ ឯសេចក្តីអស្ចារ្យនោះ កើតច្រោកដូចខ្ញុំព្រះអង្គក្រាបបង្គំទូលហើយយ៉ាងនេះពិត សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះមានព្រះភាគបានទ្រង់ព្រះសណ្តាប់ហើយ កំទ្រង់សំដែងព្រះធម៌វិសេសទេសនា ជាសណ្តាប់ដល់ពាណិជនោះឯង ។

លុះពាណិជនោះបានស្តាប់ព្រះធម៌ទេសនាហើយ កំនិមន្តព្រះសាស្តាជាម្ចាស់ ព្រមទាំងព្រះភិក្ខុសង្ឃដើម្បីទទួលភត្តនៅក្នុងថ្ងៃស្អែក កាលបើដល់ពេលថ្វាយភត្តហើយ ពាណិជក៏ចាត់ចែងមហាទានថ្វាយដល់ព្រះភិក្ខុសង្ឃ មានអង្គព្រះសម្ចាស់ពុទ្ធជាប្រធាន លុះព្រះសម្ពុទ្ធបានឆ្លើកភត្តកិច្ចរួចស្រេចហើយ ពាណិជក៏ទទួលបរិវេចញ្ជាទៅកាន់ផ្ទះខ្លួនវិញហោង ។

ចាប់ដើមតាំងពីថ្ងៃនោះមក ពុទ្ធបរិស័ទណាមិនតែងចាត់ចែងធ្វើបុណ្យ
ច្រើនប្រការ មានឲ្យទានជាដើមដរាបដល់អស់ជីវិត ក៏បានទៅចុតិកើត
ក្នុងវិមានមាសជាទិព្យ មានកំពស់ប្រមាណ ១២យោជន៍ ក្នុងស្ថានទេវ-
លោក មានស្រីទេពអប្សរចោមរោមជាបរិវារ ប្រកបព្រមដោយទេវសិរីដ៏
ប្រសើរ ទេវបុត្តនោះតែងសោយទិព្វសម្បត្តិ ជាសុខក្សេមក្សាន្តក្នុង
ស្ថានសួគ៌នោះឯង ។

ដោយអានុភាពបុញ្ញកម្មនោះ លើឯមានភាជន៍ទិព្វសម្រេចដោយកែវ
៧ ប្រការ ដ៏ពេញដោយទឹកចន្ទជាទិព្វដ៏មានរុជារសដ៏វិសេស គួរជាទី
អស្ចារ្យក្រៃលែង ។ ឯទេវតាទាំងឡាយបានឆក់ទឹកចន្ទទិព្វនោះហើយ
កំសេនវិល្យធច្រៀងកំប្រុតតូរ្យតន្ត្រី ចំរើនទេវបុត្តនោះជាប្រក្រតី ។

ព្រោះហេតុដូចនេះ បានជាព្រះអរហន្តទាំងឡាយ ពោលជាមគ
គាថាដូចនេះថា:

ន វិបុលជិនសាវំ ញាណមាជោ ជនេវំ
លភតិ វិបុលភោគំ តោយមត្តស្សុ ជាជា
វិធិតកុណាកណា ភោគីសុ វត្ថុសុ តុម្ហ
លភថ ឯលុ វិសេសំ សីលវន្តេសុ ជាជា
ជនជាសប្បុរសេ សូម្បីមិនបានដឹងច្បាស់នូវផលានិសង្ស មាន

ប្រមាណច្រើនដ៏ជាខ្លឹមសារក្នុងសាសនានៃព្រះជិនស្រី តង់អាចបានទទួលភោគសម្បត្តិជាទិព្យ មានប្រមាណច្រើនដោយហេតុដែលបានថ្វាយទឹកច័ន្ទមានប្រមាណតិចប៉ុណ្ណោះដែរ ព្រោះហេតុនោះអ្នកចាំង់ឲ្យាយសុទ្ធតែប្រទ្រង់គុណដែលខ្លួនបានដឹងហើយ គួរតែថ្វាយទឹកបានជាគ្រឿងកេសជ្ជៈចំពោះវត្ថុចាំង់បំតីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដែនកើតភោគសម្បត្តិដោយពិត ។ សូមអ្នកចាំង់ឲ្យាយបានសម្រេចនូវសម្បត្តិដ៏វិសេស ព្រោះបានឲ្យទានដល់បុគ្គលដែលមានសីលប៉ុណ្ណោះឯង ។

សំដែងរឿងនិទាន ពុទ្ធវម្មាណិជជាតំរប់ ៤ កន្លះគ្គទីមួយ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

រូបនេរីវត្ថុកថា

សំដែងរឿងនិទាននាងរូបនេរីតទៅទៀត ដោយបទបាលីថា:

អតីតេ កិរ វិបស្សិស្ស ភគវតោ កាលេ ដូច្នេះជាដើម

អធិប្បាយថា: កិរ បានឮរឿង ។ មក ក្នុងកាលព្រះមានព្រះភាគព្រះនាមវិបស្សី ។ កន្លងទៅយូរហើយក្នុងឥដ្ឋានីនោះមាននាងគាមភរិកាម្នាក់បានឆើរទៅកាន់វិហារ កំបានឃើញកំពុងយកគ្គមានជម្ម ហើយនង់មានសទ្ធាទញាប់ញ័រគណិតតិកនោះបានចូលទៅជិតថ្វាយបង្គំសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ! តើជម្មីអ្វីបៀតបៀន

សីរ:លោកម្ចាស់ឲ្យឈឺចាប់ខ្នេះ ?

តំក្នុនោះតបថា: ម្នាលនាង ! អាតាធបុកសៀតកងថ្ងៃដំណើរក្បែរភ្លៀតបៀនអាត្មាភាព ។ ឯនាងតាមការនោះ លុះបានស្តាប់ហើយ ក៏បពាវណោទិមន្តតំក្នុនោះថា: បពិត្រលោកម្ចាស់ដ៏ចំរើន ! បើដូច្នោះខ្ញុំម្ចាស់នឹងផ្សំថ្នាំរម្ងាប់ពេតនោះ ប្រគេនលោកម្ចាស់ឥឡូវនេះឯង ។ លុះបានទិមន្តស្រេចហើយ ក៏ត្រឡប់ទៅកាន់ផ្ទះនាងវិញ បានថ្ងៃឥតមានខោះដំពឋមាតាបិតាឲ្យបានជ្រាបសេចក្តីសព្វគ្រប់ កាលបើមាតាបិតាបានអនុញ្ញាតឲ្យហើយ នាងក៏រៀបណ្តាច់តាក់តែងផ្សំថ្នាំដោយរសផ្សេង ។ ធ្វើជាបបរថ្នាំចំរុងទុកជាស្រេច ។

លុះថ្ងៃព្រឹកឡើង តំក្នុអ្នកមានជម្ងឺនោះក៏បានយ៉ាំថ្នាំរដាបរមែលត្រាប់ទៅដើម្បីបំណាច់ត្រ បានចូលទៅកាន់ផ្ទះនាងតាមការនោះឯង ។

ឯនាងតាមការ កាលបើបានឃើញព្រះថេរ:ទិមន្តមកដល់ផ្ទះហើយក៏កើតសេចក្តីសោមនស្សជ្រះថ្លាក្រោកឡើងទៅទទួលយកបាត្រចេញហើយ ចាត់ចែងក្រាលអាសន:ប្រគេនព្រះថេរ:នោះ ។

លុះព្រះថេរ:បានស្ថិតនៅលើអាសន:សិប់ហើយ នាងក៏អង្គាសព្រះថេរ:ឲ្យឆាន់បង្អែនយ៉ាងស្រួល បានធ្វើសក្ការបូជាដោយគោរព ។

កាលបើព្រះថេរ:បានឆាន់កេសជ្ជាហារ ដែលជាថ្នាំសក្តិសិទ្ធិរួចក្តាម

អាតាធក្តីសរីរៈរបស់លោកក៏រម្ងាប់ទៅមួយរំពេចដែរ ដោយកម្លាំងសទ្ធា
របស់នាងតាមការកាន់នោះឯង ។

លំដាប់តពីនោះមក ព្រះថេរៈអង្គនោះ លោកពុំបានទំមន្តទៅកាន់ផ្ទះ
នាងតាមការកាន់នោះទៀតឡើយ ។

លុះថ្ងៃជាខាងក្រោយ នាងតាមការកាន់បានចូលទៅកាន់ព្រះវិហារ
ថ្វាយបង្គំព្រះថេរៈនោះហើយទូលសួរថា ព្រះគុណាពុំបានទំមន្តទៅកាន់ផ្ទះ
របស់ខ្ញុំម្ចាស់ តើព្រោះហេតុអ្វី? ព្រះថេរៈតបថា: ម្នាលឧបាសិកា! បាន
អាត្មាមិនទៅកាន់ផ្ទះនាងទៀត ព្រោះអាត្មាបានសះជារោគស្រឡះហើយ ។
ឯនាងឧបាសិកា លុះបានដឹងថា ព្រះថេរៈបានជាសះរោគហើយក៏
ទូលថា បពិត្រលោកម្ចាស់ជីវម្រើន! ការនេះប្រពៃណាស់ហើយ។ ។
នាងមានសេចក្តីសោមនស្សជ្រះថ្លាកើតឡើងក្នុងសន្តានពុំមានជាប់ ហើយ
ថ្វាយបង្គំលាព្រះថេរៈត្រឡប់ទៅកាន់ផ្ទះនាងវិញហោង ។

ដោយគេជៈផលានិសង្សបុញ្ញកម្មនោះ ។ លុះនាងអស់អាយុក៏បាន
ឡើងទៅកើតក្នុងស្ថានតាវត្តឹង្សទេវៈលោកនាយ ដូចជាស្ត្រីភ្ញាក់អំពីដេក
លក់មួយរំពេចនោះឯង ។ មានវិមានមាសជាទីត្បូងផ្ទុះឡើងប្រមាណកំពស់
១២ យោជន៍ ប្រកបដោយស្ត្រីទេពអប្សរជាច្រើនកើតប្រាកដដល់នាង
ទេពធីតានោះឯង ។ (នៅមានត)

ទើបពោធិសត្វអ្នកជណ្តឹងថា ម្នាលគ្នាយើងទាំងឡាយអើយ តុំមានអ្នកឯណាឯងអាចហ៊ានស្រដីពីតខ្លួលព្រះមហាក្សត្រាធិរាជបានដែរ អស់អ្នកផងទាំងឡាយឮហើយឆ្លើយថា បពិត្រព្រះមហោសថអើយ រឹស្តុកដ៏ហ៊ានស្រដីគ្រាថពីតខ្លួលនោះមិនជាខមូនឡើយ ដ៏យណាស់ឯងអើ ។ ព្រះមហោសថអ្នកប្រាជ្ញស្តាប់ហើយឆ្លើយថា អើបើដូច្នោះ អស់គ្នាយើងទៅហៅមកអញ្ជើញប្រជុំចុះ, ទើបអស់អ្នកផង ឱ្យទៅជ្រើសរើសកេរអ្នកដំណាសចេះចែងថ្លែងសំដី ហ៊ានពីតខ្លួលនោះ នាំមកគាន់ព្រះមហោសថអ្នកប្រាជ្ញ ។ ទើបព្រះអង្គបង្គាប់ថា ម្នាលព្រះស្តេនចូរទៅទៀតគាន់ព្រះពជមន្ទីរព្រះមហាក្សត្រាធិរាជ នាកាលហៀបទៀបទីនឹងដល់ព្រះពជកំនត់ព្រះមហាក្សត្រ ចូរព្រះស្តេនឈរសាយសក់ចុះលើស្មា ហើយលើកដៃជាក់លើត្បូងដៃមួយតក់ខ្នងទ្រហោស្រែកយំដោយខ្លួរំខន្ធញានោះផង។ គោះមានអ្នកផងដណ្តឹងប្រការដូចម្តេច ។ ត្តិ កុំបីព្រះស្តេនស្រដី

ដល់គិចឡើយ ហើយរំងាប់ភ្លើងខ្លាំងណាស់ទៀត ហើយចូលទៅឲ្យ
ជាន់ដល់ព្រះពជមន្ទីរនោះហោង, បើព្រះមហាក្សត្រាធិពជ ស្តេចគ្រាស់
ដណ្តឹងឯង កំព្រះស្តេងលើកកំបងំអញ្ជលីក្រាបថ្វាយបង្គំយំរហើយទូល
បណ្តើរថា បពិត្រព្រះសម្មតិទេពមហាពជក្សត្រថ្លៃប្រសើរអើយ, សូម
ទាន ដ្បិតអាពុកអញខ្ញុំព្រះជាទាសអម្ចាស់ មានគតិធំណាស់ថាសង្ឃែ តប្បី
ស្នមន្ធឯងប្រសូតកូនហើយ កំឥឡូវនេះ ធឯងប្រសូតពុំរួចឡើយ ជាគំរប់
៧ ថ្ងៃនឹងថ្ងៃនេះហើយ, រីអស់ទ្រព្យទេព្យរមែត សឹងប្រយុទ្ធរសាយដៃ
អស់ហើយ ខ្ញុំឥតបើនឹងពុំនាក់សំណាក់ឯណាឡើយ មានតែព្រះអង្គ
ឯង ជាពំនាក់ខ្ញុំហោង, ឥឡូវនេះ ខ្ញុំមកសំណាក់ក្រាបទូល សូមទេព្យ
លួងធឯងឲ្យជួយយកកូនអំពីកន្ងែនៃអាពុកខ្ញុំហោង, រីមហាក្សត្រាធិពជ
មានព្រះបន្ទូលថា បុរសនេះវង្វេរវើរវាយអ្វីដូច្នេះហ៎ៈខ្ញុ ជួរនេណា
ប្រុសក៏ធឯងមានកូនប្រសូតនោះហឹង អញមិនដែលមានដូចព្រះស្តេង
ស្រដីនោះហឹង វានេះឆ្កួតទេដឹងអេះ ? កាលណាបើមហាក្សត្រា
ធិពជ ស្តេចមានព្រះបន្ទូលដណ្តឹងថាដូច្នោះហើយ កំព្រះស្តេងទូលវិញ
ថា បពិត្រព្រះនរបតីស្រីសម្មតិទេពក្សត្រថ្លៃប្រសើរអើយ បើប្រុសមិន
ដែលមានប្រសូតកូនដូច្នោះហើយ តើហេតុអ្វីព្រះអង្គស្តេចឲ្យយកគោ
មន្ត្លសកពជ ឲ្យទៅសីរីវិឌ្ឍកសេដ្ឋី ទូវែសអ្នកស្រុកជាច័នយមែជ្ឈ-

ត្រាម ប្រើធ្វើគោឲ្យប្រសូតកូនហ៊ះមហាពជ ថាបើអាពុកខ្ញុំមិនដែលមានប្រសូតកូនហើយ, គោមង្គលទសពាជនោះ ក៏ពុំអាចនឹងប្រសូតបានដូចអាពុកខ្ញុំហោង ។ បុរសនោះ ស្តាប់ពាក្យព្រះមហោសថអ្នកប្រាជ្ញផ្តាំចាំឥតសំណល់ ដំណល់ទុកក្នុងចិត្តស្រេចហើយ ក្រាបលាធ្វើអស់អាថិសេចក្តី ដូចទ័យយើងស្រដីរៀងមកកាលព្រះមហោសថអ្នកផ្តាំនោះឯងហោង ។ មហាក្សត្រាធិពជជ្រាបហើយ មានព្រះបន្ទូលថា ម្នៃព្រះស្នែង អ្នកឯណាអាចរិះគិតដាអាថិប្រស្នាតបតមកដូច្នេះហ្នឹង? បុរសនោះ ក្រាបថ្វាយចង្កឹប្រណម្យទូលថា បពិត្រមហាពជអើយ ព្រះមហោសថអ្នកប្រាជ្ញឯង អាចប្រើមកធ្វើជាអាថិប្រស្នាតបនឹងព្រះអង្គ, មហាក្សត្រស្តាប់ហើយ មានព្រះហឫទ័យនោះដំ ពញខ្នូវព្រះអំណរអរក្រៃពេកហោង ។

ឯ ឧទ្ទានគាថា ។ នេះនឹងស្រដីតាមល្បឹងចាយនោះមិញ ។

អបរស្មឹ ធិវសេ បណ្ឌិតំ រាមំ សិសិស្សមាតិ ចន្តេត្វា
ចាចិនយវមជ្ឈគាមកសិនោ ការ បណ្ឌិតា អម្ហាកំ
អដ្ឋដ្ឋសមន្នាគតំ អត្ថិសោឧនំ បចិត្វា បេសេន្តុ។ល។

មានកាលសម័យថ្ងៃមួយទៀត, មហាក្សត្រាធិពជ ជំនុំរិះគិតនឹងអស់អ្នកប្រាជ្ញទាំង ៤ ស្តេចនឹងឲ្យល្បឹងលង ព្រះមហោសថអ្នកប្រាជ្ញវិញទៀត

ទើបមានព្រះបន្ទូលប្រើអាមាត្យ មួយនាំពតមានចេញទៅភ្លាមនិវត្តក-
សេដ្ឋ មួយអន្ទើទូរអស់អ្នកស្រុកថាចំនួយរមជ្ឈត្រាមថា មានព្រះបន្ទូល
ពាសេសត្រាស់ប្រើមកកាន់អ្នក ឲ្យអ្នកដណ្តាំថាយជូរ ហើយឲ្យមានប្រ-
ការនោះគាំង ៧ ជំពូក មួយតិមិនឲ្យយកអង្ករដណ្តាំ, មួយតិមិនឲ្យយក
ទឹក, មួយតិមិនឲ្យយកឆ្នាំង, មួយតិមិនឲ្យដេកជើងក្រាន, មួយតិមិនឲ្យ
យកកៅអី, មួយតិមិនឲ្យយកខ្ទស, មួយតិមិនឲ្យយកប្រុសឬស្រីដណ្តាំ,
កាលណាបើដណ្តាំថាយជាថាយស្រេចហើយ មិនឲ្យដើរទៅដោយទូរផ្លូវ
ឡើយ, បើអ្នកដណ្តាំថាយនាំទៅថ្វាយបានមានសុភាពដូច្នេះ នេះគឺជា
ការឥតទោសឡើយ, បើមិនបានដូចព្រះបន្ទូលបង្គាប់នេះហើយ ព្រះអង្គ
ធ្វើឲ្យត្រូវទោសព្រះរាជទណ្ឌជាដំណាំងមួយពាន់ជង្គង ៧ សែរវ៉ែនក
សេដ្ឋ ទូរអស់អ្នកស្រុកមហាជនធ្វើតាំងព្រាយ ឮព្រះបន្ទូលដល់ហើយ
សឹងដាំរិះគិតកាត់អាថិសេចក្តីថ្លាថ្នោះពុំបាននឡើយ ហើយនាំអាចប្រស្នា
ទៅគាន់ព្រះមហាសថអ្នកប្រាជ្ញ ឲ្យព្រះអង្គពិចារណាដោះអាចប្រស្នា
នោះហោង, ទើបព្រះមហាសថព្រះអង្គដឹងអាថិសេចក្តីប្រស្នានោះមិន
កំចាំងឡើយ, ទើបអ្នកថា ម្នាលគ្នាយើង កុំបីអ្នកតាំងព្រាយតិតបាវម្ល
ឡើយ ជាក្លាក់ងារអញឯង នាលោកថា មិនឲ្យយកអង្ករដណ្តាំនោះ
លោកថាឲ្យយកស្រែវិញ, លោកថាមិនឲ្យយកទឹកនោះ លោកថា

ឲ្យយកបន្ទើមវិញ, នាលោកថាមិនឲ្យយកខ្នាំងនោះ លោកឲ្យយកឯទ្លុះវិញ, នាលោកថាមិនឲ្យយកដើងគ្រានោះ លោកថាឲ្យយកឈើចោះកៅវិញ, នាលោកថាមិនឲ្យយកកូនឆនោះ លោកប្រើរៀរកូនឆយើងប្រក្រតី ហើយប្រើយកឫស្សីមកធ្វើជាគំនួតតួតយកកូនឆជាថ្មីវិញ, លោកថាមិនឲ្យយកទុសនោះ លោកឲ្យលៃឆទុសឈើឫស្សីបេញ ហើយលោកឲ្យយកតែស្នឹកឈើមកដុតវិញ, នាលោកថាមិនឲ្យយកប្រុសដណ្តាំ មិនឲ្យយកស្រីដណ្តាំនោះ លោកឲ្យយកខ្លួយដណ្តាំវិញ, នាលោកថាមិនឲ្យដើរដោយផ្លូវទៅថ្ងាយបាយជួរនោះ លោកប្រើឲ្យលះបង់ផ្លូវផ្លាំង, លោកឲ្យដើរកាត់ដីកយដើងដើរទៅថ្ងាយបាយជួរហោង ។ អស់អ្នកផងទាំងឡាយ សឹងធ្វើទ្រុលខ្លាយអណ្តាប់ដោយចង្កាប់ព្រះមហាសថនោះហោង, ហើយឲ្យយកអម្បោះបង់កន្ទាំង នាដណ្តាំបាយជួរនោះ ឲ្យទាំទៅថ្ងាយមហាក្សត្រាធិរាជនោះហោង ។ បពិត្រអើយ, កាលនោះ បើមហាក្សត្រាធិរាជនោះជ្រាបសុភាពដូច្នោះហើយ ទើបមានព្រះបន្ទូលថា អើ! អ្នកឯណា អាចមានព្រះប្រាជ្ញាដោះអាថប្រស្នានេះហ៊ីន ? អស់អ្នកផងទាំងឡាយក្រាបថ្វាយបង្គំទូលថា បពិត្រមហាពរអើយ ! នាអស់អាថប្រស្នាទាំងនេះ មានតែព្រះមហាសថបុត្រតហបតីឯង អាចធ្វើជាប្រស្នាឲ្យដណ្តាំបាយថ្វាយព្រះបាទឧម្មាស់ឥឡូវនេះឯង, មហាក្សត្រាធិរាជ

ជ្រាបសុភាពដូច្នោះហើយ ស្តេចមានព្រះហឫទ័យដំពេញទូវព្រះអំណរ
អរក្រៃពេកហោង ។

ញាសុភាតិ នេះ ទំនិស្រដីពីការល្បងពួរខ្សាច់នោះមិញ ។
អបរាស្មឹ ធិរាសេ បណ្ឌិតស្បែរ៉ែ រ័មិសនត្តំ តាមភាសីធំ
សាសនំ បហិណឹសុ ។ ល ។ មានការសម័យថ្ងៃមួយ មហា
ក្សត្រធំពាជស្តេចជំនុំរិះគិតនឹងអ្នកច្រាជ្ញ ៤ នោះស្រេច ស្តេចទំនឹងឲ្យល្បង
លងព្រះមហាសថអ្នកច្រាជ្ញ ទើបព្រះអង្គឲ្យទាំពតិមានៅកាន់សិរីវឌ្ឍក
សេដ្ឋីថា ព្រះបន្ទូលពីសេសត្រាស់ប្រើយើងមកកាន់អ្នក ទូវអស់អ្នកស្រុក
ចាំចង់យវមជ្ឈត្រាមថា ដ្បិតព្រះមហាក្សត្រាធិពាជ មានព្រះបំណងទំនឹង
ចង់ឲ្យអស់អ្នកឯងវិញពួរខ្សាច់ទៅថ្វាយ ដ្បិតពួរចាស់អំពីបុរាណនោះ
គណ្តុរវាគាត់អស់ហើយ ឥឡូវនេះឲ្យអ្នកវិញជាថ្មី ឲ្យបានទាំទៅថ្វាយ,
បើអ្នកវិញពួរនោះបានយកទៅថ្វាយ អើគំជាការឥតទោសទេឬយ, បើ
តុំបានទាំពួរខ្សាច់នោះទៅថ្វាយទេ នោះឃើញជាអ្នកមានទោសធ្ងន់ ត្រូវ
ព្រះពាជទណ្ឌជាជំណាំងមួយតាន់ជងហោង ។ កាលណាមេសិរីវឌ្ឍក
សេដ្ឋី ទូវអស់អ្នកផងទាំងឡាយ គិតហើយឆ្ងល់តុំអាចទំងយល់អាថ
ប្រស្នានោះទេឬយ, ហើយទាំគ្នាទៅដណ្តឹងព្រះមហាសថអ្នកច្រាជ្ញ ទ្រង់
ស្តាប់ពាក្យអ្នកផងទាំងឡាយដណ្តឹងដូច្នោះហើយ ក៏ព្រះអង្គរិះគិតដោយ

ខ្ញុំព្រះក្រុងថ្មីទៅរៀសសឯងថា មានតែរ៉ែតជាអាចប្រស្នាតបតទៅវិញ
ទើបបាន, កាលណាអ្នកគិតស្រេចហើយស្រដីថា ម្នាលអស់អ្នកចាំង
ឡាយអើយ, កុំបីអស់អ្នកចាំងឡាយគិតឡើយ ពុកជាអេតឲ្យអញឯង
ទើបអ្នកឲ្យទៅហៅអ្នកជំទេះដើងកន្ធងដំឈ្វាសវៃសំដីបាន ៤ នាក់ហើយ
ព្រះអង្គបង្គាប់ក្រាប់ថា ម៉ៃអ្នកចាំងឡាយអើយ, ចូរអ្នកចាំងឡាយទៅ
ក្រាបទូលព្រះមហាក្សត្រថា បពិត្រព្រះនាកយណ៍នរបតីស្រីសម្ភតិទេព
មហាពជក្សត្រថ្លៃប្រសើរអើយ ! រីសរ៉ាវ៉ុកសេដ្ឋ ខ្ញុំវ៉ែអស់អ្នកស្រុកចាំច-
នយវ៉ែមជ្ឈគ្រាម សឹងមកជំទុំគ្នាពិចារណាខ្លឹងវិញតួរខ្លាច់នោះពុំអាចដឹង
ជាធំជាតូចដូចម្តេចឡើយ, ហេតុនោះហោង ទើបឲ្យមកក្រាបទូលព្រះអង្គ
ឲ្យសូមយកតួរខ្លាច់ចាស់អំពីបុកណាសំណល់ដែលកណ្តៀកគាត់គង់មួយចំ-
គាមក្តី មួយហត្ថក្តី ចូរព្រះអង្គឲ្យមកយើងខ្ញុំខ្លឹងយកទៅជាក្បួនខ្លឹងមើល
វិញ ឲ្យដូចអំពីបុកណាហោង ថាបើព្រះមហាក្សត្រាធិរាជមានព្រះបន្ទូល
ទៅខ្លឹងអ្នកចាំងឡាយថា ព្រះស្តែងអើយ នាតួរខ្លាច់អំពីបុកណានោះពុំ
ដែលមានឡើយ, ខ្មោះហើយអ្នកចាំងឡាយថ្វាយបង្គំប្រណម្យទូលឡើង
វិញទៀតថា បពិត្រមហាពជអើយ ថាបើព្រះអង្គមានព្រះបន្ទូលថា តួរ
ខ្លាច់អំពីបុកណាពុំដែលមានដូច្នោះហើយ តើហេតុអ្វីព្រះអង្គប្រើទៅកាន់
សិរ៉ាវ៉ុកសេដ្ឋ ខ្ញុំវ៉ែអស់អ្នកស្រុកចាំចនយវ៉ែមជ្ឈគ្រាម ឲ្យវិញតួរខ្លាច់ថ្មី

មានក្បួនដៅ៎ ឬទេយើងខ្ញុំនឹងវៃញ្ញាន ថាបើឥតក្បួនហើយ តើនឹងវៃញ្ញដូចម្តេចបាន ? បើព្រះមហាសត្វហើយ ចាំទុកឥតសំណាប់ដឹកលក់ក្នុងចិត្តស្រេច ហើយភាវៈព្រះមហាបុរសអ្នកច្បាស់ដៅដូចបង្គាប់នោះហោង ។

បពិត្រអើយ, កាលណាបើព្រះមហាក្សត្រាធិរាជត្រាស់ហើយ មានព្រះបន្ទូលដណ្តឹងថា អើ! អ្នកឯណា អាចមានតំរិះចេះអាចប្រស្នាតបតមពាក្យដូច្នេះ តើច្បាស់អ្នកឯណាឯងហ៎ ? ទើបបុរសនោះស្តាប់ព្រះបន្ទូលពាសេសត្រាស់ដណ្តឹងមកគាន់អាត្មា ហើយក្រាបទូលថា បពិត្រព្រះមហាក្សត្រាធិរាជដ៏ប្រសើរអើយ ! សូមមានតីច្បាស់ព្រះមហាសត្វបុត្រសិរីវ័ឌ្ឍកុសលដ៏ឯក ប្រើអស់យើងខ្ញុំនោះនាំអាចប្រស្នាមកក្រាបទូលព្រះអង្គហោង ។ រីព្រះមហាក្សត្រស្តាប់ហើយ ក៏មានព្រះហឫទ័យនោះ ដំពោះក្បួរព្រះដំណាក់ត្រៃពេកហោង ។

តទ្បាកត្តិ ។ នេះ នឹងស្រដីតាមល្បងស្រះនោះមិញ ។ អបរស្មឹ ទិវសេ បណ្ឌិតំ រាជានំ រាជា ឧទក-កាឡិំ កាឡិតុកាមោ បញ្ចវិធបទុមសញ្ឆន្នំ ទោក្ខ-រណឺ បេសេន្តំ អបេសេន្តានំ សហស្សទណ្ឌាតិ ។ល។

មានកាលសម័យថ្ងៃមួយវិញទៀត ព្រះមហាក្សត្រាធិរាជ ព្រះអង្គ

ច្រើនជាមាត្យមួយទៀតនាំសិរីវឌ្ឍកសេដ្ឋីថា ព្រះបន្ទូលតាំសេសត្រាស់ប្រើឲ្យមកដល់អ្នក ដ្បិតមានព្រះបំណាងនឹងចង់ស្រង់ទឹកស្រះ ដ្បិតស្តេចជ្រះបសុកាពថា មហាសេដ្ឋកូនអ្នកបានដីកស្រះធំទូលាយ មានទឹកនោះជ្រៅជ្រះត្រចះថ្លា ជិះដេរដាសតាសនឹទៅខ្ទរឈ្លូកតាំង ៥ ព័ណ៌ ប្រាសត្រាលខ្ទាលឆ្ងៃនផ្កើដ៏រកស្ទុះស្ទាយពណ្ណកយ ហេតុនោះហោង ឲ្យអ្នកលើកស្រះនោះឲ្យដងតាំងទឹកតាំងដីតាំងឈូក ខ្ញុំឃ្លាតសង្កាតនាំទៅឲ្យធាប់ប្រញាប់ទៅថ្វាយ ថាបើអ្នកបានទាំយកស្រះនោះទៅថ្វាយ កំដាកាវេតនាសឡើយ ថាមើពុំបានទាំទៅថ្វាយហើយ កំអ្នកនឹងមានទោសធ្ងន់ ត្រូវព្រះពន្ធនាគារដំណាងមួយពាន់ដងពុំលែងឡើយ ។ រីឯសិរីវឌ្ឍកសេដ្ឋីទូរអែស់អ្នកស្រុកបាច័នយាមជ្រាមនោះ ឮព្រះបន្ទូលដូច្នោះហើយក៏សឹងមកជំនុំគ្នា ពុំអាចដើម្បីនឹងដឹងអាថប្រស្នានោះបានឡើយ ហើយសិរីវឌ្ឍកសេដ្ឋីឲ្យទៅដណ្តឹងសួរពោធិសត្វ លុះពោធិសត្វស្តាប់តែពាក្យអស់អ្នកផងទាំងនោះប្រាប់សព្វប្រការហើយ ព្រះអង្គដឹងអស់អាថប្រស្នានោះពុំកំបាំងឡើយ ហើយទើបអ្នកគិតថា ប្រស្នានេះដូច្នេះហើយតើ មានតែរំដាអាថប្រស្នាឲ្យតបតស្នងទៅវិញទើបបានអេះ ព្រះអង្គរិះគិតដូច្នោះហើយ ឲ្យទៅហៅអ្នកជិះចេះតន្ទាស់ឈ្មាសសំដីនោះមកដល់ហើយទើបព្រះអង្គបង្គាប់ប្រាប់ថា ម្នាលគ្នាយើងអើយ ចូរគ្នាយើងទៅលេង

ទឹកមានឱ្យក្អែកនោះក្រហមច្រាល ឱ្យមានសក់នោះខទឹក ដ៏មានសំពត់
សំលៀកនោះសឹងខទឹក ហើយមានខ្នងនោះសឹងច្រឡាក់ខ្លួកក់ ហើយ
មានដៃនោះកាន់ខ្លួវព្រ័ត្រតួរវិលជុំជងព្រនង់អង្រែ ហើយរត់ទៅកាន់ទ្វារ
ព្រះពជរាំងបើគេទៅក្រាបទូលហើយ សន្សឹមចូលទៅឱ្យបានដល់ឃល់
ព្រះមហាក្សត្រាធិរាជ ហើយក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រ
ព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ដ្បិតព្រះអង្គប្រោកជអាមាត្យទៅ
កាន់សិរីឧត្តុកសេដ្ឋី ខ្លួវអស់អ្នកស្រុកបាចនយវមជ្ឈគ្រាម ប្រើឱ្យស្រុះ
មកថ្វាយព្រះអង្គនោះមិញ អស់យើងខ្ញុំមកជំនុំគ្នា ឃល់ស្រះមួយនោះ
ជ័សមគួរនឹងព្រះអង្គ យើងខ្ញុំយកព្រ័ត្រតួរបងក្រៀកនឹងសន្ធឹងចង់តើប
មក យកជំបងព្រនង់គៀងគាំនាំមកថ្វាយព្រះអង្គ, រីស្រះនោះភ្លាប់តែ
នៅព្រៃមិនដែលប្រសពូនឹងមនុស្សម្នាមហាជនផងទាំងឡាយ ខ្លួវរេះ
ជំរាសេះផង សំឯតែដើរទៅវិញទៅមកពុំដែលស្ងាត់ឡើយ, រឯស្រះនោះ
មិញក្លាក់ផ្តើលកឹតខ្លាចបំរះច្រាស់ច្រាល់ទៅមកជាប់ព្រ័ត្រតួរផង រាល់ផ្លុះ
ស្ទុះរត់រួចទៅហោង ។ សូមបានយើងបានអង្រែព្រនង់ជំបងតាមដេញ
ជិតម្រកិតរត់ជើងស្ងាត់ទៅពុំអាចនឹងទាន់ឡើយ រាត់ជ្រលួសហួសទៅ
ឆាលំនៅព្រៃដែលវិញហោង ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

រឿងមរណាមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសារស្ត្រស្ងឹកតែត

សារីកាកែវកល្យាណ ច្រាប់ដើមជានសារសេចក្តី ឋតត្រម្ងាស់សារីសេ
ស្តេចកណ្តុរសម្លាប់ថ្ងា ។ ឯនាមខ្ញុំម្ងាស់នោះ សន្ទុតឈ្មោះនាងសារីកា
កណ្តុរស្តាប់ពាក្យ សួរខ្លួតថាខែមាសម្លៃ ។ ហេតុម្តេចគេចោទស្ងាប
កេមជកចតអស្រ័យ គ្មានតង់មួយសារសៃ ចូរមាសម្លៃច្រាប់យើងកំ ។
នាងច្រាប់ថាខ្លួនខ្ញុំ ក្សត្រទត្តមច្រង់មេត្តា ចំញ៉ាំមខ្ញុំនេះណា ឲ្យរក្សា
ទីបន្ទុំ ។ ឥឡូវនេះព្រះអង្គ លើកចតុរង្គសេនាធំ ទៅច្រាប់ខ្មាំងពិត
ពុំ- ខានវិធីលែមកកាក ។ មានស្តេចម្ងាក់ចិត្តកាច ចោរកំណាចច្រើស
ពាជ នាមឈ្មោះនាងធនូ រាជាច់ខ្ញុំនឹងសម្ងាប់ ។ ប្រើខ្ញុំស្រី
ម្ងាក់ខ្លួច ឲ្យរាំចោចកេមប្រញាប់ ហើយឲ្យចិញ្ចាំកាប់ សាច់ឆ្អឹង
ខ្ញុំនឹងខ្ញុំ ។ ចោចរួចមេពាស៊ី ចុះទៅដើរឆ្ងាយពី ឯខ្ញុំរត់
ជាកច់ មកពឹងពួនទៅនេះហោង ។ ខ្លួនខ្ញុំកំព្រាក្រៃ ឥតអាស្រ័យ
ទីពឹងផង ខ្ញុំសុំអ្នកជាបង ឲ្យទៅផងដោយមេត្តា ។ ទម្រាំជុះកេមស្ងាប

ត្រាប់ដកបរិធីបត្តា លុះដាច្ចខ្លួនកាលណា ខ្ញុំនឹងក្រាបលាទៅហោង ។
កណ្តុរស្តាប់សារិកា អង្វរថាសុំទៅផង ហើយសុំខ្លួនជាបង មាន
ចិត្តគិតនឹកមេត្តា ។ សង្វើតនឹកអាណិត ឆ្ពន់ឆ្អែតឆ្អិតណែនខ្នុក ហើយ
លួងលោមទៅថា ហៃប្អូនភ្ងាមាសបងអើយ ។ តាំងពីថ្ងៃនេះទៅ ចូរ
នាងនៅកុំភ័យឡើយ នាងនៅនឹងបងហើយ កុំបារម្ភនឹងកោក្តា ។
សឹមបងប្រើអស់ពស ចេញក្រៅយូរល់ត្រាប់ទិសា រកអស់ពាំងកោជនា
ចិញ្ចឹមនាងឲ្យសប្បាយ ។ រីឯមេធ្មូ ចិត្តឫស្យាចោរអន្តកយ ឆ្នើ
ចោរប្លន់គោមធាយ បងធាទាសម្ងាប់ក ។ នាងស្តាប់ឆ្លើយសាសង
កុំអ្នកបងចង់វេរ ក្រែងមានតៀរទើងគ្នា តទៅមុខទៀតមិនអាន ។
មួយទៀតគេជាមនុស្ស ខ្លួនធំខ្លាំងកំលាំងមាន យើងជាសត្វតិរច្ឆាន
ខ្លួនតូចពាបកំលាំងតិច ។ ទឹងឃុំខ្លួនតតាំង ប៉ះកំលាំងគេដូចម្តេច
ខ្លួនយើងកំលាំងតិច សូមអ្នកបងស្រឡាំមៅជា ។ កណ្តុរសេចានស្តាប់
នាងសាស័ក្តិឃាត់ពាំងក ឆ្លើយថាប្អូនតុំងា បងតុំព្រឺភេមរូបប្រាណ ។
មិនស្រឡាំមនឹងគូ កំលាំងវាមានប៉ុន្មាន យើងជាសត្វតិរច្ឆាន មិន
ខ្លាយប្រាណខ្លួនអាយ ។ ទើបស្តេចកណ្តុរស ប្រើអស់បរិពារពាំង-
ខ្លាយ ឲ្យចេញទៅខ្វល់ខ្លាយ តាំកប្បាសគរស់ឡើ ។ យកមករៀប
សសាប់ សសោះត្រាប់ក្រាលលើដី រៀបឲ្យនាងបក្សី សារិកា

តែវានាងនិទ្រា ។ ទីមួយឱ្យនាងផ្ទំ ជាទ្រង់ក្សត្តិយា ទីពីរឱ្យលីលា
ដើរលេងជាសត្វថ្ងៃ ។ ស្រេចហើយចាត់តាល ឱ្យនាំគ្នាប្រើនៃលឿ
ឡៅ តាយរូនឱ្យជ្រៅ ជំទូលាយឥតគណនា ។ ហើយប្រើអស់ពួក
តាល ឱ្យភ្ជាយទូលគ្រប់ៗគ្នា រកត័ស្តុកោដនា ចេកខៀបពុំនំចំណី ។
សណ្តែកស្រូវយ៉ាំដ៏ល្អ តោតថ្លៀលថាំដ៏ពុំខ្វី កាត់ពាំនាំយ៉ាតខ្ចី យកមក
ជូននាងសារិកា ។ បរិភោគជាប្រក្រតី ឆ្អែតឥតបីមានពុំក្លា តាំងពី
ថ្ងៃនោះណា នាងបានសុខឥតពុំក្តីភ័យ ។ ដោយសារស្តេចកណ្តុរ- សន្ទិ-
មិលមានគុណក្រៃ ប្រណីនាងស្រីថ្ងៃ ហាក់ដូចបងប្អូនឯកទទេរ ។ សារិកា
តែកែលក្សាណ បានសុខសាន្តឥតភ័យមរណ៍ ក្នុងចិត្តគិតកូដរ ជាព្រះ
រៀមកដស្ងាមី ។ សត្វថ្ងៃនោះល្ងាចព្រឹក តែងក្អកទឹកពាល់ពត្រី ថាឧ
ព្រះចក្រី ម្ល៉ះសមស្តេចវិលយាត្រា ។ យាងមកពុំឆាន់ដល់ ពាជមណ្ឌល
ក្រែងវាផ្តាំ ម្តុំពុំបានយាត្រា ឬមានហេតុម្តេចកើជាត់ ។ ស្តេចពុំជ្រាបថា
ខ្ញុំ តើតទុក្ខធំមកច្រាសត្រាត់ ចាកចោលច្រាសាទវ័ត្ត មកលំបាកនៅ
កន្លែដ ។ បើស្តេចជ្រាបថាខ្ញុំ ជាត់ហើយសមព្រះចក្រី ចាត់ប្រើតាល
សេនីយ ឱ្យតែរកសត្វព្រឹក្សា ។ នេះម្តេចក៏មកជាត់ ទាំងមហាក្សត្រទ្វៃ
សេនាំ ម្ល៉ះហើយសមក្សត្រា ស្តេចសប្បាយប្រតាតត្រៃ ។

នាងនឹកដល់កស្តា ឆ្មៀងនេត្រាតយរំពៃ កើតទុក្ខក្នុងហឫទ័យ ក្រៀមក្រំកក្តួលនេត្រា ។ ពុំស្រាកពុំស្រាន្តស្រាល ពុំស្រយាលតិចពុំក្លាន្តឆ្ងៃតក្នុងទ្រូង ត្រោះឃ្លាតឃ្លាចាកមេត្រី ។ នាងនៅក្នុងវង់ហាន ដុះស្វាបបានដូចប្រក្រតី ប៉ុន្តែស្វាបនៅខ្លី ហើរពុំបានខន់បក្ខា ។

ឯកឯវសំ ម្ខសិកាំ ចន្តេត្វា អានកាលថ្ងៃមួយណា រំដេរស្តេចកណ្តុរស ។ ទំកវិនិនឆ្ងៃនន្ធា ចាប់សាវិកាជាសត្វល្អ ក៏ចោបស្វាបខ្លួនឲ្យលំបាកស្ទើរមរណា ។ កណ្តុរគិតតក្បាបាទ បងតិយានាងឆ្ងៃនា លុះយប់ចូលសន្ធ្យា ស្តេចកណ្តុរចេញចាកន្ធ ។ ឡើងលើផ្ទះឆ្ងៃនា ស្រីត្រៀបត្រាច្រើនលើសលន់ កណ្តុរវៀរគេយគន់ រវេកមើលនាងឆ្ងៃនា ។ ឃើញតែពួកទាសី ដេកប្រក្រតីតេញត្រីហា ពុំស្គាល់នាងឆ្ងៃនា រួបដូចម្តេចទៀបឬស ។ កណ្តុរវៀរមើលត្រប់ ស្លែងបន្ទប់ខែនទីល្អ សត្វប្រកជ្រងត ។ គ្មានចន្ទោះសល់ត្រង់ណា ។ ហើយស៊ុះចូលទៅក្នុងវាដេរប់ត្រង់ត្រែក្រឡា ឆ្ងៃនាលក់សេយ្យា តិតពុំដឹងខ្លួនសូន្យរសោះ ។ កណ្តុរឃើញរូបប្លែក ស្អួចម្ខែកគេចំងអស់ មុះមាត់ស្រស់បស់ ថាខែនេះហើយនាងឆ្ងៃនា ។ ប្រាកដពិតពុំខុស តែតហើយស៊ុះខ្លើម្ខែម្ខាលើត្រែនាងឆ្ងៃនា លោះលោតផ្ទោះទាំប្រមុះ ។ ខាំមួយដាច់កំបុត ពាំសាច់តែរំពេចបុះ ដល់ដីហើយតាលណោះ ឯឆ្ងៃនាភ្ញាក់អាត្ម ។ ឈឺ

ចាប់ចេញឈោមច្រាល ខែដ៏ខ្ចាលតេញកាយា ស្រែកហៅអស់ពួកវ៉ា
ថ្លូវហ៊ុះ។ ឮឡ។ ។ ដោយដាច់ប្រមុះធេង ថ្ងៃកសម្ងើសូវគ្រលេវ ស្រែក
ចេញឮឡ។ ពួកបរិវារស្តាប់មិនបាន ។ ស្រីខ្លះស្ទុះចូលទៅ ឃើញ
ឈោមផ្តៅច្រាលអស់ច្រោណ មើលមុខស្គាល់មិនបាន ទាំងសំដីមិនដូច
មុន ។ ប្រមុះដាច់ត្រហូ ឈរមើលយូរខ្ញុចតេកតង់ ញ័រខ្លួនដូច
គេគ្រុន រត់ចេញក្រៅថាយើ។ ។ ខ្លះថាហង៍វ៉ាថ សួរមិនស្តីមៀមណី
ខ្លះចូលមើលថាយើ អ្នកនាងថ៍ក៏ក្រងិត ។ ខ្លះឆ្លើយថាងាយទេ សឹមយើង
កែឲ្យអស់ចិត្ត តិតសូនក្រមួនបិទ យកតែល្អឆើតមួយគ្រា ។ ខ្លះជេរ
ថាមីចោរ ស្តីឲ្យខ្មោលាភក្សមាយា មិនបេះគិតវែងនា អាណិតអ្នកឈឺ
ខ្លួនទំ ។ មេខ្លះឆ្លើយថាអើ ហង៍គ្រាន់បើមិនគួរគេនំ ឯយលេខហោរនឹងភ្ជួន
ខ្មោចអ្វីវាឆ្លើកញ្ជិត ។ បើកក្បួនបើកតម្រា មើលជាឲ្យអស់ចិត្ត
ប្រមុះអ្នកកញ្ជិត បិទក្រមួនជាប្តេ ? ។ មេមួយឆ្លើយទៅវិញ ថាអញ
ជ្រេញមេមុខឆ្កែ ខនេញាភក្សបែ ។ គ្មានគិតកែតរកថ្នាំ ។ ណ្តើយ
ចុះហង៍កុំស្តី មេអប្រិយស្តីសាំញ៉ាំ ជាដែកកក្តិក្តាំ ដើរចេញឆាប់
មេចង្រៃ ។ រីឯមេធន្វា រង៍វែកឈឺធ្ងន់ក្រៃ ស្រយង៍អស់សរសៃ
ពិសពើតចាប់ញ័រអស់ច្រោណ ។ ឯអស់ស្រីទាំងា ចាត់គ្នាត់សព្វ
ហ៊ាន យកតេឲ្យថ្នាំមកបាន ផ្សំថ្នាំបិទមិនបាត់ឈោម ។ ឃាត់ឈោម

មិនបាត់សោះ គ្រូចាំងអស់ឡើងដូចមាម សែកមន្តជាស់ឃាត់ឈាមមិ
ផ្សុំថ្នាំបិទមិនដល់សោះ ។ បាញ់ឈាមព្រួសតាសតេញ ហូរខ្លួរខ្ចាញ់
មកស្រស់ ។ ឆន្ទាថ្លង់ឮជសោះ ថ្លង់មុខស្ងាំងអាប់ស្មើ ។ ខុនណាង
ពួកអស់អ្នក មើលឃើញជាក់ឆ្ងល់អស់ក្តី ខ្លះថាឯងមើលវ៉ី ដូចស្នាម
មាត់កណ្តុរទាំ ។ មេមួយថាអញឆ្ងល់ តែមិនឃើញកណ្តុរទាំ កណ្តុរ
ម្តេចធំម៉ាំ ធាត់តែម្ខង់ជាច់កញ្ចែត ។ មេមួយអស់សំណើច ហាមាត់
សើចយកដៃបិទ ខ្លះថាវ៉ើយគោតចិត្ត ហាឥហាសើចមិនអន់ថ្លា ។
ឆន្ទាឈើចុកសៀត ដើរមកឆ្ងៀតអន្លះសា តើតថាប់សព្វកាយា តេឡ
អាតមង្គុំមិនបាត់ ។ តេឡថ្នាំបិទមិនបាន ឈឺញ័រប្រាណថ្នើមប្រមាត់
ចេញឈាមហូរមិនបាត់ ហូរខ្លួរខ្ចាញ់តេញកាយា ។ អស់តេឡថ្នាំ
អាតម ថែថប់ដំគាល់ប្រាជ្ញា អង្គុយស៊ីតែស្វា ឧបជង្គង់ដង្ហើមធំ ។
ឆន្ទាឈើខ្ចាំងក្រៃ ហាក់ហៀចស្ទួយដល់ស្រែកយំ ខ្លារខ្លែងជាច់ដុំ ។
ប្រុះនខៀលប្រែផ្កាប់ផ្ងារ ។ កម្មព្រោះប្រឹងសី ឲ្យញាក់ញ៊ីចោច
សាកា ឲ្យនាងរងវេទនា កម្មខ្លះឯងតាមថ្នី ។ ។ ឯស្តេច
កណ្តុរសេ ទាំហើយអរលោតចុះដី ចោលចូលរូងឃ្មុតខ្ចី ដល់
ហើយប្រាប់នាងសាកា ។ ថារមេឆន្ទានោះ អស់បានរស់ជាមនុស្សព្រ
បងទាំគ្រូរមុខ ដាច់ប្រមុះជ្រុះសៅហ្មង ។ ភាឈើខ្ចាំងស្រែកយំ

ដៃជាលដំទ្រូងមិនសើយ សម្ងេងយំឮល្ហើយ ដល់ថ្ងៃទៀតស្ងាច់មិន
ឈាន ។ ឯនាងសារិកាស្តាប់ កណ្តុរច្រោះតែយញ្ជ្រាច្រាណ តើតទុក្ខ
ទៀតមិនក្បាន្ត ថាទុះទុមេធន្ធា ។ វាប្រើអស់ពួកពលរកកណ្តុរ
ក្នុងគ្រឹហា ចើរឃើញកណ្តុរវ៉ា ឃើញតាំងខ្លួនអញនេះផង ។ ឥឡូវ
អញជុះស្ងាប គ្រប់ជាតអស់ហើយហោង ល្មមតែឲ្យកន្ទុង តំពីតយ
ពេលនេះណា ។ សារិកាគិតដូច្នោះ ហើយក្រោកចុះចរយាត្រា
អង្វរកណ្តុរថា អ្នកមានគុណចូនក្រៃស្រែក្រៃ ។ ដូចមាតាបិតា ថែរក្សា
ខ្ញុំសព្វថ្ងៃ ពុំគួរឲ្យឃ្លាតឃ្លៃ គួរតែទៅតបគុណអ្នក ។ ជាតជាតអស់ជីវិត
នៅនៃបច្ចិត្យវែនវ្រមក្ស តាល់ហ្មាំបំរើអ្នក ជាព្រះរៀមកជរេស្តា ។
តីមោះខ្ញុំចាម្តេ ដ្បិតខ្លួនខ្ញុំមានទោសា ធន្លាក៏ឬស្សា តាមពាធាធ្វើ
រាសខ្ញុំ ។ ហេតុនេះសូមក្រាបលា អម្ចាស់ជាប្អូនសូមស៊ុ អនុញ្ញាត
បើកឲ្យខ្ញុំ ចានចេញចាកភ្លូចពីតយ ។ កណ្តុរស្តាប់សារិកា លាអាត្ម
ជូញ្ចុះវៃ ឱ្យកខ្លួលអួលហួតយ ទឹកអាណិតនាងសារិកា ។ ដោយ
ថ្នាប់នៅប្រក្រតី ឲ្យចំណីបរិភោគ្ន ថ្នាប់ថែថ្នាប់រក្ស ថ្នាប់សាន្តសុខ
កន្ទហួតយ ។ មិនដែលឲ្យលំបាក ចាបតោកយាំកដល់មួយថ្ងៃ ក្រែន
ដើរវង្វេងឆ្ងាយក្រៃ គ្មានអ្នកណាជូនជាគ្នា ។ ចំអេងស្ងាបនៅខ្ញី ដើរដោយ
ដីក្រែងជូនជា ប្រទេនឯមនុស្សម្នា រាចាប់យកធ្វើពោសតែរ ។ តិត

ហើយឃាត់ទៅថា ហៃប្អូនភ្លាជួនហូយ្យ សូមឃាត់ប្អូនមាសថ្ងៃ កុំឲ្យ
ចរចេញយាត្រា ។ ខ្ញុំប្អូនមិនទាន់សះ ជាស្រឡះក្នឹកកាយ ចំរើន
ស្វាបក្តីណា នៅខ្លីខន់ហើរពុំបាន ។ បងឃាត់ប្អូនមាសស្នេហ៍ ទំរាំ
តែជាក្នឹកប្រាណ មួយក្រែងដើរអត់ឃ្លាន គ្មានចំណីបរិភោគ្គ ។ សារិ-
កាស្តាប់ហើយថា សូមមេត្តាខ្ញុំសូមលា កុំម្ចាស់ព្រួយចិត្ត ឥឡូវខ្ញុំ
ក្រែងអត់ឃ្លាន ។ លែងតែទ្រូងបើកទុំ ហើយសូមសុំតរប្រថាន ឲ្យខ្ញុំ
អម្ចាស់មាន ការសុខស្រួលបើយាត្រា ។ កណ្តុរឃាត់សាសង ពីរ
បីដងដោយមេត្តា រឹងខាងសារិកា ពុំព្រមនៅជូនបង្ហុនឯង ។ កណ្តុរយក
ចំណី ទាំងពុំខ្វីឲ្យគាស្រ័យ បរិភោគត្អែតត្អន់ក្រៃ លុះព្រលប់យប់
សន្ធ្យា ។ សារិកាលាវិលចរ កណ្តុរសឲ្យបរិភោគ ហៃបក្សីសារិកា
ជូនដំណើរទាំងពាក្រ ។ ហៃមុខនាងក្រាំរយ មានហៃគ្រោយនាងបក្សី
បន្ទាប់ស្មៅក្តី កណ្តុរទាំងាមគា ។ គោះបីដឹងស់ជាប កណ្តុរច្រាប
ពាបស្មើគ្នា លើងដួចផ្លូវគ្នា ពីបុរាណរឿងប្រក្រតី ។ សារិកាតែវិលរក
នោះ ស្វាបខើបដុះនៅខន់ខ្លី ហេតុនោះនាងដើរដើ តាមកណ្តុរទាំ
មាគា ។ ដើរតាំងពីព្រលប់ មិនហ៊ានឈប់ឈរពេល ដើរដល់យប់
ងាយភ្លារ ចាំយាមល្បាតមិនដេកសោះ ។ ចេញតាមភ្លារពុំបាន ដើររុក
ពនរកចន្ទោះ រកច្រកគ្មានសូន្យសោះ សឹងកំពែងឥដ្ឋបាយអ ។ កំពែង

ប្រាំពីរដង់ ជាប់ជាក់ស្តាន់ឥដ្ឋលាយថ្ម គ្រប់ចែងលាយបាយអ រកបន្ទោះចេញពុំបាន ។ សារិកាគន់គិតថា ពាល់ប្រាជ្ញាឈប់សម្រាន្តកណ្តុរសតិតធ្មាន ទាំអស់ពលទាំបាយអ ។ ទាំឥដ្ឋជាក់ខ្ចាត់ខ្ចាយដើងតកាយកកេរថ្ម ឬបែកធ្លុះប្រហ ទាំសារិកាចូលចេញបាន ។ កណ្តុរទាំសារិកា ចរយោគ្រាដល់ក្រៅហាន កំពែងក្រៅប៉ុន្មាន កណ្តុរទាំងុះគ្មានសល់ ។ ប្រាំពីរដង់កំពែង ក្រាស់គួរស្មើនឹងដាយគិតយល់ កកេរជ្វាយគ្មានសល់ ធំទូលាយដាមាគ៌ ។ កណ្តុរជួនទាន់ពៅ ហួសលំនៅផ្ទះមនុស្សម្នា ចូលកន្លែងព្រៃអង្គា ឈើត្រសុំដង្កិល្អ ។ ទាន់លាស្តេចកណ្តុរសន្ធិមិលចិត្តស្មោះសរ កណ្តុរលាទាន់ចរ វិលមកនៅហានថេរបិត ។ លុះព្រឹកទាន់សារិកា រកព្រឹក្សាព្រៃស្បាតជិត លាក់ខ្លួនពួនទៅនិត្យស៊ីផ្លែឈើត្រួយស្មៅខ្ចី ។ ឆ្អែតឆ្អន់ស្កល់កន្ធឹចិត្ត លែងតយុតិតលុះកត្រី ទាន់ចេញដើរដោយដី រឿងពាល់យប់មិនឈប់ខាន ។ គម្រប់ ១០ ថ្ងៃច្បាស់ ជុះពេមគ្រាស់ហើរឡើងបាន ទាន់ហើរចេញចាកហានឆ្ពោះដម្រង់ព្រៃធំនោះ ។

ទំនឹងថ្ងៃឆ័ត្តនា គាចប្តូរស្បាចិត្តមិត្រទ្រុស្ត គាលកណ្តុរទាំនោះជាប់ច្រមុះជ្រុះបាត់ទៅ ។ គ្រូថ្នាំគ្រូអាគម ពាល់ស្តោះផ្ទុំស្មៀមនិត្យនៅ ដំបៅរូងពលជ្រៅ កលជាលក៏លង់ធម៌ហិមា ។ ទាន់លើកលា

ដល់ក្បែរ ដាច់សាច់ស្បែកជ្រុះគ្រាំគ្រា រដ៏ក្លិនរងើកវែងឆ្ងាយ ឈឺ
ខ្លួនធ្ងន់ដួលដាប ។ អត់ថ្នាយត្រប់ដប់ថ្ងៃ ស្លាំងស្គមក្រៃសម្បុរក្រហម
ក្លិនស្អុយជុំឆ្អែះឆ្អាប ដាចកំលាំងក្រាយជន្ម ។

ពីរឿងធ្លាស្ងាប់ ស្ទេះចែងចាប់ជួបពណិនា ថ្លែងពីនាងជាយ
សារិកាតែវាលហើរចោទ ។ នាងហើរខ្ទាបចំ លើឈើធំឈប់
សម្រាន្ត មានពស់កាចសាមខ្យ នៅក្នុងរូងឫទ្ធឈើនោះ ពស់
ឃើញនាងសារិកា ចិត្តឫស្យាកាចក្រៃសុ្ត ចង់ចឹកសារិកានោះ យក
ចរិកាគជាកោជន ។ កាលនោះមានបក្សី ក្នុងចាលីថាសកុណា
បើប្រែឲ្យពិស្តារ ជាពាក្យសត្វថាតាជក់ ។ លលាដ៍ក្បាលរលើង
ធំខ្លួនដឹងគ្មានជុះសក់ សត្វនោះពេញអាក្រក់ ដើរវែងពេកខ្លួនដំហរ ។
មានសាច់មួយដុំទើរ ដួចគេផ្ញើរនៅដើមក បុកណាស្រដីត ត្រូវចំក្បូន
ចៅថាយាមក ។ តាជក់ហើរមកចំ ជិតខ្លួនឯងសារិកា ឃើញ
ពស់ចិត្តឫស្យា ចង់ចឹកនាងសារិកានោះ ។ តាជក់លោតទៅចឹក
ចាប់ប្រញឹកទឹងចំពុះ រឹងពស់វែកនោះ ចឹកតាជក់ជាសត្រូវ ។
សត្វពីរប្រទាំគ្នា ស្ទើតាលចិត្តឃោរឃៅ ប្រទាំគ្នាយូរទៅ ស្ងាប់-
ភ័ន្តពីរកាលនោះណា ។ សារិកាមើលយល់ជាក់ គិតក្បាក់
ក្បៀកាយា នាងហើរតក្រឹក្សា ដល់ពេលតំសម្រាន្ត ។ នាងនឹក

ដល់កស្តា អួលទុកឥតស្រាកស្រាន្ត ថាទុមហាក្សត្រកក្ខន្ធ ស្តេចប្រគាត
ទ័ហានណា ។ ឬមួយក្សត្រទុត្តម វិលចរមកដរដ្ឋា ទ្រង់ខ្ញុំខ្ញាច
ផ្សា តើតទុក្ខត្រួតព្រួតច្រើនក្រៃ ។ ទុក្ខមួយព្រោះកំណើត ក្លាយមក
តើតជាបក្សី ទុក្ខមួយក្រាត់ស្លាមី ត្រាត់អស់ស្មុំក្រមបរាំរ ។
ទុក្ខមួយមិនដឹងផ្លូវ ទីលំនៅទេពធីតា ដែលប្រាសប្រាណអាត្ម
ន៏ឯសុំថ្នាំលេបប្រែប្រាណ ។ ឲ្យក្លាយជាមនុស្សា ន៏ឯយាត្រាវិលទៅ
ហាន ឥឡូវជាតិរច្ឆាន រងលំបាកសែនវេទនា ។

បទពំនោល

តេជៈហោតុបុណ្យសម្ភារ បុណ្យទានឯធីតា វិសាលវិសេសថ្កើងថ្កល់ ។
កក្រើកអំពើតទៅដល់ ក្រឡាកម្ពល· មណ្ឌលមន្ទីរគោស្នា ។ អម្រិះអង្គ
ឥន្ទ្រចណ្ហា ក្តៅក្តាត់មហិមា ឧបមាដូចអគ្គី ។ អុជអាលកេលកលញ់
ញ៉ី ក្តួលក្តៅខែនទី ន៏ឯផ្ទំសំកន្ធំស្កល់ ។ ចៃរបើតចិត្តចក្តុទៅយល់
ឧតទាំងមណ្ឌល សកលជម្ពូទ្វីប ។ ឧត្តសព្វយល់ទាំងសាវ័កា ខ្លួញចល់
ទុក្ខា អនាថអាណិតអង្គឯង ។ លុទ្ធដ៏លន្ទោចកណ្តាង ក្នុងព្រៃធំធេង
ជាសត្វតិរច្ឆានបក្សី ។ ហេតុនាងបានសាងជាម៉ី សម្តេចគោសីយ កំ
ជ្រាបសព្វត្រួតប្រគារ ។ ថាទានដ៏ជាពុទ្ធមាតា ម្តេចប្រែក្រឡា ជាសត្វ
តិរច្ឆានប្រាសព្រាត់ ។ ពុំគួរទ្បើរទៅជាសត្វ តិរច្ឆានសូន្យស្មាត់ គួរអញ

សង្គ្រោះធីតា ។ ឲ្យទាន់កើតជាមនុស្ស តែតស្រេចយាត្រា ហ៊ានហោះ
ចេញចាកវិមាន ។ មកដល់ព្រៃធំទំហ៊ាន និម្មិតប្រែប្រាណ ជាខ្លាធំធាត់
មហិមា ។ ចំពោះមុខនាងជាយា ឯនាងសារិកា កំពុងយល់ខ្លាធំនោះ ។
ឯខ្លាឃើញនាងពុតស្មោះ ទើបខ្លាលោតផ្លោះ ស្ទុះឡើងលើជ្រៃសាខា ។
ស៊ីផ្លែជ្រៃមែកបច្ចិមា ក្លាយជាបក្សា នាមាពុំបានសំដែង ។ បក្សា
មហិមាទះវែង ហើរទំលោតលេង មែកខាងទិសតូរទិសា ។ ចឹកស៊ីផ្លែ
ជ្រៃសាខា ប្រែក្លាយកាយា ជាប្រើសទាសមែន្ទន្តី ។ ប្រើសទាសមែរ
ចោលទៀតទៅ ស៊ីផ្លែជ្រៃទៅ មែកខាងឯបូព៌ទិសា ។ ប្រើសប្រែខ្លួន
ក្លាយជាស្វា ស្វាលោតម៉ឺងា ទៅមែកទក្សិណឈប់ទៅ ។ បែរផ្លែ
មែកនោះស៊ីទៅ ប្រែប្រាណដោយទៅ អានុភាពទុសចរិតថ្លា ។ ក្លាយ
ខ្លួនកើតជាមនុស្ស ល្អល្អះជ្រះថ្លា ក្រមុំកម្ងាំឆិនឆិយ ។ កាយាល្អ
ល្អះល្មមល្មៃ មុខមាត់ល្អក្រៃ ត្រចង៉ែត្រចះជ្រះថ្លា ។ មានធ្មឹមអម្ពរកស្ត្រា
ស្រោចទៅកាយា ដ៏ក្រាលរន្ធាលព្រោងព្រាយ ។ សង្ឃឹគ្រឿងទិព្វទេស
តើតធាយ ជាំតួងភ្ញីសាយ តែពុំស្ទុះកាន្តមុត្តា ។ ស្រេចហើយ
ចុះចាកត្រីក្សា ដើរដោយអន្លូ ចាន់តិចនិម្មិតចាត់ទៅ ។ ប្រែជាអង្គឥន្ទ
ចមរៅ ហ៊ានហោះឡើងទៅ វិមានសួគ៌តែត្រឹមឫក ។តំណក្បាលឆិ ឆិស្ងា
រនាងសារិកា កំពុងយល់សត្វសេចក្តី ។ នាងគិតថាអង្គកោសីយ អម្រិន្ទ-

ដ៏ឥតិ ហ៊ិចហោះចុះចាកសួគ៌ ។ មកប្រាប់នូវសេចក្តីសោក ឲ្យអញចាន់ជា
មនុស្សដួចអំពីមុនមិញ ។ ចើញគួរតែបរីមញ្ញ ស៊ីផ្ទៃដ្រៃវិញ ខឹងចាន់ដួច
ចិត្តប្រាថ្នា ។ តិតហើយហើរតើត្រឹកឡូ ខំលើសាខា មែកដ្រៃចស្ងួមនោះ
ឯង ។ ចឹកស៊ីផ្ទៃដ្រៃខ្ចុំខែង ក្លាយខ្លួនជាត់ស្តួង ជាសត្វបក្សាធំក្រៃ ។
បក្សាហ៊ិចហើរវិលវៃ ទៅចំមែកដ្រៃ នៃខាងទិត្តរចិសា ។ ចឹកផ្ទៃដ្រៃមែក
ទិត្តក លេចទៅកាលណា កំកើតជាប្រើសមាសផ្លែ ។ ប្រើសមាសសោ
សោតទៀតទៅ ស៊ីផ្ទៃដ្រៃនៅ មែកខាងឯបូពិចិសា ។ ប្រែកាយក្លាយ
កើតជាស្វា ស្វាសោតសោះសា ទៅមែកចិសរក្សិណាទ័ ។ ស្វាចេះ
ប្រឡែផ្ទៃស៊ី ប្រែកាយទ្រីយ ជាមនុស្សស្រស់ស្រៀកាយា ។ ដួងកត្តុ
ត្រចះដ្រះថ្ងៃ មានត្រឹងរចនា ប្រជាប់ស្រាប់ស្រេចត្រចង់ ។ តបកាយ
តើតនាយចភ្លឹង ល្អាសល្អង់អស់អង្គ ប្រៀចដូចស្រីទេពអប្សរ ។ ខាង
មានចិត្តក្សត្តត្រេកអរ ទើបតិតការក្រ ឯក្រោយក្រែងពុំសប្បាយ ។ តួរិត
កេរជាមនុស្សក្រចកាយ ដើរដោយព្រៃឡាយ វិលវិញទៅហានគាត្ត ។
ខឹងកើតចោសចៃម៉ែនជា តួរអញកោត្តា ឲ្យក្លាយជាបក្សាវៃ ។ តិតហើយ
ខាងចេះផ្ទៃដ្រៃ ត្រប់មែកដទៃ ហើយវេចខ្ចុកផ្សែងពីគ្នា ។ វេចស្រេច
សម្តេចជាយា ខាងយាងចាត ទៅចេះផ្ទៃដ្រៃខ្ចុំ ។ ។ ចរិកោតផ្លែម
ដូចចឹតឃ្មុំ ក្លិនក្រៃចដ៏ធំ ក្រអូបក្រនៃចល្អែចល្អឆ ។ ខាងសោយ

ស្តប់ស្តល់កន្ទុង ប្រែកាយសៅហ្មង ជាបក្សីធំមហិមា ។ រោមស្អាត
ដូចអង្គា ភ្លឺផ្លេកសោភា ប្រដូចខ្លួសតូចដូចគ្នា ។ ខេត្រថ្ងាជួចកែវ
មណីវង្ស រស្មីរះចង់ រលើបរលេចស្រស់ស្រេច ។ ហើយនាងចឹក
តាំបង្ខូច ផ្លែត្រែដែលវេច ហើយហើរឡើងលើវេហាស៍ ។ រស្មី
ឆ្នុះឆ្លាសព្យាមា សួស្តីសមសោភា ត្រចះត្រចង់អស់ប្រាណ ។
នាងហើរត្រាច់ត្រង់ទៅមាន ព្រឹក្សត្រៃព្រហ្មិមតាន្ត ជាន់ដល់អាស្រម
សាលា ។ តាបសទ្រង់ព្រឹទ្ធស័ល សន្ទុតនាមា ព្រះមិត្តាជនឥសី ។
មានស្រះស្រង់ជោកទូរណី ខៀបទឹកកុដី ទឹកថ្លាឥតព្រាំស្មៅផង ។
ឈូកដុះកន្ទុងស្រះកន្ទុង ផ្កាដូចតេចង ដំប្រាលរន្ធាលតាសរពាញ ។
មច្ឆាតជាក្រឹមក្រាញ់ ផ្ងោងផ្ងក់រៀលលេញ ហែចហែលហិចហក់
ត្រៀបត្រា ។ នាងចុះដល់ដីធរ៉ា ស៊ីផ្លែត្រក់ក្សា ដែលវេចតាំនាំមក
នោះ ។ ផ្លែមែកខក្សីណចំពោះ ប្រាណប្រែស្មាន់ស្មោះ ជាមនុស្ស
ល្អអស់កាយា ។ ហាក់ដូចស្រីខេពកញ្ញា សួតនៃត្រែត្រឹងរ៉ា មានត្រឿង
ប្រដាប់អស់អង្គ ។ ស្រេចនាងចរចូលត្រាច់ត្រង់ អាស្រមទឹតង៉
ទឹកុដឥសីស័លា ។ ដើរដល់នាងថ្វាយនមស្ការ ស្រេចហើយឆ័តា
នាងតង់ទីមួយគួរសម ។ ឥសីឃើលនាងទុត្តម មកថ្វាយបង្គំ តំសួរ
ដោយបទថ្លៃ ។ តនោ អាគតាសិ ប្រែជាសេចក្តី ថាហៃទេវ

សិតា ។ ជួនកន្ត្រែអ្នកស្នងប្រាប់ថា នើតនាយតាយា ប្រកបដោយស្រី
សួស្តី ។ នាមអ្នកនាងតើឈ្មោះអ្វី នាងមកអំពី ជនបទនគរហ៊ានណា ។
ទើបនាងចង្អុលធ្វើយថា ខ្ញុំព្រះករុណា មកពីវិទេសពស្ត្រាដ្ឋ ។ ឥសីសួរ
ទៀតទៅថ្លាត់ ហេតុម្តេចប្រាសព្រាត់ ស្វាមីមាតាបិតា ។ តាំណ្តែនតែឯង
ឯកា តើមានប្រាថ្នា មកដល់ហ៊ានទេះរកអ្វី ។ នាងថាបពិត្រឥសី
ខ្លួនខ្ញុំក្រក្រី ពុំមានមាតាបិតា ។ ជាតិពុំនាក់អាត្មា ខ្លួនខ្ញុំនេះជា
មហេសីស្តេចវិទេសពស្ត្រ ។ សត្រូវផ្លាញខ្ញុំវិនាស ខ្ញុំព្រាត់ឱពស
មាតាបិតាស្វាមី ។ ខ្ញុំតែចេញបាតបុរី សូមពឹងបារមី ព្រះអង្គសូម
ទ្រង់មេត្តា ។ ព្រះអង្គជាម្ចាស់សិរសា ទុកជាបិតា រក្សាចិញ្ចឹមខ្ញុំផង ។
ទុកជាទាសីទៀហោង សូមជ្រែកគ្រែមល្អង ធួលព្រះបាទករុណា ។
ឥសីស្តាប់នាងធីតា អង្វរគាត្មា សូមជាតិពីងអស្រ័យ ។ នាងនេះ
ពុំពាស្ត្រីស័យ ជាមហេសីថ្លៃ ឥសីមានព្រះមេត្តា ។ ទើបថ្លាយព្រះពរ
សួរថា មាតាបិតា ហេតុម្តេចពុំមានជួបជុំ ។ ស្វាមីម្តេចព្រាត់សូន្យ
សោះ ចូរប្រាប់ដោយស្មោះ ចង់ដឹងដំណើរនោះណា ។ នាងស្តាប់
ឥសីសួរសោះ នាងទូលទៅថា រៀបរាប់អំពីដើមជាន ។ ពីកាលនាង
នៅពជ្ឈាន សព្វត្រប់ឥតមាន ដូចមានខ្ញុំនានមុនស្រាប់ ។ ព្រះមិត្តាជិន
ចាន់ស្តាប់ នាងទូលរៀបរាប់ សព្វត្រប់ឥតខ្វះត្រង់ណា ។

(នៅមានត)

រឿងព្រេងអាក៉ាប់

ចែងអំពីលាសរបស់តាស៊ុក

ភិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុពត

ប្រែពីភាសាអង់គ្លេស

> អ្នកណាល្អបមាសអ្នកដំណើរ ?
> មានតែមនុស្សពីរនាក់ទេ ដែលបានដឹង,
> ហើយម្នាក់នោះ មិនអាចនិយាយបានឡើយ ។

ខ្ញុំ (១) បានធ្វើដំណើរកាត់វាលខ្សាច់ ជាមួយលោកតាស៊ុក មាំហាមួដ អ៊ុបជិន មូសា ព្រមទាំងអ្នកដំណើរកាត់វាលខ្សាច់ចំនួន ១៩ នាក់ ទឹងអូដ្ឋ ៨០ ។

តាស៊ុក ជាមនុស្សចាស់ម្នាក់យ៉ាងវែងវែង, មានក្អែកភ្នែងងឹតគួរខ្លាច ទឹងមានពុកចង្កាសស្គុះ ។ ការបង្គាប់បញ្ជារបស់គាត់ទៅលើអ្នកដំណើរ

១.ពាក្យថា «ខ្ញុំ» នេះ ជាសំដីរបស់អ្នកដំណើរម្នាក់ ដែលបានធ្វើដំណើរកាត់វាលខ្សាច់ ជាមួយតាស៊ុក . . . . . នេះ ។

ក់លក្ខណ៍ គឺជាច្បាប់មួយ ដែលអ្នកដំណើរត្រូវស្តាប់-ដឹង ។

តាស៊ុក ដែលមានពុកមាត់ពុកចង្កាខ្មៅនេះ ជិះលាធំមួយពណ៌ស ហើយលានេះ កំប៊ុនប្រុសច់ដែរ ។ តាស៊ុក ជាពាក់អាទស្រឡាញ់ ក់ ដូចជាសំឡាញ់តាត់ ។ ឲ្យតម្លៃស្មើនឹងតាត់ ។ តាត់ទឹងលានេះ ស្ទើរតែនៅជាមួយគ្នាជានិច្ចកាលថ្ងៃ, ដេកក្នុងទុស្សកុដិ (ខ្ទមសំពត់) ជាមួយគ្នាកាលយប់ ។

ខ្ញុំបានយកទៅជាមួយខ្លួនខ្ញុំ នូវមាសចំនួន ៨០ ដុំ ដែលខ្ញុំបានពុក កន្ទបាំបស្បែករបស់ខ្ញុំ ។ ពេលយប់ៗ ខ្ញុំដាក់ហឺបមាសនោះក្នុងទុស្សកុដិ របស់ខ្ញុំ, ហើយខ្ញុំតែងដាក់ដៃទៅលើហឺបនោះកាលព្រឹក ដើម្បីឲ្យដឹងថា «វានៅទេឬបាត់ទៅហើយ» ។ នៅព្រឹកទី ៩ ស្រាប់តែហឺបនោះ បាត់ពីកន្លែងតែម្តង! ។ ខ្ញុំបានបួលទៅរកលោកតាស៊ុកភ្លាម ហើយ និយាយទៅកាន់តាត់ថា ៖

-ម៉ាហ្គូដ អ៊ុបចិន មូសា! ចំនួន ៨ ថ្ងៃហើយ ដែលខ្លួនខ្ញុំជាក្មេវ របស់លោក, ខ្ញុំសូមសម្តែងនូវគតញ្ញូគមដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ចំពោះមេត្រី ភាពរបស់លោក ។

អ៊ុបចិន មូសា ដាក់ដៃទៅលើក្បូរគាត់ហើយនិយាយថា ៖

-ការផ្តល់មេត្រីភាពចំពោះអតិថិជន ជាសេចក្តីសោមនស្សមួយដ៏

ជ្រាលជ្រៅ ហើយមានជាទិច្ចកឋិនខ្លួនខ្ញុំ ។

ខ្ញុំនិយាយតទៅគាត់វិញថា :

ខ្ញុំចាប់ មានសេចក្តីសោកស្តាយនឹងជំពប់លោត ទ្បើចាប់ជ្រាបថា : ឥឡូវនេះ ខ្ញុំចាប់ព្រួយចិត្តខ្លាំនិងណាស់ ហើយដោយខ្ញុំជាក្បៀវ ខ្ញុំគោងតែជំពប់លោតឲ្យជ្រាបអំពីការព្រួយនេះ ។

ពេលនោះ ខ្ញុំចាប់ជំពប់គាត់ អំពីការចាត់ហ៊ីបមាស ដែលមានមាស ៨០ ដុំទៅខាងក្នុងនោះ ។ គាត់សួរខ្ញុំពីរ-បីសំនួរ រួចអង្គុយច្បូតពុកចង្កាដោយស្ងាត់ស្ងៀម ។ ទីបំផុតគាត់ពោលថា ៖

-ថ្ងៃនេះ អ្នកដំណើរវាលទ្បាច់ចាំងអស់គ្នា មុខតែឥតបញ្ជាទៅណាមកណា តិចំរេ, មុនគេលល្ងាចនេះ អ្នកឯងនឹងចាប់ឃើញមាសរបស់ខ្លួនវិញមិនខាន ។

មួយរំពេចក្រោយមក ចាហុនកៈរបស់ខ្ញុំនោះ ចាប់ដើរចេញពីជំរំតែម្នាក់ឯង, ថ្ងៃជ្រេរទើបគាត់និវត្តវិញ ។ ហាមទ្រាមអ្នកដំណើរចាំងអស់នោះ កុំឲ្យយកហេតុការណ៍ផ្សេង ។ ទៅកន្លែងដែលគាត់រួចគាស៊ុកចាប់ចូលខ្លួនចាប់ទៅក្នុងទុស្សកុដិរបស់គាត់ ហើយចិត្តម្ចាស់ជិតខ្ញុំចេះតែច្រួលច្របល់ចិត្ត ពីមាសរបស់ខ្ញុំមិនឈប់ឈរសោះ ។ ខ្ញុំសង្ឃឹមថា មានតែមនុស្សម្នាក់ទេ ដែលអាចរកមាសនោះឲ្យឃើញ

ដល់ខ្ញុំបាទ, ឥឡូវស្រាប់តែគាត់ទៅសំពន្ធក្តងខ្សែក្រវាត់របស់គាត់ធ្វើ
ព្រងើយ !

ប៉ុន្តែ ក្រោយវេលាយូរក្តី បាបាទកៈរបស់ខ្ញុំ បានចេញ
សន្សឹមៗ ពីខ្សែក្រវាត់របស់គាត់មកក្រៅវិញ ដោយស្រែកគាត់ឆេតឆាយ
ជាទីបំផុត ។ គាត់បានទៅអង្គុយលើកំពូលគំនរហឹបដែលនៅចំកណ្តាល
ជំរំ ហើយបង្អាប់ខ្ញុំឲ្យអង្គុយក្បែរគាត់ក្នុងទីនោះ ។ ពេលនោះ ក្នុងសម្ងំ
ដ៏មធ្យត់របស់គាត់ គាត់ពោលថា :

-ទៅហៅមនុស្សចាំងអស់មកឲ្យខ្ញុំ !

មនុស្សចាំងក្បាយចេញចាកអូដ្ឋរបស់ខ្លួន រួចមកឈរដំរៀបគ្នា
នៅមុខលោកតា ស៊ីក ។ ជួបជុំគ្នាហើយ,លោកតាស៊ីក អង្គុយស្ងប់ស្ងៀម
សម្ងំមើលទៅមនុស្សចាំងនោះ ហើយឮតពាកបង្គាប់របស់គាត់ ។ គាត់
ឥតមានការប្រញាប់ប្រញាល់អ្វីទេ ។ គាត់សំឡឹងមើលត្រង់មនុស្សចាំង
អស់ ក្នុងពេលដ៏យូរ ហើយមនុស្សចាំងនោះ ក៏បានសម្លឹងមើលមកគាត់
វិញដោយស្ងប់ស្ងៀមដែរ ។ ទីបំផុតគាត់ពោលថា :

-ថ្ងៃនេះ មានការកង្វល់ខ្លះ បានកើតឡើងដល់ក្មេវរបស់ខ្ញុំ គឺ
អ្នកដំណើរនេះឯង (គាត់ចង្អុលត្រង់) ។ លួចគេជាអំពើទក្រិដ្ឋមួយ,
ហើយបើអ្នកណាលួចអ្វីៗ ពីក្មេវ បទទក្រិដ្ឋតែតែងត្រូវថ្លៃប្រាំពីរដង

ទៅទៀត, អ្នកដំណើរនេះ បានឲ្យសំបុត្រខ្លួនគាត់ (កូនការកម្មវត្ថុ) ចំពោះខ្ញុំ; មានជនខ្លះបានលួចវត្ថុគាត់ នៅក្នុងអាសយដ្ឋានរបស់ខ្ញុំ, ដោយហេតុតែគ្មានអ្នកណាមួយ ដែលបើកនៅខាងក្រៅចូលមកក្បែរជំរៅយើង, ចោរដែលលួចអ្នកដំណើរនេះ គឺបើកនៅខាងមុខខ្ញុំក្នុងពេលនេះឯង វាកំពុងតែឈរនៅមុខខ្ញុំ ក្នុងពេលដែលខ្ញុំកំពុងនិយាយនេះ ហើយវាគិតថា វាអាចលាក់នូវបទទ្រង់ដ្ឋនេះបាន ។

សម្ដេងរបស់តាស៊ុក កាន់តែលាន់ឮខ្លាំងឡើង។ លាយជាមួយកំហឹង នៅពេលដែលគាត់និយាយពីបទទ្រង់ដ្ឋនេះ ។ គាត់និយាយទៀតថា:

-អាចិទេពខ្លួនព្រះអង្គ ទឹងប្រាប់គាត់ឲ្យឃើញនូវចោរហើយនឹងមាសមកវិញមិនខាន ។

រួចហើយ សំឡេងតាស៊ុក ត្រឡប់ជាស្ងប់ស្ងាត់ រួចបែបឡើងមធ្យឹតម្ដងទៀត ។ ប្លូតពុកចង្កាហើយ គាត់បន្តពាក្យទៅមុខទៀតថា:

-លាស ដែលនៅក្នុងទុស្សកុដិរបស់ខ្ញុំ មិនមែនជាសត្វសាមញ្ញទេ គឺជាជាសត្វតំណាងដោយផ្ទាល់អំពីលា ដែលព្រះ មោហាមេដ ទ្រង់ជិះ ។ លារបស់ខ្ញុំ ជាសត្វមួយចេះណាស់,វាស្គាល់សច្ចៈ, វាតែងប្រាប់ខ្ញុំនូវពាក្យសច្ចៈជានិច្ច ពីព្រោះអាចិទេពបានប្រាប់វាអំពីកិច្ចការពិត ។ មែនទេ តែម្យ៉ាង ។

-តាស៊ុក ឈប់និយាយមួយភាពី រួចសម្លឹងមើលគ្រប់មនុស្សទាំងអស់នោះ ហើយនិយាយបន្តទៀតៈ

-លាវបស់ខ្ញុំ មុនតែនឹងប្រាប់ខ្ញុំឲ្យដឹងថា អ្នកណាដែលលួចមាសអ្នកដំណើរនេះមិនខាន; ចា៎ ! លាមិនអាចនិយាយភាសាយើងចានេះ ប៉ុន្តែ គាលណាវានិយាយមកគេខ្ញុំតាមភាសាវ៉ា ខ្ញុំយល់ចានជានិច្ច ។ ឥឡូវនេះ ខ្ញុំសូមឲ្យអ្នកទាំងអស់គ្នា ចូលទៅក្នុងទុស្សកុដិរបស់ខ្ញុំ ម្នាក់ម្តងៗ រួចបិទគម្របវាឲ្យជិត កុំឲ្យអ្នកណាមើលឃើញឲ្យសោះវៀរលែងតែលាខ្ញុំ នឹងព្រះគាត់ទេតប៉ុណ្ណោះ, រួចហើយចូរចាប់កន្ទុយលាវបស់ខ្ញុំ ។ គាលបើដៃឥតគេស ទៅប៉ះនឹងកន្ទុយលានោះ ពនឹងបិតនៅស្ងប់ស្ងៀម, ប៉ុន្តែគាលបើដៃវបស់ចោរទៅប៉ះវិញ លានោះនឹងនិយាយមកកាន់យើងខ្លួនឯងភ្លាមអស់ (នៃនចោរនោះ) តាមភាសាវ៉ា ហើយយើងនឹងចាប់យកចោរនោះមកប្រហារជីវិតចោលភ្លាម ដោយឥតករុណាឡើយ ។

-និយាយរួច, តាស៊ុក ចានបង្គាប់មនុស្សដែលបិតនៅខាងក្រៅឲ្យទៅមុនគេ ។ មនុស្សនោះ កំបួលទៅក្នុងទុស្សកុដិតាស៊ុក, បិទគម្របជិត ហើយបន្តាប់ពីរណៈស្ងប់ស្ងៀមមួយភ្លែតមក កំចានចេញមកវិញ ។

មនុស្សទី២ ចានចូលទៅ....រួចចេញមកវិញ , រួចដល់វេនមនុស្សទី៣ ..... ១២ នាក់ ចានចូល រួចចេញមកវិញហើយ ប៉ុន្តែនៅតែ

គ្មានសំឡេងអ្វីលាន់ចេញមកសោះ ។

មនុស្សទី១៣....១៤....១៥....១៦; នៅតែមនុស្ស ៣ នាក់ទៀត
ទេ, ...ទី១៧....១៨....។ ឥឡូវនៅតែមនុស្សម្នាក់ទៀតទេ, គាត់ទី
១៨ នេះ បានចូលទៅកន្លែងមនុស្សកុដិ ។

តាមពិតគួរតែមានសំឡេងអ្វីចេញពីមនុស្សកុដិរបស់តាស៊ុក ! តែ
ចុះសោះទី ១៨ នេះ ចូលទៅហើយ ចេញមកវិញ ក៏នៅតែគ្មានសំឡេងអ្វី
លាន់ចេញមក ។ ដូច្នេះហើយ ឃើញថាលាគ្មានការរាំងវែ ដូច
តាស៊ុក អួតនោះសោះឡើយ ។

ប៉ុន្តែ តាម៉ាហមូដ អ៊ុបប៊ុន មូសា និយាយមកកាន់ខ្ញុំដោយស្ងាត់
ថា :

-កុំបារម្ភអ្វីឡើយសោះ, ការនេះវាយ៉ាងហ្នឹងហើយ, អ្នកឯង មុខតែ
ឆឹងបានឃើញទូរហឹបមាសវិញជាក្រុកជ ។

មនុស្សពាំងឆ្ងាយ មកនៅពីមុខគាត់ម្ខងទៀត រួចគេអង្គុយចុះ ។

- ឈរឡើង ! (តាស៊ុកបង្គាប់) ។ មនុស្សពាំងអស់ក៏ធ្វើតាម
រួចគាត់បង្គាប់ទៀតថា :

- សម្លេកដៃត្រង់ទៅមុខត្រប់គ្នា, ហើយលាផ្ងារជាតដៃឡើងលើ ។
មនុស្សពាំងអស់ក៏ធ្វើតាម ។ ពេលនោះ តាស៊ុកដើរចុះពីគំនរ
ហឹប ដោយយឺតៗ ឆ្ពោះទៅមនុស្សទី ១ ក្នុងជួរ ។ គាត់ឈប់ចុះ ហើយ

ជាក់មុខទៅលើបុតវៃជនខោះ ។ បន្ទាប់ពីមួយនាទីមក គាត់ដើរទៅធ្វើ
របៀបនេះលើដៃមនុស្សទី ៦ ទៀត ។ ខ្ញុំទៅជាស្រឡាំងកាំង ដោយ
ឃើញគាត់ធ្វើយ៉ាំងនេះ ម្តងហើយ ម្តងទៀត ពីមួយទៅមួយតាមជួរ
មនុស្សទាំងនោះ ។ គាត់ធ្វើបែបនេះ រហូតទៅដល់មនុស្សទី ១២ ក៏
ស្រាប់តែគាត់ងើបមុខឡើង, ហួតជាវាភ្ញាក់ចេញមកហើយស្រែកសន្ធាប់ថា

-តាឯងហ្នឹងហើយ ដែលជាចោរគំរក់ បានលួចយកហឺបមាស,
អញសំខ្លះតាឯងឥឡូវហ្នឹង!

ជនពុំចុងតែ បានជាក់មុខចុះ, អង្វរសុំឲ្យគាត់គាណិត រួចវាស្ទុះដើរ
ឡើង ហើយគេចេញទៅក្រៅជំរំអ្នដ្ឋ ។ វាទៅគេចខាញ់ថ្មមួយដុំ ហើយ
ត្រឡប់មកវិញ ដោយយកហឺបមាសពីស្បែកខោះមកជាមួយផង ។

-ឲ្យទៅអ្នកដំណើរទៅ, (តាស៊ុកបង្គាប់) ។

ជនអតុសលបានប្រគល់ហឺបមាសខោះមកកន្លែងដែរ ហើយខ្ញុំបាន
ពិនិត្យឃើញថា មាសពាក់ ៨០ដុំ នៅតិចតួចតាំងអស់កន្លែងហឺបខោះ ។
ពេលបន្ទាប់ខោះ តាស៊ុក ឲ្យមនុស្ស ៦ នាក់សំពងចោរខោះ ។ មួយនាទី
ក្រោយមក ខ្ញុំសុំឲ្យគាត់គាណិតឈប់វាយវា ហើយតាមការបង្គាប់
អំពីជាប៉ាហ្មនកៈរបស់ខ្ញុំ ជន ៦ នាក់ខោះ បានបើកឲ្យវាទៅតាមតែចិត្តវា
ទៅវិញ ។ តាស៊ុក កិចលតាមនុស្សក្រុងរបស់គាត់ មនុស្សទាំងនោះ

តំត្រឡប់ទៅកាន់កន្លែងខ្លួនវិញដែរ ។

ខ្ញុំសប្បាយចិត្តណាស់ ដោយបានឃើញមាសរបស់ខ្ញុំ , ប៉ុន្តែខ្ញុំចង់ដឹងអំពីជាតុកូតអស្ចារ្យនេះជាពន់ពេក ។ កាលដែលយើងបន្តដំណើរទៅមុខទៀត នៅពេលថ្ងៃក្រោយមក ខ្ញុំបានសួរជាហូនកៈរបស់ខ្ញុំ សុំឲ្យគាត់ពន្យល់អំពីជាតុកូតនោះ ។

គាត់សំឡឹងមើលមុខខ្ញុំ, ញញឹកចង្អាចង្អូច និយាយមកកាន់ខ្ញុំថា ៖

-អ្នកឯង កុំនិយាយច្រាប់ពួកខ្ញុំឲ្យសោះណា !

-ចា៎ ! , (ខ្ញុំឆ្លើយ) ។

-ល្អហើយ, (គាត់ចាប់ផ្តើមបរិយាយ), កាលដែលខ្ញុំបិតនៅកន្លែងទុស្សកុដិរបស់ខ្ញុំ ពីមុនៗមុនៗ ខ្ញុំបានយក " ស្នឹកជ័រខាងវង " ទៅគ្រាំទឹក ។ កាលទឹកនោះ ប្រែក្លាយដូច ជ័រខាងវងហើយ ខ្ញុំបានយកកន្ទុយលា ទៅជ្រលក់គ្រាំវាឲ្យតាល់តែជាប់ក្លាយជ័រឡើងឈ្លុយ ទើបឈប់គ្រាំ ។ ក្រោយនោះ អ្នកចាំបានហើយថា មនុស្សគ្រប់គ្នា បានចូលទៅកន្លែងទុស្សកុដិរបស់ខ្ញុំ រួចចាប់ខ្លាញ់កន្ទុយលា, តាមពិតនោះ មានតែចោរទេ ដែលវាមិនហ៊ានចាប់ខ្លាញ់ ព្រោះខ្លាចលាខ្ញុំដឹងរឿងរបស់វា ។ ម្ល៉ោះហើយ ដៃរបស់វា ក៏ឥតជាប់ក្លិនជ័រខាងវង ដូចអ្នកឯទៀតឡើយ ។

រឿងព្រេងនិងរឿងបុរាណជាប៉ុនក្តីងមធ្យមសម័យ

(តទៅ)

លោក ង៉ែត-ប៊ុក ប្រែរៀបរៀង

រឿង ធ្មា - ជ្រើង

មានធ្មាមួយធំ សម្បុរខ្មៅ ដើរលបៗតាមទន្លាយដែលព្រះអង្គម្ចាស់ ហ៊ុយហ្សែនណាបេស្តីម៉ា នឹងស្នំឯកព្រះនាម អូតួយ៉ុ ធ្លាប់ទ្រង់យាងក្រសាលព្រះទ័យនៅទីនោះ ។ ធ្មានោះ បានទៅលាក់ខ្លួនចំតួនអាគារនៅក្នុងគុម្ពោតព្រៃ ដែលគេក្រឡេកទៅឃើញតន្ទីតែកវាចញ្ចាំងរស្មីមកដល់ ។

ព្រះអង្គម្ចាស់ទ្រង់ស្តេចមកដល់ទីនោះ ទ្រង់មានព្រះរាំណើរប្រកបដោយអកជនកាតដ៏ប្រសើរ ព្រះកន្ត្រៃទ្រង់បញ្ចេញនូវព្រះសុរសាតដ៏ថ្លៃបូណ៌ នឹងព្រះហ្ស៊ូទ័យប្រកបដោយមេត្តាករុណា ។ ឯព្រះនាងអូតួយ៉ុ ទ្រង់មានព្រះកន្ត្រៃវែង, មានពាងស្តើងល្អន់ល្អស, ព្រះនេត្រមានលំនាំផ្អែង, ព្រះនាសាស្តើង, ព្រះទស្ងួតបួលមទ្រង់ព្រះពស្ត្រព្រះកូសាពណ៌ប្រផេះ ។

ព្រះអង្គម្ចាស់ទតឃើញព្រះនាង ទ្រង់យាងតាមទន្លាយ ដែលមានរុក្ខជាតិតូច-ធំ នឹងដើមឈើយ៉ាងស្រស់បំព្រង ជាទីគួរទស្សនាពន់ពេក ។ កន

ពេលនោះ ជារដូវដែលបុប្ផាតូសស៊ុន បះញ្ជាញផ្កាក្រអូបឈ្ងុយឈ្ងប់ មានមែកប្រវែង ២០ ឬ ៣០ ម៉ែត្រ, ឯផ្កាមានពណ៌ស ស្វាយ ប្រមូលផ្កាកញ្ចុំមួលល្អមើលណាស់ ។

ព្រះនាងអូតូយ៉ូ ដែលជាវិញ្ញាណជំនាញ ទ្រង់ចាន់សូត្រនូវកាព្យនិទានមួយ ដោយព្រះសូរសៀងដ៏ពីរោះ ដែលកវីបណ្ឌិតឥសតវត្សរ៍ទី ៩ បានតែងថា :

តូស៊ីនវ៉ុក្កា បញ្ជាញបុប្ផា រីកស្រស់រុងរឿង
ត្រកាំងចំងាំបួ ម្ដេចមិនច្រឿងឡើង តាវ៉ៅទ្រង់ត្រឿង មិនស្រែកយំទៅ !

ព្រះអង្គម្ចាស់ទីឆ្ងាយព្រះនាងទ្រង់ឥតទៅវិញទៅមក ហើយក៏ទ្រង់ញញឹម ។

ក្នុងពេលនោះ ព្រះអង្គម្ចាស់ទីឆ្ងាយព្រះនាង ឥតដឹងថាមានឆ្មាខ្មៅមួយបានឃ្លាំមើល ហើយដើរតាមក្រោយព្រះអង្គសោះឡើយ ។

លុះឥតខ្សាន់រួចហើយ, ព្រះអង្គម្ចាស់ទីឆ្ងាយព្រះនាងអូតូយ៉ូទ្រង់ត្រឡប់មកព្រះដំណាក់វិញ ។

ក្នុងពាក់កណ្ដាលអធ្រាត្រនៃពេលនោះ ព្រះនាងអូតូយ៉ូទ្រង់សុបិននិមិត្តឃើញនាយពេជ្ឈឃាតម្នាក់កំពុងឃ្លាំមើលព្រះស្វាមី ហើយបំរុងនឹង

លោតទៅលើស្មាម៉ែនោះ, ព្រះនាងក៏ទ្រង់តេនឡើង ទ្រង់ញាប់ញ័រព្រះកាយជាខ្លាំង ទ្រង់បើកព្រះនេត្រចំតាទៅឃើញតម្លឹពីរមានរស្មីពណ៌ប្រផេះ ខៀវ លឿង ខៀវខ្ចី ។ គឺឆ្មាខ្មៅនោះឯង ដែលបានលបចូលទៅក្នុងក្រឡាព្រះបន្ទំ ហើយអង្គុយជិតសំរាំងព្រះនាងមិនចាំប្រិចភ្នែកសោះ ។

ទ្រង់ទតឃើញឆ្មាខ្មៅដូច្នោះ, ទ្រង់មានព្រះហឫទ័យតក់ស្លុតឥតឧបមា មានព្រះសេចក្តីភ័យស្រាក់ ទ្រង់បើកព្រះឧស្ឋបម្រុងនឹងស្រែកហៅឲ្យគេជួយ តែចំពង់ព្រះសូរដូចគេត្បាត រកឮសំឡេងក៏ម្ហឹមមិនបាន មានព្រះសារទីយមិនរួច ។ ព្រះនាងទ្រង់មិនអាចមានពេលនឹកាសនឹងបញ្ចេញកាយវិការបែបណាមួយសោះ ។ ស្រាប់តែឆ្មាខ្មៅនោះ លោតទៅចំព្រះស្មារង ហើយយកមាត់នឹងជើងវាភ្ញាក់ពីឃាដព្រះនាងទីវង្គតមួយរំពេច ។ ឆ្មាខ្មៅនោះ មានពលភាពអស្ចារ្យរាអួសព្រះសព្វព្រះនាងតាមយ៉ាងក្រៃចុះទៅកាន់ទន្សាយ ហើយមិនឲ្យនរណាឃើញស្នាមអួសថែមទៀត វាយកសាកសពទៅកប់នៅកន្លែងមួយយ៉ាងស្ងាត់ រាត្រឡប់វិលមកកាន់ក្រឡាព្រះបន្ទំព្រះនាងដែលនៅទំនេរ ហើយកាន់ភ្លាមរួបភ្លាមយមន្តអាគមឲ្យរួបជាព្រះនាងអួតយ៉ូ ។

មនុស្សពាលអស់ដែលចិត្តនៅទីនោះ មិនអាចដឹងបានខ្លួរការប្រែកាឡាវនៃឆ្មាខ្មៅទៅជាព្រះនាងអួតយ៉ូឡើយ, ព្រោះថា ព្រះនាងថ្មីនេះ

មានសណ្ឋានទ្រង់ទ្រាយដូចព្រះនាងអ្នកយ៉ូណាស់ ប៉ុន្តែតាំងតែព្រះនាងថ្មីនេះ គ្រាន់តែមានព្រះកាយខន់ល្អន់ល្អាសជាងមុន ព្រះនេត្រមានស្នេហ៍ភ្លឺចាំងចែងខ្លាំង ។

ចំណែក ព្រះអង្គម្ចាស់មិនបានជ្រាបនូវព្រឹត្តិការណ៍នេះសោះឡើយ ទ្រង់សព្វព្រះហឫទ័យចំពោះនាងនោះ កាន់តែខ្លាំងឡើង ។, ទ្រង់បានយាងកំសាន្តកន្លងទៅច្រើន ដែលមានភ្លាវតែស្ទុះស្ទាយពាសពេញ មានពណ៌ត្រចៃចៃ, នៅតាមវិថីច្រើនមានក្រាលដីខ្សាច់ ទើសស្ពានគួរជាទីរីករាយពន់ពេក ។

តែមិនយូរប៉ុន្មាន ស្រាប់តែព្រះអង្គម្ចាស់ទ្រង់មានព្រះរោគាពាធ, បើតាមពិតិត្យនូវព្រះរូបគ្មានមោះមៃអ្វីសោះ តែទ្រង់ចេះតែមានព្រះកាយពលថមថយជានិច្ច ព្រះភក្ត្រមានពណ៌ស្វាយ ព្រះក្រចាំងកំបានថយបន្តិចម្តងៗ ទ្រង់មិនស្រួលព្រះអង្គ ចេះតែអស់ព្រះកាយពលល្ហិតល្ហៃ ហើយទ្រង់ផ្ទំមិនលក់សោះ ។

ព្រះវរមាតាបិតា ទ្រង់បានត្រាស់បង្គាប់ឲ្យគ្រូពេទ្យមកពិនិត្យ នូវព្រះអាការរោគព្រះអង្គម្ចាស ។ គ្រូពេទ្យតាំងច្រើយ បានមកពិនិត្យមើលដោយហ្មត់ចត់ ខ្លះថ្វាយឧសថធ្យូង។ ខ្លះយកថ្នាំមកតឹតព្រះកាយតែគ្មានគ្រូពេទ្យណាមួយផ្សំឧសថធ្វើឲ្យសះស្បើយពីព្រះរោគបានឡើយ ។

ផ្ទុយទៅវិញ, ព្រះអាការកេតរបស់ព្រះអង្គម្ចាស់ រឹងរឹតតែមានអានុភាពខ្លាំងឡើងៗជាដរាប ។ ពេលយប់ទ្រង់ផ្ទំមិនលក់សោះ ទ្រង់មានព្រះទ័យរសាប់រសល់ជានិច្ច ។

ព្រះអង្គម្ចាស់ក្សត្រី ទ្រង់បានហៅអាមាត្យម្នាក់សំណាប់មកប្រឹក្សាកិច្ចមិនបានគ្រាន់, តមក បានចាត់ស្នំឲ្យក្រមការ ១០០ នាក់មកយាមល្បាត, ប៉ុន្តែ ក្នុងពេលយប់ដំបូង ស្នំក្រមការទាំងនោះ ស្ងាបតាំងពីល្ងាចរួចទាំងគ្នាឆ្មើងក្អែកដេកលក់គ្មានសល់ខ្លាក់ ។

យប់ទី ២ បានផ្ទាស់អ្នកយាម, អ្នកយាមថ្មីនេះ ក៏ដេកលក់ពីល្ងាចដែរ ។

យប់ទី ៣ ពួកអាមាត្យបានទាំងគ្នាចូលទៅយាម ប៉ុន្តែអត់ច្រំទឹងឯការដោកង្គុយពុំបាន ហាក់ដូចជាមានពលកាតអ្វីមួយមកសង្កត់ឲ្យដេកលក់ដែរ ។

គេបានសង្កេតពិនិត្យឃើញថា ក្នុង ១ យប់ៗ ព្រះកាយពលរបស់ព្រះអង្គម្ចាស់ ព្រះលោហិតចេះតែហូរចេញក្រៅបន្តិចម្តងៗ តែព្រះកាយព្រះអង្គគ្មានឃើញស្លាមរបួសអ្វីសោះ ។

ពីប្រឹក្សាសំណាប់របស់ព្រះអង្គម្ចាស់ ទីកទួលក្នុងចិត្តថា ប្រហែលជាព្រះអង្គម្ចាស់ខ្លួលគ្រោះថ្នាក់ដោយមន្តគាតមបិសាច ឬអ្នកតាកំមិនជឺង

ឬដោយមានខ្មោចព្រាយមកគេលយប់ ធ្វើបាបព្រះអង្គហើយ ទើបធ្វើព្រះ
កាយពលវេទនាព្រះអង្គឲ្យឋមឋយ យ៉ាងនេះ, ប្រសិនបើកព្រះសង្ឃសូត្រ
ធម៌, អាការពេគមោះ ខឹងជាសះស្បើយជាង ?

ខ្ញុំប្រឹក្សានេះ ឈ្មោះអ៊ីសាហាយ៉ាប៊ុយហ្សេន កំពុងទៅតាតពុទ្ធជីកា
លោកគ្រូ រីតេន តង់នៅព្រះវិហារម៉ាយូអិនចំពោះរឿងប្លែកនេះ ។

លោកគ្រូ រីតេន មានថេរដីកាថា លោកខឹងជួយដោះទុក្ខនេះល្បងមើល ។ ពេលសាយណ្ហសម័យ លោកគ្រូ រីតេន កំពុងបួងសួងដល់
តាតុកវេតាឲ្យបង្អុរទឹកសង្ឃឹត្ថ មកជ្រាយព្រះអង្គម្ចាស់នោះឲ្យបានជា
ស្បើយខ្លួនព្រះពេគាពនោះ ។

ពេលយប់មួយ លោកគ្រូ រីតេន សូត្រធម៌ដដែលចប់ លោកបានឮ
សម្លេងមួយដូចអណ្តូងប្របព្រះវិហារ, លោកបានបើកបង្អួចក្រឡេកមើល
ទៅឃើញភាហានម្នាក់បិតនៅក្នុងយុគាត ។ ភាហាននេះក្រោយ
ដែលបានលុបមុខជម្រះកាយស្អាតបាត ដោយទឹកអណ្តូងហើយ កំពុង
ក្បាលសំដែងគារវកិច្ចចំពោះព្រះពុទ្ធរូប ។

ក្នុងពេលយប់ស្ងាត់មោះ លោកគ្រូបានឮសំឡេងភាហាននោះ
សូត្រធម៌បួងសួងសុំឲ្យព្រះអង្គម្ចាស់ប៊ុហ្សិនណាបេស្ហ៊ីម៉ាបាន ខ្លួនខ្លួនវិសុទ្ធ
ភាពដ៏ចរិបូណ៌ឡើងវិញ ដោយតាប់ប្រសាក់ខាន់ចិត្ត ។

លោកគ្រូរ៉ាតេន មានចិត្តសោមនស្សពន់ពេក ដោយឃើញភាហាន
នេះ មានចិត្តភក្តីចំពោះចៅហ្វាយនាយ ។ លុះភាហាននេះបួងសួង
រួចហើយ, លោកគ្រូក៏ស្រែកហៅឲ្យភាហានចូលមកជាន់សំណាក់លោក ។
ភាហាននោះ ក៏ចូលទៅក្រាបថ្វាយបង្គំលោកគ្រូហើយនិយាយថា ៖

ខ្ញុំព្រះករុណាឈ្មោះ អ័ត្តសូជា , ជាភាហាននៃកងទ័ពរបស់ព្រះ
អង្គម្ចាស់ ហើយខ្ញុំព្រះករុណាចង់ប្តូជាជីវិត ដើម្បីថ្វាយព្រះអង្គជាទីបំផុត
ខ្ញុំព្រះករុណាមានបំណងចង់ថែទាំព្រះអង្គណាស់ តែខ្ញុំព្រះករុណាជា
ភាហានសាមញ្ញ ឥតកិត្តិយស មិនអាចបំពេញទៅដល់ព្រះអង្គបាន ព្រោះហេតុ
ដូច្នោះខ្ញុំព្រះករុណាគ្រាន់តែស្រែកអំពាវនាវ ចំពោះទេវតាឲ្យជួយថែទាំ
ព្រះអង្គ សូមព្រះអង្គទ្រង់មានសុភាពចិត្តបួងឧទ្ទិសវិញប៉ុណ្ណោះ ។

លោកគ្រូរ៉ាតេនមានតុទ្ធដីកាថា លោកមានវ័យទៅក្មេងណាស់ តែ
លោកមានចិត្តភក្តីចំពោះចៅហ្វាយនាយ . . . អាត្មាមានសេចក្តីគោរព
ស៊ើរលោកណាស់ . . . ; តើលោកជ្រាបឬទេ? ព្រះអង្គម្ចាស់ទ្រង់មាន
គាគារពតែបណា្តះ? តើលោកជ្រាបឬទេ? ព្រះអង្គម្ចាស់ទ្រង់សុចរិត
និម្មិត្តបែកពីធម្មតា នាំឲ្យព្រះអង្គថមថយព្រះកាយពល ហើយពួក
ភាហានដែលយាមព្រះអង្គ តែងនិទ្រាលក់ឥតដឹងខ្លួនសោះឡើយ ។

លោក អ័ត្តសូជា ក៏ទូលលោកគ្រូថា ប្រសិនជាព្រះអង្គម្ចាស់

ត្រូវអំពើគេទេដឹង ? ម្យ៉ាងទៀត ប្រហែលជាខ្ញុំព្រះករុណាអាចរកប៉ុណ្ណេះ
ទូវការនិទ្រានេះបាន ហើយខ្ញុំព្រះករុណានឹងអាចរកបុព្វហេតុនៃព្រះ
អាការរោគរបស់ព្រះអង្គបាន ។

លោកគ្រូមានពុទ្ធដីកាថា រឿងនេះ អាត្មាសូមប្រគល់ជូនទីប្រឹក្សា
ព្រះអង្គម្ចាស់ ។

លោក អ៊ីតូសូជាតបថា ខ្ញុំព្រះករុណា មានចិត្តត្រេកអរណាស់
ដោយលោកគ្រូមានព្រះទ័យល្អ, ខ្ញុំព្រះករុណា សូមសំដែងនូវគតញ្ញុ-
តាធម៌ចំពោះលោកគ្រូ សូមលោកគ្រូទូលព្រះអង្គម្ចាស់ថា ខ្ញុំព្រះករុណា
ឥតប្រាថ្នាឡើងប្រាក់ខែ យសស័ក្តិ ឬរង្វាន់អ្វីសោះឡើយ តែខ្ញុំព្រះករុណា
មានចំណង់តែមួយ សូមឲ្យតែព្រះអាការរោគរបស់ព្រះអង្គជាសះស្បើយ
ប៉ុណ្ណោះ ។

លោកគ្រូមានពុទ្ធដីកាថា បើដូច្នេះ សូមលោកមកជួបនឹងអាត្មា
ពេលស្អែក អាត្មានឹងនាំលោកទៅជួបលោកទីប្រឹក្សា ។

លុះព្រឹកឡើង លោកគ្រូ រ៉ាតេន ក៏បាននាំតាហាននោះទៅជួបនឹង
លោកទីប្រឹក្សានាម អ៊ីសាហាយ៉ាប៊ុយហ្សេន ។

លោកទីប្រឹក្សាបានទូលលោកគ្រូថា មិនសមសោះ ! លោកគ្រូ
ឲ្យមនុស្សសាមញ្ញចូលទៅជិតព្រះអង្គម្ចាស់ ។

លោកគ្រូបានតបទៅលោកទីប្រឹក្សាថា សូមលោកអនុញ្ញាតឲ្យ
ភាហានេះ ចូលទៅក្រាបបង្គំគាល់ព្រះអង្គម្ចាស់ចុះ ។

លោកទីប្រឹក្សាបានហៅភាហានក្មេងនោះ មកពិនិត្យមើលអាកប្ប-
កិរិយាយើញថា ភាហានេះ មានចិត្តស្មោះត្រង់ពិតប្រាកដចំពោះព្រះអង្គ
ម្ចាស់, ហើយក៏ទូលលោកគ្រូថា ទីឆ្ងាំភាហានេះទៅក្រាបបង្គំគាល់
ព្រះអង្គម្ចាស់កងថ្ងៃស្អែក ។

លុះដល់កំណត់ លោកអ័តូសូហ៊ា បានចូលទៅបម្រុងកងពួកកង
ភាហានយាមព្រះអង្គម្ចាស់ ក្នុងក្រឡាព្រះបន្ទំ ។

លុះដល់ម៉ោង ១០ យប់ លោកអ័តូសូដា បានក្រឡេកមើលទៅ
ភាហានឯទៀតដេកលក់អស់ ឯខ្លួនឯង កំពុងត្រេកត្រអែកចង់ដេកណាស់
ដែរ, តែបានរៀបចំផែនការរបស់ខ្លួនយ៉ាងហ្មត់ចត់ គឺយកក្រដាសស្តើង
មួយជាន់លើកន្ទេល យកកាំបិតតូចមួយរិះក្បាលជង្គង់របស់ខ្លួន ឲ្យឈាម
ស្រក់លើក្រដាសនោះ ។ មធ្យោបាយបែបនេះធ្វើមិនឲ្យខ្លួនដេកលក់
ព្រោះឈឺដោយរបួសក្បាលជង្គង់ ។

ដៃត្រាយនោះ ស្ទុះលើត្រចកត្អែកភាហាន ដើម្បីឲ្យភាហាន
នោះដេកលក់, តែភាហានបានយកកាំបិតតូចចាក់ត្រង់របួសនោះ, ហើយ
ដោយការឈឺចាប់, កំភ្លែតនោះស្តុតនៅបើកជាខ្លាំង ។

លុះដល់គេលុអង្រែត្រស្នាត់, ឪហានន៍ក្រឡេកទៅឃើញស្រាប់តែរបើកហើយមានន៍ម្នាក់ អានវូបរាមលោមមាណិស្រស់ប្រឹមប្រើយចូលទៅក្នុងក្រឡាព្រះបន្ទំព្រះអង្គម្ចាស់ ។ ឪអានន៍ដើរដោយឆាប់រហ័សយកដៃបិទមាត់ក្អកពួកគាហានយ៉ាម; រួចនាងទៅដល់ព្រះទេពអង្គឱនស្តាំកំទេរទៅលើទ្រង់ ថើប ៤ ហើយក៏ដាប់យកព្រះលោហិតឆាប់ទ្រង់ ...

ក្នុងមួយរំពេច នាងក្រាយក៏ក្រឡេកទៅឃើញស្ទឹងចំនីតែក្អកនឹងឮឯងឯតម្លួយ តែក្អកលោកអ័តូសូជា ។

នាងក្រាយក៏ស្រែកថា "ក្អកឯងជាអ្វី ? ខ្ញុំមិនធ្លាប់ឃើញមកឯងឯស្ងាត់នៅម៉ិនេះ" ។

លោកអ័តូសូជា ក៏តបទៅនាងវិញថា "ខ្ញុំឈ្មោះអ័តូសូជា ខ្ញុំចេះនឹងមកយាមព្រះអង្គម្ចាស់ នៅលើកទី ១ ក្នុងពេលនេះ" ។

នាងក្រាយពោលថា "ឪហានតាំងឯងស់ដេកលក់ត្រាប់ ។ គ្មានទៅតែអ្នកម្នាក់ឯង ចិនឯងបានដេកលក់ដូចអ្នកឯងទៀត, តែក្អកអ្នកឯងជាបើកជាន់ខ្លាំង, ខ្ញុំកោតសរសើរអ្នកឯងណាស់" ។

លោកអ័តូសូជា តបទៅនាងក្រាយថា "នាង, កុំសរសើរខ្ញុំ ។ ចង់ដេកណាស់ដែរ" ។

(នៅមានត)

កណ្ឌទី ៤១

ទុកញ៉ាំបុណ្យភជសេទា ឆ្លូ-កង ប្រៃរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> គឺងបេះទុបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិៗ

សាមកុកខ្មៀ ៤២

ឥឡូវពីចូរចូរចាប់ដុំនឹងសេទាទាហានតំបុដែកក្នុងទ្រុកដែលទឹកទឹក ចូរស្រែរឹងស្រែប្រមាថគុំគួនថា ជ្រីយើនឹងឡោះសុកនឹងដល់ខ្លួនសេចក្តីអន្តាយ លុះដល់អ៊ុយកាយចូលទ្រុកទៅជុតទឹកចូរចេះអស់។

ខណៈនោះចូរចូរដឹកស្រាស្រែរឹងជាមួយនឹងពួកមន្ត្រីខ្វិកជការ លុះដល់កាលយាម ២ យប់ ចូរស្រែរឹងស្រាទាំងណាស់ គឺកំរើបចិត្តគិតប្រមាថគេចស្រែកតឿងលើកដៃចង្អុលទៅទាហានទាំងពួងថា ឯជាយើនឹងឡោះសុកនោះ មិនបានដឹងថាអាកាសនឹងសំដែងហេតុឲ្យឃើញថាខ្លួនទាំង ២ នឹង

ដល់ខ្លួវសេចក្តីស្លាប់ក៏ឥតអង្គើមាន ប្រការមួយទៀតបណ្តាពួកឥហានក្នុង
កងទ័ពរាំកំប្រែចិត្តគំនុំតែងដោះគៀសចេញ មកចូលនៅខាងយើងជាច្រើន
ណាស់ ដ៏ជួចជាន់ធំយើញច្បាស់ថា ទេពតាចាំងឡាយមកបញ្ចូលចិត្ត
គំនុំមក ប្រថ្នាធំឲ្យយើងយកខ្លួវដ៏យង់ធំនេះដល់ឋាន ។ ស៊ុនហ៊ាវកំឃាត់
ហាមប្តូនថា លោកកុំមានប្រសាសន៍ឲ្យឮខ្លួនឯងទៅធ្វើអ្វី ក្រែងបែក
សេចក្តីនេះដឹងទៅដល់ដ៏វាយើងធំខូចការរបស់យើង ។

ប្តូនប្តូនបថា ឯណាពួកឥហានដែលបានមកប្រជុំគ្នានៅទីនេះ កំសុខ
តែជាពួកមាំការបស់យើងរួមចិត្តគំនុំតែមួយ អ្នកកុំគប្បីព្រួយថាការនោះនឹង
ដឹងដល់ទៅដ៏វាយើឡើយ ហើយលើកដៃចង្អុលទៅត្រង់ទិសស្រុកកាំងហែ
ថា ខ្លាំងនឹងខុងចេងគ្រានេះ គឺមិនមែនចេះគ្នាប្រមាណក្នុងកំឡាំងរបស់
ខ្លួនសោះ ប្រៀបដូចកណ្ឌៀវពួនដំបូក អាចគិតលូកទៅចំលោះក្តាំដ៏ធំ
ខ្លាំ គួរនឹងចាប់ចេះបានយើញឬ ឯអាយុរបស់យើងក៏ជាន ៥០ ឆ្នាំ
ហើយ បើសិនណាៈយើងជានស្រុកកាំងតាំង ក៏នឹងមានសេចក្តីគ្រេកអរ
សប្បាយ ១ ពេល ព្រោះតាំងមយើងក៏ដឹងច្បាស់ថា នាងគៀវកុកឡោ
មានបុត្រីសម្បុរល្អស្អាត ២ នាក់ ប្រកបដោយលក្ខណ៍ស័ក្តិសមជាឯក
លើសស្រីក្នុងផែនដីនេះ យើងក៏ជានត្រិះរិះពុកមកជាយូរហើយ តែថា
ជាហេតុខេពតាបណ្តាលឲ្យគ្រាត់ភ្លាត់ជានទៅជាកវាយស៊ុនសេកនឹងដ៏វាយើ

ទាំង ២ នាក់ កាលយើងច្បាំងបានស្រុកកេងដីវែងនោះ យើងក៏បានឲ្យ
កសាងស្រុកជាថ្មី ធ្វើប្រាសាទកំពូលបីខុតត្រង់ឆ្នេរទន្លេដៀងហោ គ្រា
នេះបើយើងបានស្រុកកាំងតាំងតន់ធំធឹងយើញមុខទាងកៀកកុកឡោ យើង
ឱងទៅទ្រព្រស្តីទាំង ២ នាំទៅនៅលើប្រាសាទស្រុកកេងដីវែង ឲ្យធ្វើវត្ត
ប្រតិបត្តិយើងតាមត្រូវការ ដើម្បីជាទីស្នេហាត្រាតែអស់ជីវិតក្នុងទីនោះ
ហើយបូជ្ជកអស់សំណើចសើចស្អាតស្អាយ ខ្លួលក្រឡេកទៅយើញក្អែក
មួយហ្វូងហើរព្រោងព្រាតដម្រង់ទៅទិសទក្សិណ បូជ្ជកសួរទៅប្រឹក្សាទាំង
ពួងថា ហេតុម្តេចបានជាក្អែកហើរស្រែកខុសវេលាដូច្នេះ ឱងគាចឬជា
ប្រការម្តេច ?

ទីប្រឹក្សាទាំងពួងទ្វើយថា ឯក្អែកដែលហើរស្រែកមកនេះ ព្រោះ
យើញខ្មែរស្រឡះ ក៏សំគាល់ច្បាស់ថាជនក្តី ប្រាថ្នាឱងហើរទៅរកស៊ី
ដែលលោកមកសំគាល់ថាជាឬគាចនោះមិនត្រូវទេ បូជ្ជកឮដូច្នោះក៏អស់
សំណើច ហើយលើកតែងស្រាផឹកថែមទៅទៀត ២-៣ តែង ស្រវឹង
ភ្នាំងណាស់តែតែមានចិត្តក់រើមឡើង ក៏កន្ត្រាក់យកលំពែងចេញទៅឈរ
នៅក្បាលទូក ហើយស្រែកប្រកាសថាហានទាំងពួងថា ផ្ទៃលំពែងនេះ
យើងតាន់សម្រាប់ដៃមកពីដើមកាលនៅជាកូនតាហាន តាលំតែតាំងខ្លួន
បានដល់ទីនេះបានប្រុមប្រុងពួកចោរជួតក្បាលលឿង ទឹងលីប៉ាំ, អ្នន

សៀវ, អ្នកស៊ុត ហើយបានច្រាបច្រាមអាណាខ្លែតាំងពីដើមតមកខ្លែតកំមិនដែលឮសំការ កើតមកជាជាតិគហានហើយត្រូវតែមានចិត្តភ្ញៀវក្លាដូច្នេះ រួចបួងកំប្រៀនក្មេងមានខំនុកថា:

វិស័យកំណើតកើតគួរស្ងប់ តាលរស់គួរត្រាប់ត្រង់តិច្រាយ
ត្រូវលេងលែងអីឲ្យសប្បាយ សម្រាប់ឬបកាយដែលត្រូវការ ។
តែមករយោញ្ជាប្លែកក្លែកតាំងហ្មង ផ្តើលហើរពាក្សឆ្ងាយជាអស្ចារ្យ
សូម្បីព្រៃឈើវាល្បិលតា គ្មានសោះបក្សាទំមិនជាន ។
ជានជាហើរប្លែកបែកជាតអស់ គួរឲ្យស្រណោះសត្វតិរច្ឆាន
ធម្មជាតិកំពង់ដុំដែនជាន មែនមានកំពូលស្រួលខ្ពង់ខ្ពស់ ។
រីឯសមុទ្រជ្រៅផុតដែន ជាដែនទ្រង់ទ្រាំទ្រទិសទស
ចិត្តយើងចិត្តគេគ្មានចង់រស់ គឺមានចៀសខ្លួនគ្មានសុខ ។

ខ្លែហុកទីប្រឹក្សាឮដូច្នោះក៏និយាយថា លោកលើកទំពមក ប្រាថ្នានឹងធ្វើការសង្គ្រាមយកជ័យជំនះ ហេតុម្តេចមកពោលពាក្យជាចាញ់ជ័យដូច្នេះ ។ បួងកំសួរថាអញ្ជើកូនលេង ហេតុម្តេចមកថាចាញ់ជ័យវិញ ។ ខ្លែហុកថា ខ្ញុំចាខបានឮក្មេងថាហ្វូងក្លែកគ្មានសំបុកនឹងមែកឈើខំអាស្រ័យ ទាំគ្នាហើរស្រែកឱឲ្យខុសវេលា ចានជាខ្ញុំចាខថាជាពាក្យចាញ់ជ័យដូច្នេះ ។ បួងឮដូច្នោះកំរឹងប្រឡោត ខ្លួនឯងនេះហ៊ានិយាយ

មើលឆាយប្រមាថអញ ហើយកំយកលំពែងចាត់ឲ្យហុកដួលចុះដាច់
ខ្យល់ស្លាប់ ឥហានទាំងពួងយើញដូច្នោះក៏តត់ស្តុតខ្លួតស្មារតី ទើបនាំ
ចូលចូលទៅក្នុងបន្ទាយ ។

លុះពេលព្រឹក ចូនចូស្វាងស្រីនឹងស្រា ភ្ញាក់ពីដេកឡើងក៏គិតយើញ
ថា យប់មិញអញសម្លាប់ឡៅហុកចោលនោះខុសសោះ ។ ឯឡៅហ៊ី
ជាកូនឡៅហុកក៏ចូលទៅស្រែកប្រហៀយំឲ្យចូនចូថា បិតាខ្ញុំបាទគ្មានទោស
ខុសអ្វីសោះ លោកមកសម្លាប់ចោល ឥឡូវខ្ញុំបាទសូមយកសពបិតាទៅ
ដាក់តាមទំនៀម ។ ចូនចូឮដូច្នោះ ក៏មានសេចក្តីអាណិតអនាថ យំ
ស្រក់ទឹកភ្នែកហើយថា តាលតើយប់មិញយើងធឹកស្រាស្រវឹងខឹងខ្លាំង
ណាស់ ដែលសម្លាប់បិតាអ្នកស្លាប់នោះ តើយើងធ្វើរំលោកបំពានទៅ
ហើយអ្នកកុំតូចចិត្តនឹងយើងឡើយ ចូរយកសពបិតាទៅរៀបចាត់ចែង
តាមតំណែងកូនស្តេចក្នុងក្រុងហ៊ូគោចុះ ហើយកំចាត់ឥហានឲ្យហោះហ៊ឺ
ជួយនាំសពយកទៅ ។

លុះវេលាព្រឹកឡើង អ៊ីគិមនឹងម៉ាយដែលជានាយខ័ពខ័ត កំ
ឡើងទៅដំកបប្តីនឹងចូនចូថា ខ្ញុំកចម្បាំងចាំងធំចាំងតួច កំបានចាត់ចែងត្រៀម
បំរុងត្រមតាំងត្រឿងសាស្ត្រាវុធសព្វគ្រប់ហើយ លោកនឹងលើកកងខ័ព
ទៅវេលាណាសុំឲ្យកំណត់ថ្ងៃចុះ ខ្ញុំបាទនឹងចាត់ចែងរៀបចំឲ្យត្រមគ្នា ។

ប្អូនឆ្មាជួញដូរគ្នាកើតទុរេកាន់ខ្លួនចម្លាំង តាំងឲ្យប្រមូលគាហានគាំងទ័ពទឹកមកបញ្ចូលគ្នាហើយចាត់ឲ្យមានទង់ពណ៌ផ្សេង ១ ៤ យ៉ាង សម្រាប់កងទ័ពគោកទ័ពទឹកនឹងបានដោតសំគាល់គាំង ៤ កង ឯខ្លួនខ្លានមេកងដំទ័ពហ្លួងត្រូវដោតទង់ពណ៌លឿង ខ្លួនខ្លានអ៊ុតមនឹងម៉ាយជានាយទ័ពស្រួចទង់ពណ៌ក្រហម ឲ្យលីយយជាប៉ែកស្តាំនាំខ្លួនខ្លានដោតទង់ពណ៌ខៀវ ចុងផែនាំខ្លួនខ្លានជាប៉ែកឆ្វេងដោតទង់ពណ៌សេ ឲ្យខៀវខាប់នាំខ្លួនខ្លានជាកងទ័ពក្រោយដោតទង់ពណ៌សេត ។

ឯទ័ពគោកនោះសោត ចាត់ឲ្យលីកងជានាយទ័ពស្រួចដោតទង់ពណ៌ក្រហម ឲ្យលីខៀនជាប៉ែកស្តាំដោតទង់ពណ៌ខៀវ ឲ្យគាត់ជិនជាប៉ែកឆ្វេងដោតទង់ពណ៌សេ ឲ្យហៃហ៊ូអៀនជានាយកងទ័ពហ្លួងដោតទង់ពណ៌លឿង ឲ្យស៊ីឡុងជានាយកងទ័ពក្រោយដោតទង់ពណ៌សេត ហើយឲ្យហៃហ៊ូខុនទឹងចោមជាកងណួន សម្រាប់ជួយចំពេញកំឡាំងទាំងទ័ពគោកទ័ពទឹក ហើយទឹងឲ្យយកដំណឹងជាផ្លូវភ្នែកមកថ្លឹងតម្រង់ត្រង់ពេល ឯខៀវលៀវទឹងទៅជួយកាន់អាជ្ញាសិទ្ធិជាសារវ័ត្រធំ សម្រាប់ត្រួតទ័ពបណ្តាគាហានឯក - គេទាំងឡាយក៏ចាត់ឲ្យជានាយពួកនាយកងទ័ពទឹកទាំងអស់ លុះចាត់ការស្រេចហើយ នាយគាហានទាំងអស់ក៏ទៅចាប់ស្មាគតាមកែណ្ឌទ័ពគោកទ័ពទឹក ។

ក្នុងខណៈនោះខ្លួនឯងក៏ឲ្យដកយកថ្មចេញពីក្តោងខ្លួនឯងទាំងអស់ឡើងលឿនគ្រឿនតាមមាត់ទន្លេ បណ្តាជាហានធំតូចទាំងពួងក៏រត់ទៅមកជាច្រើនឆ្លាស់គ្នាយ៉ាងតយុទ្ធ ។ នោះខ្លួនឯងទាំងអស់ដែលត្រូវឲ្យលះលែងនឹងលេកកំនឹងថ្កល់ដូចនៅលើផែនដី គ្មានផ្លែងផ្កងឃ្មោងដល់តែបន្តិចសោះ ពួកជាហានស្រុកលើកំមិនមានពុលលេក ទាំងគ្នាធ្វើការជាប្រក្រតី ។

ចូរនិយាយដូច្នោះកំមានចិត្តកំរើបជា គ្រានេះនឹងមានជ័យជំនះសឹកសត្រូវជាប្រាកដ ហើយកិបង្គាប់ឲ្យខ្លួនឯងទាំងពួងមួរក្តោងខ្លួន ចូលទៅចតនៅច្រំដែលជួបដើម ចូរធ្វើក្រឡប់ឡើងទៅលើបន្ទាយគោក ហើយនិយាយនឹងទីប្រឹក្សាទាំងពួងថា គ្រានេះទេពតាជួយយើង ទើបបណ្តាលចិត្តជ្មាំងថង មកប្រាប់ឲ្យយើងធ្វើការយកប្រព័ន្ធយាបូកចម្បាំងចងក្លាប់គ្នាជាផែនដ្ឋាន ដូច្នេះកំនឹងផ្តល់ដូចផែនដី ទឹងតតាំងច្បាំងគ្នាបានយ៉ាងចំណាប់ណាស់ ដៀងក៏ទ្រើយថា ការដែលរៀបចាត់ចែងទាំងពួងនេះកំយើញថាជាស្រួលមែនហើយ តែនៅបារម្ភក្រែងសឹកសត្រូវនឹងលបយកក្តើងមកដុតឲ្យនេះឡើង នោះយើញថាខ្លួនចម្បាំងទាំងពួងដែលចងក្លាប់គ្នានោះ នឹងកែវៃចេញពីគ្នា មិនទាន់នឹងថ្នល់ការសុំឲ្យលោកវិនិតចាត់ចែងប្រយ័ត្នខាងការពារក្បាក្តើងឲ្យមាំមួន ទើបនឹងមិនមានអន្តរាយ ។

ចូរឆ្លងអស់សំណើចហើយថា ដៃលអ្នកគិតបង្ខាំងភ័ន្តការពារខ្លួនដូចេះគឺល្អ
ហើយ តែថាដូចជាមិនដឹងផ្លូវសេចក្តីបានជាបារម្ភភ័យដូច្នេះ ដៃលអ្នក
ថាខ្លាចសត្រូវនឹងយកក្តីមកដុតនោះ កុំព្រួយបារម្ភឡើយព្រោះហេតុថា
ជាទេសកាលខែត្រជាំង ឥឡូវនេះមានតែខ្យល់ដំនោរនឹងខ្យល់បក់មកពីទិស
ឦសាន ឯកន្លែងយើងនេះគឺតាំងនៅពីលើខ្យល់ ខាងខ្លាដ៏ឃើនៅពីក្រោម
ខ្យល់ ទោះបីដ៏ឃើនឹងឲ្យភាហានមកលបដុតក្តី ខ្យល់គឺជាតំបក់បោក
មិនឲ្យក្តីដ៏នេះមកបានទេ គង់ត្រឡប់នេះនាបតាមបុងខ្យល់បក់ត្រានៅលើ
កងខ្លាដ៏ឃើវិញ បើជាទេសកាលខែកក្តិកខាងខ្លឹត បុងដូវក្តៀងគឺនឹង
តើតខ្យល់ត្បូរឈ្មោះសាលាត់នមកខ្លះ ត្រានេះកន្លងមកដល់ខែបុស្សហើយ
ផុតទេសកាលក្តៀងហើយយើងក៏មិនត្រូវខ្លាចអ្វី ទីប្រឹក្សាតាំងពួនពួតដូច្នេះ
ក៏ត្រូវក្បាលនាំគ្នាគំនាប់ចូលសរសើរថា តម្រិះប្រាជ្ញាជ្រៅទូលាយឆ្ងាយ
ណាស់ ដ៏ឯការទេសកាលក្តៀងខ្យល់មិនសល់ត្រង់ណា ។

ចូរឆ្លងគិនិយាយថា ភាហានបេះយើងសុទ្ធតែពួកអ្នកលើកុងរ៉ែ
បើមិនបានតម្រិះរិះគិតគំនិតចាំងថងមកតខ្យល់ឲ្យធ្លើដូច្នេះ យើញថាមិន
បានឆ្ងងកាត់ជ្រោយបណ្តោយចូលទៅក្នុងស្រុកកាំងតាំងបានឡើយ ។

(នៅមានត)

ពាក្យវិប្បធម៌

លោក នាង-ហ៊ួ រៀបរៀង

លោក សម-ថាំង ពិនិត្យ

អស់លោកអ្នកអានទាំងឡាយ !

វេលានេះយើងសូមអធិប្បាយអំពីពាក្យ "ក្រសួង, ក្រុម" ដើម្បីបញ្ជាក់ជូនអស់លោកអ្នកអាន ឲ្យបានចាំច្បាស់ នូវព្រំដែនរបស់ពាក្យនីមួយៗ ព្រោះមានជនរួមជាតិយើងខ្លះ ពុំទាន់ច្បាស់លាស់អំពីព្រំដែននៃពាក្យទាំងនោះនៅឡើយ ។

ដើម្បីជាគ្រឿងរំលឹកដល់ព្រំដែនរបស់ពាក្យទាំងនោះ យើងសូមបញ្ជាក់ជាថ្មីម្តងទៀតថា ពាក្យក្រសួងនេះ គណៈកម្មការវិប្បធម៌បានកំណត់ថា ឲ្យប្រើបានតែចំពោះទីស្តីការរបស់ដ្ឋមន្ត្រី ត្រូវគ្នានឹងពាក្យបារាំងថា Ministère, Département ប៉ុណ្ណោះ ។ ឧទាហរណ៍: ក្រសួងជម្នាការ, ក្រសួងមហាផ្ទៃ, ក្រសួងសិក្សាធិការ ។ល។ ឯពាក្យក្រុម ប្រើបានតែចំពោះកន្លែងចាត់ការពាណិជ្ជការ ដែលខុសបង្គាប់ពីពាក្យក្រសួង គឺរដ្ឋមន្ត្រីនីមួយៗ ត្រូវគ្នានឹងពាក្យបារាំងថា Service ឧទាហរណ៍: ក្រុមសុរិយោដី, ក្រុមគយនឹងរដ្ឋាករ ។ល។ សូមកុំប្រើហៅថាក្រសួងសុរិយោដី,

ក្រសួងគយនឹងរដ្ឋាករជួចមុន ។ល។ ។

ក្នុងពេលនេះ យើងសូមលើកយកភាសាពីរម៉ាត់គឺភាសា មន្ទីរ និង ខ្ញុំ មកអធិប្បាយជូនដូចតទៅ ៖

តាមដែលបានសំគាល់មក យើញថាខ្មែរយើងធ្លាប់ប្រើភាសាទាំងពីរម៉ាត់នេះ ដោយច្រឡំបល់គ្នាតាមតែចំនើនចិត្តចង់ថាចង់សរសេរ គឺថាបើចង់ហៅកន្លែងណាមួយថា "មន្ទីរ" ក៏ថាទៅឬចង់ហៅថា "ខ្ញុំ" វិញក៏ថាទៅ។

ឧទាហរណ៍ដែលបានសំគាល់ឃើញមក : មន្ទីរស៊ើបសួរ, មន្ទីរក្រឡាបញ្ជី, មន្ទីរឧជ្ជៃ, មន្ទីរចាត់ការ, មន្ទីរកាត់សក់, មន្ទីរតម្បាញ ក៏មន្ទីរជួសជុលពេចក្រយានយន្ត ។ល។ ជួនកាលឃើញមានប្រើថា "ខ្ញុំ" ខ្លះក៏មានដែរ ។

ក្នុងវចនានុក្រមខ្មែរ ពាក្យថា "មន្ទីរ" បានន័យថាគ្រឹហ, ផ្ទះ, វិហារមានន័យសំខាន់ពាក្យថា ខ្មែរច្រើនហៅគ្រឹហធំៗដូចយ៉ាងធម្មមន្ទីរ, សារមន្ទីរជាដើម ។

ឯពាក្យ « ខ្ញុំ » បានន័យថា កន្លែង, តំបន់ ឧទាហរណ៍: ខ្ញុំនេះ, ខ្ញុំនោះ; មុខងារ, ក្រសួង: ខ្ញុំសេនាបតី, ស្តេចយាងហ្វាង ។ ខ្ញុំពឹងអ្នកពំនឹង, អ្នកជួយខំទុកបំរុង, ខ្ញុំស្រឡាញ់ ។ ខ្ញុំពំនាក់ អ្នកផ្សំពឹងពាក់ ។

បើតាមន័យក្នុងវចនានុក្រមនេះ ខ្ញុំចាប់របស់យើងដែលប្រើភាសា

"មន្ទីរ" នឹង "ទី" នេះ យើញថាទៅច្របូកច្របល់ពេក ហាក់ដូចជាពាក្យ
ទាំងពីរមាត់នេះប្រើជំនួសគ្នាបាន ។

បើយើងនាំគ្នាក្រឡេកមើលទៅពាក្យចាស់ត្រង់សព្ទស្តីអំពីឈ្មោះ
របស់ទី កន្លែងវិញ យើងនឹងឃើញថាគេមានពាក្យច្រើនណាស់ ហើយ
សុទ្ធតែមានព្រំដែនជាក់លាក់ដាច់ដោយឡែក ។ តាគ្នា ។ តារាងណ៍ ដូចជា
Ministère, service, office, direction ។ល។

ចំពោះពាក្យទាំងនេះ កាលបើឮអ្នកឯនិយាយថា Ministère គេ
អាចស្តាប់បានភ្លាមថា ពិតជាកន្លែងធ្វើការរបស់រដ្ឋមន្ត្រី ឥតកន្តប្រឡំថា
ជាទីដទៃសោះឡើយ ។ បើឮថា Service គេស្តាប់បានភ្លាមថា ជាកន្លែង
ធ្វើការដែលទទួលបង្គាប់ពីទីស្តីការរបស់រដ្ឋមន្ត្រីនីមួយៗ ។ បើឮថា Office
គេស្តាប់បានភ្លាមថា ជាកន្លែងចាត់ការកិច្ចការ ដែលជាប់ទាក់ទងនឹងអាជ
រូបិយវត្ថុ ។ បើឮថា Direction គេក៏ស្តាប់បានភ្លាមថា ជាទីចាត់ការ
របស់ផ្នែកនៃក្រសួងដែលសំខាន់ ។ នីមួយ ។ ដែរ ។

ដូចដែលជំពាក់ខាងលើនេះ បើជាកមកមើលពាក្យរបស់ខ្មែរយើងថា
"មន្ទីរនឹង ទី" ម្ល៉ះទៀត យើងនឹងឃើញថាសព្ទនេះខ្មែរខ្លាចនិយាយមក
ឥតមានល្អក្នុងជាក់លាក់សោះឡើយ ដូចជាយើងហៅថា "ទីសំណាក់
ការ, ទីស្នងការ, ទីចាត់ការ, ទីប្រជុំ, ទីទុកឯកសារ, ទីស្តីការ" ។ល។ ជួន

កាលបែរជាខំយោយហៅថា "មន្ទីរសំណាក់ការ, មន្ទីរស្នងការ, មន្ទីរចុត់ការ, មន្ទីរប្រជុំ, មន្ទីរទុកឯកសារ, មន្ទីរស្តីការ, ដូច្នេះទៅវិញក៏សឹងមាន ។ ខ្ញុំចាប់ច្រើរភៀបនេះនាំឲ្យឥតសណ្ដាប់ធ្នាប់ផង ខុសពីពាក្យដែលគណៈកម្មការវប្បធម៌តំណាត់ឲ្យប្រើផងវិញ ។

ចុះហេតុដែលខាស់ឆ្គងនេះមកពីអ្វី ?

ឆ្លើយថា មកពីយើងចេះតែនាំគ្នាខិយម ខិយាយ សរសេរឲ្យខុសជាក់មាត់, ឆ្គាប់ដៃ ពីដើមទីមកហើយនោះ ខ្ញុំចាប់ខុសបែបនេះ លុះយូរៗទៅគេចមានតណាខុសភាព ឆ្លើយតាក្យបែបយើងមានន័យពាលជាលប្រឡូកប្រឡំឥតល្អូហានត្រង់ដែនខឿងខាត់ ទៅតាមការខិយម, តាមខ្ញុំចាប់របស់យើង តម្រូនឯកែតម្រង់ឲ្យត្រូវបាន ។

ដូច្នេះ ដើម្បីចំបាត់ខ្ញុំចាប់ ដែលប្រគាញទៅរកតែផ្លូវខុសនេះ កុំឲ្យមានតម្លាំងក្លាយទៅជាគេតសង់ផ្លូវលើយើងរាល់គ្នាបានមាន ត្រូវគណៈកម្មការវប្បធម៌ ខំឆ្លៀតយកឧកាសនេះមកអធិប្បាយ តាមការកត់ចំណាំ, ដោយជួយបំបែរលោកអ្នកមាន ទៅរកផ្លូវត្រូវតាំងពីពេលនេះតទៅ ។

នៅទីនេះ យើងគួរលើកយកពាក្យ "មន្ទីរ" ឧទាហរណ៍ថា Office មកផ្ទឹងមើល ដើម្បីឲ្យដឹងថាតើ «មន្ទីរ» មានចំហំនន័យប៉ុន្មាន ? ។

ពាក្យមន្ទីរនេះ ដូចយើងបានបើញរួចមកហើយ បានន័យត្រឹមតែ

ហៅ មុខការ, គ្រឹះស្ថាន ឬអង្គការណាមួយតែប៉ុណ្ណោះ ឥតមានន័យលែងឆ្ងាយទៅទៀតទេ ។

ឯពាក្យ Office នោះមានន័យច្រើនប្រការណាស់

១-កិច្ចការ:, មុខងារ: Office de secrétaire;

២-បន្ទុកស៊ីវិល (មុខងារជាអ្នកបម្រើគ្រប់គ្រង): Acheter un office;

៣-ជួនកាលប្រើការជាការិយាល័យ Office de puplicité;

៤-ការជួយយកអាសា, ការធ្វើហិតប្រយោជន៍: Prêter ses bons offices;

៥-ការធ្វើដោយច្បាប់តម្រូវលើ: Déplacement d'office

៦ បើប្រើជាឥត្តិលទ្ធិវិញ មានសេចក្តីថា បម្រុងដែលគេជាក់ត្រឿងបរិភោគ ។

ឧទាហរណ៍ដែលនាំមកអធិប្បាយប៉ុណ្ណោះនេះ ល្មមបញ្ជាក់ឲ្យដឹងថា ពាក្យ Office នេះ មានន័យច្រើនណាស់ តែមិនយើញន័យត្រង់ណាដែលថាមន្ទីរកាត់សក់ មន្ទីរបោកអ៊ុតនោះសោះឡើយ ។

ពាក្យមន្ទីរនេះគណៈកម្មការវប្បធម៌បានកំណត់ហៅឈ្មោះ អង្គការឬទីតាំងការដូចតទៅ ៖

១-មន្ទីរសង្គហៈនិស្សិតខ្មែរ: Office des Etudiants cambodgiens;

២-មន្ទីរឥណទានសម្រាប់ប្រជាជន: Office de crédit populaire;

៣-ជាតិមន្ទីរទេសចរណ៍ Office national de Tourisme;

៤-ជាតិមន្ទីរប្តូរប្រាក់ Office national des changes;

៥-មន្ទីរស្រូវ Office de riz;

ប៉ុន្តែចំពោះត្រឹះស្ថាន ឬ អង្គការធំ ៗ ខ្លះ ក៏គួរហៅមន្ទីរបានដែរ ដូច ជា: មន្ទីរពេទ្យ, ធម្មមន្ទីរ, សារមន្ទីរ, ព្រះរាជមន្ទីរ, សង្ឃមន្ទីរ, ។ល។

ឯពាក្យដែលយើងធ្លាប់ប្រើដោយប្រឡូកប្រឡំមកហើយនោះ គប្បី កែប្រែឲ្យបានត្រឹមត្រូវឡើងវិញដូចយ៉ាង

មន្ទីរស៊ើបសួរ ត្រូវហៅ ការិយាល័យស៊ើបសួរ,

មន្ទីរក្រឡាបញ្ជី ត្រូវហៅ ការិយាល័យក្រឡាបញ្ជី,

មន្ទីរឧទ្ធរណ៍ ត្រូវហៅ ក្រុមឧទ្ធរណ៍,

មន្ទីរចាត់ការ ត្រូវហៅ នាយកចាត់ការ,

មន្ទីរជួសជុលគោចក្រយានយន្ត ត្រូវហៅ នាយកដ្ឋាន ជួសជុលវិញ ។

ឥឡូវសុំលើកយកពាក្យ "នាយក" មកអធិប្បាយវិញ ។ ពាក្យនេះបាន ជាយើងលើកយកមកបញ្ជាក់ ព្រោះមានការប្រើលាយឡំគ្នានឹងពាក្យមន្ទីរ ដូចបានពោលខាងលើរួចហើយ ដូចជាឧទាហរណ៍ថា មន្ទីរចាត់ការ, មន្ទីរសំណាក់ការ, មន្ទីរស្តីការ ។ល។ ដែលគណៈកម្មការបានកំណត់ ឲ្យហៅថា "នាយកចាត់ការ, នាយកសំណាក់ការ, នាយកស្តីការ" ជាដើម ។

ឯពាក្យថាំងថាំងខាងក្រោមនេះ គណៈកម្មការវិបួតមិនប្រាប់ពាក្យចុងក្រោយថា : Direction, Siège ministère ។ នាយកចាត់ការមានន័យតែមួយចំពោះ

កន្លែងដែលជាតួនាទីការបម្រើក្រុមទីមួយៗតែប៉ុណ្ណោះ ។ ចំណែកពាក្យ
ថាកំណត់ថា Direction មានន័យយ៉ាងវែងច្រើនប្រការដូចតទៅ :

១-ការដើរទៅកន្លែងណាមួយដែលជាទីដៅ;

២-ការដឹកនាំឬត្រួតត្រាលើការ, អង្គការណាមួយ;

៣-ការឆ្ពោះសំដៅទៅកន្លែងណាមួយ;

៤-មុខការរបស់នាយកការិយាល័យ ឬទីធ្វើការនៃនាយកនោះ;

៥-គ្រឿងចក្រសំពាច់ជាញឹកញឹតរថយន្ត

ដូច្នេះ យើញថាពាក្យ Direction នេះ មានន័យច្រើនណាស់
មិនដូចខ្មែរយើងដែលចេះប្រើមកប្រើ ត្រឹមតែកន្លែងសម្រាប់ចាត់ការបម្រើ
ពលការ ឬបម្រើអង្គការណានោះឡើយ ។

សរុបសេចក្តីទៅ ពាក្យមន្ត្រី គណៈកម្មការវប្បធម៌ចានផ្តល់ទីឯ
ពាក្យថាកំណត់ថា Offiec តែមានន័យមិនច្បាស់គ្នាទីឯថាកុំឯទេ ។ ឯពាក្យ
ទី មានន័យត្រឹមតែ កន្លែង, តំបន់ប៉ុណ្ណោះ ។

កន្លែអាសានកថានេះ គណៈកម្មការវប្បធម៌ សូមថ្លែងអំណរគុណ
ចំពោះអស់លោក-អ្នកអានជាទីមេត្រីភាពិតឯណ្ណាយ ហើយសូមផ្ញើសេចក្តី
សង្ឃឹមថា តទៅមុខកំមុខជាទីពឹងមានការបំបាត់កំហុសដូចបានលើកយក
ជាឧទាហរណ៍ពាំងនេះពុំខាន ។

ផ្នែកកំណាត់ឯកសារប្រវត្តិការណ៍

ឥតមានផ្នែងៗរបស់ក្រសួងធម្មការ

អំពីការតាំងមន្ត្រីសង្ឃ

-ចានតាំងលោកគ្រូចៅអធិការ ជ័យ-អ័ង អាយុ៨០ ឆ្នាំ វស្សា៦០ នៅវត្តមុនីកែវសូរកាន ឃុំសូរគង ជាព្រះគ្រូបញ្ជាវិន្យ ស្រុកកងមាស ខែត្រកំពង់ចាម ។

-ចានតាំងកិត្តិ យា-អ៊ុម អាយុ ៥៥ ឆ្នាំ វស្សា ៣៥ នៅវត្តមុនីកែវសូរកាន ឃុំសូរគង ជាព្រះវិនយធរ ស្រុកកងមាស ខែត្រកំពង់ចាម ។

-ចានតាំងកិត្តិ ស៊ូ-ស៊ុយ អាយុ ៤៨ ឆ្នាំ វស្សា ២៦ នៅវត្តមុនីកែវសូរកាន ឃុំសូរគង ជាព្រះសមុហ៍ ស្រុកកងមាស ខែត្រកំពង់ចាម។

-ចានតាំងកិត្តិ អ៊ុន-ហ៊ុន អាយុ ៤១ ឆ្នាំ វស្សា ២១ នៅវត្តមុនីកែវសូរកាន ឃុំសូរគង ជាអនុលេខាធិការអនុគណ ស្រុកកងមាស ខែត្រកំពង់ចាម ។

-ចាន់តាំងភិក្ខុ អឹម-ចាន់ អាយុ ៣៤ ឆ្នាំ វស្សា ១៤ នៅវត្ត
ត្រពាំងភ្លារ ឃុំកុំកុង ជាព្រះវិនយធរ ស្រុកបន្ទាយមាស ខេត្តកំពត ។

-ចាន់តាំងភិក្ខុ ហ៊ឹម-កែម អាយុ ៦១ ឆ្នាំ វស្សា ៤២ នៅវត្តខ្ពស់
លាង ជាព្រះសមុហ៍ ស្រុកបន្ទាយមាស ខេត្តកំពត ។

-ចាន់តាំង ភិក្ខុ សឺង-ឆុច អាយុ ៦២ វស្សា ១ នៅវត្តស្រែកាន់
ឃុំទួកមាស ជាអនុលេខាធិការអនុគណ ស្រុកបន្ទាយមាស ខេត្តកំពត។

-ចាន់តាំងភិក្ខុ សេក-ប្រធំ អាយុ៦៣ ឆ្នាំ វស្សា១ នៅវត្តព្រះ
ព្រហ្មវ័ន្ត ជាអនុលេខាធិការអនុគណ ស្រុកសៀមពាយ ខេត្តសៀមពាយ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទុ:ខ៑ នបុ. សេចក្តីទុក្ខក្រៃលែង ។ – ទុ:ខិត គុ ដែលមានទុក្ខក្រៃលែង, ។ – ទុ:ខាទ្វិត គុ. ដែលប្រកបដោយសេចក្តីទុក្ខក្រៃលែង ។

អតិទុគ៌ិម គុ. ដែលទៅបានដោយកម្រក្រៃលែង ។

អតិទុជ្ជិន ឃុំ. ទុជ្ជិនក្រៃលែង ។

អតិទ្ធពិល គុ. ដែលមានកម្លាំងខ្លាយក្រៃលែង; – តា ស្ត្រី. ភាវៈនៃបុគ្គលដែលមានកម្លាំងខ្លាយក្រៃលែង ។

អតិទុម៌ន៑ស៑ គុ. ដែលខ្លួចចិត្តក្រៃលែង ។

អតិទុរ៌ិហត្ស នបុ. ភាវៈនៃ . . . ដែលតាំទៅបានដោយកម្រក្រៃលែង ។

អតិទុរ៌ិមហ គុ. ដែលអាចតាំទៅបានដោយកម្រក្រៃលែង ។

អតិទុរ៌ិត្ត គុ. ដែលប្រព្រឹត្តទៅបានដោយកម្រក្រៃលែង ។

អតិទុ:ត្រ៊ូ គុ. ដែលស្តាប់បានដោយកម្រក្រៃលែង, ដែលតិចាកស្តាប់ ។

អតិទុឡ្ហ គុ. ដែលធ្វើបានដោយកម្រក្រៃលែង ។

អតិទុស្ត្រ គុ. ដែលឆ្លងបានដោយកម្រក្រៃលែង ។

(នៅមានត)

ភក្តីសន្ទិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣២ លេខ ១០ ខែតុលា

ព. ស. ២៥០៣ គ. ស. ១៩៦០

ក្នុង ១ ក្បាល



ភ្នំពេញសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញារាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បន្លឺរឿង	ទំព័រ
- ព្រះពុទ្ធទំនិងសទ្ធិព្រះពុទ្ធសាសនា	លោក ភ្លោម-ទឹម រៀបរៀង	១០៨១
- ពុទ្ធដីវប្បវត្តិ (តមក)	ព្រះមហា ជាំង-ខាត់ រៀបរៀង	១០៨៨
- ព្រះអភិធម្មបិដក គម្ពីរកថាវត្ថុ (តមក)	លោក ប៊ូ-ប៊ូ រៀបរៀង	១០៩៩
- មធុរសាភិហិណី (តមក)	សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈីន ពិនិត្យ	១១១៣
- មហោសថជាតក (តមក)	ពេញ អឹម-ភន ចម្លងពីសាស្ត្រស្វាកវិត ព្រះពុទ្ធវង្ស កឹម-ភ្ជួរ ពិនិត្យ	១១១៩
ផ្នែកអក្សរសាស្ត្រ		
- រឿងមរណមាគ (តមក)	លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រស្វាកវិត	១១២៩
- រឿងព្រេងនិងរឿងបុរាណដប៉ុនក្នុងមធ្យមសម័យ (តមក)	លោកវ័យ-ប៊ុក រៀបរៀង	១១៥៩
- អធិប្បាយសុភាសិត	លោក ស្ងើង ធូរ រៀបរៀង លោកឧត្តមប្រឹងា ចាប-គិន ពិនិត្យ	១១៦៦
- រឿងព្រេងប្រទេសហ្វីលីពីន	ភីក្តូ ម៉ែន-រៀម ប្រែចាកភាសាអង់គ្លេស	១១៨២
- រឿងសាមកុក (តមក)	ឧកញ៉ា ន-ភន ប្រែ	១១៨៧
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍		
- ពត៌មានផ្សេង ៗ	របស់ក្រសួងធម្មការ	១១៩៤
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហា ជាំង-ខាត់ រៀបរៀង	១១៩៨

ឆ្នាំ មាន ១២ លេខ ក្នុង ១ លេខ តំលៃ ៣ រៀល

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

sommaire

Partie religieuse :

— Le Bouddha et sa religion par M. NHEM-KHEM 1081
— La Vie du Buddha (suite) par Prah maha PANG-KHAT . 1088
— Prah Abhidhammapitaka (Kathavathu) (suite) par M. BOU-PO 1099
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén. NHEAN-CHHOEUN . . . 1113
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON revu par le Vén-KEM-TO 1119

Partie littéraire :

— Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1129
— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC 1159
— Commentaire du proverbe par M. SDOEUNG-CHHO revu par M. CHAP-PIN 1166
— Contes et légendes Philippins traduits par Bhikkhu MEN REAM 1182
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1187

Notes et Chroniques :

— Nouvelles diverses du Ministère des Cultes 1194
— Dictionnaire Sanscrit-khmer (suite) par le Vén.PANG-KHAT 1198

Prix d'abonnement annuel (comprenant 12 numéros): 230,00 .

ផ្នែកសាសនា

ព្រះពុទ្ធនិងទ្រឹស្តីព្រះពុទ្ធសាសនា

យើងអាចរកប់នាមមេបង្កើតសាសនាគំនិតឯកូយក្នុងលោកបានច្រើនណាស់ តែក្នុងនិទ្ទេសនេះ សូមលើកយកតែនាមមេបង្កើតសាសនា ៤ រូបធំៗមកអធិប្បាយ ព្រោះសាសនាបួននេះមានបរិស័ទគោរពប់អានច្រើនជាងសាសនាដទៃទៀតក្នុងសាកលលោក ។ ឯនាមអ្នកបង្កើតសាសនាបួនពួកនោះគឺ ព្រះពុទ្ធ, ព្រះយេស៊ូ, ព្រះមហាម្មុត, ព្រះក្រិស្ណៈដែលជាអវតារព្រះនារាយណ៍ ។

បើយើងប្រៀបធៀបអំពីបុគ្គលិកលក្ខណៈ អំពីការប្រព្រឹត្តអំពីរបៀបផ្សាយសាសនានៃមេបង្កើតសាសនាគំនិតបួននេះ យើងសង្កេតឃើញច្បាស់ជាថា មានការខ្ចែកគ្នាវែងព្រះពុទ្ធនិងមេបង្កើតសាសនាបីពួកទៀត ។

ដំបូងបង្អស់ព្រះពុទ្ធមានការខ្ចែកគំនិតយ៉ាងបុគ្គលឯទៀត ត្រង់ព្រះអង្គមានព្រះទ័យប្រកបដោយ «ការលះបង់» មានការលះបង់ទ្រព្យសម្បត្តិនិងការលះបង់ព្រះសរីរកាយជាដើម ។

ព្រះយេស៊ូបានប្រកាសសាសនាថា លោកជាបុត្រព្រះអាទិទេព

ហើយនណាមួយក៏ពុំគប្បីទៅកើតឯស្ថានទេវតាបាននឡើយ បើមិនឲ្យលស្គាល់លោកថាជាបុត្រនៃព្រះអាទិទេព ។

ព្រះមោហាម្នុត ជាខ្លួនលោកមិនត្រឹមតែជាអ្នកនាំសារព្រះអាទិទេពមកកាន់ស្ថានក្រោមនេះប៉ុណ្ណោះទេ គឺខ្លួនលោកនេះជាអ្នកនាំសារបុរាណក្រោយបំផុតរបស់ព្រះអាទិទេពទៀតផង ។ ព្រះមោហាម្នុតមិនខុសគ្នាពីព្រះយេស៊ូទេ លក្ខខ័ណ្ឌចាំបាច់របស់លោក គឺការឲ្យលស្គាល់គុណសម្បត្តិផ្ទាល់របស់លោក ដើម្បីទៅកាន់ទីសុខក្សេមក្សាន្តមិនមានទីបំផុត ។

ព្រះគ្រិស្ណៈវិញមាននិទ្ទាការឡាយជានេះទៅទៀត គឺលោកមិនពេញចិត្តនឹងឲ្យលនាមជាបុត្រព្រះអាទិទេព ឬ ជាអ្នកនាំសារបុរាណក្រោយបង្អស់នៃព្រះអាទិទេព ឬ ពុំនោះជាព្រះអាទិទេពតែម្តងប៉ុណ្ណោះទេ ព្រោះលោកបានបញ្ជាក់ពុកថា លោកជាព្រះនៃព្រះអាទិទេពទាំងអស់ទៅទៀត។

ផ្ទុយទៅវិញ ព្រះពុទ្ធពុំដែលប្រកាសសញ្ជាតិព្រះអង្គថា ជាព្រះអាទិទេពទេ ព្រះអង្គជាបុត្រមនុស្សលោកពិតៗ ហើយនៅគ្រប់ទិសទីដែលព្រះអង្គបានយាងទៅទេសនាប្រៀនប្រដៅពុទ្ធបរិស័ទ ព្រះអង្គពុំដែលមានពុទ្ធដីកា អួតអំពីអាគតដ្ឋាន ឬ អំពាវនាំអំណាចអ្វីឲ្យហួសពីវិស័យធម្មជាតិទេ បើមានខ្លះព្រះអង្គគ្រាន់តែសំដែងថាដំហរៗ ឲ្យឃើញថាកិស្តជនទាំង

ក្នែកអ្នកស្តាប់ភ្លាមៗ ប៉ុណ្ណោះ ។

ការប្លែកទីពីរ គឺព្រះពុទ្ធជាមគ្គុទ្ទេសក៍, ជាអ្នកបង្ហាញ ជាអ្នកចង្អុលប្រាប់ផ្លូវឲ្យគេដើរ ។ ឯព្រះយេស៊ូ, ព្រះមោហាម្មត, ព្រះក្រិស្ណៈតាមការយកពាក្យថា «អ្នកដោះលែង» មកជាក់ខ្លួន ។

ព្រះពុទ្ធជាមគ្គុទ្ទេសក៍ជានេះចក្តីថា ព្រះពុទ្ធទ្រង់ស្គាល់យ៉ាងច្បាស់នូវផ្លូវប្រតិបត្តិនាំឲ្យកើតបុណ្យនឹងបាបនោះ ហើយព្រះអង្គអាចប្រាប់ដល់បរិស័ទព្រះអង្គបានថា អំពើនេះល្អគឺបុណ្យ, អំពើនេះអាក្រក់គឺបាប រួចព្រះអង្គបានបន្ថែមថា គួរគប្បីបរិសុទ្ធចាំងឡាយ ប្រព្រឹត្តតែអំពើល្អ ។ ប៉ុន្តែបើជនណាមិនដឿព្រះអង្គ។ ក៏ឥតមានបង្ខំដែរ ព្រោះអំពើបាបនឹងបុណ្យជាលទ្ធផល នៃការប្រព្រឹត្តរបស់ជនម្នាក់ៗ គឺជនណាបានសាបព្រោះនូវអំពើអ្វី ជននោះប្រតិសាត់យកផលអំពីអំពើនោះ។ ចាហារណ៍ដូចជាទ្រង់ហាមមិនឲ្យសេពសុក ព្រោះព្រះអង្គទ្រង់ស្គាល់ច្បាស់នូវទោសនៃសុក នូវហេតុដែរត្រឿងវិនាសបណ្តាលមកពីសុក ។ ការណ៍នេះអស់លោកបានសង្កេតឃើញស្រាប់ហើយក្នុងលោកបច្ចុប្បន្នកាលនេះ មនុស្សប្រមឹកសុកជាមនុស្សដែលសង្គមមនុស្សគាត់ច្រើន ចាត់ទុកជាមនុស្សកេកគាប, មនុស្សវង្វេងស្មារតី, មនុស្សគ្មានយស ។ល។ ពាក្យច្បាប់ប្រដៅកូនចៅយើងពីបុរាណក៏មានចែងថា «លោកថាឆ្កួតបី ឆ្កួតមួយ

ទីដ៏ស្រស់ ឆ្អែតមួយទីដ៏ស្រស់ ឆ្អែតមួយទីដ៏ល្អដ៏ អំពើពាលា... ។ នេះ ហើយជាផលនៃអំពើអាក្រក់, ជាផលនៃអំពើបាបដែលបណ្តាលមកពីការ មិនដឹងតាមពាក្យខ្ញុំខ្ញាន់នៃព្រះមគ្គុទ្ទេសក៍ដ៏វិសេសរបស់យើងគឺព្រះពុទ្ធ ។ អំពើបាបនេះមិនមានតែនៅក្នុងជីវិតបច្ចុប្បន្នកាលនេះប៉ុណ្ណោះទេ, ព្រះពុទ្ធទ្រង់ បានសំដែងថាវាមានទៅជាតិមុខទៀត សូមលោកអ្នកដែលចង់ជ្រាប តាមតម្រាមើលគម្ពីរនានាខាងព្រះពុទ្ធសាសនាដែលចែងពីរឿងនេះចុះ ។

ដោយយល់ នូវខ្លឹមសារនៃពុទ្ធវចនេះផង ដោយយល់ហាន: ប្រទេសកម្ពុជាដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាផង បានជាព្រះពជ-រដ្ឋកិច្ចលោយើង បានហាមប្រាមមិនឲ្យឃ្លួញខ្លួទៅលក់សុក ឬ តំឃាត សត្វ មានគោក្របីជាដើម នៅថ្ងៃឧបោសថសីលឡើយ ។

តទៅនេះ នៅមានការថ្វែកម្យ៉ាងទៀត គឺព្រះយេស៊ូ ព្រះមេ-ហាម្នាក់បានភោលអះអាងថា លោកជាប្រៃសិត ខឹងជាអ្នកនាំពាក្យនៃ ព្រះអាទិទេព លុះដែលលោកប្រឹនប្រែជាគោលឆ្នាប់សាសនាពិត ប្រាកដមិនមានការន់ប្រឡំ ត្រូវបរិស័ទខ្លួលគោរពតាមមិនបាច់មានការ ពិភាក្សាអ្វីឡើយ ចំណែកព្រះគ្រិស្តវិញ ដែលជាព្រះលើព្រះអាទិទេព ទៅទៀត សំដីរបស់លោកក៏ត្រូវបាត់ទុក ជាការពិតឥតការន់ប្រឡំដែរ ។ ឯព្រះសម្មាសម្ពុទ្ធវិញ ព្រះអង្គពុំដែលមានពុទ្ធដីកាអះអាងដូច្នេះទេ ។ ត-

ហារណ៍ដូចជាទៅក្នុងមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់ប្រទានប្រកាសប្រាប់ព្រះអានន្ទថា សាសនាព្រះអង្គមានមូលដ្ឋានទៅលើការពិសោធន៍ធ្វើការរិះរកទុសត្រូវ ។

ត្រង់នេះបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធជាអ្នកហេតុផលនិយមព្រះពុទ្ធមិនមែនជាអ្នកសុទិដ្ឋិនិយម (ដែលយល់ឃើញសុទ្ធតែល្អ ឬ ត្រូវ) ឬមិនមែនជាអ្នកទុទិដ្ឋិនិយម (ដែលយល់ឃើញសុទ្ធតែអាក្រក់ ឬ ខុស) នោះទេឬ ?

មួយចំណែកទៀត ព្រះពុទ្ធទ្រង់ទានាមថា ជាអ្នកធម្មាធិបតេយ្យ គឺព្រះអង្គយកធម៌ធ្វើជាធំ ។ ហេតុនេះហើយបានជាទៅក្នុងសាសនាព្រះអង្គ យើងសង្កេតឃើញមានការមិនប្រកាន់វណ្ណៈ បក្សពួក ពណ៌ សម្បុរជាដើម ដូចជាព្រះអង្គទ្រង់បានបញ្ជាតុសិក្ខាបរជាប់រហូតមកទល់សព្វថ្ងៃនេះថា តិក្ខណាដែលខើបនឹងចូលមកបួសក្នុងសាសនាព្រះអង្គត្រូវតែគោរពសំពះ ឧដ្ឋានរៀបក្រោយតិក្ខុដែលបានបួស ដែលមានវស្សាច្រើនជាង ព្រោះតិក្ខុបួសថ្មីនោះមកពីត្រកូលក្សត្រ សាមញ្ញក្តី មកពីត្រកូលក្សត្រក្តី ។

មុននឹងបញ្ចប់ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ព្រះពុទ្ធសាសនា ជាសាសនាដំកល់ផ្លូវចិត្ត ឧទ្ទិសបញ្ញាត្តិរិះរកទុសត្រូវជាធំ, ហើយជាសាសនា

ផ្អែកលើការពិសោធន៍ ខ្ញុំសង្កេតឃើញថា ការពិតខ្ញុំមិនពិត ។
ដូច្នេះព្រះពុទ្ធអាចកប់ថា ជាអ្នកទស្សនវិជ្ជាផង ជាអ្នកវិទ្យាសាស្ត្រផង
តែវិទ្យាសាស្ត្រព្រះពុទ្ធមានការឈមទៅកាន់ផ្លូវស្អាត ក្នុងផ្លូវចំរើន ក្នុងសុខ
ឲ្យជនទូទៅមិនមានរើសមុខ ជាវិទ្យាសាស្ត្រចំហ ។ ជនណាក៏ដោយ
បើចង់ចេះចង់ដឹងអាចរកមើលទ្រឹស្តី ឬរូបមន្តនៃវិទ្យាសាស្ត្រព្រះអង្គ នៅ
ក្នុងគម្ពីរនានាឃើញពាំងអស់ ព្រះពុទ្ធមិនចេះលាក់វិជ្ជារបស់ព្រះអង្គ
ឡើយ ។ ចំណែកឯវិទ្យាសាស្ត្រនៃអ្នកប្រាជ្ញសម័យបច្ចុប្បន្នវិញ ច្រើន
ប្រកបទៅដោយគុណសម្បត្តិផង គុណវិបត្តិផង ។បើមានជួបជាការស្រាវ
ជ្រាវរកឃើញខ្លួវជាតិបរមាណូ ។ ជាតិបរមាណូនេះបើគេយកមកប្រើ
ដើម្បីសុខភាពមនុស្សខ្លះ ឃើញថាមានប្រយោជន៍សំខាន់ណាស់ ប៉ុន្តែ
បើគេយកទៅប្រើដើម្បីជាគ្រឿងអាវុធបំផ្លាញវិញ ១ ក៏ឃើញថាមានការ
អន្តរាយសម្លឹមណាស់ដែរ ។

ទៅចប់ផុត ខ្ញុំមានបំណងសុំឲ្យលទ្ធិព្រះពុទ្ធសាសនាបានជ្រួតជ្រាប
ទៅក្នុងសតិសម្បជញ្ញៈ នៃអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រសម័យបច្ចុប្បន្នពាំង
អស់គ្នាបន្តិចទៀត ដើម្បីសូមឲ្យអស់លោកពាំងខ្លះយកវិទ្យាសាស្ត្រ
របស់ខ្លួនមកប្រើសម្រាប់តែផ្លូវសុភមង្គលបាន ហើយ ។ ខ្ញុំហ៊ានពោលថា

ដកបណ្តាលឲ្យពុទ្ធសាសនាបានចូលទៅដល់តាប់ក្តីសត្តិសម្បជញ្ញៈនៃអ្នក
វិទ្យាសាស្ត្របច្ចុប្បន្នឥឡូវនេះដែរ ដកបន្ទោះធម៌លោកៈ ទោសៈ មោហៈ ក៏វិទាសចាត់ថាតំពីសន្តានចិត្តអស់លោកដោយ
ពិត ហើយធម៌អហឹង្សាទើបចូលមកជំនួសវិញ ។ ពេលនោះសង្គ្រាម
ទើបត្រូវបាត់ជ័យ, សន្តិភាពពិភពលោកប្រាកដជាមានរូបភាពជាក់ស្តែង
ឡើង ហើយមនុស្សជាតិទាំងអស់ប្រាកដជាទទួលបានសេចក្តីសុខត្រប់ ។
គ្នាពុំមាន ។

ជ័យោ ព្រះពុទ្ធសាសនា !

ក្បែម-ឈឹម

(តទៅ)

ព្រះមហា ជ្វាន-ខាត់ រៀបរៀន

អរិន្ទមរេធិទាន ទុក្ករកិរិយាកថាទី ៦

១- ធម្មអាមាត្យត្រឡប់ទៅកបិលពស្តុ ២- ទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះ ៣- ទ្រង់សន្ទនានឹងព្រះបាទពិម្ពិសារ ៤- ទ្រង់ចូលទៅកាន់សំណាក់អាឡារតាបស ៥-ទ្រង់ចូលទៅកាន់សំណាក់ឧទ្ទកតាបស ៦- ទ្រង់ចូលទៅកាន់ឧរុវេលាប្រទេសសេនានិគម ៧- ទ្រង់ប្រព្រឹត្តភត្តកិលមថានុយោគ ៨-សេចក្តីឧបមា៣យ៉ាង ៩ ទ្រង់ធ្វើទុក្ករកិរិយា ១០-ទេពតាចូលទៅផ្សាយដំណឹងព្រះរាប៣ ១១- ទ្រង់ត្រឡប់បរិភោគអាហារវិញ ១២- បញ្ចវគ្គីយតាបសលះបង់ពោធិសត្វ ។

១- ធម្មអាមាត្យត្រឡប់ទៅកបិលពស្តុ

ព្រះពោធិសត្វទ្រង់ចព្វជ្ជាហើយ ធម្មអាមាត្យកំនាំយកគ្រឿងអាភរណៈទាំងឡាយទៅកាន់ព្រះនគរវិញ ។ ឯកណ្ឌកៈអាជានេយ្យបានឮព្រះតម្រាស់ព្រះពោធិសត្វចំពោះធម្មអាមាត្យដូច្នេះ ទឹកអាណិតខ្លួនដោយគិតយើញថា ខ្លួនកំត្រូវប្រាស់ព្រាត់អំពីម្ចាស់ដែរ ទំអត់សង្កត់សេចក្តីសោកស្រណោះអាឡោះអាល័យមិនបាន កំបែកហប្ចុំយ ស្ងាប់មួយរំពេចនោះ ទៅកើតស្ថានត្រៃត្រឹង្សឈ្មោះកណ្ឌកទេវបុត្រ ។ ធម្មអាមាត្យទៅតម្ចាក់ឯង យំសោកថប់ល្ហើរដើរបល្ហើរ ត្រឡប់ទៅព្រះពាជនគរ

ទៅដល់ហើយ យកសេចក្តីទៅក្រាបទូលព្រះបាទសុភ្មោទនៈ តាមបណ្តាំ
ព្រះពោធិសត្វសព្វគ្រប់ប្រការ ។ គ្រានោះ កោណ្ឌញ្ញព្រាហ្មណ៍បានឮ
ដំណឹងថា ព្រះពោធិសត្វចេញទៅសាងព្រះផ្នួសហើយ ទៅបបួលកូន
ព្រាហ្មណ៍ទាំង ៧ នាក់ដែលបានមកតាមគ្នារួចហើយ តែបានត្រឹម ៤ នាក់ជា
គំរប់ ៥ នឹងខ្លួន កំនាំគ្នាចេញទៅបួសតាមព្រះពោធិសត្វ ។

២- ទ្រង់ឮលាក់ក្រុងរាជគ្រឹះ

លុះទ្រង់បញ្ជូនរួចហើយ ស្តេចទៅប្រថាប់សម្រាកព្រះអង្គនៅក្នុង
អន្តរបិយម្ខាងអស់រយៈ ៧ ថ្ងៃ សោយបីតជាអាហារ, ថ្ងៃទី ៨ ទើបស្តេច
ប្រថាប់ចាត្រចេរ ទ្រង់ព្រះពាដំណើរដោយព្រះបាទ បម្លាយផ្លូវ ៣០
យោជន៍ តែ ១ ថ្ងៃដល់ក្រុងរាជគ្រឹះ ទ្រង់បទចរបិណ្ឌបាតតាមលំដាប់
ផ្ទះ ។ គាលណោះ ឮដំណឹងខ្លះខ្លាចខ្លួនទៅថាមានមនុស្សម្នាក់ចំឡែក
ធ្វើដំណើរមកដល់ទីក្រុង កំពុងដើរបិណ្ឌបាត ទើបថាជាទេវតាឬមនុស្ស
កំមិនដឹង ទើបថាជាទានវឬត្រកួនកំមិនដឹង ពួកអ្នកនគរបបួលគ្នាឈូឆរមើល
ព្រះពោធិសត្វ ។ ពួកពាដបុរសយកសេចក្តីក្រាបបង្គំទូលព្រះបាទពិម្ពិសារ
តាមដំណើរ ។ ព្រះបាទពិម្ពិសារទ្រង់ព្រះសណ្តាប់ហើយ មានព្រះ
បន្ទូលឲ្យពាដបុរសលបឃ្លាំចាំមើល បើជាអមនុស្ស ដល់ចេញពីនគរទើប
អន្តរាយបាត់ទៅ បើជាទេវតាទើបហោះទៅតាន់អាកាស បើជានាគទើប

មុជជ្រែកចូលកាន់ប្រឋមជ្ឈានទី ៤ បើជាមនុស្សធម្មតាទេ ចាន់ជាមិនបរិភោគអាហារ ឬក៏ឈប់បរិភោគមិនខាន ។ ឯព្រះមហាបុរសចាន់ជាអាហារល្មមញ៉ាំងជីវិតន្ទ្រិយឲ្យប្រព្រឹត្តទៅបានហើយ ស្តេចចេញអំពីនគរឆ្ពោះព្រះភក្ត្រទៅកាន់ញាកគ្នំបណ្តារៈ ប្រារព្ធធ្វើកត្តកិច្ចក្នុងទីនោះ ទតឃើញអាហារគួរបដិគ្គហៈ ដែលទ្រង់មិនធ្លាប់ឃើញបែបនោះសោះ ក្នុងអត្តភាពរបស់ព្រះអង្គ ទើបចូន្មានព្រះអង្គឯងថា «ម្នាលសម្ពុត្ត ! អ្នកកើតក្នុងត្រកូលក្សត្រសុទ្ធមាលជាតិ បរិភោគដោយភត្តាហារ ធ្លាប់បរិភោគតែគោជនមានក្លិនក្រអូបមានរសឆ្ងាញ់ផ្សេង ។ អ្នកមិនដឹងខ្លួនថាជាកេរបព្វជិតបែបនេះទេឬ ? ដើរបិណ្ឌបាតដូចម្តេចទើបចាន់ជាអាហារល្អ», ទ្រង់ឲ្យតាំងខ្លួនតាំចារណាបដិគ្គហសញ្ញាហើយទ្រង់សោយភត្តាហារនោះ ។

៣- ទ្រង់សន្ធនាធិងព្រះបាទពិម្ពិសារ

រាជបុរសដែលលបឃ្លាំចាំមើលឃើញដូច្នោះ ក៏ត្រឡប់យកសេចក្តីមកក្រាបទូលព្រះបាទពិម្ពិសារសព្វគ្រប់ប្រការវិញ, លុះព្រឹកឡើង ព្រះបាទពិម្ពិសារ ស្តេចឡើងរាជរថចេញទៅជាមួយនឹងរាមាត្យ ទៅកាន់ព្រះពោធិសត្វ នាបណ្ឌវបព្វត ទតឃើញព្រះពោធិសត្វហើយ កើតសេចក្តីជ្រះថ្លា ទើបត្រាស់សួរថា «បពិត្រសមណៈ ! ព្រះនាមទ្រង់ដូចម្តេច ? ស្តេចមកពីនគរណា ? មានជាតិនាមដូចម្តេច ?

ព្រះពោធិសត្វថ្វាយព្រះពរតបវិញថា «បពិត្រមហាពាជ ! អាត្មាភាព ឈ្មោះសិទ្ធត្ថ មកពីនគរកបិលព័ស្តុ ព្រះវរបិតា នាមព្រះបាទសុទ្ធោទន៍ ព្រះវរមាតា នាមព្រះនាងមហាមាយាទេវី នៅក្នុងជនបទដ៏តក្កំហិមភាន្ត សម្បូណ៌ដោយត្បាយាមដាត្រឿងរកខ្លាត ជាក្រុង ឡើងដែនកោសល ឈ្មោះគោតម(១)ដោយគោត្រ ឈ្មោះសក្យដោយត្រកូល អាត្មាភាពចេញបួសអំពីសក្យត្រកូលនោះ ដើម្បីប្រាថ្នាកាមកំឥតអង្គឺមានមួយ" ។

១-តម្លើរពុទ្ធវង្ស មានសេចក្តីពិស្តារថា តថាគតជាគោតមគោត្រ ចំរើនហើយក្នុងសក្យត្រកូល បានតាំងសេចក្តីព្យាយាមខុករូចហើយ បានសម្រេចសម្ពោធិញ្ញាណដ៏ខ្ពស់បំផុតជាសម្មាញ្ញូ ។ ល ។ ឧគ្គរៈថាតថាគតឈ្មោះកបិលព័ស្តុ ព្រះបិតាតថាគតឈ្មោះសុទ្ធោទន៍ ព្រះមាតាតថាគតឈ្មោះមាយាទេវី, តថាគតនៅក្នុងបំក្រងផ្ទះ ២៩ វស្សា មានប្រាសាទខ្ពស់ ៣ ខ្នង ឈ្មោះសុជន្ធ ១ ឈ្មោះកោក ១ នឹងកោញ្ច ១ មានស្ត្រីស្អិតស្អាងល្អហើយ ៤ ម៉ឺននាក់, នារីជាភរិយាឈ្មោះយសោធរា បុត្រឈ្មោះរាហុល ។ ដោយហេតុឃើញនិមិត្តទាំង ៤ ទើបតថាគតយកកណ្ឌកៈ ជាភាហនៈចេញចាកគេហដ្ឋាន ដើម្បីធ្វើសេចក្តីព្យាយាមដ៏ឧត្តមសំរេច ៦ ព្រះវស្សា, តថាគតបានប្រកបចក្កវត្តិលក្ខណទៃធ្វើបានដោយកម្រ ។ តថាគតជាដិនៈ ប្រកាសធម្មចក្រនៅតាព្រៃឥសិបតនៈមិគទាយវនៈទៀបក្រុងពារាណសី បានត្រាស់ជាសម្មាសម្ពុទ្ធឈ្មោះគោតមជាទីពឹងនៃសត្វលោកទាំងពួយ ។ ភិក្ខុជាអគ្គសាវក ២ រូបគឺ: កោលិតនឹងឧបតិស្ស, ឧបដ្ឋាកឈ្មោះអានន្ទ. ភិក្ខុនីជាអគ្គសាវិកា ២ រូបគឺ ខេមានឹងខេមាឧប្បលវណ្ណា, ឧបាសកជាអគ្គឧបដ្ឋាក ២ រូបគឺចិត្តៈនឹងហត្ថាឡវកៈ, ឧបាសិកាជាអគ្គឧបដ្ឋាយិកា ២ រូបគឺ ខុជ្ជុមាតានឹងនាងខុជ្ជា, តថាគតបានត្រាស់ជាព្រះសម្មាសម្ពុទ្ធដ៏ខ្ពង់ខ្ពស់ទៀបភោធិមណ្ឌល ។ ល ។

ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះគិតក្រែងព្រះពោធិសត្វស្តេចមានវាសនាជាមួយនឹងព្រះវរិន្ទព្រះអង្គ ទើបស្តេចត្រាស់សួរតេវ៉ាថា បពិត្រសមណៈ! ព្រះអង្គស្តេចមកនេះ ប្រកបដោយសិរីសួស្តីប្រសើរណាស់ ខ្ញុំព្រះអង្គគំជាអធិដ្ឋសហាយឈ្មោះពិម្ពិសារ ជាធំលើប្រទេសពីរ គឺអង្គដ្ឋនិងមគធរដ្ឋ ខ្ញុំព្រះអង្គនឹងបែងចែកពាជសម្បត្តិព្រមទាំងដែនទាំងពីរនេះថ្វាយមួយចំណែក ហើយយើងទាំងពីរនាក់ នឹងសោយពាជសម្បត្តិជាសុខសប្បាយតទៅ ។ ព្រះបរមពោធិសត្វទ្រង់ព្រះសណ្តាប់ហើយ ទើបត្រាស់តបថា សូមអរព្រះគុណថ្វៃវិសេសដែលទ្រង់ព្រះមេត្តាប្រោសបែងពាជសម្បត្តិប្រទាន តែអាត្មាភាពមកនេះ មិនមែនមានចេតនាចង់បានប្រយោជន៍ក្នុងវត្តុកាមនឹងកិលេសកាមទេ អាត្មាភាពបានលះបង់នូវចក្រពត្តិពាជសម្បត្តិដែលជិតមកកន្លងកណ្តាប់ដៃហើយ ដូចជាដុំខ្សេះ ដែលស្តោះចេញចាកមាត់ ព្រោះប្រាថ្នាសម្ងាសម្ពោធិញ្ញាណ ទើបបានជាអាត្មាភាពចេញបួស ។ ព្រះបាទពិម្ពិសារត្រាស់សួរទៀតថា " បពិត្រសមណៈ! ទ្រង់លះបង់ពាជសម្បត្តិដ៏ធំហើយចុះភ្នំជ្រោះ តើដោយហេតុអ្វី? " , ព្រះពោធិសត្វត្រាស់តបថា " បពិត្រមហារាជ! ព្រោះអាត្មាភាពបានឃើញទោសខ្លួន ៤ មានមនុស្សជរាជាអាទិ៍ ទើបបានជាចេញមកបួស " ។ ព្រះបាទពិម្ពិសារទ្រង់ត្រាស់អាពាធនាថា " សូមទ្រង់ព្រះ

រមត្តព្រោស ! កាលបើព្រះអង្គជ្ញាតសម្រេចសម្ងាសម្ពោធញ្ញាណហើយ សូមអញ្ជើញទ្រង់មកកាន់ដែនរបស់ខ្ញុំព្រះអង្គមុនគេ(១) ព្រះបរមគោតមសត្ថុ ទទួលពាក្យបដិញ្ញាថា «សាធុ។» ហើយព្រះជ្ញាតិម្ចាស់ក៏ក្រាបបង្គំលាត្រឡប់មកកាន់ព្រះនគរវិញ សមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកថា(២)។

"ព្រះរាជាពិម្ពិសារ ទ្រង់គង់លើប្រាសាទ បានទតឃើញព្រះពោធិសត្វដែលកំពុងបិណ្ឌបាត ទើបត្រាស់បំពោះអាមាត្យថា អ្នកទាំងឡាយ ចូរមើលសមណៈនេះមើល ! សមណៈនេះមានរូបល្អកំពស់ធំទំហំសមរម្យ សម្បុរស្អាត ជំណើរសម មើលទៅមុខត្រឹមមួយជ្រឹមឆ្ងាយ សំឡឹងតែបុះក្រោម មានស្មារតី សមណៈនេះដូចជាមិនមែនអ្នកត្រកូលហោកទាបចេញមកបួសទេដឹង ? អាមាត្យតាមមើលរហូតដល់ភ្នំបណ្ឌវៈ បានដឹងសេចក្តីហើយ ចូលមកក្រាបទូលព្រះរាជាពិម្ពិសារវិញ ។ ព្រះរាជាពិម្ពិសារស្តេចទៅដោយព្រះរាជរថ ជាមួយរាជបរិពារ

១- ព្រះអដ្ឋកថាចារ្យបំភ្លេចសេចក្តីថា «សូមទ្រង់មេត្តាត្រាស់ទេសនាប្រោស ខ្ញុំព្រះអង្គមុន» ។ ២- បព្វជ្ជាសូត្រ សុត្តនិបាត មហាវគ្គ សៀវ. ៥៥ ទំព័រ ១៣២ ។

ស្តេចប្អូលទៅប្រថាប់ហើយត្រាស់ចំពោះព្រះពោធិសត្វថា "ខ្លួនលោក នៅកំពុងពេញវ័យ នៅកំឡោះក្មេង ក្នុងបឋមវ័យមើលទៅដូចជាជាតិក្សត្រិយ៍ ប្អូរលោកធ្វើជាមេសេនាដ៏រុងរឿងដែលមានពួកជនប្រសើរជាបរិវារវិញទៅ! ហើយប្អូរបរិភោគនូវភោគៈទាំងឡាយចុះ! តែសូមប្រាប់នូវជាតិលោកដល់ខ្ញុំ។ បពិត្រមហារាជ! ត្រង់ទៅខាងនេះ មានជនបទមួយ នៅប្របភ្នំហិមវន្ត ជាជនបទបរិបូណ៌ដោយទ្រព្យនឹងជនមានឫទ្ធិយាមអាស្រ័យនៅក្នុងដែនកោសល គេត្រូវជាអាទិច្ចវង្សជាសាក្យៈ អាត្មាបេញ្ញាពីត្រកូលនោះមកប្អូស មិនត្រូវការដោយកាមទេ បានឃើញទោសកាមហើយ ចេញចាកកាម ប្រឹងព្យាយាមត្រេកអរក្នុងព្យាយាមនោះ" ។

៤- ទ្រង់ប្អូលទៅកាន់សំណាក់អាឡារតាបស

កាលនោះព្រះបរមពោធិសត្វត្រាច់ទ្រឹត្តស្ទះស្ទើរកតួកគណាចារ្យធំៗជាតាបសប្អូស្ស ប្អូជាពួកនិគ្រន្ថ ដែលមានឈ្មោះស្ទើថាជាអ្នកប្រព្រឹត្តត្រហ្មចរិយធម៌ម៉ត់ចត់ស្ត ចេតែងតួលទៅសាកស្ទួរដេញដេលឈានសមាបត្ត

ប្តូតិច្ចវត្តធម្មេន ។ ហើយទ្រង់ចាន់ប្រព្រឹត្តតបធម៌ តាមពួកគណាចារ្យ
ខោះ។ ល្បងមើល លុះឃើញថាមិនតេញព្រះទ័យហើយក៏ស្តេចចៀស
ចេញទៅស្វែងរកតទៅទៀត តាមស្រុកនិគមជនបទតួចដំរុងមគធរដ្ឋ ។
ថ្ងៃមួយ ទ្រង់ចូលទៅកាន់សំណាក់អាឡារតាបស ដើម្បីនឹងសាកសួរវត្ត
ប្រតិបត្តិ ដូចសេចក្តីដែលទ្រង់ចានត្រាស់ដឹងហើយ ចានត្រាស់ចំពោះ
ព្រះពោធិសត្តកុមារថា (១)

រាជកុមារ! កាលតថាគតបានបួសរួចហើយ ស្វែងរក
ផ្លូវកុសលសន្តិវរបទ(២) ក៏បានចូលទៅរក អាឡារតាបស
សូមប្រព្រឹត្តព្រហ្មចរិយធម៌ អាឡារតាបសឆ្លើយតបថា "អ្នក
ដ៏មានអាយុ ចូរនៅចុះ ធម៌នេះប្រាកដដូច្នោះ បើជាបុរសអ្នកដឹង
សេចក្តីហើយ មិនយូរឡើយ គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិ
អាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយ
សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤បាន" ។តថាគតបាន
រៀនធម៌នោះឆាប់រហ័ស មិនយូរឡើយ អាចពោលបានដល់ទៅ

១-ពោធិរាជកុមារសូត្រ, រាជវគ្គ, ម ម. ភាគ ២, ទំព័រ ៣៦០ ។ ២-ស្វែងរកផ្លូវធម៌
អ្វីជាកុសល និងធម៌អ្វីដ៏ប្រសើរដែលមិនមានធម៌ឯទៀតប្រសើរជាង ។

ញាណវិទ: និងចេវរវិទ: ដោយអាការគ្រាន់តែទន្ទេញដោយ
បបូរមាត់ និងដោយអាការគ្រាន់តែបរបាទៅមកប៉ុណ្ណោះឯង ។

តថាគត បានប្តូលទៅរកអាឡារតាបសម្ពងទៀត ហើយ
សួរថា "ម្នាលអារុឡសោកាលាម: ! លោកធ្វើជាក់ប្បាស់នូវធម៌
នេះដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យ
ដឹងបានត្រឹមតែប៉ុណ្ណោះទេឬ?" អាឡារតាបស បានប្រកាសដល់
អាកិញ្ចញ្ញាយតនឈ្មាន ។ តថាគតមានសេចក្តីត្រិះរិះថា "មិន
មែនមានសទ្ធា វីរិយ: សតិ សមាធិ បញ្ញា បំពោះតែអាឡារ
តាបសម្នាក់ឯងទេ សូម្បីយើងក៏មានសទ្ធា វីរិយ: សតិ សមាធិ
បញ្ញាដូច្នោះដែរ តែដួចម្តេចក្តី យើងត្រូវតែដំកល់ក្តីព្យាយាម
ដើម្បីធ្វើឲ្យជាក់ប្បាស់នូវធម៌ (អាកិញ្ចញ្ញាយតនឈ្មាន) របស់
អាឡារតាបសឲ្យខាងតែបាន", មិនយូរប៉ុន្មាន តថាគតក៏បានធ្វើ
ឲ្យជាក់ប្បាស់នូវធម៌នោះ(អាកិញ្ចញ្ញាយតនឈ្មាន)ដោយប្រាជ្ញា
ដ៏ឧត្តមយ៉ាងឆាប់រហ័ស ។ លំដាប់នោះតថាគតបានប្តូលទៅ

ស្តេរអាឡារតាបសម្តងទៀតថា ម្នាលអាវុសោកាលាមៈ លោក
បានធ្វើឲ្យជាក់ប្បាស់នូវធម៌នេះ(អាកិញ្ចញ្ញាយតនជ្ឈាន)ដោយ
ប្រាជ្ញាដ៏ឧត្តម ហើយញុំាងអ្នកដទៃឲ្យដឹងបាន ត្រឹមតែ
ប៉ុណ្ណោះទេឬ, អាឡារតាបសឆ្លើយតបថា ម្នាលអាវុសោ ខ្ញុំ
បានធ្វើឲ្យជាក់ប្បាស់នូវធម៌នេះ(អាកិញ្ចញ្ញាយតនជ្ឈាន)ដោយ
ប្រាជ្ញាដ៏ឧត្តមតែប៉ុណ្ណោះដែរ ។ យើងពេញជាមានលាភហើយ,
ភាពជាមនុស្សយើងបានដោយល្អហើយ ព្រោះឮពាក្យយើងបាន
ឃើញនូវសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នកដ៏មានអាយុ,
យើងបានដឹងធម៌ណា អ្នកក៏ដឹងធម៌នោះដែរ, អ្នកដឹងធម៌ណា
យើងក៏ដឹងធម៌នោះដែរ, ដូច្នេះអ្នកចូរមកចុះ យើងទាំងពីរ
នាក់នឹងនៅជួយគ្នារក្សាគណៈនេះ, ហើយតាំងតថាគត កាល
នៅជាអន្តេវាសិកឲ្យស្មើនឹងខ្លួន ឬជាតថាគតដោយការប្លែជាដំ
លើសលុប ។ តថាគតត្រិះរិះម្តងទៀតថា ធម៌នេះមិនមែនប្រ
ព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកវាគៈ ដើម្បី

សេចក្តីរំលត់ទុក្ខ ដើម្បីសេចក្តីរម្ងាប់ ដើម្បីសេចក្តីដឹង ដើម្បីត្រាស់ដឹង, ដើម្បីព្រះនិព្វានទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះ តថាគតមិនពេញចិត្តនឹងធម៌នោះ បានជាគេចចេញចាកធម៌នោះ ហើយបៀសចេញទៅ "។

៥-ទ្រង់ចូលទៅកាន់សំណាក់នុទ្ធកតាបស

លុះព្រះបរមគោដ៏សាស្តាបានសិក្សារៀនសូត្រនឹងអាឡារតាបសកាឡាមគោត្រហើយ ទ្រង់ចូលទៅកាន់សំណាក់នុទ្ធកតាបសកមបុត្រទៀត ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិជកុមារ(១) (មានដំណើរនិទានដូចគាបទ្រង់ចូលទៅសាកសួរក្នុងសំណាក់អាឡារតាបសដែរ តែកាលទ្រង់សាកសួរចប់ហើយ ទ្រង់បានសម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈានជាឈានទី៨ ប្រសើរជាងសេសជាងកាលទ្រង់រៀនក្នុងសំណាក់អាឡារតាបស តែទ្រង់តិចារណាតទៅទៀត ឃើញថាមិនមែនជាផ្លូវត្រាស់ដឹងរបស់ព្រះអង្គទេ ទើបទ្រង់ចេញចាកទីនោះទៅទៀត) ។

១-ពោធិរាជកុមារសូត្រភាដវគ្គ, ស្សៃ ២៤, ទំព័រ ៣៦៤ ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះកថាវត្ថុ

លោក ប៊ូ-ប៊ុំ ប្រែរៀបរៀង

(តមក)

បុញ្ញបច្ចយកថា

អត្ថិ អរហតោ បុញ្ញបច្ចយោតិ អាមន្តា អត្ថិ អរហតោ បុញ្ញបច្ចយោតិ ឧភោវំ វត្តព្វេ អរហា បុញ្ញកិសង្ខារំ អភិសង្ខារេតិ អនេញ្ជកិសង្ខារំ អភិសង្ខារេតិ ឧភោវំ វត្តព្វេ អរហា ចីវរំ ឧបេយ្យាតិ ។

ក៏នេះ ទីឆ្ងាយវិសជ្ជនាតនដ៏បុញ្ញបច្ចយកថាតទៅ មានដំណើរសេចក្តីថា សម្តេចព្រះមានព្រះភាគជាម្ចាស់ កាលត្រាស់ទេសនាតិហេតុអហេតុកថាចប់ពុះហើយ ទើបត្រាស់ទេសនាបុញ្ញបច្ចយកថា មានព្រះតុទ្ទដ្ឋីកាជាសកវាទិ បរវាទិ ដូចតទៅ ៖

សកវាទិ- បច្ច័យគឺបុណ្យ នៃព្រះអរហន្តមាន ឬគ្មាន ?

បរវាទិ - ខ្ញុំសូលថា បច្ច័យគឺបុណ្យ នៃព្រះអរហន្តនោះមាន ។

សកវាទិ- អ្នកថាមាន យើងមិនជាន់ជឿទេ ព្រោះឃើញក្នុងព្រះសូត្រថា " បុញ្ញកុបបហីនស្ស ព្រះអរហន្តមានបុណ្យទីឆ្ងាយលះបង់ហើយ " ហេតុអ្វីបានជាអ្នកថាមាន ។

បរវាទី អ្នកថា ព្រះអរហន្តលះបង់បុណ្យបានន្តោះកំពុងហើយ ចុំនែ្ត បុញ្ញាភិសង្ខារនៃព្រះអរហន្តនោះនឹងថាគ្មានកំថាមិនបាន ព្រោះព្រះអរហន្ត អស់អាសវៈហើយ ហើតុអ្វីបានធ្វើបុណ្យច្រើនដល់ប៉ុន្មានក៏ដោយ ក៏បុណ្យ នោះមិនបានជាបច្ច័យក្នុងភពខាងមុខឡើយ ។

សកវាទី អ្នកថា បុញ្ញាភិសង្ខារនៃព្រះអរហន្តគ្មាននោះ យើងនៅ មិនខាន់ដឿខេ, ចើព្រះអរហន្តគ្មានបុញ្ញាភិសង្ខារព្រោះអស់អាសវៈហើយ តើលោកធ្វើបុណ្យ ដើម្បីប្រយោជន៍អ្វីទៀត បុញ្ញាភិសង្ខារ អភិ-សង្ខារភេតិ យើងយល់ឃើញថា ព្រះអរហន្តរមែងធ្វើបុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អានេញ្ជាភិសង្ខារ ដើម្បីការពុសលដ៏ប្រព្រឹត្តទៅដើម្បីភព, ដើម្បីការពះនឹងឲ្យបានជាធំ, ដើម្បីកោតសម្បត្តិ ។

បរវាទី- ឯហោរំ វត្តព្វេ អ្នកកុំថាយ៉ាងនោះឡើយ មិនគួរខេ ។

សកវាទី- ព្រះអរហន្តនឹងតម្បីឲ្យទ្រព្យចីវរបិណ្ឌបាតសេនាសនៈ គិ-លានប្បច្ចយភេសជ្ជបរិក្ខារ នឹងនមស្ការព្រះចេតិយតម្បីមានខ្លះដែរឬខេ ?

បរវាទី- កំពុងលូលថាមាន ។

សកវាទី- ចើព្រះអរហន្តឲ្យភាវ នឹងនមស្ការព្រះចេតិយហើយ ពាក្យដែលអ្នកឆ្លើយថា បុញ្ញាភិសង្ខារនៃព្រះអរហន្តគ្មាននោះ មិនគួរនឹង ផឿបានឡើយ ដ្បិតពាក្យមុខនឹងពាក្យក្រោយមិនសមគ្នាសោះ ។

បាវចនៈ- សួរត្រឡប់ទៅវិញថា ព្រះអរហន្តចំពោះញាតិ ទើប
នមស្ការព្រះចេតិយនោះតើ ដើម្បីប្រយោជន៍អ្វី ?

សក្កវាទី- ម៎ំ កុកកេតិ ព្រះអរហន្តធ្វើយ៉ាងនោះ ដោយអំណាច
ទើបឲ្យឃើញជាតួយ៉ាង សត្វកើតមកខាងក្រោយទើបធ្វើតាមតទៅ
ដើម្បីទើបឲ្យព្រះពុទ្ធសាសនាបម្រើនវុងរឿងបិតថេរចើរកាល ដែលព្រះអរ-
ហន្តប្រកបដោយបញ្ញាច្រើន មានលោកច្រើននោះ អស្រ័យកុសល
អំពីបុព្វជាតិ កុសលដែលលោកបានធ្វើក្នុងកាលសម្រេចព្រះអរហន្តរួច
នោះហើយ ទើបបានជាបច្ច័យទៅក្នុងខាងមុខកំពុងអង្គឹមានឡើយ ។

បុញ្ញបច្ចយកថា ចប់

អបុញ្ញបច្ចយកថា

ឆដ្ឋំ អរហាតោ អបុញ្ញបច្ចយោតិ អាមន្តា អរហា ប-
ហីនបុញ្ញាតោ យទិទំ បុញ្ញំ កកេន្តោ ចាបំ កកេយ្យ
អបុញ្ញបច្ចយោតិ អបុញ្ញំ ឯ កកេយ្យាតិ បហីនបុញ្ញ-
តោតិ មិច្ឆាតិ ។

ក៏នេះទើបានវិសជ្ជនាក្នុងអបុញ្ញបច្ចយកថា មានដំណើរសេចក្តី
ជាសក្កវាទី បាវចនៈ ដូចតទៅនេះ

សក្កវាទី- អកុសលកម្មទើបតាមឲ្យផល ជាបច្ច័យក្នុងខាងមុខ

នៃព្រះអរហន្តខោះ មានឬគ្មានទេ ? យើងចូលចិត្តថា ការចាប់នៃព្រះអរហន្តខោះគ្មានទេ តើទឹងត្រូវដូចយើងចូលចិត្តដែរឬមិនត្រូវ ?

បរវាទី អើ, ត្រូវដូចពាក្យអ្នកថាហើយ ការចាប់នៃព្រះអរហន្តនោះទឹងជាបច្ច័យទៅទៀតមិនបានទេ ព្រោះលោកលះបង់នូវបុណ្យទឹងចាប់បានជ្រះស្រឡះហើយ ដែលលោកនឹងធ្វើ កំធ្វើតែកុសល ឯអកុសលលោកលែងធ្វើហើយ ។

សកវាទី- ពាក្យដែលអ្នកធ្វើយមកនេះ ពាក្យមុនទឹងពាក្យក្រោយមិនសមគ្នាទេ កាលដើមយើងសួរអ្នកថា អបុញ្ញាបច្ច័យនៃព្រះអរហន្តមានឬគ្មាន? អ្នកធ្វើយថាគ្មានទេ ព្រោះលោកលះបង់បុណ្យទឹងចាប់ជាច់អស់ហើយ ដល់ចុងក្រោយ អ្នកត្រឡប់ជាពោលថា ព្រះអរហន្តបើធ្វើអ្វី ។ កំធ្វើតែបុណ្យ មិនធ្វើបាបសោះ ដូច្នេះយើងនៅមានសេចក្តីសង្ស័យដូចអ្នកនិយាយថា ព្រះអរហន្តបើធ្វើអ្វី ។ កំធ្វើតែបុណ្យ យ៉ាងនេះ បុញ្ញាភិសង្ខារយ្យ ចេតនាព្រះអរហន្តនៅធ្វើបុណ្យ កំនៅតែលះបង់បុណ្យមិនបានដែរហើយយើងយល់ឃើញថា ការចាប់តំព្រះអរហន្តនៅធ្វើ ដូចពាក្យក្នុងព្រះវិន័យថា ព្រះអរហន្តរមែងប្រើឲ្យគេធ្វើកុដិ ទឹងខលួចាប់ពាល់បានជាទិស្សគ្គីយ៍ ប៉ុន្តែតុំមានអាបត្តិ ។

បរវាទី- សួរត្រឡប់ទៅវិញថា អ្នកថាព្រះអរហន្តលះបង់បុណ្យ

ខ្ញុំឯងបាបមិនបាននោះតើ ដោយហេតុដូចម្តេច ?

សការ៉ាទ័- យើងឃើញក្នុងព្រះសូត្រថា ព្រះអរហន្តដែលមានសរីរៈពិតលពិការដំណើរក្តី អង្គុះមានរូបស្ត្រីដើរតាមពីក្រោយក្តី ហើយព្រះអរហន្តនោះរមែងឲ្យចំរើនឈ្មោះថាសាសនៈ ខ្ញុំឯងសូមបំភ្លេចគាន, សំដែងធម្មទេសនា ក្នុងព្រះសូត្រពោលទុកផ្សេង។ ដូច្នេះ បានជាយើងថាលះបុណ្យខ្ញុំឯងបាបមិនបានពាំងពីរប្រការ ។ អ្នកជ្រាបគប្បីសន្និដ្ឋានថា ព្រះអរហន្តលះបុណ្យខ្ញុំឯងបាបមិនបាននោះ សំដៅយកបុណ្យខ្ញុំឯងបាបដែលធ្វើក្នុងបច្ចុប្បន្នកាល តុំពាន់បានសម្រេចជាព្រះអរហន្តលុះបានសម្រេចជាព្រះអរហន្តហើយ សូម្បីធ្វើបុណ្យខ្ញុំឯងបាបច្រើនដល់ប៉ុន្មាន បុណ្យខ្ញុំឯងបាបនោះក៏មិនបានតាមឲ្យផលក្នុងអនាគតកាលឡើយ ខ្ញុំឯងនាំរឿងមកសំដែងដោយប្រសង្ខេប ដូចមានសេចក្តីតទៅនេះ ៖

អង្គុលិមាលត្មេភេមិ មែនពិត ព្រះអង្គុលិមាលត្មេរនោះសម្លាប់មនុស្សជាច្រើនខ្ញុំឯងប្រមាណមិនបាន គ្រាន់តែកាត់យកម្រាមដៃម្នាក់ ។ មួយ ។ មកដោតត្រណោតទុកឲ្យបានគ្រប់មួយពាន់នាក់ ម្រាមដៃចាស់ ។ នោះចេះតែស្អុយរលួយអស់ទៅ មិនបានគង់នៅឲ្យគ្រប់មួយពាន់នាក់សោះ លុះបានមកជួបខ្ញុំឯងសម្តេចព្រះមានព្រះភាគ ក៏បានសម្រេចព្រះអរហត្តព្រោះបានស្តាប់ព្រះធម្មទេសនាបញ្ចូនបញ្ចាទៅតាមក្រសែព្រះ

សទ្ធម្មេទេសនា លុះបានសម្រេចព្រះអរហត្តហើយ កម្មដែលសម្លាប់មនុស្សនោះមិនបានតាមផៀឲ្យផលឡើយ ព្រោះជាអរហាសិកម្ម ។

ព្រះអរហន្តធ្វើការកុសលច្រើនដល់ប៉ុន្មានក៏ដោយ កុសលនោះមិនបានតាមផៀឲ្យផលទេ ដូចព្រះខីណាសវៈតែ១រូបមួយអង្គនិមន្តទៅគាបវេគ្នុកអន្តរាជបុរី នៅវេលាស្រុកកើតទុព្ភិក្ខភ័យ បានអាហារបិណ្ឌតែបែងចែកឲ្យក្មេងទៀត កុសលនោះមិនបានតាមផៀឲ្យផលខាងមុខទេ ព្រោះជាអរហាសិកម្ម លោកបួលនិព្វានហើយ កុសលនឹងអកុសលក៏អស់ដែរ លែងតាមផៀខាងមុខទៀត ។

ព្រះអរហន្តមានលាភច្រើន, មានយសច្រើន, មានបុត្តច្រើន, មានអាយុកាតច្រើន ប្រាកដក្នុងព្រះពុទ្ធសាសនា ហើយបានសោយសុខវេទនានឹងទុក្ខវេទនានោះ ហេតុតែផលនៃកុសលនឹងអកុសលក្នុងកាលមុនបានកសាងទុកមក ដូចព្រះសីវលិត្ថេរជាដើម បានពិឯតទគ្គៈជាព្រះមហាថេរលើសជាងព្រះមហាថេរទាំងឡាយ ដែលចាត់ថាជាអ្នកមានលាភច្រើនក្នុងព្រះពុទ្ធសាសនា ក៏ព្រោះតែកុសលដែលខ្លួនធ្វើទុកមក ។

ព្រះបូតិតត្តត្ថេរ មានសរីរវាយវៈតើតដំបៅរលួយស្អុយ ពងែបែកហូរខ្ទុះ ក៏អាស្រ័យផលនៃអកុសលកម្មក្នុងជាតិមុន ។ ព្រះបូតិតត្តត្ថេរនោះកាលជាតិមុនតើតក្នុងត្រកូលព្រាហ្មណ៍ស្តុកស្តម្ភ មានសេចក្តីប្រមាថ

សម្លាប់សត្វស្ងាបលក់ចិញ្ចឹមជីវិតជានិច្ចកាល សត្វដែលលក់សល់ជាក់
ច្រើនបន្តាំនឹងទុកខ្លះ គាប់ស្ងាបមិនឱ្យហើរបួចខ្លះ ឱ្យនៅរស់បានយូរថ្ងៃ
កាលបើលក់អស់ហើយ ទើបទៅកចាប់យកមកលក់ទៀត យ៉ាងដូចំ
នាយព្រានធ្វើអំពើអកុសលនេះដកបដល់អស់ជីវិត. ឯងមុខអំពីពុតចិត្តទៅ
បានទៅកើតក្នុងនរកអស់កាលជាយូរ លុះរួចពីនរកហើយមកកើតជា
ប្រេត, មកកើតជាសត្វតិរច្ឆាន កើតក្នុងទុគ្គតិជាយូរអង្វែងកំណត់ពុំបាន
មិនបាន ចេះតែគ្រាច់ឆ្អែតវិលវល់ទៅក្នុងវដ្តសង្សារ សោយទុក្ខ
វេទនាជាសហ័ស ព្រោះតែផលនៃអកុសលកម្មដែលខ្លួនធ្វើពុំមក ។

ឯមស្មឹ តុច្ចុបច្ចុឧ លុះដល់ព្រះពុទ្ធសាសនានេះ នាយព្រាន
នោះមកកើតជាមនុស្សទៅក្នុងនគរសាវត្ថី ចេញបព្វជ្ជាបានឧបសម្បទា
ក្នុងព្រះពុទ្ធសាសនា សេសផលនៃអកុសលកម្មនោះ ទៅមិនទាន់អស់
ក៏កើតដំរលំ តែងបែកស្លុយហូរខ្ទុះស្អុយតេញតាំងខ្លួន សោយទុក្ខវេទនា
ជាខ្លាំង ព្រោះកាលពីបុព្វជាតិបានធ្វើកម្មជាអកុសល ។

សម្តេចព្រះបរមគ្រូធំត្រាស់ថា វិស័យកម្មវិបាកនេះជា
អចិន្ត្រៃយ៍ គឺបុគ្គលមិនគួរគិត បើមិនបានដល់ព្រះនិព្វានជាបណា
កុសលនឹងអកុសលរមែងជាប់តាមខ្លួនទៅជាបន្តោះ ព្រោះផលនៃអកុ-
សលនោះ មានច្រើនស្ថាន ដោយអំណាចនៃកម្មជាអបរាបរវេទនីយ៍ បាន

ចន្លោះនៃកាលកាលណា កើឡើងដល់កាលនោះ ។

ដែលថាព្រះអរហន្តលះបុណ្យនិងបាបបានៈ សំដៅយកបុណ្យនិងបាបដែលខ្លួនធ្វើក្នុងជាតិបានសម្រេចព្រះអរហត្ត តើតជាអង្គព្រះអរហន្ត ហើយបាបនិងបុណ្យមិនបានតាមទៅឲ្យផលក្នុងព្រះនិព្វានទេ ហេតុនោះបានជាថា អបុញ្ញាបច្ចយនៃព្រះអរហន្តគ្មានទេ ។

អបុញ្ញបច្ចយកថា ចប់ ។

សញ្ញាវេទយិតនិរោធកថា

លំដាប់នេះ ទើរវិសជ្ជនាក្នុងសញ្ញាវេទយិតនិរោធកថា ដោយពាក្យជាសកវាទី បរវាទី ដូចសេចក្តីតទៅនេះ ៖

សកវាទី- សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកិយឬជាលោកុត្តរៈ ?

បរវាទី- ជាលោកុត្តរៈ ។ អ្នកកុំចូលចិត្តថា សញ្ញាវេទយិតនិរោធសមាបត្តិជាលោកិយ ព្រោះថាបុគ្គលអ្នកចូលនិរោធសមាបត្តិបាននោះ ចំពោះតែបុគ្គលបានសម្រេចព្រះអរហត្ត ទើបុគ្គលបានសម្រេចព្រះអនាគាមីពួកនេះប៉ុណ្ណោះ ។ ឯការដែលបានធ្វើសក្ការបូជាឬប្រទូសរ៉ាយដល់ព្រះអរិយបុគ្គលអ្នកចូលនិរោធសមាបត្តិ ទើចេញពីនិរោធសមាបត្តិវិញនោះ ក៏បានសោយផលនៃកុសលទើអកុសលនោះជាទិដ្ឋធម្មវេទនីយ៍

ជានសោយផលយើញជាក់ស្តែងក្នុងកាលជាបច្ចុប្បន្ន ដូចកាលវិស្ស៊ីយ
បុរសជាមនុស្សកំសត់ខ្មត់ខ្មែត ក៏ឃើញជានប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះ
មហាកស្សបត្ថេរដែលចេញពីនិរោធសមាបត្តិ ខ្លួនត្រេកអរណាស់ ពុំមាន
គេមនស្សសោះ ព្រោះកាជនាហារនោះ ក៏ឃើញកមកបម្រុងឲ្យខ្លួន
បរិភោគ ហើយបែរជាប្រគេនទៅព្រះមហាកស្សបត្ថេរវិញ ជានសោយ
ផលជាទិដ្ឋធម្មវេទនីយកម្ម ព្រះមហាកស្សត្ថេរទ្រង់ព្រះមេត្តាប្រោសព្រះពុទ
ជានាទីឲ្យធ្វើជាមហាសេដ្ឋី ។

ឯបុគ្គលេអ្នកប្រទូសព័ឃដល់ព្រះអរិយជាម្ចាស់ដែលចូលនិរោធសមា-
បត្តិ ជានសោយផលនៃអកុសលជាទិដ្ឋធម្មវេទនីយ៍នោះ ដូចនន្ទយក្ស
ប្រទូសព័ឃដល់ព្រះសារីបុត្តត្ថេរ ដែលគង់ទៅកន្លែងទីអព្ភោកាសចូលនិរោធ-
សមាបត្តិ ។ នន្ទយក្សប្រហារព្រះសិរនៃព្រះថេរៈ ចំណែងទីឆ្អឹងបែក
ធ្លាយ ។ តាមការពិត ព្រះអរិយជាម្ចាស់គាំងឡាយ ដែលចូលនិរោធ-
សមាបត្តិ សូម្បីបុគ្គលកាប់ទំងជាវ ចាក់ទំលំពែង ឬដែកស្រួច ចាញ់
ទំងធ្នូស្នាកាំភ្លើង ទំងគ្រឿងសស្ត្រាវុធអ្វី ។ ក្តី សរីរវត្ថុរបស់លោក
ទំងជានដាច់ដាចធ្លុះធ្លាយ បែកចាក់បន្តិចបន្តួចក៏ឥតអង្គើមានសោះឡើយ
សូម្បីតែឈឺចាប់បន្តិចបន្តួចប៉ុនសរសៃកេមមួយប៉ុណ្ណោះ ក៏គ្មានឈឺចាប់
ដែរ ឯនន្ទយក្សនោះ លុះប្រទូសព័ឃដល់ព្រះធម្មសេនាបតីសារីបុត្រ

រួចហើយក៏ភ្ជាក់ឡុះមកលើប្រថពី ។ ស្រូបឡុះទៅក្នុងអរិយមហានរក ហេតុតែប្រទូសកិលេសដល់ព្រះអរិយជាម្ចាស់ ដែលកំពុងចូលនិពេធសមាបត្តិ ។

សកវាទី- បុគ្គលដែលបានសម្រេចព្រះអរហត្តហើយនោះ ខ្ញុចស្លាប់ដែរឬទេខ្ញុ ?

បរវាទី- ន ភាយតិ បុគ្គលដែលបានសម្រេចព្រះអរហត្តហើយនោះ មិនខ្ញុចស្លាប់ទេ ។

សកវាទី- ដូចជាយើងបានឮមកថា បឋមពោធិយំ ក្នុងកាលសម្តេចព្រះបរមសាស្តាបានត្រាស់ដឹងជាដំបូងថ្មីៗនោះ មនុស្សទាំងឡាយបបួលគ្នាទាំលាភសក្ការៈដ៏ច្រើនមកបូជាក្នុងព្រះពុទ្ធសាសនា ពាល់តែពួកអន្យតិរ្ថយ៍សាបសូន្យបាត់លាភសក្ការៈ ។ ទើបពួកអន្យតិរ្ថយ៍ទាំងឡាយចូលទៅក្នុងទីស្ងាត់គិតអានប្រឹក្សាគ្នាថា កេ ជានាម ពួកយើងដឹងឬទេ? ។ មានអន្យតិរ្ថយ៍មួយពួកឆ្លើយថា ជានាម យើងដឹងថាលាភសក្ការៈនេះតែងមានដល់ព្រះសមណគោតម ព្រោះអាស្រ័យតែព្រះមហាមោគ្គល្លាន ទេវលោកំ កត្វា ព្រះមហាមោគ្គល្លាននោះទៅឯទេវលោក សួរអំពីកុសលដែលទេវបុត្រទេពធីតាទាំងឡាយធ្វើ លុះទេវបុត្រទេពធីតាទាំងនោះប្រាប់ឲ្យដឹងហើយ ក៏នាំគ្នាមកប្រាប់មនុស្សទាំងឡាយថា ឯវរូបំ កត្វា ទេវបុត្រឈ្មោះនេះ ទេពធីតាឈ្មោះនេះ កាលនៅ

ក្នុងមនុស្សលោក តើតក្នុងស្រុកនោះ ជនបទនោះបានធ្វើកុងកាកុសលយ៉ាងនេះ ។ លុះអស់ជីវិតហើយបានទៅកើតក្នុងស្ថានសួគ៌ បានសោយទិព្យសម្បត្តិយ៉ាងនោះ ។ មានបរិវារចំនួនប៉ុណ្ណោះ ។ ។

ប្រការមួយទៀត ព្រះមហាមោគ្គល្លានោះកោងស្ថានកេហើយសួរអំពីអកុសលកម្មដែលសត្វនរកធ្វើ ដឹងហើយនាំនាំពាក្យសត្វនរកនោះយកមកប្រាប់ពួកមនុស្សថា ម៎ាវ្ហ៎ំ តកត្វា សត្វនរកឈ្មោះនោះ ។ បានសោយទុក្ខវេទនាក្នុងនរកនោះយ៉ាងនេះ ។ ព្រោះហេតុកាលខ្លួនស៎ នៅក្នុងមនុស្សលោកនេះ បានធ្វើអំពើអកុសលយ៉ាងនោះ ។ ។

តស្ស តកំ សុត្វា មនុស្សពាលឆ្កួយបានស្តាប់ពាក្យនៃព្រះមហាមោគ្គល្លានោះប្រាប់ខ្លួវកម្មផ្សេង ។ ក៏នាំយកលាភសក្ការៈមកធ្វើបុណ្យ បំពេញចិរវេនជាដើមដល់ព្រះសមណគោតម ដោយហេតុបានស្តាប់ពាក្យនៃព្រះមហាមោគ្គល្លាន បើពួកយើងសម្លាប់ព្រះមហាមោគ្គល្លានឲ្យស្លាប់ផុតទៅហើយ លាភសក្ការៈនៃព្រះសមណគោតមក៏មុខជាសាបសូន្យអស់ទៅ ត្រឡប់ជាកើតលាភសក្ការៈដល់ពួកយើងវិញ ។ អម្ប្រត្តីរ៉ាយ៏ពាលឆ្កួយយល់ព្រមគ្នាថា ។ ចុះយ៉ាងនេះទើនាំឲ្យបានសម្រេចប្រយោជន៍ ញ៉ាំងលាភសក្ការៈឲ្យកើតខ្លាំងបាន ។

ស ឯ្ចដ្ឋាំ តកត្វា លុះសម្រេចចិត្តត្រង់គ្នាដូច្នេះហើយ ក៏បបួល

ជនតាំងពាយដែលជាឧបាសក រៃប្រាក់ចំនួយពាន់កហាបណៈហើយ
មកកកេរតាំងពាយ ឲ្យប្រាក់មួយពាន់នោះទៅពួកចោរ ប្រើពួកចោរ
ឲ្យទៅសម្លាប់ព្រះមហាមោគ្គល្លាន ។ សម្បដិច្ឆិត្វា ពួកចោរខ្លួល
ពាក្យអន្សត់ឆ្កែយើងហើយ ទៅតំកុដិព្រះមហាមោគ្គល្លាន ។ កិរ្រាបថា
ពួកចោរមកតំកុដិគេចចេញទៅតាមបង្អួចខ្លួច ពួកចោរកកលោកមិន
ឃើញនាំគ្នាលៃទៅផ្ទះវិញ លុះដល់ថ្ងៃគំរប់ពីរនាំគ្នាមកតំកុដិម្តងទៀត ។
ព្រះមហាមោគ្គល្លានត្ថេរគេចចេញទៅតាមរហាជាដ៏។

តាលបើមានរឿងយ៉ាងនេះ នឹងថាព្រះអរហន្តមិនអាចស្លាប់ដូចម្តេច
កើត បើមិនអាចស្លាប់ហើយ មុខជាមិនគេចរៃទៅណា មុខជានៅឲ្យ
ចោរសម្លាប់មិនបានឡើយ ។ ហេតុនេះ យើងយល់យើញថាព្រះអរហន្ត
អាចស្លាប់នឹងអាចអាជ្ញា ។

បរវាទី- អរហា ជាម ឈ្មោះថាបុគ្គលអ្នកបានសម្រេចអរហត្ត
ហើយនោះ មិនអាចស្លាប់ទេ សមតាមពាក្យក្នុងព្រះសូត្រមួយ សម្តេច
ព្រះបរមសាស្តាត្រាស់ទេសនាឧកថា សព្វេ សត្តា តាសន្តិ សព្វេ
តាំងពួយតាំងពួរមែងអាចនំពីមរណភ័យ គឺអាចស្លាប់នឹងអាចអាជ្ញា
ចត្តារោ បហេត្វា រៀវលែងតែសត្វបួនជំពូក គឺដំរីអាជានេយ្យ ១
សេះអាជានេយ្យ ១ គោទសកពាជអាជានេយ្យ ១ ព្រះខ័ណាស្រព ១

គ្រប់ជាបួនដំពូក ។

សត្វបីដំពូកនេះគឺ ជ័រអាជានេយ្យ ១ សេះអាជានេយ្យ ១ គោអាជានេយ្យ ១ ឋានជាមិនខ្វាចស្វាប់នោះ ព្រោះហេតុមិនឋានឃើញថាសត្វពួកណាទំនងហ៊ានមកជាសត្រូវនឹងខ្លួនសោះ សុទ្ធតែខ្លាចខ្លួន ។

ចំណែកព្រះខីណាស្រពជាំងខ្លាច មិនខ្វាចស្វាប់នោះ ព្រោះហេតុឃើញថា គ្មានសត្វណាមិនស្វាប់ទេ សុទ្ធតែស្វាប់ដូចគ្នាជាំងអស់ ។ បើនឹងថាព្រះអរហន្តខ្លាចសេចក្តីស្វាប់ ឃើញថាខុសក្រសែព្រះពុទ្ធដីកា; ដែលព្រះមហាមោគ្គល្លានគេចរត់ខ្មាំងនោះ ព្រោះលោកភ្លាំងបានតិចារណាលុះលោកតិចារណាឃើញហើយ គិលែងរត់ មកនៅចាំឲ្យចោរចាប់វាយប្រហារ ។ ព្រះមហាមោគ្គល្លាននេះមានឫទ្ធិច្រើនណាស់ លោកចង់សំដែងឫទ្ធិយ៉ាំងណា ។ ក៏បានសម្រេចតាមសេចក្តីប្រាថ្នាគ្រប់ប្រការ បើលោកគង់ដែនឹងពួកចោរ ។ វាយលោកមិនបានទេ ព្រះមហាថេរមិនបានគបគន់ឯពួកចោរសោះ លោកបណ្តោយឲ្យពួកចោរវាយតាមចិត្ត ហេតុតែលោកមិនខ្វាចស្វាប់ ។ អ្នកប្រាជ្ញទាំងឡាយគប្បីសន្និដ្ឋានថា ព្រះអរហន្តទាំងឡាយមិនបានខ្វាចសេចក្តីស្វាប់ដោយន័យដូច្នេះ ។

សញ្ញាវេទយិតនិរោធកថា ចប់ ។

អសុចិសុក្កវិសដ្ឋិកថា

ឧត្តិ អរហតោ អសុចិសុក្កវិសដ្ឋិតិ អាមន្តា អត្តិ អសុចិសុក្កវិសដ្ឋិ មារកាយិកានំ នេវតាជន្តិ ឧភោវិ វត្តព្វេ ។ មារកាយិកានំ នេវតានំ ឧត្តិតិ នោ វត្តព្វេ មារកាយិកា នេវតា ឧបសំហរន្តិតិ ។

ក៏រៈនេះ ទំនិរវិសជ្ជនាក្នុងអសុចិសុក្កវិសដ្ឋិកថាតទៅ តាំងជាសកវាទីបរវាទីដូច្នេះ៖

សកវាទី- អសុចិសុក្កវិសដ្ឋិ ប្រែថា ការបញ្ចេញទឹកអសុចិជាសុក្កនៃព្រះអរហន្ត ដែលអស់អាសវៈហើយ មានដែរឬទេ?

បរវាទី- គ្មានទេ, ព្រះអរហន្តទាំងឡាយដែលអស់អាសវៈហើយលោកមិនបញ្ចេញទឹកអសុចិជាសុក្កៈសោះឡើយ ។

សកវាទី- បើថាគ្មានដូច្នោះ ចុះហេតុដូចម្តេច តិក្ខាធាតុដែលចូលទៅនៅក្នុងជនឯព្រះអរហន្តហើយ នៅតែបញ្ចេញទឹកអសុចិសុក្កៈ តាលតែសម្តេចព្រះបរមសាស្តាទ្រង់បញ្ញត្តសិក្ខាបទ ដូចមានសេចក្តីនៅក្នុងសិក្ខាបទបញ្ញត្តិស្រាប់ ពាក្យដែលអ្នកថាព្រះអរិយបុគ្គលបានសម្រេចព្រះអរហត្តហើយ មិនបញ្ចេញទឹកអសុចិសុក្កៈនោះយើងនៅមិនទាន់ជឿទេ <u>បើលោកអស់អាសវៈហើយមិនបញ្ចេញទឹកអ-</u>សុចិសុក្កៈសោះ ចុះហេតុអ្វីបានជាសម្តេចព្រះសុគតទ្រង់បញ្ញត្តសិក្ខាបទ?

(តៅមាន៣)

មធុរសវិហិណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ឯនាងខេពជីតានោះ ជានសោយសិរីសម្បត្តិក្នុងស្ថានសួគ៌នោះ ជាសុខដ៏ប្រសើរដេកបរៀងមក តែឯអន្លើលទៅមក តែក្នុងសុគតិភពពុំដែលជួកទៅកើតក្នុងទុគ្គតិភពឡើយ តែងសោយសុខតែក្នុងស្ថានមនុស្សលោកទំនឹងខេវរលោក កន្លងទៅ ៩ ១ កប្ប ជាប់អំពីកន្លះកប្បរយើងនេះថយក្រោយ, លុះដល់មកក្នុងកាលព្រះមានព្រះភាគជាម្ចាស់នៃយើង នាងខេពជីតានោះក៏ជានច្យុតចុះមកចាប់បដិសន្ធិក្នុងផ្ទៃនាងព្រាហ្មណ៍ ជាកំរៀបរបស់ដេជ្ជព្រាហ្មណ៍ ជាត្រកូលដ៏ខ្ពង់ខ្ពស់ ក្នុងខេវបុត្រនគរជាដម្ពូបនេះឯង ។ នាងជានអាស្រ័យទៅក្នុងផ្ទៃមាតាត្រប់ខែដប់បីបួណាំហើយ ក៏កើតចេញអំពីផ្ទៃមាតាមកដោយសួស្តីឥតមានតំយកអន្តរាយអ្វីឡើយ ។

ចាប់ដើមតាំងតែអំពីនាងជីតានោះកើតចេញចាកផ្ទៃនៃមាតាហើយ មានអង្គស្រួវសាលីសុទ្ធប្រមាណ ៨ នាឡី ។ កើតឡើងសម្រាប់នាងសព្វ ១ ថ្ងៃ តុំដែលជាប់ឡើយ ។ ដោយផលនៃសង្ឃដែលនាងជានថ្វាយចង្ហាន់ព្រមតាំងកេសផ្ទះដល់តំកូនកមានជម្ងឺ ក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ។

ឯមាតាបិតាលុះបានឃើញរូបសម្បត្តិនាងជាគានោះហើយ ទើបសន្មតនាមថានាង «រូបទេវី» ត្រោះមានរូបឆោមមានលំអគួរជាទីត្រេកអរដល់ប្រជុំជនានា ។

លុះកាលជាងក្រោយ នាងធីតាចំរើនវ័យធំឡើង បានអាយុប្រមាណ ១៥ ឬ ១៦ ឆ្នាំ មាតាបិតាត្រមាំងញាតិសាច់សាលោហិតពាំងឡាយ បានរៀបចំធ្វើមង្គលអាពាហ៍ពិពាហ៍ជាមួយនឹងយុវបុរសដែលមានត្រកូលស្មើគ្នា ហើយបញ្ជូនឲ្យទៅនៅក្នុងត្រកូលស្វាមីរបស់នាង ។ កាលបើធីតានោះបានកើបយកអង្គុយមួយនាឡិហើយ ប្រុងប្រៀបនឹងចំអិនបាយ ស្រាប់តែមានមច្ឆាក្រៀមជាច្រើនមុខ គឺត្រីនឹងសាច់ជាដើមធំ គោរសពាំងប្រាំមានសម្បុរ ខវន័ត ពណ៌ ទឹងទឹកដោះស្រស់ជាដើមផង គ្រឿងហិលមានជីរទឹងម្រេចជាដើមផង គ្រឿងឧបករណ៍មានស្លឹកចេកទឹកឃ្មុំទឹងស្ករអំពៅជាដើមផង សឹងបំពេញកាជន៍ពាំងឡាយឲ្យពេញកើតឡើងព្រមគ្នាជាទីអស្ចារ្យ ដោយផលានិសង្សដែលនាងបានថ្វាយភិក្ខាព្រមពាំងកេសជ្ជៈនោះឯង ។ វត្ថុសម្រាប់ចរិភោគ ទោះបីបង្អែមក្តីចំអាបក្តី សូម្បីបន្តិចបន្តួចដែលនាងធីតានោះ បានគាន់យកដោយដៃរបស់ខ្លួនហើយ វត្ថុពាំងនោះពុំដែលប្រែទៅជាវត្ថុជូរផ្អូមឡើយ សឹងទៅតាំងកំណត់ជាប្រក្រតីដដែល ។

កាលបើនាងរូបទេវីបានដាំបាយមួយឆ្នាំងហើយ ដោះបាយនោះ
ចែកឲ្យមនុស្សដែលនៅក្នុងនគរចាំងអួល ឲ្យចំរើនកោតដកបដល់ឆ្អែតពាល់
គ្នា តែនាងតុំចាន់ជាក់ដៃចេញដកបណា បាយក្នុងឆ្នាំងកិនអស់នៅតេញ
ឆ្នាំងដដែលដកបនោះ ។ កិត្តិស័ព្ទរបស់នាងរូបទេវីនោះ កិលល្បីសុស
សាយប្រាកដក្នុងទេវបុត្រនគរចាំងអស់ បីដូចជាព្រះចន្ទនឹងព្រះអាទិត្យរះ
ឡើងក្នុងលោកដូច្នោះឯង ។

ឯនាងរូបទេវីនោះសោត តែងនិមន្តភិក្ខុប្រាំអង្គទៅនាន់ចង្ហាន់ ក្នុង
ចិលំនៅរបស់នាងអស់កាលជាងនិច្ច តុំដែលជាប់ឡើយ ។

គ្រានោះ មានព្រះថេរៈមួយអង្គ មានឈ្មោះជាព្រះមហាសង្ឃរក្ខិត
ក្នុងចំណោមភិក្ខុទាំងឡាយ លោកបែកឆ្ងាយនូវបដិសម្ភិទាទាំងបួន លោក
បានឃើញនូវបុញ្ញានុភាពនៃនាងរូបទេវីនោះ ដោយទិព្វចក្ខុរបស់ខ្លួន ឯនាង
ធីតានេះតុំបានដឹងនូវបុញ្ញកម្ម ដែលខ្លួនបានធ្វើមកក្នុងកាលមុនឡើយ ។

ព្រះថេរៈនោះត្រិះរិះថា បើដូច្នេះត្រូវតែអាត្មាអញប្រកាសប្រាប់នូវ
បុញ្ញកម្មនោះដល់នាងធីតានេះ ឲ្យបានដឹងសព្វគ្រប់ទើបគួរ ។

ឯកទិវសំ មានសម័យថ្ងៃមួយព្រះថេរៈទាន់ចង្ហាន់ក្នុងចិលំនៅ
របស់នាងធីតានោះរួចស្រេច បានធ្វើអនុមោទនាកត្តពលហើយក៏សួរថា
ម្នាលទេវធីតា! នាងបានដឹងនូវបុញ្ញកម្មដែលនាងបានធ្វើមក ក្នុងកាល
មុនដែរឬទេ ? ។

នាងធីតាទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ! ខ្ញុំម្ចាស់ពុំបានដឹងទេ តែ
ថាខ្ញុំម្ចាស់មានប្រាថ្នាចង់ស្តាប់ នូវបុញ្ញកម្មនោះដោយពិស្តារតទៅទៀត ។

ឯព្រះមហាសត្វរក្ខិតតេរ្ច កាលដែលលោកនិងប្រកាសសំដែងនូវ
បុព្វកម្មនៃនាងរួចទៅហើយនោះ ក៏បានពោលជាបទព្រះគាថាដូច្នេះថា:

ឯកនវុតិ ឥតោ កប្បេ វិបស្សី ជាម ជាយោ
អហោសិ លោកេ លោកោ- កនយនោ ច្ឆិន្នពន្ធនោ
. . ជាដើម

សេចក្តីថា: ក្នុងកប្បកៅសិបមួយ កន្លងទៅតាំងពីកប្បនេះទៅ ក្រោយ
ពីនព្រះសម្មាសម្ពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមវិបស្សី ជានាយក ក្នុងលោក
ព្រះអង្គបានកាត់ចំណងជាគ្រឿងចងក្នុងភពដាច់ស្រឡះហើយ ទ្រង់ប្រកាន
នូវព្រះនេត្រដ៏ប្រសើរពោលគឺប្រាជ្ញា ដល់សត្តនិករក្នុងត្រៃលោក, កាល
នោះនាងបានកើតជាតាមពាក្យម្នាក់នៅក្នុងបុរីនោះដែរ ។ ថ្ងៃមួយនាងបាន
ដើរចូលទៅកាន់ព្រះវិហារ ក៏ឃើញនូវសាវក១អង្គរបស់ព្រះជិនស្រី មាន
ភេតជាទម្ងន់ មានសម្បុរលឿងស្អាងស្គម ថយកំឡាំង នាងមានចិត្ត
អនុគ្រោះបានឧទ្ទិមន្តទៅប្រគេនភេសជ្ជៈនិងភត្តដល់សាវកនោះ លុះកុំនោះ
បានផាត់ភេសជ្ជៈនោះហើយ សេចក្តីទុក្ខដែលកើតពីជម្ងឺបៀតបៀនកាយ
ក៏រសាយរលាយបាត់ទៅ ប្រែជាមានសរីរកាយជាតិធំមាំមួនជាប្រក្រតិវិញ
ដោយបុញ្ញកម្មនោះ ទើបនាងឫតចាកអត្តភាពនោះបានឡើងទៅកើតក្នុង

សោតាបត្តិផលជាអរិយសាវិកា ក្នុងព្រះពុទ្ធសាសនាដោយពិត ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តខាំងឡាយលោកពោលជាបន្ទរព្រះគាថាដូច្នេះថា:

ឥតិ តវុណាកុមារី បុញ្ញមាការកិញ្ញាតា
បមុទិតមនចិត្តា តស្ស ឧត្តាធិ ឆានំ
ភវាភវេសុំ សា លត្តអម្ហេសុ បុញ្ញា
វិធិតកុសលថាកា លច្ឆថ កោ ឯ តុម្ហេ ។

អធិប្បាយថា តវុណកុមារី (កុមារីពេញដំទន់) បានកំណត់ដឹងថា អាត្មាអញបានធ្វើបុណ្យ ហើយក៏មានចិត្តរីករាយ ព្រោះបានឮសេចក្តីសម្ដែងដល់កិកុអ្នកមានដ៏ម្ចាស់ ដូចបានពណ៌នាហើយនេះ កុមារីនោះបានសោយសេចក្តីសុខក្នុងតាវតឹង្សឆកាមាវចរដ៏ចំរើន ។ ម្នាលអ្នកខាំងឡាយដ៏ចំរើន អ្នកខាំងឡាយក្នុងចំណោមនេះ សុទ្ធតែជាអ្នកមានបុណ្យ មានកុសលដែលបានដឹងច្បាស់ហើយ មុខជាទទឹងបានទៅព្រះនិព្វានដោយពិត ។

សំដែងរឿងនិទានវិមានវត្ថុទី ជាគំរប់ ១០ ក្នុងវគ្គទីមួយ ក៏ចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណេះឯង ។

ស្តាយសួតទៅលោកនាយ ចាន់សោយសម្បត្តិទិព្យ សម្រេចដោយកាម
គុណគាំងពួង ជាសុខក្សេមក្សាន្ត ស្ថិតនៅក្នុងប្រាសាទកែវ ៧ ប្រការ
ប្រដាប់ដោយឃើនកែវមណីប្រមាណមួយរយជាន់ មានផ្ទះកំពូលដ៏វិចិត្រ
ដោយល្អងមួយរយមួយ មានទីដេកទីអង្គុយដ៏ដេរដាសពៅដោយស្រីទេព-
អប្សរតែងប្រកបបម្រើ មានកំនត់ប្រឹងជាដើមជាប្រក្រតី ។ ដោយ
ផលានិសង្សដែលនាងបានឲ្យគេសង្ឃឧទ្ទិសកុំមានជម្ងឺនោះឯង ។

សេចក្តីតថា បុគ្គលដែលប្រាថ្នាបានសេចក្តីសុខតម្រាំងធ្វើទូរ
បុណ្យត្រូវតាមកាលគាំងពួង ។ ម្នាលនាងដ៏ចំរើន ! ព្រោះហេតុដូច្នេះ ត្រូវ
តែនាងខ្លាំងក្លាយក្នុងការជាកុសលសព្វ។ កាល កុំឲ្យជាប់ឡើយ ។

ព្រះមហាសង្ឃរក្ខិតត្ថេរ លោកបានប្រកាសសំដែង នូវបុព្វកម្ម
ដែលនាងរូបទេវីនោះ បានធ្វើពីកាលមុនមកយ៉ាងនេះហើយ ក៏លោក
រំឭកដាស់តឿនថា ឥឡូវនេះត្រូវនាងកុំប្រមាទប្រហែសធ្វេស ក្នុងបុញ្ញកម្ម
ឡើយ ។

ឯនាងរូបទេវី លុះបានស្តាប់ព្រះធម៌ទេសនានៃព្រះថេរៈហើយ ក៏មាន
សេចក្តីសោមនស្សរីករាយ តែងខ្លាំងក្លាយចំណាយទ្រព្យធ្វើបុណ្យ
មានការបរិច្ចាគទានជាដើម តាំងពីថ្ងៃនោះមកជាដរាប ។ ដោយសេចក្តី
សោមនស្សដែលនាងបានស្តាប់ព្រះធម៌ទេសនានោះហើយ ក៏បានដឹកលំ
នូវខយវយធម៌ (ការអស់ទៅនិងសូន្យទៅ) ក្នុងអត្តភាព បានសម្រេច

ពីនាយ ប្រណម្យមកថ្វាយព្រះអគ្គីហោង ។ ថាបើព្រះអគ្គីនឹងនាំស្រះ
ញីទៅពុំបាន ឲ្យ កំយើងខ្ញុំនឹងនាំស្រះឈ្មោលមកពុំបានដែរ ដូចព្រះ
អគ្គីនោះហោង ។

រីអស់មហាជនធឹងតាំងឡាយ ស្តាប់តាក្យព្រះមហាសថបង្គាប់ប្រើ
ហើយ ចាំអស់តតស៊ំណាល់ដំកល់ខុកក្នុងចិត្តស្រេចហើយ ក្រាបលាព្រះ
មហាសថ ទៅធ្វើដូចបង្គាប់នោះហោង ។

រីព្រះមហាក្សត្រាធិរាជស្តាប់ហើយ មានព្រះបន្ទូលដល់ធឹងថា ម្នាល
អ្នកតាំងឡាយអើយ អ្នកឯណាមានប្រាជ្ញាអាចរិះគិតជាអាថិប្រស្នាតប
មកដូច្នោះហ៊ឺង ? រីអ្នកធឹងតាំងឡាយ បង្គំប្រណម្យទូលថា សូមមាន
ព្រះមហាសថជាបុត្រសេរីខ្ញុំក្រសេដ្ឋីនោះឯង ប្រើយើងខ្ញុំមកធ្វើជាអាថិ
ប្រស្នាតបនឹងព្រះអង្គីហោង ។ ព្រះមហាក្សត្រាធិរាជជ្រាបហើយ មាន
ព្រះហឫទ័យដឹងពេញទូវព្រះអំណរអរក្រៃពេកហោង ។

ឧយ្យានន្តិ នេះនឹងស្រដីពីការលេងឧទ្យាននោះមើញ ។
បុនេកនិវេសំ មយំ ឧយ្យានកីឡំ កាតុំ ឥតិ ឧត្តាមោ
អម្ហាកញ្ច ឧយ្យានំ នោភណារុក្ខឱកក្កវិកក្តំ ចាតិ-
ឆយវមជ្ឈគាមភាសិនោ សុបុប្ផិតតរុណារុក្ខសញ្ឆន្ន
នវឧយ្យានំ មេសេន្តុ អបេសេន្តានំ សហស្សឆណ្ណាតិ

(តមក)

លោក អ៊ឹម-គន បម្លងពីសាស្ត្រាស្ងឹតរត

ព្រះពុទ្ធវង្ស គីម-តូរ តិនិត្យ

ហេតុនោះ សូមមានយោងខ្ញុំមកក្រាបទូលព្រះអង្គចង់សូមស្រេះញ៉ី អំពីបុកណា ដ្បិតធ្លាប់នៅស្គាល់ថ្នាក់មិនក្តីកមិនខ្លាចនឹងមនុស្សម្នាមហាជន ផងពាំនឹងឡាយ ហើយសូមឲ្យនាំទៅជាធ្លាក់ យោងខ្ញុំនឹងគៀងនាំស្រេះ យោងនោះមកឲ្យជាកំដរស្រុកជាមួយនឹងស្រេះញ៉ីព្រះអង្គហោង, ជាបើព្រះ មហាក្សត្រមានព្រះបន្ទូលមកនឹងអ្នកពាំនឹងឡាយថា នែព្រះស្តេង ! អំពីមុន រៀងមក អញមិនដែលឮថា ស្រេះមានញ៉ីមានឈ្មោលឡើយ, ហើយ អញពុំដែលបានប្រើស្រេះញ៉ីឲ្យទៅយកស្រេះឈ្មោល អនុងមកជូនព្រះ ស្តេងស្រដីនោះឡើយ ម្ល៉ោះហើយអ្នកពាំនឹងឡាយក្រាបថ្វាយបង្គំប្រណម្យ ទូលត្មៃយវិញថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ជាបើព្រះ អង្គមានព្រះបន្ទូលថា មិនដែលមានដូច្នោះហើយ ហេតុអ្វីឡើយព្រះអង្គ ប្រើទៅកាន់សំរីវឌ្ឍកសេដ្ឋី ប្រើឲ្យនាំស្រេះមកថ្វាយព្រះអង្គ ? លុះព្រះអង្គ ឲ្យនាំស្រេះញ៉ីអំពីអាយៈទៅនោះ ទើបបានយើងខ្ញុំឃើញនឹងនាំស្រេះឈ្មោល

ឧបាលីសុត្ត ។

មានកាលសម័យមួយទៀត, ព្រះមហាក្សត្រាធិរាជ ស្តេចនឹកចង់ល្បងប្រាជ្ញាព្រះមហាសេដ្ឋ ទើបស្តេចប្រកាសអាមាត្យទៅថានឹងសេដ្ឋីវឌ្ឍកសេដ្ឋីនោះទៀតថា ព្រះបន្ទូលតំណែងសេដ្ឋីប្រើឲ្យមកថានឹងអ្នក ដ្បិតស្តេចមានព្រះបំណងនឹកចង់ក្រសាលប្រពាតទ្បាន នាទ្បានព្រះមហាក្សត្រាធិរាជអំពីបុណ្ណោះ, មានឈើចាស់ចាក់បែក សន្ទឹកជ្រុះមែកធ្លាក់ចុះ រង្គើរអស់ហើយ; ហេតុនោះហើង ឲ្យអ្នកនាំទ្បានថ្វាយឲ្យមានឈើនោះតម្លៃខ្ពស់ មានជើមនោះធំ លំពង់ ទ្រង់ទ្បូវផ្លែផ្កាដ៏តែសម្ផស្សាយតណ្ហាយល្អនាំទៅថ្វាយ, ថាបើអ្នកនាំទ្បាននោះទៅថ្វាយបាន កំដាតាវគេសឡើយ, ថាបើពុំបាននាំទ្បានថ្មីនោះទៅថ្វាយហើយ សមអ្នកនឹងមានទោសត្រូវពាជនណ្ឌាដំណាំងមួយពាន់ជង្គឹពុំខានឡើយ។

រីសេដ្ឋីវឌ្ឍកសេដ្ឋី ទ្បូវអស់អ្នកស្រុកផងទាំងឡាយ សឹងទៅជណ្តើងសួរព្រះមហាសេដ្ឋីនោះហើង, ទើបព្រះមហាសត្វអ្នកទ្រង់ព្រះតម្រិះណាអាចប្រស្នានេះថា បើដូច្នេះមានតែរុះគិតធ្វើជាអាចប្រស្នាតបទៅវិញទើបបាន, ទើបពោធិសត្វប្រើអ្នកផងទាំងឡាយ ឲ្យទៅរុះគិតធ្វើជាអាចប្រស្នាតបទៅវិញ ដូចន័យនៃពាក្យដែលយើងស្រដីនិយាយអាចប្រស្នានោះឯងហើង ។

រីព្រះមហាក្សត្រាធិរាជ ស្តេចជ្រាបដូចមកអស់អាថិសេចក្តីនោះហើយ
ទើបមានព្រះហឫទ័យដំពេញទូវព្រះអំណារអរក្រៃពេកហោង ។ ហើយ
មានព្រះបន្ទូលដល្អាំងទៅកាន់អាចារ្យសេនកថា តើអាចារ្យសេនកអើយ
មើដូច្នោះ សមគួរយើងនឹងឲ្យទៅនាំមហាសថនោះ មកជាអ្នកច្រូតថ្ម
ប្តូរម្តងហ៊ាន ? រីអាចារ្យសេនកស្តាប់ព្រះបន្ទូលព្រះមហាក្សត្រនូវប្រការ
អម្បាលនោះហើយ ហេតុតែជាអ្នកកំណាញ់ឃុបសលាភសក្ការៈនោះមិញ
ទូលទាស់ព្រះមហាក្សត្រាធិរាជថា មហារាជ ! បពិត្រមហារាជអើយ
រមែងមហាសថបុត្រគេហបតីនោះ ចេះអាថិប្រស្នាអម្បាលនោះមិញ មិន
ហៅថាអ្នកច្រូតថ្មឡើយ, ចូរព្រះអង្គឈប់ស្ទុះទៅនេះសិនហោង ។

រីព្រះមហាក្សត្រ ស្តាប់ពាក្យអាចារ្យសេនកទូវប្រការអម្បាលនោះ
ហើយ ស្តេចទ្រង់ព្រះចិន្តាពិចារណាថា មហាសថអ្នកច្រូតអាចឆ្លើយ
ប្រស្នាយល់ឥតលាក់លៀមកំចាំងអំពីក្មេង ៧ ឆ្នាំដូច្នេះ ចេះមានចិត្តគំ
និតមិនឲ្យខុសដល់តិចឡើយ មិនយល់ថាមហាសថជាក្មេង ៧ ឆ្នាំ មក
ឆ្លើយអាថិប្រស្នានេះឡើយ យល់សុទ្ធសាធខ្នាតដូចព្រះពុទ្ធបានត្រាស់
ហើយ កំមកឆ្លើយ អាថិប្រស្នាទំនងអស់ទេវតា ឥន្ទព្រហ្មផងតាំងពីយ
ខោះ មានប្រការដូចម្តេចមិញ ? កំដូច្នេះ ហេតុអ្វីអាចារ្យសេនកអ្នក
ច្រូតមិនអាចអារ ឲ្យអញទៅនាំមហាសថនោះមកយកជាអ្នកច្រូតហ៊ាន ?
ថាបើដូច្នេះ អញកុំដោយតាមពាក្យអាចារ្យសេនកនេះឡើយ អញនឹង

ទៅនាំមហាសព្វនោះមកឯងឥឡូវ ។ ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះចិន្តាពិចារណាខ្លួនប្រកាអម្បាលនោះហើយ ស្តេចឲ្យប្រជាប់ប្រដាប់ដោយខ្លួនព្រះដំណើរ ស្តេចនឹងលីលាយាត្រាចេញអំពីព្រះនគរ មួយអន្ទើតឯងអស់អាមាត្យមុខមន្ត្រីសេនាចតុរង្គស្តេចប្រដាប់ មហាជនផងច្រើនជាបរិពារស្តេចត្រអាលតណ្ដាលផ្លូវ រីឯផងសេះអាជានេយ្យមង្គលនោះមិញ ជាន់ធុងទៅក្នុងក្រហែងដី ចាក់ថ្នល់ត្រេច ស្តេចខានតុំបានទៅឡើយ ហើយត្រឡប់វិលមកកាន់ប្រាសាទព្រះរាជមន្ទីរនោះវិញឥឡូវ ។

កាលនោះ, អ្នកប្រាជ្ញទាំង ៤ ពួក ថា ព្រះមហាក្សត្រស្តេចខានតុំបានទៅដូច្នោះហើយ សឹងនាំគ្នាឡើងទៅតាល់ ហើយធ្វើជាសួរខ្លួលខ្លួលដំណឹងថា មហាជន ! បពិត្រព្រះសម្ងួតខេតមហាជនអើយ រីយើងខ្ញុំឮបន្តិចថា ស្តេចលីលាយាត្រាទៅកាន់ស្រុកចាចីនយ៉ាមជ្រាម ប្រយោជន៍ដើម្បីនឹងទៅនាំមហាសព្វបុត្រសិរីឧត្តមសេដ្ឋីនោះមកពិតមែនឬអម្ចាស់ ? ព្រះមហាក្សត្រស្តាប់ហើយមានព្រះបន្ទូលថា ម្នាលអាចារ្យសេនកអើយអញទៅមែនពិតឯងឥឡូវ ។ រីអាចារ្យសេនកទូលវិញថា បពិត្រមហាជនអើយ ម្តេចឡើយព្រះអង្គមកធ្វើខ្លួវអាត្មើតប្រយោជន៍អ្វីដូច្នេះ, មកលំឯងតំនិតយើងខ្ញុំចង់មឿតវិញ យើងខ្ញុំបានខ្លួលអម្ចាស់អំពីដើមហើយមិញតើ អម្ចាស់, ឲ្យព្រះអង្គឈប់ស្នេរនៅខេះសិន បន្តាន់អ្វីព្រះអង្គលេះ

រលាំងត្រអាលចេញទៅអំពីព្រះខនរ ព្រះចាខអម្ចាស់ទើបស្តេចលីលា
យាត្រាទៅជាប្រថម កំដើងសេះព្រះទីនាំងមង្គលមិញ ចាក់តើតជាស្តុន
ព្រះដំណើរដូច្នេះ ។

មានកាលសមយ័ថ្ងៃមួយទៀតទៀត, ព្រះចាខវិទេហរាជ មួយអន្ទើ
ន្ទរអាចារ្យទាំង ៤, ស្តេចបន្ទូលថា ហៃអាចារ្យសេនក ឥឡូវនេះ តើយើង
ទីងឲ្យទៅយកអ្នកប្រាជ្ញនោះមកថ្វាយដូចម្តេចហ៊ឹង ? រីអាចារ្យសេនកទូលថា
មហារាជ! បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ រីព្រះអង្គអម្ចាស់កុំបី
ស្តេចទៅឡើយ អម្ចាស់ប្រើតែរាជទូតទៅឲ្យថាទីងទៅអ្នកប្រាជ្ញថា ហៃ
ទៅអ្នកប្រាជ្ញអើយ យើងមកគាន់ទៅឲ្យទៅកេដើងសេះ ព្រះទីនាំងមង្គល
អស្សតរយើងកំពុក់, ឥឡូវនេះ ចូរឲ្យសិរីខ្ពុកសេដ្ឋី ខ្លួរទៅមហាសេដ
អ្នកប្រាជ្ញកេសេះអស្សតរក្តី សេះសេដ្ឋតរក្តី ឲ្យបានសេះប្រសើរទាំង
២ នេះ ហើយថ្លៃនាំទៅថ្វាយជាដំណួសសេះព្រះទីនាំងហោង, ថាបើបាន
នាំទៅថ្វាយនោះ ; កំជាការឥតគោសឡើយ, ថាបើពុំបាននាំទៅថ្វាយ
ទេ នោះទីងឲ្យត្រាំព្រះកដណ្តើជាទម្ងន់មួយពាន់ដង, យើងធ្វើជាប្រស្នា
ដូច្នេះហើយប្រើទៅ ពោះយោបើអាចមានប្រាជ្ញាដឹងក្នុងលក្ខណៈអាថ
ប្រស្នានេះ ថាឲ្យដូនសេះអស្សតរនេះមក ឬក៏អ្នកប្រាជ្ញនោះទីងមកខ្លួនឯង,
ពោះយោបើទីងឲ្យសេះសេដ្ឋតរមក ឬ ក៏ទីងអាពុកមកហោង ។ រីប្រស្នា

យើងនេះទំនងលុះបរិបូណ៌ហោង ។

រីព្រះចុងវិនេហាកជ ខ្ជូលយកពាក្យនោះថាតាប់ហោង ទើបស្តេច
ប្រែកជអាមាត្យនោះទៅថាទំនងសំរីវឌ្ឍកសេដ្ឋី ខ្ញុំវិអស់អ្នកស្រុកជាច្រើនយ-
រមជ្រត្រម មានសំរីវឌ្ឍកសេដ្ឋីឯងជាធំ មកជំនុំរិះគិតអាថ៌ប្រស្នានោះ
តុំឃើញឡើយ, ទើបទៅហៅព្រះមហាសថអំពីទីកន្លែងនោះមក
ហើយប្រាប់អស់អាថ៌សេចក្តីនោះ ។ រីព្រះមហាសថអ្នកប្រាជ្ញ ស្តាប់
ពាក្យនោះហើយ អ្នកដឹងជ្រាបមួយរំពេចនោះឯង ហើយអ្នកសំពះអាពុកថា
បពិត្រអ្នកអាពុកអើយ កុំបីអម្ងាស់ចារម្ភឡើយ ដ្បិតស្តេចមានព្រះបំណង
ទំកចង់ឃើញលំអ្នកអាពុកខ្ញុំសោតហោង ។ ឥឡូវនេះ ចូរអម្ងាស់អ្នកទៅមួយ
អន្ទើដោយពពួកសេដ្ឋីមួយពាន់ជាបរិវារ កាលណាបើអម្ងាស់ទីឯទៅនោះ
កុំទៅតែដៃទេទៅឡើយ, ចូរអម្ងាសយកប្រអប់ចន្ទន៍ ដំពេញទូរគ្រឿងគន្ធ
ពិសោរ ដ៏មានដំឡៃនោះមួយសែនដង្គឹងមាសទៅជាដង្ហាយនៃព្រះមហា
ក្សត្រ ។ កាលណាបើអ្នកចូលទៅគាល់ហើយ រីព្រះមហាក្សត្រសួរព្រះ
អង្គទំនងធ្វើប្រស្រ័យសួរខ្ជូលអ្នកអាពុកថា ភៃតហាបតិ ព្រះស្តេចមើល
ហានបង្គយឯណាសមគួរ ចូរព្រះស្តេចអង្គុយហោង ។

លំដាប់នោះ, អ្នកអាពុកមើលហានឯណាសមគួរទំនងអាត្មា ចូរអម្ងាស់
អង្គុយហោង ។ កាលណាបើអ្នកអាពុកអង្គុយហើយ កំប៉ុំទំនងទៅឯក្រោយ ។

លំដាប់នោះ, អ្នកស្តេចទន្លីធ្វើប្រស្រ័យសួរខ្លួលមួយអន្ទីដោយខ្ញុំហើយ អ្នកទន្លីមានព្រះបន្ទូលទៅថា ហៃឫទ្ធានុភាពប្រាជ្ញា ឫមើលឋានបង្គុយណា សមគួរ ឫអង្គុយហោង ។ លំដាប់នោះ, បើអញខ្ញុំក្រឡេកទៅអ្នកអាពុក តែអ្នកអាពុកដឹងដោយសំគាល់នោះ ហើយតំបូរអម្ចាស់ដោះឡើងអំពីបង្គុយ នោះ ចូរអម្ចាស់ថា ហៃឫទ្ធានុភាពមហាសថ ចូរឫទ្ធានុភាពអាពុកនេះ ហោង តែឱប្រស្នាខ្ញុំនេះ ទន្លីលុះបរិបូណ៌ក្នុងកាលនោះហោង ។

រីសិរីវឌ្ឍកសេដ្ឋីមិញ ខ្លួលយកពាក្យកូននោះថាតាមហោង ។ ទើបប្រជាប់គ្នាទៅមួយអន្ទីទន្លីសេដ្ឋីតាំងមួយគាន់ជាបរិភោគ លុះទៅដល់ទ្វារព្រះរាជវាំងហើយ ឲ្យចូលទៅក្រាបទូលដោយទូវដំណើរមកឈប់នៅទ្វារនោះហោង ។ ទើបស្តេចឫទ្ធានុភាពហើយមានព្រះបន្ទូលថា ឲ្យសិរីវឌ្ឍកសេដ្ឋីនោះចូលទៅ, រីមហាសេដ្ឋីនោះ ទៅឈរនៅឋានមួយអន្ទី ហេតុតែស្តេចចង់ឃើញព្រះមហាសថតាមមិញ ស្តេចមានព្រះបន្ទូលជណ្តើនថាហៃឫទ្ធានុភាពតែអើយ, រីមហាសថកូនត្រូវស្តែង តើនៅឯណា ? រីមហាសេដ្ឋីទូលថា ព្រះឫទ្ធានុភាពអើយ ឋានទន្លីមកឯក្រោយខ្ញុំព្រះឫទ្ធានោះឯងហោង ។

រីព្រះឫទ្ធានុភាពវិសេសកាជ ឮថាទៅមហាសថអ្នកឫទ្ធានុភាពទន្លីមកជួបកូន ស្តេចមានព្រះកាជហឫទ័យត្រេកអរសោរ ហើយមានព្រះបន្ទូលថា ហៃ

គហបតី ចូរព្រះស្តេចរមើលរមើលហានបង្គុយឯណា សមគួរនឹងព្រះស្តេច ចូរព្រះស្តេចអង្គុយហោង ។ រួចហាសេដ្ឋីនោះ អ្នកដឹងហានបង្គុយតាមសមគួរហើយ គាត់អង្គុយឰដ៏ហានមួយអន្លើនោះហោង ។

រឿងមហាសេដ្ឋអ្នកស្តាធព្រះអង្គធ្លងដ៏ប្រជាប់ប្រជា ដ៏មានក្មេងធងតាំងមួយពាន់ជាបរិវារ អ្នកតង់លើកជវេដ៏ប្រជាប់ប្រសើរដ៏មានដំរៀថ្លៃហើយ អ្នកលីលាទឹងចូលទៅក្នុងកំឡូងព្រះនគរ តែអ្នកយល់លាមួយទៅលើខ្នងគួ ហើយទើបអ្នកប្រើកំលោះឯណាមានកំលាំង ហើយអ្នកបង្គាបថា ចូរព្រះស្តេចទៅចាប់លានោះ ហើយព្រះស្តេចឃ្លុំមាត់ពាះឲ្យខ្ជាប់កុំបីឲ្យស្រែកបានឡើយ ហើយព្រះស្តេចនុំនឹងកន្ទេលកណ្តៀតទៅបង្ហិនយកមកហោង រីកំលោះធងធ្លើរដោយខ្លួបង្គាប់នោះ ។ រីតោធិសត្វព្រះអង្គលីលាទៅមួយអន្លើដោយបរិពារ ចូលទៅក្នុងកំឡូងព្រះនគរ ។ រីដំណើរតោធិសត្វនោះ ដ៏ប្រកបខ្លួលំអរសិរីសួស្តីបីដូចសម្តេចឥន្ទ្រាធិរាជ កំសត្តចលីលាគង់លើពជយន្តប្រាសាទ ដ៏មានពពួកទេវតានៅពិភពត្រៃត្រឹង្ស ចោមរោមជាបរិពារនោះហោង ។

រីអស់មហាជនធង សឹងបបួលគ្នាមកមើលតោធិសត្វនោះ ធោធ្លាអឺងកង ហើយមានពាក្យស្រដីសរសើរថា នុដូចយើងបានឮរឿងមកនេះ រីអ្នកនេះជាកូនសិរីវិឌ្ឍក្រសេដ្ឋីឈ្មោះចោមហោសថបណ្ឌិត ឮថាកាល

តែតមកតាន់តំណឹងកំណាត់ថ្មំពិព្ធ ចេញមកអំពីព្រះទន្តព្រះវរមាតា ហើយ
ស្រដីសំណេះសំណាលមួយអន្ទើនឆឹងព្រះវរមាតា នាកាលថ្ងៃក្រោយឯង
ហើយថា មានប្រាជ្ញាអាចដោះអាថប្រស្នាល្បងតំបួងឥតឯកំចាំងបាន
ឡើយ, រីអស់អ្នកផងនោះ សឹងដឹងតែកូនមកមើលព្រះមហាសថនោះ ដំ
របូតកូនចេញអំពីដៃពុំដឹង ពុំចេះឆ្អែតឆ្អន់ដល់តិចឡើយ ។ រីព្រះមហាសថ
នោះ អ្នកទៅដល់ទ្វារព្រះរាជវាំងហើយ ឲ្យអ្នកផងចូលទៅទូលព្រះមហា
ក្សត្រនោះហោង ។

រីព្រះមហាក្សត្រាធិរាជ ស្តេចឮពាក្យនោះហើយ ព្រះអង្គមានព្រះ
រាជហឫទ័យនោះ ដំណើរញូវព្រះអំណារក្រែកអាសារមានព្រះបន្ទូលថា
ព្រះសែ្តងឲ្យមហាសថចូលមកហោង ។ រីព្រះមហាសត្វអ្នកមានក្តេងផង
តាំងមួយពាន់ជាបរិវារ រៃហមរោមរោមស្រែចហើយ អ្នកឡើងលើប្រា
សាទព្រះរាជមន្ទីរថ្វាយបង្គំស្រែចហើយ ឋិតនៅឰដ៏ហ៊ានមួយអន្ទើនោះ
ហោង ។ គរលណាបើស្តេចបានឃើញព្រះមហាសថនោះហើយ មាន
ព្រះហឫទ័យនោះដំណើរញូវសោមនស្សប្រមូលប្រស្រ័យសួរនឹងព្រះ
បន្ទូលនោះតើរកេះថា ម្ចាស់លោកអ្នកប្រាជ្ញអើយ, ចូរបានមើលហ៊ានបង្គិយ
តាមសមគួរនឹងអាត្មា ចូរបានអង្គុយហោង ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

រឿងមរណាមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្ទឹកតែត

ឥសីអាណិតជាតា ផ្នែតឆ្អែតទុក អនាថអាណិតពេកក្តាត់ ។ ឥសីប្រណី
ស្រីវ័ត្ត ដូរតនាងប្រាសត្រាត់ ដូចកូនបង្កើតស្មោះស្មាន ។ ទើបព្រះឥសី
ស៊ីលសាន្ត តាក់តែងទីហាន សមគួរហើយថ្វាយក្សត្រី ។ នាងតែងចំរើឥសី
សព្វថ្ងៃប្រក្រតី ដងទឹកកុសសារពើ ។ ផលាផ្លែឈើ
ផ្កាឈើ បេះបានពូលទើរ នាំយកមកថ្វាយឥសី ។ តាបសមានចិត្ត
ប្រណី អាសូរក្សត្រី តុំដែលឲ្យអាក់ព្រះទ័យ ។

បទពាកពត្តិ

នៃនេះស្ទេះនី- ថានៅអំពី បរមក្សត្រថ្ងៃ រៃមលបត់ត្រ រឿង
ប្តូរជាញាដ័យ ស្តេចលើកពលក្រៃ ចេញចាកភាព ។ ច្រាបភ្នំដ
តីយ៍ ចាញ់ព្រះបារមី ព្រះបាទកាជា ស្រែចស្តេចប្រពាត រុក្ខជាតិ
អជ្ឈា សប្បាយទយា ក្នុងព្រឹក្សាសាន្ត ។ តម្រង់មាសា បីទៅក្សត្រា
ក្នុកនឹកពជាន នឹកនាងសាវិកា ចិន្តាពុំក្សាន្ត ស្តេចលើកទាហាន

ចូលក្រុងភាព ។ ស្រេចដល់ប្រាសាទ ស្តេចយាងព្រះបាទ ដើរ
ដោយមាគ៌ា ព្រះនេត្រទតទៀង ពស់រៀងនានា ឈើឥតគណនា
រលួសមាសមៃ ។ ផ្លែផ្កាពេញពាស ដូចកល់ភ្នំមាស ប្រាស់ប្រាល
ពេកក្រៃ ទតស្រេចក្សត្រា លីណាចាប់ពៃ ឡើងវែនចិញ្ចៀម តែងខុក
សាកា ។ ស្តេចស្ងៀមទាំងឡាយ ខុនណាងអស់យោយ ឡើងគាល់
ក្សត្រា ស្តេចទៀងទតច្បាស់ ទើបត្រាស់សួរថា ម្តេចបាត់សាកា ពុំ
ឃើញមកផង ។ អស់យោយស្ងំស្ងៀម ទូលថាបពិត្រ ក្សត្រថ្ងៃច្បាស់ច្បង
កាលស្តេចចេញច្បាំង ប្រាបទាំងទ្រើសឃ្មង ស្តេចយាងកន្ទង ចាន
ជីវិត ។ សាកាកែវបាត់ យើងខ្ញុំកស្តាត់ សព្វទីនានា ពុំឃល់
យើងគិត ភ័យតិតមហិមា រកពស់គ្រឹហា ផ្សារផ្សាទីហាន ។ ពុំ
ឃល់សាកា កើតភេមនស្សា ទៀងទុក្ខគ្រប់ប្រាណ សូមចានក្សត្រ
ថ្ងៃ ប្រពៃថ្លៃដ៏ថ្លាន មេត្តាប្រោសប្រាណ យើងខ្ញុំគ្រប់គ្នា ។ កាល
ធន្លាចាប់ សាកាប្រញាប់ ឱ្យតាសីវ៉ា ចោកចោចរកមស្ងាប ដកប
អង្គា ឈើមាសត្រាំគ្រា ស្រគោនជ្រុះស្ងឹក ។ លុះនាងសាកា ចាន
ក្បាន្តសុខា រឹងពាជព្រឹក្ស លួតលេចបុប្ផា ផលាសន្ធឹក សាខាញែកញឹក
ដូចគាលប្រក្រតី ។ ហេតុនោះព្រះបាទ រិមលនរនាថ ឆិពាជក្រី
ស្តាប់ពាក្យស្ងំស្ងៀម ទូលពិតអស់ក្តី ទើបព្រះចក្រី ស្ងៀមពុំចរចា ។

ស្តេចទ្រង់ត្រេកត្រុះ ថាសាកែនេះ ហ៊ានហើរយោគ្រា ទៅព្រៃហិមពាន្ត ខ្លាឃ្មុំក្បាល រកខេតធ្លាត ឲ្យប្រាសប្រៃប្រាណ ។ ជាមនុស្សរូបរ័ត្ន ហេតុនោះទើបចាត់ តុំយល់ក្នុងហាន ស្តេចទ្រង់ចិត្តា ហើយមហាក្សត្រ ក្សាន្ត ស្ងៀមស្ងប់តុំមាន ទុក្ខារខៀតទៅ ។

ន័យនេះស្មុះទៅ ទីឆនទិតានទៅ ទេវបុត្រមួយណា វិមានតង់ ថត តុសិតសួគ៌ា សន្ធតនាមា បច្ចុកនោធ ។ កំណត់ជន្មា ទីឆ សោយវិលា- ល័យចុះចាកទី ចាកតួទេវបុត្រ ច្យុតមកទី. ម្ចិត ជាតិជាទី កំសត់ជាតិជា ។ បដិសន្ធី យកជាតិក្នុងទី ជាបទុមា ទៅស្រះឥសី មិត្តាដិនា កំណាត់ទិព្វ ប្រាំពីរថ្ងៃបាន ។ ទើបកើតជាអង្គ បរិបូណ៌ព្រាយទ្រង់ ជាមនុស្សប្រុសក្រាណ រីឯឈ្លូកនោះ ជាលដុះ ឡើងបាន ធំក្រៃប្រមាណ ប៉ុនដុំថ្មា ។ ល្អល្អះចំភ្លោន ធំក្រៃឯកឯង លើសលែងអស់ផ្លា ត្របកស្រទាប់ ខ្ចាន់ខ្ចាប់បុប្ផា ធរីជ្រះថ្លា កណ្តាលដលស័យ ។ ចាគោវសោ ព្រឹកស្រាងសុរិយោ ឥសីសីល ថ្ងៃ បាចុះទៅស្រង់ កំតង់ដលស័យ ឆ្នៀងទត្រាំពៃ ទតទៅបុប្ផា ។ ឃល់ធំចម្ងៃក ល្អល្អះអនេក ក្រៃលែងអស្ចារ្យ ឥសីបេះយក មកបកបុប្ផា មើលឃើញកុមារ ក្នុងផ្លាឈ្លូកនោះ ។ តគ្រាំបំព្រង ទ្រង់ព្រាយឆ្នៀងឈ្នង ល្អល្អះតេញប្រុស ប្រកបលក្ខណា សោភា

ទ្រង់យស ជាមហាបុរស ឯកអគ្គវង្ស ។ ឥសីអាសល់ ទាំយកទៅដល់
ចណ្ណសាលា ហើយថ្វាយក្សត្រី មរណមាតា ឲ្យនាងរក្សា ជាបុត្រ
ស្ងួនត្រង ។ មរណមាតា ខន្ធលកុមារ គ្រែកអរកន្ធង ខើបនាង
សច្ចា អធិដ្ឋានផ្សង ចង្អុំខេតផង ក្នុងព្រឹក្សាសាន្ត ។ ជាបើកុមារ
នេះមានសំការ មានបុណ្យថ្លៃឆ្លាន មានចិត្តសប្បុរស ចំពោះប្រុស
ស្រ្តាណ ដឹងគុណអ្នកមាន- គុណគួរក្សា ។ សូមឲ្យទឹកដោះ
ខ្ញុំហូរមកស្មោះ ចូលមាត់កុមារ បើមនុស្សទុគ្គត ជួជាតិពង្ស
ពុំស្គាល់មាតា ឋិតាប្រធាន ។ កុំឲ្យទឹកដោះ ខ្ញុំហូរចេញស្មោះ
នោះខ្ញុំទឹងឆាន ដឹងជាក់ស្មានស្មោះ ចំពោះកុំខាន នាងអធិដ្ឋាន
សូរចេកាលណា ។ រីឯទឹកដោះ ហូរចេញមកស្មោះ ចូលមាត់កុមារ
នាងមានព្រះទ័យ មេត្រីករុណា ចិញ្ចឹមកុមារ ជាន់មួយឆ្នាំគត់ ។
រូបកាន់ល្អស្អុះ តក្កាត្រចះ ត្រចង់ចរិសុទ្ធ អស់អង្គល្វាសល្វន់ ខន់
គួនជាន់បទ ឥសីសន្ធត តាមជាតិកន្លង ។ ថ្វាយនាមព្រះអគ្គ
ឈ្មោះចតុមវង្ស កុមារថ្លៃថ្លា ព្រះអង្គជាតំណ សក្តិសមរូបា លុះ
ដល់ជន្មា ពីរជណ្តប់ត្បាំ ។ សំដីពីកោះ ផ្អែមល្ហែមស្មោះស្មោះតែចង
ចាំ ច្រាជ្រាជ្រះថ្លា ទស្សាហ៍មួនមាំ មាតានាងនាំ ទៅថ្វាយឥសី ។
ស្បែរឿនសិល្បសិទ្ធិ ឥសីទ្រង់ប្តូរ ប្រជៀបជាលី លំនិតអក្ខរៈ

សិល្បៈសាស្ត្រគ្រប់ រៀនចប់គ្រប់បី ទើសមាល់ច្បាស់ ។
មានកាលមួយថ្ងៃ បពុមវង្សវៃ ជណ្តើងមាតា បពិត្រព្រះអម តាមតែ
មេត្តា ហេតុម្តេចអាត្មា យើងនៅកន្លែងត្រៃ ។ តែព្រះមាតា ឱងអយ្យ-
កោណា កំព្រាឃ្លាតឃ្លៃ ឥតញាតិសន្តាន ត្រឿងលាន់ដល់ខៃ ព្រះបិតា
ថ្លៃ ខ្ញុំមានឬទេ ? ។ សាតំសុត្វា ឯព្រះមាតា ស្តាប់បុត្រខ្ញុលថៃ
នាងមានសង្វេគ ថាហៃមាសម៉ែ កូនអើយរឯ អង្គព្រះបិតា ។
នៃបាត្មានេ ជាមកអំពី សួគ៌តុសិតាមា មកយកកំណើត បង្កើត
កូនផ្កាឯអញមាតា ជាឯឱសព្វថ្ងៃ ។ សោតសឱងឥតញាតិ កំព្រា
ឃ្លាឃ្លាត សូរសែងកន្លែងត្រៃ ដួបឱងតាបស សប្បុរសគេតក្រៃ
ឡែម្តាយអាស្រ័យ នៅនេះណាបា ។ បពុមវង្សស្តាប់ មាតាថ្លែង
ប្រាប់ ជាសង្វេបណា ហើយអ្នកឆ្លើយឆ្លៃត សួរទៀតៗថា
បពិត្រមាតា សូមទ្រង់ប្រណី ។ ថ្លែងប្រាប់ប្រការ រឿងអ្នកមាតា ឲ្យ
អស់សេចក្តី អ្នកត្រាប់ព្រឹក្សា ប្រាថ្នាកេអ្វី តើមកអំពី ឧតរាឧណា ។
ព្រះវរជនឱ នាងថ្លែងប្រាប់តី រឿងខ្លួននាងថា ហៃកូនសំឡាញ់
ពាលតេញរូបា ខ្លួនអញមាតា ជាកូនកុដុម្ពីក៍ ។ នៅឧតរ វិទេសរដ្ឋា
បុរីធានី កុដុម្ពីក៍បិតា តរំយោនៃ ឈ្មោះកុលកេសី ម្តាយអញណា
បា ។ មួយឈ្មោះកាលី ប្រពន្ធបុងថ្មី ចិត្តតាបថ្លុស្យា ញុះញង់អាពុក

ធ្វើទុកមាតា អញស្លាប់តើតជា មច្ចុដំរី ។ មានទេពធីតា ប្រាប់ព័ទ្ធមាតា
សព្វគ្រប់សេចក្តី ម្តាយយកអង្ករ ល្អិតល្អន់ស៊ី ទៅជូនឲ្យត្រី ជាន់បរិ-
ភោគ្តា ។ កាលដំណឹងដាក់ ប្រើកូនពីរនាក់ ចង្ហោតមច្ចា យកមកសម្លាប់
ធ្វើជាភោជនា នៅសល់ស្រកា ត្រីពីរខើបមាន ។ ពញ្ញីមួយតិត ស្ទុះ
ទៅហួហិត ស្រកាត្រីជាន មកឲ្យខើបម្តាយ កកាយដីញាន ជាំដុះឡើង
ជាន ជាដើមត្រប់ធ្លី ។ កាលីលួចដក ដើមត្រប់យកមក បេះផ្លែ
ស្វាស៊ី ឆ្នាញ៉ីមួយពាំ យកឫសត្រប់ធ្លី នាំរត់ពីទី កាលីឫស្សា ។
នាំយកឲ្យម្តាយ ខើបម្តាយកកាយ ដីដាំកាលណា ដុះឡើងរំពេច
លូតលេចផ្លែផ្កា ជាដើមព្រឹក្សា រលួសមាសផ្អៅ ។ ពីដើមល្អល្អះ
ភ្លឺផ្លេកត្រចះ ត្រចង់សន្ធៅ ដូចកល់កុំមាស ទុកាសគ្នំនផ្អៅ
ម្តាយបេះផ្តាំទូរ ក័ស្តុភោជនា ។ ខន់ធត្រវ័ត្តយ នាំយកទៅថ្វាយ
សំពះបូជា សព្វថ្ងៃរៀងពាល់ ពុំសល់ទំពាំ កាលនោះពារា ព្រះបាទក្សត្រ
ថ្លៃ ។ វិមលបតិត្រ ធ្លាជត្រង់ឫទ្ធិ ស្តេចចេញលេងព្រៃ ឃាត់ដើម
ព្រឹក្សា ខ្វេហាស្តព្រៃ ដែលម្តាយអាស្រ័យ ងាំទុកនោះណា ។ ស្តេច
សួមយកទៅ ម្តាយថ្វាយព្រះចៅ ចមបក្រចេស្តា ស្តេចយកទៅដាំ ថែ
តាំរក្សា ហើយមហាក្សត្រា ប្រើមុខមន្ត្រី ។ ខ្លួលម្តាយទៅ
ដល់ហើយព្រះចៅ ចមក្រុងបុរី អតិសេកម្តាយជា អាយិអគ្គមហេសី

នៅបានឆ្នាំបី គាលីឫស្សា ។ វាប្រើកូនស្រី មួយឈ្មោះចន្ទណី មួយ
នោះឈ្មោះថា ចន្ទាចិត្តគាច កំណាចឫស្សា បញ្ឆោតម្តាយថា ចិតាឈឺ
ធ្ងន់ ។ ម្តាយទៅដល់នោះ វាទាំងចូលចុះ ចូលជាន់ក្តារយន្ត ធ្លាក់កូន
ប្រែឆ្កៀ ដល់ទៅជីពជន្ម គាលីមិនតន់ មិនគិតអនិច្ចា ។ វាយក
ឆ្នឹងម្តាយ ទៅចោលព្រៃឡាយ មានខេតធីតា យកថ្មាំមកប្រោះ រស់
ជាមនុស្សា ទើបខេតធីតា យកថ្មាំដរៃ ។ ឲ្យសេតកាលណា តើតជា
សារិកា ម្តាយហើរវិលរៃ ចូលក្រុងភាព តាល់មហាក្សត្រថ្ងៃ ព្រះបាទ
ជៀស្តជ័យ រៃលរបស្ត ។ ម្តាយទូលអស់ក្តី ព្រះបាទចក្រី ជ្រាបត្រង់
ប្រការ ទើបស្តេចប្រើជាង ឲ្យស្អាងរថនា ទ្រុងមាសថ្លៃថ្លា ឲ្យម្តាយ
និត្យនៅ ។ មានកាលមួយថ្ងៃ ព្រះមហាក្សត្រថ្ងៃ ស្តេចលើតទ័ពទៅ
ច្រាបញ្ចាំងក្រៅស្រុក ស្តេចទុកម្តាយនៅ មានស្តីម្នាក់ទៀ បិត្តគាច
ឫស្សា ។ ចាប់យកម្តាយបាន ជកស្វាបពេមច្រាណ ម្តាយធ្វើរវែនា
ឯធន្លានោះ វាចុះលើលា ម្តាយតែយាត្រា ទៅភួនិត្យនៅ ។
ទឹងរូងកណ្តារ- សរសោតបានយល់ ម្តាយហើយចៅរ៉ើ ថៃតាំក្សា
ឥតមានហ្មងសៅ ម្តាយនៅយូរទៅ លុះត្រាស្វាបជា ។ ទើបម្តាយ
លាស្តេច កណ្តុរសត្រាច់ ចេញបរលើលា មកដល់ឈើធំ ត្រសុំ
សាខា ម្តាយទំព្រឹក្សា សម្រាន្តអង្គកាយ ។ ទើបមានស្តេចភ្នំ

ស៊ុំផ្លែព្រីក្ស បួនមែកកើតក្លាយ មែកមួយកើតជា បក្សាកបក្សាយ
មែកមួយកើតក្លាយ ជាប្រើសមាសធំ ។ មែកមួយជាស្វា មែកមួយ
កើតជា មនុស្សាស័ក្តិសម ម្តាយយល់ដូច្នោះ ហើរឆ្ពោះទៅទំ
លើឈើទុតម ជាថ្នាំពិឌូល្ហ ។ ហើយម្តាយកោតា កើតជាមនុស្សា
រូបកងឋវរ ត្រាច់ដើរស្វះស្វែង ម្នាក់ឯងចេញចរ មកនៅនេះប-
រិបូណ៌ជាន់សុខ ។ នៅនឹងឥសី តំបន់ឆ្នាំបី នេះហើយណ៎ាបា
កុមារជាន់ស្តាប់ សាសតូមាតា មានចិត្តអនិច្ច សង្វេគពេកពន់ ។
ហើយអ្នកវ័ំងឆ ថាអញនេះនឹង ចង់សងព្រះគុណ មាតាបិតា
ទុតមាមហាធន់ ដោយនៅដាំបន់ ហានាយឯណ៎ា ។ លុះគិតដោយ
ន័យ យល់ហេតុប្រពៃ ថាគួរអាត្មា ចូលទៅនគរ សួរកេរ៌ឋិតា
មើលឈើសុវណ្ណា ពជព្រឹក្សតីរពន្ធ ។ គិតហើយខូលថា បតិត្រ
មាតា តាលអ្នកគ្រាច់ត្រង់ ចេញព័នគរ បវរដ្ឋរង់ បិតាជាន់ត្រង់
ប្រពន្ធត្រូវអ្វី ? ។ ឥឆ៌ស្តាប់ឆ្លើយថា ម៉ៃកូនស្នេហា ម្តាយជា
សាក្ស៊ី តាលនោះបិតា មេត្តាប្រណី យកចិញ្ចៀនថ្មី មាសឆ្លុំនរចនា ។
ជាំតួងមកិត ទាំងព័រសន្ធត ជាកងសុវណ្ណា ជាក់ជើងម្តាយអ្នក
ទាំងជាក់ណ៎ាបា នេះត្រូវបិតា ប្រពន្ធមកម្តាយ ។ សោតំសុត្វា
ព្រះរាជកុមារ រឿងវិត្តិប្រាជ្ញប្រាយ ជាន់ស្តាប់មាតា រៀបហារអធិប្បាយ

អ្នកជ្រាបសព្វសាយ សត្វសុសសេចក្តី ។ ទើបអ្នកទូលថា បពិត្រ
មាតា សូមទ្រង់ប្រណី ខ្ញុំសូមលាទៅ លំនៅបុរី មើលឈើតាំងទ្វី
ទ្រព្យអ្នកមាតា ។ សូមព្រះទំវង់ ជាំត្បូងបញ្ចង់ ជាកងនោះណា
ដែលចិតជាក់ ដើងអ្នកមាតា គ្រាន់ខ្ញុំបានជា សំគាល់សាក្សី ។
មាតាស្តាប់បុត្រ ទូលលាចំហុត ទឹងទៅបុរី នាងមានព្រះទ័យ អាល័យ
ប្រណី ដ្បិតក្មេងសេចក្តី នាងយាត់ទៅថា ។

បទព្រហ្មគីតិ

ហៃកូនស្ងួនសំឡាញ់ ជាតាលគេញចិត្តចិន្តា កូនអើយកុំបីជា
ចរចេញឆ្ងាយម្តាយជាម្ត ។ ហេតុត្បិតជានៅក្មេង ដើរម្នាក់ឯងកន្លងព្រៃ
ជំ ព្រៃស្វាត់ ។ ពុតិម សោតសឹងសត្វតាឡយង៉ឹងឡង ។ មួយក្រែងអត
កោជមា គ្មានអ្នកណាជាតាវេជ៍ សត្វថ្លែម្តាយស្ងួនគ្រែង ពុំឲ្យហ្មង
ចិត្តនៃជា ។ បទុមវែង្សប្រែត្នែ ឮម្តាយយាត់ដូច្នោះណា អ្នកទូលអង្វរថា
បពិត្រអ្នកមានគុណថ្លៃ ។ កុំបីអ្នកជាម្ត ទីងខ្លួនខ្ញុំឡើយម្ចាស់ថ្លៃ
មេត្តាឲ្យផ្ទៃជ្រៃ ឲ្យបរិភោគថ្លែងកាយា ។ ជាសត្វបក្សីធំ ហើយទើប
ខ្ញុំហើរយោគ្រា ដោយឋានអាកាសា គ្មានសត្វតាឡអ្វីបៀតបាន ។
បើបានដល់ទគរ ហើយចុះបរចាកប្រែប្រាណ បរិភោគមួយខ្មៀតបាន
ក្លាយជាមនុស្សបរយោគ្រា ។ នាងស្តាប់ពាជបុត្រែត្នែ នាងពុំយាត់ពុំទាំងខា

ទើបនាងយកផលា ផ្លែឈើទៅបុត្រស្តេចថ្លៃ ។ ហើយឲ្យព្រះទំរង់ ទាំង
គូផង់ល្អប្រពៃ ហើយឲ្យព្រះតារជ័យ បុត្រកំសត់ដោយស្នេហា ។ ហើយ
ឲ្យបុត្រប្រមប្រិយ លាឥសីជាឪពុក ភុមារស្តាប់មាតា អ្នកឲ្យទៅថ្វាយ
បង្គំ ។ ក្រាបលូលាឥសី សព្វសេចក្តីស្រេចហើយផង់ ក្រាបលាម្ចាស់
ទុក្ខឆ្អឹង ទៅនគរសូរបិតា ។ ឥសីព្រមបើកទៅ ទើបប្រដៅមន្តនាថា មួយ
ឈ្មោះមណិចិត្តា អ្នកទន្ទេញចាំគ្មានក្រេច ។ ហើយទើបព្រះឥសី ច្រាប់
អស់ក្តីសព្វសេចគ្រប់ ទុបទេសមន្តស្នូទុបកិច្ច ឲ្យគាថាសព្វវេលា ។
កុំបីចៅប្រហែស ដើរក្រមែសក្លេចគាថា បើសូត្រសព្វវេលា ជាស្នេហ៍
មុខមន្តស្ងាំងឡាយ ។ ពោះបីពួកសត្វម្រឹគ កាចតន្ទឹកសឹង្ហចៀស
ឆ្ងាយ ការភ័យការអន្តរាយ ការទុក្ខគ្រប់ឆនាគា ។ ពោះមន្តស្នូសត្វ
ណាក្តី យក្ខិនីត្រាយហឹង្សា ប៉ិសាចការចសំដាំ សឹងស្រឡាញ់ឃាត់
តុំបាន ។ ឆ្លាំស្រេចព្រះឥបី សូត្រសុតីឲ្យពរក្សាខ្លួន ជាចៅទៅឲ្យបាន
ឈ្នះសត្រូវផងនាគា ។ ឲ្យបានដល់នគរ តែបវរដួចច្រាថ្នា ដួចចិត្តប៉ងច្រាថ្នា
ដែលសច្ចាកុំបីឃ្លាត ។ ឲ្យពរស្រេចកុមារ ទនសំសោក្រាបអគតាទ
ចេញចរសីហនាទ គ្រាច់កណ្តែងកងអង្គា ។ ទិជាទតឲ្យច្រាំ ជួប
ចាប់ចាំពោលពណិនា តាំងពីនាងជាយោ ជាសារិកាតែកែលក្សាណ ។
លុះបានសោយផ្លែជ្រៃ ទើបប្រពៃក្លាយប្រែក្លាណ ជាមនុស្សលុះដល់

ចាន បុត្រសាសនគ ។ បន្ទែបន្ទាយលើក លង្ហិលលិចលើកពោល
ពាណិនា បរិបូណ៌ដូចចូលជា ខ្សែប្រាំមួយសូរចេហាន ។

បរកាតត

ន័យនេះថ្លែងត ដំណើរដំណ ដំណាលទំនង តាំខ្សែប្រាំ-
មួយចាំដូចចង ចរចាទំនង ពីរជកុមាក ។ បទុមវន្ស ស័ក្តិសមទុត្តង្ស
ទុត្តមអតុលា ស្តេចយាងសីហទាទ គគាតយាត្រា ចេញចាកលំលា
អាស្រមកុដី ។ ម្នាក់ឯងទុតម សូបសូត្រធ្លាំ ឮតែបក្សី ចចាតខ្វែក
ក្អែក យំស្រែកតេញព្រៃ អ្នកនឹកអាលយ ដល់ព្រះមាតា ។ មយូរ
តេនតន់ ក្រៀលក្រចហែមហង្ស សត្វសារិកា ក្អែកទុងតោម សេកសោម
សេកយា ហ៊ាចហ៊ោរខ្ញៀវខ្ញា យាសយំអឺងកង ។ អ្នកយាងចណ្តើរ ឆ្នៀង
នេត្រមៀងមើល បក្សីសាសង អ្នកតែងកាវនា គាថាមន្តងង ខ្សែ
បក់ម្តង ។ សាយសព្វទិសា ។ មានស្តេចប្រើសមាស បរិវ៉ាតេញតាស
ក្នុងព្រៃចាមក ប្រើសមាសដើរដល់ យង់យល់កុមាក មានចិត្តស្នេហា
ស្រឡាញ់អ្នកព្រៃ ។ ដោយតេជះបុណ្យ វិសេសតេកពន់ ត្រូវប្រើស
មាសមៃ ប្រើសមាសគន់គិត ចាប់ចិត្តអាល័យ អាណិតអ្នកថ្លៃ ដោយ
ដើរម្នាក់ឯង ។ ប្រើសមាសគិតថា ចង់ជួនជាគ្នា សោះស្ងាត់កណ្តែង
កុំឲ្យកុមាក យាត្រាតែឯង តិតស្រែចចារចែង សាកសួរកុមាក ។ ថា

អ្នកកម្ទេះ មុខមាត់ស្រស់ឆ្អះ អញ្ជើញទៅណា កុមារស្តាប់ហើយ ឆ្លាស់ឆ្លើយទៅថា យើងនឹងយាត្រា ទៅវិទេសក្រុង ។ ប្រើសស្តាប់ ឆ្លើយភ្លាន អ្នកទៅតើមាន ហេតុអ្វីអ្នកមាស កុមារស្តាប់ស្រេច ច្រាប់ ស្តេចប្រើសមាស ថាយើងយាងយាស ទៅមើលព្រឹក្សា ។ សុវណ្ណ-ភជព្រឹក្ស ពីរពង្សអធិក ជាទ្រព្យមាតា ប្រើសមាសឆ្លើយឆ្លៃត សួរ ទៀតទៅថា ឯព្រះមាតា អ្នកឯងនោះក្តី ។ ស្តេចគង់ហាន់ណា កុមារ ឆ្លើយថា មាតាក្សត្រី អ្នកគង់អាស្រម បរមកុដ ជិតព្រះឥស៊ី មិត្តា ជិនជាក់ ។ ប្រើសមាសឆ្លើយថា រាំងមាតា បិតានៃអ្នក មកដល់កុដ ក្សត្រីវរលក្ខណ៍ ព្រះមាតាអ្នក នោះឆ្ងាយមហិមា ។ ម្តេចអ្នកសួរសែង ហានត្រាច់ម្នាក់ឯង កណ្តែងកំព្រា ចេះខ្ញុំជូនអ្នក វរលក្ខណ៍សោភា កំដរជាគ្នា តាមផ្លូវទៅហោង ។ សូមអ្នកស្នេហ៍ស្និទ្ធ អញ្ជើញឡើង បិត ឡើងគង់លើខ្នង ខ្ញុំទន់នាំហោះ ផ្លេកផ្លោះកន្ទុង ហួសព្រៃព្រឹក្ស ផង ឆាប់ដល់តុំលង់ ។ កុមារស្តាប់ជាក់ ត្រេកអរហើយអ្នក យាន យាសឡើងគង់ លើខ្នងប្រើសមាស ឧកាសវារវង្ស ហ៊ោបហោះដម្រង់ វិទេសរដ្ឋា ។ គំរប់បីថ្ងៃ ឋានដល់ក្រុងវិត្រ នៃពជភាព ប្តីរដ្ឋនោះ ហើយចុះយាត្រា ដើរដល់សាលា ទៅក្រៅខន្ធ ។ ទៀបទីសាលា នោះមានតង្ឃ ស្រះមួយដ៏ល្អ កុមារចុះស្រង់ ជ្រះតង្ឃ

កាយតរ ហើយអ្នកចរចរ ឡើងលើសាលា ។ បរិភោគភោជន ស្រេច
ហើយអ្នកតន់ អ្នកតែតមេត្តា បើកប្រើសមាសភៅ រកស្មៅភោគ្គា ស្រេច
ហើយកុមារ សម្រាកអង្គកាយ ។ អស់អ្នកនគរ ប្រុសស្រីតែវរ ច្រាប់
គ្នាសុះសាយ ថាមានកុមារ ក្លាងធ្វើតធាយ ល្អណ្តុះអង្គកាយ ដូចជាខេមៈ-
បុត្រ ។ ដំរះលើប្រើសមាស ក្តីផ្ទេកនុកាស ល្អណ្តុះបរិសុទ្ធ ឯអង្គកុមារ
សមជាពជបុត្រ មិនតឹកស្តួសុទ្ធ ថយថោកតង្ហា ។ ដោយតេជបុណ្យ
សីក្តីសច្ចិលើសលន់ បញ្ជូនចិត្តា គ្រប់មនុស្សក្នុងស្រុក គគុកត្រៀបត្រា
មានចិត្តស្នេហា ស្រឡាញ់ក្រៃពេក ។ សឹងនាំចំណី តំស្តុកភោជន៍សាលី
អនន្តអនេក មកជូនកុមារ ត្រៀបត្រាពន់ពេក ចំណីថម្ងៃក ពុំហ៊ានភោគ្គា ។ ខ្លះថាអ្នកប្រុស មុខមាត់ស្រស់បស់ បែរមកអាយ៉ា ខ្លះភ្ញែច
វិញ្ញាណ មើលប្រាណកុមារ ខ្លះលាន់មាត់ថា យើល្អអ៊ីម្ទេះ ។ ឧកូនឯ
អ្នកណា មេ្លះសមមាតា ស្រឡាញ់ម្តេចអេះ បើជាកូនអញ ពាលពេញដូច្នេះ ហើយអញមិនចេះ ឲ្យនឿយព្រួយទេ ។ ឯអស់មនុស្សម្នា
ម្បើងលើសាលា ដណ្តើងសួរថៃ ថាអ្នកមាសថ្ងៃ ប្រពៃស្មាលស្នេហ៍
អ្នកមកនេះតែ ម្នាក់ឯងឯកា ។ រីឯដំហាន ម្តាយបុកណា អ្នកនៅឋានណា
កុមារស្តាប់ហើយ ទើបឆ្លើយភៅថា យើងទៅព្រឹក្សា ព្រៃព្រះហិមពាន្ត ។
មហាជនសួរថា វិញ្ញាតិកា ត្រៀងណានសន្តាន ត្រកូលពូជពង្ស

ជាតិវង្សប៉ុន្មាន ក្នុងស្រុកនោះមាន ខ្លះដែរឬទេ ? ។ កុមារធ្វើយវែ
យើងជាអ្នកព្រៃ យើងមកត្រោះតែ ចង់មើលរាជព្រឹក្ស ពន្ធឹកពាំងខ្ទ
ហេតុត្បិតព្រះកេ័ត្ន មាតាបិតា ។ រីឯញាតិផៅ បងប្អូនកូនចៅ គ្មានស្គាល់
អ្នកណា ជាញាតិសន្តាន ត្រឿងលាន់តន្ត្រី ត្រង់ញាតិកា មានគ្មានមិន
ដឹង ។ មហាជនបានស្តាប់ កុមារថ្លែងប្រាប់ សព្វគ្រប់សោតសឹង ឆ្ងល់
ក្នុងចិត្ត គ្រប់គ្នាជញ្ជឹង ថាបើដោយដឹង សំបុត្រក្សត្រា ។ ជាអម្ចាស់
យើង ទើបរូបល្អក្លើង ដួងកក្រើជ្រះថ្លា ដំណើរសើហនាទ គគាតក្តៀវក្លា
ប្តូរលំថ្កើងឥរិយា កណ្តាលដំនុំ ។ ឈាមមុខថ្លាជ្រះ កបកាយល្អល្អះ
ឫកពារម្យាទំ សម្ងើនព័ភេះ សព្វនោះរងើ ផ្អែមល្ហែមសួនសម
ជាបុត្រក្សត្រា ។ គិតហើយសួរទៅ ថាអ្នកល្ខេញល្ខៅ ជាបុត្រអ្នកណា
ចូលអ្នកថ្លែងប្រាប់ យើងស្តាប់រាប់ថា រីនាមបិតា មាតាឈ្មោះអ្វី ? ។
ព្រះបទុមវង្ស ស្តាប់ហើយអ្នកទ្រង់ តតបសំដី ម្តេចអ្នកហ៊ានសួរ
មិនគួរគប្បី យើងប្រាប់អ្នកអ្វី មាតាបិតា ។ គួរសួរឈ្មោះយើង
ម្តេចហ៊ានចេចែ សួរហួសមាត្រា ដល់ព្រះនាមថ្កែ នៃព្រះមាតា បិតា
នោះណា យើងប្រាប់ម្តេចបាន ។ មហាជនបានស្តាប់ អ្នកថ្លែងសារសេព្ធ
ហាក់ក្រោធពុំក្សន្តិ កិតព័យខ្លួចខ្លាច អំណាចត្រប់ប្រាណ ស្ទើមស្ងាត់
ពុំហ៊ាន ហើយហាមាត់ស្តី ។ លាចុះយាត្រា ទៅផ្ទះអាត្មា ចាំធ្វើប្រុស

តំនស្រី សឹងតែនិយាយ ឮសាយឥតបើ សរសើរបារមី នៃពជបុត្រា ។
ព្រះបពុមវង្ស លុះយប់អ្នកទ្រង់ ផ្ទំលើសាលា ជាសុខក្សេមក្សាន្ត
សម្រាន្តកាយា ប្រើសមាសសោតណា តាំយាមពុំឃ្លាត ។

នឹងថ្ងៃឯកាទសី ព្រះបាទវិមល ធម្មពជលោកនាថ ស្តេចផ្ទំ
សុខា វេលាអធ្រាត្រ ទេវីក្នុងជាតិ ឈ្មោះទេពធីតា ។ គឺកុលកេសី
តែនៅប្រក្រតី រក្សាព្រឹក្សា លួសមាសខ្លី ក្នុងទីក្សត្រា ដឹងថាកុមារ
ឈ្មោះបពុមវង្ស ។ កូនទាងមរណ- មាតាសោកស័ត យាត្រាដល់ក្នុង
ប៉ុរីរដ្ឋា ចិន្តាបម្រុង ចង់ស្គាល់នូវអង្គ ព្រះវរបិតា ។ ទើបទេពទេវី
នាងចូលទៅជិ- មិត្តក្រាប់ស្តេចថា ទៅបពុមវង្ស ជាអង្គបុត្រា
មរណមាតា ចូលក្នុងបុរី ។ គង់លើប្រើសមាស រុងរឿងឧត្តាស
ផ្ទុះឆ្ងាស់ធ្ងី ឈប់នៅសាលា វេលាពត្រី ទៅក្រៅបុរី ផ្ទំសុខ
សយនា ។ ព្រឹកនេះចូលមក ក្រោថ្នាំនឹងរក ស្តេចជាបិតា ក្រាប់
ស្រេចនិម្មិត ជាត់ចិត្តកាយា រឯក្សត្រា វិមលធិបតី ។ ស្តេចផ្ទំសុខា
លើទីសយនា ព្រឹកព្រាងសូរ៉ាយ៍ សូរ្យសែងរឿងរះ ក្តីច្បាស់ស្មើ
ព្រះបាទចក្រី តើនចាកសយនា ។ ស្តេចទ្រង់វិតក្ក វិចារណ៍ពុំសុខ
សង្ស័យគិតថា នាងនាថវេលាក្តណ៌ មរណមាតា កូនទីងនណា
ទីងអញឬតេ ។ មរណមាតា នាងក្រាយជន្លា ហើយក្តាយក្រាណប្រែ

ជាសត្វសាកល បក្សាវិញទេ ឯងតើកូនគេ មិនកូនអញ្ចឹង ។ បើកូន
ក្សត្រី ខាងមានស្វាមី បុរសឯណា អញនឹងទៅចាប់ សម្លាប់អាសារ
បើជាក្សត្រា ខុសដៃ ។ អញនឹងលើកទ័ព ទៅច្បាំងចោមចាប់
សម្លាប់ឲ្យក្សយ រីអញនឹងយក បណ្តោយដោះដៃ ឲ្យបានស្រីថ្លៃ
ទៅគេកាលណា ។ ហើយក្សត្រទ្តម ចេញចាកបន្ទំ ទ័ពសយខា
តន់ចុងកេងត្តេ មហាក្សត្រត្រាស់ថា ហៃអស់សេនា អមាត្យទាំងឡាយ ។
ចាត់គ្នាចេញទៅ ចាំទ្វារកំងក្រៅ ទាំង ៤ ទិសឲ្យយ បើឃើញក្មេងប្រុស
មុខស្រស់ឆើតឆាយ ដឹះប្រើសមាសកាយ នាំមកឲ្យអញ ។ អមាត្យ
ចានស្តាប់ ខ្លួលបង្គាប់ បង្គំលាចេញ ចាំគ្រប់ទ្វារ ៤ គ្រប់ខ្លួនទៅមិញ
មានតែឯងខ្លួញ ខ្លួងកុមារ ។ ឯកុមារកេ ព្រឹកព្រាងសុរិយោ
ចាំងចែងជ្រះថ្លា ព្រះបពុមវង្ស ទ្រើសទ្រង់ចេស្តា តើនចាកសយខា
បន្ទំសុខសាន្ត ។ ស្រាប់តែគ្រូស្អាងស្អាត សោយគន្ធជាត អាហារ
ស្រេចចាន ហើយសោយផ្ទៃថ្ងៃ ប្រពៃថ្លើងថ្លាន ថ្នាំទ័ពដែលចាន
ពីព្រះមាតា ។ តេជៈផ្ទៃថ្ងៃ ថ្នាំទ័ពប្រពៃ ប្រែប្រាណរូបា ល្អល្អះ
លើសមនុស្ស ល្ងង់ល្ងាសកាយ ហាក់ដូចទេព្តា ចុះចាកសួគ៌ថ្លៃ ។
ហើយអ្នកគាំពា មណីចិន្តា សិល្បសិទ្ធិសាស្ត្រសៃយ រូបកងល្អល្អះ
ថ្នាជ្រះប្រពៃ តន់ប្រើសមាសមៃ ចេញចរយាត្រា ។ មហាជនតាំង

ឡាយ យើញរូបឆើតឆាយ ចាប់ចិត្តស្នេហា មកមើលជួបជុំ កុះកុម
ត្រៀបត្រា ហែជាបរិវារ ច្រើនកៃក្នុងសង្កៀ ។ ព្រះបទុមរ៉ង្សី ក្តល់
ថ្កើងពួជតង្សី ថ្កើងបុសតសៅ ស្តេចយាងយាត្រា មនុស្សម្នាហែ៧
ចូលដល់កំងក្រៅ ខាងទិសបូពា ។ មនុស្សក្នុងនគរ ជ្រួលច្រាលំ
រឹកវែ បង្ហាញគ្នីគ្នា មើលហើយមើលទៀត ច្រើនជ្រៀតមហិមា
ប្រហៀតជ្រៀតគ្នា តាមមើលមិនឆ្អែត ។ សង៏ខាងមាគ៌ា ខ្លះសួរសន្ទនា
ថាអ្នកប្រុសតន់ អ្នកមកពីណា កាយាល្អាសល្អន់ អ្នកអើយចូលតន់
មកនេះខ្លះក៏ ។ ស្រីខ្លះឥតខ្មាស លូកស្ទាបប្រើសមាស ស្ទាបដល់កុមារ
ខ្លះស្រែកតីឡាយ អ្នកអើយមេត្តា បែរមកអាយក៏ យើង៏មើលមុខផង ។
ព្រះបទុមរ៉ង្សី ស្តាប់ហើយអ្នកទ្រង់ ញញឹមមួង។ ស្រីខ្លះហុចស្ទា ហុចផ្កា
កម្រង ឲ្យទឹកអប់ផង ស្រឡាបអង្គកាយ ។ ខ្លះបានចំណី ចេកពុំ
ដូងខ្ចី ខ្លះតត្រីង៏ស្វាយ ខទឹមរៀបពុំ ខ្លះទំពាំង៏ឡាយ សែង៏រែក
ខ្លួលស្តាយ តាមជួនត្រៀបត្រា ។ ព្រះបទុមរ៉ង្សី យាត្រាត្រាច់ត្រង់
ដល់ទ្វារទិសា ពីមុខពជកំង ជួបទាំង៏អមច្ច អមាត្យក្សត្រា ឲ្យចាំនោះ
ហៃ ។ អមាត្យបានយល់ កុមារទំមិល រូបពង៏ល្មមស្មៃ មានចិត្តស្រឡាញ់
តេកតេញហួចំយ ហើយហៅថាហៃ អ្នកមានរូបល្អ ។ អញ្ជើញមក
អាយ យើង៏នឹង៏និយាយ សួរសាកនាមករ ព្រះបទុមរ៉ង្សី ទ្រើសទ្រង់

បវរ ស្តាប់ហើយចូលបវរ ចូលដំតអមច្ចា ។ អមាត្យតាំងអស់
សួរថាតម្ងោះ អ្នកមកពីណា កុមារបានស្តាប់ ឆ្លើយច្រាប់ទៅថា យើង
បរយាត្រា មកពីហិមពាន្ត ។ អមាត្យសួរថា អ្នកមានច្រាថ្នា រកអ្វី
ឬមាន ញាតិផៅនៅអាយ តាយាយត្រឿងណា ចូលអ្នកព្រមាន ច្រាប់
យើងផងវ៉ា ។ ព្រះបពុមវ៉ែ្ស ស្តាប់ហើយអ្នកទ្រង់ តតបវ៉ាថា ថា
យើងត្រាប់ដើរ មានបើច្រាថ្នា ចង់យល់ព្រឹក្សា តាំងតូមាសផ្តៅ ។
ជាទ្រព្យមាតា អ្នកតាមរក្សា ពីដើមទុកនៅ អមាត្យបានស្តាប់ អ្នក
ច្រាប់ហេតុខ្លៅ ទំសួរខ្លែតៅ ថាឯមាតា ។ អ្នកតើឈ្មោះអ្វី ចូរអ្នកស្រដ
ច្រាប់យើងផងវ៉ា កុមារស្តាប់ជាក់ ហើយអ្នកឆ្លើយថា អ្នកសួរតាត្តា
យើងនេះហៅគ្គន ។ មិនសួរឈ្មោះយើង សួរមូលចបើង ដល់ម្តាយជា
ម្តន មិនគួរយើងច្រាប់ សារសត្វសួរសេង អ្នកឯងហៅគ្គន សួរស្ទើម
ទៅជា ។ អមាត្យស្តាប់ហើយ ថាឧអ្នកអើយ អ្នកកុំក្រោធា យើង
មិនសួរឯង សំដែងខ្ជិច្ឆា ព្រោះព្រះរាជា ត្រាស់ប្រើសួរទេ ។ កុមារ
ឆ្លើយថា បើមហាក្សត្រា បរមត្តិយេ ដល់យើងឡើងទៅ តាល់
ហ្មាតង់តែ ស្តេចសួរយើងថៃ សឹមឱលក្សត្រា ។ អមាត្យស្តាប់ហើយ
ឆ្លើយថាអ្នកអើយ ឯនាមមាតា ពុំគួរពុំសម យើងពុំសួរថា សួរតែ
នាមា អ្នកឯងឈ្មោះអ្វី ។ បពុមវង្ស ទ្រើសទ្រង់ចេស្តា បានស្តាប់

សំដី អមាត្យទំនៀត សួរទៀតជាថ្មី ទើបអ្នកស្រដី ប្រាប់នាមអាត្ម ។
ថាយើងប្រាប់ត្រង់ ឈ្មោះបទុមវង្ស កុមារបុត្រា យើងទៅសត្វថ្ម
អាស្រ័យព្រឹក្សា គឺព្រហ្មមក បរមសុខសាន្ត ។ អមាត្យស្តាប់ជាក់
ថាច្នេះចូរអ្នក សណ្តាំតឈប់ខាន ចាំយើងទូលក្សត្រ បក្រតត្តិថ្កើងថ្កាន
អមាត្យចូលបាន ឡើងគាល់ក្សត្រា ។ ហើយក្រាបទូលថ្នូរ ថាតាលព្រះ
អង្គ មានព្រះរាជា ត្រាស់ប្រើយើងខ្ញុំ មើលក្មេងកំព្រា ឥឡូវយាត្រា
មកជល់ក្រៅហាន ។ ស្តេចត្រាស់សួរថា ជាកូនអ្នកណា ពង្សាសន្តាន
មាតាបិតា កុមារថ្កើងថ្កាន ទៅសួរតើបាន ប្រាប់ថាឈ្មោះអ្វី ។
អមាត្យទូលថា សួរនាមមាតា បិតានោះក្តី ថាពុំគួរប្រាប់ សារសេពួ
ទ្រើអ្វី បើព្រះបក្រី ទ្រង់សួរអាត្ម ។ សឹមក្រាបទូលអស់ ចេញតំណ
នាមឈ្មោះ ចំពោះភក្ត្រា មហាក្សត្រជាន់ស្តាប់ សារសេពួរាប់ថា មាន
ព្រះបញ្ញា ត្រាស់ប្រើតែម៉ា ។ នាំពាជកុមារ បរចូលត្រកាល តាំង
ប្រើសមាសន្តែ ឲ្យចូលមកធាប់ ប្រញាប់ណាទៅ អមាត្យតែស្ទៅ
អញ្ជើញកុមារ ។ ព្រះបទុមវង្ស ឮថាស្តេចទ្រង់ ហៅខ្លួនច្នោះណា
អ្នកតង់ប្រើសមាស ទុកាសថ្ងៃថ្ងា ដូចពាជសីហា ខនាថតក្លឹក ។
តម្រួតជាហាន បតុង្គេប្តីខ្លាន ហែច្រើនពន្ធឹក ខ្វៀងកូសបើកជុំង ត្រែ
សង្ខ័សន្ធឹក សេនាគគឹក ចោមហែកុមារ ។ ព្រះបទុមវង្ស ថ្កុំថ្កើងពួជ

តាស្ស កណ្ហាលសេនា ច្ចេដ្ឋកេរ្តីខ្ចង់ខ្ចស់ ច្ចេដ្ឋយសសក្តា ច្ចេដ្ឋវិទ្ធិ
ក្ខៀវក្លា តាទុកាតស្ថច់ស្ងែង ។ តង់លើប្រើសមាស ក្លឹផ្កេតុតាស
ចិញ្ចាចចិត្តែង តក្ត្រាស្រៀវស្រស់ ខ្ពង់ខ្ពស់ឯកឯង តើតឆាយលើស
លែង កណ្ហាលនគរ ។ មហាជនតាំងឡាយ តាមមើលក្មេចតាយ
ស្ទាំងតាំងឈប់ឈរ មើលឃើញសេនា យោធាវីករ តលពាលនិករ
ចោមរោមកុមារ ។ តម្រួតតាហាន ច្ចើរដើងប៉ុន្មាន ចោមជាបរាវ
មហាជនស្ងប់ស្ងែង តិតក្រែងក្សត្រា ច្ចើរទោសកុមារ រួចតែឆោម
ឆាយ ។ ខ្លះរត់យ៉ាងខ្លាំង រលេរលាំង តាមមើលឥទ្ធាយ ដល់ខ្លារ
ភជរាំង តាយតាំងពាយមាយ ក្មេចតិតសប្បាយ ដោយចិត្តស្នេហា ។
ព្រះបទុមវង្ស យាងចូលដល់ក្នុង ក៏ងហើយសួរថា សុវណ្ណភជ្រឹក្ស
តន្ទឹកថ្ងៃថ្ងៃ តើនៅទីណា ជាឯតប្បាយ ។ អមាត្យក្រាបថា
សុវណ្ណព្រឹក្ស តាំងតូរតើតឆាយ នៅខៀបច្រាំងមាស ទុកាសភ្នំសាយ
ខាងតូងពុំឆ្ងាយ បទុំក្សត្រា ។ បទុមវង្សស្តាប់ អមាត្យថ្លែងច្រាប់
សព្វត្រប់ហើយណា ចុះពីច្រើសមាស យាងយាសយាត្រា ដើរដល់ក្រឡា
ទីចុងកេងតែ ។ ដល់ហើយអ្នកថ្វាយ បង្គំកបកាយ តង់តាល់
មហាក្សត្រ ស្តេចយល់កុមារ សោការូបតែ ជួនកក្រែផ្ទូរជាត់ កប
ខ្នូរលក្ខណា ។ ស្តេចតេញព្រះទ័យ ស្រឡាញ់តេកក្រៃ ដូចសង្សារក

ចុះតាំងនាំង បល្ល័ង្កអាសនា ព្រះហស្តប្រាប់ ឲ្យអង្គុយជាបុត្រ ។ ថៃ
ថើបកេសា ហើយត្រាស់សួរថា ម្នាលកូនបរិសុទ្ធ ទ្រង់ធោមនិមិល
ដូចគល់ខេរបុត្រ លក្ខណាវិសុទ្ធ សួស្តីសមការយេ ។ កូនអើយមាតា
នៃអ្នកយាត្រា មកផងឬទេ អ្នកស្លាប់ទុក្ខវេ ខ្លួលថាអ្នកម៉ែ តុំបានមក
ទេ សូមជ្រាបចំព្តា ។ ស្តេចត្រាស់សួរទៅ ម្នាលកូនតាលទៅ ទ្រង់
ធោមទាយ អាយុអ្នកបាន ប៉ុន្មានវស្សា ចូរប្រាប់ឪពុក ណ៎ាមាស
ទត្តម ។ កុមារខ្លួលថា បានបីវស្សា អាយុនៃខ្ញុំ ស្តេចតិតថាបើ
ប្រមើលឲ្យសម ប៉ែតាមទំហំ សោឡសវស្សា ។ កូននេះមានបុណ្យ
រឿងឫទ្ធិលើសលន់ រូបធំទត្តមា ទើបត្រាស់សួរបុត្រ បរិសុទ្ធថ្លៃថ្លា
ថាឱមាតា នៃអ្នកឈ្មោះអ្វី ? ។ កុមារខ្លួលថា ឱមាតា នោះ
ព្រះចក្រី ព្រះអង្គជ្ញាបជ្រាប ដកឫសេចក្តី ស្តេចសួរថាបី-តាអ្នកឯណា ។
កុមារបង្គំ ថាបិតាខ្ញុំ សោយភព្វនគរ នេះឯងអនេក ជាឯកពាថា ស្តេច
ថាបិតា អ្នកនុ៎ះឈ្មោះអ្វី ? ។ កុមារខ្លួលថា នាមព្រះបិតា ធំរាជចក្រ
មាតាខ្ញុំប្រាប់ ដកឫសេចក្តី ស្តេចសួរទៀតខ្ញុ ថាឯមាតា ។ អ្នក
ឲ្យទ្រព្យអ្វី មកជាសាក្សី សំគាល់ខ្លួនថា កុមារបានស្តាប់ .សារសតួ
ខ្លួលថា គាលព្រះមាតា ចេញចាកបុរី ។ ជាសត្វសាវិកា ព្នាក់
ព្រះបិតា ទ្រង់ប្រោសប្រណី ប្រគានទំរង់ រ័ត្នដង់រង្វី ពាំងគួតីសិ

ដាក់ដើងមាតា ។ ខ្ញុលហ៊ើយអ្នកយក ព្រះខំរងំមក លើកថ្វាយ
ក្សត្រា ស្តេចទទួលវៃ តាំដៃកុមារ ទតហើយក្សត្រា ស្តេចស្គាល់
ដៀងជាក់ ។ ជ្រាបក្នុងព្រះទ័យ តុំមានសង្ស័យ សន្ទុះអន់អាក់
គិតថាកុមារ សោកាទ្រង់លក្ខណ៍ កូនខាងមរណៈ មាតាមែនពិត ។
ទើបស្តេចត្រាស់ថា ម្នៃកូនសង្សារ សំឡាញ់មាសមិត្រ មាតាអ្នកថ្លៃ
ប្រពៃស្នេហ៍ស្និទ្ធ ឥឡូវថេរបិត តំបន់ហានណា ។ ព្រះបទុមវង្ស
ចានស្គាល់ស្តេចទ្រង់ សួរហានមាតា អ្នកទូលទៀតទៅ ដោយនូវសត្យ
ថាឋានមាតា គន់ព្រៃហិមពាន្ត ។ ស្តេចស្តាប់ថាអើ មាតាអ្នក
តើ នៅនិត្យបិតហាន ទីឯអ្នកឯណា មេត្តានៃប្រាណ សត្វថ្លៃតើ
ចាន អ្វីបរិភោក្តា ។ រីមូសស្រាំងស្រួយ ពិសពស់ក្អែបខ្លួយ ម្រឹត-
មហឹង្សា ទីឯមានទៀបប្រាណ ទៀបហានមាតា ឬមួយសុខា
កាយជាឬទេ ។ កុមារទូលថា ឯអ្នកមាតា សុខក្នុងកាយ
សត្វម្រឹគតាលា ហឹង្សាគ្មានទេ សត្វថ្លៃសោយតែ ផ្លែឈើមើមឈើ ។
អ្នកគង់នៅនិត្យ អាស្រមទៀបជិត ឥសីប្រសើរ អ្នកទ្រង់ពប់អាន ប្រ-
ចានសារតើ ផ្លែឈើមើមឈើ ឱ្យបរិភោក្តា ។ តាបសនោះឯង ចិត្តល្អ
គួរស្រែង ទ្រង់សាងសីលា ស្តេចទ្រង់ស្តាប់ថែ ពាក្យឯកុមារ ទូលទើប
ក្សត្រា ត្រេកទ្រង់ដំណើរ ។ ស្តេចគិតថែថា មរណមាតា នៅបរិសុទ្ធល្អ

ឬមានស្នាម បក្រឹសួរត ដោយមានអំណរ ត្រាស់សួរទៀតថា ។
ម្នៃបពុមវង្ស កុមារទ្រើសទ្រង់ បុត្រវ័ត្តសង្ឃរ មាតាអ្នកតើ ជំណើរ
ប្រការ ហេតុម្តេចយ៉ាតយ៉ា ពីបិតាទៅ ។ ព្រះពជកុមារ ឮនស្តាប់
បិតា ត្រាស់សួរខ្នោះកូវ ត្រូវដូចអ្នកគិត ពិនិត្យទុកទៅ គិតដោះ
ហ្នឹងសៅ មន្ទិលមាតា ។ ស្រេចហើយទូលទៅ បពិត្រព្រះបៅ ចម
បក្រក្សត្រា មាតានិយាយ ប្រាប់ប្រាយខ្ញុំថា កាលដើមមាតា ជាកូន
កុដុម្ពីក៍ ។ ឯកុដុម្ពីក៍មាន កសិយាពីប្រាណ រួមសុខមួយខែ ប្រពន្ធ
ចុងឈ្មោះ កាលីទីវ៉ សម្ងាប់ជនន៍ មាតាខ្ញុំទៅ ។ ចាប់ជាតិជា
ត្រី កាលីអប្រិយ ក៏ប្រើកូនទៅ សម្ងាប់ត្រីទៀត តន់ត្រៀតសល់
ទៅ ស្រកាពីក្តៅ ទើបអ្នកមាតា ។ យកមកដាំចុះ រំពេចជាល
ដុះ ជាត្រប់ខ្ទុហា កាលីលួចដក យកចោលអស្តារ សល់ប្លុសខ្ទុហា
មាតាដាំបាន ។ ដុះជាព្រឹក្ស លេចសុវណ្ណា កាលនោះក្សត្រក្សាន្ត
ចេញទៅប្រភាត រុក្ខជាតិខ្ទុដ្ឋាន ឃើលឃើមាសមាន រស្មីជ្រះថ្លា ។
ស្តេចសត្វព្រះច័យ ទើបមហាក្សត្រថ្វៃ សុំឈើនោះណា មាតាលើក
ថ្វាយ ឥតស្តាយសោះសា ស្តេចប្រើសេនា ជីកតាស់ពុំបាន ។
ទើបព្រះមាតា អញ្ជើញាត្រឹក្ស រួចថ្វាយក្សត្រក្សាន្ត ត្រឹក្សអណ្តែត
ត្រសែតលើហាន អាកាសមកផ្ទាន ដល់កំធឹតុលធ៌ ។ ទើបព្រះមាតា

អញ្ជើញព្រឹក្សា ចូនចុះដល់ក្នុង អាងមាសរចនា ទើបឯងត្រង់ រៀប
រោងតែង្គាំង អតិសេកមាគា ។ ជាអគ្គមហេសី នៅចូនឆ្នាំបី ព្រះវរ
បិតា ចេញប្រាបសត្រូវ ស្រុកក្រៅសីមា កាលីឫស្សា លួងមាតាថា ។
ឱ្យជាន់ក្តារយន្ត ភ្នាត់ឆ្លាក់លើសលន់ ក្នុងខ្នុះប្រែងក្តៅ អ្នកឫយជន្ម
កាលគ្រានោះថា កាលីឃោរឃៅ ចិត្តកាចឫស្សា ។ ឃាតឆ្អឹងអ្នកម្តាយ
ចាក់ចោលអន្តរាយ ក្នុងព្រៃអសារ ចូនខេតខេវ៉ែ នៅទីព្រឹក្សា ប្រស់
ប្រាណមាគា រស់ដូចប្រក្រតី ។ ទើបខេតធីគា ឱ្យនុសថា លេម
ជាបក្សី ជាសត្វសារិកា លាមកបុរី ឡើងគាល់ព្រះប៉ា- តាត្រង់
មេត្តា ។ ទើបព្រះរាជា ស្តេចឱ្យនៅនា ត្រង់មាសរចនា នៅយូរ
ប្រមាណ ចូនមួយវស្សា ព្រះវរបិតា ចេញប្រាបសត្រូវ ។ ឯក្រោយ
នោះមាន សារិឡឹកមួយប្រាណ ចិត្តកាចខ្លីខ្លូវ ឈ្មោះនាងធន្លូ ចំជា
សត្រូវ ខេរទឹងក្រញូវ ចាប់យកសារិកា ។ ចោចរោមជាចំជាច ធន្លូ
ចិត្តកាច មិនគិតអនិច្ចា ហើយខុកជិតខាង ទឹកអាងរងថ្លា ត្រជាក់
កាយា ក្បាក់ដីនិស្ចារតី ។ ហើយក្រោកឡើងស្ទុះ ឈានដើងកៀរគោះ
ចឹកចាប់ឫស្សី ខោបចន្ទោះ លោតស្ទុះដល់ដី ចូលតួនក្នុងទឹ ស្តេច
តណ្ឌុរស ។ តណ្ឌុរមេត្តា រៀបឱ្យកោតា ចំណីយ៉ាងល្អ អ្នក
នៅជាប រោមស្វាបដុះប- រំបូណ៌ហើយចរ ចាកចេញយាត្រា ។

ក្រែងឆន្ទារក ឃើញហើយមិនយក មកចងគោសា លាកណ្តុរស
ចេញចរយាត្រា ដល់ដើមព្រីក្ស ឈើធំមួយមាន ។ ហើយឃើញ
ស្តេចខ្លា ស៊ីផ្លែព្រីក្ស មែកមួយបែរបាន ជាបក្សីធំ សំក្តិសមរូប
ក្រាណ ស៊ីមែកមួយបាន ជាប្រើសមាសធំ ។ មែកមួយជាស្លា មែក
មួយកើតជា មនុស្សាសួនសម ហើយនិម្មិតបាត់ សូន្យស្ងាត់ជ្រងំ
ទើបអ្នកហើរទំ ចឹកចាប់ផលា ។ ជាថ្មាំទិព្វថ្នៃ គ្រប់មែកប្រពៃ ហើយ
ហើរយាត្រា ទៅដល់កុដិ ឥសីសីលា សន្ធតនាមថា មិត្តាជិនជាក់
ទើបបរិភោគ្គា ថ្នាំទិព្វកាលណា ប្រែក្រាណឥតអាក ជាមនុស្សដូច
មុន ល្អសល្អនក្រៃលែងគួណ៌ ត្រាច់ដើរស្មែនស្មាក់ តាមជងិមាតិ ។
ដើរដល់កុដិ អាស្រមឥសី ចូលថ្វាយវន្ទា ទៅនឹងឥសី ជានប័ទិវ
ឥសីមិត្តា- ជិនចរបុះស្រែង ។ ទឹកស្រះរលើសខ្ញុំ ក្នុងផ្ទាបខ្ទុម
ហើយនាំត្រាច់ត្រង់ ឲ្យអ្នកមាតា រក្សាយូរលង់ លុះធំពេញអង្គ
ជានប័ទ្មាំហើយ ។ ឯព្រះជនន៍ វៀលាកត្រី សោកពុំមានស្បើយ
នកដល់ក្សត្រា ពុំមានក្តេចឡើយ នឹកឈើមាសហើយ អ្នកសោយ
សោកា ។ ខ្ញុំឃល់ជនន៍ អ្នកកើតទុក្ខទី ទុក្ខពេមនស្ស
កណ្តែងកណ្តាច គ្រមោចឯកា ផ្សាខ្ញោចឧរ សង្រ្តែងសង្រៃ ។
ខ្ញុំយកអាសារ មិនឲ្យមាតា កើតទុក្ខតេកក្រៃ ខ្ញុំត្រាច់ដើរមក សួរកេ

ក្សត្រថ្ងៃ មើលឈើទាសមៃ ឲ្យដឹងកិច្ចការ ។ ឥឡូវព្រះអង្គ កេរ្តិ៍មក្សត្ត
ចានច្រើន ឥតមានពេត ឈើមាសតាំងគួ ដុះដូរសាខា សព្វគ្រប់
ប្រការ ពុំមានអន្តរាយ ។ សូមលោក្សត្រក្សត្ត ទីឆ្ងាំពតិមាន ៗ
ប្រាប់អ្នកម្តាយ កុំឲ្យអ្នកមាន ព្រួយប្រាណតិតឆ្ងាយ តិតក្សត្រឯងទាយ
ឲ្យស្បើយទុក្ខា ។ ទើបស្តេចយាត់ៗ ហៃកូនតាលៗ កុំគាល
យាត្រា ចូរអ្នកឈប់ចាំ ទំពំបិតា កេណ្ឌពលសេនា ជួនអ្នកៗផង ។
ទើបស្តេចតាក់តែង ប្រាង្គមាសចរំញ័ង ល្អល្អះកន្ទុង ហើយរើស
ក្មេងស្រី ប្រមប្រយ័ត់ហ្មង ប្រាំរយឲ្យផង បំរើបុត្រា ។ ក្មេងប្រុស
មួយពាន់ ថ្លាយជាកំណាន់ បពុមវង្ស តែងកេងមុខបួន សមសួន
សោភា បិទមាសរចនា ប្រពានប្រើសមាស ។ មានពលប្រាំរយ រែក
ស្មៅដេយ ប្រក្រតីតេញ្ញាស រើសរកស្មៅខ្ចី ចំណីប្រើសមាស ក្រាល
ពេជ្រតាស កន្ទេលប៉ាន់ ។ ក្រាលក្រោមស្ពាន់ស្ពាស កន្ទេលតាស
ទង់ដែងសំពាន់ ខាងលើក្រាលប្រាក់ ឆ្លៀតធ្លាក់ច្រើនជាន់ ពួកពលកំណាន់
ផ្ទាស់គ្នារក្សា ។ យាមយប់ដើរល្បាត តាមថែរក្រោងក្រាត ពេញកេងរចនា
ពេលថ្ងៃលាងតឹក ពេលព្រឹករក្សា ឲ្យស្មៅគោក្តា ជាក់ទីឆ្ងាជ័ន
មាស ។ អាងមាសជាក់តឹក ឲ្យប្រើសមាសផឹក ថ្លៃឆ្ងាអង្គតាស ព្រះ
បពុមវង្ស អ្នកគង់ប្រាង្គមាស មន្ត្រីកស្តេតាស ឡើងគាល់ត្រៀបត្រា ។

ព្រះបាទបពិត្រ រីមលង្រង់ប្តូរ្ជ ឲ្យដ្ឋុំសេនា ភាហានបតុរង្គ ប្រៀបប្រុងអាត្មា ពលពាលរថា គជេន្ទ្រអស្សតរ ។ ពលថ្មើជើងស្មាត់ រួបពង់ជំនាត់ ប្រុងប្រាណកាងករ កាន់គ្រឿងគ្រប់ដៃ វ៉ាងវៃឈានឈរ មានចិត្តត្រេកអរ បង់យល់ហ៊ាមតាន្ត ។ ពលច្រើនធោះឡា ច្រាំពីរអោនកិនីបីមាន លុះបានឫក្សពារ ពេលដោតញាណ ផ្ទុមត្រែស័ង្ខសាន ប្រគំជន្ត្រី ។ ស្តេចយាងយាសគង់ គជេន្ទ្រវែម – ឆ្ងល់តាប់រង្ស៊ី សុទ្ធសឹងចេនា ជ្រះថ្លារង្ស៊ី ខុនណាងសារស្រី សឹងជិះសេះណា ។ ព្រះបទុមរង្ស៊ ឈរលាឡើងគង់ ប្រើសមាសថ្លៃថ្លា ចេញជាទ័ពស្រួច ត្រជួចខ្មៀវខ្មា ទាំថ្លូបបិតា ខនោថតតក្រែង ។ បើកចាំងអគារម្យ ក្លៀវក្លៃសំត្រសុំចាមរសូរ្យសែង រីជនីជាយជាត់ (១)រ៉ូត្តចាំញែង សូរសេតូតត្រែងខ្ទរខ្ទាយតសុធ ។ ធូលីផ្សែងផ្សព្វ ហ៊ោរហួសត្រឡប់ ទ្រលោមព្យោមាស្រទំអាកាស ដេរដាសមេឃា ដោយឫទ្ធិសម្ភារ ព្រះបទុមរង្ស៊ ។ ខង់ជ័យជាមុខ ច្រាលច្រើនគគុក ភាហានពលតង្ស៊ ក្រោយខោះពលរដ្ឋប្រតិទ្ធរឿណង្គ ពលសេះទ្រង្រង់ សុះស្មាត់ក្លៀវក្លា ។ គជេន្ទ្រសារសឹក ខ្មៀវខ្មៃអជិក បន្ទាប់ក្សត្រា ពលថ្មើប្រុងច្រាឆ សង៍ខាងមាគា ច្រាំជួរជិតគ្នា គ្រឿងគ្រប់ដោយដៃ ។ ស្តេចលើកភាហានចេញចាកពជង្ហាន សប្បាយក្សត្រៃថ្ងៃ ចូលព្រៃព្រឹក្ស សាខាត្រៃឈើ

១– រ៉ូ : ពាក្យបុរាណ ប្រែថា: ផ្ទួន, ផ្ទួនដា ។ រ៉ូត្ត ប្រែថា: ផ្ទួនកែវ ។

ត្រុយឈឹងល្ងឹងល្ងៃ លូតលេចបុប្ផា ។ ឈើផ្កាភាំងព្យាយ ដុះជិតពុំផ្ងាយ តាមដងមាគា ម្ទិរតន្ទនស្រី ចំប៉ុចម្បាំ រំដួលគ្លាំងផ្ការ ខ្ចីងខ្ចម្ពមាលតី ។ ធត្រែតឈូកវ័ត្ត ច្បាសែតច្រេនក្តាត់ ស្រឡែតស្រឡី សារិយុតមហាហង់ ប្រយង្គកាកី កាកែសពីសី រំចេកនៃរ្យ ។ ឈើឈរធំ ។ ដើមដុះជាដុំ ជាម្លប់ដង្ហែ ឱដចតឱដឈប់ បើយប់តាមតែ ដេកដោយសព្វកែ មិនព្រួយរោសផាត់ ។ ដ៏កបស្នើរេធង ស្មៅស្មើរលើង ស្មុតដូចគេខាត់ មិនស្អិចមិនស្អុះ ដេកចុះលក់ផ្ងាត់ មិនគិតខ្លាចសត្វ សាហាវពាធ ។ ព្រះពាយរំតើយ ត្រសៀកល្អែល្អើយ មះនារមា ជាឱតម្រេក ចិត្តត្រេកគ្រប់គ្នា មានឱតគ្នាស្រះស្រង់រៀងៗ ។ ឈូកវ័ត្តតេញាសស ផ្ការីកដេរជាស ក្រអូបចាំនៅ ត្រីត្រាច់ហែហមហែល ក្រាស់ក្រែលមកៗ កន្ធឱតឱតជ្រៅ ត្រែងនោង ។ សេនាលពាល ត្រេកត្រេះត្រអាល ចាប់ភ្ញៀនរុក្ខជាតិ ព័ជោរស្ពប់ស្ពល់ ដោយខ្យល់មន្ទរត សប្បាយក្មេចញាតិ ក្មេចបុត្រកនិយា ។ ព្រះបាទបតិត្រ ធិកជង្រឹងប្ញទ្ធ ស្តេចលើកយោធា ព្រះចន្ទមវន្ស ទ្រើសទ្រង់សំការ អ្នកនាំមាគា ព្រះចិតាៗ ។ ស្តេចយាងយូរថ្ងៃ ច្រាំជណ្តើរថ្ងៃ ខៀបឱលំនៅ អាស្រមមាគា ក្សត្រគ្រាចមៅ ចាប្រម៉ង់ឱតៅ. ចម្ងាយប្រមាណ ។ ព័ភស្រមបទ ចានមួយយោជន៍តត ដល់ឱតក្សត្រ

ក្សត្ត ព្រះបទុមវង្ស ស្តេចទ្រង់គិតឆ្ងាន់ បញ្ជាប់ទាហាន ទៀបទីតង្គ្គ ។
ស្រះស្រែន់ធំទ្វាយ ប្រវែងចម្ងាយ មួយយោជន៍តណា អស់ពល
រៀបឈប់ ដោយម្ចប់ព្រឹក្សា រៀបបរិភោគ្គា ដោយតួទៃ ។ ព្រះ
បទុមវង្ស ស្តេចឡើងលាអង្គ ប៉ិតាដៀស្ដង្ឃ ទៅប្រាប់មាតា ទឹង
មហាវសី កុំឲ្យកិតក័យ ទឹងពលសេនា ។ ព្រះប៉ិតាស្តាប់ បុត្រណែ
ប្រញាប់ ទៅឯមាតា ហើយទូលសារស័ព្ទ ជ្រាបដោយប្រការ
ស្តេចបើកបុត្រា ទៅតាមបំណង ។ កុមារវ័យ ឡើងតង់ប្រើស
មាស យាត្រាត្រាប់ត្រង់ ដល់ទីមាតា កុមារនុទអង្គ លុតលើកកំបង់ បង្គំ
មាតា ។ ទូលសព្វសេចក្តី នាងអវតប៉ ឥតឯឧបមា នាងនាំបុត្រទៅ
គាល់ហ្លួងព្រះមហា ឥសីស៊ីលា ទូលសព្វសេចក្តី ។ ឯាតឲ្យតព្រះបាទ
វិមលនរោជ ជាព្រះស្វាមី ស្តេចលើកយោធា សេនាមន្ត្រី ឈប់
ទៅស្រះស្រី នាទីបព្វតា ។ មកទូលខ្ញុំ ទៅបុរីរម្យ រីទេហ៍រដ្ឋា ខ្ញុំលា
ព្រះអង្គ សូមទ្រង់មេត្តា ទៅសួរព្រះមហា ក្សត្រជាស្វាមី ។ ឥសីបានស្តាប់
នាងទូលគួរគាប់ ទើបព្រះឥសី ថ្វាយព្រះពរថា បើមហាក្សត្រី ទៅសួរ
ស្វាមី អត្ថាភាពអរ ។ នាងស្តាប់ឥសី បើកស្រួលក្សត្រី នាំបុត្រចេញចរ
ទៅទូលក្សត្រ ចក្រពត្តិបវរ ប្រើសមាសសោតចរ តាមក្រោយបុត្រក្លា ។
ក្សត្រីវរវង្ស នាងយាងតីរអង្គ ទឹងពជបុត្រា ដល់ទៀបពួកពល សកល

សេនា ទើបមហាកប្បត្រា ខតយល់ឥតឮយ ។ ត្រាស់ច្រើសារវៃដ ស្រីផ្ការ
ឆាប់វៃ រួតរត់ប្រញាយ ខលួមហេសី កប្បត្រាឆោមឆាយ ស្ទុះស្ទុំទាំង
ខ្លាយ ខលួលធីតា ។ ខ្លះថ្វាយទឹកអប់ ឲ្យនាងលាយលុប លាបលាង
កត្ត្រា ខ្លះថ្វាយផ្កាក្រង កម្រងរចនា ខ្លះថ្វាយតន្ទា ត្រៃស្រីដួងចន្ទ ។
នាងស្រង់ទឹកអប់ បែតន្ទខលាយឡប់ ឯស្រីកំណាន់ ខ្លះដុសកាយា
កត្ត្រាសោភ័ណ ថ្វាដូចដួងចន្ទ ឋូណាមីចាំងវែង ។ អត់យោងខុន
ណាង យកគ្រឿងសំអាង រចនាទិព្វវែង រឿបស្អាងមហេសី ប្រឹម
ប្រឹមចាំញ្ជង លួលួះឯកឯង ឯកអគ្គនារី ។ កត្ត្រាផ្ទរផង់ ស្មើរលង់
រលើងធៅ ចំព្រងព្រះខាត់ រូបរ័ត្នមណី នេត្រាចាំងខ្ញី ដូចនីលរតនា ។
ព្រះស្ទុំសំអាង ស្អាងរូបហែនាង ឡើងគាល់ក្សត្រា នាងថ្វាយចង្កឹ
ប្រណម្យចេស្តា ហើយនាងធីតា តង់ទីគួរសម ។ ស្តេចខតយល់ព្រះ
មហេសីល្អល្អះ ដួងកក្តីស័ក្តិសម តើតឆាយលើសលន់ ល្អាសល្អន់រម្យ៉ែ
ឡើងហែសួនសម សមស័ក្តិលក្ខណា ។ ចំឡែកលើសមុន ជារយ
ពាន់គុណ ព្រោះសោយផលា ថ្នាំទិព្វថ្លៃធ្ងន់ វិប្រធ្វាណធីតា ជា
ក្រមុំណា ល្អល្អះគួរស្រែង ។ ស្តេចរែងបេតី ស្រឡាញ់មហេសី ពេក
រៃក្រលើសលែង ដួងកត្ត្រពុំធ្លា សោភាចាំញ្ជង រស្មីសូរ្យសែង សួស្តី
សមកាយា ។ (នៅមានត)

រឿងព្រេងនឹងរឿងបុរាណជាប់ទក់ទងមកក្នុងសម័យ

លោក ភ័ក-ប៊ុក ប្រែរៀបរៀង

(តទៅ)

នាងព្រាយក៏សួរទៅលោកអ័តូសូជាថា «ម្តេចក៏លោកមិនសម្រាន្តឲ្យលក់ដូចជាហានឯទៀត, ខ្ញុំធ្វើឈាស់ ? ។ អ្វីនេះ, ឈាមហូរចេញពីក្បាលជង្គង់អ្នក ។

លោកអ័តូសូជា កំតបទៅនាងព្រាយថា: «ខ្ញុំធ្វើឲ្យរបួសក្បាលជង្គង់ដោយចិត្តស្មោះស្ម័គ្រ ដើម្បីឲ្យសេចក្តីឈឺចាប់ដោយរបួសនោះធ្វើឲ្យខ្ញុំស្តាប់នៅចេកក្អែកជានិច្ច, មិនឲ្យខ្ញុំដេកលក់ទៅបាន» ។

នាងព្រាយក៏ឆ្លើយតបទៅលោកអ័តូសូជាថា «ខ្ញុំគួរសរសើរចំពោះអ្នកពន់ពេក; អ្នកឯងត្រូវតែគេកោតសរសើរគេញាលក្តណា:» ។

លោកអ័តូសូជា កំតបទៅវិញថា: «របួសនេះដូចជាស្នាមអុះប៉ុណ្ណោះ មិនត្រូវនិយាយទេ ! ខ្ញុំនឹងអាចបំពេញការណ៍យកចិត្តឲ្យបានប្រសើរជាងនេះទៅទៀត, បើចៅហ្វាយនាយលោកត្រូវការខ្ញុំ" ។

នាងព្រាយក៏ឆ្លើយមកវិញថា: «អ្នកឯងជាមាហាន គួរជាទីជ្ឈន្ទនៈតែដល់មាហានទាំងឡាយ ហើយជាអ្នកបម្រើការប្រកបដោយសុក្រិតភាព» ។

នាងព្រាយកំញ្ជាញ់មកៅកលោកអ័គ្គូសូជា យ៉ាងស្រស់ស្រាយ សប្បាយក្នុងចិត្តា ទំកមុខរកសមជួបប្តូរត្រព្រះសុរិយោគលបុត្តណ្ហសម័យ, ចិត្តត្រឹត្រួចកបស្នេហាគួរជ្រាថ្នាត់ស្ងួយ រួបគោមនាយស្រស់ប្រឹមប្រើយ គួរសុះកៅនុចកែវថ្លើមថ្លៃ ។

នាងព្រាយកំគិតថា "អញធ្វើឲ្យលោកអ័គ្គូសូជាជាក់ចិត្តកៅកាន់សេចក្តីស្នេហា ហើយនាងងាកមុខកៅកព្រះអង្គម្ចាស់ ទឹកក្នុងចិត្តថា: "តើព្រះអង្គយាំងណាកៅ យប់នេះ" នាងព្រាយកំទុកកាយបេះខ្លួនកៅលើព្រះអង្គម្ចាស់ ។

លោក អ័គ្គូសូជា ខប់ខល់បានឮវាសេចក្តីស្នេហាចំពោះនាងព្រាយ, លោកកំក្រោកឡើងមកឃាត់ហាមនាងព្រាយ កុំឲ្យតាល់ព្រះអង្គម្ចាស់បាន ។ នាងព្រាយអស់តំរេះកំចេញពីត្រឡាព្រះបន្ទំព្រះអង្គម្ចាស់កៅខាងក្រៅជាត់កៅ ។

លុះដល់តេលព្រឹក ពួកមហានដែលយាមព្រះអង្គម្ចាស់ក្បាត់ពីនិទ្រាទាំងអស់គ្នាឡើង មានសេចក្តីកោតសរសើរមហានអ័គ្គូសូជា ដែលស្ងិតនៅយាមតេញលក្ខណៈឥតបានដេកសោះឡើយ ដោយប្រើមធ្យាបាយថ្មែក តែធ្វើរបួសក្បាលជង្គង់នោះឯង, ហើយខ្លួនមានការអៀនអន់ស្រពន់ចិត្តដោយមិនបានប្រើខ្លួរមធ្យាបាយបែបនេះ ។

លោកអ័តូសូជា កំពុងទៅតាន់តេហង្ហានលោកអ័សាហាយ៉ាប៊ុយ ហ្សេន ទីប្រឹក្សាព្រះអង្គម្ចាស់ហើយ កំដរបលោកអំពីរឿងកាតាយប់ម៉ាញ ឲ្យលោកជ្រាបសព្វគ្រប់ ។ លោកទីប្រឹក្សាក៏ថ្លែងនូវសេចក្តីសរសើរ ចំពោះតាហានអ័តូសូជា ។ លោកទីប្រឹក្សាគិតក្នុងចិត្តថា ថ្ងៃនេះអញមុខ ជាបានខួលរង្វាន់ដ៏ជាទីគាប់ចិត្ត ដោយតាយប់ម៉ាញ នាងព្រាយមិនបានទៅជិតព្រះអង្គម្ចាស់ ដោយតាហានអ័តូសូជាហាមឃាត់ ហើយព្រះអង្គម្ចាស់ទ្រង់ផ្ទំលក់ស្កប់ស្កល់, ទ្រង់តែនទ្បើងចាកសុបិនា មានព្រះកាយពេលសុខស្រួលតន់ពេក ។

ដល់ពេលយប់ស្អែក តាហានអ័តូសូជា ក៏ត្រូវចាត់ឲ្យយាមទៀត ។ ដល់ពេលអធ្រាត្រស្ងាត់, ទ្វារកើរបើក, ស្រាប់តែមានតារូបនោមលោមពណ៌ស្រស់ប្រិមប្រិយ ចូលមក (មានគេជ្រាប់លោកអ័តូសូជាថា: នារីនោះ មានតាមឈ្មោះថា ព្រះនាងអ្លូតូយ៉ូ) ។

លោកអ័តូសូជា បានឃើញនាងព្រាយដែលខ្លួនសំគាល់ថា ព្រះនាងអ្លូតូយ៉ូ ចូលទៅកន្លែងក្រឡាព្រះបន្ទំព្រះអង្គ ។ តែដល់នាងឃើញតាហានអ័តូសូជា ស្ទុះមកឃាត់ហាមប្រាមនាងមិនឲ្យចូល, ក៏នាងថយចេញទៅក្រៅវិញទៅ, ឥតមានប៉ះពាល់ដល់ព្រះកាយព្រះអង្គឡើយ ។

ដល់យប់ក្រោយទៀត ។ មកនាងព្រាយលែងហ៊ានមកកន្លែងក្រឡាព្រះបន្ទំ

ព្រះអង្គម្ចាស់ ។ កំទ្រង់ដួលក់សុខព្រះកាយសប្បាយព្រះរាជហឫទ័យ ។ មួយទៀត អាហ៊ានតាំងខ្លាយកំលែងជេកលក់តទៅទៀត ។ ព្រះអង្គម្ចាស់ ទ្រង់លែងមានព្រះរាជហឫទ័យរសាប់រសល់ដូចយប់មុន ។ ព្រះសុខភាព ព្រះអង្គ កំចម្រើនស្រួលតាមលំដាប់ ។

តាហានអ៊ីតូសូជា ត្រូវបានព្រះអង្គម្ចាស់ទ្រង់ប្រទានឲ្យឡើងហានខ្ពស់ក្តីជាខាយតាហាន ត្រមាំងទ្រង់បំពេញព្រះរាជអំណាចដ៏មួយកន្លែងជាកម្មសិទ្ធិរបស់តាហាននេះ ដោយតាហានអ៊ីតូសូជា មានគុណូបការៈដ៏ធ្ងន់ចំពោះទ្រង់ ។

តែលោកអ៊ីតូសូជាយល់ថា ខ្លួនមិនទាន់បានបំពេញការណ៍យកឈ្នះជាស្ថាពរនៅឡើយ ។ លោកក៏បានអញ្ជើញ ទៅជួបនឹងលោកទីប្រឹក្សាអ៊ីសាហាយ៉ាប៊ុយហ្សេន ក៏ដំណរលោកថា :

"កល្យាណមិត្ត នឹងអ្នកដែលមានស្នាមកក្តៃនៃព្រះអង្គ នឹងមិនអាចទុកចិត្តបានថា ទ្រង់នឹងផុតពីភយន្តរាយនោះបានឡើយ" ។

លោកទីប្រឹក្សាប៊ុយហ្សេន ក៏យល់ព្រមតាមយោបល់លោក អ៊ីតូសូជា ។ ក៏បន្តែមតទៅទៀតថា :

"ព្រះអង្គម្ចាស់ទ្រង់ប្រហែលជាត្រូវអំពើគេ ។ បើតាហានដែលយាមព្រះអង្គចេះតែជេកលក់ ប្រហែលជាមានហេតុអ្វីមួយ ដែលធ្វើស្ងាត់

តាមទុស្សឲ្យទៅជាដូច្នោះបាន ។

លោកប៊ុយហ្សេន កំតប់ទៅលោកអ័ត្តូស្ហាថា « តើពិតឬក្រែកដូចលោកថា » ។

លោកអ័ត្តូស្ហា កំពោលតទៅទៀតថា « ក្នុងពេលដែលខ្ញុំបានយាមល្បាតព្រះអង្គម្ចាស់, មានតែនារីម្នាក់ទេ ដែលចូលទៅក្នុងក្រឡាព្រះបន្ទំទ្រង់ គឺព្រះនាងអូតូយ៉ូ(១) ។ តាលណាព្រះនាងនេះលែងយាងទៅតាន់ក្រឡាព្រះបន្ទំព្រះអង្គ ។ កំប្លែងតំស្រួល លែងតានតាកឬកិរិយារសាប់រសល់ដូចមុនៗទៀត ។ ខ្ញុំបានមានសេចក្តីត្រួយចារម្ភជាខ្លាំង ដោយខ្ញុំបានចាត់ប្រតាន់លើនារី ដែលទ្រង់សព្វព្រះហឫទ័យ ។ តែខ្ញុំបានគ្មានអ្នកណាសង្ស័យ ក្រៅពីព្រះនាងនេះទេ ។ តួកត្រាយតាមដែលជាហេតុនាំឲ្យកើតតាការពេត ប្លែកពីជម្មតាច់ពោះព្រះអង្គ គឺនាងនេះឯង ។

លោកបីត្រីក្សាអ័សហាយ៉ាប៊ុយហ្សេន កំពោលតាក្សតិច ។ ថា

๑- យោបលអ្នកប្រែលោកអ័ត្តូស្ហាមិនបានដឹងថា: ឬាខ្មៅនោះពិតឃាតព្រះនាងអូតូយ៉ូយកទៅកប់ក្នុងទីស្ងាត់ទៅហើយ ហើយវាប្រែក្រឡាខ្លួនវាជាព្រះនាងអូតូយ៉ូ ។ ឯឬាខ្មៅ-ត្រឹងភាសាបារាំងថា: chat, vampire ត្រូវយល់ថា vampire ប្រែជាភាសាខ្មែរថាត្រឹង ជាពួកសត្វរន្តិចរឬកត្រឹចរដែលរកស៊ីតែពេលយប់, ជាចម្ងាបក្សី (chéiroptéres) ដែលមានស្បែកខ្លួនរែងទៅជាស្លាប, ហើយតែងដណ្តើរឈាមសត្វនឹងមនុស្សដែលដេកលក់ ។ ព្រោះហេតុនេះ នារីនេះមានរូបរាងជាឬាខ្មៅ តែមានលក្ខណៈជាបក្សាត្រឹង គឺចេះដណ្តើរឈាមធ្វើឲ្យមនុស្សថមថយកំលាំង ។

"ខ្ញុំជឿជាក់ណាស់ដែរ . . . ខ្ញុំខ្លាចណាស់ចំពោះរឿងនេះ ។ មិនអីទេ លោក ចាំខ្ញុំសួរយោបល់លោកទីប្រឹក្សាឯទៀតសិន, ចូរលោកអញ្ជើញមកជួបនឹងខ្ញុំម្តងទៀត, ពេលស្អែក ។

ដល់ពេលស្អែក,. លោកទីប្រឹក្សាអ័ាសាហាយ៉ាប៊ុយហ្សេន កំប្រាប់លោកអ័តូស្សាថា "លោកបានសួរដោយសម្ងាត់ចំពោះពួកលោកទីប្រឹក្សាឯទៀត។ គំយល់ស្របនឹងយោបល់លោកនឹងខ្ញុំហើយ, គឺព្រះនាងអូតូយ៉ូនេះឯង ជាបុព្វហេតុនៃអាការរោគព្រះអង្គម្ចាស់ ។

លោកអ័តូស្សាគំពោលថា "ដើម្បីនឹងធ្វើឲ្យព្រះអង្គម្ចាស់មានព្រះសុខភាពដ៏ពេញលេញឡើងវិញ ត្រូវតែសម្ងាប់មេត្រាយនោះចេញ ។ សូមលោកទីប្រឹក្សាមេត្តាអនុញ្ញាតឲ្យខ្ញុំចាត់សម្ងាប់មេត្រាយនេះចុះ ខ្ញុំចាត់នឹងសម្ងាប់ភ្លាម កន្លះពេលថ្ងៃនេះ, សូមតែព្រះតេជព្រះគុណ ចាត់ឲ្យជាក់ខាហានយាម ៨ នាក់ចំពីមុខទ្វារបន្ទប់ក្រាំ កុំឲ្យវារតរួច ។

ដល់សាយណ្ហសម័យ, លោកអ័តូស្សា កំបានទូលព្រះនាងអូតូយ៉ូថា លោកនឹងយកប្រអប់តូចមួយ ដែលមានព្រះសារលិខិតព្រះអង្គម្ចាស់មកថ្វាយព្រះនាង ។ គេក៏អនុញ្ញាតឲ្យលោកអ័តូស្សា ចូលទៅជួបនឹងព្រះនាងអូតូយ៉ូ ។

ព្រះនាងអូតូយ៉ូទ្រង់មានបន្ទូលថា: ចូរលោកឲ្យប្រអប់នោះមកខ្ញុំ . . .

ខ្ញុំសូមឲ្យតែព្រះអង្គម្ចាស់ជាទីស្នេហាចេស់ខ្ញុំ កុំឲ្យមានអាការពេតតទៅ
ទៀត . . . ។

លោកអ៊ីតូសូជា តបទៅព្រះនាងអូតូយ៉ូថា "ព្រះអង្គម្ចាស់ឥត
មានពេតាពាធអ្វីសោះឡើយ . . .តែសូមព្រះនាងទ្រង់ទតព្រះសារលិខិត
ព្រះអង្គ រួចឲ្យព្រះនាងធ្វើយទៅព្រះអង្គឲ្យឆាប់" ។

គឺនពេលដែលព្រះនាងអូតូយ៉ូកំពុងបើកប្រអប់នោះ លោកអ៊ីតូសូជា តិ
ហូតជាវគ្រែភ្លាម ។ តែព្រះនាងអូតូយ៉ូក៏តន្ត្រាក់ឃើញព្រះខ័នមានដងស្រោប
មាស ហើយក៏តយុទ្ធជាមួយនឹងលោកអ៊ីតូសូជា ។ ព្រះនាងមានបន្ទូល
ខ្ញាំងៗថា "ម្តេចឯងហ៊ានតយុទ្ធនឹងស្ត្រីកូនព្រះបរមកជកំធ ហើយដាស្តីសំ
ណប់ព្រះអង្គម្ចាស់ថែមទៀត អញនឹងដេញអាឯងចេញពីព្រះបរមកជកំធ ។

លោកអ៊ីតូសូជា តំយកជាវគៀសព្រះខ័នព្រះនាងភ្លាត់ហើយក៏
កាត់ក្បាលព្រះនាងអូតូយ៉ូបាន ។

ស្រាប់តែនៅលើផែនដី, មិនមែនជាសាកសពស្ត្រីប្រែទៅជាសាក
សពឆ្មាឡើង ដែលមានក្បាលជាប់តំរួនទៅវិញ, ឆ្មាឡើ-ជ្រើនដែល
រាល់យប់ រាមកជញ្ជក់ព្រះលោហិតព្រះអង្គម្ចាស់ណាចេស្តាមាំ ហើយ
មានតែលោកអ៊ីតូសូជាទេ ដែលជាអ្នកធ្វើឲ្យព្រះសុខភាព ព្រះអង្គបាន
ស្រួលដូចដើមវិញ ។

អធិប្បាយសុភាសិត

ទំពក់វាទៅ ទើបល្អៀវាទ្រុះ

លោក ស្តើង-ឆួរ រៀបរៀង

លោក ទត្តមប្រជា ចាប-តាន ពិនិត្យ

សេចក្តីអធិប្បាយ

ដើម្បីញ៉ាំងចរិយានៃពួកជនណាដែលខ្ជិលច្រអូស ក្នុងកិច្ចសិក្សារៀនសូត្រ ក្នុងការងារសព្វសារពើ, កុំឲ្យដេកចាំព្រួងវាសនាជូនផលមកឲ្យនោះ ចាស់ទុំបរមបុពណ ចានចង់ក្រងជាភាសិតមួយបទខុទ្ទកក្រើនរលឹកជនពាលនោះថា: "ទំពក់វាទៅ ទើបល្អៀវាទ្រុះ" ។

តាមអត្ថានុរូប ភាសិតនេះ ចានប្រាប់ន័យយ៉ាងជាក់ច្បាស់មកយើងរួចស្រេចទៅហើយ គឺផ្លែល្អៀដែលជាប់នៅនឹងសណ្តង់នៅឡើយមិនអាចនឹងជ្រុះមកចូលក្នុងកញ្ជើរបស់យើង នៅពេលដែលយើងគ្រាន់តែហាមាត់និយាយថា: ចង់ចានផ្លែល្អៀ ។ នោះទេ ។ ដូច្នេះ, បើយើងចង់ចរកោតផ្លែល្អៀ ត្រូវតែយើងយកទំពក់ទៅថ្កក់បេះវាទើបចាន ចើពុំនោះសោតទេ ច្បាស់ជាយើងអង្គុយលេចធ្មេញមាត់ផ្អូស ។ ពិតប្រាកដ ។

តាមអត្ថប្បដិរូបវិញ ភាសិតនេះមានន័យថា: បើយើងចង់ចានផល

អ្វីទំមួយ ។ ដូចជាប្រាថ្នាព្រឹត្យសម្បត្តិឲ្យបានបរិបូណ៌ហូរហៀរ ដើម្បីធ្វើជាសេដ្ឋីគហបតីក្តី ឬប្រាថ្នាវិជ្ជាជ្រៅជ្រះ ដើម្បីបានធ្វើជាមន្ត្រីធំដុំទីឆ្ងាគេក្តី, យើងមិនត្រូវដេកចាំព្រេងវាសនា ឬ បន់ស្រន់បួងសួងព្រះអាទិទេពឲ្យមកជួយយើងនោះទេ, យើងត្រូវខំខ្នះខ្នែងប្រឹកម្ចាំងកាយ ចិត្ត-បញ្ញា ព្យាយាមរៀនសូត្រ, ធ្វើការងារសេពូសារតើតាំងអស់ ដើម្បីផ្គត់យកផលដែលយើងប្រាថ្នានោះ ។ ។ បើពុំដូច្នោះទេ ផលនោះមិនអាចផ្តល់ ហុចផលប្រយោជន៍ឲ្យយើងបានឡើយ ។ សេចក្តីនេះសមដូចសុភាសិតសំស្ក្រឹតមួយបទថា:

ការងារតែងសម្រេចដោយព្យាយាម
ពុំមែនចានតាមមនោរថា
ម្រឹគពុំដែលចូលក្នុងមាត់សីហា
កាំពុងនិទ្រាលង់លក់នោះឡើយ ។

សេចក្តីថា ចំណេះវិជ្ជា ការងារសេពូសារតើតាំងអស់សម្រេចបានដោយសេចក្តីព្យាយាមធ្វើ, ព្យាយាមកេ, ព្យាយាមសិក្សារៀនសូត្រតែប៉ុណ្ណោះ, មិនមែនយើងដេកចាំ ឲ្យព្រឹត្យសម្បត្តិចំណេះវិជ្ជាហូរចូល ដោយឥតបានព្យាយាមកេ, ព្យាយាមសង្វែសង្វៃ ព្យាយាមរៀនសូត្រនោះសោះឡើយ ។ បើប្រាសចាកសេចក្តីព្យាយាមអស់ហើយ តើចំណេះវិជ្ជា

ទ្រព្យសម្បត្តិ ខំធ្វើសម្រេចឲ្យយើងប្រើប្រាស់រួចម្តេចបាន ? ព្រោះហេតុ
ហ្នឹង បានជាបុរាណាចារ្យ លោកបានចងក្រងជាពាក្យប្រៀនប្រដៅមាន
ច្រើនបែបច្រើនយ៉ាង ខុតជាស់តែនិយាយក្រើនរំលឹកកូនប្រៀបប្រាយ ។ ថាកុំឲ្យ
ខ្ជិលច្រអូស ឲ្យខំរកស៊ី ឲ្យខំរៀនសូត្រទើបតែខ្លួនរួចអំពីក្រ ទៅជាមាន,
អំពីល្ងង់ខ្លៅ ទៅជាអ្នកចេះដឹងជ្រៅជ្រះ, អំពីពាល ទៅជាបណ្ឌិត,
អំពីហ៊ានតាព ទៅជាទត្តមតាព; អំពីឥសតាព ទៅជាគុជិសុតាពបាន ។

ឧបាហារណ៍:

មានសេចក្តីដំណាលថា: មានត្រកូលមួយមានកូនប្រុសម្នាក់ ជា
ត្រកូលខ័ណ្ឌក្រយ៉ាន់វែកលែង ។ កុងកាលកុមារជាបុត្ត មានវ័យ
វ័ន្តនោការចំរើនរៀង មាតាបិតាក៏បានទៅស្តីដណ្តឹងនាងកុមារីកាម្នាក់
ឲ្យជាភរិយា ។ ត្រកូលតាំងពីរនេះ បានរៀបអាពាហ៍ពិពាហ៍មង្គលការ
បុត្តធីតារួចស្រេចហើយ កំគ្មានបានចែកគ្រឹមតិកអ្វីជាសំខាន់ ដើម្បីឲ្យ
បុត្តធីតាប្រកបអាជីវកម្ម តាមសភាពជាអ្នកស្រុកសោះឡើយ ។
មាតាបិតាខាងស្វាមីបានចែកឲ្យតែ ១ ផ្ទះ១, មាតាបិតាខាងភរិយាចែក
ឲ្យស្វា ១ ប៉ុណ្ណោះ ។ គូស្វាមីភរិយា លំបាកវេទនា កុងចិត្តតើតទុក្ខ
ក្រៀមក្រំយ៉ាន់វែកលែង មិនដឹងគិតរកវេអ្វីចញ្ចឹមជីវិតបាន ។

ថ្ងៃមួយ បានប្រឹក្សាគ្នាថា: បើយើងនៅកុងតំបន់នេះតទៅទៀត យើញ

ជារឹតតែលំបាកឡើង ព្រោះយើងគ្មានកែ្ដមតិតអ្វីទាំងប្រកបរបរចិញ្ចឹម ដំរៃសោះ ។ ដូចេ្នះ, យើងគិតបេញ្ជៀកទៅរកទីកន្លែងណាមួយ ដើម្បីប្រកបរបរកសិកម្មតាមសម្មាអាជីព ។ គិតស្រេចហើយ កំស្រុះស្រួលមូលមតិគ្នារៀបចំអីវ៉ាន់រៀបជាសម្ពាយរៀបចេញទៅ ។ មុនទាំងចេញទៅ បុរសប្តីបានទឹកដល់គុណព្រះតេនដៃគ្រែ និយាយទាំងភាំងថា: «បើទីកន្លែងណាដែលគ្រជាក់ត្រជុំ កេសុីទៅមានបានកើតកាលវាលគួម្ត, បានសេចក្តីសុខចំរើនោះ សូមឲ្យតែដែលជាទំមិត្តនេះ ឈប់ទៅត្រង់ទីនោះ" ហើយលែងភាំងនោះទៅ ។ បុរសប្តីបណ្តើរដែ្ត ទាំងគិយោចិស្សាដើរតាមខាងក្រោយតែដែលលែងទៅមុខ ។ ពេលចេះតែចោលទៅ។ កាត់វាលចូលដែ្ត លេចដែ្តចូលវាល សែនឆ្ងាយជាប់ស្រយោល លុះទៅដល់កន្លែងមួយ នាមាត់ស្ទឹង ដែលមានទឹកមានស្មៅគ្រប់គ្រាន់ ជាទីមានដែ្តឈើដុះស្រោងស្រឹងស្ងាត់ជ្រងំ កណ្តាលអារណ្យប្រទេស ពពែក៏ឈប់ឆឹកទឹក ស៊ីស្មៅតាមស្រួល ។ បុរសប្តីប្រពន្ធក៏សន្ទិដ្ឋានថា «ទីដែ្តនេះហើយ ជាទីមានសុភមង្គលល្អ» ព្រោះពពែបានឈប់នៅទីនេះ ។

បណ្តាប្តីប្រពន្ធទាំងពីរនាក់នេះ, ប្តីស្រឡាញ់ពពែខ្លាំងណែ្ន, ប្រពន្ធស្រឡាញ់ស្វាណាស់ ព្រោះសត្វទាំងនេះសុទ្ធតែកែ្ដមតិតរបស់ខ្លួន ។ ។ ទាំងពីរនាក់ កំដាក់សម្ពាយចងស្វាស្រួលបួលហើយ, ប្តីក៏ទៅកាប់ឈើ

ឆ្ពាំព្រៃពន្លដ៏ ដើម្បីនឹងដាំស្រូវយកផល ។ ឈើណាដែលល្អ ។ គ្រាន់
បើ តែរើសដញ្ជួនយកមកធ្វើខ្លួបឆ្អឹង ជាជម្រកនៅសំណាក់ភ័ក្តអស្រ័យ
រថស់ខ្លួនកណ្តាលព្រៃនោះ ។ ប្រពន្ធនៅចាំខ្លួមដាំថ្ងាយ ថោស
ប្រាសសំអាតទីលំនៅឲ្យបានស្អាតល្អ ។ រៀងរាល់ថ្ងៃ, ត្រួសារថ្មីនេះឥត
មានទុកកាយរបស់ខ្លួន ដែលនៅកំពុងពេញកម្លាំងពលំឲ្យនៅទំនេរឥត
ប្រយោជន៍សោះឡើយ ។ ប្តីនៅស្រែ ចាចទឹកជាក់ស្រូវ, ប្រពន្ធនៅផ្ទះ
រៀបចំទីលំនៅឲ្យបានប្រសើរ ។ គោះបីខ្លួមតូចមួយរបស់នាង ដែល
សង់ឡើងអំពីកូនឈើប្រក់ស្លឹកគ្មានត នៅកណ្តាលព្រៃផ្សេងៗនោះក៏ដោយ
ក៏នាងចេះតែចៃលៃលកលៀបចំឲ្យគាល់តែខ្លួមនោះ ក្រាយទៅជាគ្រឹស្ថាន
មួយយ៉ាងប្រសើរ គួរជាទីគាតពិសរមិលមើលនៃអ្នកផងទាំងពួង ។ អ្នក
ទាំងពីរស្រឡាញ់គ្នាណាស់, ថ្លើមម្នាក់ ។ ទំនើងការពេញ ។ មួយថ្ងៃ, មាន
ការនឿយហត់យ៉ាងណាក៏ដោយ ក៏នៅតែមានសេចក្តីស្រស់ស្រាយ
រួសពយញញឹមញញែមរកគ្នាជានិច្ច ឥតចេះប្រចែងប្រចំណូនិយាយគំរោះ
គំរើយ ទាស់ចៃដន្យខ្លួនគំនិតគ្នាសោះឡើយ ។

មានពត្រីមួយ ជាពត្រីអតមន្តិលអស្ចារ្យ; ក្រោយដែលគាត់ធ្វើ
ការនឿយហត់អស់កម្លាំងពីពេលថ្ងៃ គាត់ក៏និទ្រាលង់លក់ស្កប់ស្កល់ឥត
ភម្រើក ។ យប់នោះមានសត្វខ្លាចង្រៃមកចាប់យកពពែរបស់គាត់ដែល

វាដេកនៅក្បែរខ្លួន យកទៅស៊ីជាអាហារបស់វាបាត់ទៅ ។ គាត់ភ្ញាក់ឡើងរកតែមិនឃើញ មានសេចក្តីតក្កមាន់ពេក ។ គាត់ទំដើរកេសព្វទីកន្លែងដែលតែធ្លាប់កេស៊ីរាល់ថ្ងៃ ដើរហួតទៅដល់មាត់ស្ទឹងដែលតែធ្លាប់ផឹកទឹកក៏មិនឃើញ ស្រាប់តែឃើញស្នាមដើងវាយ៉ាងធំ ។ ទៅត្រង់កន្លែងតែដេក ។ គាត់ដឹងច្បាស់ថា ពិតជាខ្លាចាប់យកទៅស៊ីហើយ ។ ដូច្នេះ, គាត់ក៏មកនិយាយប្រាប់ប្រពន្ធថា "តែយើងពិតជាខ្លាចាប់យកទៅស៊ី, ព្រោះខ្ញុំឃើញស្នាមដើងវាធំ ។ ទៅត្រង់កន្លែងតែដេក បើប្រសិនណាជាយើងមិនកេងបាយកលល្បាយមចាប់សម្លាប់វាឲ្យបានទេ, ថ្ងៃក្រោយវាចាប់ស៊ីនឹងស្លាបរបស់យើង រហូតដល់ចាប់យើងគាំងពីនាក់យកទៅស៊ីជាអាហារបស់វាទៀតមិនខាន" ។ មួយរំពេចនោះ, គាត់ក៏ទៅកាប់ឈើយកមកធ្វើអង្គប់ ដើម្បីជាកំភ្លុំប្រហារដើរតែវាឲ្យបាន ។ លុះធ្វើរួចស្រេចក៏គិតថា« បានអ្វីហ៎ ! ទឹងយកធ្វើនុយឲ្យខ្លាវាបូល, បើយកន្លែងទៅឃើញថាគាណិតវាខ្លាំងពេក ព្រោះតែនេះជាទីស្រឡាញ់ ហើយជាកន្លែមតែវានៅសល់តែមួយនេះផង ។ គាត់ក៏ទៅនិយាយតង្វាល់ជាមួយភរិយាថា« អូនជាទីស្រឡាញ់ ! ឥឡូវបងធ្វើអង្គប់រួចស្រេចហើយ, ទៅខ្វះតែនុយទៀតប៉ុណ្ណោះ, ដូច្នេះ សូមអូនឲ្យស្នាមកបង ។ ទឹងយកទៅធ្វើនុយឲ្យខ្លាវាបូល, បើអូនទុកស្លានេះទៅក៏ពុំសូវបានផលអ្វីដែរ" ។ ភោះបី

ថ្ពើអង្វរលួងលោមដោយពាក្យផ្អែមល្ហែមយ៉ាងណា កំប្រពន្ធមិនត្រមង់ឲ្យ
សោះ ។ គាត់កំគាត់សេចក្តីអាណិតចំពោះផ្កែ, ចាប់ផ្កែយកមកនុបដើម
ហើយនិយាយទាំងអកអួលថា "ឱ! ផ្កែជាទីស្រឡាញ់បេស់អញ, អញ
ស្រឡាញ់ឯងណាស់,អញគ្មានចង់ឲ្យឯងឃ្លាតចេញអំពីបេះដូងបេស់អញ
ទេ, តែពេលនេះ ដើម្បីឯងមិនអាណិតជីវិតអញផង អញត្រូវតែស្លាប់,
ព្រោះសត្វខ្លាវាចេះតែមកយាយីជីវិតអញរាល់ថ្ងៃពុំខាន, ដូច្នេះអញសុំយក
ឯងទៅចងនៅក្នុងអង្គប់ ធ្វើជាខ្មុយ ឲ្យខ្លាវាចូលមក អង្គប់ទឹងថ្លង់
ជាប់វាមិនខាន ។ ;ហេតុនេះ, ជីវិតឯងត្រូវតែស្លាប់ដំនួសជីវិតអញ ។
ឱ! ខ្មៅតាអ៊ីយ សូមលោកមេត្តាជួយជីវិតផ្កែបេស់ខ្ញុំយ៉ាងណា កុំឲ្យ
ខ្លាចូលមក ហើយអង្គប់ថ្លង់មានគ្រោះថ្នាក់ដល់ជីវិតផ្កែបេស់ខ្ញុំឡើយ»។
លុះនិយាយរួចស្រេច កំថើបផ្កែខោះ ហើយដាក់ទៅចងនៅក្នុងអង្គប់;
ប្រមាណជាពាក់កណ្តាលអង្រាត្រ, ខ្លាដែលឆ្ងាប់តែរកស៊ីបានទៅកន្លែង
នោះកំមកដល់, ដើរក្រឡឹងអង្គប់ចុះជុំហើយចូលទៅចាប់ផ្កែនៅក្នុងអង្គប់ ។
កំថ្លង់សង្កត់ខ្លាជាប់ ។ ចំណែកខាងផ្កែ, ដោយគុណានុភាពនៃមេត្តា
ចិត្តបេស់ម្ចាស់ កំបានរួចរួតពាក់គ្រោះថ្នាក់ ចោលតម្រង់មករកម្ចាស់
ម្ចាស់វិញ, ម្ចាស់ឃើញផ្កែរួចមក មានសេចក្តីត្រេកអរណាស់ ស្ទុះទៅ
ថើបផ្កែដោយសេចក្តីស្រឡាញ់ទឹងសេចក្តីនឹកអាល័យ ។ ពាំងពីរនាក់

ថ្ពីប្រពន្ធ កំយកលំពែងស្ពុះរត់ទៅដាក់ភ្នៅក្នុងអង្គីច់ស្ងាប់ទៅ ។ មួយ
រំពេចនោះ យកខ្មោចខ្លាមកពន្លះយកស្បែកចុកលក់ ។

ឥរបើថ្ងៃក្រោយមក បុរសថ្ពីកំលាប្រពន្ធយកស្បែកខ្លាទៅលក់ឯផ្សារ
ដែលតាំងនៅឆ្ងាយ ជាច់សង្កែងឥជំរបស់ខ្លួន ។ មុនទីដំរចញទៅ
បានន័យាយផ្តែផ្តាំប្រពន្ធឲ្យមើលថែទាំផ្ទះសម្បែង, មើលចាបកុំឲ្យស៊ីស្រូវ
ក្នងស្រែ ដែលកំពុងតែទុំស្រគាល, ហើយជាពិសេស ឲ្យមើលឆ្កែនឹង
ស្វាផង ។ ប្រពន្ធខ្លួលបណ្តាំហើយ រៀបចំជាយសំណុំទឹកចំតង់ឲ្យប្តី
រួចស្រែចផ្តាំថា «បើបងលក់ស្បែកខ្លានេះជាច់ សូមទិញ «សាកតា"ឲ្យខ្ញុំ
មួយផង» ។ ថ្ពីកំយកស្បែកខ្លាពុនវែកដាក់លើស្មា ដើរតម្រង់ទៅកេទី
ផ្សារដែលខ្លួនមិនធ្លាប់ស្គាល់សោះ ត្រមង់ត្រមោចលន្ទង់លន្ទោចតែម្នាក់
ឯងគាត់ពាលចូលព្រៃ គាត់ព្រៃចូលភលត្រាតែដល់ផ្សារដោយប្រជុំជនមាន
មនុស្សម្នាច្រើន ។ ដល់ហើយ ជាត់លក់ស្បែរគេឯង ទៅក្នងផ្សារ ។
មានជនជាតិស្បែកសម្នាក់បានមកទិញយកស្បែកខ្លានោះទៅ ដោយឲ្យ
ថ្លៃ ៤៥ រៀល ។ បុរសនេះមានសេចក្តីត្រេកអរណាស់ប្រញាប់ប្រញាល់
វិលមកផ្ទះវិញ យកប្រាក់នោះមកបង្ហាញប្រពន្ធ ។ គំមានសេចក្តីត្រេកអរ
យ៉ាងមហិមា ព្រោះខ្លួនមិនធ្លាប់មានប្រាក់ច្រើនដល់ម្ល៉ះ ។ ដោយ
សារតែគាត់ជាមនុស្សខ្វៃខ្លៃក្រៃពេក បានប្រាក់មកហើយរកកន្លែង

ខុកជាក់មិនបាន ទើបយកប្រាក់នោះទៅជាក់កូនស្បៅដ៏តូចមួយគ្រួរ ទៅលើដើងក្រានចាយ ។ ពត្រីមួយ, ដេកទៅយល់សប្តិឃើញសក្កទេវរាជមកប្រាប់ថា "អ្នកឯងត្រូវទំរកស៊ី កាន់ធម៌សាមគ្គីឲ្យខ្ជាប់ខ្ជួនចំពោះគ្នាទឹងគ្នា កុំតស៊ូខែងខ្វែងគំនិតគ្នា, យូរទៅ ទឹងបានឡើងជាអ្នកមានស្តុកស្តម្ភមាំមួនមិនខាន" ។

ក្រោយមក គាត់ក៏ទំរកស៊ីធ្វើការទូទៅឡើងវិតតមានទំនើសោះឡើយ ។ កាលបើស្រូវនោះខុអស់ហើយគិប្រគុតកាត់បែនចោក ប្រកជង្រុក ប្រកស្បៅខុកជាក់តាមធម្មតា ។

រដូវក្រោយមក គាត់ទំទៅកាប់គាស់តកាយភ្នាក្រៃ ពនដីថែមទៀត ដើម្បីឲ្យស្រែនោះបានរីកធំឡើងលើសមុន, រួចធ្វើភ្លឺឲ្យមាំ, ជាក់ជ័រ, ចាចតឹកជាក់ស្រែ តតមានឈប់ឈរ ។ គាត់កាប់ឈើយកមកធ្វើនង្គ័លរនាស់, ចានគ្រឿងខេត្តប្បករណ៍សព្វគ្រប់ ទៅខ្វះតែគ្រប៉ីគោប៉ុណ្ណោះ ។ គួរអនិច្ចាបុរសតំសត់ពីនាក់ប្តីប្រពន្ធនេះពេក, បុរសប្តីអ្នកអូសនង្គ័លធ្វើក្នែកក្តុះ ។ ឃើញតែទឹកក្នែកទឹកសម្បារហូរហៀរ,ប្រពន្ធកាន់តន្ទុយយោមដាអ្នកបរនង្គ័ល តាំងពីព្រឹកទាល់ថ្ងៃត្រង់, មុខមាត់ខ្លួនប្រាណរបស់គាត់ ប្រឡាក់ពាសដាសដោតេតស្បាប់ មានសេចក្តីខ្មួលំបាកវេទនាយ៉ាងក្រៃលែង ។ គាត់ទំបង្អូរញើសឈោមយ៉ាងពេញទំហឹង

ដើម្បីប្តូរយកជីវភាពថ្ងៃក្រោយ ក្តុំក្តើងរុងរឿងក្នុងអនាគតកាល ។

ដោយហេតុតែគាត់ចាំងពីនាក់ ទៅធ្វើការបាត់ ។ ពីផ្ទះកាលថ្ងៃ, ស្វាទៅផ្ទះបានដៃ ឡើងរុករើតេញចាំងផ្ទះ, លុះឃើញស្បោងក្តារទៅលើដើងក្រាន ទឹកស្មានថាជាអាហារកំលោតទៅកន្ត្រាក់បូតស្បោងប្រាក់នោះភ្លាក់ចូលក្នុងដើងក្រាន, ត្រូវព្រះអគ្គីឆេះអស់ប្រាក់គ្មានសេសសល់តិចតួចឡើយ ។ លុះគាត់ត្រឡប់មកពីធ្វើការ មិនឃើញស្បោងប្រាក់ក៏ទឹកធ្លាល់មើលទៅក្នុងដើងក្រាន ឃើញតែកំទេចក្រដាស់ប្រាក់ដែលក្តៅឆេះអស់ ។ មានសេចក្តីខឹងចំពោះស្វាខ្លាំងណាស់ កំរាយស្វាមួយត្រចង៉ាំហើយបោះទៅក្នុងព្រៃ, ស្វាក៏ចោលបាត់ទៅ ។ ប្រពន្ធកើតទុក្ខគោមួញ ដោយសារតែស្វាម៉ាយស្វាបែរខ្លួនចោះចោល ។ លុះស្វាធំកំហឹងអស់ហើយ ថ្ពិនិយាយលួងលោមប្រពន្ធថា "សក្តិខ្លាចវាសនាមកពាល់យើងថា កុំឲ្យឈ្លោះទាស់ខែងខ្វែងគំនិតគ្នា យើងនឹងរកស៊ីមានបានត្រឹមសម្បត្តិស្តុកស្តម្ភ ដូច្នេះនាងកុំកើតទុក្ខអ្វីចំពោះស្វានេះចាំយើងរកស៊ីមានបងធំនឹងរកស្វានេះឲ្យអូនវិញ" ប្រពន្ធឮថ្ពិនិយាយដូច្នោះមានសេចក្តីត្រេកអរណាស់ កំពួតដៃគ្នាទំរកស៊ីតទៅទៀត ។

ក្នុងវេលាព្រឹកដូចមួយនោះ, ព្រះកុំណាមិនបង្អង់ចុះដើម្បីឲ្យកសិករធ្វើស្រែបានដោយស្រួលសោះ, កំដរ ស្លឹតហួតហែង, ចាំងត្រចាំងបងឆ

ប្អូនក៏រើសយកអស់គ្នានសល់, កសិករពាំងប្រទេសស្ទើរតែជាចំពោះស្ងាប់ដោយការអត់ឃ្លានគ្នានទឹកធ្វើស្រែ ។

បុរសប្តីប្រពន្ធប្រឹក្សាគ្នាថា: បើយើងនៅទំនេរពាំងអស់គ្នាដូចសព្វថ្ងៃនេះ ឃើញថាគ្មានបានផលអ្វីសោះ ។ ដូច្នេះ, បងសុំលាអ្នកនៅភេសុីឈ្លួសគេ ត្រាន់បានប្រាក់កាសនឹងទិញក្របីមែម ។ ប្រពន្ធក៏ទទួលព្រមហើយជូនពរស្តីសាធុការចំពោះប្តីថា: សូមឲ្យបងអញ្ជើញទៅបានប្រកបដោយសេចក្តីសុខ ចំរើន, កេការងារកុំឲ្យបានប្រទះតែសម្បុរសជនកុំបីឃ្លាត" ហើយរៀបចំបាយសំណុំទឹកចំតង់ជូនដំណើរប្តីឥតមានខ្វះ ។ ប្តីក៏ចេញអំពីផ្ទះចាលប្រពន្ធ ជាទីស្រឡាញ់ ទាំងសេចក្តីអាល័យយ៉ាងក្រៃលែង ។ លុះដើរឆ្ងាយទៅ ។ បាននៅដល់ផ្សារមួយជាទីប្រជុំជនយ៉ាងធំមានគេហដ្ឋានកុះករច្រើនមហិមា ។

នៅកងផ្សារនោះមានដង្កៀះឈើម្នាក់ ដែលប្រើសុទ្ធតែដំរីឲ្យអូសឈើទម្ងាក់ពីលើភ្នំ ។ បណ្តាដំរីទាំងនោះមានដំរីមួយកាបសាហាវបានសម្លាប់ទ្រមាក់ម្នាក់ស្លាប់ថ្ម ។ ។ ដង្កៀះឈើទំនុះសែងក៏ទ្រមាក់ថ្មទៀត តែមិនបានដូចបំណង ។

បុរសកំសត់ព្រាត់ពីប្រពន្ធជាទីស្រឡាញ់ បានទៅដល់ទីផ្សារនោះហើយ បានដឹងថា: ដង្កៀះឈើកំពុងខ្វះទ្រមាក់ដំរីដូច្នោះ មានសេចក្តីត្រេក

អរណាស់, ប៉ុន្តែមានសេចក្តីព្រួយបន្តិចមកវិញ ដោយគេប្រាប់ថាដីរនោះ
គាប ចោកសម្រាប់ទ្រមាក់អស់ច្រើនណាស់ហើយ. វាទើបនឹងចោក
ទ្រមាក់ម្នាក់ស្លាប់ក្នុងពេលថ្មីៗ នេះ ។ គាត់ក៏ប្រញាប់ប្រញាល់ដើរសំដៅ
ទៅផ្ទះដង្ហែឈើ ។ បានទៅសំពះដំរាបសួរតាមសេចក្តីគួរសម ចៅក
បានទទួលសំពះតបដោយចិត្តរីករាយ ហើយសួរថា:

- អ្នកមកពីណា? មានការអ្វី?

- តានជ្រោស, ខ្ញុំបាទជាអ្នកនីទ័លក្រ មកពីស្រុកឡាយ ដើម្បី
នឹងមកសុំស៊ីឈ្នួលទៅកន្ទឹងសំណាក់លោក ។

- អ្នកអាចកាន់កាប់ដំរានោះបានដែរ ? (ចង្អុលទៅដំរី)

- តានជ្រោស, ឲ្យតែព្រះគុណឲ្យការធ្វើ, តោះបើឲ្យខ្ញុំ
បាទធ្វើការអ្វី ខ្ញុំបាទនឹងធ្វើតាមបង្គាប់ទាំងអស់ ។

ចៅក បានចុះឈ្មោះបុរសនេះ ទៅក្នុងបញ្ជីសម្រាប់កម្មការស្រួល
បួលហើយ កំនាំកម្មការថ្មីនេះទៅប្រគល់ដំរាឲ្យ ។

កម្មការផងទាំងពួង មានសេចក្តីអាណិតអាសូរទ្រមាក់ថ្មីនេះណាស់
ព្រោះទ្រមាក់មុន ។ មានឧជាតធំមាំមួនក្រអាញ ម្តេចដំរានេះសម្លាប់អស់ជា
ច្រើន, ចំណង់បើបុរសនេះមានតួចស្គមកំព្រឹង មានតែស្បែកដណ្តប់ឆ្អឹង
យ៉ាងនេះ មុខតែដំរានេះសម្លាប់ខ្មៅតមិនខាន ។ បុរសកំសត់, កាលបើ

ថៅកែប្រគល់ដំរីដ៏សាហាវមកឲ្យខ្លួនដូច្នោះ កំតាំងអធិដ្ឋានដោយមេត្តាចិត្តថា: " ខ្ញុំ! ដំរីដ៏កាចសាហាវ, ខ្ញុំនេះជាមនុស្សទីទ័លក្រ, មករកស៊ីឈ្លេសគេ យកលុយកាក់ គ្រាន់ទិញបានចំណីមដំរីតូចមួនធឹងប្រតន្ទកូនតែប៉ុណ្ណោះ ខ្ញុំមិនមែនមកប្រាថ្នាដើម្បីធ្វើទុក្ខបុកម្នេញដល់អ្នកឡើយ" ។ គ្រាន់តែនឹកអធិដ្ឋានក្នុងចិត្តដូច្នេះ, ដំរីដែលឆ្ងាច់តែមានចិត្តកន្ត្រឹសឫស្យារឹងរូស កាចសាហាវមហិមា ក៏មានចិត្តប្រែក្លាយទៅជាគោរទន់អាណិតអាសូរគ្រប់ណា ចំពោះទ្រមាក់ថ្មីនេះ ដែរមុខមករកទ្រមាក់ថ្មីនោះហើយឈរសម្រក់ទឹកភ្នែកហាម ហាក់ដូចជាគិតឃើញថាទ្រមាក់ថ្មីនេះមានមេត្តាចំពោះខ្លួនយ៉ាងក្រៃលែង ។ នេះដោយអំណាចមេត្តាធម៌របស់បុរសនោះ ។ ទ្រមាក់ថ្មីក៏ចូលទៅស្រាយខ្សែច្រវាក់ ដែលគេចងវាអស់ ២-៣ ថ្ងៃមកហើយនោះ ឲ្យបានរបួសរបេចស្រេច ទើបឡើងជិះតាមស្រួលឥតមានគ្រោះថ្នាក់អ្វីឡើយ ។

តាំងពីថ្ងៃនោះមក កម្មករថ្មីនេះ ត្រូវបានសេចក្តីគោរពស្រឡាញ់ច្រើនអំពីសំណាក់ថៅកែ-អំពីកម្មករជនរួមគ្នា ទើងអំពីអ្នកស្រុកជុងជាំងពួង ។ គាត់ខិតធ្វើការដោយយកចិត្តទុកដាក់ ចំពោះថៅហ្វាយនាយឥតមានធ្វេស, ទំនៀមក្បាដំរីដែលខ្លួនគាន់គាប់ ដោយឲ្យស្មៅស៊ី-ទឹកផឹកបានឆ្អែតគ្រប់គ្រាន់ឥតខ្វះខ្លួះ ។ ដំរី ដែលកាលពីដើមជាសត្វស្គមកំព្រឹង ឥឡូវប្រែក្លាយ

ទៅជាសត្វឆាត់ធំ មានកម្លាំងពស់មាំមួន អាចប្រើការអូសឈើបានដូច
បំណង ។ កង ១ ថ្ងៃ។ គាត់បង្ខំឲ្យអូសឈើទម្ងន់ពីលើ២ដង់កុំ ជាមួយនឹង
កម្មករឯទៀតជាច្រើន ។ ឈើណាដែលកម្មករឯទៀតឲ្យដំរីអូសមិនរួច,
គាត់អាចប្រើដំរីរបស់គាត់ឲ្យអូសបាន់តែបាន ។ ដូច្នេះហើយ បានជាគាត់
បានសេចក្តីកោតសរសើរជាច្រើនអំពីហ្វាយនាយ ។

ចំណែកកិរិយានៅផ្ទះវិញ ទំប្រព្រឹត្តតាមដំបូន្មានប្តីឥតធ្វេស ។
នាងអង្គុយនៅមាត់ទ្វារផ្ទះ ដេរប៉ាក់ ស្រែះចាត់ទូរសំលៀកបំពាក់ណា
ដែលរហែកចុះឆ្លាយ ឲ្យបានដិតឡើងវិញផង, មើលថាបងមិនឲ្យស៊ីស្រូវក្នុង
ស្រែផង ។ ពេះប៉ដៃរបស់នាងទំធ្វើការឲ្យរវើកយ៉ាំងណាក៏ដោយ ចិត្តរបស់
នាងតែងនឹកមមៃដល់ស្វាមីជានិច្ច ។ ជួនកាលនាងសម័យឃើញហាក់
ប៉ដូចជាឮសំឡេងប្តីនាងស្រែកហៅ , តែនាងរកមើលមិនឃើញសោះ
គឺគ្រាន់តែជានិមិត្តរូប មកលងវិញ្ញាណរបស់នាងប៉ុណ្ណោះ ។ នាងនឹក
ថា មិនដឹងជាថ្ងៃ-ខែ-ណាប្តីនាងនឹងវិលមកវិញ, ណាមួយនាងនៅតែ
ម្នាក់ឯង ខ្លាចក្រែងឈឺក្បាលវិលមុខ ឬក៏មានសត្វក្រៃគបសាហាវយង់
ឃ្មង់ណាមួយមកយាយីដល់នាង ។

ថ្ងៃឯតីប្តីនាងវិញ, ក៏មានសេចក្តីនឹកអាល័យមកកិរិយាណាស់ដែរ ។
កម្មកររងគ្នា គេសប្បាយរីករាយយ៉ាំងក្រៃលែង ផ្ទុយទៅវិញគាត់តែងតែ
មានមុខស្រពាប់ស្រពោនជានិច្ច ។ គាត់បង្ខំរៅធ្វើការពេលថ្ងៃ

វិញ្ញាណរបស់គាត់ តែងតែសាត់អណ្តែតតាមព្រះពោយមកកាន់គេហដ្ឋាន
របស់គាត់ ជាពិសេស មកកាន់កវីយា ។

ថ្ងៃមួយកំពុងបរដំរីទៅអូសឈើ, គាត់សំឡឹងមើលទៅចំការរបស់
គាត់ ឃើញផើងក្រៀងខ្មៅងងឹត, គាត់នឹកថាក្រៀងនេះភ្លាក់ចំផ្ទះ
អញពិតហើយ ។ ដូច្នេះ, អញទើសុំលាថៅកែទៅផ្ទះវិញ ។ មួយ
រំពេចនោះ គាត់បរដំរីរលេមកចង់ទៅកន្លែង ហើយទៅលាថៅកែថា :

ខ្ញុំបាទសូមលាលោកទៅផ្ទះវិញ ។ គោះបីថៅកែអង្វរកេរយ៉ាងណា
ក៏បុរសនោះមិនព្រមនៅ ដោយនិយាយថា "សូមលោកមេត្តាចុះ,
ខ្ញុំបាទមិនគាន់ចង់ទៅប៉ុន្មានទេ តែខ្ញុំបាទមើលឃើញផើងក្រៀងភ្លាក់ចុះ
ច្រើននៅឯស្រុកខ្ញុំ, ហេតុនោះ ខ្ញុំប្រញាប់រលេទៅដើម្បីកែ ក្រែង គេ
នឆ្ងិល រនាស់ធ្លើស្រែ ។ ថៅកែក៏ខ្ជួលព្រម ហើយឲ្យប្រាក់ខែតាម
កំណត់ពេលដែលគាត់ធ្វើការ, មិនតែប៉ុណ្ណោះ, ថៅកែបានឲ្យ
ប្រាក់បន្ថែមលើប្រាក់ខែនោះទ្វេឡើងវិតផង ព្រោះគាត់ធ្វើការល្អហើយ
យកចិត្តទុកដាក់ ។ បុរសទុគ៌តបានប្រាក់ហើយ មានចិត្តត្រេកអរ
ណាស់សំតៈលាថៅកែ, ហើយមកលាកម្មករជាមិត្តភក្តិទាំងអស់ ដោយ
សេចក្តីស្រឡាញ់ ។ គេលនោះគាត់ចេញអំពីសំណាក់ថៅកែ អំពីកម្មករ
ទាំងអស់ ទាំងនឹកអាល័យ ខ្លាសេចក្តីខ្វះក្រៀមក្រំយ៉ាងវិក្រៃលែង ។
គាត់ធ្វើដំណើរទៅតាមផ្លូវ ញញាបានក្រមួយយ៉ាងស្គម ដើម្បីយកទៅ

ទីមធ្លើស្រែ ។ លុះទៅដល់ផ្ទះ ចាន់ជួបជុំប្រពន្ធប្តីហើយ ចាន់សំណេះសំណាលតាំនេះតាំនោះ, ហើយជាពិសេស, ចាន់រៀបរាប់អំពីដំណើរដែលខ្លួនចាន់ទៅកេស៊ីនោះ ឲ្យប្រពន្ធចាន់ដឹងសព្វគ្រប់តាមដំណើរ ។

តអំពីនោះមក, បុរសប្តីប្រពន្ធ ចាំទុកស៊ីដោយទឹមតែក្រមួយដើម្បីអូសនង្គ័ល ។ ក្នុងមួយថ្ងៃ ។ គាត់ចាន់ដល្បងលើសលប់រកប្រៀបពុំចាន ។ ប្អូនថ្មាំក្រោយមក, តាំងតាំនាក់ ចាន់ឡើងហាន: ទៅជាអ្នកមានសម្បត្តិយ៉ាងស្តុកស្តម្ភ, មានកេរ្តិ៍ឈ្មោះតាំកេះខ្ទរខ្ទាយពាសពេញតាំងប្រទេស ក្នុងស្រុកនាងក្រៅស្រុក ។

– ដោយសារតែគាត់យកចំតក់ទៅបេះផ្លែញៀនលោលគឺ: ការចំប្រឹងប្រែងខ្នះខ្នែង ឥតចំនេះក្នុងការកេសាងជីវភាពឲ្យថ្លៃថ្នូរ ។

– ដោយសារតែគាត់បេះបង្ស សាមគ្គីភាពរវាងគ្នានឹងគ្នា មិនពាស់ស្រែងខ្នែងគំនិតគ្នា ។

– ដោយសារតែគាត់ ប្រៀបចាន់នឹងសត្វកណ្តៀរដែលចំព្យាយាមយកអាចម៍ដីបន្តិចម្តងៗ មកតួនកកើតជាដំបូកយ៉ាងធំទៅចាន ។

– ដោយសារតែគាត់ មានគំនិតអធ្យាស្រ័យប្រកបដោយមេត្តាជានិច្ច ។

ចំបំផុតគាត់ចាន់ឡើងទៅជាគហបតីមួយរូបយ៉ាងល្បីល្បាញ នៅក្នុងក្រុង ។

រឿងព្រេងប្រទេសហ្វីលិពីន

ចែងអំពី

អណ្តើក នឹងស្វាបែកឈើគ្នា

តាំកុ មែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

ថ្ងៃមួយ អណ្តើកកំពុងតែអង្គុយអាំងថ្ងៃនៅមាត់ទឹក ស្រាប់តែបាន
ឃើញវត្ថុមួយអណ្តែតតាមទន្លេ នៅចំពីមុខវា ។ កាលវត្ថុនោះអណ្តែត
មកជិត អណ្តើកបានស្គាល់ថាជាដើមចេក វាលោតចុះទៅក្នុងទឹក,
ចោលសំរៅទៅដើមចេកនោះ ហើយទាញយកមកឯច្រាំង ប៉ុន្តែ វាជា
សត្វគ្មានកំឡាំងល្មមនឹងលើដើមចេកនោះ យកមកជាក់ទៅលើដីវិញបាន
ឡើយ ។ ម្ល៉ោះហើយ វាចេញដើរទៅ, បានឃើញស្វា រួចនាំស្វានោះ
ត្រឡប់មកមើលលទ្ធលនោះវិញ; វានិយាយប្រាប់ស្វាថា៖

–នេះហើយជាដើមចេក ដែលអញស្រាប់តែយកឥតក្តីទឹកមក, ចូរ
ឯងជួយសែងដើមចេកនេះ ទៅចំការរបស់អញ, អញនឹងជាវ ។

ដោយស្វាជាសត្វថោកទាបណាស់, វានិយាយតបថា :

-បើប្រសិនជាអញត្រូវធ្វើដូច្នោះ អញត្រូវតែបានចំណែកដើមឈើនេះដែរ ។

-ឲ្យតែឯងជួយអញចុះ អញនឹងចែកឲ្យឯង ។

ពេលនោះ ស្វាទន្ធឹងអណ្តើកតាំងពីនាក់ ក៏ទំពាញអូសដើមចេកនោះ ទៅរោងចំការរបស់អណ្តើក ។ ដល់ចំការ, អណ្តើកនិយាយថា:

-ឥឡូវនេះ យើងត្រូវដីតរណ្តៅដាក់ ។

-ខេ ,យើងបាននិយាយថា យើងត្រូវចែកគ្នា! (ស្វានិយាយ) ។

-ពិតហើយ, យើងត្រូវដាក់សិន ហើយដល់គាលណាក៏ផ្លែ ស៊ីមយើងចែកគ្នាតាក់កណ្តាលម្នាក់ ។

-ខេ! ខេ? យ៉ាងហ្នឹង មិនមែនជារបៀបចែកខេ, យើងត្រូវតែចែកគ្នាឥឡូវនេះ ឲ្យហើយទៅ, ឯងយកដើមចេកនេះតាក់កណ្តាល អញយកតាក់ កណ្តាល ។

-ចែករបៀបឯងហ្នឹង មិនល្អស្អីខេ !

-យ៉ាងណាក៏ដោយ អញត្រូវតែយកចំណែករបស់អញឥឡូវនេះឯង ។

ដូច្នេះហើយ អណ្តើកក៏តាប់ដើមចេក ជាពីរកំណាត់ស្មើគ្នាដោយខ្មើសគាល់ក្នុងចិត្ត ។

ស្វាក្រឡេកមើលចំណែកខាងចុង ប្រកបដោយស្មឹកខឿវែងខ្លីដែលវាយល់ថា ជាចំណែកល្អបំផុតនោះ ក៏បន្ទឺសំដីថា :

-អាតាក់កណ្តាលខាងចុង ត្រូវបានអញ ! ។ រួចហើយ វាទាំយកចំណែកដែលមានស្មឹកខឿវែងខ្លី ទៅក្នុងចំការរបស់វា ។

ឯអណ្តើកក៏ដាំចំណែកដើមចេកដែលសល់ គឺខាងគល់, លុបដីជាន់បង្ហាប់យ៉ាងខ្លាំងខ្លួនដុំវិញដើមនោះ ។ ចំណែកដើមដ៏ខឿរបស់ស្វា មិនឃ្លេបុំខ្មាន់ក៏ស្វិតស្រពោនងាប់ទៅ ។ ប៉ុន្តែ ចំណែករបស់អណ្តើកដែលមានឫសនេះ, បានលូតលាស់ទូវស្មឹកថ្មី ហើយគ្រាយមកមិនឃ្លេបុំខ្មាន់ក៏ចេញរួបកងក្រាកដជាដើមចេក មានផ្លែកើតឡើង ។

កាលដែលផ្លែចេកនោះពុំ អណ្តើកចង់បេះស៊ី ប៉ុន្តែវាមិនអាចឡើងបេះបានឡើយ ។ ដូច្នេះហើយ វាក៏ទៅនាំស្វាមកម្ចងខឿត ហើយសុំឲ្យស្វា ឡើងទៅបេះចំណាត់មកឲ្យវា, វាទំាយថា :

-ដោយសេចក្តីខ្នះខ្នែងរបស់ឯង, អញនឹងឲ្យផ្លែចេកទៅឯងខ្លះ ។

ស្វាបានឡើងទៅអង្គុយលើចុងដើមចេក រួចតាំងភ្ញក្សផ្លែចេកមើល ឯអណ្តើកបានអង្គុយចាំខាងក្រោម ប៉ុន្តែស្វាឥតចំណាត់មកឲ្យអណ្តើកមួយឡើយ វាអង្គុយស៊ីផ្លែព្រាឆើយ លើចុងចេកនោះ; អណ្តើកនិយាយថា :

-ចំណាត់ឲ្យអញខ្លះមក អញនឹងចាប់ !

- កុំអី! (ស្វាធ្វើយតប), ឥមុនឯងបានបោកបញ្ឆោតអញ ដោយឲ្យចំណែកខាងអាក្រក់មកអញ, ឥឡូវនេះ អញត្រូវតែស៊ី !

- បោះឲ្យអញឥ.ចឹ មក ! ។

- ហឹ ! នេះសំបក! ស៊ីទៅ! ។ ថាហើយស្វាក៏បោះសំបកចេកចំលាក់មកលើដី ។

ដល់មកថ្នាក់នេះ អណ្តើកត្រឡប់ជាខឹង ហើយវាបានទៅប្រមូលតណ្តាកវត្តុ (វត្តដែលមានសណ្ឋានដាំបន្លា) នឹងបន្លាឈើផ្សេង ។ អំពីព្រៃស៊ុំខ្ញុំ យកមកពាយដុំវិញគល់ចេក រួចវាទៅតូងចាត់ ។

កាលដែលស្វាស៊ីផ្លែចេកអស់ហើយ វាលោតចុះមក ហើយបានជាន់ទៅលើបន្លាតាំងនោះ វាស្រាប់តែលោតកញ្ឆក់វាយកញ្ឆេង ស្រែកដោយការឈឺចាប់ ចំពោះបន្លាមុតជើងយ៉ាងវេទនា ។ ជាន់ត្រង់ណាក៏ដោយ ស្វាចេះតែចំរើលើបន្លាជាដរាប ។

ទីបំផុត អណ្តើកឃើញទិដ្ឋភាពដូច្នោះ ក៏អត់សើចមិនបាន ។ ឮសំណើច, ស្វាស្ទុះទៅក្រញីអណ្តើក ចាប់ក្បាលទាញចត់ទៅលើស្មក ធ្វើឲ្យអណ្តើករកតំនាក់គ្នាន ។

- ពេលនោះស្វាប្រកាសឡើងថា ៖

- ឥឡូវនេះ អាឯងត្រូវខូលខណ្តាកម្ម ចំពោះបទទ្រុងទ្រដបបោស

អាឯងវា , តើឲ្យអញសំពងអាឯងនឹងដំបង ឬឲ្យអញជាក់អាឯងទៅក្នុងស្ទាល់ថ្ម រួចកិនអាឯងឲ្យទៅជាម្សៅតែម្តងទៅ ? ឬមួយកំពង់ឲ្យអញ គ្រវែងអាឯងចុះពីលើកំពូលភ្នំវិញ ? ។

ស្វាបាននិយាយណែនាំអណ្តើក តាមរបៀបនេះ ច្រើនបែបច្រើនយ៉ាងទៀត ។

ទីបំផុត អណ្តើកឆ្លើយថា ៖

-បាទ ! ឆ្លើយបែបនេះ ជាការប្រពៃណាស់, អញ្ចឹញឆ្លើតាមចិត្តចុះ, ចោះខ្ញុំពីកំពូលភ្នំកំបាន, កិនខ្ញុំកំចិចក្នុងស្ទាល់ថ្មក៏បាន, សំពងនឹងដំបងក៏បាន, ការធ្វើពាំងអស់នេះ នឹងនាំឲ្យខ្ញុំរឹងតែតែសប្បាយឡើងទៀត, ប៉ុន្តែ សូមមេត្តាអាណិត កុំតែចោះខ្ញុំទៅក្នុងទឹកឲ្យសោះ ! ។

-អ៊ូ , ទឹក ? ម៉េចបានជាអញគិតមិនដល់ហ្ន៎ ?

បើអីចឹង អញនឹងបង្ហើយអាឯងឲ្យស្រេចទៅក្នុងទឹកតែម្តង ! ។

ថាហើយ ស្វាចាប់លើកអណ្តើកយួរ សំដៅទៅមាត់ទន្លេ ហើយបានគ្រវែងអណ្តើក ទៅត្រង់ទឹកដ៏ជ្រៅបំផុតឮសូរប្រូង លិចបាត់ពីភ្នែកភាព ។ ស្វាសប្បាយចិត្តណាស់ ។ ភ្លាមនោះអណ្តើកបានងើបក្បាលផុតពីផ្ទៃទឹកមកវិញ រួចនិយាយទៅកាន់ស្វាថា ៖

-អរគុណសំឡាញ់, អរគុណ ! អ្នកឯងមិនដឹងថា ទឹកជាគេហដ្ឋានរបស់ខ្ញុំទេឬ ? ។

កណ្ឌទី ៤១

ទុតញ៉ាវិបុលភជសេនា ឆ្លូ-ភន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទឹងបេះខុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ។

ដៀវហៀនឆីដៀវឡាំ ដែលជាមហាទន្ទឹងសៀវឆ្នើយដំពាក់ចូលគ្នាថា ខ្ញុំបាទជាពួកអ្នកលើកំមែន តែចំណានការខាងខ្លួនគ្រាន់បើដែរ ខ្ញុំបាទនឹងសុំខ្លួនចម្បាំង ២០ ផ្លុកមហាទន្ទឹមព្រម លើកទៅវាយកងទ័ពដ៏យើវៃលានេះ យកជ័យជោគជាដំបូងឲ្យប្រាកដក្តីឈ្មោះថាជាមនុស្សអ្នកលើចំណានកងការខ្លួនក្តារ ។

ចូចូតបថា ដែលអ្នកតាំង ២ ទីនឹងចំណានការខ្លួនកំមែន តែបានខាង ឯកងស្ងួនទីនឹងត្រែក ឯពួកស្រុកកាំងតាំងភ្នំនឹងពួកែខាងខ្លួនខោះ

រួសរហ័សណាស់ ចាជូចគ្រាហែលប្រឆ្នាស់គ្នាក្នុងទឹក អ្នកទាំង ២ កុំបី
មើលងាយ ដែលទឹងអាសាវៅនោះតឹតាប់ចិត្តខ្ញុំណាស់ហើយ តែ
យើងនឹងឲ្យវៅនោះ ចាជូចក្មេងធ្វើឲ្យអ្នកទាំង ២ ស្អាប់អសារឥតការ ។
ដៀវហៀ, ដៀវឡាំចេះតែអង្វរ បើខ្ញុំបានអាសាវៅដល់សេចក្តីស្អាប់
កងកងទឹត សូមលោកយកបុត្រកន្លែយាចងក្តួនខ្ញុំបានទាំង ២ នាក់ មក
ចំលាក់ទឹកចេញឲ្យអស់វៅចុះ ។ ចូគួតបថា ខ្លួកចម្បាំងធំ ។ កំចង
ភ្ជាប់គ្នាអស់វៅហើយ វៅតែខ្លួកតួចរហ័សសម្រាប់ប្រើប្រាស់ឃាមល្បាត
ហើយកំចុះមាហានតែ ២៥ នាក់ ដែលទឹងវៅនោះឃើញជាមិនបាន ។

ដៀវហៀ, ដៀវឡាំថា តែត្រឹមខ្លួកតួចកំបានដែរ ទឹងបានធ្វើការ
រហ័សចើនឹងប្រាសហើយ ចែងខ្លួកឲ្យដៀវឡាំពាក់កណ្តាល លើក
ទ្នូងវៅវាយខ្ជប់យកកងទ័ពខ្លួកជីវើ កាត់យកក្បាលជីវើឲ្យបាន ។
ចូគួថា ចើទឹងអាសាវៅក៏វៅចុះ យើងនឹងឲ្យមាហាន ៥០០ ហើយ
ទឹងឲ្យចុងផេងទាំងខ្លួកចម្បាំង ៣០ លើកជូនវៅក្រោយ តែអ្នកទាំង ២ ធ្វើ
តែល្មមឲ្យយើញថ្ងៃដែ កុំរំលោកបំពានចូលវៅឲ្យថ្លង់ការ; ដៀវហៀ
ដៀវឡាំ មានសេចក្តីត្រេកអរក៏តិនាប់លាចូគួចេញមក ហើយចាត់ចែង
មាហានទឹងត្រឿងសាស្ត្រាវុធឲ្យចុះខ្លួក ២៥ លើកជម្រើងវៅកងទ័ពជីវើយ ។

ឯមាហានជីវើយ កាលថ្ងៃដែលចូគួឲ្យបណ្តែតផែខ្លួកចម្បាំងនោះ

ធំធំដំណាំធំហើយ កំចូលទៅប្រាប់ដាវយី ។ កំនាំតាហានឡើងទៅមើលលើកំពូលភ្នំខ្ពស់ ឃើញតាហានភ្នំកងចំពាក់ចូច បណ្តែតដែខ្លួនចម្បាំងវាយស្ទុះស្រែកហោកគ្រាញ់រៃអីធំកង ទើបដាវយីត្រឡប់មកបន្ទាយវិញ កាលដៀវហៀ, ដៀវឡាំលើតទ័ពខ្លួនទៅខោះ តាហានយាមល្បាតកំចូលទៅប្រាប់ដាវយី ។ កំប្រឹក្សាធំធាហានតាំងតួធំថា តាហានប៊ូឆូលើកកន្ទុងចូលមកដល់មុខកងទ័ពខ្លួនយើងហើយ ឧណាធំអាចខ្លួលអាសាចេញទៅតធំរឹកសត្រូវបាន ហ៊ានតុងធំធំដាវថាយ កំលាដាវយីចេញទៅចុះខ្លួន ព្រមតាំងតាហានត្រប់ខ្លួនតាំង ៥ ។

ឯដៀវហៀ, ដៀវឡាំ ឃើញតាហានដាវយីចេញមកកំស្រែកថា អញតាំង ២ មានថ្លៃដៃខ្លាំងតួតែណាស់ ឧណាអាចហ៊ានមកតស៊ូធំងអញកំឲ្យចេញមុខមកចុះ; ឯដៀវហៀគាន់លំតែងឡើងទៅឈរខាងក្បាលខ្លួនឲ្យតាហានស្រួតចែវហើយឲ្យបាញ់ធ្នូចម្រុះទៅដាច្រើន ឯហ៊ានតុងកំយកខែលរងព្រួញ លុះខ្លួនចម្បាំងចូលទៅជិតគ្នា ហ៊ានតុងកំយកលំតែងចាក់ត្រូវដៀវហៀស្លាប់ ហើយលោតឡើងលើខ្លួនកាប់សម្លាប់តាហានកងខ្លួនខោះស្លាប់អស់លើង ដៀវឡាំឃើញដូច្នោះ កំឲ្យតាហានស្រួតចែវខ្លួនដំនួយចូលទៅតយុទ្ធទៀត ដាវថាយកំដេញខ្លួនតាហានចូលទៅជិតគ្នា ហើយលោតឡើងទៅលើខ្លួន យកក្រចឹកាប់ដៀវឡាំស្លាប់ ហើយ

តាប់ចាត់ពាហនក្នុងទូកនោះ ស្លាប់អស់គ្មានសល់ ឯទូកពាហនដៀវហៀ, ដៀវឡាំដែលសល់នោះ ក៏ស្រួតចៃវចេះរត់ទៅក្រោយវិញ ហ៊ានតុងក៏លើកទូកដេញតាម ខ្លួលប្រទះនឹងទូកប៊ុនផេងលើកជាជំនួយមកតាមពីក្រោយ ក៏ចូលចង្កាំប្រយុទ្ធគ្នាជាគោលហាល ។

ក្នុងខណៈដ៏វេយើងទៅលើកំពូលភ្នំ ក្រឡេកទៅខាងដើមឃើញទូកកងទ័ពចូរដោតទង់ច្រងច្រះជាច្រើន ហើយក្រឡេកមកត្រង់មុខបន្តាយរបស់ខ្លួន ឃើញទង់ទូកចម្បាំងហ៊ានតុង, ដ៏វេថាយ កំពុងចង្កាំងគ្នានឹងប៊ុនផេង ជាសន្ធឹកណាស់ ឃើញទូកទ័ពប៊ុនផេងខ្លះលង់ពុំឈ្នះ ក៏ថយរត់ទៅ ឃើញទូកទ័ពហ៊ានតុង , ដ៏វេថាយនៅចៃវដេញតាម ដ៏វេយើចារម្ភខ្វាចក្រែងទ័ពចូរទ្រទឹងបង្ក្រាប់ចាំធ្វើអន្តរាយ ហ៊ានតុងនឹងដ៏វេថាយឲ្យថ្លង់ការ ដ៏វេយើកំប្រឹក្សាទឹងនាយទ័ពនាយកងទាំងពួងថា ទូកចម្បាងចូរច្រើនលើសលុបហួសវិស័យដែលនឹងគណនាកប់ ឧបមាដូចស្មឹកឈើដែលនៅលើដើម យើងនឹងរិះគិតគន់ចង្កាំងប្រការម្តេច ទើបនឹងបានជ័យជំនះ ។

ពីប្រឹក្សាទឹងសេនាពាហនទាំងពួង នៅមិនទាន់ឆ្លើយថាប្រការម្តេច ខ្លួលកើតឃ្លល់ឮរបក់បោកមកខ្លាំងណាស់ ដ៏វេយើក្រឡេកទៅឃើញទង់លឿងក្នុងទ័ពចូរធ្លាក់ដងលង់ចុះ ដ៏វេយើក៏សើចហើយថា

ដែលខន់ដ័យចូធ្លូថាក់ដងនោះ ជាការអពមង្គលដល់ចូធ្លូ ល្មមផុតពាក្យ
និយាយ ចុងឲ្យល់កំបក់ចោកមកខ្យែត ត្រូវខន់ដ័យក្តងតងខ័ពដ៏វែយ
រចូតចេញពីដង អណ្តែតខ្យើងទៅថ្នាក់លើកុំ ចំពោះមុខដ៏វែយ ។

ដ៏វែយឃើញដូច្នោះ កំភ័យស្ងុតចិត្តគិតថា ឥឡូវនេះកងខ័ពចូធ្លូជា
ដើមឲ្យល់ ឯភាងខ័ពយើងទៅជាចុងឲ្យល់ ការដែលគិតខុកថានឹងផុត
ខ័ពកូធ្លូនោះ ឃើញជាមិនបានសម្រេច ព្រោះឲ្យល់មិនបានបក់ត្រឡប់
ទៅភាងខ័ពចូធ្លូ តើនឹងរិះគិតប្រការម្តេចអេះ មិនឃើញប្រកល្អកសោះ
ដូច្នេះ មិនដឹងជាយ៉ាងណា ។ ដ៏វែយក៏មានសេចក្តីស្តៅក្រហាយព្រួយ
ខ្លួនគ្មានសុម្រិទសប្បាយ ចេះតែក្រហល់ក្រហាយញ័រអស់សព្វសាច់តែ
គិតទៅគិតមកមិនជាច់ស្រេច រឹតតែខ្លួនខ្លាំងខ្សោយ ទាល់តែក្អួតធ្លាក់មក
សុទ្ធតែឈាម ហើយដួលសន្លប់ទៅទីនោះ ឥហានតាំងអស់ក៏ភ័យស្ងុត
ស្មារតី ជួយគ្នាគ្រាប់នាំខ្លួនដ៏វែយត្រឡប់ចុះទៅបន្ទាយ លុះតែត្រូវច្រាប់
ដងខ្លួនហើយ ឥហានតាំងពួងក៏ប្រឹក្សាគ្នាថា គ្រានេះដ៏វែយជាមេកងធំ
កងខ័ពត្រឡប់ជាឈឺដូច្នេះ បើសិនណាជាចូធ្លូដងកំទីងលើកខ័ពមកច្បាំង
គ្រប់សង្កត់ យើងកំទីងបានសេចក្តីភ្លាំងភ្លាត់បរាជ័យ, ហេតុនេះត្រូវយើង
នាំសេចក្តីទៅជំរាបស៊ុនគួន សូមខ្លួនប្តេជ្ញាដែលឯក នាំមកព្យាបាល
រក្សារោគដ៏វែយឲ្យសះជា ទើបទីងបានធ្វើការជាធាប់តទៅ ។

ខណៈនោះ ឡោសុកឃើញដីវាយឈើក្រោកមិនរួចដូច្នោះ កំមិន
មានសេចក្តីសប្បាយទេបន្តាំរឿងតំរៅទៅប្រមាណប្រាប់ខុងបេងថា ដីវាយ
ក្តុតឈាម ឥឡូវនៅដេកឈឺមិនខាន់ជា ខុងបេងក៏ក្តែងសួរថា តាល
ម៉ើដីវាយឈឺអួរនៅដូច្នេះ តើអ្នកបានឃើញការតំរាំតួនោះខំឆ្ងាជាប្រការ
ម្តេច ឡោសុកថា ដែលដីវាយជាមេកងធំក្នុងខ័ពបង្គាប់បញ្ជាការតំរាំ
តួន ឥឡូវមកឈឺដូច្នេះ កំជាបុណ្យរបស់ចូវ ជាកម្មរបស់ពួកស្រុកតាំង
តាំង ខុងបេងឮដូច្នោះក៏អស់សំណើចហើយថា ឯកេតដីវាយនេះខ្ញុំតិល្មម
ខំឆ្លក្បាញ្ជាជ្រលឲ្យសះជាបាន ។

ឡោសុកថា បើលោកអាចកេតដីវាយឲ្យសះជាបាន កំជាបុណ្យ
របស់អ្នកស្រុកតាំងតាំង ហើយឡោសុកក៏នាំខុងបេងចូលទៅកងបន្ទាយ
ឲ្យខុងបេងនៅខាងក្រៅ ខ្លួនឡោសុកឯងក៏ចូលទៅខាងក្នុង ឃើញដីវាយ
កំពុងដេកឈឺ ឡោសុកសួរថា ដែលលោកឈឺនេះ ឋណ្ឌាលមកតំកេត
អ្វី ? ដីវាយឆ្លើយ កេតក្នុងខ្លួនខ្ញុំ។ មិនដឹងប្រាប់ថាឈឺនោះយ៉ាងម្តេចទេ
តែកងដើមទ្រូងត្រង់ថ្លើមប្រមាត់នោះញាប់ញ័រ ចាប់ដូចជាត្រូវអាវុធផ្សេង។
ឡោសុកសួរថា លោកបានពិសាថ្នាំអ្វីខ្លះដែរឬទេ ? ដីវាយប្រាប់ថា ថ្នាំមាន
ត្រប់មុខ តែផឹកមិនបាន ព្រោះហេតុថាខ្យល់មកស្ទះបំពេះដកចេ ឡោសុក
ថា កេតលោកដែលឈឺនេះ ខុងបេងថាខំឆ្លើមឲ្យជា ឥឡូវខុងបេង

មកដែរនៅខាងក្រៅ ដាវយ៉ាក៏ឲ្យអញ្ជើញពុងបេងចូលទៅ ហើយឲ្យមនុស្សដែលថែរក្សាគ្រាប់ឲ្យអង្គុយ ពុងបេងថា ខ្ញុំមិនបានមកសួរលោក ៤-៣ ថ្ងៃនេះ លោកតបឆ្លើតបច្ចុប្បន្នកេតមកភ្លាម ខ្ញុំមិនដឹងសោះ; ដាវយ៉ាថា ធម្មតាកើតមកជាមនុស្សនេះ កម្រនឹងដឹងការក្នុងអាកាស ។

ដាវយ៉ាឮពុងបេងថាដូច្នោះក៏ខឹងណាស់ តែមិនចេញស្តីថាប្រការម្តេច ធ្វើជាស្រួល តែកេតនោះក៏តែតែងកំរើកខ្ញាំងឡើងទៀត ពុងបេងថា កូនដើមទ្រូងលោកតំរង់ប្រកបដោយសេចក្តីវិតក្កចេះតែប្រមូលគ្នាជាច្រើនឡើង ជាន់ជាបណ្តាលទៅដាកេតដូច្នេះ ត្រូវតែប្រកបថ្នាំត្រជាក់ទើបសះជា ដាវយ៉ាថា ថ្នាំត្រជាក់ក៏ជាន់ផឹកលេបច្រើនមុខមកហើយ កេតមិនអន់ស្រាន់ចុះ ហើយសួរពុងបេងថា ថ្នាំត្រជាក់របស់អ្នកឈ្មោះអ្វី ? ក្រែងផឹកទៅប្រកបខុងកេតខ្ញុំ ។

ពុងបេងក៏បណ្តេញមនុស្សបំរើទាំងអស់ចេញទៅ ហើយក៏យកពិធមកសរសេរអក្សរ ១៦ តួជាសេចក្តីថា ដែលខឹងគិតកំចាត់ចូរនោះបានចាត់របៀបរៀបខុងជាស្រេចអស់ហើយ គឺថ្នាំថ្នូខឹងយកក្តីដុតចំពាចូរទៅខ្លះតែឲ្យលស់សល្ងាច់ខមួយមុខ ដែលមិនបានបាក់មកដូចបំណងថ្នាំថ្នូលោក លុះសរសេរហើយក៏ហុចទៅឲ្យដាវយ៉ាហើយថា ឯកេតដែលឈឺនេះ ១បមាដូចធាតុទាំង ៤ ក្នុងរូបកាយរបស់លោក ឯជាតុដ៏ជាតុខឹងក៏មាន

(នៅមានត)

ផ្នែកកំណាត់ឯកសារ

ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

ព្រះរាជក្រឹត្យ

តែងតាំងព្រះបវរនុត្តរៈជាទីវាជាគណៈ

ធំឯរៀនានុក្រម

តាមព្រះរាជក្រឹត្យលេខ ២៣ រ.ស. នៃសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គ
ព្រះសីហនុព្រះរាជហ្ឫទ័យ តែងតាំងព្រះថេរានុត្តរៈឲ្យឡើងឋានន្តរស័ក្តិ
មានដូចតទៅនេះ ៖

ក- ព្រះទេពាលង្ការ សូរ-ហាយ ជន្មាយុ ៥៦ ឆ្នាំ វស្សា ៣៤
វាជាគណៈសម្រាប់ត្រៃ នៅវត្តទេពាសោម ក្រុងភ្នំពេញ ជាទីពាជាគណៈ
សម្រាប់ពេ មានតារម្យង៉ារជា "ព្រះមុនីកោសល" ជាជំនួស
ព្រះមុនីកោសល សោម-ឈុន ដែលអនិច្ចធម្ម ។

ខ- ព្រះឥន្ទមុនី កែវ-រ័ណ្ឌ ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣២ ពាជា
គណៈសម្រាប់ចត្វា នៅវត្តទេពាសោម ក្រុងភ្នំពេញ ជាទីពាជាគណៈ
សម្រាប់ត្រៃ មានតារម្យង៉ារជា „ព្រះទេពាលង្ការ„ ជាជំនួសព្រះទេពាលង-

វង្ស សួរ-ហាយ ដែលឡើងកាន់ឋានៈជាទីពាជាគណៈសម្រាប់ខេ ។

គ- ព្រះវិន័យសំវរ ពជ-គីន ជន្មាយុ ៥០ ឆ្នាំ វស្សា ៣០ ពជាគណៈសម្រាប់ចត្វា នៅវត្តសាកវ័ន ក្រុងកំពង់ចេញ ជាទីពាជាគណៈសម្រាប់ត្រី មានគោរម្យងារជា "ព្រះសិរីសម្ពតិវង្ស" ជាដំណួសព្រះសិរីសម្ពតិវង្ស ប៉ែន-មាំ ដែលអនិច្ចធម្ម ។

ឃ- ព្រះគ្រូមុនីសោភ័ណ សេខ-ទាង ជន្មាយុ ៤៩ ឆ្នាំ វស្សា ២៥ ឋានានុក្រម នៅវត្តទណ្ឌាលោម ក្រុងកំពង់ចេញ ជាទីពាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះឥន្ទមុនី" ជាដំណួសព្រះឥន្ទមុនី កែវ.រ័ណ្ណ ដែលឡើងកាន់ឋានៈជាទីពាជាគណៈសម្រាប់ត្រី ។

ង- ព្រះគ្រូសំវរប្បញ្ញា ចក់-សេង ជន្មាយុ ៤៥ ឆ្នាំវស្សា ២៥ ឋានានុក្រម នៅវត្តសាកវ័ន ក្រុងកំពង់ចេញ ជាទីពាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះគម្ពីរត្ថេរ" ជាដំណួសព្រះគម្ពីរត្ថេរ ខន់ ហង្ស ដែលអនិច្ចធម្ម ។

ច- ព្រះគ្រូពុទ្ធបណ្ឌិត ភុំង-ភួង ជន្មាយុ ៥១ ឆ្នាំវស្សា ៣០ ឋានានុក្រម នៅវត្តព្រះពុទ្ធមានបុណ្យ ក្រុងកំពង់ចេញ ជាទីពាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះវិន័យសំវរ" ជាដំណួសព្រះវិន័យ-សំវរ ពជ-គីន ដែលឡើងកាន់ឋានៈជាទីពាជាគណៈសម្រាប់ត្រី ។

ឆ- ព្រះគ្រូសង្ឃសុមេធ ឆន់-ភិន ជន្មាយុ ៤៥ ឆ្នាំ វស្សា ២៥ ហានានុក្រម នៅវត្តទណ្ឌាលោម ក្រុងភ្នំពេញ ជាពីជាគណៈសម្រាប់ចគ្វា មានគោរម្យងារជា "ព្រះសិរីវិសុទ្ធិ" ជាជំនួសព្រះសិរីវិសុទ្ធិ អ៊ិន-ជួន ដែលអនិច្ចធម្ម ។

ជ- ព្រះវិន័យធរ ដុំ-ម៉ក ជន្មាយុ ៥៣ ឆ្នាំ វស្សា ៣២ ហានានុក្រម នៅវត្តទណ្ឌាលោម ក្រុងភ្នំពេញ ជាពីជាគណៈសម្រាប់ចគ្វា មានគោរម្យងារជា "ព្រះញាណសំវរៈ" ជាជំនួសព្រះញាណសំវរៈ ទុំ-ឯក ដែលគនិច្ចធម្ម ។

ឈ- ព្រះវិន័យធម្ម ម៉ែ-ខាន់ ជន្មាយុ ៥០ ឆ្នាំ វស្សា ៣០ ហានានុក្រម នៅវត្តទណ្ឌាលោម ក្រុងភ្នំពេញ ជាពីជាគណៈសម្រាប់ចគ្វា មានគោរម្យងារជា "ព្រះបិដកធម្ម" ជាជំនួបព្រះបិដកធម្ម អ៊ុង-ឃឿន ដែលអនិច្ចធម្ម ។

ញ- ព្រះវិន័យធរ អ៊ុំ-ទិត ជន្មាយុ ៥៣ ឆ្នាំ វស្សា ៣៣ ហានានុក្រម នៅវត្តមហាមន្ត្រី ក្រុងភ្នំពេញ ជាពីជាគណៈសម្រាប់ចគ្វា មានគោរម្យងារជា «ព្រះវិកន្ធញ្ញាណ" ជាជំនួសព្រះវិកន្ធញ្ញាណ ឡុង-ចាន ដែលអនិច្ចធម្ម ។

ប្រការ ២- អ្នកទទួលភារកិច្ចអគ្គនាយកក្រសួងនានាក្នុងព្រះបរមរាជ

កំណត់ចំណាំពីព័ត៌មានសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវទទួលការៈ
ចាត់ការរៀងខ្លួន ឲ្យបានសម្រេចការតាមព្រះរាជក្រឹត្យនេះ ។

ព្រះរាជក្រឹត្យធ្វើនៅក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ
នៅថ្ងៃ ៦ ១២ ១០ ឆ្នាំជូតទោស័ក ព.ស. ២៤០៣
ត្រូវនឹងថ្ងៃទី ២ ខែកញ្ញា គ.ស. ១៨៦០

សម្តេចព្រះនរោត្តមព្រះហស្តលេខា :

ន. សីហនុ

ចាងយកសេចក្តីក្រាបបង្គំទូលថ្វាយ សូមព្រះរាជ
ទានព្រះរាជហស្តលេខា នៃព្រះប្រមុខរដ្ឋ

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា: ផូ-ត្រឿង

(តទៅ)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទ្វារ គុ. ដែលធ្លាយក្រៅលែង; នប៉ុ. ចំណាយក្រៅលែង ។ – ភូ នប៉ុ. ភាវនៃ... ធ្លាយក្រៅលែង ។

អតិទ្ធប្ប គុ. ដែលឆ្អើងឆ្អៃក្រៅលែង ។

អតិទេវិនិ ក. ន. អ្នកលេងក្រៅលែង ។

អតិទេវិ ប៉ុ. *អតិទេវ*, ការរីកចម្រើន; ការប្រហែលគ្នា ។

អតិទ្រុត គុ. ដែលចាំក្រៅលែង ។

អតិទ្វយ–យី គុ. ដែលក្រៅលែងដោយពីរ, ដែលមានតែមួយ ។

អតិធនិនិ គុ. ដែលមានទ្រព្យក្រៅលែង ។

អតិធន្វនិ ប៉ុ. ឈ្មោះក្រុមភ្នាក់ ។

អតិធវិល គុ. ដែលសក្រៅលែង, ដែលសស្គុស ។

អតិធីរតា ស្ត្រី. ភាវនៃបុគ្គលនឹងធឹងក្រៅលែង; – វិនយ, នប៉ុ. ភាវនៃបុគ្គលនឹងធឹងក្រៅលែង, ភាវនៃបុគ្គលម៉ឹងម៉ាត់ក្រៅលែង ។

អតិនម្រតា ស្រ. ភាវនៃ... ទន់ក្រៅលែង ។

អតិនម៌និ ប៉ុ. កិរិយារីករាយក្រៅលែង ។

(នៅមានត)

ភក្តីសាសនា


ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣២ លេខ ១១ ខែវិច្ឆិកា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ



អង្គុលិសាសនីយសារ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញាវន្តខែពិពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មាតិកា	ទំព័រ
–	តុទ្ធដីវិច្ឆវត្តិ (តមក) ព្រះមហា ជាំង-ទាត់ រៀបរៀង	១២១១
–	តម្លៃនៃព្រះពុទ្ធសាសនា លោក ស្តើង-ធួរ រៀបរៀង	១២២០
–	ព្រះអភិធម្មបិដក តម្ពីរព្រះពាវាក្នុ (តមក) លោក ប៊ូ-ប៊ូ រៀបរៀង	១២៣៤
–	មធុរសរាហិណី (តមក) សម្តេចព្រះធម្មលិទិត ស្វ៊ី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈីន តិត្ថ	១២៤៨
–	មហោសថជាតក (តមក) លោក អ៊ឹម-កន បន្ទងពីសាស្ត្រាស្វាំករិត ព្រះពុទ្ធវង្ស កឹម-ឆួរ តិត្ថ	១២៥៥
	ផ្នែកអក្សរសាស្ត្រ	
–	រឿងមរណមាត (តមក) លោក ប៊ី-សុវណ្ណ បន្ទងពីសាស្ត្រាស្វាំករិត	១២៦១
–	រឿងខាងសក់ក្រអូប លោក ភៀម-ទឹម រៀបរៀង តាមឯកសារទំនៀមទម្លាប់	១២៧១
–	រឿងសង្គ្រាមរវាងតិង្គកំនិងព្រះព្រហ្ម លោក លាង-ហាប់-អាន រៀបរៀង	១២៧៧
–	រឿងព្រេងប្រទេសអ៊ុយក្រែន ភិក្ខុ ម៉ែន-រៀម ប្រែចាកភាសាអង់គ្លេស	១២៨៣
–	រឿងសាមកុក (តមក) ទាកញ៉ែ ន្ហ-កន ប្រែ	១២៨៤
	ផ្នែកកំណត់ឧទ្ទិសប្រវត្តិការណ៍	
–	វិបាតនុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ទាត់ រៀបរៀង	១៣១៨

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០០

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

sommaire

Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT . 1201
— L'influence du Bouddhisme par M. SDOEUNG-CHHO . 1226
— Prah Abhidhammapitaka(Kathavathu) (suite) par M. BOU-PO 1238
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN . . . 1248
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 1255

Partie littéraire :

— Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1261
—Légende "La dame aux cheveux odoriférants", par M. NHEM-KHEM d'après les renseignements de la Commission des Mœurs et Coutumes 1271
— La lutte entre le crapaud et le maitre du ciel par M. LEANG HAB-AN 1277
—Légende de l'Ukraine traduite de l'anglais par le bonze MEN-RIEM 1283
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1294

Notes et Chroniques :

— Dictionnaire Sanscrit-khmer (suite) par le Vén.PANG-KHAT 1318

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

តុន្ទជីវប្បវត្តិ

(តមក)

ព្រះមហាថ៌ង - ភាត់ រឿបរឿង

៦-ទ្រង់ចូលទៅកាន់ទុរវេលាប្រទេសសេនានិគម

លុះព្រះបរមពោធិសត្វរៀនក្នុងសំណាក់ទូកតាបសកមបុត្រ ចាន សម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈាន ជាសមាបត្តិទី ៨ គឺរូបជ្ឈាន ៤ អរូបជ្ឈាន ៤ ហើយ ឃើញថាមិនមែនជាផ្លូវត្រាស់ដឹង កំទ្រង់មានចំណងទឹងចំពេញមហាបធានវីរិយៈ ដើម្បីសំដែងកំឡាំងសេចក្តីព្យាយាមដ៏ក្រៃដូរបស់ព្រះអង្គ ឲ្យប្រាកដដល់មនុស្សទេវតា ទើបស្តេចចូលទៅកាន់ទុរវេលាប្រទេស ទ្រង់ពិចារណាឃើញភូមិភាគនោះ ជាទីសុខភាពិរម្យសមគួរដល់កុលបុត្រចំពេញព្យាយាម ចំរើនសមណធម៌ស្ងប់រកគុណវិសេស ទើបស្តេចសម្រេចព្រះវិរិយាបថអាស្រ័យធ្វើមហាបធានវីរិយនៅក្នុងទីនោះ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិជកុមារ ថា(១)

"ម្នាលវាធិកុមារ! តថាគតនោះឯង កាលស្វែងរកកុសល

១- ពោធិវាធិកុមារសុត្រ ឯកវត្តូ, ម ម សៀវ -២៤ ទំព័រ ៣៦៨ ។

សន្តិវរបទ ត្រាប់ទៅកាន់ចារឹកក្នុងដៃនមគធៈ ដោយលំដាប់
សំដៅទៅឧរុវេលាប្រទេសសេនានិគម ក្នុងទីនោះ តថាគតបាន
ឃើញភូមិភាគគួរជាទីត្រេកអរ មានដងព្រៃត្រជាក់ត្រជុំ មាន
ស្ទឹងកំពុងហូរមានទឹកដ៏ត្រជាក់ ប្រជាប់ដោយកំពង់រាបស្មើ គួរ
ជាទីរីករាយ ទាំងគោចរគ្រាម ក៏តាំងនៅដោយជុំវិញ តថាគត
ត្រិះរិះថា ទីនេះហ្ន៎ ! ល្មមតាំងសេចក្តីព្យាយាម សំបតក្នុងទី
នោះបាន” ។

*លំដាប់នោះ បព្វជិតចាំង ៥ រូបមាននាមប្រាកដថាបញ្ចវគ្គិយតី
កោណ្ឌញ្ញៈ ១ វប្បៈ ១ ភទ្ទជិ ១ មហានាម ១ អស្សជិ ១ បបួលគ្នាដើរ
ស្វែងរកព្រះបរមពោធិសត្វក្នុងប្រទេសផ្សេង។ ហើយដើរចំណុចតតិយវារ
ជីវិតរៀងៗតាមនិតមជនបទ ទៅជួបព្រះបរមពោធិសត្វនៅក្នុងឧរុវេលា
ប្រទេសនោះឯង បានឃើញព្រះមហាបុរសចំពេញមហាបធានវីរិយៈកំ
តតគ្គាថា ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធតតិយប្រាកដ ដូច្នេះកំ
បបួលគ្នាធ្វើកិច្ចប្រណិបត្តិចំពោះ មានតិរោចោសទ្រាសខែចរវេណជាដើម
ហើយសម្រេចតិរោនៅក្នុងទីនោះ ៧ ។*

៧-ទ្រង់ប្រព្រឹត្តអត្តកិលមថានុយោគ

ព្រះបរមពោធិសត្វស្តេចតាំងព្រះទ័យធ្វើសេចក្តីព្យាយាមយ៉ាងក្រៃដ្ច

មិនបន្ទរបន្តិច មិនមានឧរណាធ្លាប់ដូចបាន ទ្រង់ធ្វើត្រាប់តាមរបស់អន្យតិរ្ថិយ ផ្សេង ។ ដើម្បីល្បងសាកមើល ព្រោះមានបំណងចង់បានត្រាស់ជាព្រះពុទ្ធ ក្រែងបានដួចប្រទះកំពុសលស្ដីរបេះដែលទ្រង់ច្រាំ ដូចដំណើរសេចក្ដីដែលទ្រង់ត្រាស់ចំពោះព្រះសារីបុត្តត្រង់ថា(១)

" ... ម្នាលសារីបុត្ត ! តថាគតផ្គាប់ប្រព្រឹត្តព្រហ្មចរិយៈ(២) ប្រកបដោយអង្គ ៤ គឺ

១- បើនិយាយពីតបៈ តថាគត មានតបៈដ៏ក្រៃលែង, ២- បើនិយាយពីសៅហ្មង តថាគតមានសេចក្ដីសៅហ្មងដ៏ក្រៃលែង, ៣-បើនិយាយពីការខ្ពើមបាប តថាគតខ្ពើមបាបដ៏ក្រៃលែង, ៤-បើនិយាយពីការស្ងប់ តថាគតស្ងប់ដ៏ក្រៃលែង ។

១- តបៈ របស់តថាគតក្នុងព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ នោះដូចម្ដេច គឺតថាគតជាអ្នកអាក្រាត លះបង់មារយាទល្អ(៣) ប្រព្រឹត្តហត្ថាវលេខនប្បដិបត្តិ(៤), ជាអ្នកកាន់វត្តមិនទទួលភត្ត ដែលគេនិមន្តថា « លោកដ៏ចំរើន ចូរបួលមក »,

---

១.មហាសីហនាទសូត្រ សីហនាទវគ្គ-មជ្ឈិម សៀវ ២០, ទំព័រ ២៩១ ។ ២. ព្រហ្មចរិយៈក្នុងទំនេះសំដៅយកសេចក្ដីព្យាយាម ។ ៣- ឈប់បន្ទោរបង់ទន្លាប់ស្លាប់ឥឡូវឈរបរិភោគ ។ ៤- បរិភោគភោជនលើឆ្នាំដៃយកម្រាមភៃកើតណាមក ព្រោះសំគាល់កំណត់ថាជាសត្វ ។

មិនរង់ចាំតាមគេនិមន្តថា « លោកដ៏ចំរើន ! សូមរង់ចាំសិន »,
មិនត្រេកអរនឹងបង្ហាន់ដែលគេកាន់យកមកមុន, មិនត្រេកអរ
នឹងបង្ហាន់ ដែលគេប្រាប់ថាធ្វើចំពោះខ្លួន, មិនត្រេកអរនឹង
បង្ហាន់ដែលគេនិមន្ត, មិនទទួលបង្ហាន់ដែលគេកំពុងដោះដូរ
អំពីឆ្នាំង, មិនទទួលបង្ហាន់អំពីមាត់កញ្ចឹ, មិនទទួលបង្ហាន់
ដែលគេឲ្យត្រង់បន្លោះធរណី, មិនទទួលបង្ហាន់ ដែលគេឲ្យត្រង់
បន្លោះត្បាល់, មិនទទួលបង្ហាន់ដែលគេឲ្យត្រង់បន្លោះអង្រែ, មិន
ទទួលបង្ហាន់របស់មនុស្សដែលកំពុងបរិភោគពីរនាក់, មិនទទួល
បង្ហាន់របស់ស្ត្រីមានគភ៌, មិនទទួលបង្ហាន់របស់ស្ត្រីដែលកំពុង
បំបៅក្មេង, មិនទទួលបង្ហាន់របស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស,
មិនទទួលបង្ហាន់ដែលគេអង្គាសគ្នាធ្វើ, មិនទទួលបង្ហាន់ក្នុងទី
ដែលមានឆ្កែចាំ, មិនទទួលបង្ហាន់ដែលមានរុយចោមរោម, មិន
បរិភោគត្រី, មិនបរិភោគសាច់, មិនផឹកសុរានឹងមេរ័យ, មិនផឹក
ទឹកឃ្មុំត្រាំដោយស្រូវទាំងពួង ។ តថាគតទទួលបង្ហាន់តែក្នុង
ផ្ទះមួយឬបរិភោគភោជនតែមួយពំនូត, ទទួលបង្ហាន់ក្នុងផ្ទះពីរឬ

ចរិភាគភោជនតែពីរពីនូត ។បេ។ ទុន្ទលបង្ហាន់ក្នុងផ្ទះ ពីឬបរិ-
ភោគតែពីពីនូត ។ តថាគតចិញ្ចឹមអត្តភាពដោយបង្ហាន់១ភាជន៍
តូចខ្លះ ដោយបង្ហាន់ ២ ភាជន៍តូចខ្លះ ។បេ។ ដោយបង្ហាន់ ពី
ភាជន៍តូចខ្លះ, ធាន់អាហារវិលង៉ថ្ងៃខ្លះ វិលង៉២ថ្ងៃខ្លះ។បេ។
ធាន់អាហារវិលង៉ពីថ្ងៃខ្លះ, តថាគតប្រកបរឿយៗនូវការបរិភោគ
ភត្តតាមលំដាប់ថ្ងៃយ៉ាងនេះ រហូតដល់វិលង៉កន្ទះខ្លះ ដូចសំ
ដែងមកនេះឯង ។ តថាគតមានបន្ទៃជាអាហារខ្លះ, មានស្រូងជា
អាហារខ្លះ, មានស្មៅគៃលលកជាអាហារខ្លះ, មានចំនៀះស្បែក
ដែលគេបៀរចោលជាអាហារខ្លះ, មានសាយជាអាហារខ្លះ,
មានកណ្ណកជាអាហារខ្លះ, មានបាយក្តាំងជាអាហារខ្លះ, មានម្សៅ
ជាអាហារខ្លះ. មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារ
ខ្លះ, មានមើមគំនុំងផ្លែជាអាហារខ្លះ. តែងបរិភោគផ្លែឈើដែលជ្រុះ
ឯងខ្លះ ។ តថាគតប្រើប្រាស់សំពត់ដែលត្បាញដោយសំបកឆៃ
ខ្លះ, ប្រើប្រាស់សំពត់ត្បាញលាយបម្រុះគ្នាខ្លះ, ប្រើប្រាស់សំពត់
ដែលគេរុំសាកសពខ្លះ ប្រើប្រាស់សំពត់បំសុកូល[1]ខ្លះ ប្រើ

---

១ កំណាត់សំពត់ដែលគេលាស្លៀកដែរនឹង ។

ប្រាស់សំពត់សំបកឈើខ្លះ, ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ,ប្រើប្រាស់សំពត់ដៃលក្រងដោយស្បូវខ្លះ ប្រើប្រាស់សំពត់ដៃលក្រងដោយសំបកក្រចៅខ្លះ, ប្រើប្រាស់សំពត់ដៃលក្រងដោយសំបកផ្ទៃឈើខ្លះ,ប្រើប្រាស់សំពត់កម្ពលដៃលត្បាញដោយសក់មនុស្សខ្លះ,ប្រើប្រាស់សំពត់ដៃលត្បាញដោយរោមកន្ធុយសត្វខ្លះ, ប្រើប្រាស់សំពត់ដៃលត្បាញដោយស្លាបមៀមខ្លះ, កាន់វត្តទុកសក់ធំងពុកមាត់ពុកបង្កាខ្លះ, ប្រព្រឹត្តតៃឈរមិនអង្គុយខ្លះ, អង្គុយប្រហោងប្រកបរឿយ ។ ឆ្លូវសេចក្តីព្យាយាមប្រហោងខ្លះ,ដេកលើបន្ទាសម្រេចការដេកលើបន្ទាខ្លះ, ប្រកបរឿយ ។ ឆ្លូវសេចក្តីព្យាយាមចុះត្រាំក្នុងទឹក (ដើម្បីបន្សាត់បាប) ក្នុងមួយថ្ងៃ ៣ ដង(១) ប្រកបរឿយ ។ ឆ្លូវសេចក្តីព្យាយាមដុតកំៈជាឆ្លូវកាយប្រើនប្រការ មានសភាពយ៉ាងនេះដូច្នេះឯង ។ ម្នាលសារីបុត្ត ! នេះជាវត្តរបស់អ្នកមានតបៈនៃតថាគត ។

២- សេចក្តីសៅហ្មងរបស់តថាគត ក្នុងព្រហ្មចរិយៈ

---

១ ពេលព្រឹកព្រហាមម្តង, ថ្ងៃត្រង់ម្តង ល្ងាចម្តង ។

ធម៌ប្រកបដោយអង្គ ៤ នេះដូច្នេះ មន្ទិលគឺធូលីរាប់ដោយឆ្នាំដ៏ច្រើនដែលជាប់នៅនឹងកាយ ក៏ក្លាយទៅជាក្រមរស្រទាប់ៗ ។ ម្នាលសារីបុត្ត ! ដង្កត់ដើមដង្កោ ដែលតាំងនៅរាប់ដោយឆ្នាំដ៏ច្រើនក៏កើតជាក្រមរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចមន្ទិលគឺធូលីរាប់ដោយឆ្នាំដ៏ច្រើន ដែលជាប់នឹងកាយតថាគត ក៏ក្លាយទៅជាក្រមរដូច្នេះឯង ។ តថាគតមិនត្រិះរិះថា- " ឱហ្ន៎ ! អាត្មាអញ គប្បីយកបាតដៃដុសមន្ទិលគឺធូលីនេះចេញដូច្នេះទើយ ។ ម្នាលសារីបុត្ត ! សូម្បីតែគំនិតថា " ជនទាំងឡាយ ដទៃគប្បីយកបាតដៃដុសក្អែលរបស់តថាគតនេះដូច្នេះក៏មិនមានដល់តថាគតទើយ " ម្នាលសារីបុត្ត ! នេះជាវត្តដែលសៅហ្មងរបស់តថាគត ។

៣- វត្តទាងទ្វើមបាបរបស់តថាគត ក្នុងព្រហ្មចរិយៈប្រកបដោយអង្គ ៤ នេះដូច្នេះ តថាគតនោះឯង ឈានទៅមុខមានស្មារតី បិយក្រោយក៏មានស្មារតី· តថាគតដំកល់សេចក្តី អា

ណាតបំពោះដំណាក់ទឹក[1]ដែរ។ បានចម្រកថា «តថាគតមិនបានឃើញ
ពួកសត្វ។ គឺដំណាក់ទឹក ដែលដក់ជាប់នៅក្នុងទីផ្សេងៗឡើយ
ឆ្ងល់តែសេចក្តីវិនាសទេឬ។ ម្នាលសារីបុត្ត! នេះឯងជាវត្តនៃការ
ខ្ជិលច្រអូស របស់តថាគត។

៤-វត្តខាងការស្ងប់ស្ងាត់របស់តថាគត ក្នុងព្រហ្មចរិយៈ
ប្រកបដោយអង្គ ៤ ដូច្នេះ តថាគតនោះឯង តែងចូលសំដៅ
ទៅនៅអាស្រ័យក្នុងព្រៃរំលោងណាមួយ កាលណាបើតថាគត
ឃើញគង្វាលគោក្តី គង្វាលសត្វពិញ្ចឹមក្តី អ្នកកាប់ស្មៅក្តី
អ្នកកាប់ឫសក្តី អ្នកការបរក្នុងព្រៃក្តី តថាគតក៏បញ្ឈប់អំពីព្រៃទៅ
កាន់ព្រៃ, បញ្ឈប់អំពីព្រៃស្បាត់ទៅកាន់ព្រៃស្បាត, បញ្ឈប់អំពីទី
ទាបទៅកាន់ទីទាប, បញ្ឈប់អំពីទីទួលទៅកាន់ទីទួល ព្រោះ
តថាគត បានអធិដ្ឋានថា «សូមកុំឱ្យជនទាំងឡាយនោះ បាន
ឃើញតថាគត ទាំងតថាគតសោត ក៏កុំឱ្យឃើញជនទាំងឡាយ

១-ដំណាក់ទឹក ក្រួស, ថ្ម កំណាត់ឈើ ដំងដំឡូងដ៏ជាដើម ពួកនេះត្រូវបញ្ញត្តថាជាសត្វក្នុង។ ។

នោះឡើយ" ប្រៀបដូចម្រឹគឃើញមនុស្សទាំងឡាយតែងរត់អំ
ពីព្រៃឆ្ងល់ទៅកាន់ព្រៃ. ចេញអំពីព្រៃស្បាត ឆ្ងល់ទៅកាន់ព្រៃ
ស្បាត, ចេញអំពីទីទាបឆ្ងល់ទៅកាន់ទីទាប, ចេញអំពីទីទួល
ឆ្ងល់ទៅកាន់ទីទួល យ៉ាងណាមិញ ម្នាលសារីបុត្ត ! តថាគត
ក៏យ៉ាងនោះដែរ ម្នាលសារីបុត្ត ! នេះឯងជាវត្តខាងសេចក្តី
ស្ងប់ស្ងាត់ របស់តថាគត ។

ម្នាលសារីបុត្ត ! តថាគតជាអ្នកវារដោយជង្គង់ ៤ ឆ្ងល់ទៅ
រកក្រោលគោដែលមានគោចេញហើយ មានគង្វាលគោចៀស
ចេញទៅហើយៗ ស៊ីអាចម៍របស់ក្មួនគោជំទង់ដែលនៅចោមមេៗ
ម្នាលសារីបុត្ត ! អ្នកត្រឹងការីសរបស់តថាគត មិនទាន់អស់
ជារាបណា តថាគតក៏ស៊ីនូវអ្នកត្រឹងការីសរបស់ខ្លួនឯង ជារាប
នោះៗ ម្នាលសារីបុត្ត ! នេះឯងជាវត្តខាងភោជនយ៉ាងចំឡែក
ធំរបស់តថាគត ។

ម្នាលសារីបុត្ត ! តថាគតចូលទៅអាស្រ័យនៅក្នុងដងព្រៃមួយដែលគួរស្បើម, សេចក្តីត្រាស់ដឹងដងព្រៃគួរស្បើមនោះតែងមាន, បុគ្គលណាន៏មួយមិនទាន់ប្រាសចាករាគៈទេ ចូលទៅកាន់ដងព្រៃនោះ ប្រែនតែត្រឹមត្រូវបរោម រាត្រីទាំង ៨ ជាបន្តោះខែមាឃនឹងខែផល្គុនក្នុងហេមន្ត(១)រដូវ ជាសម័យធ្លាក់ទឹកសន្សើមដ៏ត្រជាក់ ក្នុងរាត្រីមានសភាពដូច្នេះ តថាគតនៅក្នុងទីវាលក្នុងពេលយប់, នៅក្នុងដងព្រៃក្នុងវេលាថ្ងៃ ខែជាខាងបុងគិម្ហរដូវ តថាគតនៅក្នុងទីវាលក្នុងវេលាថ្ងៃ នៅក្នុងដងព្រៃក្នុងវេលាយប់ ។ ម្នាលសារីបុត្ត ! អើក៏គាថាដែលគួរអស្ចារ្យនេះ ដែលតថាគតមិនដែលបានស្តាប់ក្នុងកាលពីមុនទេ, ស្រាប់តែភ្លឺច្បាស់ប្រាកដ ដល់តថាគតថា :

សោ តន្តោ សោ សិនេរោ ឯកោ

ឯកោ កីសនទោ វនេ

១-គឺខាងបុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុន ៤ រាត្រី រួមជា ៨ រាត្រី ។

ឧត្តោ ឧ ចត្តំមាសំនោ

វសេ បសុតោ មុនីតិ ។

ប្រែថា: "អ្នកប្រាជ្ញដែលខ្វល់ខ្វាយក្នុងកិរិយាស្វែងរក (នូវ
សេចក្តីបរិសុទ្ធិ) អ្នកប្រាជ្ញនោះត្រូវតែក្តៅ អ្នកប្រាជ្ញនោះត្រូវ
តែត្រជាក់ម្នាក់ឯង ជាអ្នកត្រូវតែនៅក្នុងព្រៃ គួរស្បើមតែម្នាក់
ឯង អាក្រាតមិនបួលទៅរកភ្លើងទៀយ ។

ម្នាលសារីបុត្ត ! តថាគតនោះសម្រេចនូវឥរិយាបថដេក
ក្នុងព្រៃស្មសាន កើយលើឆ្អឹងសាកសពទាំងឡាយ ។ ចំណែក
ពួកក្មេងឃ្វាលគោ នាំគាបួលទៅជិតតថាគត ហើយស្មោះ
ដាក់ខ្លះ នោមដាក់ខ្លះ យកដីរោយដាក់ខ្លះ យកអំកាប់ឈើ
មករុកក្នុងរន្ធត្រចៀក[1]ខ្លះ តថាគតមិនដែលធ្វើចិត្តឲ្យអាក្រក់
បំពោះពួកក្មេងឃ្វាលគោទាំងនោះទៀយ ។ ម្នាលសារីបុត្ត !
នេះឯងឈ្មោះថា ជាវត្តខាងការនៅប្រកបដោយខុបេក្ខា របស់

១- ពួកក្មេងបង្កំត្បូពោធិសត្វដ៏ឃោរឃៅ ហើយទ្រង់មិនដឹងឃោរឃៅ ទើបពួកក្មេងវាធ្វើអំពើ
អាក្រក់យ៉ាងនេះ ។

តថាគត ។

ម្នាលសារីបុត្ត ! មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ យល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិ កើតមានព្រោះអាហារ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏ស៊ីផ្លែពន្រ្លឹះ ស៊ីលំអិតនៃផ្លែពន្រ្លឹះ ផឹកទឹកដែលប្របាច់លាយដោយផ្លែពន្រ្លឹះ បរិភោគនំដែលធ្វើដោយផ្លែពន្រ្លឹះប្រើនខ្លះ ។ ម្នាលសារីបុត្ត ! តថាគតធ្លាប់យកផ្លែពន្រ្លឹតែមួយប៉ុណ្ណោះមកធ្វើជាអាហារ. ម្នាលសារីបុត្ត ! ប្រហែលអ្នកមានសេចក្តីយល់យ៉ាងនេះថា « ផ្លែពន្រ្លឹកុងសម័យនោះជាផ្លែធំៗណាស់ ដំណើរនុ៎ះ អ្នកមិនគួរយល់យ៉ាងនោះទេ ព្រោះថាផ្លែពន្រ្លឹកុងកាលឥឡូវនេះ មានទំហំប៉ុនីណា កុងកាលពីដើមក៏មានទំហំប៉ុណ្ណោះដែរ » ។ ម្នាលសារីបុត្ត ! កាលតថាគត យកផ្លែពន្រ្លឹតែមួយប៉ុណ្ណោះមកធ្វើជាអាហារ កាយក៏ដល់នូវភាវៈស្គាំងស្គមហួសប្រមាណ អវយវៈតូចធំរបស់តថាគត ក៏ដូចជាំង

វល្លិឈ្មោះអុសីតិ (ដែកគន់ ឬលៃនពែន) ឬដូចជាថ្នាំងវល្លិកាលា (វល្លិអណ្តាតគ្រួត) ទ្រគាករបស់តថាគតក៏ដូចជាជើងសត្វទុដ្ឋ, ឆ្អឹងខ្នងរបស់តថាគតរគឹមរគាមដូចជាខ្សែដែលគេវេញ. ឆ្អឹងជំនីរទាំងទ្បាយរបស់តថាគត រគឹមរគាមដូចជាបង្គងសាលាចាស់ដែលរខេករខាក, ប្រស្រីភ្នែករបស់តថាគត ក៏ខ្លួងជ្រៅទៅក្នុងរណ្តៅភ្នែក ដូចជាទឹកដែលជ្រៅខ្លួងទៅក្នុងអណ្តូងទឹកដ៏ជ្រៅ, ស្បែកក្បាល របស់តថាគតក៏រួបរឹតស្ងួតស្រពោន ដូចជាផ្លែឪឡោងព្រៃដែលគេកាត់ទាំងខ្ចី តែងរួបរឹតស្ងួតដោយខ្យល់និងកំដៅថ្ងៃ ។ ម្នាលសារីបុត្ត ! តថាគតស្មាបស្បែកពោះ ហើយចាប់ទៅ ត្រូវទ្រនុងឆ្អឹងខ្នងវិញ, តថាគតស្មាបទ្រនុងឆ្អឹងខ្នង ហើយចាប់ទៅត្រូវស្បែកពោះវិញ ស្បែកពោះរបស់តថាគតជាប់គ្នាឆ្អឹងទ្រនុងឆ្អឹងខ្នង ។ ម្នាលសារីបុត្ត ! តថាគតបន្ទោបង់វិច្ចៈឬទឹកមូត្រក៏ដួលផ្កាប់មុខទៅលើដែនដី ព្រោះតែអាហារតិចនោះឯង ។ ម្នាលសារីបុត្ត ! តថាគតកាលធ្វើកាយនោះ

ឯងឲ្យបានស្រួល ក៏យកដៃស្ទាបខ្លួន រោមទាំងឡាយដែលមានគល់ស្អុយក៏ជ្រុះបញ្ចាកកាយព្រោះតែអាហារ[1] តិចនោះឯងៗ

៨- សេចក្តីឧបមា ៣ យ៉ាង

កាលដែលព្រះបរមគោតមសត្ថុកំពុងបំពេញមហាបធានវិរិយៈយ៉ាងតឹងរឹងនេះ មានសេចក្តីឧបមា ៣ ប្រការកើតប្រាកដឡើងដល់ព្រះអង្គ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិកជកុមារ[2]ថា

" - - - ម្នាលរាជកុមារ ! ឧបមា ៣ ប្រការ មិនស្រួវដាអស្ចារ្យណាស់ណា ដែលតថាគត មិនធ្លាប់បានស្តាប់ឮមកពីមុនក៏បានកើតប្រាកដ ដល់តថាគត ។

ឧបមា ទី ១ ម្នាលរាជកុមារ ! ប្រៀបដូចឈើស្រស់ប្រកបដោយជ័រ ដែលបុគ្គលត្រាំទុកនៅក្នុងទឹក ហើយបុរសគិតថា "យើងនឹងកាន់យកឈើពំនួតខាងលើ មកឰតភ្លើង

១- តពីនោះទៅមានសេចក្តីដូចគ្នាគ្រាន់តែថ្វាស់ការបរិភោគ ដូចជាទ្រង់បរិភោគសណ្តែកបាយ, ល្ង អង្ករកុំណ្ណោះ, ព្រះអង្គបានល្បងធ្វើមើលត្រាប់ដែរ ថ្វាស់ប្តូរគ្នា ៣ ៗ ទៅ, លុះទ្រង់ឃើញថាមិនជាប្រយោជន៍ដល់ការត្រាស់ដឹងព្រះអង្គទេ ទ្រង់លះបង់ចោលទៅ ។ រឿងទាំងនេះសំដែងឲ្យឃើញថា ព្រះអង្គទ្រង់បានប្រព្រឹត្តវត្តនីត្រួតដែលហៅថាអត្តកិលមថានុយោគត្រាប់ ។ យ៉ាង ដល់រំលេចបានត្រាស់ ទ្រង់ចង់សេចឲ្យលះបង់មិនគួរប្រតិបត្តិតាម ។

២ ពោធិរាជកុមារសូត្រាជវគ្គ ម.ម. សៀវ. ២៤ ទំព័រ ៣៦៩ ។

នឹងធ្វើតេជោជាតុឲ្យកើតប្រាកដឡើងបាន ។ ។ ម្នាលរាជ-
កុមារ! អ្នកសំគាល់សេចក្តីនោះដូចម្តេច ? បុរសនោះគប្បីពួត
ឲ្យកើតភ្លើង ធ្វើឲ្យតេជោជាតុកើតឡើងបានឬទេ ? បពិត្រ
ព្រះអង្គដ៏ចំរើន ! មិនកើតទេ ព្រោះឈើឯណោះនៅស្រស់
ប្រកបដោយផ្សែ ថែមទាំងឈើនោះត្រាំនៅក្នុងទឹកផង, បុរស
នោះ គ្រាន់តែបានចំណែកនៃសេចក្តីលំបាក បង្អៀតបង្អល់តែ
ប៉ុណ្ណោះ ។ ម្នាលរាជកុមារ ! សេចក្តីនេះក៏ឧបមេយ្យ
ដូច្នោះដែរ ពួកសមណព្រាហ្មណ៍ណាមួយ មិនបានបៀស
បេញ្ជាចាកកាមដោយកាយ សមណព្រាហ្មណ៍ទាំងនោះ ថែម
ទាំងមានសេចក្តីពេញចិត្តក្នុងកាម ស្នេហាក្នុងកាម ជ្រប៉ិកក្នុងកាម
ស្រេកឃ្លានក្នុងកាម ក្រហល់ក្រហាយព្រោះកាមក្នុងកាមទាំង
ឡាយ កាមនោះជារបស់ដែលសមណព្រាហ្មណ៍ទាំងនោះមិន
ទាន់លះបង់ដោយប្រពៃ មិនទាន់ធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ
ឡើយផង ប្រសិនបើពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ

បានទទួលនូវវេទនា ជាទុក្ខក្តៀវក្តាខ្លោចផ្សា កើតអំពីសេចក្តីព្យាយាម ។ ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបានទេ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានរងទុក្ខវេទនា ដ៏ក្តៀវក្តាខ្លោចផ្សា ដែលកើតអំពីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ទាំងនោះមិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានទេ ។ ម្នាលវាជិកុមារ ! នេះឯងជាឧបមាដំបូង មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកពីមុន មកប្រាកដ ដល់តថាគត ។

ឧបមាទី ២ ម្នាលវាជិកុមារ ! ដូចយើស្រស់ប្រកបដោយជំរ ដែលគេដាក់លើគោក នៅឆ្ងាយពីទឹក បុរសគិតថា "យើងនឹងតាន់យកឈើពំនូតខាងលើ មកពួតភ្លើង ធ្វើតេជោធាតុឲ្យកើតប្រាកដទេ" ។ ម្នាលវាជិកុមារ ! អ្នក

សំគាល់សេចក្តីនោះដូចម្តេច ? បុរសនោះគប្បីពួតឲ្យកើតភ្លើង ធ្វើតេជោធាតុឲ្យកើតបានឬទេ ? បពិត្រព្រះអង្គដ៏ចំរើន ! មិនកើតទេ ព្រោះឈើឯណោះសើស្រស់ ប្រកបដោយជំរាតំមែន តែគេដាក់លើគោកនៅឆ្ងាយពីទឹក, ឯបុរសនោះ គ្រាន់តែបានភាគនៃសេចក្តីលំបាកបង្តៀតបង្តល់ប៉ុណ្ណោះ ។ ម្នាលរាជកុមារ ! សេចក្តីឧបមេយ្យ ក៏ដូច្នោះឯង ពួកសមណព្រាហ្មណ៍ឯណាមួយ បៀសចេញចាកកាម ដោយកាយហើយ តែសមណព្រាហ្មណ៍ទាំងនោះ នៅមានសេចក្តីពេញចិត្ត ក្នុងកាម ស្នេហាក្នុងកាម ជ្រៃប់ក្នុងកាម ស្រេចឃ្លានក្នុងកាម ក្រហល់ក្រហាយព្រោះកាមក្នុងវត្ថុកាមទាំងឡាយ, កាមទាំងនោះ សមណព្រាហ្មណ៍ទាំងនោះ មិនទាន់លះបង់ដោយប្រពៃ មិនទាន់ធ្វើឲ្យស្ងប់ស្ងាត់ដោយប្រពៃ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ បានរងវេទនាជាទុក្ខដ៏ក្តៅក្រហាំងខ្លាំងផ្សា ដែលកើតអំពីព្យាយាម ក៏ដោយ ពួកសមណព្រាហ្មណ៍ទាំងនោះ

ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ដ៏ប្រសើរបានឡើយ ។ បើទុកជាពួកសមណព្រាហ្មណ៍ដ៏បរិសុទ្ធទាំងនោះ មិនបានរងវេទនា ជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សាដែលកើត អំពីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។

ឧបមាទី ៣ ម្នាលរាជកុមារ ! ដូចឈើស្វត ជាឈើពុក ដែលគេដាក់លើគោកនៅឆ្ងាយពីទឹក, បុរសគិតថា «យើងនឹងកាន់យកឈើពិន្លតខាងលើមកពួតភ្លើង ធ្វើតេជោធាតុឲ្យកើតប្រាកដឡើង» ។ ម្នាលរាជកុមារ ! អ្នកសំគាល់សេចក្តីនោះដូចម្តេច ? បុរសនោះគប្បីពួតឲ្យចេញភ្លើង ធ្វើតេជោធាតុឲ្យកើតបានឬទេ ? បពិត្រព្រះអង្គដ៏បំរើន ! យ៉ាងនោះទើបកើតបាន, ព្រោះឈើស្វតឯណោះជាឈើពុក ថែមទាំងឈើនោះសោត គេដាក់លើគោកនៅឆ្ងាយពីទឹកផង ។ ម្នាល

រាជកុមារ! សេចក្តីឧបមេយ្យក៏ដូច្នោះឯង ពួកសមណព្រាហ្មណ៍ណាមួយ បៀសចេញចាកកាមដោយកាយហើយ ទាំងមិនមានសេចក្តីពេញចិត្តក្នុងកាម ស្នេហាក្នុងកាម ជ្រប៉ិះក្នុងកាម ស្រេកឃ្លានក្នុងកាម ក្រហល់ក្រហាយ ព្រោះកាមក្នុងវត្ថុកាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ក៏បានលះបង់ដោយប្រពៃ បានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ នូវរាគៈកាមនោះឡើងខាងក្នុង ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏បំរើនទាំងនោះ បានរងវេទនាជាទុក្ខដ៏ក្តៀវក្លាខ្លោចផ្សា ដែលកើតអំពីព្យាយាមពិតមែន ប៉ុន្តែពួកសមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះញាណដ៏ប្រសើរបាន ។ បើទុកជាពួកសមណព្រាហ្មណ៍ដ៏បំរើនទាំងនោះ មិនបានរងវេទនាជាទុក្ខដ៏ក្តៀវក្លាខ្លោចផ្សា ដែលកើតអំពីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិញ្ញនដ៏ប្រសើរបាន ។

(នៅមានត)

តម្លៃនៃព្រះពុទ្ធសាសនា

លោក ស្តើង-ឆូរ ប្រមូលរៀបរៀង

អស់លោកអ្នកអានជាទីគោរពទាំងឡាយ !

វេលានេះ ខ្ញុំសូមរៀបរាប់អំពីតម្លៃនៃព្រះពុទ្ធសាសនាដែលខ្ញុំបានអាន បានយល់តាមសតិបញ្ញាដូចតទៅនេះ ៖

ព្រះពុទ្ធសាសនានេះ, គួរអស់លោកអ្នកអានទាំងឡាយជ្រាបថា ជាពាក្យប្រៀនប្រដៅមានតម្លៃយ៉ាងក្រៃលែង ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សុទ្ធតែជាពាក្យប្រៀនប្រដៅដ៏កន្ទាំមនុស្សសត្វព្រមទាំងទេពតា ឲ្យដើរត្រង់ទៅរកសេចក្តីសុខ-ចំរើន ទាំងក្នុងលោកនេះនឹងលោកខាងមុខ ។ បណ្តាពាក្យប្រៀនប្រដៅទាំងនោះ មានពាក្យប្រៀនប្រដៅខ្លះបានត្រូវគ្នានឹងសុភាសិតអ្នកប្រាជ្ញទាំងឡាយ អំពីបុរាណកំមាន, មានពាក្យប្រៀនប្រដៅខ្លះទៀត ជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វព្រមទាំងទេពតាទាំងអស់; ក្រៅតែអំពីព្រះសម្ពុទ្ធជាម្ចាស់ ឥតមានអ្នកណាម្នាក់ អាចរកគិតបង្កើតឡើងបានដូចនោះកំមាន ។

ព្រះពុទ្ធសាសនា មានឧត្តមដំបូងនៅក្នុងមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌាសម័យសព្វថ្ងៃនេះ ។ នៅក្នុងមជ្ឈិមប្រទេសទាំងមូល, កាលដែល

មិនមានមានព្រះពុទ្ធសាសនាទៅឡើយ មនុស្សទាំងអស់ តែងទាំងគ្នា ប្រព្រឹត្តប្រតិបត្តិ តាមលទ្ធិសាសនាព្រាហ្មណ៍ខ្លះ, តាមលទ្ធិសាសនាឯទៀត ។ ខ្លះ ដែលជាផ្លូវប្រតិបត្តិតឹងពេកកំមាន ធូរពេកកំមាន ដូចយ៉ាងប្រព្រឹត្តប្រតិបត្តិបង្អត់អាហារខ្លួន ឲ្យលំបាកវេទនាយ, ប្រព្រឹត្តខ្ទុកសក់ឲ្យវែងអន្ទាយ, ប្រព្រឹត្តដេកលើបន្ទា, ប្រព្រឹត្តអាងភ្លើងក្នុងវេលាថ្ងៃនាផ្លូវក្តៅដាដែម ដែលសុទ្ធតែជាសេចក្តីប្រតិបត្តិឥតប្រយោជន៍ទាំងអស់ ក៏ឥតមានមនុស្សណាម្នាក់គិតយើញថា ជាសេចក្តីប្រតិបត្តិឥតប្រយោជន៍ ហើយនឹងរើគិនគិតកែផ្លូវប្រតិបត្តិជាថ្មីទៀតនោះសោះឡើយ ។

លុះដល់ព្រះសម្មុទ្ធជាម្ចាស់ ចាន់ត្រាស់ដឹងឡើងក្នុងលោកព្រះអង្គ ចាន់សំដែងធម៌ទេសនាជាដំបូង ចំពោះបញ្ចវគ្គិយកុក្ខ ដើម្បីកែប្រែសេចក្តីប្រតិបត្តិទាំងនោះ គឺពន្យល់មិនឲ្យប្រតិបត្តិតាម ខ្លួវសេចក្តីប្រតិបត្តិឥតប្រយោជន៍ទាំងនោះ ហើយឲ្យត្រឡប់មកប្រតិបត្តិតាមបែប ដែលព្រះអង្គទ្រង់យល់ថាជាផ្លូវប្រតិបត្តិមានប្រយោជន៍ពិត ។ នោះវិញ ។ ធម្មទេសនាដែលព្រះអង្គចាន់សំដែង ជាដំបូងនោះមានសេចក្តីថា :

ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិដ៏លាមកអាក្រក់ទាំងពីរយ៉ាងនេះ, បព្វជិតមិនគួរសេព គឺថាមិនត្រូវប្រតិបត្តិឡើយ ។ សេចក្តីប្រតិបត្តិ

អាក្រក់ចាំងពីរយ៉ាងនោះគឺ កាមសុខល្ងីកាឧយោគ ការប្រកបខ្លួនឲ្យជាប់ជំពាក់ដោយសេចក្តីសុខក្នុងកាមចាំង១យ ១, អត្តកិលមថានុយោគ ការប្រកបសេចក្តីលំបាកដល់ខ្លួន ឲ្យខឿយលំបាកឥតប្រយោជន៍ ១ ។ សេចក្តីប្រតិបត្តិចាំង ២ យ៉ាងនេះ ជាអំពើបោកបាបជាការនាំឲ្យសាបសូន្យ មិនជាសេចក្តីចំរើនទេ; មិនតែប៉ុណ្ណោះ ថែមចាំងជាហេតុនាំបណ្តាលឲ្យបានសេចក្តីទុក្ខព្រួយថែមទៀត ។

ឯតេ តេ កិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា ម្នាលភិក្ខុចាំង១យ សេចក្តីប្រតិបត្តិជាកណ្តាលដែលមិនជាប់អាស្រ័យនូវសេចក្តីប្រតិបត្តិដ៏លាមក អាក្រក់ចាំង ២ យ៉ាងនោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតប្រាជ្ញា ឲ្យកើត សេចក្តីដំងប្លាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងត្រៃលោក ដើម្បីសេចក្តីដឹងល្អ ដើម្បីព្រះនិព្វាន ។

សេយ្យថីទំ សេចក្តីប្រតិបត្តិជាកណ្តាលនោះតើដូចម្តេចខ្លះ ?

សេចក្តីប្រតិបត្តិជាកណ្តាលនោះ គឺធម៌ដែលគួរស្វែងរកមានអង្គ ៨ ហៅថា អដ្ឋង្គិកមគ្គ ជាគ្រឿងចេញផុតចាកសត្រូវគឺកិលេស ។ អដ្ឋង្គិកមគ្គនោះគឺ: សម្មាទិដ្ឋិ ប្រាជ្ញាយល់ត្រូវ ១, សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ ១, សម្មាវាចា សំដីនិយាយត្រូវ ១ សម្មាកម្មន្តោ

ការដ្ឋាត្រូវ ១ សម្មាគាជីវៈ ការចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមៈ សេចក្តីព្យាយាមត្រូវ ១ សម្មាសតិ សេចក្តីរលឹកត្រូវ ១ សម្មាសមាធិ កិរិយាដំកល់ចិត្តត្រូវ ១ ។

មានធម៌ជាតុទ្ធសាសនាថ្នាក់ខ្ពស់ទៀត ហៅថា សច្ចធម៌ ជាធម៌ប្រកាសនូវសេចក្តីពិត ជាធម៌កំចាំងនឹងគំនិតប្រាជ្ញារបស់មនុស្សខេតតាំងអស់, កាលមុនដែលពុំទាន់មានព្រះពុទ្ធសាសនានោះ ឥតមានអ្នកណាមួយចេះប្រដៅគ្នាឲ្យយល់ពិតដូចជាសច្ចធម៌នេះឡើយ, ប៉ើទុកជាមានបុគ្គលអ្នកឃើញខ្លះ ក៏ឃើញនោះត្រាន់តែត្រិល ។ មិនច្បាស់លាស់, លុះដល់ព្រះពុទ្ធបានត្រាស់ដឹងឡើង ទើបព្រះអង្គសំដែងអំពីសច្ចធម៌នោះ ឲ្យអស់មនុស្សខេតតាំងអស់ បានស្គាល់ច្បាស់ប្រែនគ្នាឡើង ហៅថា អរិយសច្ច ។ អរិយសច្ចនោះមាន ៤ យ៉ាងគឺ:

១- ទុក្ខំ ការកើត, ការចាស់កំណើត, ការកើតប្រាកដនៃខន្ធប្រាំ ជាទុក្ខ ១ ឈ្មោះថាជាតិទុក្ខ; ជរា គឺការចាស់ទ្រុឌទ្រោមគ្រាំគ្រានៃខន្ធប្រាំជាទុក្ខ ១ ឈ្មោះថាជរាទុក្ខ; សេចក្តីស្លាប់ក៏ជាទុក្ខ ១ ឈ្មោះថាមរណៈទុក្ខ; សេចក្តីស្តាយស្រណោះអាឡោះអាល័យ ក្តៅក្តួលខាងក្នុង ព្រោះសេចក្តីវិនាសនៃញាតិសន្តាន ទ្រព្យធនគ្លួស្រករគ្រួសារជាដើម ជាទុក្ខ ១ ដែរឈ្មោះថាសោកទុក្ខ; សេចក្តីខ្សឹកខ្សួលយំសង្រេងសង្រែ

អាល័យ ញាតិសន្ដានទ្រព្យធនគួរស្រែករត្រែសារជាដើម ដែលវិនាសស្ងាប់ ឬត់ចង់ៗ ជាទុក្ខ ១ ឈ្មោះថា បរិទេវទុក្ខ; ជម្ងឺតាត់តើតមានក្នុងកាយ ធ្វើឲ្យលំបាករូបកាយ ជាទុក្ខ ១ ឈ្មោះថាទុក្ខទុក្ខ; សេចក្ដីក្ដួចចិត្ត លំបាកចិត្ត ជម្ងឺតើតអំពីចិត្ត ជាទុក្ខ ១ ឈ្មោះថាទោមនស្សទុក្ខ; សេចក្ដីខឹងក្រោធពាក្យ តើតអំពីសេចក្ដីលំបាកចិត្តខ្លាំងពេក ដោយហេតុវិនាសនៃញាតិសន្ដាន ទ្រព្យធនគួរស្រែករត្រែសារជាដើម រួមសេចក្ដីថា ការតាន់តឹងក្នុងចិត្ត បង្អៀតចង្អល់ចិត្តជាទុក្ខ ១ ឈ្មោះថា ឧបាយាស.ទុក្ខ; ការជួបប្រទះនូវសត្វ (ឬនដល់រូបមនុស្សសត្វខ្លួនៗ) ឥតសង្ហារ (ឬនដល់រូប-សំខ្លែង.ក្នុង វស.សម្ផស្ស) មិនជាទីស្រឡាញ់ ជាទុក្ខ ១ ដែរឈ្មោះថា អប្បិយសម្បយោគទុក្ខ; ការព្រាត់ប្រាសនឹងសពាកសត្វ ឥតសង្ហារជាទីស្រឡាញ់ ជាទុក្ខ ១ ឈ្មោះថា បិយវិប្បយោគទុក្ខ; បុគ្គលប្រាថ្នានូវវត្ថុណា ហើយមិនបាននូវវត្ថុនោះដូចប្រាថ្នា អំពើនោះជាទុក្ខ ១ ឈ្មោះថាឥច្ឆិតាលាភកទុក្ខ; បើនិយាយឲ្យខ្លី ឧបាទានក្ខន្ធទាំង ៥ សុទ្ធតែជាទុក្ខទាំងអស់ហៅថា ឧបាទានក្ខន្ធទុក្ខ ។

២- ទុក្ខសមុទយោ ហេតុដែលជាមេនាំបណ្ដាលឲ្យតើតសេចក្ដីទុក្ខនោះ ហៅថាអរិយសច្ច ឬនខាងតណ្ហាជាធម្មជាតិតាក់តែងនូវកពថ្មីជាប្រក្រតី ប្រកបដោយសេចក្ដីត្រេកត្រអាល ត្រេកអរក្នុងកពនោះៗ

ប្ដូរគឺអារម្មណ៍នោះ ។ ។ តណ្ហានោះមាន ៣ យ៉ាងគឺ: កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

៣- ឧក្កដិកៈនោ ជម្ងឺជាគ្រឿងលេតម៉ងសល់នៃតណ្ហានោះឯង ហៅថាអរិយសច្ច គឺសេចក្ដីសោយរលាចៅ ទីដ៏សេចក្ដីលេតំៅដោយមិនសល់នៃកិលេស មានតណ្ហាជាដើមនោះ ។

៤- ឧក្កដិកៈនតាមិនិ បដិបទា សេចក្ដីប្រតិបត្តិធ្វើអ្នកដែលប្រតិបត្តិតាម ឲ្យដល់នូវខុក្ខនិរោធ ហៅថាអរិយសច្ច ជាឧបាយមគ្គដ៏ប្រសើរ មានអង្គ ៨ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត ដូចបានរៀបរាប់ពីខាងដើមរួចមកហើយ ។

អរិយសច្ចធម៌ទាំង ៤ ប្រការនេះ មានអ្នកប្រាជ្ញជាច្រើនដែលបានរៀនគិត ជូនស្ដាប់ បានសិក្សា ទៅតាមលំអានព្រះពុទ្ធដីកានេះហើយ មានសេចក្ដីស្ទើចសរសើរថាត្រូវពិតឥតឃ្លៀងឃ្លាត ។ សម័យសព្វថ្ងៃនេះ, ជាន់ដំណាំនថា នៅកងមហាប្រទេសចាំងឡាយនៅក្នុងទ្វីបអឺរ៉ុប ដែលពីដើមគេមិនដឿព្រះពុទ្ធសាសនាសោះ, លុះបានពិនិត្យដល់ព្រះពុទ្ធសាសនាត្រង់ណោះ នេតំដឿ នាំគ្នាកាន់តាម ប្រតិបត្តិតាម ។ ដូច្នេះ, បានជាព្រះពុទ្ធសាសនាយើងឃើញមានប្រតិស្ឋាននៅកងទ្វីបអឺរ៉ុបស្ទើរតែគ្រប់ប្រទេស គ្រាន់តែច្រើននឹងតិច ថ្កុំថ្កើងនឹងអន់ថយប៉ុណ្ណោះ ។

ធម៌ជាពុទ្ធសាសនាម្យ៉ាងទៀត សម្រាប់ប្រដៅមនុស្សឲ្យចេះគិតពិចារណាដល់រូបកាយ ឲ្យឃើញជាក់ច្បាស់ថាមិនទៀង ជាទុក្ខ នឹងមិនមែនជារបស់ខ្លួនហៅថា ព្រះត្រៃលក្ខណ៍ ជាប្រយោជន៍កុំឲ្យមនុស្សពាំងអស់មានសេចក្តីស្រឡាំងកៀកក្នុងរូបកាយ ។

ធម៌ជារបៀបនៃពុទ្ធសាសនា ដែលនាំយកមកពន្យល់ក្នុងទីនេះបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីឲ្យឃើញជាតួយ៉ាងនៃព្រះពុទ្ធសាសនាដែលមានតម្លៃពិសេស រស់នៅប្រចាំលោកជានិច្ចមិនចុះតម្លៃ ព្រោះជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វ នឹងខេត្តពាំងអស់, ឥតមាននរណាមួយ ក្រៅអំពីព្រះពុទ្ធ គិតប្រដៅគ្នាឲ្យដូចបាននឡើយ ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់របៀបនេះនៅមានច្រើនណាស់ មិនអាចដកស្រង់យកមកពន្យល់ឲ្យសព្វគ្រប់បានទេ, ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដែលហៅថា ព្រះធម៌ នោះមានដល់ពោ ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ដែលត្រើសនឹតិតការចារឬបានបែកចេញជាចំដកមាន ៣ គឺ: ព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្ម ។

ព្រះពុទ្ធសាសនាដែលជាដីកនាំប្រៀនប្រដៅមនុស្សសត្វ ឲ្យមានប្រយោជន៍ ឲ្យបានសេចក្តីសុខនោះ មិនមែនឲ្យបានប្រយោជន៍នឹងសេចក្តីសុខក្នុងបរលោកដែលយើងមើលទៅមិនឃើញនោះទេ ជាពាក្យ

ប្រៀនប្រដៅឲ្យបានប្រយោជន៍ ឲ្យបានសេចក្តីសុខក្នុងលោកនេះ ខ្មែតផង ដូចពុទ្ធដីកា ដែលខ្ញុំសូមរៀបរាប់ខ្លះ ។ ខាងក្រោមនេះ ៖

ក្នុងសង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ ថ្កាដីកាព្រះពុទ្ធជាម្ចាស់ ទ្រង់សំដែងអំពីអបាយមុខ ៦ យ៉ាង ចំពោះសង្គាលមាណពថា: មិនឲ្យផឹកសុរា ១, មិនឲ្យដើរលេងតាមប្រកល្ហកក្នុងវេលាយប់ ១, មិនឲ្យដើរមើលល្បែងមហោស្រព ១, មិនឲ្យលេងល្បែងស៊ីសង មានបៀប៉ោជាដើម ១, មិនឲ្យសេពគំនិតនឹងមនុស្សខូច យកធ្វើជាមិត្តសំឡាញ់ ១, មិនឲ្យខ្ជិលធ្វើការងារកសិចិញ្ចឹមជីវិត ១ ។

ក្នុងបាកវសូត្រ គម្ពីរខុទ្ទកនិកាយ សុត្តនិបាត ព្រះពុទ្ធជាគ្រូនៃយើង ទ្រង់បានសំដែងយ៉ាងច្បាស់លាស់ អំពីហេតុដែលនាំឲ្យបានទទួលសេចក្តីវិនាស ផ្ទុយគ្នានឹងសេចក្តីចំរើន ចំពោះទេវតា ១ អង្គដែលមានឈ្មោះនឹងគោត្រមិនប្រាកដ ។

សូមដកស្រង់យកពុទ្ធភាសិតក្នុងបាកវសូត្រនោះ មកបង្ហាញអស់លោកអ្នកឲ្យបានជ្រាបដូចតទៅ :

១- សុវិជានោ ភវំ ហោតិ ។ ល ។ ធម្មទេស្សី បាកភវៃ ។

សេចក្តីថា: ទេវតាណាមួយមានចំណេះវិជ្ជា គឺចេះអក្សរសាស្ត្រ

សេខនតន្តគុណហារជាដើម ជាវិជ្ជាលោកីយក្តី វិជ្ជាលោកុត្តរក្តី, ខជនខោះនឹងបានខ្លួរសេចក្តីចំរើន ក្នុងលោកខាងមុខ ។ ខជនណាមួយ ខោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលអាប់ឥតចំណេះវិជ្ជាអ្វី ខៅកន្លងខ្លួន ខជនខោះឈ្មោះថានាំសេចក្តីវិនាសមកជាក់ខ្លួន ក្នុងលោកខេះនឹងលោកខាងមុខ មិនខាន ។

២- អសន្តសន្ន បិយា ហោន្តិ ។ល។ តំ បាកវសេន មុខំ ។

សេចក្តីថា: ខជនណាមួយ យកមនុស្សអសប្បុរសពាលយង់ឃ្នង ដែលប្រព្រឹត្តធ្វើតែអំពើលាមកអាក្រក់គ្រប់បែបគ្រប់យ៉ាង មានធ្វើអំពើបាណាតិបាតជាដើម មិនជឿកម្មនឹងផលរបស់កម្ម នៃកុសលអកុសលឡើយ មកធ្វើជាមិត្រសំឡាញ់ រួមសុខ-ទុក្ខជាមួយគ្នា មិនសេពគប់នឹងអ្នកប្រាជ្ញជាមិត្រភ័ក្តិ ពាប់អាខចូលចិត្តតែនឹងអសប្បុរសប្រុស្តមិត្តដូច្នេះ ជាហេតុជាប្រជាខធ្វើឲ្យខជនខោះដល់នូវសេចក្តីវិនាសដែរ ។

៣- និច្ចាសីលី សភាសីលី ។ល។ តំ បាកវសេន មុខំ ។

សេចក្តីថា: ជនណាមួយ ល្មោកដេកច្រើន ចូលចិត្តប្រជុំគ្នានិយាយលេងនូវពាក្យកេងកាយឥតប្រយោជន៍, ខ្ជិលប្រកបសមិនធ្វើការងារ,លុះក្នុងគំណាចនៃសេចក្តីក្រោធ, ចិត្តមួរទ្រឹងច្រើន យ៉ាងនេះគំជាទុច្ចរិតជាប្រធានទាំងនោះឲ្យដល់នូវសេចក្តីវិនាសដែរ ។

៤- យោ មានរំ ភ បិតរំ ភ ។ល។ តំ មភាកវតោ មុខំ ។

សេចក្តីថា ជនណាមួយ មានទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួនឥតមានកេតព្យាធិអ្វីមកបៀតបៀន, ឃើញមាតាបិតាចាស់ជរា មានវ័យកន្ទុឆ្នត់ទៅហើយ មិនជួយចិញ្ចឹមបីបាច់ថែរក្សា ដោយតែតាំងឡាយមានកោដនាហារជាដើម ជននោះឈ្មោះថាជាមនុស្សអកតញ្ញូ មិនដឹងឧបការគុណលោកអ្នកដ៏មានគុណ នេះគំជាហេតុនៃសេចក្តីវិនាសដែរ ។

៥- យោ ព្រាហ្មណំ សមណំ ភ ។ល។ តំ ឧភាកវតោ មុខំ ។

សេចក្តីថា: នរជនណាមួយ បានឃើញសមណៈ គឺអ្នកបួសក្នុងព្រះពុទ្ធសាសនា, ព្រាហ្មណ៍ ឬ សូមយាចកណាមួយ មកកាចំណីបាត ឬ សូមទាន ហើយខ្លួនគោលពាក្យទ្រគោះបោះបោកបញ្ឆោតដោយមុសាវាទថា គ្មានអ្វីឲ្យទេជូរចុះជាដើម អ្នកនោះឈ្មោះថា

ជាមនុស្សក្រខ្លះឬស្ទាស្ទះពុំដឹង ប្រថុស្តនឹងសម្ដែងនូវ ពោះបើឲ្យក្តី មិនឲ្យក្តី តប្បីពោលពាក្យសមគួរដោយវាចា ។ ដែលពោលពាក្យអសុរោះ ទ្រគោះទៅរកសមណ, ព្រាហ្មណ៍ះ, សូមយោចកនោះ កំជាហេតុជាប្រធានៃសេចក្តីវិនាសដែរ ។

៦- បហុតរិត្តា បុរិសោ ។ ល ។ តំ បភកវតោ ម្ដុំ ។

សេចក្តីថា នរជនណាមួយ មានទ្រព្យសម្បត្តិច្រើន មានមាសប្រាក់តែវត្ថុប្រុសបុរិតាន្តស្តុកស្តម្ភ, មានចាំដរគ្រឿងបរិភោគនិងភោគបរិបូណ៌ត្រប់គ្រាន់ តែចិត្តសន្ធឹពុំដឹងតំណាញ់ស្ងួតហួសហេតុ ជាន ចំណីអាហារឆ្ងាញ់ពិសា ក្លួនស៊ីតែម្នាក់ឯង មិនចែករំលែកឲ្យទៅអ្នកជំងឺផងគ្នាបរិភោគផង, នរជននោះឈ្មោះថាជាមនុស្សអប្បលក្ខណ៍ឥតសិរី គ្មានអ្នកផងដឹងជាទីចូលចិត្តរាប់អាន ។ នេះ, កំជាប្រធានៃសេចក្តីវិនាសដែរ ។

៧- ជាតិត្តន្ធោ ជនត្តន្ធោ ។ ល ។ តំ បភកវតោ ម្ដុំ ។

សេចក្តីថា: អ្នកណាមួយ មានជាតិខ្ពង់ខ្ពស់ មានគោត្រត្រកូលខ្ពង់ខ្ពស់ មានសម្បត្តិច្រើន តែមានចិត្តឆ្មើងកន្ត្រើង ប្រកាន់

ជាតិត្រកូល អាងខ្លួនសម្បត្តិ ចិត្តរបស់ឯងស្រេចយើញញាតិសាលោហិត ឬអ្នកជាខៃដែលទ័ល់ក្រ មានចិត្តប្រមាថមើលងាយ មិនរាប់អាន ធ្វើហាក់ដូចជាអ្នកកន្ទៀត ឬធ្វើជាមិនដឹង មិនឃើញ ប្រកាន់អស្ថិមានៈរតើតរតើងក្រអឺតក្រអោង កោងកាច អ្នកនោះឈ្មោះថាស្វែងរកសេចក្តីទុក្ខមកដាក់ខ្លួន អំពើដែលធ្វើទាំងអស់នេះកំណាប្រធាន ជាទុជ្ជយនាំបណ្តាលឲ្យបានសេចក្តីវិនាសដែរ ។

៨- ឥត្ថីឆុត្តោ សុភឆុត្តោ ។ ល ។ ន បភកវតោ មុខំ ។

សេចក្តីថា ជនណាមួយ ប្រព្រឹត្តលេងស្រី , ប្រព្រឹត្តផឹកស្រា , ប្រព្រឹត្តលេងល្បែងស៊ីសងក្តាល់គ្នា ។ អ្នកលេងស្រីនោះត្រូវអាទីនវស្ត្រីភាព បានដល់អ្វី ? មានមាសប្រាក់ជាដើមលុបលាក់យកទៅឲ្យតែស្រី ? , ធ្វើឲ្យខ្ទេចខ្ទីនវិនាសអស់ ពីព្រោះតែស្រី; អស់ខ្លួនសម្បត្តិម្យ៉ាងចំពោះការស៊ីចាយ ដើម្បីឲ្យស្រីស្រឡាញ់ខ្លួន, អស់ម្យ៉ាង កូនការឲ្យទៅពួកស្រី ? ដែលខ្លួនត្រូវការយកមកសម្បុយអស់ម្យ៉ាងទៀត កូនការទិញថ្នាំយកមកចាក់ ព្យាបាលរោគ ស្លាយប្រមេះ ខៀមធ្មេញ ថ្នាំកន្ទោមផ្តែម ដែលមានសម្បជ្ជានកើតមកអំពីស្ត្រីពេស្យាជាមាសចាំងនោះ ។ ឯអ្នកផឹកស្រា តែស្រវឹងឡើងកាល

ណា កំរង្គើនភ្ញាំងភ្លើងក្ងេចស្មារតី មិនស្គាល់ថាបុណ្យ គុណទោស
លែងស្គាល់អ្នកធំ អ្នកតូច, យកខុសជាត្រូវ យកត្រូវជាខុសប្រទូស្ត
ខឹងខ្លួនឯង ឬ អ្នកដទៃ រហូតដល់ហ៊ានប្រទូស្តចំពោះអ្នកមានសីល មាន
គុណវិសេស, សូម្បីមាតាបិតាបង្កើត គំហ៊ានប្រទូស្តតបផង ។ ឯអ្នក
ដែលប្រព្រឹត្តលេងល្បែងភ្នាល់ស៊ីសង មានបៀ-អាប៉ោង-ឆ្នូ ជាដើម
គំជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិ ដែលរកបានមកដោយក្រ ។ មិន
តែប៉ុណ្ណោះ ថែមទាំងភាគពេលដែលត្រូវរកគំហានរក ព្រោះរវល់តែ
ខឹងដើរលេង, ភាគទាំងពេលរៀនសូត្រ (ចំពោះអ្នកសិក្សា) ខូចទាំង
ពេលដេកពេលសម្រាក, ខូចចិត្តខូចគំនិត ភ្លេចភ្ញាំងស្មារតី នាំឲ្យ
អាប់កិត្តិយសឈ្មោះអាក្រក់ ចេះភ្លេចគុណគេ លួចប្លន់ ចោកបញ្ឆោត
ប្រវ័ញ្ចយកទ្រព្យរបស់អ្នកដទៃ, ក្បត់ជាតិ, ក្បត់
សាសនា, ខឹងក្បត់ព្រះមហាក្សត្រិត្រៃថមទៀត ។ កាលបើអំពើទាំងនេះ
កើតមានក្នុងខ្លួនហើយ, ខ្លួនត្រូវមានការលក់ផ្ទះសម្បែង, លក់គ្រឿងគោះ
លក់របស់ពីដូនពីតា លក់ស្រែចំការច្បារដំណាំអស់, រហូតដល់ទៅ
មានទោសទុក្ខ ជាប់គុកប្រាក់ ដោយសារតែខ្លួនប្រព្រឹត្តធ្វើនូវអំពើពុំ
គប្បី នាំឲ្យគប្រើយទុយ៌ស ឆ្ងាត់ដល់ជាត់ជីវិតទៅក៏មាន ។

ល្បែងទាំង ៣ ប្រការនេះ ជាហេតុជាប្រធានទាំងឲ្យធ្លុត ទាំងឲ្យ
វង្វិន ទាំងឲ្យវិនាសហិនហោចទ្រព្យសម្បត្តិ ។ នេះជាសេចក្តីវិនាស
យ៉ាងធំក្រៃលែង ។ សមដូចសុភាសិតខ្មែរយើងមួយឈ្មោះថា លោក
ជាធ្លុតបី ធ្លុតមួយទឹងស្រី ធ្លុតមួយទឹងស្រា ធ្លុតមួយទឹងល្បែង
អំពើពាលា បីនេះលោកថា មហាធ្លុតកន្ធ ។

៩- សេយ្យថា ជាវេហិ អសន្ថដ្ឋោ ។ ល ។ តំ
បាកភវតោ មុខំ ។

សេចក្តីថា: បុរសបុគ្គលឯណាមួយ មានចិត្តប្រកបដោយភាព
ភត មិនត្រេកអរនឹងភរិយារបស់ខ្លួន ត្រេកត្រអាលតែនឹងស្ត្រីដទៃ
ប្រព្រឹត្តសេពសមនឹងស្ត្រីគេស្បាថ្លាមាស ឬ ភរិយារបស់អ្នកដទៃ ។ គប
នឹងស្ត្រីគេស្បាថ្លាមាស ទាំងឲ្យវិនាសទ្រព្យសម្បត្តិ រហូតដល់ជាក់ខ្លួន
ទៅជាកើតរោគាព្យាធ៍ មានរោគស្វាយប្រមេះ ខៀមឡាជាដើម ។ គប
នឹងភរិយាអ្នកដទៃ មានទោសជាទម្ងន់កន្លងបន្ទប់ក្នុងផង កន្លងបរលោកផង ។
ទោសកន្លងបច្ចុប្បន្ន គឺកើតទៅជាទាស់ទែងវ៉ៃឈ្លើគំនិតគ្នានឹងភរិយាខ្លួន
ក៏មាន ស្វាមីគេវិលប្តឹងផ្តល់ក៏មាន ទៅជាមានគំនុំគុំគួន លបចាក់
គាប់សម្លាប់គ្នាក៏មាន, ទាស់ខុសនឹងច្បាប់សម្រាប់ប្រទេស ត្រូវពេជ្ឈការ

លក់ព្រិនិយត្រូវជាប់ឃុំឃាំងមានជាក់ខ្លះ ជាក់គុកច្រវាក់កំមាន បងិ្គព្យ
សម្បត្តិកំមាន ។ ទោសកងិ្ចវរលោក, លុះធ្វើមរណកាលអំពីលោកនេះ
ទៅកាន់លោកខាងមុខ សោយទុក្ខកងិ្ចនរក ឡើងរកាវដែកអស់កាល
ជាយូរសែសសល់ផលកម្មនោះ ចាមកកើតជាមនុស្ស ពុំលួសភាពខ្វាក់ខ្វិន
ភរិយាសោត កំមានចិត្តមិនស្មូតត្រង់ចំពោះខ្លួន, មិត្រកក្តិកំមិនស្មូ
សុច្ចរិតមានចិត្តមិនស្មោះត្រង់នឹងខ្លួន, ក្មួនប្រុសស្រីកំមិនលុះកងិ្ចដំបូន្មាន,
ព្យសម្បត្តិកំអន្តរាយ ពាំងនេះកំជាហេតុជាប្រធានធ្វើបុរសបុគ្គលនោះ
ឲ្យដល់នូវសេចក្តីវិនាសដែរ ។

១០- អត្តីតយោព្យាបោ ទោសោ ។ ល ។ តំ
បហាកវគោ ម្ភុំ ។

សេចក្តីថា: នរជនណាមួយ មានរ៉ែយកទ្វង់ហួសផុតទៅហើយ
ទ្មេញចាក់ត្រហុប, សក់ស្វាត់ព្រាងឹ, ក្អែកងងឹតវែមវែងតាឡើងជាបួន
សាច់ស្បែកជ្រីវជ្រួញយុរយោ មិនគួតប្រយោគរូបអាត្ម ទៅទាំយកឯស្រី
ក្រមុំដោះកំព្រីក្រពុំដូចផ្លែខម្ចាប់ សាច់ខ្លីខន់ល្ងន់ល្ងាសសត្រសូលដូចបណ្តូល
ចេក មកធ្វើជាភរិយា សេចក្តីដំរេកត្រេកត្រអាលដោយកាមរាគ មិនល្មម
គ្រាន់ដល់ចិត្តភរិយា ដ្បិតខ្លួនគេក្រងខ្លួនឯងឯចាស់ ធ្វើដូចម្តេចគេនឹង

ស្រឡាញ់ពេញចិត្តបាន, សេចក្តីប្រច័ណ្ឌកំកើតមានឡើង កើតទុក្ខក្តៅក្រហាយពេលកលក្នុងសន្តាន ព្រោះពាន:គ្រប់សង្កត់ ជួនកាលកើតទុក្ខស្ទាប់ចាំងខ្លួនកំមាន ហេតុនោះកំជាប្រធាននៃសេចក្តីវិនាសដែរ ។

១១- ឥត្ថី សោណ្ឌី វិកិរណី ។ ល ។ តំ បភវតោ មុខំ ។

សេចក្តីថា : បុរសណាមួយលើកតំកើងខ្លួនវាស្ត្រីអ្នកលេង ស៊ីផឹកខ្ជះខ្ជាយឲ្យជាធំក្នុងផ្ទះ តុំនោះសោតស្ត្រីណាមួយលើកតំកើងបុរសមានសកាតជូញ្ចោះដែរ ឲ្យជាម្ចាស់ផ្ទះ ជាមនុស្សខ្ជះខ្ជាយ ចាយវាយឥតសណ្តាប់ធ្នាប់ បុរសស្ត្រីនោះទំនឹងមានសេចក្តីហិនហោច ខ្វត់ខ្វាយក្រីក្រលំបាកវេទនា ហេតុនោះកំជាប្រធាននៃសេចក្តីវិនាសដែរ ។

១២- អប្បកោ តោ មហាតណ្ហោ ។ ល ។ តំ បភវតោ មុខំ ។

សេចក្តីថា: បុរសបុគ្គលណាមួយ កើតក្នុងត្រកូលក្សត្រមានភោគសម្បត្តិនឹងបរិវារសម្បត្តិតិច ចំណេះវិជ្ជាតិច, តែមានសេចក្តីប្រាថ្នា លោភលន់តន់ប្រមាណ ចង់សោយរាជ្យជាម្ចាស់ផែនដី ដែលមិនគប្បីខ្លួនឯងខ្លួលបាន ម្ល៉ោះហើយចែកចាយទ្រព្យសម្បត្តិដែលមានចំនួន

តិចតួចស្តួចស្តើងបញ្ចេះបញ្ចូលមនុស្សទាំងឡាយ . មានរសនាយោធាជាដើម . លុះមិនបានសម្រេចដូចចំណង់ អាត្មាខ្លួនដល់នូវទោសជាខ្លាំងហេតុនោះគឺជាប្រធានៃនៃសេចក្តីវិនាសដែរ ។

ពុទ្ធដីកា កន្លងមកក្នុងសូត្រទាំង ១២ ចំនេះ បើយើងពិនិត្យគិតតាមលំអាននេះទៅ យើងនឹងបានយល់ថា: ស្រួលពិតដូចព្រះពុទ្ធដីកានេះមែន ។

ម្យ៉ាងទៀត, ព្រះអង្គបង្ហាញប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាងទៀតគឺ :

១- ឧដ្ឋានសម្បទា ឲ្យមានព្យាយាមក្នុងការរកចិញ្ចឹមជីវិត ។

២- អារក្ខសម្បទា ឲ្យចេះថែរក្សាទ្រព្យសម្បត្តិ ដែលកើតឡើងដោយសេចក្តីព្យាយាមនោះ ។

៣- កល្យាណមិត្តតា ឲ្យរកមនុស្សល្អធ្វើជាមិត្រភក្តិ

៤- សមជីវិតា ឲ្យចេះចាយវាយទ្រព្យសម្បត្តិតាមសមគួរដល់របរដែលខ្លួនរកបាន ។

-ព្រះអង្គប្រដៅមនុស្សទាំងអស់ឲ្យចេះសង្គ្រោះគ្នាទៅវិញទៅមកតាមជាន់តាមថ្នាក់, ដូចមាតាចិតានឹងបុត្តធីតា, ត្រូវនឹងស្វាមីមិត្តសំឡាញ់នឹងមិត្តសំឡាញ់ផងគ្នា, ចៅហ្វាយនាយនឹងកម្មករ, ព្រះមហាក្សត្រនឹងប្រជាពលរដ្ឋ ។

- ព្រះអង្គប្រដៅមនុស្សឲ្យចេះសំអាតកាយ សំអាតចិត្តនៅ
ឥឡូវសិនលៀកបំពាក់ជាដើម ដែលក្នុងបាលីលោកហៅថា:វត្ថុវិសោធិយោ ។
ព្រះពុទ្ធសាសនា ដែលនាំយកមកតាឲ្យស្រួល បច្ចុប្បន្នបុប្ផំណោះ
គ្រាន់តែឲ្យឃើញថា ជាពាក្យប្រៀនប្រដៅ មានប្រយោជន៍ក្នុងបច្ចុប្បន្ន
នេះឯង ។

ព្រះពុទ្ធដីកានៃព្រះសម្មាសម្ពុទ្ធទាំងអស់ ចេញអស់លោកអ្នកឯណាមួយបាន
សិក្សា បានសង្កេតពិនិត្យមើលឲ្យសព្វគ្រប់ ហើយប្រតិបត្តិតាមគង្វាំ
ខ្ញុំឯបានដឹងថា ព្រះពុទ្ធប្រាកដជាអ្នកវិទ្យាសាស្ត្រខាងផ្លូវចិត្ត, ជាអ្នកដឹកនាំ
មនុស្សឲ្យដើរតាមផ្លូវសន្តិភាព ស្ងប់កាយស្ងប់ចិត្ត មិនឲ្យកើតវិវាទឈ្លោះ
ទាស់ខែងគ្នា ដែលក្លាយទៅជាសង្គ្រាម កាប់ចាក់សម្លាប់គ្នា; បង្រៀនឲ្យមាន
គ្នារាងឯមនុស្សធំឯមនុស្សឡើយ ។

រៀបរាប់មកអំពីតម្លៃនៃព្រះពុទ្ធសាសនា ដែលដឹកនាំមនុស្សឲ្យ
មានប្រយោជន៍ក្នុងបច្ចុប្បន្នធំដ៏ឋរលោក សន្មតថាចប់តែប៉ុណ្ណេះ ។

ព្រះអភិធម្មបិដក

គម្ពីរព្រះកថាវត្ថុ

លោក ជួ-ជុំ ប្រែរៀបរៀង

អសុចិសុក្កាវិសដ្ឋិកថា

(តមក)

ចរកថា- ទេវតាទាំងឡាយជាពួកនៃមារ មានចិត្តប្រុងប្រៀបនាំទឹក អសុចិមកជាក់កងអាយវែះដ៏កំចាំង ហេតុតែពួកភិក្ខុទាំងនោះ មិនទាន់ បានសម្រេចព្រះអរហត្ត សឹងលក់កងវែលាត្រី លុះដល់ពេលជិតភ្លឺ ភ្ញាក់ពីលក់ឃើញទឹកអសុចិ កំសាំងថា ទឹកអសុចិរបស់ខ្លួនហូរចេញ មក ទើបដាស់តឿនព្រួកស្មារតីគ្នាឲ្យចំពោះការ ខ្លួនស្អាតមិនឲ្យឃើញ ច្បាស់ ដោយព្រះត្រៃលក្ខណញ្ញាណ បានសម្រេចព្រះអរហត្តភាព តែលេសជាច់ឫសមូលច្បុះបង្ហាញ នាំគ្នាចេញពីព្រៃចូលមកកងវត្ត ប្រាប់ ធនឋាយចង្អឹគាល់ព្រះបរមគ្រូ ដំណាលរឿងខ្លួនប្រាប់ភិក្ខុទាំងឡាយ ។ ចូលចិត្តថា ពួកភិក្ខុដែលត្រឡប់មកពីព្រៃនោះមិនមែនជាព្រះអរហន្តទេ ប៉ុន្តែនិយាយថាខ្លួនបានសម្រេចព្រះអរហត្ត ទើបនាំសេចក្តីនោះក្រាប ទូលព្រះបរមសាស្តា ។ ឲ្យហៅពួកភិក្ខុទាំងនោះ ចូលមកគាល់ ហើយទ្រង់ត្រាស់សួរឿងរ៉ាវ ។

សកវាទី- សន្តា ន ជាតាតិ សម្តេចព្រះបរមសាស្តាមិនទ្រង់ជ្រាបថា ពួកតិត្ថិតាំងនោះបានសម្រេចព្រះអរហត្តទេឬអ្វី ឬបានជាចាំឲ្យហៅកេចូលមកគាល់ហើយត្រាស់សួរដូច្នោះ ?

បរវាទី- សម្តេចព្រះសម្ពុទ្ធទ្រង់ជ្រាបប្រវត្តិហេតុនោះគ្រប់ប្រការគ្មានសល់បន្តោះត្រង់ណាទេ ; ប៉ុន្តែទ្រង់ត្រាស់សួរតិត្ថិតាំងនោះឲ្យបានជាដើមហេតុ ទើបបានទ្រង់បញ្ញត្តសិក្ខាបទដល់សាវកតាំងឡាយ តាលត្រាស់សួរតិត្ថិតាំងឡាយ ។ តំណែបចូលសេចក្តីនោះតាំងពីដើមរហូតដល់ចប់ បានទ្រង់ព្រះសណ្តាប់ហើយទើបទ្រង់តិះដៀលទូវតិត្ថិដែលមិនបានសង្រួមឥន្ទ្រីយ៍ច្រាំមួយប្រការ ហើយទើបទ្រង់បញ្ញត្តសិក្ខាបទអ្នកគប្បីចូលចិត្តដោយនិយដូច្នេះចុះ ។

អសុចិសុត្តវិសជ្ជិតា ចប់ ។

សុគន្ធជាតិកថា

ពុទ្ធស្ស កតវតោ ឧប្បាទេ សព្ពកេ អតិវិយគន្ធោ អញ្ញេ គន្ធជាតេ អធិគណ្ហាតីតិ អាមន្តា កតវ គន្ធកោដីតិ ឧទោវំ វត្តព្វេ កតវ គន្ធកោដីតិ ។ ឧទុ កតវ ចិន្តិ កម្មាសំ កុញ្ជតីតិ ។

ព៉ារៈនេះទើបវិសជ្ជនាកថាសុគន្ធជាតិកថាតទៅ កថាសុគន្ធជាតិកថា

នេះ សម្តេចព្រះមានព្រះភាគត្រាស់ទេសនាជាសភាវធម៌ដូចតទៅនេះ

សភាវធម៌- ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវកម្មំ ព្រះពុទ្ធោរៈនឹងបស្សាវៈ[1]របស់ព្រះពុទ្ធទ្រង់ព្រះភាគនោះ មានក្លិនក្រអូបឈួយឈ្ងប់លើសលុប ត្រឹមសង្កត់ នូវគ្រឿងក្រអូបទាំងឡាយដទៃដែលមាននៅក្នុងលោកទាំងស្រុងទាំងអស់ ពាក្យនេះពិតមែនឬមិនពិតទេ ?

បរវាទី- អាមន្តា អើ ! ពិតមែន ដូចពាក្យអ្នកថានោះហើយ ព្រះពុទ្ធោរៈនឹងបស្សាវៈរបស់ព្រះពុទ្ធទ្រង់ព្រះភាគនោះ ក្រអូបក្រអែមផ្សព្វផ្សាយលើសគ្រឿងក្រអូបក្នុងកាលពាំងប៉ ។

សភាវធម៌- ភគវា ភន្តេ កោដិតំ សម្តេចព្រះមានព្រះភាគជាទីសេពគប់នៃទេពតានឹងមនុស្សទាំងឡាយ ព្រះអង្គសោយតែភោជនាហារដែលឈ្ងុយឆ្ងៃជាងវត្ថុមានក្លិនក្រអូបឈួយ មិនសោយនូវវត្ថុដ៏ជាអាហាររបស់មនុស្ស មានជាយនឹងសណ្តែកល្ងង់ដើមទេ ឬដូចម្តេច ?

បរវាទី- ឧភោវំ វត្តព្វេ អ្នកកុំនិយាយយ៉ាងហ្នឹងឡើយ សម្តេចព្រះមានព្រះភាគ មិនមែនសោយតែគ្រឿងក្រអូប នឹងភោជនាហារដ៏ឈ្ងុយឆ្ងៃជាងវត្ថុមានក្លិនក្រអូបនោះទេ ព្រះអង្គទ្រង់សោយចំណូលបាតតាមពុទ្ធវិស័យជានយ៉ាងណា ក៏សោយយ៉ាងនោះ នឹងកំណត់

១-ព្រះឧច្ចារៈ ប្រែថា អាចម៍, ព្រះបស្សាវៈ ប្រែថា ទឹកនោម ។

ថា ព្រះអង្គសោយតែតិត្ថមានក្តួនក្រអូបមិនបានទេ ដូចភាគក្នុងព្រះសូត្រថា នាងមល្លិកាជាធីតា នៃនាយមាលាការ នាងបានទាំយកនំល្មមកថ្វាយជាក់ចុះក្នុងបាត្រ ហេតុតែកុសលនោះ នាងបានជាអគ្គមហេសីនៃព្រះបាទបសេនទិកោសលរាជ ឲ្យឃើញផលជាទិដ្ឋធម្មវេទនីយ៍ ។ ក្នុងព្រះសូត្រមួយទៀតថា ព្រះមហាមោគ្គល្លានត្មេរជាម្ចាស់និមន្តទៅនិមន្តិយសេដ្ឋី ឲ្យធ្វើទំអំបែងមកថ្វាយព្រះពុទ្ធអង្គក្នុងវត្តជេតពន ។ ក្នុងព្រះសូត្រខ្លះទៀតថា ព្រះពុទ្ធអង្គបរមគ្រូសោយកត្តាហារ ដែលជនទាំងឡាយនាំយកមកថ្វាយជាច្រើន ប្រកបដោយសូបព្យញ្ជនៈ គឺបង្អែមនិងអន្ទក់ស្រស់ ជាច្រើនយ៉ាង ប៉ុន្តែក្នុងព្រះវិន័យថា ព្រះពុទ្ធអង្គស្តេចយាងទៅកាន់ទន្លេរវែញ្ជា ចាំព្រះវស្សាអស់ត្រៃមាស មានចូលបង្វិលចិត្តអ្នកទន្លេ មិនឲ្យអ្នកណាម្នាក់ជ្រះថ្លានឹងព្រះពុទ្ធអង្គ ឯវែញ្ជព្រាហ្មណ៍ ថ្វាយអាហារចំណូលបាត្រ បានសោយតែបាយក្រៀមបាយគ្រាំងដែលឈ្នួញសេះនៅកន្លងទន្លេរវែញ្ជានាំចូលទៅថ្វាយ ។ ក្នុងព្រះសូត្រ នឹងព្រះវិន័យនោះ មានសេចក្តីជាអនេកបរិយាយដូចសំដែងមកប៉ុណ្ណេះជាដើម ។

សភាវៈ- ឯកុ ភគភ សម្តេចព្រះមានព្រះភាគសោយបាយនឹងសូបព្យញ្ជនៈ តើសម្អូអន្ទក់នឹងសណ្តែកល្មមែនឬទេ ?

បវរៈ- សម្តេចព្រះមានព្រះភាគ ទ្រង់សោយភោជនាហារតាមតែការគួរដែលបានមកដោយឧត្តុំភាពវត្ត មិនមែនរើសសោយតែភោជនមានក្លិនក្រអូបទេ ។

សភរៈ- ហាញ៉ុំ ភគវា ចើសម្តេចព្រះមានព្រះភាគសោយភោជនាហារ តិចយ៉ាងត្រីសាច់សណ្តែកល្ងាដើមដូច្នេះ ទំនងជាព្រះទន្តាះបស្សាវៈរបស់ព្រះពុទ្ធជាម្ចាស់ក្រអូបត្របស្ទក់ក្លិនត្រឹងក្រអូបពាំងឡាយជាដែលបានដែរឬអ្វី ? យើងនៅតែសង្ស័យ មិនទាន់ជឿពាក្យអ្នកឆ្លើយទេ ។

បវរៈ- ដោ វត្តវេ វត្តព្វេ ជនពាំងឡាយមិនគប្បីនិយាយថា ព្រះទន្តាះទំងឯបស្សាវៈរបស់ព្រះមានព្រះភាគ មិនក្រអូបទេ រមែងនិយាយថា ក្រអូបត្រប់គ្នា ; សម្តេចព្រះមានព្រះភាគនោះ ជាមនុស្សមស្ចារ្យមិនគួរបុគ្គលទំងឯសង្ស័យទេ ព្រោះហេតុព្រះអង្គបានកសាងសន្សំ កងការកុសលកល់ជាតិ ពាល់តែបានសម្រេចព្រះសព្វញ្ញុតញ្ញាណជាយូរយារណាស់ រាប់ជាយកោដិនៃកប្បជាច្រើន បំពេញបញ្ចាមហាបរិច្ចាគ លះទ្រព្យ, លះព្រះអង្គ, លះព្រះជន្ម, លះព្រះអគ្គមហេសី, លះព្រះនរសព្រះធីតា គ្រាន់តែឆ្កៀលព្រះនេត្រចេញបំពេញទាន ទំងឲ្យដួងហឫទ័យដោយសទ្ធា ទំងកាត់ព្រះសិរឲ្យជាទាន

ទីដ៏ប្រមាណពប់ជាតិមិនបាន ទីដ៏បាច់ទិយាយទៅថ្វី ដល់ទៅព្រះទត្តារៈ
ទីដ៏ព្រះបស្សារៈថាមិនបានក្រអូប គឺក្រអូបដោយសម្តេចព្រះពុទ្ធអង្គជា
អគ្គបុគ្គល រកអ្នកណាទីដ៏ប្រៀបផ្ទឹមឲ្យត្រឹមស្មើគ្មានទេ គឺក្រអូបដោយ
ហេតុជាមនុស្សអច្ឆរិយពិតប្រាជក ហើយព្រះអង្គខ្ចែខ្ចាំទូរអធិសីល
អធិចិត្ត អធិបញ្ញាក្រៃលែងជាងព្រះអរិយចាំងឡាយនោះៗ លុះតែបានស្តាប់
ទូរព្រះពុទ្ធាធិប្បាយ ទើបបានខ្ចែខ្ចាំទូរអធិសីល អធិចិត្ត អធិបញ្ញា
កន្លងកាលជាមានិះក្រាយ សម្តេចព្រះមានព្រះភាគជាម្ចាស់មានព្រះទត្តារៈ
ទីដ៏ ព្រះបស្សារៈត្រេបសង្កត់គ្រឿងក្រអូបចាំងពួងនោះ គួរទីដ៏ស្តាប់
បានដោយតុទ្ធវិស័យ បុគ្គលមិនគួរគេតធ្លល់ទេ គ្រាន់តែបុគ្គលស្តាប់
ព្រះធម៌ទេសនាហើយចង្អៀតចាថាសាធុៗ ប៉ុណ្ណោះ ក្លិនកាយក្រអូប
ដូចក្លិមចន្ទន៍ ក្លិនមាត់ក្រអូបដូចក្លិនផ្កាឧប្បលទៀវ ក្នុងព្រះពុទ្ធ
សាសនានេះបាន ដូចព្រះមហាថេរជាស្វាមីរបស់ស្ត្រី ដែលព្រះបាទ
បសេនទិកោសល នាំយកទៅទុកក្នុងព្រះបរមកដ៏ងៗ

ប្រការមួយទៀត ដូចសន្តតិមហាមាត្យ កាលពីជាតិមុនដើរ
ត្រាច់ចាំវែងឆ្ងាយប្រកាសឲ្យអ្នកទនតស្តាប់ព្រះសទ្ធម្មទេសនា ក្លិនមាត់ក្រអូប
ឈ្ងុយ ផ្សាយចេញដូចក្លិនផ្កាឧប្បល ក្លិនសរីរៈកាយក្រអូបដូចក្លិនក្លិម
ចន្ទន៍ សេចក្តីនេះមានប្បាស់នៅក្នុងរឿងសន្តតិមហាមាត្យ ។ កាល

លោកថ្នាមបម្រែចព្រះអរហត្តហើយ ទូលលាទីឯចូលអមតមហានិព្វាន
ហើយក្រាបទូលនូវគុណសលដែលខ្លួនបានធ្វើពីជាតិមុនមក ចំពោះសម្តេច
ព្រះមានព្រះភាគចប់ហើយ ទើបចូលកាន់ព្រះនិព្វាន ។

ហេតុដូច្នេះ អ្នកប្រាជ្ញតប្បីសន្និដ្ឋានថា ព្រះទន្តធាតុនិងព្រះបស្សាវៈ
របស់ព្រះពុទ្ធអង្គនោះ ក្រអូបត្រចះសង្កត់នូវគ្រឿងក្រអូបទាំងពួងដោយ
ពុទ្ធវិស័យ ហើយក្លិនសីលរបស់ព្រះមានព្រះភាគនោះ ក្រអូបខ្ទៀ
ពេញសាកលលោកធាតុ ដោយអំណាចក្លិនរបស់ព្រះពុទ្ធអង្គនោះ រមែង
ជាទីស្រឡាញ់នៃទេវតានិងមនុស្ស ។

ព្រះអដ្ឋកថាចារ្យពោលទុកថា ឥទ្ធិសាលកុហាយំ វិហា-
រន្តោ កាលសម្តេចព្រះបរមសាស្តាចារ្យសម្រេចពុទ្ធកិច្ចដោយចតុព្វិធ
អរិយាបថក្នុងឥទ្ធិសាលគុហា ។ អថខោ កកកា ក្នុងគ្រានោះ
សម្តេចព្រះមានព្រះភាគទ្រង់ប្រឈួនពេគាពាធ សង្កេ ឧទវាជា
សម្តេចអមនុទេវរាជទ្រង់ជ្រាបនូវប្រែវត្តិហេតុនៃព្រះប្រឈួន ទើបស្តេច
ប្រញាប់ប្រញាល់ចុះពីតាតែង្សតិភតា មកកាន់សំណាក់សម្តេចព្រះបរមគ្រូ
ធ្វើទបង្គំកដោយគោរពពុំមានសេចក្តីរង្គើសធុញទ្រាន់សោះឡើយ សី-
សេន ឯហារន្តោ នាំយកនូវភាជនៈដាក់ព្រះទន្តធាតុនៃព្រះមានព្រះភាគ ដោយព្រះសិរ ទៅចាត់ចែលក្នុងមហាសមុទ្រ

ហាក់ដូចជាភាជនៈដាក់គ្រឿងក្រអូប មានព្រះកក្តស្រស់ប៉ប្រឹមញញឹម ញញែមឥតដូរ ឫក្រញូវបន្តិចបន្តួចសោះឡើយ លុះព្រះពុទ្ធអង្គសោះជាព្រះកេតាភាធហើយ ព្រះឥន្ទ្រាធិរាជក៏លៃកាន់ទៅស្ថានវិញ ។

ធម្មសភាយំ ភន្តេ សមុដ្ឋាបេសុំ តិក្ខុត្តំ ឯត្តាយ សន្និបាតប្រជុំគ្នាក្នុងភេងធម្មសភាហើយ សន្តនាគ្នាថា អហោ ពុទ្ធា-ឧក្កាភៈ ឥច្ចាំ ! គួរឲ្យអស្ចារ្យនឹងអានុភាពរបស់ព្រះពុទ្ធដ៏ម្ចាស់ពេកណាស់ អម្បាលសម្តេចអមរិន្ទ្រទៅរាជជាធំជាងទៅតា ក្នុងទៅតិ-ភពម្តេចគង់ចុះមកបម្រើព្រះអង្គ ព្រោះហេតុមានសេចក្តីស្រឡាញ់ព្រះបរមសាស្តាយ៉ាងក្រៃលែង ។ សត្តា អាកង្ខា កាលដែលតិក្ខុំ-ពាំងនោះកំពុងតែសន្តនាគ្នាដូច្នោះ សម្តេចព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់ដោយព្រះសោតធាតុ ទើបស្តេចយាងមកគាន់ភេងធម្មសភាគង់លើព្រះបវរពុទ្ធាសនៈ ហើយមានព្រះពុទ្ធដីកាសួរថា តាយនុត្ថ តិក្ខាវេ ម្នាលតិក្ខុំពាំងឯង អ្នកពាំងពួងមកសន្និបាតកុងភេងធម្ម-សភា សន្តនាគ្នាអំពីរឿងអ្វី ។

សត្ថារំ- កស្មា ហេតុអ្វី បានជាសម្តេចព្រះសាស្តាស្តេចមកដល់ហើយត្រាស់សួរ ? ។ ពាក្យដែលថាព្រះអង្គត្រាស់សួរនេះ យើងមានសេចក្តីសង្ស័យណាស់ ព្រោះពាក្យមុនទំនឹងពាក្យក្រោយមិន

សមគ្គា ។ ដែលថាព្រះអង្គទ្រង់ជ្រាបហើយគ្រាស់សួរនោះមិនស្រេចគ្នាសោះ ។ បើថាមិនគ្រាស់សួរទើបស្រេចគ្នា ព្រោះហេតុថាព្រះសម្ងាសម្ពុទ្ធលះបង់នូវមាយាបានដាច់ស្រេចហើយ ។ បើទ្រង់ជ្រាបរួចហើយនៅតែគ្រាស់សួរដូច្នោះ ពាក្យដែលថា ព្រះអង្គលះបង់មាយាបានជ្រះស្រឡះហើយនោះ មិនគួរឲ្យជឿសោះឡើយ ។

បរវាទ - ចូរអ្នកកុំយល់ឃើញដូច្នោះ ខុសទេ ; ការដែលព្រះពុទ្ធជាអម្ចាស់ទ្រង់ជ្រាបហើយនៅតែគ្រាស់សួរនោះ មិនមែនជាអាការនៃមាយាសោះឡើយ ដ្បិតព្រះអង្គទ្រង់លើកសេចក្តីដែលពួកភិក្ខុក្រាបទូលនោះឡើងជាទេសនាហេតុ ហើយទ្រង់បានសំដែងព្រះសទ្ធម្មទេសនា ។

កិក្ខុហិ វុត្តេ កាលដែលព្រះពុទ្ធអង្គគ្រាស់សួរនោះ ភិក្ខុទាំងពួងក៏ក្រាបទូលសេចក្តីដែលខ្លួនសន្ធនាគ្នាតាំងអំពីដើមរហូតដល់ចប់ ព្រះពុទ្ធអង្គទ្រង់ប្រទានព្រះសទ្ធម្មទេសនាថា សីលវតំ ភន្តេ ភូមនៃសីលនោះ ក្រអូបទៅក្នុងទេវតាទាំងមនុស្សទាំងឡាយ ក្រអូបទៅក្នុងទិសទាំងក្រោមទាំងលើ ក្រអូបទៅប្រាសឈ្លក់ជាន បណ្តាយឈ្លក់ជាន ឥតប្រកាន់ទិសទីណាឡើយ ក្រអូបក្រៃលែងជាងភូមនៃគ្រឿងក្រអូបទាំងពួង បណ្តាគ្រឿងក្រអូបដែលមានក្នុងស្ថានមនុស្សទាំងស្ថានសួគ៌ ។ ភូមក្រអូបវិសេសបំផុត ក្នុងមនុស្សលោកនោះ គឺក្រឡាភ្ញាំពាក់

ឧដ្ឋិតមិនបានឡើយ ក្នុងនៃប្រជុំជាតិដែលក្រអូបក្នុងស្ថានសួគ៌នោះ ជានដល់ក្នុងផ្កាចាប៉ែតក្រវ៉ាក្រអូបទៅប្រាសខ្សល់បានតិចតួចមែនហើយ ប៉ុន្តែមានកំណត់ ។ ឯក្នុងនៃសីលរបស់បុគ្គលអ្នកមានសីលនេះ ក្រអូបឈ្ងុយឈ្ងប់ឆាយកាយទៅរហូតដល់ព្រហ្មលោក មិនរេចរោត់ក្រអូបសោះឡើយ ក្រអូបតាំងថ្ងៃតាំងយប់គ្រប់ពេលវេលាមិនរេចឈប់ ហេតុដូច្នោះ បានជាសម្តេចអមរិន្ទទេវរាជបុរមកបម្រើព្រះតថាគត ។

តាមលំអានព្រះពុទ្ធដីកាសំដែងព្រះសទ្ធម្មទេសនាដូច្នេះ បណ្ឌិតជាតិអ្នកមានបញ្ញាញាណបានសមាទានវិសីលហើយ គប្បីព្យាយាមរក្សាឲ្យចរិសុទ្ធល្អ ឧដ្ឋិបានជាទីស្រឡាញ់របស់មនុស្ស ព្រមទាំងទេពតា បើពុំជាមានសត្រូវឬអមនុស្សមកប្រទូសក៏ឃាតិមិនបាន ។

ឯព្រះទច្ចារៈឧដ្ឋិព្រះបស្សារៈរបស់ព្រះសង្ឃសម្ពុទ្ធក្រអូបលើសលែងត្រឿងក្រអូបទាំងអស់ក្នុងលោកវិសេសនោះ ជាពុទ្ធប្រៃណីរបស់ព្រះពុទ្ធជាអម្ចាស់ទាំងពួង បុគ្គលមិនគួរនឹងតិះដៀលទេ ព្រោះថាព្រះពុទ្ធវិសេសនោះឈ្មោះថា អចិន្តេយ្យហេតុ ។ សេសមេត្ត យថា ចាលិយំ ៧ ពាក្យដែសេសសល់ត្រាតែបានសំដែងមកនេះ ដូចជាពាក្យក្នុងព្រះបាលី ពុំបានខុសគ្នាទេ ។

សុគន្ធវាតិវគ្គោ ឆដ្ឋោ ។

មង្គុរសវិបាំណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ឆន្ទកវាជវគ្គទី ២ មានរឿងនិទាន ១០

ឆន្ទកវាជវត្ថុកថា

សំដែងរឿងនិទានព្រះចាខន្ទកវាជជាបឋមកឆវគ្គនីពីរ ដោយចាលីថា: ឥតោ កិរ កប្បសតសហស្សមត្ថកេ បទុមុត្តរោ នាម សត្ថា លោកេ ឧទបាទិ ដូច្នេះជាដើម

អធិប្បាយសេចក្តីថា: កំរចាខន្ធរឿង ។ មកថា: មានព្រះសាស្តាចារ្យមួយព្រះអង្គទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់ចានត្រាស់ដឹងបរមាភិសេកសម្ពោធិញ្ញាណ ជាព្រះពុទ្ធទ្រ្ចាកដក្នុងលោក ក្នុងទីបំផុតមួយសែនកប្បអំពីកន្លួកប្បយើងនេះ ហើយព្រះអង្គញ៉ាំងមនុស្សលោកព្រមទាំងទេវលោកឲ្យឆ្លងរួចផុតចាកសំសារវដ្ត ឲ្យចានសម្រេចនូវមគ្គនិងផលដល់ព្រះនិព្វានជាទីរំលត់កងទុក្ខទាំងពួង ។

ក្នុងសម័យនោះ មានកុដុម្ពិកម្នាក់ ចានស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាចារ្យហើយមានចិត្តជ្រះថ្លាចានទំមន្តព្រះកិកូសង្ឃ មានអង្គព្រះសម្ពាសម្ពុទ្ធជាប្រធាន ហើយចាត់ចែងនូវមហាទានចានធ្វើប្រជាប់នូវ

ទ័លនៅរមស់ខ្លួនឲ្យល្អប៉ិដូចជាកតវេទិតា ហើយចាត់ចែងឲ្យគ្រាលទ័
អាសនៈដ៏ប្រសើរ គួរដល់ព្រះសម្មាសម្ពុទ្ធ អាកាធានមន្តិព្រះមានព្រះ
ភាគថា: បពិត្រព្រះអង្គដ៏ចំរើន កាលនេះជាកាលគួរដល់ព្រះអង្គហើយ
សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃមន្តចូលទៅកាន់ភេនភត្ត ក្នុងកាលឥឡូវ
នេះឯង ។

កាលនោះ ព្រះមានព្រះភាគមានព្រះភិក្ខុសង្ឃប្រើន ចោមរោម
ជាបរិវារ ស្តេចចូលទៅកាន់ភេនភត្តដោយពុទ្ធានុភាពដ៏ប្រសើរ ហើយ
គ្រង់គង់នៅលើពុទ្ធាសនៈដែលបុគ្គលតាត់តែងថ្វាយ ។

លំដាប់នោះ កុដុម្ពិក៍ព្រមទាំងបរិស័ទរបស់ខ្លួន ក៏មានចិត្តរីករាយ
ត្រេកអរជ្រះថ្លាពន់ពេក ឃ្លានឥដ្ឋាសចង្ហាន់ដ៏មានឧជារសឆ្ងាញ់ពីសាជា
អនេក ថ្វាយព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ ។

កាលនោះ មានព្រះមហាថេរម្នាយព្រះអង្គ ព្រះនាមវសភគ្គៈជា
សាវកដ៏ប្រសើរលើសជាងព្រះថេរៈទាំងពួងឃ្លាយ ដែលជាអ្នកទ្រទ្រង់នូវ
ធុតង្គ កន្លងសាសនានៃព្រះមានព្រះភាគអង្គនោះឯង, លោកគ្រាច់ទៅ
បិណ្ឌបាតតាមលំដាប់ច្រកជាប្រក្រតី ក៏បានចូលទៅឈរដិតទ្វារផ្ទះនៃ
កុដុម្ពិក៍នោះ ។

ចំណែកឯកុដុម្ពិក៍នោះបានឃើញព្រះថេរៈហើយ ក៏ពួលអាកាធនា
និមន្តថា: បពិត្រលោកម្ចាស់ដ៏ចំរើន ! ព្រះសាស្តាគង់នៅឯណេហើយ

ជូនសង្ឃនោះ សូមលោកម្ចាស់និមន្តចូលមក ។ ព្រះថេរៈលោកពុំបាននិមន្តចូលទៅឡើយ ហើយលោកក៏និមន្តហួសទៅ ។ រីកុដុម្ពីក៏ចូលទៅកាន់សំណាក់ព្រះមានព្រះភាគហើយ ក្រាបបង្គំទូលសួរថា: បពិត្រព្រះមានបុណ្យដ៏ចំរើន បុគ្គលដែលប្រសើរជាងគេដោយគុណវិសេស រៀវលែងតែព្រះអង្គ ; ក្នុងមនុស្សលោកត្រមាំងទេវៈលោកមានដែរឬទេ ?

កាលនោះ ព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្តែងសរសើរនូវព្រះថេរៈនោះថាដូចជាបុត្រវបស់ព្រះអង្គ ហើយពណ៌នានូវគុណនៃព្រះថេរៈដោយព្រះគាថា ដូច្នេះថា:

ចាលេន្តិ និម្មលំ កត្វា ចាដិមោក្ខាធិសំវរំ
សមាធិក្ខន្ធបញ្ញា អបិច្ឆា មុនិសត្តមោ ។

អធិប្បាយថា: បុត្រតំណាងនៃព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុគ្គលមិនមានសេចក្តីប្រាថ្នា បានធ្វើនូវកិរិយាសង្រួមតាមសីលតំណាងបួន មានជាដំបូងថាសំវរសីលជាដើមផង នូវកិរិយាសមាទានបុគ្គលគុណផង ហើយរក្សាពុំឲ្យមានសេចក្តីសៅហ្មងឡើយ ។

និច្ចមន្តកយុទ្ធម្ហិ ឧទ្ធយោជាវ ឧបដ្ឋិតា
បុញ្ញានំ វត្តតេ តស្ស ឯវមាទុសញ្ញកោធិនំ ។

អធិប្បាយថា: សាវកជាពុទ្ធបុត្រតំណាងឡាយ ជាវត្តសម្រាប់បណ្តុះ

បុណ្យ ចំពោះនវជនចាំងឡាយមានទេវតានឹងមនុស្សជាដើម លោកប្រព្រឹត្តទៅដោយជំនះល្អ ដ៏ដូចជាយោធាទ្រទ្រង់នូវគ្រឿងអាវុធដោយប្រពៃ គ្រេចទៅកន្លងស្ថានចម្ងាំងគឺមរណភ័យអស់កាលជានិច្ច ។

ជាវេ មហាំ វណ្ណាវន្តំ សិរីយ្យាំ ច ជីវាំ
ពុទ្ធបុត្តា មហានាគា ជាវន្តំ ន តថាវិធំ ។

ម្យ៉ាងទៀត បុគ្គលទ្រទ្រង់នូវសំពត់មានថ្លៃច្រើន មានពណ៌ល្អផ្សេង។ ដែលគេបូជាហើយ ជាសំពត់កើតក្នុងដែនឈ្មោះសិរីយ៉ាំងណាមហានាគជាពុទ្ធបុត្រចាំងឡាយ មិនទ្រទ្រង់នូវចីវរមានពណ៌ល្អយ៉ាំងនោះទេ ។

ជាវន្តំ តេ បំសុកូលំ សង្ឃាដេត្វា ច សោតិ តេ
វណ្ណាឆាទនចោទ្យម្ហា ឥច្ចាសោកំ វិវជ្ជិត្វា ។

អធិប្បាយថា ព្រះមហានាគជាពុទ្ធបុត្រចាំងឡាយនោះ តែងវៀរចង់នូវសេចក្តីវិញ្ញាទនឹងសោកៈ ដើរស្វែងរក ប្រមូលមកនូវកំណាត់សំពត់ចាំងឡាយ អំពីកំណាត់សំពត់សំពាប់ជុំដំបៅជាដើម ហើយស្ទុះកដណ្តប់ឲ្យជាសំពត់បង្សុកូលជាប្រក្រតី ។

សាធិយាមិ សធា មាម្ភា ឧបាសក ឯមន្តំ
នេវ សាធេន្តំ សម្ពុទ្ធ- បុត្តោ ឥសក យាចនំ ។

ម្នាលឧបាសកដ៏ចំរើន ! តថាគតតែងត្រេកអរនូវការដែលគេនិមន្ត

ត្រង់កាលពាំនឹងភ្លឺ ; ម្នាលទុជ្ជសក ! មហាជនពាំនឹងឮឃើញជាបុត្រនៃ
ព្រះសមុទ្ទ តាំងពីត្រកអន្ទូរកែរយៅដែលគេនិមន្តនាន់ឡើយ ។

ម្យ៉ាងទៀត ក្តីណាសៅហ្មងក្តី ទុក្ខមិថ្លង់ក្តី ដែលអ្នកបួសត្រូវ
បាន ដោយពាន់ដែលជនឲ្យតាមសទ្ធា បុត្រពាំនឹងឮឃើញនៃតថាគត តែង
រៀវលែងសេចក្តីចង្អៀតចង្អល់ គឺចំណង់ក្នុងរសដ៏ប្រពៃ ត្រកអរចំពោះ
តែពាន់ដែលជនឲ្យដោយសទ្ធានោះឯង ។ តថាគតតែងផ្តំលើទីដំណេក
ល្អ គឺបុគ្គលក្រាលដោយកម្រាលដ៏ប្រពៃ ឯបុត្រពាំនឹងឮឃើញនៃតថាគត
តែងភ័យខ្លាចសំសារវដ្ត មិនចាន់សំរេចទីដំណេកយ៉ាំងនោះឡើយ គ្រាន់
តែសំរេចតរិយោជឈានទី៤ដើរតែប៉ុណ្ណោះ ។ តថាគតតែងទៅកន្លែ
ប្រាសាទដ៏ប្រឡាំដោយជនច្រើនខ្នះ ឯពុទ្ធបុត្រពាំនឹងឮឃើញនៃតថាគត ពុំ
ចាន់ចូលទៅកាន់ប្រាសាទដែលមានដំបូលប្រក់ចិទ្ធាំង ដូច្នោះឡើយ ។
ពុទ្ធបុត្រពាំនឹងឮឃើញនោះ តែងត្រកអរតែក្រោមដើមឈើ ក្នុងព្រៃស្ងាត
ក្នុងទីវាលល្ហល្ហៅជាប្រក្រតី ដែលពុទ្ធបុត្រពាំនឹងឮឃើញចូលទៅកាន់ព្រៃ
នោះមិនប្រយោជន៍អ្វីទេ គឺប្រយោជន៍តែនឹងចំរើនព្រះធម៌ឲ្យជាហេតុផល
ដ៏ទុតមចំពោះអ្នកពាំនឹងឮឃើញដោយអំណាចការានោះឯង ។ តថាគតតែង
ចូលទៅកាន់ស្រុកញ៉ាំងប្រជុំជនឲ្យចាន់ដល់ទូវ ព្រះនិព្វានជាធម៌ទៀងពាត់
ឯបុត្រពាំនឹងឮឃើញរបស់តថាគតនោះពុំចាន់ចូលទៅក្នុងស្រុកឡើយ គ្រាន់
តែត្រកអរក្នុងទីសេនាសនៈដ៏ស្ងាត់ជាប្រក្រតីតែប៉ុណ្ណោះ ។ ឯកិក្ខុនេះ

មានកិត្តិគុណប្រាកដក្នុងសាសនាតថាគត ជាជាអ្នកទ្រទ្រង់ទូវធុតង្គដ៏ប្រសើរផង ជាជាអ្នកជាប់ជំពាក់តែក្នុងធុតង្គពុំជាប់ផង កិក្ខុនេះឯងមានឈ្មោះថាសេក្ខត្តេ ជាសប្បុរសវិសេសឯកជាងពួកបុត្តទាទាដោយពិត ។

ព្រះបច្ចុម្មត្តសម្មាសម្ពុទ្ធជាម្ចាស់ លុះទ្រង់សំដែងយ៉ាងនេះហើយ កំលើកឡើងទូវព្រះហស្តខាងស្តាំប្រកាសគុណរបស់ព្រះសេក្ខត្តេ ដូចជាបុគ្គលចង្អុលបង្ហាញទូវមណ្ឌលព្រះចន្ទឲ្យឃើញប្រាកដក្នុងកាលនោះ ។

ឯកុដុម្ពិកនោះ កាលបើបានស្តាប់ទូវគុណកថានៃព្រះសេក្ខត្តេហើយ កំមានសេចក្តីប្រាថ្នាចង់បានទីសាវកនោះចំពោះខ្លួន ទើបតាំងប្រាថ្នាថាម៉ែដូច្នេះ ខ្ញុំសូមប្រាថ្នាទៅអនាគតសូមឲ្យបានជាសាវកដ៏ប្រសើរជាងសាវកទាំងពួងឲ្យ ដែលជាអ្នកទ្រទ្រង់ទូវធុតង្គ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គឯណាមួយជាខាងក្រោយដោយពិត ។ លុះតាំងប្រាថ្នាក្នុងចិត្តយ៉ាងនេះហើយ កំចូលទៅក្រាបទៀបបាទមូល នៃព្រះដ៏មានព្រះភាគក្នុងខណៈនោះឯង ។

សម្តេចព្រះសាស្តា ទ្រង់រំពឹងពិចារណាទូវអនាគតសញ្ញាណ កំបានជ្រាបច្បាស់ទូវហេតុនោះហើយ ទ្រង់ត្បាតរ (៣) ថា ឱធីមានព្រះសាស្តាចារ្យនាមព្រះគោតមត្រាស់ដឹងឡើងប្រាកដ ក្នុងទីបំផុតមួយសែនកប្បពីរអំពីកប្បនេះ រូបអ្នកនឹងបានជាសាវកដ៏ប្រសើរលើសសាវកទាំងពួងឲ្យ អ្នកទ្រទ្រង់ទូវធុតង្គ មានឈ្មោះប្រាកដថាមហាកស្សបត្ថេរក្នុង

កាលនោះឯង ។

ឯកុដុម្ពីក៍កំមានចិត្តសោមនស្សជ្រះថ្លា ចាប់ដើមតាំងតែពីបានពុទ្ធព្យាការណ៍នោះមកហើយតែងចំរើញនូវបុញ្ញកម្មជាបដល់អស់ជីវិត លុះច្យុតចាកអត្តភាពនោះ កំបានទៅដើតកើតសោយសម្បត្តិទិព្យដ៏មានសិរីសួស្តីក្នុងស្ថានទេវលោកនាយ អស់កាលជាអង្គឯយូរពន់ពេក ដល់មកក្នុងសាសនាកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី កំបានមកកើតជាព្រាហ្មណ៍មានឈ្មោះឯកសាដក បានបរិភោគទ្រព្យចំណាយធ្វើទានយ៉ាងធំក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ។ គ្រាន់តែអង្គាលទៅមកក្នុងស្ថានមនុស្សទេវតាសោយសុខក្សេមក្សាន្ត តុំដែលផ្ទាក់ទៅក្នុងអបាយដល់ម្តងឡើយ ។ កាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ទ្រង់បានត្រាស់ជាសម្ពោធិញ្ញាណ ហើយចូលព្រះបរមនិព្វានទៅនោះ ឯកសាដកព្រាហ្មណ៍កំបានមកជាសេដ្ឋីក្នុងនគរពារាណសី បានបួជានូវព្រះសរីរៈធាតុនៃព្រះសម្មាសម្ពុទ្ធអង្គនោះ ។ លុះច្យុតចាកអត្តភាពនោះហើយតែងអង្គាលទៅកើតសង្សារវដ្ត អស់កាលជាអង្វែង ទើបបានត្រឡប់មកកើតជាកុដុម្ពីក៍ម្នាក់ក្នុងនគរពារាណសីទៀត មានទ្រព្យសម្បត្តិច្រើនស្តុកស្តម្ភមាំមួន ដល់សម័យមួយជាខាងក្រោយកុដុម្ពីក៍នោះឯង បានត្រេចទៅក្នុងព្រៃ កំបានឃើញព្រះបច្ចេកពុទ្ធមួយព្រះអង្គ មានឈ្មោះពុំប្រាកដ ស្ថិតនៅក្នុងដងព្រៃមួយ ទៀបស្រុកជនបទជាទីបំផុតនៃដែន ។ (នៅមានត)

មហោសថជាតក

(តមក)

លោក អឹម.កន បម្រុងពីសាស្ត្រាស្ងឹកវែត

ព្រះពុទ្ធវង្ស តឹម-តួរ តិនិត្ស

ឮដំណាលនោះព្រះមហាសត្វអ្នកមើលមើលឃើញសិរីវឌ្ឍកុសេដ្ឋីជាព្រះបិតា, ឯសិរីវឌ្ឍកុសេដ្ឋីនោះកំដោះខ្ពោះខ្លែងចេញអំពីអាសនាអង្គុយនោះ ហើយសំគាល់ព្រះមហាសត្វដែលអង្គុយមើលនោះហើយថា ម្នាលបាមហោសថ ចូរបាមកអង្គុយឮដំអាសនានេះ, រីព្រះមហាសត្វនោះមកអង្គុយឮដំអាសនាដែលអាពុកអង្គុយនោះហោង ។

រីអាចារ្យទាំង ៤ មានអាចារ្យសេនក បុក្កុស កាមិន្ទ ទេវិន្ទជាដើម ឮថាអ្នកអនុតាលជឆឹដូចេ យល់ព្រះមហាសត្វអ្នកឲ្យអាពុកដោះខ្លែងហើយកំអង្គុយឮដំអាសនាដែលអាពុកនោះវិញទៀតហោង ។ រីអាចារ្យទាំង ៤ យល់ពោធិសត្វឲ្យអាពុកដោះខ្លែងដូច្នោះហើយ កំសឹងខះដៃហើយសើចដៀវត្រមគ្នា ហើយអ្នកទាំងអម្បាលនោះស្រដីតុះតិះដៀលថា អ្នកកំឡៅដូច្នេះមកថាជាអ្នកប្រាជ្ញ អ្នកឯណាកំឲ្យអាពុកដោះខ្លែងអំពីអាសនាហើយកំយកខ្លួនឯងមកអង្គុយដែលអាពុកវិញ ហើយអ្នកប្រាជ្ញនោះមិនសមគួរហៅថាអ្នកប្រាជ្ញទេ ។

ស្តេចស្តាប់តស់អ្នកផងគ្នុះគ្នុះដៀលថៅអ្នកច្រាជដូច្នេះហើយ ស្តេចមានព្រះតំរ្កត់ខោះឡើងក្រហមខុំអាក្រក់ ពុំស្រណុកកង់ព្រះរាជហឫទ័យឡើយ ។ ឮដំណាលនោះ, ព្រះមហាសត្វអ្នកទូលដណ្តឹងស្តេចថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រដ៏ប្រសើរអើយ, ស្តេចមានព្រះតំរ្កត់អាក្រក់ពុំស្រណុកកង់ព្រះហឫទ័យឬអម្ចាស់ ? ទើបស្តេចថា អើ ចៅអ្នកច្រាជអើយ, អញមិនស្រណុកចិត្តហោង ។ ព្រះមហាសត្វអ្នកទូលថា ព្រះបាទអម្ចាស់គ្រាន់តែឮអំពីដើមថា ខ្ញុំមិញគំនាប់ព្រះរាជហឫទ័យ, ឥឡូវនេះ លុះអម្ចាស់បានយល់អញខ្ញុំហើយ ក៏តើតែខ្លួនពុំគាប់ព្រះរាជហឫទ័យវិញតើហេតុអ្វីអម្ចាស់ ? ទើបស្តេចចន្ទលថា អញយល់ឃើញអាពុកជោះឡើងអំពីគាសនាហើយ យកខ្លួនឯងមកអង្គុយដែលវិញ គួរឲ្យអស់សំណើចដល់អ្នកផងពាំនាំឮ ហេតុនោះហោង អញមានចិត្តពុំស្រណុកឡើយ, ហេតុអ្វីក៏ជាមកធ្វើអំពើដូច្នេះហ៊ាន, ព្រះមហាសត្វអ្នកទូលថា បពិត្រមហារាជអើយ, អម្ចាស់គ្មានថាដ៏ហានអាពុកសំនួនតួមប្រសើរក្រៃលែងសត្វហានពាំនាំគួនឬ អម្ចាស់ ? ។ ស្តេចថា អើចៅអ្នកច្រាជអើយ អញយល់ថាដូច្នេះហោង ។ ព្រះមហាសត្វទូលថា មហារាជ បពិត្រមហារាជអើយ, មួយទៀតសោតថា ព្រះបាទអម្ចាស់ខ្ជួរអ្នកច្រាជពាំនាំឮ ជានផ្តាំទៅកាន់អញខ្ញុំដូច្នេះថា រ័ស៊ីវ័ឌ្ឍកសេដ្ឋី

ខ្ញុំវេមហោសថ ឲ្យដូនសេះអស្សតរ ខ្ញុំវេសេះសង្គតរមកកាន់យើងខ្ញុំ
ថាមែនដូច្នេះប្តូមហាកដ ។ ព្រះមហាសត្វអ្នកថា អម្បាលនោះហើយ
តំប្រែព្រះនេត្រឆ្មៀងមើលទៅកំលោះនាក់កាន់លានោះ រីអ្នកកាន់លានោះ
ជីងហេតុនោះហើយម្ចាយកលានោះមកឲ្យ ទើបពោធិសត្វអ្នកឲ្យចាប់លា
នោះទៅផ្តែកខៀបព្រះបាទនៃស្តេចស្រេច ទើបព្រះមហាសត្វអ្នកខ្ញុលថ្វាយ
លានោះរួចហើយ អ្នកខ្ញុលជណ្តើងថា បពិត្រអម្ចាស់អើយ, មួយទីសោត
រីដំឡៃថ្ងៃនៃលានេះ តើប៉ុន្មានអម្ចាស់ ? ។ ស្តេចបន្ទូលថា ម្នាលវេ
អ្នកច្រាជអើយ រីដំឡៃលានេះតិចទេ ថាបើវាទាំងមានគុណានោះ
រីដំឡៃវាកនេះអស់តែ ៧ ដំឡឹងទេហោង ។ ព្រះមហាសត្វអ្នកខ្ញុលវិញថា
ឯពិត្រមហាកដអើយ ថាបើសេះអស្សតរ មកអស្រ័យនឹងលានេះ ក៏
តើតកងនៃមេអាជាខេយ្យនាមានកំឡាំងច្រើនានោះ តើនាដំឡៃអស្សតរ
ប៉ុន្មានសោត ។ ស្តេចត្រាស់ថា ម្នាលវេអ្នកច្រាជអើយ, ថាបើ
ដូច្នោះនឹងកាត់ដំឡៃពុំបាននឡើយ ។ ព្រះមហាសត្វអ្នកខ្ញុលវិញថា
បពិត្រមហាកដអើយ, អ្វីអម្ចាស់បន្ទូលថាដូច្នោះសោត ។ រីព្រះបន្ទូល
ថា នាអាតុកកំប្រសើរលើលវែកលែងកូនសត្វហានតាំងពួងមិញ មុខជា
អម្ចាស់មិនបន្ទូលឯងឬអម្ចាស់ ? ។ ស្តេចថា វេអ្នកច្រាជអើយ អញ
ថាដូច្នោះហោង ។ ព្រះមហាសត្វអ្នកថា បពិត្រមហាកដអើយ ថាបើ

អម្ចាស់បន្ទូលថាដូច្នោះពិត , កំលានេះទត្តមក្រែលែងទំនីសេះអស្សតរវិញ
នោះកំបូរអម្ចាស់យកឯអាពុក ថាបើអម្ចាស់បន្ទូលថា សេដ្ឋតរប្រសើរថ្លៃ
ក្រៃទំនីសរវិញ , កំអម្ចាស់យកឯខ្ញុំហោង ។ បពិត្រមហាភជអើយ
រីអ្នកប្រាជ្ញអម្ចាស់នេះ អម្ចាស់ឲ្យយកអំពីឯណាមកចិញ្ចឹមឲ្យជាអ្នកប្រាជ្ញ
យល់ហាក់មានប្រាជ្ញាចេះស្រដី ។បមាមិដូចគ្នាខ្លាក់ពញាក់តពើលលើដូច្នេះ.
ទេកូវ ទំនីកេរដោះប្រស្នាតែតម្រិះខ្លួនឯងគំពុំបានផងសោត ម្តេចឡើយកំ.
ហ៊ានស្ទើចទះដៃដៀលអញហ៊ាន , ថាឯអ្នកប្រាជ្ញអម្ចាស់ប្រកបន្ទរប្រាជ្ញា
ដូច្នោះទេកូវ អម្ចាស់ចិញ្ចឹមឲ្យហៅថាអ្នកប្រាជ្ញវាបង់ឈ្មោះអ្នកប្រាជ្ញតែទេ
អម្ចាស់ ។ ព្រះមហាសត្វអ្នកដៀលអ្នកប្រាជ្ញទាំង ៤ នោះហើយ មក
សូត្រជាបទគាថានេះមានឮដំកុងតម្ពីរឯកនិបាត ។

ហាសិ តុវំ ឃវំ មញ្ញសិ សេយ្យោ បុត្តេន បិតាតិ
ភ ដ សេដ្ឋ ហន្ទ សុត្តរសុត្ត តេ អយំ អសុត្តរសុត្ត
ហិ កន្ទ្រកោ បិតាតិ ។

បពិត្រមហាភជប្រសើរក្រែលែងភស្តុផងទាំងឡាយអើយ សម
អម្ចាស់គ្មានសន្ទិដ្ឋានស្មានជាអាពុកប្រសើរថ្លៃ ក្រែលែងកូនសត្វហានទាំង
ពួងឬអម្ចាស់ គ្មានអនុគ្រោះកុងព្រះហឫទ័យដូច្នេះថា បើដូច្នោះសមជាលា
ប្រសើរថ្លៃក្រៃទំនីសេះអស្សតរហោង, រីលានេះ ប៉ុន្តែគ្មានទំនីអាពុក

អស្សត្ថរ ឬ ទឹងប្រសើរថ្លៃក្រៃទឹងសេះអស្សត្ថរមិនបានឡើយ ។

ព្រះមហាសត្វអ្នកថាអម្បាលនោះហើយ អ្នកឲ្លូលវិញថា បពិត្រមហាក ថាបើអាពុកប្រសើរថ្លៃក្រៃលែងកូននោះ កំព្រះអង្គយកអ្នកអាពុកវិញ , ថាបើកូនប្រសើរថ្លៃក្រៃលែងទឹងអាពុក តំអម្ចាស់យកឯអញឱ្យហោង អញឱ្យបំរើព្រះបាទអ្នកជាអម្ចាស់ហោង ។

រីព្រះបាទវិទេហកជ ស្តេចស្តាប់បម្រើយពោធិសត្វដោះសាអាថិប្រស្នានោះហើយ មានព្រះកដជាឫទ័យដំលុះខ្លាំសោមនស្សសាទរក្រៃពេកក៏ជប់សេចាំងឡាយនោះ ឲ្យសាធុការព្រះមហាសត្វជាពាន់ជង ដំមានស័ព្ទសម្រែកជាដើមថា ប្រស្នានេះ ចៅអ្នកប្រាជ្ញធ្វើយពីពេះ ។ ប្រពៃក្រៃពេកហោង សឹងដំទះដៃរំកាយកន្ទែងរវែងមាល ។ រីអ្នកប្រាជ្ញចាំង ៤ នោះមិញ ដំមានមុខនោះអាក្រក់ខ្មួលស្រួមសុបសៅនៅ ។

រីពាក្យចំណោទចោទថាដូច្នេះ នាបីហៅអ្នកឆងចាំងឡាយកំទឹងដំងគុណម្តាយ-អាពុក ទឹងលើសត្រៃទឹងស្មើពោធិសត្វនោះឥតអង្គីមានឡើយ ហេតុអ្វីព្រះមហាសត្វក៏ក្លើដូច្នេះ ? រីពាក្យបម្រើយថាដូច្នេះ ឯប្រយោជន៍អ្នកទឹងមើលងាយអ្នកជាអាពុកឥតអង្គីមានឡើយ ។ បទតែស្តេចប្រើឲ្យអ្នកស្រុកឯកើតជូនសេះអស្សត្ថរមកហោង ។ កំព្រះមហាសត្វអ្នកធ្វើដូច្នេះ ធ្វើប្រយោជន៍ទឹងឲ្យល្អាស់នៃប្រស្នានោះឯង, មួយទៀត

ប្រយោជន៍ធំធេងសំដែងក្រាបថ្វាយអាត្មា, មួយទៀត ប្រយោជន៍ក្តីឲ្យអាស្រូវ
តាសនៃអ្នកក្រាបថ្វាយទាំង ៤ នោះឯង ។ តន្ត្រកបញ្ហោ និដ្ឋិតោ ។
រីឯធំស្រដីអាចប្រស្នាព័តាលល្បងលាមិញ កំស្រេចនូវប្រការអម្បាលនេះឯង
ហោង ។

ភជា តុសិត្វា ។ ល ។ រីព្រះបាទវិទេហរាជ ស្តេចមាន
ព្រះរាជហឫទ័យត្រេកអរ ហើយស្តេចយកកុណ្ឌីមាសដ៏តេញនូវទឹកអប់
ត្រឡប់នូវតន្ទពំដោរប្រសើរស្រេច ស្តេចច្រួចលើដៃមហាសិរីវិឌ្ឍកសេដ្ឋី
ហើយស្តេចមានព្រះបន្ទូលមធ្យត៍កេះថា ម្នាលសេដ្ឋី ចូរព្រះស្តេងចរកោត
ស្រុកជាច័ន្ទយវមជ្ឈគ្រាម ចូរធ្វើអំពើនូវសម្បត្តិក្រមក្រីត្យជាស្តេចហោង ។
ហើយស្តេចបន្ទូលនឹងមហាសេដ្ឋីសំណល់លែងនោះថា ម្នាលសេដ្ឋី
ទាំងឡាយអើយ ចូរព្រះស្តេងឡើងចុះគាល់ហ្អែនៅចំរើសរីវិឌ្ឍកសេដ្ឋីដូច
អ្នកផងនឹងចំរើអញ្ជាហោង ។ ស្តេចថាអម្បាលនោះហើយ ស្តេចឲ្យណ្តាច់នូវ
គ្រឿងជារង្វាន់ប្រជាប់ទាំងពួង ឲ្យដូនៅព្រះមាតាតោធសត្វនោះហោង ។

រីព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យជ្រះថ្លា ទ្រង់ព្រះអំណរ
អនេងអាចប្រស្នានោះហើយ ស្តេចទទឹងយកតោធសត្វជាកូន ស្តេចបន្ទូល
ថា ម្នាលសេដ្ឋី ចូរព្រះស្តេងឲ្យមហោសថបណ្ឌិតជាកូនសំឡាញមក
អញ្ជាហោង ។

(នៅមានត)

រឿងមរណមាតា

(តមក)

លោក ប៉ី-សុវណ្ណ ចម្លងពីសាស្ត្រស្ងឹកវិត

ស្តេចពេញមេត្រី អាឃិអគ្គមហេសី វែងវិងស្នេហា ខត
ហើយមហាកប្បត្រ សួរថ្លាត់ៗថា ម្ដៃទាងធីតា តាលចាកបុរី ។
ជាសត្វសាកៃ ហើរហើយយាត្រា លំបាកក្រក្រី ឋ្មមួយយ៉ាងណា ម្ដេច
ម្ដាក្សត្រី ចូរប្រាប់សេចក្ដី ឲ្យដឹងថ្លៃថ្លា ។ នាងស្ដាប់ស្ងាម៑ សួរ
សព្វសេចក្ដី ទុក្ខសុខអាត្មា នាងទូលរៀបរាប់ ដោយកិច្ចការ ដូចបាន
ពណិនា អំពីមុនស្រាប់ ។ ស្តេចស្ដាប់មហេសី ទូលសព្វសេចក្ដី
ទុក្ខសោករៀបរាប់ ពីនាងលំបាក តោកយ៉ាកអង្គអាប់ អង្គឲ្យអក់ព្ង
ព្រោត់ព្រះនេត្ត ។ ស្តេចមានព្រះទ័យ អាសូរនាងក្រៃ សង្វេគ
អនិច្ច អាក់អួលអាណិត ផ្អែតផ្អួតនុក ព្រះហស្តប្រាប់ ទុចអង្គមហេ-
សី ។ ទ្រង់ព្រះសោកា ទោះទន់កាយា ព្រះបាទចក្រី ញាប់ញ័រ
ចំប្រប់ សន្ធប់ស្មារតី ព្រះស្ងំសាស្ត្រី សឹងយំគ្រប់គ្នា ។ បន្ទោរសោក
ស្រេច នោះទើបសម្ដេច បរមកជា ឲ្យរៀបពជ្ឈាន សូរ៉ាគនសោកា

ភហានយោធា ចតុរង្គពលនិកាយ ។ ស្តេចយាងចូលទៅ អាស្រម លំនៅ ក្សត្រីនោមនាយ លុះឥលក្សត្រក្សត្តិ ចុះយានសិវិកាយ យាង ចូលទៅថ្វាយ បង្គំឥសី ។ រៀបភ័ស្តុនានា ខៀនធួបភ្ជាំ ភារៈ តើចំណី ដំកល់កាជន៍មាស ឆ្នុះធ្វាសរស្មី មហាក្សត្រពាំង៣ ចូល ថ្វាយនមស្ការ ។ ផ្កាមាសផ្កាប្រាក់ ផ្កាកែវផ្កាគ្នាក់ លើកថ្វាយ ព្រះមហា ឥសីរួចស្រេច ទើបស្តេចសួរសារ សព្វគ្រប់ប្រការ ទុក្ខ សោកអ្វី ។ ។ ឥសីថ្វាយពរ សាសន៍ទៅមក ស្មានស្មោះ មេត្រី ស្រេចហើយក្សត្រា ទូលមហាឥសី ថាសូមក្សត្រី មរណមាតា ។ ន័ងរៀបអគ្គ- សេកសូមឡើងខ្ញុំ ជាអគ្គមហា មហេសី ទុត្តម សូមសុំមេត្តា ឥសីសីលា បើកតាមព្រះទ័យ ។ ស្រេចក្សត្រពាំងបី លាព្រះឥសី យាងយាសវិលវៃ មកអាស្រមនាង ជិតខាងជលសៃ កុមារ បុត្រថ្លៃ តង់គាល់ថ្ងៃតា ។ ទើបក្សត្រនរោត្ត ត្រាស់ប្រើអមាត្យ ឲ្យតែង រថនា ពេងរ័ត្នលលង់ សង់ត្រុះពន្លា រួចស្រេចក្សត្រា ឡើងគង់សុខ សាន្ត ។ លុះបានពេលា ជោគជ័យជតា ល្អល្អះបើកបាន ស្តេច ប្រើខ្ញុំនណាង ស្អាងនាងកលប្បាណ ហែយាងទៅហាន ពេងរ័ត្នរថនា ។ គង់លើផ្ទះរ័ត្ន ព្រាហ្មណ៍ព្រឹទ្ធសារសេត្យ សារសូត្រសាត្រា ស្តុតី មង្គល សកលជយោ ព្រឹកព្រាងសុរិយោ បង្វិលពពិល ។ ប្រគំ ជន្ត្រី ត្រែ.ម៉ង្ហឹកគ្រើ ក្អេងក្អាងទាមទិល មានច្រៀងថ្វាយពរ កំដរពពិល

ជំរះមន្ទិល ចង្រៃចាំងឡាយ ។ ទើបយកតពិល មាសមកបង្ហិល
មន្ត្លកបកាយ ហើយរៀបក្តីផ្កា បុប្ផាវត្ថុថ្វាយ ទេព្តាចាំងភ្លឺឡាយ
បិតសព្វបព្វតា ។ ខ្ញុំមន្តឥសី សារសូត្រស្មុតី ឱ្យពរព្រះមហា
មហេសីតួម ឱ្យសមសក្តា ឥសីសីលា សូត្រថ្វាយវរៈ ។
អាយុវណ្ណំ សុខំពលំ ជយជយោ ជយតុករំ រដ្ឋសោភ្ជេ
សុខត្តិយោ មហារាជា ។ ឥសីសូត្រចប់ ស្មុតីសារសព្វ ទើបព្រាហ្មណ៍
ព្រឹទ្ធា សូត្រថ្វាយតាមក្រោយ បណ្តាយកល់គ្នា ភរិយោងា ថ្វាយពរ
អឺងកង ។ ខុទណាងចាស់ខុំ អស់យោយស្ងួតស្ងាំ ថ្វាយពរត្រមង
ប្រគំជន្ត្រី កេរ៉ែពេង ត្រែស័ង្ខផ្ទុងផង ហៃស្រង់តង្គ្នា ។ ហើយថ្វាយ
ព្រះនាម ក្សត្រីខ្មែតាម នាមដើមនោះណា សម្តេចមហេសី សិរី
សេដ្ឋា មរណាគា បរមចពិត្រ ។ អភិសេកក្សត្រី តំរង់ថ្លៃបី
អស់ចាំងស្ងំស្ងុំ សឹងសុខក្សេមក្សាន្ត ពុំមានភ័យកិត ទើបស្តេចគន់
គិត លាត្រះឥសី ។ លុះបានពេលា ឫក្សដ៏ជោគជា ទើបព្រះបក្រី
ឱ្យរៀបកជយាន សូវ្យកាន្តរង្ស៊ី ជុំពលសេនីយ យាងចូលនគរ ។
ទើបក្សត្រចាំងបី ឡើងលាឥសី ទឹងវិលចេញបរ ឥសីសីលសាយ
សោតថ្វាយព្រះពរ ថាបើស្តេចបរ ស្តេចចេញយាត្រា ។ ឱ្យមានតេជះ
ជោគជ័យជំនះ សត្រូវនានា ឱ្យមូលមហេសី ក្សត្រីក្សត្រា ឱ្យគ្រងរដ្ឋ
ក្សេមក្សាន្តពស្ត្រផង ។ ទើបក្សត្រចីអង្គ ខ្លួនពរម- ង្គលគាថ៌កន្ទង

ក្រាបលាឥសី មុនីឥតហ្មង ឯក្សត្រីច្បង ខ្ញុំវរាជបុត្រា ។ អ្នកទំពក់ស្រោណោះ
អាល័យអាឡោះ ឥសីសីលា ធ្លាប់នៅសាន្តសុខ ឥតខ្វក់ខ្វិចិត្តា ឥសី
មេត្តា តែសត្វ។ ថ្លៃ ។ ឥឡូវយើគ្រា ចាកចោលព្រះមហា ឥសីសីលថ្លៃ
ទុសមអ្នកស្ងាត់ យើងខ្ចាត់ឃ្លាតឃ្លៃ មានតែសត្វព្រៃ កំដរជាគ្នា ។
ទុអាស្រមយើង ធ្លាប់នៅចុះឡើង សុខសត្វវេលា ឥឡូវយើងៅ ចោល
នៅសាធារណ៍ សូន្យស្ងាត់មហិមា រលើងឆេងទេ ។ នាងទំពក់ឥសី ទំពក់ដល់
កុដិ ធ្លាប់នៅធ្លាប់ថៃ ទេត្រនាងហូរទ្លុយ សត្វសាយការយ ខ្ញុំក្តួងខ្ញុំ
សែនខ្លៃ ផ្អែតផ្អិតទុក ។ ឥសីបានឃើញ ក្សត្រីរ៍ខ្ញុំកូនលើ លួងឱ
លោមៅថា សូមស្តេចក្សេមក្សាន្ត សំពន្ធចិត្តា កុំគិតអាត្មា នាំ
ឲ្យកើតវេរ ។ ឥសីលួងថ្នាក់ ទើបចាំងចីក្សត្រ គ្រាបលាចេញចរ
ចេញចាកឥសី មុនីបវរ ពួកពលនិករ ប្រៀបប្រុងអាគ្នា ។ ឯក្សត្រ
ចីអង្គ ស្តេចយាងឡើងគង់ ទីនាំងរថា ព្រះបទុមវង្ស ស្តេចគង់
អស្សាហន៍ អភិរមា មើកចាំដ៏ថ្លាយក្សត្រ. ។ ព្រះបាទវិមល គង់
យានមង្គល គជេន្ទ្រសារសត្វ មូលទំនឹងមហេសី ក្សត្រីរ៍បវរ៉ត្ន គង់មែប
មហាក្សត្រ ចេញចរយាត្រា ។ ប្រុគំដន្ត្រី ត្រែស័ង្ខខ្ទុយប៉ី សំភោរ
រមនា ក្អេងខែកពីងពាង មានចាំងស្គរជ្វា តាំងរហ័ចីគ្រា កក្រើក
ព្រឹក្សព្រៃ ។ ព្រះបទុមវង្ស ស្តេចទ្រង់ប្រើអង្គ ប្រើសមាសវិលវៃ ៅ

រកសេនា អាត្មាពេញចិត្ត ប្រើសមាសអាវក្រៃ លាស្តេចយាត្រា ។
ព្រះបទុមវង្ស កុមារវ័ន្តង្គ រីឯបុត្តិក្សៀវក្អា ចេញជាខ័ពស្រួច ត្រដួចយាត្រា ពួកពលសេនា ប្រាំពីរគោះ - ។ កិនិច័មាន ហែមុខក្សត្រ
ក្សាន្ត សប្បាយនោះឡា ព្រះអង្គប្រណាត រុក្ខជាតវនោ វនេចព្វតោ
ត្រៃត្តិហ៊ាមភាន្ត ។ ព្រះបាទវិមល ធម្មកដប្តើនឆ្កល់ ស្តេចលើកទាហាន
ប្រពាតសប្បាយ ស្អាកស្អាយក្សេមក្សាន្ត បង្ហាញហ៊ាមភាន្ត មហេសី
ធីតា ។ ព្រះបទុមវង្ស ឃល់ប៊ិតទ្រង់ ក្រសាលត្រឹកក្ស អ្នកយាង
ចូលជិត នៃបនិត្សបិតា រៀបរាប់ត្រឹកក្ស ថ្វាយក្សត្រឥណ្ណាយ ។
ជួរវនេមង្ឃឹត ក្រូចក្រាយស្វាយល្មុត ដកឥដកឥឆាយ ដើមដុះទាបស្រាប់
លួតចាប់បេះងាយ ផ្លែទុំជ្រុះពាយ ដោយដីត្រៀបត្រា ។ ពួកពលតាំង
ឡាយ បេះស៊ីវែកស្ពាយ តាសពេញត្រឹកក្ស មាក់ប៉ែនចេកចាន់
សិរមាន់សៃដា មៀនខៀបត្រៀលស្ងា សន្ធាន់សន្ធៃ ។ ផ្លែត្រាលខែងទុំ
ផ្លែមដូចតឹកឃ្មុំ ជុះដាសតាសត្រៃ មើលឃល់សឹងយប់ ជាមួយត្រឈៃ
ផ្លែតាបល្មុកដៃ បេះចាន់គោក្តា ។ មាក់ប្រេងមាក់ក្រូច មាក់ដោក
មាក់សាង ក្រូចក្រាយទាទា ទ្រមូងក្រពាន់ តាប់តាន់ត្រៀបត្រា ខ្នាប់
ខ្នា ទ្រមែងត្រើងទុំ ។ ពង្រីតង្រៀង ដើមល្វារៀង ៤ជ្រើង៤ជុំ
បង្អាបង្អៀ សារមាំវិនិងភ្លួម ខ្ញីតខ្ញាវស្រែតំ កំងកេតត្និលស្ងៅ ។

ត្រឡុបក្រឡាញ់ អង្គើលអង្គាញ់ អំពិលអំពៅ ឥឡឹកឥឡោក មាក់ដោតជុះខៅ ម្រំម្រោមម្រុះព្រៅ ត្រឡតត្រឡាត់ ។ ផ្លែល្អក្រគាល ខ្លះខើចស្រគាល ខ្លះក្តិចច្រែនក្តាត់ ខ្លះពុំជោរជាំ សត្វពាំខ្លាយខ្លាត់ ជ្រុះដែលមាត់សត្វ ដោយដីពេញពាស ។ ស្វាយចេកស្វាយក្បាល- ដំរីពុំប្រាស ស្វាយមីងស្វាយមាស ស្វាយឥន្ទសាំ ជ្រុះខ្លាំពេញពាស ស្វាយក្រាមរមាស ក្បាលសេះអង្រ្តែង ។ ផ្លែឈើហ៊ាមពាន្ធ ផ្លែផ្លាមិនមាន រជូវឡើយហោង ខ្លះផ្លាខ្លះផ្លែ ហូរហែរជាមួង ខ្លះពុំពាំនែនតាបល្មមបេះបាន ។ ដើមខ្ពស់មានមែក ពាក់ព័ន្ធញឹកញែក ជាថ្នាក់ជាស្តេន ទំនឹងឡើងកំរាយ សប្បាយឈរឈាន ចង់ដើរកំបាន មិនភ័យខ្លាចខ្លាត់ ។ មែកវែងត្រសាយ យារយុរយោកឆ្ងាយ ត្រសុំត្រសាក់ ទំនឹងឈប់ចាត់ក្តៅ មានស្មៅត្រជាក់ ក្រោមដើមដូចម្តេចលាតលាកខ្នើល ។ ស្មៅស្មើត្រឹមធេង បើចង់ដេកលេង លុះលក់រឿងរេល គ្មានមូសសុចស្មោះ ដេកចុះរំណែល ធូលីមិនដែលហូរជាប់មុខមាត់ ។ ឯខ្យល់មកវាល បោកបក់ឲ្យស្អាត ឆ្អែះឆ្អាបស្អុយចាត់ ហើយបក់ក្លិនផ្កា ប្លុងផាយផាត់ ល្វេងល្វើយតេកក្តាត់ សាយសព្វព្រឹក្សា ។ ស្រឡឹតស្រឡៅ ម៉ូរតួនស្រី ចំប៉ីចម្ប៉ា រំដួលរំដេញ ពាសពេញបព្វតា រំចេកយុក្តា សារិយុតមហាហង់ ។ វែង

រែកស្ទុះស្ទាយ ធ្លុំកូនតកាយ សាយសព្វអង្គ ក្ងិនក្លាយឆ្អែះឆ្អាប
ដកបង្កាត់បង់ សូរសេពកន្ធរ ជញ្ជក់តេសរ ។ ដូចសូរសេពកន្ធរ ពីពេះ
ល្ងើយល្ងង់ កងព្រឹក្សាករ ពួកពលទាហាន ក្បែរក្បាន្តត្រែកអរ
សោមនស្សស្មោះសរ ក្អេងបុត្រតរៃយោ ។ យោធយោសសប្បាយ ផ្លែ
ឈើតាំងខ្លាយ មានរសឆ្ងាញ់ ស្តេចសោយស្កប់ស្កល់ ត្រប់ផលព្រឹក្ស
មហេស៊ីធីតា សឹងសោយសប្បាយ ។ ពួកពលសេនា ចតុរង្គអាសា
ទាហានតាំងខ្លាយ ឃើញព្រៃហិមពាន្ត ក្បែរក្បាន្តសប្បាយ ឡើង
លេងប្រញាយ ដោយព្រៃព្រឹក្ស ។ ខ្លះទៅរៀងភ្នំ ឡើងឈើតូចធំ
បូតបេះផលា ខ្លះបុះរំលូតទឹក ពន្ធឹកវង្វាំ លោតលេងបេះផ្កា ឈូកស
រឿងកយ ។ ផ្លែឈូកក្រៃ ឈូកឈោងដៃទៅ បេះបានដោយងាយ
កងទឹកគ្មានឈ្នើង ទាមជើងជាប់កាយ ហែលលេងសប្បាយ ទាល់
ល្ងាចឥតអ្វី ។ ក្រតើពេញពាស ខ្លាចមនុស្សម្នាណាស់ ពួនដោយ
រូងដី មិនដូចក្រតើ ស្រុកយើងខ្មៅ ព្រហើនពេកក្រៃ ទាំមនុស្សស្មើ
ហោង ។ គាក្បែហិមពាន្ត ឃើញមនុស្សពុំហ៊ាន តាធាយើងផង
គ្មានចាញ់ទឹកដី ប្រុសស្រីជាមួង ឱនោមដុះហោង មិនខុសអ្នកតា ។
មិនព្រួយនឹងតម នឹងកាន់ត្រណម លេងស៊ើបម្តេចខ្លា មិនចេះខុសមាត់
ភ្ញាំងក្លាត់ត្រដំណា តាមតែនឹងថា ម្តេចៗក៏បាន ។ ដើរលេងតាមចិត្ត

សប្បាយដូចគ្នា ត្រែកអង្រែប់ប្រាណ ខ្លះរើសត្បូងពេជ្រ ដោយខ្លាចតំមាន ខ្លះកាប់ត្បូងបាន ជុះដោយខ្លួនឯង ។ ពួកពលទាំងឡាយ ដណ្តើមប្រញាយ សើចសាំនត្រែកអង្រែ ខ្លះរើសបានច្រើន ក្រអើនរំភើក ខ្លះគ្មានលួចលាស លួចលេងជាល្បែង ។ ខ្លះបានផ្កាឋ ខ្លះបានដីស ច្រកជាលវែកសែង សំបកខ្យងខ្ចៅ លៀសជាវគ្រំគ្រែង សម្បុរច្រាលវែង ខ្លះខ្យៃខ្លះស ។ ខ្លះលឿងខ្លះខ្មៅ ខ្លះដូចគេដៅ បញ្ចេញណិស្រស់ល្អ ពួកពលទាំងឡាយ តើបកាយរើសយក ខ្លះយកតែវត្ថុក្រឡឹងដន្ទាប់ ។ ជាក់ក្តុកដំរី រនេះសាលី សូរសាំនអឺងកង ខ្លះឃើញថ្មប្រឺ ត្រែកដីជុះជាប់ ថ្នាំងញឹកហើយកាប់ ធ្វើខ្យៃជក់ថ្នាំ ។ មានកោដន៍សាលី ជុះជាសដោយដី ហាក់ដូចអ្នកដាំ គួរែងមួយហត្ថ ច្រើនក្តាត់ជ្រុះខ្លាំ បើបន់ដណ្តើ ជាយបរិភោគ្គា ។ ទៅបូតយកមក មិនព្រួយបុកបក ផុំស្មៅឡើយណា ផ្ទៃជាអង្គរ ស្អាតល្អជ្រះថ្លា សម្បុរដូចផ្កា ម្ជុះលាក្រពុំ ។ បូតបានច្រើនកែ ច្រកក្នុងឆ្នាំនវែ ដាក់លើក្រានផ្ទុំភ្លើង ឆេះរំគេច ពុះស្រេចជាត់ផ្ទុំ ឆ្អិនដោះរៀបចំ បរិភោគសប្បាយ ។ មិនព្រួយរកត្រី រកម្ហូបអ្វី ឥឡូវឆ្ងាយ បរិភោគខេ ដូចរសសាយ ឈ្ងុយឈ្ងប់លើសជាយ ស៊ុនឆ្ងាស់ឡ ។ ពលទាំងប្រាំពីរ- អាខោប្រឹងវីរ បូតបានល្អ ។ ត្បាញជាលច្រកច្រើន

ក្រវើនទឹងយក៍ ទឹងដកទាំមក៍ ផ្លើកូនប្រពន្ធ ។ ខ្លះស៊ីម៉ែមឈើ ផ្លែឈើសារតើ ផ្លែតន្ត្រន់លើសលន់ ចាត់ឃ្លានចុយសោះ ស្រួលស្រស់ពេកពន់ កំលាំងលើសលន់ មាំមួនធំជាត់ ។ មានឈើត្រឿងខេស ថ្នាំទំពូរសេស រំសាលច្រែនក្តាត់ ដួងចាន់ក្រឹស្ណា កង្កុរស្នែងសត្វ កំចាយកំចាត់ ក្លាំពាក់ក្លាំពា ។ កំញានដីប្លី ក្រវាញកាតី សម្បុរលែងល្អ កគោកកគោះ ខ្ទៀលត្រស់ធ្ងន់ធ្ងា ពជង្គុះខន្ធា កណ្តឹងជំរី ។ កុមារពេចពួច សង្ឃរសេង្ហួច សង្ឃាស្មែស្មី លំពាកលំពោះ មោកមោះមេត្រី ស្មាច់ស្មាក្រមើ ក្រចៅចកមាស ។ ម្រេចម្រំអង្គ្រង សំកេងកូកូង កំងកេកពជជាស កណ្តាលកណ្តាក តាថុកខ្លែងខ្លាស់ ចង្រ៉ាសអាកាស កែវកាសកន្ទី ។ គោតសគោតខ្លៅ តោនពេជ័ក្សៅ សារយុតខន់ដី ក៏យវើកក្លៅមាន់ តោតពាន់តីសី ប្រស់ប្រដំណ្ហោលញ៉ី ញាញោកសិលា ។ ចំរុះបាកាល ឯអន្តេយ្យណ្ហាល តំកុលតំកា លំពាន់ បំពាំង មាសម៉ាំងមេដា មានម្ខាងសិលា លោតលៀបលាំងដៃ ។ ព្រះមួបព្រះក្រាប ព្រះក្រុងរដ៏ចាប ចេកចាកតោនតៃ រលួមរលោយ ក្រូចក្រាយធ្នងដែ្ន សណ្តាន់សន្លែ សន្ធះឡងវ្យា ។ ពាពុកឆ្នាជ្រុង ពេគកកសំពុង គ្នាមគ្នាតកា រៀបគាគារ ផ្ចាគួបចារ សម្រែកកុមារ កុមារសមហាភិក្ខុ ។ ចិត្រមួបក្តើង ភ្ញាំងដោង

ឈើភ្លើង កន្ត្រោកប្រយង្គ ស្រមពាកក សម្រែកច្នៃចិន កណ្តាលកណ្តឹង ដំរីវែងភ្ញា ។ រំដួលដោះខាង ដោះទឹងឥដ្ឋាង ក្រញ្ជាំក្រញ៉ាញ ក្រញាំសុខ ចំបក់ប្រដាញ ប្រដាក់ម្រះម្រែញ ត្រមាមដៃខាងនួន ។ សហស្សគុណ តាំងទុំតាំងគុណ ដាំដុះប្រក់គួន ប្រក់ដីសីសាច់ស្មៅស្មាច់មុខបួន លីងលាក់ត្រកួន កន្លែតទុំម្ភរ ។ ស្លាក់ស្លែងស្លុតស្លឹក សោកមាំកញាតញ៉ឹក កំខ៊ិកំខរ កំខេចប្រាក់ប្រញ រំដេញជកពរ ជកពាយពាយវរ រមៀតមៀនមង ។ ជន្លសជន្លាត់- ដៃដើមពាល់ពាត់ ចោះប៉ាយហ្មាត់ហ្មង ស្រកាក្តាមក្តាត ស្តុំស្ងាតជូនដង ដើងដីសដុះរង សំពោងពេតពាជ ។ ឈើឯមអកលួង អកពាជតបជូង កញ្ជើចាយជាច ជ្រួយច្រេសច្រកែង-ខួយតែនច៏ប្រាច ប៉ប្រក់ស្នាយស្នាច ខាងនិលពាស៊ ។ ជន្លួញកំងក្តុំ រុះពេនសុក្រំ សុក្រាចចាល ដំប្លីចំបក់ ត្របកឆ្មេញត្រី ក្រចកក្រចើ កប្បាសព្រៃត្រាល -។ ប្រមាត់ដាំដុះ ក្អែកព្រាបលាជជុះ កង្រ្កៀលមហាកាល មហារីកស្រឡប់ ឆ្នួនឆ៊ីតពាល ខាត់និលចាក់ជាល ចាក់ដោរជាតព្រឹក្ស ។ ដូងដុះសែជា ខោលទឹកដោះខ្ចា ប្រមាត់សត្វម្រឹគ ត្រចៀកប្រើសក្រោង លោតលោងប្រកែក ស្រវឹងផ្តក់ទឹក ផ្តក់ខេសខ្លូសកេ ។

(នៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

រឿងនាងសក់ក្រអូប

លោក ញ៉ែម-វឹម រៀបរៀង

កាលពីសម័យដើម មានស្តេចមួយព្រះអង្គព្រះនាមបទុមពរសោយរាជ្យនៅកន្លែងគរកូមា ។ ព្រះមហាក្សត្រអង្គនោះទ្រង់សព្វព្រះរាជហឫទ័យចង់បាននាងសក់ក្រអូបធ្វើជាមហេសី ។ នាងសក់ក្រអូបជាស្ត្រីមានរូបឆោមលោមពណ៌ល្អក្រៃលែង តែនាងមានព្រះស្វាមីរួចទៅហើយ គឺព្រះបាទបយង្ការសោយរាជ្យនៅនគរគ្រាំង(១) ជិតភ្នំជើងកងដុំ ។ ព្រះនាងសក់ក្រអូបនេះទ្រង់មានព្រះរាជបុត្រមួយ ព្រះនាមព្រះបាទព្រះហស្តខ្វី ។

ដោយព្រះបាទបទុមពរនៃនគរកូមា ទ្រង់ចង់បាននាងសក់ក្រអូបធ្វើជាមហេសីពន់ប្រមាណ ព្រះអង្គក៏ទ្រង់សម្រេចព្រះទ័យថានឹងដណ្តើមយកនាងសក់ក្រអូបដោយកលឧបាយឲ្យបានតែបាន ។ ដូច្នេះ ព្រះអង្គក៏ទ្រង់គ្រាស់បង្គាប់ឲ្យគេធ្វើក្បូនមួយយ៉ាងធំ នៅកន្លែងត្រពាំងមួយឈ្មោះត្រពាំងខ្ទក ដែលកាលជំនាន់នោះជាសមុទ្រ រួចព្រះអង្គក៏នាំនាងកាវ៉ែនឯងពួកក្មេង

១– គ្រាំងជាខេត្តមួយនៃប្រទេសកម្ពុជា ឯកនៅខាងទិសឦសានៃក្រុងភ្នំពេញ ពីដើមគេច្រើនហៅថា ជីគ្រាំង. មានខេត្ត ១១ រួមបញ្ចូលហៅថា ខេត្តគ្រាំង: គឺ គ្រាំង , បន្ទាយមាស ៣ម, កំពត, កោះធំ, ស្ពឺង, ព្រៃកប្បាស , បាទី , កណ្តោលស្ទឹង , ឧដុងពិសី ចឹងភ្នំស្រួច ។

ទៅលេងកំសាន្តលើទំនោះ ព្រមទាំងបានអញ្ជើញស្តេច នឹងព្រះនាង សក់ក្រអូបទៅរួបរួមជាមួយនឹងព្រះអង្គផង ។

ជាអកុសលនៅថ្ងៃនោះ, ព្រះបាទបយង្ការមិនបានយាងមកកាន់ទី កំសាន្ត តាមសេចក្តីអញ្ជើញនៃព្រះបាទបទុមវរះទេ ព្រះនាងសក់ក្រអូប ទ្រង់យាងមកមួយអង្គឯង ជាមួយនឹងព្រះរាជបរិវារ ។ ព្រះបាទបទុមវរ ទ្រង់សង្កេតឃើញព្រះនាងយាងមកមួយអង្គដូច្នោះ ហើយនៅពេលដែល ព្រះនាងកំពុងតង់តអង្គកំនឹងស្តាប់ភ្លេង ក៏ទ្រង់លបកាត់ពួចនឹងក្បួនបណ្តែត ចេញទៅកណ្តាលសមុទ្រ ។ អាស្រ័យហេតុដូច្នោះហើយ បានជានាង សក់ក្រអូបត្រូវព្រះបាទបទុមវរ ចាប់នាំយកទៅដល់នគរកូមា ។

ព្រះនាងក៏ត្រូវស្តេចបទុមវរ បង្ខំឲ្យនៅក្នុងនគរបស់ព្រះអង្គ អស់ កំឡុង ៦២ ឆ្នាំ ។ នៅពេលនោះ ព្រះអគ្គមាស់ព្រះហស្តខ្វិកំទ្រង់ធំពេញ វ័យហើយ ។ ព្រះអង្គក៏ទ្រង់សួរទៅបិតាព្រះអង្គថា តើព្រះមាតាព្រះអង្គនៅ ឯណា ។ ស្តេចបយង្ការតបទូលប្រាប់ថា ស្តេចបទុមវរសោយរាជ្យនៅ នគរកូមា, បានមកលេងនឹងព្រះអង្គតាមក្បួនមួយយ៉ាងធំ ។ នៅលើក្បួន នោះ មានពួកនាជការនឹងពួកភ្លេងជាច្រើនមកជាមួយព្រះអង្គផង ដើម្បី នឹងមកអញ្ជើញមាតាកូនឲ្យទៅលេងជាមួយ ហើយនៀតយកឧកាសដែល មាតាកូនឯង ឃាត់ទៅតែម្នាក់ឯងនោះ, ចាប់មាតាកូនឯងយកទៅបាត់ទៅ។

ព្រះបាទបយង្កោរ ទ្រង់មានព្រះរាជបន្ទូលរាប់រៀបប្រាប់ព្រះរាជបុត្រព្រះអង្គ តាំងអំពីរបៀបដែលស្តេចបទុមតរាជានលបកាត់ភ្លុចឆ័ត្រទ្វេ, បណ្តែតទៅកណ្តាលសមុទ្រ, ហើយលួចយកមហេសីព្រះអង្គធ្វើតទៅ អស់ពេលចំនួន ២២ ឆ្នាំមកហើយ ។

ព្រះអង្គម្ចាស់ព្រះហស្តខ្វិ កាលបើបានទ្រង់ព្រះសណ្តាប់នូវព្រះបន្ទូលបិតាដូច្នោះ គំនុំអនុញ្ញាតព្រះបិតាចេញទៅរកព្រះមាតាឯនគរកូមា ។ ព្រះរៃបិតាក៏ទ្រង់យល់ព្រមតាមសេចក្តីសុំនៃព្រះរាជបុត្រ ។ លុះក្រោយពីបានយាងទៅដល់នគរនោះ ទើបក្រោយពីបានធ្វើឲ្យព្រះមាតាស្គាល់ព្រះអង្គម្ចាស់ហើយ, ព្រះអង្គម្ចាស់ក៏បបួលព្រះមាតារត់ចេញពីនគរកូមាជាមួយព្រះអង្គ ។ អាស្រ័យហេតុនេះ, ព្រះនាងសក់ក្រអូបក៏បានត្រឡប់មកជួបទើបព្រះបាទបយង្កោរឯប្រាសាទដើមកចង្អុលទៅនគរទ្រាំងវិញ ។

ឯស្តេចបទុមតរាលបើទ្រង់បានជ្រាបថា ព្រះនាងសក់ក្រអូបបានរត់ចេញពីមហាប្រាសាទបាត់ហើយ ក៏ទ្រង់លើកពលរៃហ៍តាមមួយរំពេច (មកដល់បន្ទាយគ្រាល ដែលបិតាទៅទើបទ្រង់ទ័ស្សាយឮ នៃប្រាសាទតាន័សព្វថ្ងៃនេះ) ប៉ុន្តែ ឥតបានទាន់ព្រះនាងសក់ក្រអូបទេ ។ ព្រះបាទបទុមតរាជបញ្ជាប់កងទ័ពទៅខាងមុខ ដើម្បីទ័ទៀបចំស្ទូចបម្បាំង ។

ព្រះនាងសក់ក្រអូបកាបបើទ្រង់បានជ្រាបថា ស្តេចបទុមតរាជទ្រង់

ឃើញនៅត្រង់កន្លែងនោះ, ក៏ចាត់ប្រតិភូម្នាក់ឲ្យទៅទូលព្រះអង្គថា សូមព្រះអង្គកុំចាំបាច់ធ្វើចម្បាំងជាមួយនឹងស្តេចបយង្គោរ ជាព្រះស្វាមីព្រះនាងព្រោះតែរឿងព្រះនាងជួញដូរឡើយ, ព្រោះព្រះនាងមានមធ្យោបាយប្រសើរជាងនេះ ដើម្បីនឹងដោះស្រាយរឿងនេះ ឲ្យបានស្រួលដោយសន្តិវិធី គឺព្រះនាងបានសន្យាថា នឹងត្រឡប់មករកព្រះអង្គវិញ បើសិនជាព្រះអង្គអាចសង់ប្រាសាទមួយនៅជិតបន្ទាយព្រះអង្គនេះ ឲ្យបានហើយស្រេចមុនពេលផ្កាយព្រឹកនេះ ។

ព្រះបាទបុមពរកើរឡើយល់ព្រម តាមសេចក្តីស្នើរបស់ព្រះនាងហើយបានរើឡើងត្រឡប់ទៅព្រះនាងវិញថា ព្រះអង្គនឹងសង់ប្រាសាទមិនត្រឹមតែមួយប៉ុណ្ណោះទេ គឺពីរក៏បានដែរ ឲ្យបានហើយមុនពេលផ្កាយព្រឹកនេះ ។ បន្ទាប់ពីនោះភ្លាមមក, ព្រះអង្គក៏ឲ្រើសប្តាប់ឲ្យពលសាកលយោធាព្រះអង្គ ចាប់សង់ប្រាសាទពីរ មួយនៅត្រង់កន្លែងវត្តប្រាសាទតំបន់តាទីសព្វថ្ងៃនេះ ក្នុងស្រុងបន្ទាយមាស, មួយទៀតនៅលើកំពូលភ្នំកំពែង ក្នុងស្រុកគ្រំង ។

ចំណែកឯព្រះនាងសក់ក្រអូបវិញ ក៏ចាប់សង់ប្រាសាទមួយនៅលើកំពូលភ្នំកន្ទុំ, កាលបើសង់ប្រាសាទបានបួនថ្ងាក់ហើយ ព្រះនាងដែលជាស្ត្រីមានប្រាជ្ញាឆ្លាតវៃយ៉ាងខ្ពង់ខ្ពស់ ក៏ឲ្រើសប្តាប់ឲ្យគេ

បង្គិតតាមមួយធំឡើងខ្ពស់ទៅលើចំកណ្តាលប្រាសាទ ដែលសង់ពុំ
ទាន់ហើយ, ដើម្បីចំកាន់ព្រះបាទបទុមតរថាជាផ្កាយព្រឹកវិញ ហើយព្រះអង្គ
មុខជាអស់សង្ឃឹមឲ្យពួកជាឆ្លងចប់សង់ប្រាសាទតាំងតែនោះពុំបាន ។

ស្តេចបទុមតរទើងពលទាហាន កាលបើក្រឡេកទៅឃើញពន្លឺតាម
ផ្លូវភ្នែ តំឡល់ថាជាផ្កាយព្រឹកវិញ ហើយអស់សង្ឃឹមកំមកឃាត់ពួកពល
សេនាឈប់សង់ប្រាសាទតាន ទឹងប្រាសាទក្នុកំពែងនោះទៅ ។

លុះក្រោយបន្តិចមក ទើបឃើញផ្កាយព្រឹកមែនទែនវិញ, ព្រះ
អង្គឃល់ថា តែងជាចាញ់ចិត្តយកលព្រះនាងសក់ក្រអូបហើយ តែធ្វើ
ដូចម្តេចបើវាជ្រុលហួសទៅហើយ ។ អាស្រ័យហេតុនេះបានជាព្រះ
បាទបទុមតរ ត្រូវព្រាត់ប្រាសពីនាងសក់ក្រអូប, ព្រាត់ប្រាសដោយ
ចាញ់ចិត្តយកលព្រះនាង, តែព្រះអង្គពុំហ៊ានប្រើទំនាំងតទល់ឡើយ
ហើយព្រះអង្គក៏លើកកងទ័ពថយដោយសេចក្តីអាឡោះអាល័យ ទៅតាំង
ទីលំនៅខាងកើតភ្នំម្ចាស់ ខាងត្បូងតានវិញ ។ ទៅដល់នោះ ព្រះអង្គ
បានទ្រង់ព្រះបញ្ជាឲ្យគេចារឹករឿងនៅលើសិលាមួយផ្ទាំងធំ ទឹងទ្វាក់រូប
ព្រះនាងសក់ក្រអូបជាប់នៅជាមួយនោះផង ។ រួចព្រះអង្គក៏យកសិលា
ចារឹកទឹងរូបបម្លាក់នោះទៅដំកល់ទុកនៅលើភ្នំម្ចាស់ រួចព្យាករថាកុំឲ្យនរណា
មួយអាចមើលអក្សរចារឹកនេះយល់បានឡើយ ។ តមក, ព្រះមហាក្សត្រ

ព្រមទាំងពួកពលសេនាយោធា ស្តេចយាងនឹងត្រឡប់ទៅនគរ ភូមាវិញ ។

ព្រះនាងសក់ក្រអូបកាលបើទ្រង់ជ្រាបថា ស្តេចបពុមពាជាន យាងថយចេញពីនគរហើយ ។ ជានចាំកអក្សរនឹងរូបចម្លាក់ពុកចោលនៅ លើភ្នំម្រាំ ក៏ប្រញាប់ប្រញាប់យាងទៅមើលរូបចម្លាក់នោះ ជាមួយនឹងពួក ភាហានព្រះនាង ។ កាលបើព្រះនាងជានតរូបចម្លាក់ នឹងអក្សរចាំក នោះចប់ ព្រះនាងក៏ទ្រង់ព្រះកន្សែងហើយជូលសន្ទប់ជាត់ស្មារតីទៅត្រង់ទី នោះ ។ ពួកភាហានរក្សាព្រះអង្គ កាលជានឃើញដូច្នេះក៏ចូលទៅជិត ហើយសាកសួរព្រះនាងអំពីហេតុ ដែលព្រះនាងទ្រង់ព្រះកន្សែង , ប៉ុន្តែ ព្រះនាងមិនមានព្រះសង្វាន៍យ៉ែឡើយតបដូចម្តេចឡើយ ។ ដូច្នេះគ្មាន ជនណាម្នាក់អាចដឹងរឿងនោះ, ព្រោះគ្មានជនណាម្នាក់អាចមើលអក្សរ ចាំកនោះដាច់ឡើយ ។

លុះក្រោយមក ដោយហេតុថា ប្រាសាទដែលព្រះបាទបពុមពាជាន សង់នោះនៅត្រង់វត្តតានី , គេហៅវត្តនោះថា វត្តប្រាសាទតានី, ឯ កន្សែងរូបចម្លាក់ព្រះនាងសក់ក្រអូប ដែលបិតនៅលើភ្នំម្រាំនោះ, ក៏ជាន ឈ្មោះថាភ្នំម្រាំព្រះខ្សែរ ។

រឿងសង្គ្រាមរវាងគីង្កាក់ ធំង ព្រះព្រហ្ម

លោក លាង-ហាប់-អាន រៀបរៀង

សម័យពីព្រេងនាយ ក្នុងកាលមួយ, ពីកតាលោកកើតមានទុក្ខក្រៃអត់ធ្មេញ ក្តៅហួតហែងគ្រប់ទិសទី ព្រះកំណាមិនបង្អុរភ្លៀងមួយដំណក់មកលើផែនដីនៃទ្វីបលោកនេះ សោះ ។ ស្មៅ ថ្នក, ត្រពាំង, បឹង, ព្រែក, រហួតដល់ទៅទន្លេរីងខ្សឹងតែគ្មានមួយដំណក់; សត្វធំៗតូចៗឃ្លាយស្ងាប់តៀងគ្នាលើគ្នា រុក្ខជាតិនានាស្វិតក្រៀមក្រញាងជាគ្រប់បន្លាំជីវិត សឹងតែឥតសល់ឡើយ ។ ពួកមណ្ឌកសត្វ មានតង្កូក, ហ៊ីង, កង្កែប, ដែលជាសត្វប៉ុនអត់ធន់ ស្គមលៀនក្នែកនៅតែស្បែកនឹងឆ្អឹង មិនដឹងរកទីកងណាអាស្រ័យរស់នៅជាន ។ ថ្ងៃមួយ តង្កូតជាមេបានប្រកាសដល់ក្រុមញាតិសាលោហិតទូរហ៊ីង កង្កែបជាមិត្តថា ហៃមិត្តទាំងអស់គ្នាអើយ មើលទៅព្រះព្រហ្មមិនបង្អុរភ្លៀងមកឲ្យល់ដល់ជីវិតយើងទេ ចេះយើងមានស្មៀមយាំងនេះ មិនអើពើទេ មុខជាជាប់ពោះលៀនអណ្តាតស្ងាប់អស់ហើយ ។ មកវ៉ើយមិត្តយើង តែណាគ្នាទៅសុំទឹងតាព្រហ្មយកព្រះកំណាឲ្យបាន, តាសន្ធដល់ហើយ ស្មៀមក៏ស្ងាប់, ចូលប្រយុទ្ធក្នុងសង្គ្រាមក៏ស្ងាប់ ចេះតែមិនទឹងស្ងាប់ ។ ក្នុងចម្បាំង យកជ័យជំនះដល់ក្រុមញាតិនឹងដល់ជីវិត ទើប

ប្រសើរ, មក! មក! ទៅប្រយុទ្ធ! ។ ក្រោយដែលបានប្រកាសយ៉ាងនេះ ពលគន្ធក៌ជាញាតិនឹងមិត្តភក្តិអស់ កំព្រមព្រៀងលើកព្យូហយាត្រាចេញទៅតយុទ្ធនឹងតាព្រហ្មជំអាកាស ក្នុងព្រះវិមានលោកឥតបច្ចន្ត ។ កងទ័ពមណ្ឌកសត្វដើរកាត់ទីវាលឥតញាប់ញ័រ ឋន្តិចមកស្រាប់តែប្រទះនូវទ័ពមួយហ្វូងធំទៀត លើកកាត់ជម្រងមក ។ មេបញ្ជាការធំ នៃទ័ពគន្ធក៌បានស្រួតទៅពិនិត្យ ស្រាប់តែប្រទះនូវពលត្រីអណ្តង់ធំៗ យ៉ាងខ្លាំង ខ្លួនប្រឡាក់ស្រមក ក្រាំងទៅដោយកំទេចជួលីនឹងផេះនៃវាលស្រែ ។ មេគន្ធក៌សួរប្រញាប់ថា «នែវ៉ុយ តើកនងនឹងទៅណាកំប្រមៀលខ្លួនហុយដីសំពោងតាត់មុខទ័ព ឲ្យរំខានដល់សេចក្តីភាពអញដែលកំពុងលេងយ៉ាងនេះ? ។ ត្រីអណ្តង់ជាមេទ័ពឥតឥតសង្ឃឹយថា កៀនអើយ! យើងដឹងហើយ; មកយើងព្រួតគ្នាជាទ័ពតែមួយ ទៅតយុទ្ធយកជ័យកុំបច្ចន្ត ក្រុមយើងនេះជាដំណាងមិត្តភក្តិមកួគ្នាយើង ដែលបានបញ្ជូនយើងជាមួយបងក្រាញ់ ប៉ុនប្រសប់ខាងតំលួនឆ្នងក្តី ទឹងបាកយណ៌ជាច្រើន ទៅវាយយកភ្លៀងពីព្រះព្រហ្ម មកចំតេញបឹងស្ទឹង យើង;! ទៅ! ទៅកៀន! ។ គន្ធក៌ឮដូច្នោះអរណាស់ គំនាំដំណើងមកកងទ័ពគេ ។ មួយរំពេចនោះ ស័ព្ទដ៏ហោ ទឹងការស្រែកអំណរ បានលាន់ឮចេញពីទ័ពតាំងពីក្រុម ហើយសត្វតាំងពីរពួកកំប្រមូលគ្នាទំយាត្រា

កាត់តាមវាលក្តៅហួតហែងទៅមុខឥតឈប់ ។ ឆ្ងាយបន្តិចទៅ ស្រាប់តែក្បាច់ទីធ្លាហ៊ោរនៃចាណកជាតិមួយហ្វូង ខ្ចៅខ្ចាប់ឮសូរឆ្ងល់ ។ ។

ខ័ពដើងគោកឈប់ច្រឹងច្រងឹងស្មារតី ស្រាប់តែមួយរំពេចនោះមេខ័ពឃ្មុំធំធាំលាន់បន្ទឺសម្លេងពីអាកាសមកថា «នែវ៉ើយ ! កនឯង តន្លង់, ហ៊ុង, កង្កែប, ត្រីអណ្តែង, ត្រីក្រាញ, ឯងទៅណាខ្លួនស្រួមកយ៉ាងនេះ ? ។ តន្លង់ឆ្លើតតបក្នាមថា « មកវ៉ើយ ! កើនឃ្មុំ យើងដឹងហើយថាក្រុមបងលើកខ័ពទៅច្បាំង ព្រោះមុតក្លៀង ខ្លះឈឺព្រួតផ្តាំផ្តាធ្លើសបុកដល់បងមែនឬទេ ? មកកុំបង្អង់ យើងព្រួតគ្នាទៅតយុទ្ធនឹងគាត្រហ្នុកុំថយដៃ កុំខ្លាចស្លាប់ ! ទៅ ! " ខ័ពគោកនឹងគាកាស ហោះយកជ័យស្រុះស្រួលគ្នាហើយកំលើកតទៅទៀត ។ លុះដល់ដីតបម្ភាវស្ងួតមួយស្រាប់តែខ័ពនេះប្រទះឮវាំផ្លែត្រសក់ស្រួវ រដូវណែលលើផ្លែដំ ដាច់រហែងពីចន្លឹតួរឱ្យគាណិតគាស្ងួរពេក ។ ត្រសក់មួយស្រែកដោយឱខាន សង្ឃឹមថា កើនអើយ ! ឱ្យគ្នាយើងដោយសារទៅផង តែទំយើងស្លូតស្លាប់អស់ហើយ កើនទៅច្បាំងយើងកំសិស្លាប់ចំពោះត្រួសារយើងដែរ មិនឱ្យទៅវេទនាទេ; មេខ័ពភាំងប៉ាំយល់ព្រមឱ្យត្រសក់ស្រួវប្រមៀលខ្លួនទៅតាមក្លួន ។ លុះផុតពីវាល កំបាំងដល់ទៅព្រៃមួយដែលវុក្ខជាតិតាំងឡាយក្រៀមញ៉ាំមស្លាប់ជិតអស់ ។ ខ័ពបានទៅដល់

ឃើញវាល្ងង់ផ្តៅធំ ។ ពីរដើមនៅនឹងគល់ឈើស្វាប់មួយដើម ។ ផ្តៅសួរ
យ៉ាងរីករាយថា នែកឿន ! នៅណាហ្នឹងគឺសន្ធឹកម៉្លេះ កឿនមិនអាសូរ
ដល់មិត្តរួមជាតិគ្នា យ៉ាងខ្លះ ? ឃើញខ្លេស្វាប់ដេកពេញដោយដៃតាព្រហ្ម
អស់ហើយ, ឲ្យយើងទៅច្បាំងផង យើងនៅយ៉ាងនេះកំរៃខ្ទាណាស់
ដោយការសង្កត់សង្កិនពីគេ យើងស៊ូទៅស្វាប់ក្នុងសង្គ្រាមជ័យ ដើម្បី
ជណ្តើមយកជ័យ មកផ្តល់ជូនដល់ជីវិតសត្វលោក ។ ចំពាំងអស់ក៏មិន
ឮយោគយល់ដែរ គេឮនឹងព្រមឲ្យផ្តៅគោចរទៅតាមគេ ។

ក្រោយមកចំពាំងអស់ក៏ឮមកដល់ទីហានព្រះព្រហ្ម ។ តន្ត្រីក៏
ឮបញ្ឈប់ឲ្យឃុំប្រជុំវាយសម្រុក ទៅខ្លោងទ្វារទាន់មុខនឹងខាងក្រោយ
ត្រគមណ្តែង, ខឹងក្រាញ់ ដែលខ្លួនប្រឡាក់គេញាយដោយក្បាលនេះ ឲ្យទោ
ចូលកូនពាននឹងធើដឹកទៅមាត់ទ្វារក្រោយ នឹងពាងឆ្នេង ។ ឲ្យតែ
មានទឹក, ផ្តៅទាំងពាងធំ ។ ឲ្យឈរប្រជុំនៅមាត់ទ្វារប្រាសាទ, ត្រូវក់
ស្រូវឲ្យប្រមៀលទៅទៀបជើងក្រមាសទៈតាព្រហ្មគង់នៅ, ឯក្រុម
តន្ត្រីក, ហ៊ឹង, កង្ហែប, ជាទំពស្រួចអ្នកចូលលុក ។ លុះចាត់ស្រេច
ហើយ ទំពមណ្តើកសត្វក៏ចូលស្រែ ចំពោះអាសនៈព្រះព្រហ្មគង់នៅ
ដោយស្រែកហ៊ោសន្ធាប់យ៉ាងខ្លាំង ធ្វើឲ្យតលរេហ៍អស់ទាំងវាលា, មេនំ,
មេខាង, ចៅដែត, ចៅចម ដំពាវរត់ចេញព័ទ្ធប្រាសាទស្ទុះស្ងោគត្រូវទឹក

ផេះ, ទឹកក្តួនដែលពួកត្រីអណ្តើងទឹងក្រាញ់ កន្ត្រោកចាកចាបដះមក
លើក្អែកផ្សារលេញទឹងស្រាក់ងរកេងសំបង់តុំយើញ ថែមទាំងត្រូវពួកយុំ,
ឧម៉ាល់ទិច ចុកឈឺរមួលស្រែកយំរំពងរកេងក្រកតុំយល់ ។ ព្រះព្រហ្ម
រកេងក្រកតុំទាន់ស្រែកសួរថា នែវើយ អាពួក តន្តិក, ហ៊ុន, កង្កែប
ចង្រៃឯងធ្វើណា ? ពួកមណ្ឌុកសត្វតបថា យើងមកច្បាំង យើងមក
ច្បាំង - - តែប៉ុណ្ណោះ ។ តាព្រហ្មកំពុះចាកអាសនៈដោយមិនមើលក្រោម
កំជាន់លើត្រសក់ស្រូវអើលដួលផ្ងារស្រពាន ត្រូវផ្តេទាំងពីរបន្ទុំខ្លួន
ប្រញាប់ សង្កត់កជាប់ ឃ្មុំកំចិចឈឺផ្សា ស្រែកបុះញ៉ាមពួកសត្វទឹងរុក្ខជាតិ
ថា: ចាញ់ហើយ ! ចាញ់ហើយ ! ។ ឮដូច្នោះ មេបញ្ជាការ
សេនាខុភាពតន្តិក កំឃាត់ទ័ពឲ្យឈប់ ដើម្បីដោះស្រាយបញ្ហាបុះ
ចាញ់ តន្តិកសួរទៅតាព្រហ្មបាដយ័ថា « មើចកំលោកបង្គត់ក្តៀងដល់
សត្វលោកយ៉ាងនេះ ? ធ្វើម្យ៉ាស្មាច់គ្រប់កន្ទែងដូច្នេះ, គ្នាយើងមកនេះមិន
សុខចិត្តទេ បើលោកមិនបង្អុរក្តៀងបុះទៅទេ នោះយើងនឹងកំទេចវិមាន
លោក សម្លាប់អស់តាលនឹងលោកពុំមាន' តាព្រហ្មទឹកភ័យកំនិយាយអង្វរ
អស់ពលសាកលយោធាសត្វទឹងរុក្ខជាតិថា: សូមអស់ព្រះស្តេងកុំខឹង,
យើងខ្ញុំចហើយ យើងនឹងផ្តល់ទឹកក្តៀងឲ្យព្រះស្តេងឥឡូវនេះហើយ
សូមអ្នកអញ្ជើញបុះទៅវិញដោយក្សេមក្សាន្តទៅ, កុំខឹងអី, តន្តិកតប

ថា ទេ ! កនយើងមិនយល់ព្រមទេ, បើយើងទៅ នោះលោកនឹងផ្តល់ក្មៀងឲ្យយើងតែមួយដេម ដល់ក្រោយទៀតលោកត្រូវយើយកន្តើយ នាំឲ្យពីជាកយើងលើកទ័ពទៀងមកទៀត ដូច្នេះ សូមលោកសន្យាឲ្យពារពិសេសដល់យើងសិន ទើបកនយើងព្រមសុខចិត្ត ។ លុះជញ្ជឹងមួយសន្ទុះ ព្រះព្រហ្មក៏មានបន្ទូលថា អើ ! យើងព្រមឲ្យពារដល់អ្នកពាល់គ្នា ។ តិង្គក, ហ៊ីង, កង្កែប ! បើកាលណាអ្នកត្រូវការក្មៀង ត្រូវអ្នកសង្កៀតឆ្មេញបន្ទឹសម្ងួតពីក្រោមមក ពេលនោះយើងនឹងបង្អុរក្មៀងឲ្យអ្នកភ្លាម ។ កាលបើសន្យាចុះហត្ថលេខា លើសន្ទិសញ្ញារួចស្រេច ចំពាំណុកសត្វ, ជាណកសត្វ ទើរក្លែងតែក៏លើកថយមកលំនៅវិញ ។ ដល់ដំកង្កែប តិង្គក, ហ៊ីង, ក៏តាំងសង្កៀតឆ្មេញបន្ទឹសម្ងួន រៃអប ! អោក ។ ហ៊ីងហ៊ីង ! ក្មៀងក៏ជ្រាក់មកជាមានក្រោយ ។

យ៉ាងនេះហើយ ជានគេនិយមដឿតសម្រាប់ហេតុសម្រាប់ផលថា ក្មៀងគឺតាព្រហ្មឬព្រះព្រហ្មធ្វើឲ្យធ្លាក់មក ។ ដោយពិត គឺចំហាយទឹកដែលហួតហែង ដោយកំដៅព្រះអាទិត្យកកដោយធាតុត្រជាក់ជាពពកខន្ធិចគ្នាបង្កើតជាទឹកធ្លាក់មកសោះ ។ ឯជាហ៊ីង, កង្កែប, តិង្គក់យំហៅក្មៀងនោះក៏ជាពាក្យដំណាលតំណាន្តសោះ, ដោយពិតគឺវាក្តៅហើយស្រែករកទេ តែបើនរណាគេដឿតាមរឿងនិទាននាងលើនេះក៏មិនខុសដែរ ព្រោះគេតែងសំគាល់ឃើញក្រោយការមណ្តុកសត្វយំក៏មុខជាមានក្មៀងមែន ។

រឿងព្រេងប្រទេស អ៊ុយក្រែន

ចែងអំពី

កូនឲ្យបិតាជារាយាត្រាទៅរៀន

ភិក្ខុ ម៉ែន រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

សម័យមួយ មានតាចាស់ម្នាក់ មានកូនប្រុសបួននាក់ ។ តាចាស់នោះ កាលដែលវ័យរបស់គាត់កាន់តែជរាទៅ គាត់បានចែកទ្រព្យសម្បត្តិទាំងអស់របស់គាត់ ឲ្យកូនប្រុសទាំងបួននាក់នោះ ដោយគាត់គិតថា ថ្ងៃណាមួយ អាត្មាអញនឹងទៅកាន់បរលោក ចោលកូនទាំងអស់មិនខាន ។

កាលចែកដូច្នេះហើយ តាជរាក៏យាត្រាទៅនៅជាមួយកូនច្បងរបស់គាត់ ។ ដំបូង កូនច្បងនោះ បានគោរពប្រតិបត្តិគាត់ដោយគេទិយាយថា យើងត្រូវតែជួនមុខចំណី, ទីសំណាក់អាស្រ័យ, សម្លៀកបំពាក់ឲ្យគាត់ ទប់ឆក់ទាក់ថែរក្សាគាត់ឲ្យត្រឹមត្រូវ ហើយឲ្យស្អាតបាតផង ។ តែលនេះហើយជាតែលដែលកូនច្បង បានទៅជាកូនមួយយ៉ាងគាប់ប្រសើរចំពោះបិតារបស់ខ្លួន ។

ប៉ុន្តែ មិនយូរប៉ុន្មាន, កូនប្សាធ៍នោះក៏ទៅជាមានវិប្បដិសារី ចំពោះគ្រឿងសក្ការៈរបស់ខ្លួនទៅវិញ, ជាអ្នកគ្រោតគ្រាតទៅលើ គាត់ ថែមទាំងពេលខ្លះ ឃុនតំហកកំហែង ជាក់គាត់ទៀតផង ។

គាត់សត់ មិនអាចនឹងទ្រាំនៅអាស្រ័យក្នុងផ្ទះកូនប្សាធ៍នោះ ឲ្យ យូរតទៅទៀត ដូចកាលពីមុនមកនៅនោះឃុនឡើយ ។ សំលៀក បំពាក់របស់គាត់ជាច់ជាច ដោយគ្មានអ្នកណាជ័នឲ្យ, គ្មានអ្នកណា ចាត់ចែងរៀបចំម្ហូបអាហារឲ្យគាត់ទៀតឡើយ ។ កូនប្សាធ៍ ដោយកើត វិប្បដិសារី ចំពោះការដែលខ្លួនឃុនថែរក្សាគាប់ សំសែងអាការៈ មិនពេញចិត្ត (ស្អាយ) គ្រប់ចំណិតនំបុ័ង ដែលគាត់ពិសារ ។

ទីបំផុត ដោយតាគ្មានការគាប់ចិត្តមែបនេះសោះនោះ គាត់ឃុន ចេញពីផ្ទះកូនប្សាធ៍ រួចទៅនៅជាមួយកូនទីពីរ ។ ប៉ុន្តែ កន្លងពេល យ៉ាងខ្លី តាបាស់ឃុនក្បាត់ខ្លួនដឹងថា គាត់គ្រាន់តែប្តូរស្រុកសោះ យក ចំបើងវិញប៉ុណ្ណោះឯង ។

គ្រប់តែពេលដែលគាត់ចរិកាត, បុត្រទីពីរ ឧត្តមកូនប្រសាស្រី របស់គាត់ ក៏សំដែងអាការៈជូរចត់, ខ្សឹបខ្សៀវម៉ុនេះម៉ុនុះ រកេចរអួច ដែលមិនជាទីគាប់ចិត្ត ចំពោះគាត់ ។ ជាញឹកញយណាស់, ឧត្តមកូន ប្រសា នេះតែរអ៊ូរទាំជាក់តាដោយពោលថា ៖

– កាលពីពេលមុនដែលគាត់ញ៉ាស់មកទៅផ្ទះយើង, យើងមានប្រាក់គាស្មមតែនឹងសេចក្តីត្រូវការរបស់យើងប៉ុណ្ណោះ; ស្រាប់តែឥឡូវនេះ យើងត្រូវខ្ចីកមួយថែមមកទៀត ! . . ។

ពេលនោះ គាថាស់ ក៏មិនគាចនឹងគ្រាំទៅជាមួយកូនទីពីរនេះទៀតបាន ទ្បាំះហើយ គាត់ក៏ចេញទៅទៅជាមួយកូនទីបី ។ កូនទីបីនេះ កំដូចជាកូនទីពីរដែរ ហើយគាត់ក៏បានចេញទៅទៅជាមួយកូនសៅរបស់គាត់ទៀត ។

ឯកូនសៅសោត ក៏មិនថ្លែកអ្វីពីពួកកូនបង ។ ដែរ ។ គាថាស់បានចេញទៅ ពីផ្ទះកូនមួយ ទៅផ្ទះកូនមួយទៀត តាមបែបនេះ ។ ទីបំផុត គាមានសេចក្តីរីករាយ ចេញពីផ្ទះកូនទាំងអស់នោះតែម្តង ។

ត្រង់កូនទាំងអស់ ម្នាក់ៗបានជម្រាបបន្ទុកនៃការថែរក្សាបិតាខ្លួនទៅលើម្នាក់ដទៃទៀត ។ ពេលនោះ, មានការពិភាក្សាគ្នាយ៉ាងសម្បើមរវាងកូនទាំងឡាយនោះ ដើម្បីដោះស្រាយបញ្ហាថា «តើអ្នកណាល្អមខ្លួនខ្លះត្រូវចំពោះបិតាបាន ?" ។ ម្នាក់ថា ពិបាកយ៉ាងនេះ, ម្នាក់ទៀតថា មានការពិបាកយ៉ាងនោះ ។ ទីបំផុត គ្មានអ្នកណាមួយស្ម័គ្រខ្លួនចិញ្ចឹមបិតាខ្លួនឡើយ ។ ម្នាក់នេះ មានកូនតូចៗច្រើនពេក, ម្នាក់ទៀតនោះ មានប្រពន្ធជាស្រីញាំញីជាក់គាត់, ផ្ទះកូន

នេះតូចពេក ហើយផ្ទះឯណោះក្រពេក ។ «ល្អហើយ ! អញ្ជើញទៅណា កំតាមចិត្ត ចុះ ! គ្រាន់តែកុំមករកយើងតែប៉ុណ្ណោះបាន ហើយ !» (ពួកកូនឱយ) ។

គាត់សត់ កំយំហ៊ឺ ។ មុខកូនខ្លួន, មិនដឹងជាឱនឆីទៅឯណា មកវាងឯណា ។ គាត់អស់ការតស៊ូអ្វីទៀតហើយ, ស្រេចតែកូនច្រណែងចង់ធ្វើអ្វីចំពោះគាត់ កំតាមចិត្តចុះ ។

ពេលនោះ ពួកកូនមកជួបជុំគ្នា ដើម្បីសំរេចការថា តើត្រូវធ្វើដូចម្តេចចំពោះគាត់ ? ។ ទីបំផុត, គេព្រមព្រៀងគំនិតគ្នាថា កិច្ចការប្រសើរបំផុត ដែលមនុស្សជាស់អាចធ្វើបាន គឺត្រូវបញ្ជូនគាត់ទៅរៀនឯសាលាកងទ័ណាមួយ ឲ្យស្រឡះទៅ ។ គេនិយាយថា ទៅសាលារៀនឯណោះ ទឹងមានដើងម៉ាំសំរាប់ឲ្យគាត់អង្គុយរៀន, កាលណាគាត់ទៅរៀន ត្រូវយើងដាក់អាហារក្នុងស្បាងរបស់គាត់ ដើម្បីឲ្យគាត់យកទៅពិសារតាមផ្លូវចុះ ។

ពិភាក្សារួចហើយ, គេបានប្រាប់គាត់ឲ្យជ្រាបពីរឿងនេះ ។ ដំណឹហើយ, គាត់តបចង់ទៅសាលានោះសោះ, គាត់បានអង្វរសុំកុំឲ្យកូនបញ្ជូនគាត់ទៅទីនោះធ្វើអ្វី, រួចហើយគាត់ខ្សឹកខ្សួលម្តងទៀត ។ គាត់រៀបរាប់ថា ៖

- ក្មេកប៉ាត់ស្រកំឆ្នងអស់ទៅហើយ ប៉ាមើលឃើញគ្នាទេតើ ។ ដែលមានទៅជុំវិញប៉ាំ ដោយតែបាកណាស់ បើដូច្នេះ ឲ្យប៉ាំទៅមើលអក្សរពុម្ពខ្មៅល្អិត ។ ក្នុងសៀវភៅម្តេចបាន ថែមទាំងមួយអាយុប៉ាំនេះ ប៉ាំឥតដែលបានរៀនអក្សរលំនាំអ្វីទំនឹងគេបន្តិចសោះផងនោះ ? ឲ្យប៉ាំទៅផ្តើមរៀនឥឡូវនេះ ម្តេចកើត ? តើឲ្យគេយកមនុស្សក្រញាស់ជួចប៉ាំ ដែលជិតវិលទៅស្រុកដើមវិញហើយនោះ ធ្វើជាស្នៀនម្តេចបាន ? ។

ប៉ុន្តែការស្តីអង្វរកនេះ ជាការឥតប្រយោជន៍ ។ ពួកកូនបានសំរេចថា ត្រូវតែឲ្យគាត់ទៅសាលារៀន, រួចគេបញ្ជានគាត់ឲ្យទៅទាល់តែបាន ។

កាលដែលគាត់សត់ បានចរយាត្រាកាត់ព្រៃព្រឹក្សាខ្ពោះទៅសាលារៀន ដែលតាំងនៅក្បែរទីក្រុងតូចមួយនោះ, គាត់បានជួបអតិជនម្នាក់ កំពង់ចរេះតាមផ្លូវខ្ពោះមក ។ គាថាស់ បានឈប់សៃបចិញ្ចើមថ្នល់ ដោយសេចក្តីគោរព ដើម្បីបើកផ្លូវឲ្យចរេះបរមក ។ ប៉ុន្តែពេលនោះអតិជន បានបញ្ឈប់សេះ ហើយលោតចេញពីចរេះមក ស្រែកសួរទៅគាថាស់ថា ៖

- អញ្ជើញទៅណា គា ?

– ទៅរៀន ! (គាត់ឆ្ងល់)

– ទេ ! ទៅរៀនឬ លោកឪពុក ? ។ តាមពិតចំណាស់ប្រហែលលោកឪពុក គួរតែឈប់សំពាក ដោយស្ងប់ស្ងៀមក្នុងផ្ទះវិញទើបសម ! ។

ពេលនោះ ទឹកភ្នែក បានហូរជោកមុខគាត់សព្វគាត់បានថ្លែងសេចក្តីខ្វល់ខ្វាយរបស់គាត់ ប្រាប់អតិជននោះ ។ កាលអតិជន បានស្តាប់រឿងគាននោះហើយ គេមានចិត្តអាណិតគាយ៉ាងក្រៃលែង ។ គេគិតមួយសន្ទុះ រួចនិយាយថា ៖

– ល្អហើយ លោកឪពុកជា, តាមពិតសាលារៀនមិនមែនជាកន្លែងរបស់លោកឪពុកទេ, សូមលោកឪពុកឈប់សោយសោកទៅហើយសូមលោកឪពុក កុំបង្អើតចង្អល់ចិត្តឲ្យសោះ ខ្ញុំនឹងជួយលោកឪពុក ។

អតិជនបានយកចេញពីខ្សែក្រវាត់គាត់ នូវកាំបិតសូត្រមួយ – គឺជាវត្ថុមួយ ដែលពួកចោរតែងតែយក, ហើយគាត់បានចាក់ជាក់ទៅក្នុងកំភួកនោះ នូវវត្ថុអ្វីមួយលុះត្រាជិតពេញដល់មាត់កំភួក ។ គាត់ចង់មាត់កំភួកយ៉ាងជិតជាប់ រួចជាក់កំភួកនោះ ទៅក្នុងហិបឈើមួយដែលគាត់យកពីក្នុងរទេះមក ។ គាត់ហុចហិបនេះទៅតាចាស់ ដោយ

វាចាថា ៖

– អញ្ជើញយកវត្ថុនេះទៅផ្ទះលោកឪពុកចុះ ហើយប្រាប់កូន ។ លោកឪពុកថាយ៉ាងនេះ ។

ពេលនោះ អតិជនបានបង្រៀនពាក្យ ដើម្បីឲ្យតាបាស់យកទៅប្រាប់កូន ។ តាបាស់ បានអរគុណទីឆ្ងាំសំដែលសេចក្តីកតញ្ញូជ្រាលជ្រៅចំពោះអតិជន រួចត្រឡប់ទៅផ្ទះពួកកូនគាត់វិញ ។ កាលគាត់ដល់ទៅដល់ផ្ទះកូន, ពួកកូន ។ ក៏បានឃើញគាត់យូរហើយនោះ ។ តាមធម្មតា, កាលបើអ្នកណាមួយយូរហើយត្រឡប់ ហើយនោះមុខជាមានអ្វីមួយនៅខាងក្នុងជានិច្ច ។

ពេលនេះ ពួកកូន ។ ទើបប្រញាប់បើកឃ្លាំ ឈប់ហាមឃាត់ឪពុកខ្លួនហើយ ។ ពួកវា ស្ទុះរត់ទៅជួបគាត់ ដើម្បីឲ្យដឹងថា តើគាត់នាំយកអ្វីពីក្នុងព្រៃមក ។ មានអ្នកខ្លះស្រែកយកកំពាំងចំពោះគាត់ថា ៖

– អញ្ជើញទៅសម្រាកលោកប៉ា, លោកប៉ាច្រកជង្គង់ស៊ីកម្ងាំងណាស់ហើយមើលទៅ ! ។

អ្នកខ្លះថា ៖

– អញ្ជើញទៅពិសាលោកប៉ា, លោកប៉ាមុខជាស្រេចឃ្មាំងណាស់ហើយមើលទៅ ! ។

ក្រៃណោះ តាបាស់តំបាច់ធ្លើមថ្ងៃដ៏រឿងរបស់គាត់ប្រាប់កូន តាមពាក្យដែលអត់ជនជាសំឡាញ់ បានបង្រៀនគាត់រួចមកហើយថា ៖

– អាកំកូនប៉ា ជាទីស្រឡាញ់ចំងឹអស់គ្នា, យូរអង្វែងណាស់ទៅហើយ តាលដែលប៉ាទៅតែម្នាក់ ហើយបានធ្វើដំណើរទៅកាន់ទីនេះទីនោះ កន្លងតែតលោកកន្លងតែលដំរីនោះ, ប៉ារកប្រាក់បានបន្តិចបន្តួច ។ ប៉ាគិតថាអញនឹងសំចៃប្រាក់នេះ ទុកសម្រាប់អនាគត, ព្រោះថាដោយតែត មនុស្សម្នាក់ ។ មិនអាចដឹងអនាគតរបស់ខ្លួនថាជាយ៉ាងណាបានឡើយ ។ ប៉ាបានចូលទៅកន្លែងព្រៃ រួចដាក់រណ្តៅមួយគ្រាមដើមអូក ហើយកប់គំនរប្រាក់ទុកកន្លែងនោះ ។ ចាប់តាំងពីតែលនោះមក ប៉ាលែងតែយកព្រួយ ឬខ្វល់ច្រលំចិត្តពីរឿងប្រាក់សោះតែម្តងឯ ព្រោះប៉ាមានកូនល្អ ។ ម្យ៉ាងទៀត ដោយធម្មតា គឺអាក៉ាងឹអស់គ្នានេះឯងជាតំនឹង ។ ប៉ុន្តែ លុះដល់អាក៉ាងឹឯងបញ្ចូនប៉ាឲ្យទៅរៀនឯសាលា ប៉ាក៏បានដើរកែ្សរដើមអូកនោះ ហើយប៉ាក៏និយាយនឹងខ្លួនឯងថា យ៉ាអ៊ីហ្ន៎, អញដូចជាសន្សំយូរណាស់ ដុំប្រាក់ពីរ-បីដុំនេះ តើវានៅធំចាំម្ចាស់ក្នុងគ្រប់តែលទេឬមួយយ៉ាងម៉េចកេះ ! ។ តែលនោះប៉ាក៏ដឹករណ្តៅកប់ប្រាក់នោះ ហើយបានឃើញប្រាក់ចំងឹនោះនៅដូចដែល ទើបប៉ានាំយកមកផ្ទះតែលនេះឯង ។ ប៉ានឹងរក្សាប្រាក់ចំងឹនេះទុក ដរាបដល់

ប៉ាស្លាប់ ។ តែក្រោយប៉ាស្លាប់ទៅ, អ្នកណាដែលនឹងរក្សាប៉ាជាដរាត, អ្នកណាដែលនឹងប្រព្រឹត្តប្រតិបត្តិប៉ាដោយត្រឹមត្រូវបំផុត, អ្នកនោះត្រូវបានចំណែកច្រាក់ដែលមានកន្លះហិបនេះច្រើនជាងគេ ។ ដូច្នេះ, ឥឡូវនេះ ចូរអោយតាំងអស់គ្នាខួលប៉ាវិញចុះ ម៉េស, អាក៏ណាដែលសប្បុរសចំពោះប៉ាចាស់ ដើម្បីច្រាក់ ? ។

ឮដូច្នោះ ពួកបងប្អូនតាំងនោះ គំនែងគ្នាទៅវិញទៅមក កន្លះការធ្វើសប្បុរសដល់ឪពុកខ្លួន ។ ម្នាក់និយាយថា "សូមលោកប៉ាគង្វាញទៅទៅផ្ទះខ្ញុំ" ។ ម្នាក់ទៀតថា «ទេ ! ទៅផ្ទះខ្ញុំវិញ» ។

ពួកអ្នកអស់នោះ បានយកចិត្តទុកដាក់ចិញ្ចឹមតាចាស់ដោយត្រឹមត្រូវ ហើយថែទាំប៉ះសំលៀកបំពាក់ឲ្យគាត់ ព្រោះតែឪពុកបានសម្លឹងមើលគាត់ប៉ុណ្ណោះឯង ។

នេះជាឧទាហរណ៍មួយ ដែលប្រព្រឹត្តទៅរហូតដល់ទីបំផុត ហើយតាចាស់ក៏អនិច្ចកម្មទៅ ។

ពេលនោះ កូនតាំងឡាយនោះ បានប្រញាប់ប្រញាល់ទៅយកហិបមកតិកាក្សាគ្នាថា តើអ្នកណាដែលជាអ្នកសប្បុរសបំផុត ចំពោះខ្លួនឯងដែរ ហើយដែលត្រូវបានខួលចំណែកច្រាក់ដែលមានកន្លះហិបនោះច្រើនជាងគេ, ។ ពួកអ្នកស្រុកភូមិផងរបងជិតមួយ បានត្រូវគេហៅ

មកធ្វើជាចៅក្រមក្នុងរឿងចែកនេះ ។ ទីបំផុតទៅ គេសំរេចថា កូនទាំងបួននាក់ សុទ្ធតែជាអ្នកមានចិត្តសប្បុរស ចំពោះបិតាខ្លួនស្មើៗគ្នាចាប់តាំងពីពេលដែលគាត់ត្រឡប់មកពីព្រៃ, ម្ល៉ះហើយត្រូវតែចែកមតកឲ្យស្មើភាគគ្នាទើបបាន ។

ពួកកូនទាំងនោះ បានរៀបចំធ្វើបុណ្យយ៉ាងអស្ចារ្យ ទុកិសចំពោះខ្មោចឪពុកខ្លួន, បានរៀបដាក់លៀងយ៉ាងទូលាយដល់គ្រឿកងក្នុងភូមិដែលបានជួយការខ្លួន, បានចំណាយប្រាក់និមន្តព្រះសង្ឃពីព្រះវិហារ (Church) មកសូត្រធម៌អស់រៃសិបថ្ងៃ ។ ម្ចាស់ៗ ទំធ្វើឲ្យលើសគ្នាទៅវិញទៅមក, គេបានចំណាយប្រាក់ថែមទៀត ទៅលើព្រះវិហារជាគ្រឿងបូជាចំពោះការសូត្រធម៌ ។

កាលដែលពីធីបុណ្យចប់ហើយ គេបានប្រញាប់ប្រញាល់ទៅបើកហិបមើល ។ គេក៏បានឃើញកំប៉ុកសូន្យជ្រៅឆ្ងៃតនាយទៅក្នុងហិបនោះ ។ គេលើកកំប៉ុកអង្រួនមើល ក៏ឮសំឡេងច្រឹង ។ យ៉ាងពីរោះ ។ ពួកគេបានស្រាយមាត់កំប៉ុកចេញ រួចគាំងរលាក់អាច្រឹង ។ នោះជាកំភៅលើតុមួយ ។

បពិត្រអើយ ឮដំណាលនោះ ពួកគេរកគល់មិនដឿតែកគេសោះឡើយ, វាគ្មានឃើញអ្វីសោះ, ឃើញដូចជាសុទ្ធតែអំបែងវែកៗ ! ... ។

លុះដល់ព្រលឹមស្រាងឡើង កនកាវែកទាំងនោះ ក៏ឃើញ ច្បាស់លែងសង្ស័យថា អាច្រឹង។ នោះ សុទ្ធតែជាអំបែងកែវ គ្មានតម្លៃអ្វី បន្តិចសោះ ដែលជាហេតុនាំឲ្យគេខ្ជិលខ្ជាតខឹង ហើយជជែកគ្នាយ៉ាង សម្បើម ។ ប៉ុន្តែ ពួកអ្នកស្រុក នាំគ្នាសើចស្ទើរបុកពោះ ។ ពួកអ្នក ស្រុកនាំគ្នានិយាយថា ៖

- អើ! ហ្នឹងហើយជាកម្រៃនៃការបញ្ឆោតដុតថៅសាលារៀន ការចេះដឹងរបស់គាត់ នាំឲ្យគាត់សុខសប្បាយឯណាយូរ, ប៉ុន្តែ អ្វីដែល គាត់ជាន់រៀន គឺគាត់ចេះចំណាប់មែន ! ។

កណ្ឌទី ៤២

ទុតញ៉ាវិបុលភជសេនា ជួ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធឹងបេះខុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិៗ

ជាប្រក្រតីមកហើយនៅខ្វះតែជាតុខ្សល់ទឹងជាតុភ្លើងនៅខន់ណាស់ ដើម្បីខ្សល់ចាក់មកត្រូវភ្លើងកំរើកឡើងភ្លាហើយ ភេគលោកគំនឹងជាស្រឡះ ។

ដាវយ៉ើយឃើញសំបុត្រទឹងស្តាប់ពាក្យខុងបេងនិយាយចប់មាដូច្នោះគំតក់ស្នុតស្មារតីគិតថា ខុងបេងនេះកន្ទុងដឹងដម្រិះគិតរបស់យើង ដូចទេពតាមកបញ្ជាលចិត្ត ដាវយ៉ើងក៏សាស្រាយអធិប្បាយសេចក្តីទាំងពួង ដែលគិតនោះ ឲ្យខុងបេងស្តាប់គ្រប់ប្រការហើយសួរខុងបេងថា គំនិតរបស់អ្នកទឹងគិតយើញប្រការម្តេច ទឹងឲ្យកើតខ្សល់សាត៌មកបាន ឯខុងបេង

នោះបានដឹងក្នុងតម្រាថា ដល់ថ្ងៃ៩ ពេលថ្ងៃបុស្សនោះទឹងកើតឃ្លល់សលាតន់ជាប្រាកដ តែខ្លាចក្រែងដំរីយើងទឹងយើង ធ្វើការជាមួយគ្នាតទៅ ដំរីយើងមិនគោតខ្លាចគំនិតដែលគិតទឹងនាំឲ្យដំរីយើងមើលងាយ យើងត្រូវតែប្រើកលឧបាយទិយាយប្រាប់ឲ្យដំរីយើងគិតធ្វើការ ហើយទឹងបបរត់ទៅ ។

លុះគិតហើយទុងបេងថា ខ្ញុំនឹងនេះមានដម្រេះប្រាជ្ញាគិច តែបានប្រទះឃើញក្បួនតម្រាអាចារ្យម្នាក់ ប្រដៅឲ្យរៀនសុំឃ្លល់សុំក្បៀង ខ្ញុំចាំខុកមក បើលោកទឹងប្រាថ្នាចង់បានឃ្លល់សលាតន់ ត្រូវឲ្យចាត់សង់កន ៣ ជាន់កំពស់ ១ ជាន់ ៣ ហតុថាយ នៅលើកំពូលកុំឲ្យភ្លាំពិនសានេះ ហើយសូមគាហាន ១២០ នាក់ កាន់ទង់ផ្សែង ។ អង្គុយព័ទ្ធកងពិធីជុំវិញ ដើម្បីទឹងបានបំរើប្រើការ ខ្ញុំទឹងឡើងទៅសែកគាថាមន្តតាមតម្រាគ្រប់ ៣ ថ្ងៃ៣យប់ សុំឲ្យឃ្លល់សលាតន់មានមក ៣ ថ្ងៃ ៣ យប់បាន លោកទឹងបានលើកកងទ័ពទៅបំផ្លាញទ័ពទឹកចូនបានយ៉ាងមាំ ។ ដំរីយើងថា អ្នកកុំបាច់ធ្វើឲ្យដល់ ៣ យប់ ៣ ថ្ងៃឡើយ សូម្បីតែ ១ ថ្ងៃប្ត ១ យប់ក៏ទឹងធ្វើការនោះឃកជ័យជំនះបានដោយស្រួល បើអ្នកទឹងធ្វើហើយ កំត្រូវធ្វើឲ្យបានពេលយប់នេះប្តស្អែកព្រឹកឡើងឆ្លងទុកឲ្យយូរតទៅ សេចក្តីដែលគិតនោះកំទឹងឮសាយសុសទៅដល់ចូនចូរ ទុងបេងថា ខ្ញុំទឹងធ្វើការហៅឃ្លល់ឲ្យបានកនថ្ងៃ៩ ពេលថ្ងៃបុស្ស ពេលយាម ១ ប្តាយឲ្យឃ្លល់សលាតន់ជាក់មកជា

យ៉ាងខ្លាំង លុះដល់ថ្ងៃ ៧ ពេចទើបស្ងប់ ។

ដំរីយើញដូច្នោះ ក៏មានចិត្តសោមនស្ស ត្រេកអរ ដូចខ្លួនបេងយកថ្នាំ ពិពួមកលាយលាបឲ្យពេតដែលឈឺនោះសះជាមួយរំពេច ទើបក្រោកឡើង គំនាប់ខ្លួនបេងហើយក៏ចង្អាប់ឲ្យពួកមេការៀបចំធ្វើពន្លិច ឲ្យតាហាន យាមរក្សាតាមភាក្យខ្លួនបេងបង្គាប់ ។ ខ្លួនបេងថា ដែលលោកនឹងឲ្យទៅ សុំឲ្យលន់នោះ ខ្ញុំត្រូវសុំអាជ្ញាសិទ្ធិទៅផង ទើបនឹងធ្វើការបានស្រួល ។ ដំរីយើមិនពាន់គិត ក៏ឯកក្រចឹដែលស៊ុនគួនឲ្យមកនោះ ប្រគល់ទៅឲ្យខ្លួនបេង ខ្លួនបេងទទួលយកក្រចឹហើយក៏នាំឲ្យសុកនឹងតាហានទាំងពួងឡើងលើកំពូលភ្នំឲ្យពិនិត្យ ហើយធ្វើជាមើលកូមិហ៊ានដែលនឹងឲ្យតាហានសង់ពេញពិធីនោះគ្រប់ ៣ ជាន់ កួន ១ ជាន់កំពស់ ៣ ហត្ថ ប្លាយ ជាន់ដើមទំហំ ២០ ព្យាម ៤ ជ្រុង ហើយឲ្យដឹកយកដីខាងទិសអគ្នេយ៍ មកចាំន់ជារូបមកដំកល់ទុកខាងទិសបូព៌ កន្លែងជាន់ដើមឲ្យដៅតទាំ ៧ រួត ចាំន់ជារូបខែវតា ឈ្មោះហៀនថ្ងៃដំកល់ទុកខាងទិសខ្តួរដៅតទាំ ៧ រួតចាំន់ជារូបខ្លាដំកល់ទុកខាងទិសបស្ចឹមដៅតទាំ ៧ រួត ចាំន់ជារូបក្អែកដំកល់ទុកខាងទិសឧត្តរដៅតទាំ ៧ រួតដូចគ្នា ឯជាន់កណ្តាលនោះមានមនុស្សគាន់ទាំលឿនប្រចាំទិសទាំង ៨ ទិសនិមួយៗ មនុស្ស ៨ នាក់ ជាន់លើបង្អស់មានមនុស្ស ៨ នាក់ ម្នាក់នៅទិសបូព៌ គាន់តាម

រៃយ៉ាំ ៧ដួង ម្នាក់ទៅទិសឧត្តរគាន់ឈើចង្កឹងទាន់ ម្នាក់ទៅទិសបស្ចឹម
គាន់ក្រចឹ ម្នាក់ទៅទិសទក្សិណគាន់គោករដូចខៀន លុះចាត់ការស្រេច
ហើយទុនបេនក៏ធ្វើជាទិយាយទន្លឹងឡោសុកថា អ្នកចូរជួយត្រឡប់ទៅ
ប្រាប់ដីរយើងា ដែលខ្ញុំមកសុំឲ្យលំឲ្យនេះ បើមិនបានដូចសេចក្តីគិតទេ
ក៏កុំឲ្យដីរយើយកគោសខ្ញុំឡើយ ។ ឡោសុកទទួលពាក្យហើយក៏លាចុះ
ទៅ ។

ឯទុនបេនវិញ កាលថ្ងៃ ៣ ពេជវិខបុស្សវេលាព្រឹក ក៏តាំងទៅ
ឆ្ងាតទឹកជំរះកាយ ហើយតែងខ្លួនស្លៀកពាក់ដណ្តប់សំពត់ឆៀងស្មាមាន
រំសាយសក់ចុះ ហើយនិយាយទន្លឹងពាហានទាំងពួងថា គ្រានេះយើងនឹងធ្វើ
ការតាំងពិធីជាធំ ឯបណ្តាពាហានដែលយើងបានរៀបចំចាត់បេនទុកទាំង
ប៉ុន្មាន បើឃើញយើងធ្វើប្រការម្តេច ក៏កុំឲ្យនិយាយគ្នា ឬដើរទៅមក
ចាកទីកន្លែងឡើយ ត្រូវតែនៅឲ្យស្ងៀមជាប្រក្រតី ទំពាំយើងធ្វើការឲ្យបាន
សម្រេច បើនរណាហើយមិនស្តាប់ យើងនឹងយកក្រចឹងាជាសិទ្ធិដែល
ដីរយើងឲ្យមកនោះកាត់ក្បាលចេញ លុះផ្តាំពាហានរួចហើយ ទុនបេន
ក៏ឡើងទៅលើកនពិធីជាធំលើ ទើបតាំងអុជធូបខៀនឡើងបូជាទេវតា
ហើយធ្វើជាអង្គុយការនាសែកមន្តគាថាហៅខ្យល់ លុះវេលាសមគួរហើយ
ក៏នាំពាហានទាំងអស់ចុះមកឆ្លងទឹកចរំកោគអាហារ ហើយក៏ត្រឡប់ឡើង

ទៅធ្វើការដូចដើម ។

ឯដីវាយីតបង្គាប់ឲ្យឡោសុកនឹងធៀតៅចាត់ចែងកងព័តទូកឲ្យត្រមះថែ កេតឃ្លាំសាលាន័នមកកាលណា កំឲ្យលើកទាហានទៅធ្វើការឲ្យទាន់ពេលហើយធ្វើសំបុត្របកទៅដល់ស៊ុនគួនឲ្យលើកកងព័តមកជួយ ។ ឯអ៊ុយកាយតាំរៀបចាត់ចែងទូក ២០ យកស្មៅ ទឹងចម្បើងផ្ទុកពេញទូកទាំងអស់ហើយតាំយកភួញត្រីចាបសាចទៅលើស្មៅ ទឹងចម្បើង ឲ្យខឹកជាប្រនេះក្តើងហើយយកវាំសេវនឹងស្ពាន់ធរ ចាបសាចទៅលើស្មៅចម្បើងថែមទៀតគ្រប់ចាំង ២០ ទូក ហើយយកទង់ក្អែបទៀរដោតលើក្បាលទូកជាសំគាល់ លុះត្រៀមស្រេចហើយតាំចតទូកចាំស្តាប់ដីវាយីមានបង្គាប់វិលាណា តាំនឹងចានលើកចែវទៅដោយរហ័សវិលានោះ ។

កាលតាំឡេងនឹងដាំតេកចានសេចក្តីជាក់លាក់ហើយ តាំតែងរក្សាឈ្នួតនុង, ឈ្នួរហោះទុកជាប់នឹងខ្លួន ហើយចង្កាប់ចាហាទឲ្យរឹងមើលឈ្នួតនុង, ឈ្នួរហោះកុំឲ្យវេះតន់រួចទៅចាន ចេដីវាយីលើកទ័ពចេញទៅកាលណា នឹងចានធ្វើការតាមដីវាយីបង្គាប់ទុក ឯទាហានយាមល្បាតតាំចូលទៅជំរាបដីវាយីថា ឥឡូវស៊ុនគួនលើកកងព័តមកឈប់នៅចម្ងាយផ្លូវតិចន្លាយនេះទៅប្រហែល ៨០០ សិន (៣២-គ.ម) ដីវាយីឮដូច្នោះតាំអរណាស់ទើបប្រើឡោសុកទៅប្រកាសប្រាប់ទាហានទាំងពួងថា ឲ្យរៀបចំទូកចម្បាំង

ទុកឲ្យត្រម បើនឹងលើកចេញទៅកាលណាឲ្យទាន់ការ បើកងណាមេណាធ្វើឲ្យយឺតយូរត្រូវប្រហារជីវិត ឡោសុកក៏ចេញទៅប្រកាសតាមពាក្យដែរយើបង្គាប់ ខោះនាយកងទាយទ័ពកំប្លងប្រៀបរៀបចំត្រមស្រេចទាំងទូកនឹងគ្រឿងសស្ត្រាវុធគាំងព័ត្រលប់ លុះដល់ភ្លឺក៏មិនបានឃើញឲ្យលំឆ្មាក់មកសោះ ដែរយើក៏និយាយនឹងឡោសុកថា ខុងបេងទៅធ្វើការអស់ ១ ថ្ងៃ ១ យប់ទៅហើយ ក៏មិនទាន់ឃើញមានឲ្យលំសាសន៍ឆ្មាក់មកសោះ ។ ឡោសុកថា ខុងបេងធ្វើការខោះមុខជាកើត លុះនិយាយគ្នាដូច្នោះហើយក៏នាំគ្នាចាំមើលពីព្រឹក លុះដល់ពេលយប់យាម ២ ឬ៣ ក៏ឮសូរសំឡេងសន្ធឹកសន្ធាប់ពីទាងទិសអគ្នេយ៍ ដែរយើក៏នាំឡោសុកចេញទៅមើលកណ្តាលវាល ក៏មិនឃើញមានឲ្យលំអ្វីសោះ សូវឈឹងទាំងអស់ លុះមួយស្របក់ក៏ឆ្លាក់ឲ្យលំឮសាសន៍បក់ចោកមក ។ ដែរយើក៏មានសំណារណាស់ និយាយនឹងឡោសុកថា ឯងម្រេះប្រាជ្ញាខុងបេងដឹងតម្រាហៅឲ្យលំក្នុងអាកាសបានដូច្នេះ ទំនឹងកម្លាំងឯណាប្រៀបផ្ទឹមឲ្យត្រឹមស្មើគ្នាន ។ បមាដូចទឹងរាប់ផ្កាយតាមនៅលើអាកាសបានទាំងអស់ពុំនោះទឹងញ៉ាំងព្រះមហាសមុទ្រ ដំរជ្រៅឲ្យមើលឃើញបៃតាំងពួងបាន បើយើងទុកខុងបេងឲ្យនៅតទៅខាងមុខ ទុក្ខកំនឹងមានដល់ស្រុកកាំងតាំងតងំអន្តរាយ ត្រូវតែរិះគិតរកកល ។ ជាយសម្លាប់ខុងបេងចេញ ទើបស្រុក

យើងនឹងបានសេចក្តីសុខតទៅ លុះនិយាយហើយក៏បង្គាប់តេងហានឲ្យឈើសេងឲ្យលើកតាហានម្នាក់ ១០០ ចេញទៅចាប់ខ្លួនខុងបេងសម្លាប់ ។ ឯឈើសេងក៏លើកតាហានស្រួតទៅចុះទូក លើកស្ពាត់ទាងមាត់ទន្លេ ថាបើឃើញខុងបេងនឹងចាប់ខ្លួនសម្លាប់ចេញ ។

ខណៈនោះខុងបេងដែលបានឃើញឲ្យលស់សលាតន័នបោកបក់មកជាខ្លាំង ក៏សំឡឹងមើលតាហានទាំងពួង ឃើញគាន់ចង់នឹងគ្រឿងក្តីការគ្រប់ដៃជាប្រក្រតីតាមបង្គាប់ខុងបេងក៏លបតេះចុះពីលើភនតិធី ស្រួតរួតទៅគាន់កំពង់ទឹកដែលបានកំណត់ទុកឲ្យជួបគ្នាមកខលួនោះ ។ តាហានទាំងអស់ក៏មិនបានសំគាល់ជាខុងបេងនឹងតេះទេ ។ លុះតេងហាងទៅដល់កណ្តាលផ្លូវ ខលួនឲ្យលស់សលាតន័នបោកបក់មកយ៉ាងខ្លាំង តេងហានក៏បង្ខិចរសេះឡើងទៅដល់ទីភនតិធី ឃើញតាហានភាំងពួងគាន់ចង់ប្រជ្រុងខ្លួនមិនមានកំរើក តេងហានក៏ចុះពីលើសេះគាន់ក្រប៉ីឡើងទៅលើភន ស្រាប់តែរកខ្លួនខុងបេងមិនឃើញសោះ ក៏ត្រឡប់ចុះមកសួរពួកតាហានដែលនៅក្នងទីនោះថា ខុងបេងទៅឯណាទៅហើយ ? ។ តាហានដែលគាន់ចង់ក្រាបថ្វាយថា ខុងបេងចុះទៅមុនលោកអម្បាញ់មិញទៅហើយ ។ តេងហានក៏ចុះទៅដល់ដី ឡើងសេះបំផាយចុះមកវិញ លុះទៅដល់មាត់ទន្លេ ប្រទះទឹងឈើសេងក៏សាកសួរគ្នាទៅវិញទៅមកមិនបានសេចក្តី ខលួល

មានកូនទាហានម្នាក់មកប្រាប់ថា គរុលពេលត្រលប់ទៅបានឃើញ
ខ្លែតួច ១ មកចតទៅក្បាលជ្រោះត្រង់ឆ្នេរខ្សាច់មាត់ទន្លេ លុះរំលង
យាម ២ ទៀប ឃើញខុងចេងដើរមកចុះខ្លែនោះ ហើយថែវ
លឿនទៅទិសឯជើង តេងហានទីឈើសេងកំចុះខ្លែហើយ បើកស្ពោង
ទៀតគ្នាតាមទៅ ។

ឈើសេងថែវតាមទៅបានប៉ុន្មានហើយ ស្រែកហៅខុងចេងឲ្យឈប់ទៅសិន
ហើយប្រាប់ថា ដើរយឺតមកអញ្ចឹងញាក់ទៅវិញ ។ ខុងចេងឮទាហាន
ស្រែកហៅដូច្នោះ កំឡើយតបទៅវិញថា អ្នកឯងត្រឡប់ទៅប្រាប់ដើរ
យឺតវិញចុះថា ខ្យល់ដែលយើងសូត្រស្រែកហៅនោះបានភ្លាត់មកហើយ
ឲ្យខំឡើការទីឯងចូរឆ្លូវឲ្យល្អចុះ ឯខ្លួនយើងទីឯណាដើរត្រឡប់ទៅស្រុក
តាំងពីហែសិន ដល់ថ្ងៃក្រោយសឹមត្រឡប់មកសួរដើរយើងវិញ ។ ឈើសេង
ក៏ថែមថាឲ្យឈប់សិន ! ខ្ញុំទីឯងដំណរសេចក្តីដែលដើរយើងបង្គាប់មកជាការ
សម្ងាត់ ។ ខុងចេងថា ដែលអ្នកមកនេះយើងក៏ដឹងជាមុនទៅទៀត
តើដើរយើងគិតខុកទីឯងធ្វើអន្តរាយដល់យើង ។ កំឲ្យជួយទីឯងមកចាំទទួល អ្នក
ឯងចូលវិលត្រឡប់ទៅប្រាប់ដើរយើងចុះ បើមិនត្រមស្តាប់នៃចូលមក ទីឯ
រកកំឡាំងតទីឯយើងមិនបានទេ ។

ឈើសេងឃើញខ្លែខុងចេងមិនបានបើកស្ពោង ក៏ឲ្យទាហានថែវ

ស្រួតតាមទៅ ។ ដូច្នឹងឃើញឈើសេដ៏តាមមកជិតក៏ស្រែកថា អញ ឈ្មោះដូច្នឹង បានខឹងលួសតាស្យុងដ៏បេដ៏បង្គាប់ឲ្យអញឡើងមកខឹងលួសវេលានេះទុដ៏បេដ៏ក៏បានឱយហាមច្រើនដង ។ មិនស្តាប់ ចេះតែតាមមក ប្រុងនឹងធ្វើអន្តរាយទុដ៏បេដ៏ បើយើដ៏មិនយកឆ្កួបាញ់ឲ្យស្លាប់ឥឡូវនេះទេ ឡៅតីហៅហ្វាយយើដ៏ទឹដ៏សុខគួនក៏ទឹដ៏ទុសអញស្រែយគ្នាមិនស្រួល យើដ៏ក៏បាញ់ឲ្យតែល្មមដឹនថ្លើដៃចុះ ថាហើយក៏យឺតឆ្កួបាញ់ត្រូវខ្សែក្តាដ៏ ដាច់ធ្លាក់ក្តាដ៏ចុះ ខ្លួកឈើសេដ៏ក៏វិលត្រឡប់ស្ទើរតែនឹដ៏ក្លួកលិច ដូច្នឹងក៏ឲ្យពាហនបើកក្តាដ៏ចេញទៅ ។

ឯឈើសេដ៏លុះឃើញខ្លួក តដ៏ហដ៏តាមទៅពន់ ក៏ប្រាប់អាថិសេចក្តីពាដ៏តួដ៏ឲ្យស្តាប់ ហើយថាដូច្នឹងនោះមានថ្លើដៃខ្លាំដ៏ពូកែណាស់ ការគ្រាប្បាំដ៏នៅវាលប៉ន់ប្បានោះ ក៏បានសម្លាប់ពាហនបួនអស់ជាច្រើនដែលយើដ៏ទឹដ៏តាមជិតដោយទៅមុខជាតស៊ូនឹដ៏ដូច្នឹដ៏មិនបាន លុះប្រឹក្សាគ្នាហើយក៏ត្រឡប់ទៅប្រាប់ដីវើ តាមដំណើរដើមរហូតដល់ចប់សព្វគ្រប់ប្រការ ។ ដីវើបានឮដូច្នោះក៏ភ័យណាស់ហើយថា ជម្រិះរិះគិតរបស់ទុដ៏បេដ៏នោះជ្រៅពូលាយឆ្ងាយណាស់ បើមិនគិតសម្លាប់ឲ្យហើយទេ ខ្លួនយើដ៏ក៏ទឹដ៏ដេកឆ្នេចភ្នែកមិនជិត ទបមាដូចបន្ទាមុតជាប់ក្នុដ៏ដើមទ្រូដ៏ ។ ឡោសុកក៏និយាយឃាត់ថា លោកកុំបង្ខិតឲ្យកើតវិការឡើយ ចូរគាំដ៏

ចិត្តខំគិតធ្វើការកំចាត់ចូរឆ្ងូចេញឲ្យបាន ឯការខាងខ្លួនបេះនោះសឹមគិត
តទៅជាឯក្រោយ ។

ខណៈកាលកើតឲ្យលំបាកសាត់នោះ ដាវយីកំបង្គាប់កាំឡើង
ឲ្យលើកទាហានទៅផ្លូវគោកដល់ដំបន់ប៊ីលឹម ហើយឲ្យចូលលុកដុត
ចូរឆ្ងូ កាលបានឮក្សត្រីនឹងលើកទៅឲ្យសម្ងាប់ឈ្មួតនឹងចេញ ហើយកាត់
យកក្បាលសែនខន់ជ័យឲ្យជាអំណាចកងខ្លួន ឯខ្លួនឈ្មួហោនោះឲ្យយក
ខ្លួនប្រើធ្វើកជាការខាងខ្លួនតែកន្ទឹងបានធ្វើការ ឲ្យលើបងលើកទាហាន ៣
ពាន់ជាកងជំនួយកាំឡើង ហើយថៃស្ងួជួលើកទាហានវា ពាន់ទាងដើង
គោកទៅដំបន់ហ័បហ៊ុយ .ចាមវាយកាត់ទាហានចូរឆ្ងូកុំឲ្យលើក៥ជំនួយ
មកបាន បើយើញក្លើងនេះឡើងកងខ្លួនចូរឆ្ងូ ត្រូវឲ្យមីលខង់
ក្រហមជាសំគាល់ហើយ ឲ្យបង្គំទាហានលើកមកប្រសព្វគ្នា កាំឡើង,
លើបង ន៏ថៃស្ងួជួ កិលាទៅចាត់បែងលុះបានឮក្សត្រីកំលើកព្រៃកគ្នា
ទៅជាមុខកងខ្លួន ព្រោះជាផ្លូវឆ្ងាយ កាលកាំឡើងនឹងលើកខ្លួនទៅ
នោះ កំចាប់យកខ្លួនឈ្មួហោទៅប្រគល់ខុកកងខ្លួន ហើយយកឈ្ម
តុងទៅសម្ងាប់ចេញ រួចកាត់យកក្បាលទៅសែនខន់ជ័យទើបលើក
ខ្លួនទៅ ។

ដាវយីកឲ្យឡើងថងលើកទាហាន ៣ ពាន់ទៅដំបន់អ៊ុឡើង បើ

ឃើញតទ្ទឹកភ្លើងនោះដែរ ដូចនេះហើយ កំឡុងពេលដែលគេកំពុងតែបាញ់ប្រហារគ្នានោះ ខ្ញុំបានឃើញទាហានចាស់ម្នាក់ ដែលមានឋានៈជាមេទ័ពធំ ដែលមានឈ្មោះថា ហ៊ុន ណុង ដែលជាបងប្រុសរបស់លោក ហ៊ុន សែន ដែលបច្ចុប្បន្នកំពុងតែកាន់តំណែងជានាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានបាត់បង់ជីវិតនៅក្នុងសមរភូមិនោះ ដោយសារតែគ្រាប់កាំភ្លើងធំ ដែលបានបាញ់ចូលមកក្នុងតំបន់ដែលគាត់ស្នាក់នៅ ដែលជាតំបន់ដែលមានទីតាំងនៅជិតនឹងតំបន់ដែលខ្ញុំស្នាក់នៅ ដែលមានចម្ងាយប្រហែលជាមួយគីឡូម៉ែត្រប៉ុណ្ណោះ ដែលគ្រាប់កាំភ្លើងធំនោះ បានធ្លាក

កំឡាំងប្រការម្តេច ទើបបានជួយឲ្យកំឡាំងឲ្យខ្លាសុក ឆ្អឹតេតនៅរក្សាបន្តាយ ។ ធ្វើតៅយើញដីរយើចាត់ចែងចំណែកគោកចំពោះកងក្បួនមុនមាំដូច្នោះ កំតិតខ្លាចជាវយើជាច្រើន ។

ខណៈនោះមានសំបុត្រស៊ុនគួនមកដល់ដីរយើសេចក្តីថា ស៊ុនគួនឲ្យឡុកស៊ុនលើកទាហានជាកងមុខ ខ្លួនស៊ុនគួនជាចំហួង ទើងលើកជាជំនួយទៅផ្លូវអ៊ុយតេ ដីរយើយើញសំបុត្រស៊ុនគួនដូច្នោះក៏ត្រេកអរណាស់ បង្គាប់ទាហានឲ្យយកជាវឡើងទៅចាំនៅលើកំពូលភ្នំឡាំពិខាន ហើយដល់ពេលព្រលប់ឲ្យអុជជាវជាសំគាល់ កងចំពូកទើងបានលើកព្រមគ្នាចូលទៅ ។

ឯខ្លៅតីដែលតាំងចំតទៅបន្តាយហៃទៅនោះ លុះបានយើញឃ្លាំសលាតន្លាក់បក់មក កំតាំងចិត្តគិតខ្ទើងមើលផ្លូវដូឡងដែលទៅខួលខុងបេង លុះយើញខ្លៅគីលើកចំពូកមកដល់ ហើយឡើងទៅជួបទើងខ្លៅតីៗក៏ប្រាប់ថា យើងឲ្យដូឡងទៅខួលខុងបេងតំទៅមិនទាន់ទៅមិនទាន់ យើញត្រឡប់មកវិញសោះ ទើងថាប្រការម្តេចក៏ឥតដំណឹងឡើយ ខ្លៅតីមិនទាន់ទើងតបធ្វើយថាប្រការម្តេច ខួលយើញដូឡងនាំខុងបេងចូលទៅដល់ ខ្លៅតីក៏មានចិត្តអរណាស់ ទើបសាកសួរថា លោកទៅធ្វើការអ្វីខ្លះ ? ខុងបេងថា ទើងធ្វើយដំកបមិនទាន់ភ្លាន់ខែនាំឲ្យ

ឃ្លាការ ហើយសួរខ្លៅពីថា តើចុងដែលខ្ញុំបង្គាប់ពុកនោះ បានរៀបចំជាស្រេចហើយ ឬម្តេច ? ។ ខ្លៅពីឆ្លើយថា ការទាំងអស់បានរៀបចំពុកត្រមអស់ហើយ ។ ខុងបេងក៏ប្រើដូឡឹងលើកគាហាន ៣ តាន់ ទូងទៅស្រុកកាត់ទៅពួនបង្គប់នៅជិតជំបន់ហ៊ួលឹម គេលយាម ៣ ថ្ងៃនេះ កងទ័ពចូនធូនីងបែកទៅតាមផ្លូវនោះ អ្នកចូរលើកគាហានចាមវាយកាត់កណ្តាលទ័ព ទោះបីគាហានចូនធូនីងវិនាសមិនអស់ ក៏គង់ស្លាប់ប្រហែលពាក់កណ្តាលគង់នីងបានសេះនឹងអាវុធជាច្រើន ។ ដូឡឹងថា ជំបន់ហ៊ួលឹមនោះជាផ្លូវបំបែក ២ អន្ទឹ ផ្លូវ ១ទៅស្រុកឡាំកុន ផ្លូវ១ទៅស្រុកកេងជីវ ខ្ញុំចាមិនដឹងជាចូនធូនីងលើកទៅខាងផ្លូវណា ។ ខុងបេងថា ផ្លូវទៅស្រុកឡាំកុនជិតខាងកងទ័ពជីវយើ គាហានជីវយើតង់នីងដេញតាមមុខជាចូនធូនីងបែកទៅផ្លូវស្រុកកេងជីវ អ្នកចូរទៅចាំនៅផ្លូវនោះ ហើយឲ្យខ្លៅហ៊ុយលើកគាហាន ៣.០០០ ទៅបង្គប់នៅនីងភ្នំតែ្សផ្លូវនីងទៅជំបន់ហោលោកុក រៀលព្រឹកនេះភ្លៀងនីងធ្លាក់ ចេះភ្លៀងពាំងហើយចូនធូទៅដល់ជំបន់នោះនីងឈប់សំរាកឲ្យគាហានដាំភ្លាយស៊ុ បើអ្នកបានឃើញផ្សែងភ្លើងកាលណា ក៏ឲ្យដេញគាហានចេញចាមកេមវាយកុំឲ្យដណ្តើភ្លាយគ្នាន់ គោះបីនីងចាប់ចូនធូមិនបាន អ្នកក៏នីងមានសេចក្តីគាប់ប្រសើរព្រោះបានគាប់សម្លាប់គាហានចូនធូអស់ជាច្រើន ។ ដូឡឹងនីងខ្លៅ

ហ៊ុយទទួលភាក្យខុនបេង៉ហើយ ក៏លើកទាហានចេញទៅ ។

ខុនបេង៉ក៏ប្រើបីតុក; ប៊ីហង, លើកទាហានទូកទៅប្រចាំនៅតាមមាត់ទន្លេ ចាំចាប់ទាហានចូនួដែលរត់ចុះមក ហើយឲ្យឡៅគីនាំទូកចម្បាំងទៅតាំងនៅដងចន់ហួដឿងដែលជាទីសំខាន់ បើឃើញចូនួបែកទៅផ្លូវនោះ ល្មមការដែលនឹងចាប់បានក៏ព្រួតចាប់ទុក មួយទៀតអ្នកនឹងបានការងារស្រុកតាំងហែងផង ។ ឡៅគីនឹងទាយទាហានតាំង ៣កងក៏ទទួលភាក្យខុនបេង៉ ហើយលើកទូកចម្បាំងញែកគ្នាទៅ ។ ខុនបេង៉ក៏និយាយនឹងឡៅគីថា ឲ្យលោកនាំទាហានទៅចាំមើលលើកំពូលភ្នំ ពេលយប់នេះជាវេយ៉ានឹងធ្វើការបានសម្រេចហើយ ។

គួនអ៊ូ ឃើញខុនបេង៉ប្រើអ្នកឯទៀតទៅធ្វើការតាមមុខងារអស់ហើយ ក៏គិតគូរចិត្តថា ខុនបេង៉មិនបានចាត់ចែងប្រើខ្លួនទៅធ្វើការនៅពីកន្លែងណាមួយសោះ ទើបចូលទៅនិយាយនឹងខុនបេង៉ថា ខ្លួនខ្ញុំបាទនេះបានចូលមកនៅធ្វើការនឹងឡៅគីជាបងក៏យូរហើយ តោះបើឡៅគីនឹងធ្វើការអ្វីក៏រមែងប្រើប្រាស់ខ្ញុំបាទឲ្យគាស៊ាទៅធ្វើការមុនគេគ្រប់កន្លែង គ្រានេះលោកមានមន្ទិលសង្ស័យនឹងខ្ញុំបាទយ៉ាងម្តេចបានជាមិនប្រើទៅធ្វើការជួបគេតាំងពួនផង ។ ខុនបេង៉ថា ទៅមានទីសំខាន់មួយអន្លើ តែថាបើនឹងប្រើអ្នកឲ្យទៅធ្វើការនោះកំនាំឲ្យមានមន្ទិលសង្ស័យ ។ គួនអ៊ូថា

លោកសង្ឃឹយដោយហេតុអ្វី ? ពុទ្ធិបេនិថា ដែលយើងមិនទុកលុះសង្ឃឹយនឹងអ្នកនោះ ព្រោះហេតុថាកាលពីដើមអ្នកបានសៅនៅទីដ៏ចចួ្ច តំបន់នាណិតស្រឡាញ់ជួយទំនុកបំរុងអ្នកដោយអស់ពីចិត្ត ឯកិត្តិរបស់អ្នកមានសេចក្តីស័ក្សកតញ្ញូដ៏គុណគេ រៀលថ្ងៃនេះចួបបែកចំពត្រឡប់រត់សៅតាមផ្លូវហ្ងឺយ៉ុង បើយើងនឹងឲ្យអ្នកសៅចាំបំរុងចាប់ចួបសៅទីនោះមុខជានឹងបាន បើជួបប្រទះមិនខានកំតង់មិនសម្ងាប់ ព្រោះអ្នកនឹងតិតដល់គុណដែលគេមានមកស្រាប់ ឃើញបានចំណាប់ហើយក៏ឲ្យរួចខ្លួនសៅដាអាសារឥតការ ? គួនអ្វីថា ឯដម្រេះប្រាជ្ញារបស់លោកនោះគ្រប់ពូលាយមែនណាស់ហើយ តែថាដែលចួបបានមានគុណូបការនឹងខ្ញុំបាទនោះ ខ្ញុំបាទក៏បានធ្វើការយកអាសារតបគុណចួបរួចជាស្រឡះព្រោះខ្ញុំបាទបានសម្ងាប់ដាន់លៀវនឹងប៊ុនជីវាតិតបគុណ បើលោកឲ្យខ្ញុំបាទសៅគ្រានេះ ហើយបានជួបប្រទះនឹងចួប ខ្ញុំបាទមិនបានកាត់ក្បាលចួបមកជូនលោកទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទជំនួសវិញចុះ តែខ្ញុំបាទក្រែងចួបនឹងមិនរត់សៅតាមផ្លូវស្រុកហ្ងឺយ៉ុងនោះវិញ តើលោកនឹងមានប្រសាសន៍ជួបម្តងសៅទៀត ? ពុទ្ធិបេនិថា បើអ្នកលើកទាហានសៅហើយមិនជួបប្រទះនឹងចួបសៅតាមផ្លូវនោះទេ ក៏ឲ្យប្រញាប់លើកទ័ពវិលមកវិញចុះ យើងនឹងកាត់ក្បាលរបស់យើងជាជំនួសក្បាលចួបឲ្យអ្នក លុះនិយាយ

ហើយកំបង្គាប់ប្រើគួនម៉ូឡេលើកតាហាន ៩០០ ទៅចាំស្កាត់ទៅផ្លូវហ្លួយ៉ុង ព្រោះទីនោះជាផ្លូវ ២ មេគ្នា ទីឆ៍ទៅលើស្រុកកេងដ៏វែ តែផ្លូវកោងខ្លាយ ជាងផ្លូវកាត់ដល់ ៩០០ សិន ឯផ្លូវកាត់នោះធាប់ តែដើរលំបាក ព្រោះជាច្រកភ្នំ អ្នកចូរឲ្យតាហានដទៃយកបម្រើឯទីឆ៍ ៩ សទៅតរជាក្នក់ក្លែងខុកទៅមាត់ផ្លូវកាត់ ឲ្យចូរឆ្លើយញែរួនក្លែងក៏ទឹងឆ៍តរ៉ែទៅតាមផ្លូវកាត់ ព្រោះជាផ្លូវត្រង់ ។ គួនអ៊ូប្លាថា ចូរឆ្លើនឆ៍តរៀសពីសេចក្តីស្លាប់ ហេតុម្តេចលោកត្រឡប់ថា ចូរឆ្លើនសំដៅទៅតាមផែ្លងក្លែងនោះវិញ។ ខុងបេងតបថា ចូរឆ្លើនោះជាមនុស្សឈ្លាសវៃណាស់ក្នុងការល្បួងបន្លោត បើយើញផែ្លងក្លែងហើយក៏គង់គិតថា ដ៏យើក្លែងធ្វើកលឲ្យទៅតរក្លែងខុក មុខជាតួនបង្គាប់ទ័ពស្កាត់ខាងផ្លូវនំវិញ ចូរឆ្លើក៏គង់ទៅខាងផ្លូវដែលមានក្លែង អ្នកចូរបាប់សម្លាប់ចេញ ហើយកាត់យកក្បាលមក ។ គួនម៉ូឡេលឆាកក្បែខុងបេងហើយ ក៏នាំគួនបេង, ជ័រឆេង ទីឆ៍តាហាន ៩០០ លើកចេញទៅ ។

កាលគួនម៉ូចេញទៅហើយ ឡៅពីក៏សួរខុងបេងថា ខ្ញុំលោកជាន់ជ្រាបចិត្ត គួនអ៊ូថាជាមនុស្សមានសេចក្តីស័ត្យកតញ្ញូទឹងអ្នកមានគុណណាស់ ដែលលោកប្រើគួនអ៊ូទៅគ្រានេះ ពោះប៉ាងជួយទឹងឆ៍ឆ្លើមែនតែគួនអ៊ូមិនធ្វើអន្តរាយ ព្រោះតែដល់គុណបការទឹងឆ៍ឡាយជាច្រើនដងឯការដែលគិតមកហើយទឹងឆ៍មិនអត់អំពើទៅឬ ? ។ ខុងបេងតបថា ខ្ញុំ

ថាខ្ញុំបានមើលឆ្កាយសម្រាប់បុណ្យចូលឆ្នាំថ្មីហាសិបកន្លះ កំឃើញនៅមុនរឿងជ្រះថ្លា ព្រោះជនភាសីចូលនៅមិនទាន់ជាប់បានជាខ្ញុំក្លែងប្រើគួនអ៊ូសៅធ្វើការសឹកគ្រានេះ ដើម្បីទឹងឲ្យគួនអ៊ូសងគុណចូលឆ្នាំសល់ទៅ តទៅមុខគួនអ៊ូទឹងបានធ្វើការតទឹងចូលតេញដៃតេញជើង ។ ឡៅតីបានឮដូច្នោះកំភើតសេចក្តីជ្រះថ្លាសរសើរដេម្រះក្រុងថាខុងចេងថា លោកគិតនេះហាត្រូវពេកណាស់ ។ ខុងចេងកំពុកស៊ុនឱនឆ្ងាយទឹងកាន់យុំដឹងឲ្យនៅរក្សាបន្តាយហៃទៅ ហើយនាំឡៅតីចុះទូកទៅចាំមើលកងទ័ពចូលនៅខេត្តហៃទៅ ។

ឯចូលនោះ តាំងចិត្តខន្ធឹងគិតមើលផ្លូវអ៊ុយកាយត្រង់វេលា ។ ដៀយ៉ុកកំនិយាយខំឯងចូលថា វេលាថ្ងៃនេះឡល់សលាត៍នបក់មកខ្លាំងណាស់ សុំឲ្យលោកវ៉ែរវាំងកងទ័ពយើងកុំឲ្យមានសេចក្តីអន្តរាយ ។ ចូលតបថា អ្នកកុំរិតក្តាឡើយព្រោះខេសកាលនេះ ខោះចាំឡល់សលាត៍ននឹងមានមកកំតិចខេ ចង់ឯងមានហេតុគេខុំដួកាលយ៉ាងណា កំល្មមនឹងការពារបាន ។

ឯមនុស្សស្ងួនអ៊ុយកាយ លុះទៅដល់កំបូលទៅក្នុងបន្ទាយចូលហើយជូនសំបុត្រទៅចូល ។ ខ្លួលយកទៅមើលដឹងសេចក្តីហើយ កំនាំពាហនចុះមកទៅកងទ័ពទូក ដើម្បីចាំទទួលអ៊ុយកាយ ។

ឯជាយ លុះវេលាល្ងាចជិតបានថ្ងៃត្រ កំឲ្យយកខ្លួនឈ្លបហាមកចងហើយសួរថា ហេតុម្តេចបានជាឯងមកបញ្ឆោតអញ ឥឡូវអញទឹង

លើកកងទ័ពទៅទៅខ្លះត្រឿងទឹងសែនខង់ជ័យ អញឲ្យគាត់ក្បាលឯង
សែនពួកយេកឯកក្បាលជ័យដំនះ ។ ឈ្លួហោថា តារនេះកាំឡើងទឹង
ឆ្នាំតេកកំបានរួមតំនិតជាមួយគ្នាទឹងខ្ញុំបានដែរ ហេតុម្តេចលោកមកសម្លាប់
តែខ្ញុំបានម្នាក់ឯង មិនសម្លាប់អ្នកទាំងនោះចេញផង ។ ជាវយើជាឯកាំ
ឡើងទឹងឆ្នាំតេកនោះ យើងប្រើឲ្យទៅបញ្ជោតចៅហ្វាយឯង ទៅតើ ខ្លួន
ឯងទាំង ២ ទើបជារួចសេចក្តីដែលខុសត្រូវតែទឹងអញ លុះនិយាយហើយឲ្យ
សម្លាប់ឈ្លួហោស្លាប់ហើយកាត់យកក្បាលសែនខង់ជ័យ លុះពេលព្រលប់
ជាវយើកំឡុងអ៊ុយកាយនាំពួក ២០ ដែលរៀបដោតខង់ខៀវចុកនោះឲ្យចៃ
ចេញទៅ ។ អ៊ុយកាយកំរៀបស្មៀកពាក់គ្រឿងប្រដាប់សម្រាប់ចម្បាំង
តឹក្រឹសទឹងអាវុធ ហើយចុះពួកលើកទាហានដុតភ្លើងគោមត្រប់ពួកទាំង ២០
ទៅត្រង់ដំបន់សេកផេក ។

ខណៈនោះខ្លួលកើតព្យុះខ្យល់សលាតន្ទាំងណាស់ ព្រះច័ន្ទកំភ្លឺ
ច្បាស់លើវេហាស៍ ។ ពួកចេញទៅអង្គុយសន្ទនានៅក្បាលពួកជួបជុំសេនា
ទាហាន ក្រឡេកមើលទៅឃើញលេកដំ ។ ណាំគ្នាតាមខ្យល់ពួកគ្នាន
ពិតាល់អ្វីដោយប្រមាទថា ជាវយើម្តងនេះមុខជាមិនរួចពីដៃយើងទេពួល
មានទាហានម្នាក់ចូលមកប្រាប់ថា ឥឡូវអ៊ុយកាយឲ្យពួកគូចមួយចូលមក
ប្តឹងថា ខ្លួនអ៊ុយកាយនាំពួកស្បៀងមកហើយ ពួកគូព្រួយរួចកំត្រេក

អរណាស់ និយាយថា អ៊ុយកាយមកគ្រានេះ គឺជាបុណ្យវាសនារបស់យើង ដោយខេតតាបត្តាលចិត្តនាំឲ្យមក ខ្ញុំលក្រឡេកឃើញខ្លួកទាំងនោះចែវជិតមក ឆៀយ៉ុកមើលទៅឃើញខ្លួកទាំងនោះ ស្រាលអណ្តែតខ្ពស់លើទឹក កំមានសេចក្តីសង្ស័យនិយាយនឹងប្អូនថា គ្រានេះខ្យល់សាត្តន៍កំភ្លាត់មកជាខ្លាំង ដែលនឹងខ្លួកចិត្តឲ្យអ៊ុយកាយចូលមកដល់តែម្តងមិនបាន ខ្លាចក្រែងជាកលទ្ធាយមានរឿងហេតុនឹងកែវខែកម្រណាស់ ។ ប្អូនសួរថា អ្នកឃើញហេតុយ៉ាងម្តេច ? ។ ឆៀយ៉ុកថា ឯធម្មតាខ្លួកផ្លុករបស់ជនមានតែតៀប ឥឡូវមើលទៅឃើញស្រាលអណ្តែតលើទឹកខ្ពស់ទាំងអស់ ខ្លួកអ៊ុយកាយនេះមុខជាមានហេតុហើយ ប៉ានជាខ្ញុំបាទឃាត់លោក ។ ប្អូនយល់ឃើញត្រូវ ទើបប្រើប៉ុនផេងចេញទៅឃាត់កុំឲ្យចូលមក ប៉ុនផេងនឹងតាហានប្រហែល១៤-១៥ នាក់ កំប៉ុះខ្លួកគួបចេញទៅស្រែកឃាត់ថា មហាឧបាជ្ឈាមកហាមឃាត់ថា ឲ្យខ្លួកអ៊ុយកាយចតខ្លួកពីឆ្ងាយសិន កុំអាលចូលមកព្រោះជាវិលាកណ្តាលយប់ ។ លុះថាឆុតពាក្យ តាហានអ៊ុយកាយកំយឺតធ្វើញ៉ាំមក ត្រូវស្មាស្តាំប៉ុន ផងដួលចុះ ហើយថយខ្លួនទៅតាំងអុបដាវជាសញ្ញាឡើង អ៊ុយកាយបានឮសូរដាវអុបជាសញ្ញាដូច្នោះ កំឲ្យបាកខន់ជាសញ្ញារៀងខ្លួន ខ្ញុំលខ្យល់ព្យុះសាត្តន៍ចត់មកខ្លាំង

ខ្លួកទាំង ២០ កំបើកក្តោងតាមខ្សល់ចូលទៅដុតក្តៅឡើង ហើយលឿនចំរើនលើគ្នា ចូលទៅទន្ទឹចនឹងផែទំពាចូច ។

សាមកុកខ្សែ ៤៣

តាំងពីអ៊ុយកាយដុនទំពាចូចបែក ចូចូរតាំឡើងគោកទៅប្រទះនឹងដូច្នេង. ទៀហ៊ុយ, តួនអ្វី. ចូចូឲ្យថោយិនទៅឈរស្រុកឡាំកុន ចូចូរលើកទ័ពទៅ ស្រុកហ្គីតោ ថោហែង' ថោយិន, ថោស៊ុនលើកចូលស្រុកឡាំកុន ។

ឯគាហានចូចូរយើញក្តៅនេះជាប់ឡើងលើខ្លួកខ្លាន កំនាំគ្នាគុបសាចទឹករំលត់ក្តៅនឹងជ្រូលប្រមល់ តែថាខ្សប់បក់មកជាខ្លាំងណាស់ យើញថាទប់ទល់ពុំឈ្នះ ព្រោះជាប់សោច្រវាក់ប្រគាក់ខ្សែគាបរឹងជាផែទាំងអស់ ក្តៅនឹកនេះពលជាលពេញទៅទាំងខ្លួកផែ ឯអ៊ុយកាយកំនាំគាហានប្រហែល ៩ នាក់ឬ១០ នាក់ចុះខ្លួកចូលទៅ ប៉ងនឹងភាប់ចូចូរសម្លាប់ចេញ។ ចូចូរកំត្រៀមដំបងទំនក្រជីដេញគាហានឲ្យចូលលត់ក្តៅ ។ កំពាន់តែនេះពលឡើង គាហានទាំងពួងធន់ទឹងក្តៅមិនបានកំស្ទុះរត់ទៅ ចូចូរស្រែកឲ្យឃកខ្លួកតូច ។ ចំឡងមនុស្សឡើងគោក ក្រឡេកមើលទៅបម្លាងគោក ក្តៅនឹកនេះឡើងជាច្រើនអន្លើ កំតែតែកំយាំងណាស់ លុះក្តៅពលនេះទៅដល់ខ្លួកខ្លានដែលចូចូរនៅ ខ្លួលយើញខ្លៀវលៀវយកខ្លួកមកខ្លួលចូចូរ ។កំចុះខ្លួកត់ទៅឡើងលើគោក ។

អ៊ុយកាយកាន់ក្រចឹអង្គុយលើក្បាលទូក ក្រឡេកឃើញចូនឆ្ងាត់តាវ ក្រហមរត់ចេញពីភ្លើង ចុះទូកប្រញាប់រត់ឡើងទៅលើគោក ក៏ឮតាហាន ស្រែកទូកចូលទៅហើយស្រែកថា តាចូនអាឯងរត់ទៅណា ។ ចូនឮដូច្នោះក៏រឹតតែស្ទុតក្នុងចិត្ត ខឿវលៀវឃើញអ៊ុយកាយតាមមកក៏យឺតជ្រុលប្រាប់ទៅត្រូវអ៊ុយកាយេធ្លាក់ទៅក្នុងទឹក ខឿវលៀវក៏នាំចូនឡើងទៅដល់មាត់ច្រាំង ឃើញកងទ័ពភ្ញាក់ផ្អើលច្របូកច្របល់មិនបានជាស្នូនទ័ព ខឿវលៀវ ក៏បង្គាប់ឲ្យយកសេះមកឲ្យចូនជិះហើយនាំតាហានស្រែករត់ទៅ ។

ឯហ៊ុនតុងដែលនាំទូកចម្បាំង៣០០ លុះទៅដល់កំចំរុលទូកចាំងអស់ចូលទៅតាមបន្ទោះទូកខ្លួន ខលួលបានឮសំឡេងមនុស្សនៅក្នុងទឹកស្រែកឲ្យជួយ គិតថាបានជាសំឡេងអ៊ុយកាយ តាំងតែដេញតាហានប្រញាប់លោតហែលទឹកទៅស្រង់គ្រាហ៍ឡើងមក ហើយតាញុកគ្រាត់ព្រួញជកចេញពីស្មាបាន បុងព្រួញគិចក់ជាប់នៅក្នុងសាច់ ហ៊ុនតុងយកបុងក្រចឹវះផ្តាច់ខ្នែងយកបុងព្រួយដែលចាក់នោះបាន ហើយយកព្រៃហែករុំរបួសនោះ រួចហ៊ុនតុងក៏ដោះអាវខ្លីខ្លួនឲ្យអ៊ុយកាយពាក់ ។

ខណៈកងលភ្លើងនេះទូកខ្លួននោះ នាយតាហានដែលឃុំនាំទូកចម្បាំងម្ភាក់ ៣០០ ជិវឃើមកក៏លើកទូកចម្បាំងទាំង ៣០០នោះ ជាជំនួយហ៊ុនតុងចូលទៅទៀត ចំណែកខាងតំនចូកឃុំទូកចម្បាំង ៣០០ វាយប្រសព្វ

ចូលតាមបង្អួចខ្លះខ្លួនតាមខ្លាងខាងលិចដើរដាយកំទាំខ្លួកចម្បាំង ៣០០ដាយ ប្រសព្វតិចសងកើត ។ ក្នុងខណៈនោះខ្លួកចម្បាំងដើរយើនីងខ្មៀកៅ មានឈ្មោះសេង, គេងហាងជាចៃកស្តាំនីងធ្វេង ដើរយៅដល់ចន្លោយកំពង់ប្រសព្វចូយៅព្រមគ្នា ។ ឯក្លីងដែលនេះនោះ បើកលៅដល់ទីណាកំនេះជាប់នៅទីនោះ ។ ខាហានដើរយើតាមតំក្រោយក្លីងចូលៅដុតបន្ទមឲ្យនេះកលតៅខ្មៀត ខ្យល់ព្យុះភ្លាំងក្លីងរំតែនេះភ្លាំងចោលអណ្តាតកលជាប់តេញត្រប់ខ្លួកខ្លាន ខាហានដើរយើកំចូលប្រកាប់ជាប់ក្បែរក្លីងពីលើខ្យល់ ខាហានចូនកំប្រលប្រថល់កមកតដៃ ណាកំយទីនីងក្លីងតាំងសងខាង ខ្លះកំត្រូវអាវុធបួសពីការស្លាប់ ខ្លះកំជាប់នៅកណ្តាលក្លីងនេះឡើងកេលស្លាប់លើដែ ខ្លះកំបែរៅលោតទឹកឆ្លាក់ស្លាប់ជាប់លើគ្នានីងគណនាត្រាកប់ពុំបាន ។

ឯកាំខ្សែងមេទ័ពគោកខាងដើរយើ កាលចូលៅដុតស្បៀងក្នុងបន្ទាយហ្លួមនេះអស់ហើយ លើចង្រៃខ្សែកយើញពន្ធីក្លីង កំលើកខាហានជំនួយចូលៅដុតបន្ទាយជាលំដាប់គ្នាៅខ្មៀត កាំខ្សែងនីងលើចងកំបានចាក់កាប់សម្លាប់កងទ័ពតេញស្លាប់ជារច្រើនណាស់ ។ ឯតាំងស៊ុតនីងក្លួងៀងកំឲ្យខាហានយកក្លីងដុតរន្ធាយ ខាហានចូនត្រប់ចាំង ៤ ទិស ពួកកងទ័ពចូនកំស៊ុតច្បាងគាស់តែរបួសពីការស្លាប់នីងកប់ពុំអស់

សល់អំពីនោះកំរត់បែកចាក់គស់ទៅ ។ ចូរធ្លូនឆ័ទៀវលៀវទៅសល់ថា-
ហានប្រហែល ១០០ ថ្ងៃ ។ កាលរត់ឡើងទៅលើមាត់ច្រាំង កំតាំងតែទំ
ស្រួតចូលទៅកេចន្លាយគោក កាលចេញចូលទៅដល់បន្ទាយណា ក្តើង
តំពាលដាលទៅដល់ពីនោះឆេះឡើងជាច្រើនបន្ទាយ ចូរធ្លូនាំគហានចាំង
ឡាយរត់ទៅចូលបន្ទាយដែលក្តើងមិនឆេះ ។

កាលចុំនឆេងត្រូវព្រញ្ញត្រឡប់មកវិញ ឃានឃើញក្តើងឆេះបន្ទាយ
ពីពីតគ្រប់ចូកខ្លាន ។ ម៉ាយរត់ចេញឃាន កំទៅជួបនឹងចុំន ផង ហើយ
នាំគ្នាឡើងទៅលើច្រាំងឃានគហានប្រហែល ៥០ នាក់ កំរត់ប្រញូន
ប្រពាក់ទៅជួបនឹងចូរធ្លូ ។ តំសួរទៀវលៀវថា យើងនឹងរត់ទៅពីណា
ទើបរួចពីភ័យអន្តរាយនេះ ។ ទៀវលៀវឆ្លើយថា ឲ្យលោករត់ ៧
ថ្ងៃដំបន់ហ្គីលីមទើបនឹងរួចភ័យ ។ ចូរធ្លូតីរវៀសរវៃនាំគហានចាំងនោះ
រត់ចេញទៅ លុះរៀបទំងំទៅដល់ដំបន់ហ្គីលីមតំពូសំឡេងនិស្រែកហៅ
ខ្លួមពីខាងក្រោយថា ចូរធ្លូតីភ័យស្លូតីស្លាតៃ ។

ឯលីបដ៏លើកចំពាទៅដល់ជិតកំស្រែកថា អាចូរធ្លូឯងរត់ទៅណា ?
អញជាគហានស៊ុនតួនមកពួនចាំស្លាត់នៅទីនេះ អញនឹងប្រឡេះយក
ក្បាលអាឯងឲ្យឃាន ចូរធ្លូដូច្នោះតំភ័យណាស់ ឲ្យទៀវលៀវកមក
តខ្លាំពីក្រោយ ខ្លួនចូរធ្លូតំស្ទុះបណ្តាយទៅមុខ ក្រឡេកទៅឃើញ

ក្តីឆ្នេះគឺកគុកខ្ទឹងផ្លូវដែលទឹងទៅនោះជាសន្ធឹកណាស់ មិនដឹងចៀសទៅខាងណា ឮសំឡេងភាហានម្នាក់ស្រែកចុះមកពីលើក្តីថា អញឈ្មោះឡេងថង លើកកងទ័ពមកបង្ក្រាបចាំនៅទីនេះ ចាំឆកដីវិតឯងហើយ ចូរធ្លាក់ណាស់ ខ្លួលស៊ុឡងបរសេះទៅទាន់ហើយស្រែកថាមហាទបពជកុំខ្លាច ហើយស៊ុឡងក៏បរសេះថ្មែកទៅមុខ ចូលក្រលុកតដៃទឹងឡេងថងជាប់គ្នា មិនទាន់ចាញ់ឈ្នះ ស៊ុឡងក៏ស្ទុះបំពារទាំយកចូរធ្លេចញទៅមុខបាន ។

ឯមាំអៀនទឹងខ្មៅគឺ ដែលចូរធ្លេឡេទៅតាំងបន្ទាយទៅដំបន្លឹមយ៉ាងនោះ ឃើញបន្ទាយចូរធ្លេក្តីឆ្នេះ ក៏លើកភាហាន ៣០០០ ស្រុតមកជួយ ខ្លួលជួបប្រទះគ្នាកណ្តាលផ្លូវ ចូរធ្លេក៏មិនសូវតែយណាស់ បានធ្លាស្រឡះក្នុងចិត្ត ឲ្យមាំអៀនទឹងខ្មៅគឺនាំភាហាន ១០០០ នាំផ្លូវទៅមុខ, ឯភាហាន ៦០០ ទៀត ចូរធ្លេឲ្យទៅការពារពីក្រោយ មាំអៀន, ខ្មៅគឺក៏នាំភាហាន ១០០០ នាំមុខចូរធ្លេទៅ ចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គ.ម) បានឮសំឡេងកងទ័ពស្រែកហ៊ោសន្ធាប់ពីមុខ នាយភាហាននោះស្រែកប្រាប់មកថា ខ្លួនអញឈ្មោះតាំឡេង លើកទ័ពមកចាំឯងនៅទីនេះ អញនឹងចាប់ពួកអាកំណាចតាំងអស់សម្លាប់ចោញ ។

(នៅមានត)

វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិនិទ្រ គុ. ដែលដេកលក់ច្រើនពេក ។ *អតិនិទ្រាលុ* គុ. ដែលមានកិរិយាដេកលក់ច្រើនលែង ។

អតិនិភ្ឫតមិ ក្រ. វិ. ដោយអាថិកំបាំងច្រើនលែង ។

អតិនិឃ្ឫណា គុ. សហាវច្រើនលែង ។

អតិនិទីឃ គុ. ដែលនឹតមានសេចក្តីអាណិតច្រើនលែង ។

អតិនិពិន្ធេន ឬ និពិន្ធតសិ ក្រ. វិ. ដោយអាការរួសរាន់ច្រើនលែង ។

អតិនិមិបិន ឧបុំ. កិរិយាក្លះ (សម្លាប្រទឹកដោះ) ច្រើនលែង ។

អតិនិវ្ឫតិនិ គុ. ដែលប្រព្រឹត្តផ្ទុយនឹងច្រើនលែង, ដែលប្រព្រឹត្តផ្ទុយ (សុនីវ័ធម៌) នឹងច្រើនលែង ។

អតិនិវិសុត្ត ឧបុំ. ការនៃពុទ្ធលង់ឥតច្បាស់ច្រើនលែង, សេចក្តីព្រឺព្រួចច្រើនលែង ។

អតិនិឝ្ឫត គុ. ដែលប្រព្រឹត្តប្រាន់ច្រើនលែង, ដែលមានទុក្ខរលត់ហើយច្រើនលែង, ដែលរីករាយច្រើនលែង ។

(នៅមានត)

ភ្នំពេញ


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣២ លេខ ១២ ខែធ្នូ

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ



អក្ខរសិទ្ធិ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បញ្ជាក់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បណ្ឌិតរៀន	ទំព័រ
- ពុទ្ធដីវប្បវត្តិ (តមក)	ព្រះមហា ចាំង-ខាត់	រៀបរៀង . . . ១៣២១
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក)	លោក ប៊ូ-ប៊ី	រៀបរៀង . ១៣៣៥
- មធុរសភាហិណី (តមក)	សម្តេចព្រះធម្មលិទ្ធិគត	ល្វី-ឯម ប្រែរៀបរៀង
ព្រះញាណកោសល	ញាណ-ឈិន	ពិនិត្យ ១៣៤៤
- មហោសថជាតក (តមក)	លោក អឹម-ភន	បម្លងពីសាស្ត្រស្លឹករឹត
ព្រះពុទ្ធវង្ស	កឹម-ឆ្លូរ	ពិនិត្យ ១៣៥០
ផ្នែកអក្សរសាស្ត្រ		
- រឿងមរណមាត (តមក)	លោក ប៊ី-សុវណ្ណ	បម្លងពីសាស្ត្រស្លឹករឹត . . ១៣៦១
- រឿងសាមកុក (តមក)	ទកញ្ចិ	ឆ្លូ-ភន ប្រែ ១៣៧១
- រឿងស្តេចជាយង្គោរ	លោក	ញ៉ែម-ទឹម រៀបរៀង ១៣៨៦
- រឿងព្រេងប្រទេសវៀណហ្សុយអេឡា	ភីកុ	ម៉ែន-រៀម រៀបរៀង . . . ១៣៩៧
-ឆ្លងផ្ទឹងទំនៀមទំលៀមទៅប្រទេសឥណ្ឌូណេស៊ី	អ្នកស្រីពេជ-សល់	តាមដើមសារៈយ៉ាន់ប្រៃ ១៤០៦
- រឿងត្រួកតប្លុកៈ	លោក ហេង-សមភាន	រៀបរៀង . . . ១៤១១
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍		
- ពត៌មានរបស់ក្រសួងធម្មការ	អំពីពិធីបុណ្យព្រហ្មទាន	លោក ភ័យ-ប៊ុក រៀបរៀង ១៤២៤
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហា	ចាំង-ខាត់ រៀបរៀង . ១៤៣៨

មួយឆ្នាំ មាន ១២ សៀវភៅ តំលៃជាវ ៤៣០០០

KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

sommaire

Partie religieuse :

— La Vie du Buddha (suite) par Prah máha PANG-KHAT . 1321
— Prah Abhidhammapitaka(Kathavathu) (suite) par M. BOU-PO 1335
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN . . . 1344
— Prah Mahcsothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON. revu par le Vén-KEM-TO 1350

Partie littéraire :

— Légende de Marana Màtâ(suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1361
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1370
— Légende du Roi Bayanko par M. NHEM-KHEM. . . . 1386
— Contes et Légendes de Venezuela par le bonze MEN RIEM . 1397
— Quelques coutumes indonésiennes traduites par Mme PICH-SAL née SARIS-YANN 1406
— Légende du porc Tacchaka (en poème) par M. HENG-SAM AN 1411

Notes et Chroniques :

— Nouvelles du Ministère des Cultes La distribution des Prix aux bonzes par M. RAY-BUK 1424
— Dictionnaire Samscrit-khmer (suite) par Vén.PANG-KHAT . 1438

Prix d'abonnement annuel (comprenant 12 numéros): 230|00 .

ពុទ្ធជីវប្បវត្ថិ

(ពមក)

ព្រះមហាថ្នាំង - ខាត់ រៀបរៀង

៩- ទ្រង់ធ្វើទុក្ករកិរិយា

ព្រះបរមពោធិសត្វ កាលព្រះអង្គបានធ្វើវត្តប្រតិបត្តិបង្ហើយនូវទីឆ្ងាយ ដោយមានចំណងថាល្បងមើល ព្រោះតែសន្មតថាប្រសើរណាស់ក្នុងសម័យនោះ ទ្រង់យើញថាមិនជាប្រយោជន៍ដល់ការត្រាស់ដឹងរបស់ព្រះអង្គទេ ទើបទ្រង់លះបង់ចោលហើយចៀសចេញទៅរកថ្ងៃមួយទ្រង់នឹកដល់កាលដែលទ្រង់នៅជាព្រះកុមារ គឺកាលស្តេចទៅចតពិធីប្រតក់ព្រះនង្គ័លរបស់ព្រះបិតា ទ្រង់បានបំពេញឈានទី១ ឈានទី២ ឈានទី៣ ទើបទ្រង់គង់ព្រះជំងឺធ្វើការបានឈានទី៤ ប្រព្រឹត្តយ៉ាងតឹងរឹង តឹងណាស់តែវត ការអ្នកណាមួយអាចធ្វើដូចបាន ឆ្លងជាកន្លះមានខ្មាមក្រាកដថាទុក្ករកិរិយាគឺអំពើដ៏ក្រៃក្រៃដែលមិនអាចបុគ្គលណាមួយធ្វើបានងាយ ដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ចំពោះពោធិកុមារថា(១)

១- ពោធិរាជកុមារសូត្រ មជ្ឈិម, ម.ម- លេខ ២៤, ទំព័រ ៣៣៤ ។

វិរៈទី ១- ម្នាលរាជកុមារ ! តថាគតត្រិះរិះថា "គួរតែអាត្មាអញទាំងឆ្មេញដោយឆ្មេញ ទល់ពិតានដោយអណ្តាតសង្កត់សង្កិនបៀតបៀន ដុតកំដៅចិត្តដោយចិត្ត, កាលតថាគតធ្វើដូច្នោះ ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ប្រៀបដូចជាបុរសដែលមានកំឡាំង ចាប់បុរសមានកំឡាំងខ្សោយជាងឲ្យដាច់ក្បាលឬក ហើយសង្កត់សង្កិនបៀតបៀនញាំញីយ៉ាងដូច្នោះដែរ ។ ម្នាលរាជកុមារ , សេចក្តីព្យាយាមដែលតថាគត បានប្រារព្ធហើយក៏មិនធ្លុះចេញ សតិដែលតថាគតបានដំកល់មាំមួនហើយក៏មិនរាយមាយ ប៉ុន្តែកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់សោះ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះ មកបណ្តាលចាក់ដោត ។

វិរៈទី ២-ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរតែសំឡឹងឈានមិនដកដង្ហើមជាអារម្មណ៍ គឺអត់ឃ្លាំអស្សាសបស្សាសៈតាមមាត់តាមច្រមុះ កាលតថាគត ធ្វើដូច្នោះសំឡេងឃ្លាំដែលចេញតាមរន្ធត្រចៀកខ្លាំង លើសប្រមាណ

ប្រៀបដូចជាស្នប់របស់ជាងសោហាជាតិ ដែលកំពុងសប់មាន
សំឡេងខ្លាំងដូច្នោះឯង ។ ម្នាលរាជកុមារ ! សេចក្តីព្យាយាម
ដែលតថាគតបានប្រារព្ធហើយមិនធ្លុះបង្ក សតិដែលតថាគត
ដំកល់មាំហើយក៏មិនរាយមាយ ប៉ុន្តែកាយរបស់តថាគត ក៏
នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់ ព្រោះសេចក្តីព្យាយាម
ដ៏លំបាកនោះ មកបណ្តាលចាក់ដោត ។

វារៈទី ៣-ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរ
សំទ្បឹងឈានមិនដកដង្ហើមជាអារម្មណ៍ទៀត, គឺអត់ឱ្យល់អស្សា-
សបស្សាសៈតាមមាត់តាមច្រមុះនឹងតាមរន្ធត្រចៀក កាលតថា-
គតធ្វើដូច្នោះ ខ្យល់យ៉ាងខ្លាំងលើសប្រមាណក៏វិលមកចាក់ដោត
ត្រង់ក្បាល ប្រៀបដូចជាបុរសដែលមានកំឡាំង ចោះក្បាល
ដោយដែកស្រួចយ៉ាងមុតដូច្នោះឯង ។ ម្នាលរាជកុមារ ! សេចក្តី
ព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធ្លុះបង្ក សតិ
ដែលតថាគតបានដំកល់មាំហើយ ក៏មិនរាយមាយ ប៉ុន្តែកាយ
របស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់

ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះ មកបណ្តាលចាក់ឫសគល់ ។

វិរៈទី២-ម្នាលវាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរតែសំឡឹងឈាន មិនដែលដង្ហើមជាអារម្មណ៍ទៀត គឺអត់ខ្យល់អស្សាសបស្សាសៈតាមមាត់តាមច្រមុះនឹងតាមអន្ត្រាចៀក ចាលតថាគតធ្វើដូច្នោះ វែទនាកើតក្នុងក្បាល ខ្លាំងលើសប្រមាណ ប្រៀបដូចជាបុរសមានកំឡាំង បង្ត្រៃបង្ត្រាចំណាងក្បាលដ៏ក្បាល ដោយព្រ័ត្រដ៏មាំដូច្នោះឯង ។ ម្នាលវាជកុមារ ! ប៉ុន្តែសេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធ្លាប់ឃ្លាតសតិដែលតថាគតបានដំកល់មាំហើយ ក៏មិនរាយមាយ ទាំងកាយរបស់តថាគតក៏នៅតែក្រវែលក្រវាយ មិនទាន់ស្ងប់រម្ងាប់ទៀត ព្រោះសេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលជាក់ផោត ។

វិរៈទី-ម្នាលវាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញសំឡឹងឈាន មិនដែលដង្ហើមជាអារម្មណ៍ទៀត គឺអត់ខ្យល់អស្សាសបស្សាសៈតាមមាត់តាមច្រមុះនឹងតាមអន្ត្រាចៀក

ការសតថាគតធ្វើដូច្នោះ ឱ្យល់លើសប្រមាណក៏កាត់នូវដំបារធ្វើ
ប្រៀបដូចជាបុរសអ្នកសម្លាប់គោក្តី អ្នកជំនួយរបស់អ្នកសម្លាប់
គោក្តី ជាអ្នកប្រសប់វាងវៃ កាត់ដំបារពោះគោដោយកាំបិត
ដ៏មុតសម្រាប់កាត់ពន្លះនូវសាច់គោ ដូច្នោះឯង ។ ម្នាលរាជ
កុមារ ! សេចក្តីព្យាយាម ដែលតថាគតបានប្រារព្ធហើយ
មិនធ្ងន់ឯយ សតិដែលតថាគតបានដំកល់មាំហើយ ក៏មិនវាយ
មាយ ឯរាងកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិន
ទាន់ស្ងប់រម្ងាប់ទៀត ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង
មកបណ្តាលចាក់ដោត ។

វារៈទី ៦ ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែ
អាត្មាអញសំឡឹងឈាន មិនឯកដង្ហើមជាអារម្មណ៍ទៀត គឺ
អត់ឱ្យល់អស្សាសបស្សាសៈ តាមមាត់ តាមប្រមុះ តាមរន្ធ
ត្រចៀក, ពេលតថាគតធ្វើដូច្នោះ សេចក្តីក្តៅក្រហាយដ៏ខ្លាំង
លើសប្រមាណ ក៏កើតមានក្នុងកាយ ប្រៀបដូចជាបុរសមាន
កំឡាំងពីរនាក់ ចាប់បុរសដែលមានកំឡាំងខ្សោយ ត្រង់ដើម

ដៃម្ខាងម្នាក់ ហើយយកទៅឆ្អែកក្នុងរណ្តៅរងើកភ្លើង ឲ្យ
ក្រហល់ក្រហាយដូច្នោះឯង ។ ម្នាលរាជកុមារ ! កាលតថាគត
អត់ឃ្លាន់អស្សាសបស្សាសៈ តាមមាត់ តាមច្រមុះ តាមរន្ធ
ត្រចៀកហើយ សេចក្តីក្តៅក្រហល់ក្រហាយ ខ្លាំងលើសប្រ-
មាណក៏កើតមានក្នុងកាយ ។ ម្នាលរាជកុមារ ! សេចក្តី
ព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធ្លាយឆាយ សតិ
ដែលតថាគតបានដំកល់មាំហើយ ក៏មិនរាយមាយ ឯកាយ
របស់តថាគត ក៏នៅតែក្រវាល់ក្រវិយមិនស្ងប់រម្ងាប់ទៀត ព្រោះ
សេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលចាក់ដោត ។

ម្នាលរាជកុមារ ! គ្រានោះ ពួកទេវតាឃើញតថាគត
ហើយ បាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតម ធ្វើ
មរណកាលទៅហើយ, ទេវតាពួកខ្លះបាននិយាយគ្នាថា ព្រះ
សមណគោតម មិនទាន់ធ្វើមរណកាលទេ តែព្រះសមណ
គោតមនឹងធ្វើមរណកាលឥឡូវនេះ, ទេវតាពួកខ្លះនិយាយគ្នាថា

ព្រះសមណគោតម មិនទាន់ធ្វើមរណកាលទេ ទាំងមិនទាន់ធ្វើមរណកាលឥឡូវនេះដែរ ព្រះសមណគោតមជាព្រះអរហន្ត ន៎ុះជាវិបរិណាមធម៌ទេតើ ! សភាពយ៉ាងនេះ រមែងមានដល់ព្រះអរហន្ត ។

វារៈទី៣-ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញ ប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួង ។ លុះដាប់នោះពួកទេវតាទាំងនោះ បានប្រួលមករកតថាគតហើយ បប្រួលគ្នានិយាយថា "បពិត្រអ្នកនិរទុក្ខ ! អ្នកកុំប្រតិបត្តិដើម្បីផ្តាច់បង់អាហារ បើទ្រង់ប្រតិបត្តិដើម្បីផ្តាច់បង់អាហារដោយប្រការទាំងពួងហើយ ពួកយើងនឹងបញ្ចាលឱជាជាទិព្យតាមរន្ធរោមរបស់ព្រះអង្គ នឹងញ៉ាំងព្រះអង្គឲ្យរស់នៅដោយឱជាជាទិព្យនោះ" ។ ម្នាលរាជកុមារ កាលនោះ តថាគតត្រិះរិះថា បើអាត្មាអញនឹងប្តេជ្ញាចំពោះពួកទេវតា ក្នុងកាលឥឡូវនេះទៅ ពួកទេវតាទាំងនេះនឹងបញ្ចាលឱជាជាទិព្យតាមរន្ធរោមរបស់អាត្មា

អញ្ជ ចំណែកខាងអាត្មាអញតប្បីញ្ញុំងជីវិតឲ្យរស់នៅដោយ
ខ្លួនជាទីព្យនោះ ពាក្យនោះនឹងជាពាក្យកុហកដល់អាត្មាអញ ។
ម្នាលរាជកុមារ ! តថាគត ឃាត់ពួកវេនាំងនោះថា
និយាយថា " ល្ងើយកុំឡើយ " ។ ម្នាលរាជកុមារ ! តថាគត
រិះថា គួរតែអាត្មាអញសម្រេបអាហារកិច្ចបន្តិច ។ បាំនួនជាមួយ
ទ្លុកដៃខ្លះ ប៉ុនសាច់គ្រាប់សណ្តែកបាយខ្លះ ប៉ុនសាច់គ្រាប់
ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្តែកកាំខ្លះ ពុំនោះសោតប៉ុន
សាច់គ្រាប់រំលឹងឈ្លកខ្លះ ។ ម្នាលរាជកុមារ ! កាលតថាគត
សម្រេបអាហារកិច្ច បន្តិចម្តងមួយតិចម្តង ។ ដូច្នេះ កាយរបស់
តថាគត ក៏ដល់នូវអាការស្គាំងស្គមខ្លាំងលើសប្រមាណ ។
អវយវៈតូចធំរបស់តថាគត ប្រៀបដូចវល្លិមានថ្នាំងប្រើន
និងវល្លិមានថ្នាំងខ្មៅ ទ្រគាករបស់តថាគត ក៏ស្តៀតបួលគ្នា
ដូចជាស្នាមជើងទន្សាយ ទ្រនុងឆ្អឹងខ្នងរបស់តថាគត ក៏រជិរជុំប
ដូចខ្សែស្រួសដែលគេវៀចបួលគ្នា ឆ្អឹងជំនីរតថាគត ក៏

រួតមរគាម ដួចជាបង្កងនៃសាលាចាស់ ប្រស្រីភ្នែករបស់តថាគត ក៏ជ្រៅខ្លងប្លួលទៅក្នុងរណ្តៅភ្នែក ដួចកំពែងទឹកដ៏ខ្លងជ្រៅប្លួលទៅក្នុងអណ្តូងទឹកដ៏ជ្រៅ ។ សម្បុរស្បែកក្បាលសម្រាប់ទទួលសម្ផស្សរបស់តថាគត ក៏ស្វិតជ្រីវទៅ ដួចផ្លែឃ្លោកទីដែលគេកាត់បេញអំពីទង ហើយស្វិតស្រពោនដោយខ្យល់នឹងកំដៅថ្ងៃដួច្នោះ ព្រោះទោសដែលមានអាហារតឹបនោះឯង ។ ... ម្នាលរាជកុមារ , តថាគតនោះគិតថា នឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវឆ្អឹងខ្នងវិញ គិតថា នឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវស្បែកពោះវិញ, ស្បែកពោះរបស់តថាគត ជាប់គ្នានឹងឆ្អឹងខ្នង តថាគតនោះគិតថា នឹងបត្ថោរបង់គូរវិច្ឆ្ឫមូត្រ ក៏ដួលពោបនៅក្នុងទីនោះ ព្រោះទោសអាហារតឹបនោះឯង ។ ម្នាលរាជកុមារ ! តថាគត កាលធ្វើកាយនេះឱ្យស្រួលហើយទើបស្ទាបខ្លួនដោយដៃ, កាលតថាគតស្ទាបខ្លួនដោយបាទដៃទៅ រោមទាំងឡាយមានឫសស្អុយ ក៏ជ្រុះបេញពីកាយ ព្រោះ

ទោសអាហារតិចនោះឯង ។ ម្នាលរាជកុមារ ! គ្រានោះមនុស្ស
ទាំងឡាយឃើញតថាគតហើយ ក៏នាំគ្នានិយាយថា ព្រះស-
មណគោតមមានសម្បុរខ្មៅ ខ្លះនិយាយថា ព្រះសមណគោតម
មិនមែនមានសម្បុរខ្មៅទេ ព្រះសមណគោតមសម្បុរសណ្តែក
បាយទេតើ ! ពួកខ្លះនិយាយថា ព្រះសមណគោតមមិនមែន
មានសម្បុរខ្មៅទេ ទាំងមិនមែនមានសម្បុរសណ្តែកបាយទេ គឺ
ព្រះសមណគោតមមានសម្បុរប្រផេះទេតើ ! ។ ម្នាលរាជកុមារ !
ឆវីវណ្ណរបស់តថាគត ដ៏បរិសុទ្ធដ៏ល្អោះហើយ ត្រឡប់ទៅ
ជាអាប់អន់ទៅវិញ ព្រោះទោសអាហារតិចនោះឯង ។

១០- ទេពតាបួលទៅថ្វាយដំណឹងព្រះវរបិតា

*ខណៈនោះ ទេពតាមួយអង្គជាពួកមារ គិតស្មានថា ព្រះបរម-
គោធិសត្វស្តេចទំវង្គតហើយ ក៏បួលទៅគាន់ក្រែងតថាលព័ស្តុ យក
សេចក្តីថ្វាយព្រះបាទសុទ្ធោទនថា "ឥឡូវនេះ ព្រះរាជបុត្រនៃព្រះអង្គ
ទ្រង់ទំវង្គត់ហើយ" ។ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្ងាច់ហើយ
ទើបត្រាស់សួរថា "ព្រះរាជឥសរបស់យើង បានត្រាស់ជាព្រះសម្ម-*

សម្ពុទ្ធហើយឬទៅ?» ទេតតាតបថា «ស្តេចទៅមិនទាន់ឆ្ងាយត្រាស់ដឹងទៅ ឡើយទេ» ។ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្តាប់ហើយ បណ្តេញថា «អ្នកចូរចៀសចេញឲ្យឆាប់ទៅ ទុរាសរបស់យើង បើមិនទាន់ បានត្រាស់ជ្រាបសារតេជគុណាណាទេ ទឹងមិនទាន់ធ្វើមរណកាលទេ» ។ ទេតតាខោះ ក៏អន្តរធានបាត់ពីវិសេសឆាប់ទៅ ។

๑๑- ទ្រង់ត្រឡប់បរិភោគអាហារវិញ

ទ្រង់ពិចារណាឃើញទោសការបរិភោគអាហារខុសពេក ទើបទ្រង់ បរិភោគអាហារតាមប្រក្រតីដើមឡើងវិញ ដូចសេចក្តីដែលទ្រង់ត្រាស់ទៅ កោះពជកុមារថា (๑)

«... ម្នាលរាជកុមារ! តថាគតត្រិះរិះថា ពួកសមណ ព្រាហ្មណ៍ឯណាមួយ ក្នុងអតីតកាលក្តី ក្នុងអនាគតកាលក្តី ក្នុងបច្ចុប្បន្នកាលនេះក្តី ដែលកំពុងតែរងទុក្ខខ្លោចផ្សាដ៏ក្លៀវក្លា ដែលកើតអំពីសេចក្តីព្យាយាម មានកំណាត់ត្រឹមប៉ុណ្ណោះ មិនលើសជាងនេះទៅទៀតបាន តែទោះបីដូច្នោះ តថាគតក៏នៅតែមិនទាន់ត្រាស់ដឹង នូវទុត្តរិមនុស្សធម៌ ជាគុណវិសេសគួរដើម្បី

๑- កោធិរាជកុមារសូត្រ រាជវគ្គ, ម.ម. លេខ ๒๔. ទំព័រ ๓๘๕ ។

ឃើញដោយប្រាជ្ញាព្រះអរិយៈ ដោយទុក្ករកិរិយាដ៏ខ្លាំងផង្សាអេះ បានឡើយ ទំនងជាផ្លូវត្រាស់ដឹងនឹងមានដោយយ៉ាងដទៃទេដឹង?។

ម្នាលរាជកុមារ! តថាគតត្រិះរិះថា តថាគតនៅចាំបាន កាលព្រះបិតាប្រទ័ព្រះនង្គ័ល តថាគតអង្គុយក្រោមម្លប់ជម្ពុព្រឹក្សដ៏ត្រជាក់ បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈានមានវិតក្កៈវិចារៈ មានបីតិនឹងសុខៈដែលកើតអំពីវិវេក ហើយគិតថា «អេះជាផ្លូវត្រាស់ដឹងបានដែរឬ?»។ កាលនោះ វិញ្ញាណដែលស្ទុះទៅតាមសតិ ក៏កើតឡើងដល់តថាគតថា «អេះហើយប្រាកដជាផ្លូវត្រាស់ដឹង»។ ម្នាលរាជកុមារ! តថាគតត្រិះរិះថា អាត្មាអញខ្លាចសេចក្តីសុខដែលជាសុខរៀរស្រឡះចាកកាមទាំងឡាយ ដែលជាសុខរៀរស្រឡះចាកអកុសលធម៌ទាំងឡាយដែរឬ? ប៉ុន្តែសេចក្តីសុខបែបអេះ តថាគតមិនខ្លាចឡើយ សេចក្តីសុខនោះដែលបុគ្គលមានរាងកាយ មានកាយដ៏ល្អវិសេចក្តីស្ងាំងស្ងុម លើសប្រមាណ

យ៉ាងនេះ មិនងាយនឹងសម្រេចបានឡើយ បើដូច្នេះ គួរតែអាត្មាអញបរិភោគអាហារដ៏គ្រោតគ្រោត គឺបាយ នឹងនំកុម្មាសឡើងវិញ ទើបទ្រង់បរិភោគអាហារតាមធម្មតាឡើងវិញ ។

១២- បញ្ចវគ្គិយតាបសលះបង់ពោធិសត្វ

លុះទ្រង់បរិភោគរួចហើយ បញ្ចវគ្គិយក៏ចោះបង់ព្រះអង្គចោលទៅ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិកុមារថា(១)

«. . . ម្នាលរាជកុមារ ! សម័យនោះឯង ពួកបញ្ចវគ្គិយតាបសអ្នកបំរើតថាគត គិតគ្នាថា បើព្រះសមណគោតមត្រាស់ដឹងធម៌ណា នឹងសំដែងធម៌នោះ ប្រាប់ដល់យើងទាំងឡាយ តែឥឡូវនេះទ្រង់បរិភោគអាហារដ៏គ្រោតគ្រោតគឺបាយ នឹងនំកុម្មាសវិញហើយ ។ ត្រានោះ ពួកបញ្ចវគ្គិយតាបសអម្បាលនោះ ក៏ឆ្ងល់ណាយនឹងតថាគតហើយ បៀសបេញ្ចទៅដោយគិតថា ពឹងអ្វីទឹងកើតបើសមណគោតមជាអ្នកល្មោភ ឃ្លាតចាកសេចក្តីព្យាយាម ត្រឡប់មកដើម្បីល្មោភវិញ ។ ម្នាល

១- ពោធិរាជកុមារសូត្រ រាជវគ្គ. ម.ម. សៀវភៅ ២៤ , ទំព័រ ៣៨៧ ។

រាជកុមារ! លុះតថាគតបរិភោគអាហារដ៏គ្រោតគ្រាតហើយ ក៏
បំរុងរាងកាយឲ្យមានកំលាំង ស្ងាត់ចាកកាមទាំងឡាយ ។ ។

ឯពួកបញ្ចវគ្គិយតាបស ប្រដាប់ខ្លួនជាស្រេចហើយ កំលះបង់ព្រះបរមពោធិសត្វ ហើយបបួលគ្នាដើរទៅកាន់ព្រៃឥសិបត្តនមិគទាយវ័ន ទៀបក្រុងពារាណសី អស់បម្ងាយផ្លូវ ១៥ យោជន៍ ចូលទៅជ្រកអាស្រ័យនៅក្នុងដងព្រៃនោះ ។ ចំណែកព្រះពោធិសត្វ លុះពួកបញ្ចវគ្គិយតាបសចេញចាកចោលព្រះអង្គហើយ ទ្រង់កំចាន់សម្រេចបត្តផ្លាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

(នៅមានត)

ព្រះអភិធម្មបិដក

កម្ពីរព្រះកថាវត្ថុ

(ភាគ)

លោក ប៊ូ-ប៊ូ ប្រែរៀបរៀង

កុសលចិត្តកថា

ក្នុងលំដាប់នេះ ខ្ញុំឯងបានវិសជ្ជនាក្នុងអរហន្តកុសលចិត្តបរិនិព្វានកថា តទៅ តាំងជាសកវាទិបរវាទីមានសេចក្តីថា ៖

សកវាទិ- កុសលចិត្តោ បរិនិព្វាយតិ ព្រះអរហន្តដែលអស់អាសវៈហើយនោះមានចិត្តជាកុសលចូលកាន់ព្រះបរិនិព្វានមែនឬទេ?

បរវាទិ- អាមន្តា អើ! ត្រូវតែតបដូចពាក្យអ្នកថាហើយ ព្រះអរហន្តដែលអស់អាសវៈហើយនោះ តាលនឹងរលត់ខន្ធចូលកាន់ព្រះបរិនិព្វានមានចិត្តជាកុសល ។

សកវាទិ ដែលអ្នកថា ព្រះអរហន្តមានចិត្តជាកុសល ចូលកាន់ព្រះនិព្វាននោះ ខ្ញុំនៅសង្ស័យទើសមាក់ចិត្តមិនទាន់យល់ស្របតាមពាក្យបស់អ្នកទេ ព្រោះហេតុថាព្រះអរហន្តនោះ រមែងធ្វើនូវបុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អនេញ្ជាភិសង្ខារ តើព្រះនិព្វានជាបច្ច័យតើ-អកុសលតាក់តែងមែនឬទេ ?

បរវាទី – មិនមែនទេ ! អសង្ខតធម៌ឈ្មោះ ព្រះនិព្វានោះ គ្មានបច្ច័យ តែកុសលនឹងអកុសលប្រជុំតាត់តែងទេ ។

សកវាទី – ព្រះនិព្វានោះ អ្នកនិយាយថា បច្ច័យតែអកុសលប្រជុំតាត់តែង ខ្ញុំកំយល់ឃើញតាមផងបាន ព្រោះហេតុព្រះនិព្វានប្រកបដោយសុខមួយចំណែក ជាសុខពិតប្រាកដមិនលាយឡំទៅដោយទុក្ខ ដែលនឹងថា ព្រះនិព្វានកុសលមិនបានប្រជុំតាត់តែងនោះ ខ្ញុំទៅសង្ស័យ ព្រោះហេតុព្រះនិព្វានទៅបាន ចំពោះតែព្រះអរហន្តមួយពួកប៉ុណ្ណោះ កាលលោកទៅនោះទៀត ក៏មានចិត្តជាកុសលទើរទៅបាន ។

បរវាទី–អ្នកតប្បីបួលចិត្តថា ព្រះនិព្វានពំមានបច្ច័យប្រជុំតាត់តែងទេ ដ្បិតព្រះនិព្វានជាអត្ថាកតធម៌ ប៉ុន្តែ បុគ្គលនឹងទៅកាន់ព្រះនិព្វានបានដោយអំណាចនៃមហគ្គតកុសល អ្នកតប្បីបួលចិត្តដោយន័យដូច្នេះចុះ ។

កុសលចិត្តកថា ចប់ប៉ុណ្ណេះ ។

ទុតិយសកវាទកថា

ទុតិយោ កិលេសេ បដិហតិ សកិលេសាតីតិ អាបន្នា សកិលេសាមិមក្លេន ចត្តារិ ឯដ្ឋិវិប្បយុត្តា ទ្វេ នោមនស្សសហគតានិ ទុតិយវាទកាមកតព្យាទ-

វាសេន ច ចិត្តានិ បហាយន្តិ ។

វារៈនេះ ទីឃភាណកនិកាយ ពាហិយកសុត្តសង្គហ-
បុគ្គលតៅ ។ អ្នកប្រាជ្ញតម្រាំសន្និដ្ឋានថា សម្តេចព្រះបរមសាស្តាចារ្យ
ប្រទានព្រះសទ្ធម្មទេសនាជាសកវាទីបរាវាទី ដូចនិយាយដែលបានសំដែងមក
ហើយ កុងបឋមប្រស្នា គឺត្រាស់ឫទ្ធិហើយត្រាស់វិសជ្ជនា ដូចតៅនេះ ៖

សកវាទី - តាំលេសេ បជហាតិ ព្រះសក្យតាមិបុគ្គល
នោះ លះតិលេសបានតែជាចំណែក។ ឬក៏លះបានជាប់ស្រឡះទាំង
អស់តែម្តង ។

បរវាទី - អាមន្តា អើ ! ព្រះសក្យតាមិបុគ្គលលះតិលេសបាន
តែជាឯកទេសចំណែក។ មិនបានលះទាំងអស់តែម្តងទេ នៅមានតិលេស
សេសសល់ ព្រះសោតាបុគ្គលលះតិលេសបានដូចម្តេច ព្រះសក្យតាមិ-
បុគ្គលក៏លះតិលេសបានដូច្នោះដែរ ។

សកវាទី - ហាញ្ចិ បើដូច្នោះ មិនឈ្មោះថា ឯកទេសសក្យ-
តាមិបុគ្គលតៅហើយឬ ?

បរវាទី- ន ហោតិ វត្តព្វេ អ្នកកុំថាយ៉ាងនោះ មិនសមគួរ
ទេ ព្រះសក្យតាមិបុគ្គល មិនមែនលះតិលេសបានជាឯកទេសសក្យ-
តាមិទេ ។

សកវាទី - កាលខ្ញុំសួរពីដំបូង អ្នកឆ្លើយថា ព្រះសកិទាគាមិបុគ្គលលះកិលេសបានដោយឯកទេសដូចព្រះសោតា លុះដល់ខ្ញុំសួរថា ព្រះសកិទាគាមីមិនបានឈ្មោះថា ឯកទេសសកិទាគាមីទេឬ អ្នកត្រឡប់ជាឆ្លើយថា មិនមែនជាឯកទេសសកិទាគាមីទេ ពាក្យដែលអ្នកឆ្លើយមុនមិនសមនឹងពាក្យឆ្លើយក្រោយសោះ អ្នកបួនទេដួលខ្លួរទោសដែលអ្នកនិយាយខុស ទើបខ្ញុំអត់ទោសឲ្យអ្នក ។ ចុះព្រះសកិទាគាមីបុគ្គលនោះលះកិលេសបានប៉ុន្មាន ?

បរវាទី - ព្រះសកិទាគាមិបុគ្គលនោះ ចាប់ផ្តើមមុនដំបូង ជម្រះសីលច្រើនប្រការឲ្យបរិសុទ្ធ កាត់ចោសខ្លួរបលិពោធដប់ប្រការ មានកង្វល់ដោយអាវាសជាដើម ហើយចូលទៅជិតខ្លួរមិត្តមានចិត្តជាកុសលមានគុណជាអាទិ៍ គឺជាមនុស្សដែលស្រឡាញ់ត្រេកអរស្មោះត្រង់ ហើយទើបរៀនព្រះកម្មដ្ឋាន រៀរលែងវិហារគឺលំនៅមិនសមគួរ ១៨ កន្លែង មានអាវាសធំជាដើម មានអាវាសដែលខ្លួនមិនបានខ្លួរកល្យាណមិត្តជាបរិយោសាន ហើយទៅទៀតក្នុងវិហារប្រកបដោយអង្គច្រើ មានវិហារមិនត្រូយពេកមិនជិតពេកល្មមទៅមកបានជាដើម ហើយលះបង់ខ្លួរកង្វល់មានក្របកវៃនឹងសក់វៃឯហួសប្រមាណជាអាទិ៍ ហើយចំរើនខ្លួរព្រះកម្មដ្ឋានប្រកបជាមិច្ចដោយសមាធិប្រការ គឺបរិកម្មសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១

បានន័យថាដំណាតនិមិត្តនឹង១គួហនិមិត្ត បានរួចហើយបានអរូបាវ-
ចរសមាបត្តិ លុះបានសមាបត្តិច្រើនប្រការហើយ ច្រើនថ្ងៃនឹងឲ្យដល់
ព្រះអរហត្ត តើញ្ចឹងញាណទស្សនវិសុទ្ធិឲ្យច្រើនដង ក្នុងលំដាប់នៃវិសុទ្ធិ
ច្រើនមួយប្រការ មានសីលវិសុទ្ធិជាដើម មានមគ្គាមគ្គញាណទស្សន-
វិសុទ្ធិជាទីបំផុត ហើយទើបយកនូវព្រះនិព្វាន3ជាអារម្មណ៍ កន្លងផុតនូវ
បុថុជ្ជនគោត្រភូញាណ ចូលកាន់ព្រះអរិយគោត្រភូញាណ ក្នុងលំដាប់នៃ
អរិយគោត្រភូញាណនោះ តើកំណត់នូវខុក្ខអរិយសច្ចមានជាតិទុក្ខជាដើម
ហើយលះបង់នូវសមុទយអរិយសច្ច គឺសេចក្តីប្រាថ្នាក្នុងកាមភព, រូបភព,
អរូបភព ធ្វើឲ្យជាក់ច្បាស់នូវនិរោធអរិយសច្ច ទើបចំរើនមគ្គសច្ច ហើយ
លះបង់នូវកិលេសបានដោយកាល តាំងនៅក្នុងហ្វូងអរិយភូមិគឺព្រះសោ-
តាបន្ន ហើយធ្វើសេចក្តីព្យាយាមដើម្បីនឹងឲ្យដល់នូវមគ្គជាតំរង់ពីរគឺព្រះ
សកិទាគាមិមគ្គ ព្រះសកិទាគាមិផល ធ្វើសេចក្តីព្យាយាមញ៉ាំងកាមភព
គឺសេចក្តីតម្រេកក្នុងកាម ទើបសេចក្តីព្យាបាទឲ្យវិនាសឆាត់សូន្យ បាតនូ
សន្តាន ហើយពិចារណានូវសង្ខារទាំងច្រើន គឺរូប, វេទនា, សញ្ញា,
សង្ខារ ទើញវិញ្ញាណ ដោយព្រះត្រៃលក្ខណញ្ញាណ ពិចារណាបញ្ច
ញសង្ខារដោយព្រះ អនិច្ចំ, ទុក្ខំ, អនត្តា គឺឃើញថាបញ្ចសង្ខារ
មិនទៀងនាំមកនូវទុក្ខទើមិនមែនជារបស់ខ្លួន លុះពិចារណាឃើញដូច្នេះ

ហើយ កំយាងចុះកាន់វិបស្សនាវិថី តសេ្តរំ បដិបន្ទសេ្ស កាល
ប្រតិបត្តិដោយប្រការដូច្នេះហើយ អនុលោមគោត្រភូញ្ញាណទាំងឡាយ
កំបង្កើតកន្លងលំដាប់នៃគោត្រភូញ្ញាណនោះ ព្រះសកិទាគាមិមគ្គកំបង្កើត
កន្លងលំដាប់នោះ ផលចិត្តទាំងឡាយកំបង្កើត ជានឈ្មោះថាសកិ-
ទាគាមិបុគ្គល លះបង់នូវចិត្តជាទីប្រឡុកត្ថូនដូង ចិត្តប្រកបដោយ
លោមនសេ្សរដូង ទីដ៏លះបង់នូវកាមរាគនិងតាជាច់ណាចំណែកៗឯព្រះស-
កិទាគាមិបុគ្គលនោះ ចែកចេញទៅទៀតជាន២៦ពួកជានឈ្មោះថាសកិ-
ទាគាមិបុគ្គលនោះ ព្រោះថានឹងមកកាន់លោកចេះមួយគ្រាទៀត ជាន
សម្រេចព្រះសកិទាគាមិផលក្នុងមនុស្សលោកនេះ លុះអស់ជីវិតន្ទ្រើយ
ជានទៅកើតក្នុងទេវលោកនៅក្នុងទេវលោកនោះ ដរាបដល់អស់កំណាត់
កាល លុះរលត់បញ្ចាសង្ខារហើយចុះមកកើតក្នុងលោកនេះ ជានសម្រេច
មគ្គផលដកថដល់ព្រះអរហត្តផល លុះអស់ជីវិតហើយចូលកាន់ព្រះនិព្វាន
ក្នុងមនុស្សលោកនេះ ។

សកវាទី – សទ្ធិ ឯកវីសតិ ព្រះសកិទាគាមិបុគ្គលនិងឯក-
ពីជិសោតានោះ មានហេតុផ្សេងគ្នាដូចម្តេច ដ្បិតព្រះសកិទាគាមីកំមក
កាន់លោកនេះមួយជាតិទៀត ព្រះសោតាដែលឈ្មោះថាឯកពីជិនោះកំ
មកកើតក្នុងលោកនេះមួយជាតិទៀតដូចគ្នាដែរ ?

បរវាទី - ฝ กោ៎ះ បដិសន្ធិ ឯកព័ជិសោតានោះ មានបដិ-
សន្ធិតតែក្បាច់បញ្ចកន្ធតែមួយជាតិប៉ុណ្ណោះ ឯព្រះសក្យាតាមិបុគ្គលនោះ
មានបដិសន្ធិពីរដង ឥទំ ឯតានាការណំ ហេតុផ្សេងគ្នានៃព្រះ
សក្យាតាមិបុគ្គលទាំងឯកព័ជិសោតានោះដូច្នេះ ។

សកវាទី - កិ បន ភន្តេ ព្រះអនាគាមិបុគ្គលលះកិលេសបាន
ប៉ុន្មាន ?

បរវាទី - ព្រះអនាគាមិបុគ្គលលះកិលេសបានដោយឯកទេស គឺ
លះកិលេសបានជាចំណែក។ ដូចព្រះសោតាលះបានដែរ ។

សកវាទី - បើដូច្នោះ ទើបហៅថាឯកទេសអនាគាមី ហៅថាអនា
គាមីបានដែរឬទេ ?

បរវាទី - ន ហោតិ អ្នកកុំនិយាយយ៉ាងនោះ មិនគួរទេ ព្រះ
អនាគាមិបុគ្គលនោះ មិនមែនជាឯកទេសអនាគាមីទេ ។ ព្រះអនាគាមិ
បុគ្គល កាលមិនទាន់បានសម្រេចព្រះអរហត្ត កំពុងតាំងនៅក្នុងភូមិនៃព្រះ
សក្យាតានោះ រមែងធ្វើព្យាយាមដើម្បីទំលះបង់នូវកាមរាគៈ, ព្យាបាទ
ដោយឥតសេសសល់ ប្រកបនូវសេចក្តីព្យាយាមដើម្បីទំនងឲ្យដល់នូវព្រះ
អរិយភូមិជាគំរប់ប៊ី តែព្រះអនាគាមិចារណា សាចុះសាឡើងនូវបញ្ចសង្ខារ
ដោយព្រះវិត្តលក្ខណញ្ញាណវិបស្សនា កាលប្រតិបត្តិដូច្នេះ អនុលោម

គោត្រភូញ្ញាណ ពាំងឡាយកំបង្កើត ក្នុងកាលជាលំដាប់នៃគោត្រភូញ្ញាណ
នោះ ព្រះអនាគាមិមគ្គក៏បង្កើត ក្នុងលំដាប់នៃព្រះអនាគាមិមគ្គនោះ ផល
ចិត្តពាំងឡាយក៏បង្កើត លុះផលចិត្តពាំងឡាយបង្កើតហើយ ក៏ឋានឈ្មោះ
ជាព្រះអនាគាមិបុគ្គល ជាព្រះអរិយបុគ្គលគំរប់ប៊ី មិនចាប់ព្យាយាមដើម្បី
ឲ្យបានសម្រេចព្រះអនាគាមិផលទៀតទេ ។

អដ្ឋចត្តាឡីស បើទំនងចែកព្រះអនាគាមិបុគ្គលចេញទៅទៀត
មានដល់ ៤៨ ពួក គឺ ដើមជំបូងចាត់ជាដប់ប្រាំ (១៥) ជាអន្តរាភវនិព្វាយី
ប្រាំពីរ (៧) ជាឧបហច្চវនិព្វាយីមួយ (១) ជាឧទ្ធំសោតអកនិដ្ឋគាមី
មួយ (១) ហើយចែកចេញទៅជាអសង្ខារចនិព្វាយីប្រាំ (៥) តាំងអំពី
ជាន់ អវិហា អតប្បា សុទស្សា សុទស្សី ពាំងប្លួនជាន់នេះស្មើ
គ្នា ប៉ុន្តែជាន់អកនិដ្ឋនោះលើកឧទ្ធំសោតអកនិដ្ឋគាមីមួយពួកចេញ ព្រោះ
គ្មានកន្លែងជាន់អកនិដ្ឋទេ ។ ព្រះអនាគាមិបុគ្គលលះអកុសលចិត្តបានប្រាំ
មួយដូចគ្នា ឧបបាតិសោ អជាវត្តិធម្មោ ព្រះអនាគាមិបុគ្គលនោះ
លុះលះបង្អកុទ្ធច្ចកមនុស្សលោកហើយ រមែងទៅបង្កើតដោយអំណាច
នៃឧបបាតិកៈកំណើតក្នុងជាន់សុទ្ធាវាសពាំងប្រាំ លែងចុះមកកាន់មនុស្ស
លោកនេះទៀត អន្តរាភវនិព្វាយី ព្រះអនាគាមិបុគ្គលពួកណា
មិនទាន់ដល់ពាក់កណ្តាលអាយុបានកិលេសនិព្វាន ព្រះអនាគាមិបុគ្គល

ពួកនោះឈ្មោះថាអន្តរាភវនិព្វាយី ។

ព្រះអរិយបុគ្គលឈ្មោះអន្តរាភវនិព្វាយីនោះ ចែកចេញជាបីពួក ប្រាថ្នាដល់អនាគាមិបុគ្គលដែលតើតកន្លងជាន់អវិហា ទើបដល់នូវព្រះអរហត្តកន្លងទីនៃខ្លួនតើត បើមិនប្រាថ្នាដល់នូវព្រះអរហត្តកន្លងទីនៃខ្លួនតើតទេ តំបូលដល់កន្លងទីចុងផុតនៃអាយនៃកប្បជាបឋម យ៉ាងនេះឈ្មោះថាអន្តរាភវនិព្វាយីមួយពួក ។ ព្រះអនាគាមិបុគ្គលពួកដទៃមិនអាចដល់នូវព្រះអរហត្តដូច្នេះ ទើបដល់នូវព្រះអរហត្តកន្លងទីចុងផុតនៃពាក់កណ្តាលកប្ប តំណោះថាអន្តរាភវនិព្វាយីមួយពួក ទៅដល់អរហត្តកន្លងទីចុងផុតនៃបួនអាយកប្បមួយពួក តំណោះថាអន្តរាភវនិព្វាយីដូចគ្នា ។ ព្រះអនាគាមិបុគ្គលឈ្មោះថាអន្តរាភវនិព្វាយីនោះ មានប្រាកដដូចវិសជ្ជនាមកនេះ ។

បញ្ចសតកប្បា ឧបហច្ច ព្រះអនាគាមិបុគ្គលមិនបានកន្លងបង់នូវអាយនៃកប្បតម្រាំប្រាំ ទើបបានសម្រេចព្រះអរហត្តផាត់ឈ្មោះថាឧបហច្চបរិនិព្វាយី អ្នកប្រាជ្ញគប្បីប្រកបចិត្តដោយនិយាយដូច្នេះ តាំងអំពីជាន់អវិហាជាដើមទៅ ។

សសង្ខារបរិនិព្វាយីនោះ បានដល់ព្រះអនាគាមិបុគ្គលតើតកន្លងជាន់សុទ្ធាវាសណាមួយ ប្រកបសេចក្តីព្យាយាមដើម្បីឲ្យបានដល់ព្រះអរហត្តដោយលំបាក យ៉ាងនេះឈ្មោះថាសសង្ខារបរិនិព្វាយី ។

(នៅមានត)

មង្គុរសរិបាំណឹ

(តមក)

សម្តែងត្រៃធម្មលិខិត ល្អ-ឯម ប្រៃរៀបរៀង

ឯព្រះបច្ចេកពុទ្ធអង្គនោះ កំពុងតែធ្វើចីវរកម្មកំរិះសំពត់អនុវាត ប៉ះ ចីវរពុំគ្រប់គ្រាន់ ព្រះអង្គប្រារព្ធនឹងស្វែងរកសំពត់មកបំពេញថែមរៀត ឲ្យគ្រប់គ្រាន់ ។

កុដុម្ពីក៍ ឃានឃើញព្រះបច្ចេកពុទ្ធធ្វើអាការយ៉ាងដូច្នោះហើយ ក៏ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ! ព្រះអង្គមានកិច្ចអ្វី ? ព្រះ បច្ចេកពុទ្ធ ក៏លោកពុំបានតោលតបវិញដល់តិចតួចឡើយ ព្រោះព្រះអង្គ ជាអ្នកច្រើនថ្នាក់តិច ។ ឯកុដុម្ពីក៍សោត កាលបើព្រះបច្ចេកពុទ្ធពុំបានតោល តបដូច្នោះហើយ ក៏បានដឹងថា ច្រើនជាសំពត់ចីវរបស់ព្រះបច្ចេកពុទ្ធ នេះពុំគ្រប់គ្រាន់ ទើបយកសំពត់បង់ក្បេះរបស់ខ្លួន ទៅដំកល់ទុកទៀបព្រះ ឃានៃព្រះបច្ចេកពុទ្ធ ហើយដើរចៀសចេញទៅកន្លែកាលនោះឯង ។

ចំណែកឯព្រះបច្ចេកពុទ្ធ ក៏បានកាន់យកសំពត់សាដកនោះមកប៉ះ ថែមជាសំពត់អនុវាត បានដេរបួចស្រេចគ្រប់គ្រាន់ ពុំមានខ្វះខាតឡើយ ហើយជ្រលក់ប្រើច្រាស់ជាដកបៅ ។

កុដុម្ពីក៍នោះសោត កាលបើធ្វើមរណកាលអស់ជីវិតហើយ ក៏បាន

ឡើងទៅ កើតក្នុងស្ថានតាវតឹសពិភព សោយទិព្វសម្បត្តិ ដរាបដល់អស់អាយុ ហើយច្យុតមកកើតកង្វក់ត្រកូលមួយមានឧត្តមពុំប្រាកដ ក្នុងនគរជាខេដ្ឋក្រុងពារាណសី មានចម្ងាយប្រមាណជាមួយយោជន៍ប៉ុណ្ណោះ ។

ឯមាតាបិតា កំបានឲ្យឈ្មោះថា ឧទ្ទកុមារជាមង្គលសួស្តីដល់បុត្តនោះឯង ។

រីឯឧទ្ទកុមារនោះ មានបងប្អូនប្រុងមួយនាក់ ។ បងប្អូនតាំងប្រុងមួយនាក់នោះ កំពុងលំនាំយកក្នុងការងារផ្សេង ។ សឡាំបស់មកចំពោះមាតាបិតាអស់កាលជាទិច្ច ។

ចំណែកឯឧទ្ទកុមារ ឥតមានរវល់ធ្វើការងារអ្វីឡើយ តែងនៅតែក្នុងផ្ទះ ពុំបានយកចិត្តទុកដាក់ ប្រឹងខំធ្វើការងារពាំងនោះដល់តិចសោះ ។ ព្រោះហេតុដូច្នោះ បានជាបងប្អូនដ៏សេសគេប្រតង្គាំងខំធ្វើឧទ្ទកុមារតែម្នាក់ ។ គ្នា គេរិះគន់ថា ជាមនុស្សខ្ជិលឥតពិចារណា គេបានព្រមានដល់មាតាបិតាឲ្យប្រដៅផងខ្មៅ ។

ឯមាតាបិតា កំបានហៅឧទ្ទកុមារមកនិយាយឲ្យដំបូន្មានប្រៀនប្រដៅ ឲ្យចំយកចិត្តទុកដាក់ធ្វើការងារកុំឲ្យខ្ជិលច្រអូសតទៅទៀត ។

ឧទ្ទកុមារលុះបានស្តាប់ពាក្យប្រដៅមាតាបិតាហើយ កំធ្វើព្រងើយកន្តើយ ពុំស្តីនិយាយតបតថាអ្វីឡើយ នៅតែប្រព្រឹត្តដូចមុន តឹតឥត

មានធ្វើការងារអ្វីដល់តិចតួចសោះ, លុះដល់មកកាលជាខាងក្រោយទៀត
មានទុក្ខត្រូវឫក្សគឺកកង់ក្នុងស្រុកនោះឯង, ជនទាំងឡាយគេចប្លែងគ្នាស្លៀក
សំពត់ពាក់អាវស្អាងអាត្មាទៀត ។ ដើម្បីលេងទុក្ខត្រូវឫក្សក្នុងកាលនោះ ។

គ្រានោះ ខន្ធកុមារនិយាយទៅទូលមាតាថា: បពិត្រអ្នកមេដ៏មានគុណ ! សូមអ្នកមេឲ្យទានសំពត់សាដកមួយមកខ្ញុំ ។ ទូលស្លៀកគ្រាន់លេងទុក្ខត្រូវឫក្សទូលគេកកង់កាលឥឡូវនេះ ។

មាតាក៏បានយកសំពត់សាដកមួយ ដែលខ្លួនបានលាងស្អាតឲ្យទៅខន្ធកុមារជាបុត្រវេស់ខ្លួន ។ ឯខន្ធកុមារ កាលបើបានឃើញសំពត់នោះហើយ ក៏និយាយឃាត់មាតាថា: បពិត្រអ្នកមេ ! សំពត់នេះមានសាច់ក្រាសណាស់ ខ្ញុំពុំត្រូវការឡើយ សូមអ្នកមាតាឲ្យសំពត់យ៉ាងល្អដ៏មានសាច់ម៉ដ្ដដ៏ទៃមកខ្ញុំវិញ មាតាក៏យកសំពត់សាដកដ៏ទៃមកឲ្យទៀត ។

ខន្ធកុមារបានឃាត់ទៀត ពុំព្រមទទួលយកសំពត់សាដកដែលមាតាឲ្យនោះឡើយ ។ កាលនោះ មាតានិយាយទៅទូលខ្ញុំជាបុត្តវេស់ខ្លួនថា: ម្នាលកូនអើយ ! កន្ទបន្លះយើងនេះពុំមានសំពត់ណាដ៏ទៃក្រៅលើសសំពត់នេះឡើយ បើបុណ្យវេស់អ្នកមានតណ្ហាទូលបានសំពត់ល្អវិសេស ដ៏មានសាច់ម៉ដ្ដជាងសំពត់នេះដោយពិត ។

ឯខន្ធកុមារជាបុត្ត លុះបានស្តាប់ពាក្យមាតាហើយ ក៏និយាយតបវិញថា: បពិត្រអ្នកមេ ! បើដូច្នេះ ខ្ញុំទូលទៅសុំរកសំពត់សាដក

ដ៏មានសាច់ម៉ដ្ឋនោះ តាមទឹកថ្នែងដែលគួរបាន តាមបំណងរបស់ខ្ញុំ ។

មាតាបានស្តាប់ហើយ កំនិយាយផ្ងួនថែមទៀតថា: ម្នាលកូនសម្លាញ់អើយ ! ចិត្តមាតាដែលស្រឡាញ់កូនបានថា មានគ្រាន់ថ្នាចង់ឲ្យបានសោយភោជសម្បត្តិកន្លងនគរពាណសីទាំងអស់ កន្លងថ្ងៃនេះជាយ៉ាងក្រៃលែង ។

ឯទន្ធកុមារជាបុត្ត លុះបានស្តាប់ពាក្យមាតាពោលយ៉ាងនេះហើយ កំមានចិត្តត្រេកអរនន់ពេក មើលពោលតបថា: បពិត្រអ្នកមេ ! ពាក្យដែលអ្នកមេពោលមកនេះ ប្រពៃណាស់ ។ ហើយលើកដៃឡើងសំពះមាតា ដើរប្រទក្សិណបីជុំពោលលាថា: ខ្ញុំសូមលាអ្នកមេទៅហើយ សូមអ្នកមេស្ថិតនៅឲ្យបានសេចក្តីសុខសប្បាយចុះ និយាយលាស្រេចហើយ កំដើរចៀសចេញទៅកន្លងកាលនោះឯង ។

ចំណែកមាតា កំមានសេចក្តីរីករាយគិតថា កូនអាត្មានេះវាឆ្លងទៅណា វាឆ្លងទៅអង្គុយលេងកន្លងផ្ទះគេឯនេះខ្លះឯនោះខ្លះ ហើយវាឆ្លងត្រឡប់មកកាន់ផ្ទះនេះវិញ ដូចការពីមុន ។ តុំលែងឡើង ។

ចំណែកឯទន្ធកុមារវិញ្ញេសោត គឺបុណ្យដែលខ្លួនបានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធ ប៉ះធ្វើជាអនុភាពចាំរពៅអតីតជាតិនោះ ហាក់ដូចជាមានចិត្តគំនិតរំលឹកងាស់តឿនរឿយៗ កន្លងចិត្តកុមារនោះ ដែលចេញអំពីស្រុកសំដៅទៅកាន់នគរពាណសី ហើយនៅអាស្រ័យកន្លងផ្ទះនៃ

អាមាត្យម្នាក់ ឈ្មោះសេនតុត្តកដ៏ក្រែនោះឯង ។

ដល់ថ្ងៃមួយជាខាងក្រោយ នោរវេលាយប់ខន្ធកុមារនោះបានឱយយ
ចរបាទខ្លែការងារផ្សេង ។ ជាមួយនឹងសេនាតុត្ត លុះអង្គុយយូរទៅគំនាក
ដូចជេកលក់ ស្រាប់តែបានឃើញសុបិននិមិត្ត ហាក់ដូចពោះរៀនរបស់
ខ្លួនចេញអំពីមាត់ លៀនវែងផ្សាយទៅព័ទ្ធជុំវិញភ្នំតាំងអស់ ហើយចូល
មកខាងក្នុងពោះវិញ ។ លុះភ្ញាក់ឡើងគិតក៏យល់ច្បាស់ស្រែកសម្រែក
លាន់ឮខ្ទាំងក្នុងខណៈនោះឯង ។

គ្រានោះ សេនាតុត្តបានឮសំឡេងស្រែកហើយក៏សួរថា: ម្នាល
ខន្ធៈអ្នកឯងស្រែកថ្ងៃ ឮសំឡេងខ្ទាំងដល់ម្ល៉េះ ។

ខន្ធកុមារនោះក៏និយាយប្រាប់ថា: ខ្ញុំស្រែកនេះព្រោះខ្ញុំបានឃើញ
សុបិននិមិត្តប្លែកណាស់ ។

កាលបើសេនាតុត្តបានសួរសុបិននិមិត្តនោះហើយ ក៏និយាយប្រាប់
សព្វគ្រប់ តាមនិមិត្តដែលខ្លួនបានឃើញនោះឯង ។

កន្លងកាលនោះ សេនាតុត្តក៏បានសួររឿងសុបិននិមិត្តនោះ ចំពោះ
បរិព្វាជិកា ដែលជាអ្នកចូលមកកាន់ត្រកូលនៃខ្លួនថា: បពិត្រនាងជាម្ចាស់
ថាបើបុគ្គលណាន័មួយ បានឃើញនូវសុបិននិមិត្តដ៏ប្រាកដយ៉ាងនេះ
បុគ្គលនោះនឹងបានទទួលផលដូចម្តេច ? នឹងមានទោសដូចម្តេច ? ។

លុះនាងបរិព្វាជិកាបានស្តាប់ហើយ ក៏ទំនាយសុបិននិមិត្តនោះថា:

ម្ចាលសេនាតុត្ត បើស្ត្រីបានឃើញសុបិនទិមិត្តយ៉ាងនេះ នឹងបានទៅ
ហានន្តរ អភិសេកជាព្រះអគ្គមហេសីនៃព្រះពជារៀងថ្ងៃទី ៧ ដោយពិត,
ជាបើបុរសបានឃើញសុបិនទិមិត្តយ៉ាងនេះ នឹងបានជាស្តេចសោយភជ
សម្បត្តិក្នុងរៀងថ្ងៃទី ៧ ដូច្នោះដែរ ។

ឯសេនាតុត្ត កាលបើបានស្តាប់ទំនាយទិមិត្ត ដែលនាងបរិព្វាជិកា
ពាយនោះហើយ គិតគិតពិចារណាថា: អញនឹងធ្វើនន្ទកុមារនេះឲ្យជាញាតិ
របស់អញ លុះគិតដូច្នេះហើយ ក៏ហៅកូនស្រីទាំង ៧ នាក់ឲ្យចូលមក
ជិតហើយសួរតាមលំដាប់ថា: ម្ចាលនាងទាំងឡាយដ៏ចំរើន ! នាងចូល
ចិត្តនៅជាមួយ ក្នុងសំណាក់នន្ទនេះដែរឬដូចម្តេច ?

កូនស្រីទាំងនោះពុំបានទទួលយល់ស្របឡើយ ហើយពោលត្រម
ង់ថា: យើងទាំងឡាយ ពុំបានស្គាល់នន្ទនេះ ដែលជាអ្នកទើបមកពី
បម្ងាយថ្មីៗឡើយ មិនដឹងជាគាត់មានត្រកូលតូចធំឬស្ត្រ ឬអាក្រក់យ៉ាង
ណាៗទេ យើងទាំងឡាយនឹងនៅរួមជាមួយដូចម្តេចបាន ។

ឯសេនាតុត្ត បានស្តាប់ពាក្យកូនស្រីទាំង ៦ រូបនោះហើយ ក៏ហៅ
កូនស្រីបង្អួនពៅបង្អស់ មកសួរជាខាងក្រោយ កូនពៅនោះក៏ទទួល
ត្រមថា: ស្រេចលើលោកមាតាបិតាចុះ នឹងឲ្យខ្ញុំនៅជាមួយនឹងអ្នកណា
ខ្ញុំក៏ពុំបានទទឹងទាស់នូវពាក្យនៃមាតាបិតាឡើយ ។

(នៅមានត)

មហោសធជាតក

(តមក)

លោក អ៊ឹម-ភន បម្រងតាមសារស្ត្រាស្ងឹកវត

ព្រះពុទ្ធវង្ស គឹម-តូរ តាំងតាម

រីសិរីវឌ្ឍកសេដ្ឋីទូលវិញថា បពិត្រមហារាជអើយ រីមហោសធក្មេងក្លាត់ហោង, តាមប្រពៃនេះ ធ្លុំតែកូនទីកដោះនៅមាត់ឡើយកូរ៉ា ទំនងនៅបំរើព្រះអង្គស្មាម៉ាត់ក្តី ព្រះបាទអ្នកជាអម្ចាស់ម្តេចបាន កាលណារីមហោសធបំរើនធំឡើងហើយ តំណមមកនៅបំរើជាស្មាម៉ាត់ក្តីព្រះបាទអម្ចាស់នោះហោង ។ ស្តេចបន្ទូលថា ម្នាលសេដ្ឋី អំពីថ្ងៃនេះទៅ កុំបីព្រះស្តេចអាល័យចាមហោសធឡើយ, មហោសធនេះ ចូរឲ្យមកនៅជាកូនអញអំពីថ្ងៃនេះឯង, នាព្រះស្តេចនឹងចិញ្ចឹមកូនក្បាកូនព្រះស្តេចដូចម្តេចមិញ ក៏អញនឹងចិញ្ចឹមក្បាក្បាចាលកូនអញដូច្នោះឯងហោង ។ ស្តេចថាអម្បាលនោះហើយ ស្តេចឲ្យដំណើរសេដ្ឋីនោះថា ម្នាលសេដ្ឋី ចូរព្រះស្តេចទូលទៅហោង ។

សេដ្ឋីនោះ ថ្វាយបង្គំមហាសត្វនុបតែផ្តេកចៅអ្នកច្រាជ្រលើច្រែងចើចស្ងួន ឲ្យដំបូន្មានប្រដៅព្រះមហាសត្វថា ម្នាលកូនស្នងសំឡាញ់តេញ

ចិត្តអាតុកអើយ ចាហោងជាថ្មើមដង្កើមជាកែកអាតុក ហៃចាមហោសថ
កុំបីចាផ្ញើឲ្យយើងកំព្រាជាអ្នកឥតពំនាក់ឡើយ អំពីថ្ងៃនេះទៅ ចូរចា
ទស្សាបាំបំរើព្រះចាទអ្នកជាអម្ចាស់កុំប្រហែសឡើយ ។ ព្រះមហាសត្វ
អ្នកសំពះព្រះបិតាហើយថា បពិត្រអ្នកអាតុក កុំបីអ្នកគិតចារម្ភនឹងខ្ញុំឡើយ។
ព្រះមហាសត្វអ្នកឲ្យដំណើរព្រះបិតាទៅហោង ។

លំដាប់នោះ, ស្តេចបន្ទូលដល់ពួកអ្នកច្រាជ្ញថា ម្នាលចាមហោ-
សថចានឹងបំរើឯកូង ឬនឹងបំរើឯក្រៅ ។ ព្រះមហាសត្វអ្នកគិតថា អញ
មានបំរាំរបៃខ្លួន ដូច្នេះគួរអញបំរើឯក្រៅវិញចុះ ។ ទើបព្រះមហាសត្វ
ថា បពិត្រព្រះចាទអម្ចាស់អើយ អញខ្ញុំនឹងបំរើឯក្រៅវិញហោង ។

ឮដំណាលនោះ ស្តេចប្រើអ្នកផងឲ្យធ្វើថ្នូរគួរនឹងព្រះមហាសត្វទៅ
ហើយស្តេចប្រើឲ្យដាក់ស្បៀងឲ្យក្មេងអស់ពាំងមួយពាន់ជាដើម ប្រើឲ្យ
សព្វគ្រប់គ្រឿងប្រដាប់សម្រាប់អំពីសម័យថ្ងៃនោះរៀងទៅហោង ។ រី
ព្រះមហាសត្វសោត អ្នកតែងចុះគាល់ហ្លួងបំរើស្តេចពុំដែលដាច់ឡើយ ។

មានកាលសម័យថ្ងៃមួយ ស្តេចនឹងចង់ល្បងលនូវប្រាជ្ញានៃចាមហោ
សថអ្នកច្រាជ្ញ, ស្តេចគិតថា ម្នាលចាមហោសថអ្នកច្រាជ្ញអញឮថា អ្នក
មានច្រាជ្ញាឈ្លាសវៃគប្បីដោះអាថ៌ប្រស្នាពាំងពួង តែគឺមោះ រីអញពុំដែល
ចានយល់ឲ្យដាក់ប្លាស់ច្រាកដនឹងកែកអញឯង, អញនឹងល្បងចៅអ្នក

ប្រាជ្ញឲ្យប្រាកដនឹងភ្នែកអញឯង ។ ស្តេចតិតអម្បាលនោះហើយ ទើប
ប្រើកដអាមាត្យមួយឈ្មោះ (អនុជិត) ឲ្យយកកែវមណីរ័តន៍ឡើងទៅជាក់
ព្វដ៏សម្បុកភ្នែកមានលើពុនត្នោត ទៀបនឹងនេះស្រះមិនឆ្ងាយអំពីព្រះ
ឧតរទិសឯណ្ឌឯង ពុំឲ្យអ្នកផងដឹងដំណឡើយ លុះព្រះអាទិត្យរះត្រចះចាំងមកត្រូវ
កូរ៉ែស្រមោលមណីរ័តន៍នោះឆ្លុះយល់ប្រាកដនាក្នុងទឹកស្រះនោះ ។
រីអស់អ្នកផងយល់ហើយ សឹងទៅទូលស្តេចថា មណីរ័តន៍មាននៅក្នុង
ស្រះនោះ, ស្តេចបន្ទូលដណ្តឹងអាចារ្យសេនកថា ម្នាលអាចារ្យសេនក
អញឮថាមានមណីរ័តន៍នៅក្នុងស្រះ យើងនឹងយកមណីរ័តន៍នោះម្តេច
ហ៊ាន ? អាចារ្យសេនកទូលថា គួរតែប្បីយើងបង្ហិតទឹកចេញ ក៏ស្តេចបន្ទូល
ថា បើដូច្នោះអំពើពាំងពួនខេះទុកជាខមូន់នៅអាចារ្យ ចូរអាចារ្យធ្វើឲ្យបាន
ដូចតំនិតនោះហោង ។ រីអាចារ្យសេនកឲ្យដំទុំប្រជុំនូវមនុស្សផងច្រើន
ហើយឲ្យបង្ហិតទឹកចាកស់ចេញ ជីកដីកកាយរកពុំឃើលឡើយ ហើយ
បើកទឹកជាកវិញ ក៏ឃើលស្រមោលមណីរ័តន៍នោះវិញទៀត ។ រីអាចារ្យ
សេនកនោះឲ្យធ្វើព្រួលទល់ ហើយឲ្យបង្ហិតទឹកចេញវិញ នោះក៏មិនឃើល
មណីរ័តន៍ឡើយ ។

លំដាប់នោះ, ស្តេចបន្ទូលនឹងពៅអ្នកប្រាជ្ញថាដូច្នេះ ម្នាលចុមហោ-
សថ មានមណីរ័តន៍មួយឃើលប្រាកដក្នុងស្រះ ។ រីអាចារ្យសេនកឲ្យ

បង្គំតទឹកថ្វាយគេក់ចេញ កាប់ដីកកាយរកកំពុយល់មណីរ័តន៍នោះ លុះបង្គំតទឹកខ្លួលវិញ ចំយើញវិញទៀតជាដែល ។ ម្នាលថ្មមហោសថអ្នកច្រាំជ្ញ ថ្វាអាចយកមណីរ័តន៍នោះថ្វាយបានឬទេហ៊ីន? ព្រះមហាសត្វខ្លួលថា បពិត្រមហាក្ស រ័អំពើនឹងយកមណីរ័តន៍នោះមិនជាខម្ងន់ក្រទ្បើយ អញនឹងយកថ្វាយបង្ហាញព្រះថ្វាអម្ចាស់ហោង ។ ស្តេចមានព្រះហឫទ័យត្រេកអរថា អញនឹងបានមើលតំឡុងនឹងច្រាំជ្ញាថៅអ្នកច្រាំជ្ញឥឡូវនេះ ។ ស្តេចលាយាត្រាចេញអំពីព្រះរាជមន្ទីរ មានមហាជនផងច្រើនជាបរិវារ ស្តេចត្រអាលចេញទៅតង់ខៀបនេះស្រះនោះ, រឯព្រះមហាសត្វអ្នកឈរនៅឰដ្ឋល់ស្រះនោះ ហើយអ្នកមើលមើលមណីរ័តន៍ដឹងថា មណីរ័តន៍មាននាឫនគ្មានោះហោងមិនខេទ្បើយ, អ្នកដឹងដូច្នោះហើយ អ្នកខ្លួលថា បពិត្រមហាក្ស រ័មណីរ័តន៍មិនអង្គឹមានក្នងស្រះនោះខេ, ស្តេចថា ម្នាលថ្មអ្នកច្រាំជ្ញ ថ្វាថាមិនយល់មណីរ័តន៍ក្នងស្រះនេះ ម្តេចកឹថ្វាថាដូច្នោះហ៊ីន ? ព្រះមហាសត្វអ្នកថា បពិត្រមហាក្ស ថ្វាបើអម្ចាស់មិនជឿពាក្យខ្ញុំដូច្នោះ ចូរអម្ចាស់ទតហោង ។ ទើបអ្នកយកទឹកដាក់នឹងភាជន៍មួយមកដំកល់ហើយ អ្នកខ្លួលថា បពិត្រមហាក្ស ចូរអម្ចាស់ទតស្រមោលមណីរ័តន៍ក្នងស្រះឯងឦក្តី ក្នងទឹកភាជន៍នេះក្តី ? ក៏យល់ច្រាកក្ស ហោង ។ ស្តេចបន្ទូលថា ម្នាលថ្មមហោសថអ្នកច្រាំជ្ញម៉ែយ មើ

ដូច្នោះតើមណីរ័តន៍នោះនៅឯណា ? ព្រះមហាសត្វថា បពិត្រមហាជ
សូមឰក្ខ័ស្រះក្តី ក្ខ័ទឹកកាជន៍ក្តី កំយល់តែស្រមោលខ្លួនវិញ រីឯតួមណី-
រ័តន៍ឥតអន្តីមានឰដ៏ហានេះទេ មហាជ, រមណីរ័តន៍នេះ ទីដ៏មានឱកឰ
សម្បុកក្អែកឰដ៏ចុងត្នោតនោះវិញ, អ្នកថាអម្បាលនោះហើយអ្នកប្រើប្រុស
មួយឲ្យទៅដឹងយកមណីរ័តន៍នោះមក ។ ស្តេចបន្ទូលថាឲ្យយកមកទំនឹង
មើល ។ ព្រះមហាសត្វអ្នកយកមណីរ័តន៍នោះមកថ្វាយ ។ ស្តេច
ខ្ជួលយកមណីរ័តន៍នោះមកដំកល់ជាក់ឰដ៏ចំពាតព្រះហស្ត ។ រីអស់ពួក
មហាជនឥតឰតាំងឰាយ សឹងដឹងត្រេកអរឲ្យសព្វសាធុការដល់ចៅអ្នកប្រាជ្ញ
ហើយកំដរត្មេះតិះដៀលអាចារ្យសេនកថា មណីរ័តន៍មានឱកឰដ៏ត្នោត
ឯណោះ រីឯអាចារ្យសេនកកញ្ជោតមិញ ឲ្យបរហ៍ពលច្រើនទៅ
បើកចំណាយឯស្រះវិញ ហ៎ះ, ហើយមកស្រដីសរសើរព្រះមហាសត្វថា
តាប៉ាហៅថាអ្នកប្រាជ្ញឲ្យដូចចៅមហាសត្វនេះ ទើបហៅថាអ្នកប្រាជ្ញ
ប្រសើរហោង ។

រីព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យត្រេកអរសាទរ ឰង់
ព្រះកុណាព្រះមហាសត្វនោះក្រៃពេក ហើយស្តេចដោះមុក្តាហារត្រ-
ណោតមកជាគ្រឿងប្រដាប់សំពាប់ព្រះសូរ៍ព្រះអង្គឯង ព្រះរាជទានឲ្យ
ទៅចៅមហាសត្វអ្នកប្រាជ្ញ ហើយស្តេចឲ្យដោះកង់មុក្តាទៅឲ្យក្មេង

សំពត់ព្រះមហាសថពាំនមួយភាន់នោះ ស្តេចទ្រង់ព្រះករុណាចេក ព្រះមហាសត្វក្តី ក្មេងជាងវាក្តី ឲ្យឡើងចុះគាល់ហ្អា ឲ្យបំរើជាបរិពារ តាមពាក្យសច្ចានេះហាន ។

ឯក្នុងវិសតិបញ្ញា ឯដ្ឋតោ ។ តែការល្បងអាចប្រស្នាមែកខ្ទុះ១ មានល្បងសាច់ជាដើម ស្រេចមកដល់ល្បងតែវ ត្រូវជា ១៩ គ្រប់បរិបូណ៌ ហោង ។

បុនេកទិវសំ មានកាលសម័យថ្ងៃមួយវិញទៀត, ព្រះបាទ វិទេហរាជ ស្តេចទៅប្រពាតទ្យាន ខ្ចូវចៅមហាសថអ្នកប្រាជ្ញ ។ ឮដំ កាលនោះ មានសត្វបង្កួយមួយអាស្រ័យនៅលើពុងតោរណៈ (ខ្ទោងទ្វារ) បង្កួយនោះយល់ព្រះបាទវិទេហរាជ ស្តេចមកខ្ចូវយសបរិពារច្រើន ។ រី បង្កួយនោះ មានចិត្តកោតខ្ចាចខ្ចូវអំណាចស្តេច ហើយគិតថា អញនេះ ពុំគួរនៅលើហានខ្ពស់ដូច្នេះសោះ បង្កួយនោះលោតចុះមកអំពីពុងតោរណៈ ហើយក្រាបនៅជ្រុំថ្នល់ ស្តេចទតឃើញខ្ចូវអំពើបង្កួយនោះ ស្តេចដណ្តឹងថា ម្នាលចៅអ្នកប្រាជ្ញ បង្កួយនេះ ធ្វើខ្ចូវអំពើអ្វីដូច្នេះហ៊ឺន ? ទើបព្រះមហា សត្វថា បពិត្រមហារាជ រីបង្កួយនេះ វាចុះមកគាល់ព្រះអង្គព្រះបាទ អម្ចាស់ ។ ស្តេចថា ម្នាលចៅអ្នកប្រាជ្ញ ថាចើវាមកគាល់ហ្អាដូច្នេះ ពិត តែកុំថាឲ្យវាឥតប្រយោជន៍ឡើយ ចូរបាទឲ្យសម្បត្តិវាហោង ។

ព្រះមហាសត្វទូលថា បពិត្រមហាភាគ វ័ន្ទិនឲ្យសម្បត្តិទ្រព្យធនអង្គឹមាន
ទំនងវាជាបង្ហិយនោះឡើយ ឲ្យតែចំណីចំណុកតួនេងវាហោង ។ ព្រះ
មហាសត្វថា បពិត្រមហាភាគ អម្ចាស់ឲ្យគានចំណីវាហោង ។ ស្តេចថា
វាធ្វើអ្វី ? ព្រះមហាសត្វថា អម្ចាស់វាធ្វើសាច់, ស្តេចថា សាច់ប៉ុន្មានតួ
នេងវា ? ព្រះមហាសត្វថា បពិត្រមហាភាគ តួតែសាច់មួយចម្លៀ
ក្អែកហោង ។ ព្រះបាទវិទេហភាគ ស្តេចបង្គាប់បុរសមួយថា នាម
ហៅអំណាយតែមួយចម្លៀក្អែកដូច្នោះមិនគួរឡើយ ម្ល៉ោះហើយស្តេចគ៌
ឲ្យមាសកន្ធាស់សណ្តែកជាមួយក្រាមថា ចូរអាយកទៅទិញដូរសាច់ឲ្យ
បង្ហិយនេះវាធ្វើសព្វ។ ថ្លៃគុំបីជាច់ឡើយ ។ រីបុរសនោះទទួលព្រះបន្ទូល
ថា សាធុ ! គាច់ហោង ។ អំពីថ្ងៃនោះទៅ បុរសនោះតែងទៅទិញ
សាច់អំពីផ្សារ ឲ្យជាចំណីបង្ហិយនោះជាប្រក្រតីពុំដែលជាច់ឡើយ ។
មានកាលសម័យថ្ងៃមួយ ជាថ្ងៃឧបោសថសីល អ្នកផងមិនសម្លាប់សត្វ
លក់ឡើយ, បុរសនោះនឹងទៅរកទិញសាច់ជាចំណីបង្ហិយពុំបានឡើយ
ហើយបុរសនោះគិតនឹងយកមាសកន្ធាស់សណ្តែកនោះ មកជាដោតឲ្យ
ធ្វើជាគ្រឿងប្រដាប់បំពាក់ខ្លួកបង្ហិយនោះ, ដ្បិតបុរសនោះគិតក្រែងបង្ហិយ
នោះវាខឹង ដ្បិតពុំបានឲ្យចំណីវាធ៌ ហើយបុរសនោះយកមាសបង្គ៌ក
បង្ហិយសោះវាខឹងរត់ចាត់នោះហោង ។ អំពីគាលបុរសនោះ យកមាស

មកធ្វើជាគ្រឿងប្រដាប់នោះមិញ រីបង្គុយនោះអាស្រ័យទឹងមាសជាគ្រឿងប្រដាប់ កំមានះកើតខ្លើងអំពីកាលនោះហោង ។

មានកាលសម័យថ្ងៃមួយនោះឯង ស្តេចទៅលេងនាឧទ្យាន ខ្លួរចៅអ្នកប្រាជ្ញ បង្គុយនោះយល់ស្តេចមកដូច្នោះក្បូរ ក្តីនោះកើតមានៈ ហេតុពីងមាសមួយក្រមនោះហោង កំធ្វើដំកើងអាត្មាផ្ទឹមមួយអន្ទើនឹងស្តេច គិតកង់ចិត្តឯងថា នាស្តេចរិះខហាជអ្នកមានទ្រព្យច្រើន ឬអញនេះមានទ្រព្យច្រើន ? រីបង្គុយនោះគិតដូច្នោះហើយ មិនចុះមកឡើយ ប្រឹងប្រែងពួតភ្លើងដំកើងអាត្មា អង្រួនក្បាលនៅលើចុងគោរណៈនោះហោង, រីឯព្រះបាទរិះខហាជ ស្តេចរមិលមើលបង្គុយនោះ ហើយមានព្រះបន្ទូលដណ្តឹងព្រះមហាសត្វថា ម្នាលជាមហោសថ រីបង្គុយនេះយល់មិនដូចអំពីមុនហ៎ៈ ? ឥឡូវនេះ ហេតុអ្វីក៏មិនចុះមករកស្តេចហើយដណ្តឹងជាគាថាដូច្នេះថា :

ជាយំ បុរេ ខុណ្ណាមតិ គោរណាក្តេ កកកណ្ឋាកោ
មហោសធ វិជានាតិ កេន ន ភុក្ខោ កកកណ្ឋាកោ ។

សេចក្តីថាៈ ម្នាលជាមហោសថអើយ, រីបង្គុយនេះមិនចុះមកអំពីចុងគោរណៈឡើយ ងក់ក្បាល ពួតភ្លើង ដំកើងអាត្មាត្រើយទៅវិញ; មហោសថអើយ បង្គុយនេះមិញ ខ្វៃប្រជារឹងត្អឹងដូច្នេះ ហេតុអ្វី? ចូរជ្រាបដឹងហេតុនោះហោង ។

លំដាប់នោះ, ហៅអ្នកច្រូតស្មៅមកហើយ កំដរដោយនូវច្រូតស្មៅ អធ្យាស្រ័យទូលថា បពិត្រមហាវេស្សវណ៍ រីឯបុរសដែលព្រះបាទអង្គាស់ឱ្យចិញ្ចឹមបង្ហើយនេះ នាអំពីមុនលិមិញជាថ្ងៃទោសថ្លើម ជ្រុតឥតគេសម្លាប់សត្វកំបុរសនោះរកញ៉ាំមិនបានសាច់ឱ្យបង្ហើយឆ្ងើយ, កំបុរសនោះយកមាសមួយក្រាមដង្ហែមកនោះមិញ មកដោតខ្សែព្រួរកបង្ហើយនោះ ហេតុតែវាបានមាសមួយក្រាមនោះហាន វាប្រែជារឹងត្អឹងវិញ ព្រះមហាសត្វស្រដីទូលស្តេចជាគាថាដូច្នេះវិញទៀតថា :

អលទ្ធបុព្ពំ លទ្ធាន អគ្ឃមាសកំ កកណ្ហាកោ
អតិមញ្ញតិ រាជានំ វេទេហំ មិថិលគ្គហំ ។

បពិត្រមហាវេស្សវណ៍ រីឯបង្ហើយនេះ អំពីមុនមកវាមិនដែលបានមាសកំសព្វវារនេះ ល្មើកវាមកបានមាសមួយក្រាម ក៏វាមើលងាយព្រះបាទអង្គាស់ជាំងព្រះមហាក្សត្រនៃកជ ជាមានច្រកន្លង់ច្រាសាខធំបិតព្ងដីតណ្ដាលមិថិលមហានគរ ដ៏រុងរឿងល្អ, ហេតុវាគិតដូច្នេះថា ព្រះបាទវិទេហរាជនោះមានទ្រព្យច្រើន, អញសោតក៏មានទ្រព្យច្រើន ។

ឮដំណាលនោះ ស្តេចឱ្យហៅបុរសរក្សាបង្ហើយនោះមកដណ្តឹងសួរ ។ បុរសនោះទូលដោយនូវពាក្យពិត ។ ព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យជ្រះថ្លាក្រៃឮដំព្រះមហាសត្វ ហើយបន្ទូលសរសើរថា

អ្នកប្រាជ្ញថា ចូមហោសថអ្នកប្រាជ្ញនេះ ពុំបានដឹងមុនដល់តែច កំស្រាប់តែមកដឹងអធ្យាស្រ័យចំគួបច្ឆិយនេះ ហាក់ដូចប្រាជ្ញា សតិជ្ញាណហោង ហើយស្តេចបើកស្រុកឲ្យដឹកាំគាំង ៤ បួយ សឹងមានសួយរៃងារភ្លោនៃព្រះពោធិសត្វនាគាលនោះហោង ។ ព្រះមហាក្សត្រ ស្តេចទ្រង់ញាល់ទឹងបច្ឆិយនោះ ឆ្ពោះពោសទឹងឲ្យក្រយែជីវិតនោះ ។ ព្រះមហាសត្វអ្នកទូលឃាត់ថា បពិត្រក្សត្រថ្លៃប្រសើរអើយ នាសត្វបច្ឆិយតែបានេះ មិនគួរគេប្លឹព្រះអង្គឧទឹងឲ្យធ្វើពោសឡើយ សូមព្រះអង្គអត់ពោសនៃសត្វបច្ឆិយនេះ ។ រីព្រះមហាក្សត្រាធិរាជ ក៏ទន់យកទូវាក្យព្រះមហាសេច ហើយក៏ស្តេចអត់ពោសបច្ឆិយនោះ ស្តេចឲ្យស្រាយយកមាសអំពីក ហើយលែងបច្ឆិយនោះចេញទៅហោង ។

កកណ្ឋកបញ្ហោ ឯដ្ឋិតោ ។ បពិត្រអើយ, រឿងស្រដីនាថ្ងៃប្រស្នាបច្ឆិយនេះមិញ ជាសុរេចទូវប្រកាអម្បាលនេះឯងហោង។

អថេកោ មិថិលាសិ បិង្គុត្តរោ ជាម មាណវោ តក្កសីលំ តទ្ធា ឯសាទាមោក្ខសុ អាចរិយសុ សន្តិកេ សិប្បំ សិក្ខន្តោ ទិប្បមេវ សិក្ខតិ ។

បពិត្រអើយ, កាលនោះ មានបុរសមួយនៅកំឡុងកងស្រុកមិថិលាមហានគរ ឈ្មោះបិង្គុត្តរមាណព ។ នោះឯង, ប្រាសលះលែងស្មែងទៅ

រៀនសិល្បៈមន្តអាគម ឯស្រុកតក្កសីលាមហានគរអំពីបុរាណ ក្នុងសំណាក់អាចារ្យទិសាបាមោក្ខព្រាហ្មណ៍ បង្គំគុរុមាណពនោះឯង រៀនសិល្បៈសាស្ត្រឈ្មោះសសត្ថគ្រប់ចប់ស្រេចហើយ បង្គំគុរុមាណពយកវង្វាន់មានរៀនព្យាប្រជាប់ប្រជាគ្រប់ស្រេចហើយ ទើបលាគ្រូអាចារ្យទៅលំនៅអាត្មា ។ បពិត្រអើយ ក្នុងណានោះ រ័ទិសាបាមោក្ខាចារ្យបណ្តាលឲ្យចិត្តគិតថា រីឯពិជវណីសាស្ត្រគ្រូអាចារ្យយើងនេះ បើមានកូនប្រុសឯង គ្មានកូនប្រុសឡើយ មានតែកូនស្រីនោះ គប្បីទើបរៀបធ្វើអាពាហ៍ពិពាហ៍ផ្សំឲ្យជាប្រពន្ធសិស្សជាចម្បងនោះឯងហោង ។ បពិត្រអើយ រីអាចារ្យទិសាបាមោក្ខមិញ គាត់មានកូនក្រមុំមួយ (ឈ្មោះនាងកុមារី) ប្រកបទ្យូរូបនោះដ៏ច្រើនឥតលក្ខណាល្អអស់ពាំនាំពួន ម៉ាដូចស្រីសួគ៌ មុខគួរតែចង់ពិតពិលរមិលមើល ។

អថ ខំ អាចរិយោ ឥតរំ តេ តាត ឧស្សាមិ តំ អាធាយ កមិស្សសីតិ អាហ ។ លំដាប់នោះ រ័ទិសាបាមោក្ខាចារ្យ ត្រអាលឮវាក្យមេត្រីស្រដីទៅនឹង បង្គំគុរុមាណពនោះថា ម្នាលបង្គំគុរុមាណពអើយ រីឯងឯងជាសិស្សឲ្យនឹងអញហោង, អញនឹងយកកូនក្រមុំផ្សំជាប្រពន្ធនៃឯង កំបីរឯងធ្វើដោយឮវាក្យអញហោង ។

(នៅមានត)

រឿងមរណមាតា

(តមក)

បើចាកទ្រាយ ញាន់លងទំលាយ នគរម៉ាទ្រ្ត ព្រះនាត
ត្រូចាន់ កែកមាន់កាមកេ កំសួលអន្តេយ៍ អ្នកនៅខាងក្រាយ ។
ចេកខុំចេកខេស កំរើតខាងកែស ខាងកូរសណ្តាយ សណ្តែក
ត្នងក្តុំ ចំព្រំទឹកជ្រាយ ប្រមាត់ខ្លាខ្លាយ ក្រូចក្រាយរមាស ។ ដំរីជ្រាំ
ដក ប្រមាត់ចចក តន្ត្រែងទ្រៀកទ្រាស ទំលាយស្នងស្មៅ ពកខ្លូ
ចេកមាស ក្បាលពុយអង្កា- ដំដង្កៀបក្តាម ។ ត្បាល់ដែកអង្រែ-
ដែកដើមជ្រៃជ្រែ ប្រគាលប្រគាម ពពេចចង្ក្រា ក្តុលក្តារស្លាត្រាម
ចំរូងព្រះពម ព្រះរំកែដែកស ។ កែកខ្នាស្លាកែត ថ្លើមថ្មអណ្តែត
ចេសចុងអង្គរ ក្រចកអណ្តើក កំរើកតម្រ ជាក់ដើមសំណ
សំណាកតាងាង ។ កំទេចពពេល ពពុះទឹកសែល ចង្កឹមស្ពារ
ខាង ក្រចកក្រៀលក្រ ដកពត្រះណាង ត្រាលថ្ងៃមខាង- ខ្លួនខ្លូ
សត្វា ។ ស្តុកស្តុះស្តើស្តៅ ឈើកែសតាត្រៅ តន្ទុងអាចម៍ខ្លា
ត្រចុកត្រចៀង កណ្តៀងឈាមក្រា រំដេងក្រោះស្ងួ ព្រះស្ងួត

តាខ្មៅ ។ អណ្តាតត្រកួត ដំរីចង់ចូត ស្រឡូកស្រឡៅ សម្បក
ពពេច កំរេចឈើខ្មៅ គោមួយប្រឡៅ អំពិលពោធ៍ចាយ ។
ឯឈើគ្រឿងទេស ថ្នាំពិត្យវិសេស វិសាលឆើតឆាយ បើមានរោគ
គ្រាំគ្រាក្នុងកាយ យកឈើទាំងឡាយ ផ្សំតាមតម្រា ។ ស្មៅផើកជា
សះ ជួរខ្លួនល្អណាស់ ចូលថ្នាយណាស់ណា ពោះកូនប្រដិត
រឹងរឹតកាយា រាក់ឆ្នេញក្តីណា ថ្នាសជូនវិលមុខ ។ ក្អកក្អួតរបង
ខ្សោះខ្សាចសម្ងួន កូនហល់ខ្លាំងពុក ចុះពកមួលសាញ អង្ហាញ
អង្ហក់ អង្ហង់តំលក់ ប្រមេះខឹកថ្នាយ ។ គ្រុនស្រែវញាក់
ញាប់ ប្រមេះមានគ្រាប់ ឃ្លង់ស្រែងទាំងឡាយ ដំរៅពកពួច
ថ្នាំរូចខ្មោចព្រាយ អាបចូលកយមាយ សន្ធំថ្នាត់មាត់ ។
យកដើមប្រចាក់ ស្វឹកមួយមកជាក់ ខ្មោចស្តុះរត់ថ្នាត់ ក្រែកឡើង
ពារស៊ី ជម្ងឺក្តាយខ្លាត់ ពេគាក៏ថ្នាត់ អាយុយឺនក្រៃ ។

ព្រះបទុមវង្ស កាលព្រះអង្គទ្រង់ រៀនសិល្បសាស្ត្រសៃយ រៀន
ចប់ត្រៃវេទ សាស្ត្រាសេដ្ឋាចប់រៃ ឥសីសិលក្រៃ ប្រជៀបានបទ ។
ក្សត្រខ្មាតគុណហារ ថ្នាំរោគតម្រា ចេះហ្មាត់ប្រាកដ ប្រពាលគជ់តន់
ព្រះអង្គចេះហ្មត់ ថ្នារតបៀមអត់ – ថ្នាយថ្នាខដប់ថ្ងៃ ។ សត្វសិល្ប
សាស្ត្រា សក្តិសិទ្ធិក្បៀក្បា លើសលោកតពក្រៃ ព្រះអង្គប្រាប់ថ្នាំ ខ្លះ

ចាំអារក្ខ ឃកមកសំពៃ បំរុងអាត្មា ។ អស់ពលទាំងឡាយ ដើរលេង
សប្បាយ ស្គប់ស្គល់ចិត្តា ស្រេចហើយប្រៀបប្រុង រៀបរង់ក្សត្រា ទុក
ស្បៀងអាហារ គ្រុបក្រុមទៃ ។ ពួកនាយដំរី រៀបរង់ហត្ថី គ្រឿងគ្រប់
ប្រពៃ ពួកនាយរថា អាសាអាជានេយ្យ រៀបរថពិដ័យ ចងគ្រឿង
រចនា ។ នាយសេះចងអាន ចងគ្រឿងគ្រប់ប្រាណ សំដែរត្នោរា ពល
ថ្មើរជើងជាតិ រៀបស្អាតកាយា ទំពាស្បៀងអាហារ រៀបរង់គ្រប់
ប្រាណ ។ រវេះដឹកស្បៀង ដឹកគ្រឿងរៀបរៀង រៀបរង់ក្សត្រក្សាន្ត
រវេះព្រះសោយ រៀបជោយពួកចាន ក្រវើនគ្រប់ប្រាណ គ្រប់តួគ្រប់
គ្នា ។ ដំរីទំាំង ចងគ្រឿងគ្រប់ទំាង ប្រដាប់រចនា ក្សត្រក្សាប់ធ្នុះផ្ទេក
ល្អឯកជ្រះថ្លា ចាំងវែងសុរិយា ព្រាក ។ រស្មី ។ ព្រះពជយាន កើយ
កែវស្បែកាន្ត រៀបរង់ចក្រ ព្រះភូសំមូលភ្នំ អភិមេរង្សី គ្រប់ក្រុម
សេនីយ រៀបចូលប្រុងប្រាណ ។ ព្រះមហាក្សត្រថ្កៅ ប្រពាតព្រឹក្សព្រៃ
សប្បាយក្សេមក្សាន្ត ចានមួយទៃតត់ កំណត់ប្រមាណ ស្តេចលើកពាហាន
ចូលក្រុងភាព ។ ពួកពលពាហាន ចានដល់ទីហាន ឃើញបុត្រកំយោ
សួរញាតិសន្តាន ត្រឿងលានគ្រប់គ្នា រៀបតំស្តុជាជា ចងដៃត្រែកអរ ។
សេនាមន្ត្រី រាំហក្សត្រធិបតី ចូលកន្លងនគរ នាហ្នឹងកន្លងកំផង តាំងគ្រឿងបវរ
ខ្ពួលស្តេចបវរ ចូលកំងរចនា ។ សម្តេចក្សត្រី អាយិកគ្គមហេសី មរណ-

ម្ចាស់ ដល់ស្រេចហើយទាន យាសយាងយាត្រា ទៅក្រាយឆ្នាំ
សុរិណ្ណភជព្រឹក្ស ។ ខ្ញុំនឮបក្សីផ្សា គោជនវាក ជួនចន្ទន៍ទ្វីគ-អប់
ក្រអូបសាយ នាងថ្នាយភជព្រឹក្ស ស្រេចហើយស្រោចទឹក ក្រអូប
ភ្ញុនសាយ ។ ស្រេចហើយព្រះទាន រៃលវិញចំការ ឡើងប្រាង្គរតែក
ឆាយ ខ្ញុំនណាងថាស់ខ្ញុំ ស្ដេចស្នំអគ្រយោយ ឡើងគាល់រៀងពយ សាក
ស្ងួរសន្ធូរ ។ ស្ងួរសត្វខ្លែសោក ជរាបដល់មក ប្លួលក្រុងភាព នាង
សោតរៀបពប់ សាសត្វនានា អគ្រយោយស្រឡាំង ស្ពាប់ហើយ
ឡឹកឡួល ។ សង្វែគអនិច្ច អាណិតធ័តា ឧពអន់ឆួល អន់អាក់អា
ណិត កងចិត្តរំដួល ដង្ហើមខ្សឹកខ្សួល ដោរដលនគ្រ ។ ស្រេច
ហើយដូតមុខ កំសាន្តះសាកខ្ញុំ រកវៀចឧជា- រសតែងព្រះស្ងោយ
ថ្វាយដោយមុខរ៉ាវ រៀបថ្វាយពាជា ឧត្តមហេស៊ី ។ ហើយគន់
មើលអង្គ ល្អស្អុះត្រចង់ ដួងកត្តិ៍ឋិមប្រើយ ឆើតឆាយលើសមុខ
ពាន់គុណទៀតខ្លី មើលក្មេងស្មោតើ ពុំដឹងអត្ថា ។ ខ្ញុះថាម្ចាស់យើង
ល្អប្លែកថ្កល់ថ្កើង ដូចស្រីទេព្តា មើលហើយមើលទៀត មិនឆ្អែតនេត្រ
ស្ងំខ្ញុះលួចថា អម្ចាស់មានបុណ្យ ។ ទ្រង់សោយថ្នាំអ្វី ប្រកបសិរី ព្រះ
អង្គលើសមុខ នាងប្រាប់តបការ សត្វសារៈតីគុណ ថ្នាំពិព្វលើសលន់
ពុំមានមុសា ។ អស់ស្នំគាំងឡាយ ស្រឡាំងអគ្រយោយ ឋានស្ពាប់ធ័តា

សព្វគ្រប់សេចក្តី ឥតប៉ាសង្ឃា សរសើរពាសទា ក្សត្រ័កល្យាណ ។ នាហ៊ីនតូចធំ ឡើងគាល់ដួចដុំ ខ្លួសម្ភរស្មោះស្មាន ហើយថ្វាយកសុំ ការ ពស្ត្រគ្រប់ប្រាណ ថ្វាយទាងកល្យាណ ច្រើនឥតទប់មា ។ ខ្លះថ្វាយប្រាក់មាស ក្បួងកែវពេញពាស គោសេយ្យគោសា ទុម្មរត្តែ ឱលផាត់ផ្ទុះជ្ជា លូកករហត្ថា ជញ្ជាត់ត្រលឹង ។ ក្មេងជូរ្យដន្ត្រី ត្រែស័ង្ខ ខ្លុយប៉ី សូរសព្ទទ្រហឹង ថ្វាយជ័យមង្គល សកលអ៊ឹងអ៊ឹង ស្រែចហើយ វិលវែង ហានត្រប់អាត្ម ។ ព្រះចុងមៃល ធម្មកជថ្លើងថ្កល់ បរមក្សត្រ នៃបទឹងមហេស៊ី សិរីសេដ្ឋ ក្សេមក្សាន្តសុខ មនោរមេ ។ ទើបស្តេចប្រទាន ប្រាសាទមាសមាន រូតរ៉ែតហានេ ព្រះបទុមវង្ស ស្តេចតង់ស្ងួនស្នេហ៍ ប្រទានតលរេហ៍ ចំរើបុត្រា ។ រីទុមន្ត្រី ស្អុះស្អុបថ្លើម-ប្រើយ សុទ្ធសឹងកញ្ជ្រោ ប្រាំរយស្មើតស្មង់ ត្រប់ទាងធីតា ចំរើបុត្រា សព្វថ្ងៃប្រក្រតី ។ ក្មេងប្រុសមួយតាន់ ឡើងគាល់តាប់តាន់ ក្មេងជូរ្យដន្ត្រី តីលៀងរមេំ ដួចដុំប្រក្រតី អស់ទាំងមន្ត្រី ឡើងគាល់បុត្រា ។ ព្រះបទុមវង្ស ថ្កល់ថ្កើងទ្រើសទ្រង់ រឹតរឹងក្លៀវក្លា ព្រះបិតាទ្រង់ ថ្នមបុត្រថ្ងៃថ្នា មិនឲ្យបុត្រា អន់គាក់ព្រះទ័យ ។ ឯទាង ធីតា ទាំកដបុត្រា ឡើងគាល់ក្សត្រថ្ងៃ ឯព្រះពជបុត្រ បរិសុទ្ធប្រពៃ គាល់មាតាថ្ងៃ តាមក្រឹត្យក្សត្រា ។ សម្តេចមហេស៊ី បរមក្សត្រី

នាងទ្រង់ចំណាំ តិតគុណកណ្តុរ រឹមលង្ហែថ្វាយ លុះនាងយាត្រា ទៅដែន
គាល់ស្វាមី ។ នាងទូលរៀបរាប់ សេចក្តីសាសត្វ កាលជាបក្សី ចាន
ស្តេចកណ្តុរ យង់យល់មេត្រី មេត្តាប្រណី ចានសង្រ្គោះ ។ ឥឡូវ
ខ្ញុំសុំ ពរក្សត្រទុត្តម សូមទ្រង់មេត្តា ប្រោមប្រាប់អស់ពស្ត្រ តាំង
ផ្តាសនានា កុំឲ្យហឹង្សា កណ្តុរតាំងឡាយ ។ ស្តេចស្តាប់មហេសី
ទូលទើបចក្រី បន្ទូលប្រាប់ប្រាយ ប្រាប់អស់មន្ត្រី សេនីយតាំងឡាយ
ឲ្យចេញប្រញាយ គ្រប់ទិសត្រគាម ។ ឲ្យរាយតង្រាប់ អស់ពស្ត្រ
ធ្វើគ្រាប់ កុំឲ្យពាល កណ្តុរតូចធំ ត្រូវកុំរាំងវាំ ឲ្យក្រុយជន្លា កណ្តុរ
តាំងនោះ ។ ថាបើពុំតាម ពុំស្តាប់បំពាក ច្បាប់ថាត្រូវកោះ យកមក
លក់ផ្តៃ យកថ្លៃខ្លួននោះ ជាប្រាក់ចំពោះ មួយពាន់ដំឡឹង ។ អស់
ពស្ត្រជិតឡាយ ក្នុងក្រៅបន្ទាយ ពុំហ៊ានរបឹង អមាត្យប្រាប់សព្វ ត្រូវប់
រឹលរឹង កណ្តុរចាន់តាំង ដោយបុណ្យក្សត្រា ។ សម្តេចក្សត្រី គាយ
អគ្គមហេសី ស៊ីរីសេដ្ឋា នាងទ្រង់ជញ្ជឹង រំពឹងគន្ធិច្ច តិតថាសង្ឃរ
ពិតពុំខ្វៀងខាត់ ។ ប្រាកដដោយតំណ ដោយខុទ្ទកនិត្រ សង្រ្គេង
ស្តាប់ក្តាត់ មានក្តីអន្ទះយ ខ្ចាត់ខ្ចាយបង់ចាត់ ចានសុខចិត្តក្តាត់ តិច
ក្តីសប្បាយ ។ នាងតិតយល់ច្បាស់ ប្រាកដពេកណាស់ ពិតទំនឹងព្រះ
កាយ ច្បាស់ទំនឹងព្រះនេត្រ យល់ហេតុតាំងឡាយ នាងពុំសប្បាយ

ឱដ៏សង្ឃឹក ។ គិតស្រេចក្សត្រី យកទ្រព្យពិស័ ប្រដាប់ប្រដា ឲ្យ
ទៅដោយ តុំមានរួញរា ដំណើរគិតជា មាសឆ្ងៃនេះសុទ្ធ ។ សែន
ជួនតុំមាន ដំរីដ៏មែនមាន មួយថ្លៃចំហុត មានពេងសង៉ែនទៅ ទ្វារ
ក្រៅចំផុត ទ្វារខាងដ៏ជួនសុទ្ធ សឹងពេងជាកំមាន ។ អស់សម
ត្ថកំសត់ គោកយាកគុគិត ជិតឆ្ងាយសឹងមាន ចិត្តត្រេកសាទរ ស្មោះ
សរគ្រប់ក្រោណ ទទួលព្រះមាន ប្រទះទ្រព្យល្អ ។ ហេតុដោយជា
ពស្ត្រ មិនដែលបានមាស ប្រាក់ប្រុះកុះករ ហូលព្រៃចរចាប់ ចំណាប់
ល្អ ។ ធ្លាប់ជាអ្នកក្រ ពាក់ចិញ្ចៀនស្ពាន់ ។ ប្រទះបានមាស ដាំត្បូង
ទុំទ្លាស យ៉ាងល្អសំខាន់ ត្រេកអរសេទ្ធប់ ចំប្រប់តាំងកាន់ ខ្លះបាន
ភោគាន់ កាសាយមមា ។ តាមចិត្តចង់បាន ត្បូងកែវសូរ្យកាន្ត រថស់
ជា ។ គ្រឿងប្រើបានស្រាប់ ប្រដាប់ពាល់គ្នា ចំណីតស្ដុកា បរិភោគ
សឹងបាន ។ សម្ដេចមហេសី បរមក្សត្រី ប្រសើរថ្កើងថ្កាន ឲ្យសង់
សាលា នៅខាងក្រៅហាន ទិសតាំង ៤ បាន មានទាយក្សា ។
សំរាប់សំណាក់ អាគន្ដុកៈដើរមកកាលណា ឲ្យក្រាលចៀមចំ ព្រៃ
ព្រំពស្ត្រា កម្រាលអាស្នា តែសព្វៗថ្ងៃ ។ ព្រឹករៀបចង្ហាន់ ប្រគេន
ឆ្ងាន់ ព្រមទាំងបច្ច័យ ទាំងជួនប្រគេន មែនមានដំណែ្ល បតុបច្ច័យ
ប្រគេនគ្រប់អង្គ ។ ហើយមហាក្សត្រី ស្នាងានប្រក្រតី សីល ៥

តុំបង់ ទោសថបាន ស្មាគានន្លិតផ្ទង់ សត្វសីលហើយទ្រង់ សង្រ្គឹម
កាយា ។ ហើយនាងនឹកគុណ ទេព្តាតំមុន ដែលទ្រាសអាត្មា
ទើបនាងឱ្យមាន សង់កនទេព្តា តាំងបួនទិសា ក្នុងការប្រក្រតី ។ នាង
នឹកដល់គុណ កណ្តុរសមុន កាលជាបក្សី ហើយនាងចាត់ចែង ថូ
ជាចំណី កណ្តុរកន្លងដី លើផ្ទះក្តីណា ។ នាងឱ្យចំណី ចេកទុំនំ
ក្តី ត្រប់គោជនា ឱ្យគានកណ្តុរ ស្អប់ស្អល់គោក្តា សត្វថ្ងៃក្បុ ពុំ
ដែលមាតមាន ។ នាងនឹកគុណទា ដែលតាំស្រុកា ត្រូតីរលោកជាន
ទុកឱ្យស្រីថ្ងៃ ប្រពៃកល្យាណ នាងរៀបឱ្យគាន តបវ៉ុគោក្តា ។
នាងនឹកដល់ឆ្នា ពាំឫសវុក្តា ឱ្យកាលនោះណា នាងរៀបចំណី ពិ
សីពិសា ឱ្យឆ្នាគោក្តា សត្វថ្ងៃប្រក្រតី ។ គោះជ្រូកមាន់ទា កណ្តុរ
ឆ្កែឆ្មា កែកសត្វអ្វី ។ នាងឱ្យអាហារ គោក្តាប្រក្រតី សត្វសត្វអ្វី ។
តិរច្ឆានទាន ។ គោះមនុស្សប្រុសស្រី ចង់បានទ្រព្យអ្វី ព្រះពុជ-
ធីតា តើរឱ្យតាមចិត្ត តន់តិតប្រាថ្នា តួងតែរំមុក្តា កប្បាសសំឡី ។
សត្វត្រប់ធនធានា ក្សត្រីតុំមាន តំណាញ់ទ្រព្យអ្វី ជាយនឹកគោក្តា
អាហារចំណី ក្មេងចាស់ប្រុសស្រី យកបានត្រប់គ្នា ។ អ្នកក្សត្រជាមាន
ដោយសារព្រះទាន ក្សត្រីសោភា អស់អ្នកនគរ សាទរមហិមា
ជានអស់រាស្ត្រា ស្អប់ចិត្តឆ្អែតឆ្អល់ ។ និទានតាំងត ខ្សែប្រាំមួយមក

កាលនាងនិមិត្ត កើតជាសារិកា គោគ្គាកស្ទុះលះ ជាកបមកដល់ ជាន ជាមនុស្ស ។ បានរៀបអភិសេក ជាក្សត្រីឯក គ្រប់ស្នំបរិវារ នាង គិតគុណគ្រប់ សព្វសត្វទេវ បរិបូណ៌ចូលជា ខ្សែប្រាំពីរតែង ។

រឿងមរណមាតាបង្កើតប្តីណោះ

កណ្ឌទី ៤២

ទេសនាវិបុលភជសេនា ជួ-កាង ប្រៃរៀបរៀង

(តមក)

> រឿងសាមកុកកុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> ទឹងបេះខុបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិៗ

ម៉ាអៀនឮហើយខឹងណាស់ បរសេះចូលទៅប្រយុទ្ធគ្នាមិនខាន់ តាំងបានបះពារដល់អាវុធផង កាំឡេងកិងកជាវមុខមុតកាប់ម៉ាអៀនដាច់ពាក់កណ្តាលខ្លួនធ្លាក់ពីលើសេះស្លាប់ ទៀតស៊ុនចូលទៅប្រញាប់តទឹងកាំឡេងទៀត កាំឡេងកិបរសេះចូលប្រយុទ្ធនឹងទៀតី ហើយស្រែកដោយសំឡេងសន្ធាប់យ៉ាងខ្លាំង ទៀតីក៏ភ័យស្លាំងកាំងគេចរត់មកក្រោយ កាំឡេងដេញតាន់ទៀតីទម្លាស់ ឃារដាវឡើងកាប់ត្រូវទៀតីស្លាប់ពីលើសេះធ្លាក់ចុះ តហានតាំងអស់កិបែកខ្ចែករត់ព្រាត់ព្រាយវិលទៅប្រាប់ចួរួ ។ ឮហើយកិនាំតហានរត់វាងតម្រង់ទៅផ្ទះហ៊ានហ៊ុយ ។

ឯស៊ុនគួនដែលលើកទ័ពទៅតាំងនៅដំបន់ភ្នំយតេនោះ លុះឃើញ
ពន្លឺភ្លើងនេះឡើង ត្រង់បន្ទាយភាហានបូធូគិសោមនស្សណាស់ គិតថា
គ្រានេះដីរយើងធ្វើការមានជ័យជំនះបូធូហើយ ទើបប្រើឲ្យកងស៊ុនឲ្យអុចភ្លើង
ឡើងជាសំគាល់ ។ លុះថៃស៊ូដូរទៅជួបទឹងស៊ុនគួន ។ កំឲ្យឲ្យកងស៊ុនទឹង
ថៃស៊ូដូរប្រមូលភាហានចូលគ្នា ហើយលើកស្រុតទៅជួបទឹងជីរយើយកជ័យ
ជំនះបូធូឲ្យបាន ឲ្យកងស៊ុនទឹងថៃស៊ូដូរកំលើកស្រុតទៅស្អាត់ផ្លូវបូធូ ។
យើញកងទ័ពឲ្យកងស៊ុនទឹងថៃស៊ូដូរលើកទៅស្អាត់ពីមុខ កំនាំភាហានតែ
កាត់ចៀសផ្លូវទៅត្រង់ដំបន់អ៊ីឡេន ខ្លួលប្រទះទឹងកងទ័ពខៀវភាប់
បូធូកំឲ្យកងទ័ពតស៊ូពីខាងក្រោយជាមួយទឹងខៀវលៀវ ហើយបរសេះ
រត់សៀវរាងទៅមុខ លុះដឹតភ្លឺស្រាងក្រឡេកមើលទៅក្រោយ ឃើញ
ពន្លឺភ្លើងឆ្ងាយណាស់ កំធ្លាស្រាលក្នុងចិត្ត ទើបដាកមកសួរភាហានតាំង
តួងថា ទីនេះឈ្មោះដំបន់អ្វី ? ។ ភាហានឆ្លើយថា មកដល់នេះដឹត
ដល់ដំបន់ហ្លីមហើយ ។

បូធូឮដូច្នោះ កំបង្ខិបរសេះទាំភាហានទៅតាមផ្លូវប្រកក្នុ, ឯទីនោះ
ជាវាលរហាហានធំណាស់ បូធូឆ្លើបមើលលើហើយអស់សំណើចដោយ
សំឡេងខ្លាំង អស់តាំងភាហានឮដូច្នោះកំដំពឋសួរថា គ្រានេះបរាជ័យ
សឹកសង្គ្រាមរត់មក មហាទបរាជ័យដោយហេតុអ្វី ? ។ បូធូឆ្លើយថា

យើងសើចនេះគ្រោះយើញថា ជម្រិះរៃតិតរបស់ខុនបេនឹងដឹងយើនោះ តិចពេកណាស់ មិនសមនឹងល្បីដែលឮ បើជាយើងធ្វើការដូចខុនបេងឹងដឹងយើញ យើងត្រូវចាត់តាំងមកបង្កប់ក្នុងគ្រែនេះ កាលណាស្តេចវែងមួយនឹងដៃយើង នេះខុនបេងដឹងយើមិនបេះគិតដូចយើងសោះ លុះថាល្ងាចតែផុតមាត់ខ្លួលឮសូរជាវ ឧឹងសូរមនុស្សស្រែកហៅអុចក្តើងនេះឡើងពាំងសង្ឃានផ្ទះ ពាហានក៏ស៊ុះស្រេចញាតៅជាច្រើនណាស់ ជួយឡុងស្រែកមកទៀតថា ខ្ញុងអញ្ជើញឈ្មោះដូឡុង ខុនបេងប្រើឲ្យមកចាំស្តាត់ចាប់អាសត្រូវពួកជសម្បត្តិសម្ងាច់ចេញ បួនក្នុងជួនោះក៏ភ័យណាស់ ស៊ុះបរសេះថយមកក្រោយ ឲ្យទៀវលៀវ. ទៀវខាប់ចូលប្រញាប់តឹងដូឡុង ។ បួនក៏រត់លឿនស៊ុងតៅក្រោយបណ្តាយផ្លូវតៅស្រុកកេងដ៏វ ។

ខណៈនោះ បួនខួចខាតពាហានឹងសេះហើយឧឹងត្រឿងសស្ត្រាវុធច្រើនណាស់ខ្លះដែលរួចរស់ក៏ដោះខ្លួនតាមបួន ។ ឯដូឡុងនឹងពលពាហានក៏ចាប់បានសេះនឹងត្រឿងសស្ត្រាវុធពុកជាច្រើន ។ កាលបួនរត់តៅនោះ ខ្យល់សលាតឹងក៏បក់បោកមកមិនឈប់ តាំងពីពេលព្រលប់ពាល់ភ្លឺស្រាង ភ្លៀងក៏ធ្លាក់យ៉ាងធំ ។ លុះភ្លៀងភ្លឺងហើយ, ពាហានពាំងអស់ក៏នាំគ្នាតៅវាយដណ្តើមយកជ័យ តឹកចំណីអាហារបស់អាណាប្រជាខុរស្តេអ្នកស្រុកមកបរិភោគ ។ បួនក៏ជាន់ប្រទះគ្នាឧឹងតៅជួ ស៊ីឡុង

ខ្ពស់ពួកទ័ប្រឹក្សាជាលំដាប់ប្រហែល ៤-៥ នាក់ គឺបានចូរស្រាលក្នុងចិត្ត ចាត់ព្រួយហើយសួរទៅហានថា តើព្រះនេះឈ្មោះអ្វី ? ។ ពួនហានឆ្លើយថា ដែនតើព្រះដំបន់អ៊ុខ្លែងបែកជា ២ ផ្លូវ ។ បុរសួរថា យើងទៅស្រុកឡាកុនខឹងទៅតាមផ្លូវណាឲ្យរហ័សធាប់ ? ។ ពួហានឆ្លើយប្រាប់ថា ទៅផ្លូវក្រោមធាប់ដល់ជាងផ្លូវលើ តាត់ដម្រង់ចេញតាមមាត់ផ្លូវទៅដំបន់ហោលោកុត ។ បុរបួញផ្លូវនោះគឺនាំពួហានស្រុតទៅ លុះទៅដល់ដំបន់ហោលោកុត យើញពួហានតាំងឡាយខ្យែយហាត់អស់កំឡាំងណាស់ គំឡែយប់សម្រាកកំឡាំងនឹងជាំបាយទឹកបរិភោគ ហើយឲ្យសម្លាប់សេះរៃយកសាច់ចែកគ្នា បណ្តាពួហានគឺដោះគាវដោះក្រែះគ្រឿងប្រដាប់ហាលថ្ងៃឲ្យស្ងួត ហើយកិចនឹសេះឲ្យស៊ីស្កៅ ។

ខណៈនោះពួកពួហានតាំងអស់គំនាំគ្នាចៅរៅជាំស្ងួ បាយទឹសម្លមិនពាន់ឆ្អិនទៅឡើយ ឯបុរបួក៏អង្គុយទៅក្រោមម្លប់ឈើក្រឡែកមើលលើហើយសើចម្តងទៀត ។ ពួហានតាំងពួងក៏ភ្ញៀតសាកសួរព្រោះមន្ទិលសង្ស័យថា តាលជិតក្តីមុខនេះយើងសើចម្តង ហើយថាខុងបេងនឹងជីយើមិនចេះគិត ដូច្នឹងចេញពីព្រៃងឹតមកចោមរាយពាលតែអន្តរាយអស់ រត់ដោះខ្លួនទើបមកដល់ទីនេះ មិនពាន់អស់ហាត់ផងឥឡូវហេតុម្តេចលោកមកសើចដល់ ២ ដងដូច្នេះ ។ បុរបួថា ដែលយើង

សេចក្តី ព្រោះឃើញថាគំនិតគិតរបស់ខ្លួនបានធំដល់ដើរនោះតិចណាស់ ធ្វើការមិនឲ្យហួតដុំភ្នាល ដើរដូចខ្លួនយើងដែលបានធ្វើការសម្លាញដូចគេវិញដូច្នេះ យើងនឹងចេះចាត់កងទ័ពមកបង្ក្រាបចាំនៅមាត់ផ្លូវនេះ ១ ក្រុម បើសត្រូវរត់មកប្រជុំតាមផ្លូវនេះ កំនឹងចាប់ខ្លួនបានដោយងាយ លុះនិយាយផុតមាត់ ខ្លួលឃើញក្តីន ធេព្រោនប្រុះត្រង់ទិសពាំង ៤ សំឡេងគាហានកំស្រែកហ៊ោផ្លូនលើកចេញមកស្ទាក់មាត់ផ្លូវ ១ កង ពីមុខពីក្រោយខ្នងក៏ចេញមកខ្មៅ ព័ទ្ធជុំវិញពាំងអស់ច្រើនណាស់ ។ ឯខ្មៅហ៊ុយក៏ស្ទុះមកស្រែកថា អាចូឆ្លងសត្រូវផែនដី ខ្លួនបងឲ្យអញមកចាំស្ទាក់ផ្លូវនៅនេះ ម្តងនេះមុខជាអាឯងមិនរួចពីដៃអញទេ ។ ចូឆ្លួក្រឡេកឃើញខ្មៅហ៊ុបស្រែកជូនោះ កំលោះព្រលឹងស្ទាត រវៀសរវៃលោតឡើងសេះពាំងគាហាន ៤-៥ នាក់ស្ទុះរត់ទៅមុន ឯគាហានស្រាប់តែនោះក៏ស្ទុះរត់ទៅមុនបែកខ្មែកគ្នានៅតែទៅជួ, ខ្មៅលៀនឹងស៊ីឡែនតាំងច្បាំងនឹងខ្មៅហ៊ុយការពារពីក្រោយ ហើយដោះរត់ទៅតាមចូឆ្លួ គាហានខ្មៅហ៊ុយក៏ដេញកាប់សម្លាប់ យកបានត្រឿងអាវុធនឹងសេះច្រើនណាស់ ខ្មៅហ៊ុយក៏មិនបានដេញជិតដោយចូឆ្លួទៅ វិលត្រឡប់មកក្រោយវិញ ។

ឯចូឆ្លួលុះរត់ទៅឆ្ងាយហើយ ក្រឡេកឃើញគាហានរបស់ខ្លួន

ដែលតាមមកនោះត្រូវគាប់ធ្លុះបួសពិតាត្រង់គ្នា កំសួរថាហានទាំងពួងថា យើងនឹងទៅស្រុកឡាំកុននោះ ទៅផ្លូវណានឹងធាប់ហ៊ាស ? ។ ពាហាន ខ្លះឆ្លើយថា ផ្លូវគាត់នោះគួបរហ៊ាសជាងផ្លូវធំ ៩០០ សិន តែថា ផ្លូវគាត់ដើរទៅពីជាក ព្រោះជាទីប្រកបដ្ឋានមានដុំថ្មកបង្ក្រកជាច្រើន ចាំខ្ញុំ បានស្រុតទៅមើលខាងផ្លូវគាត់សិន ពាហានម្នាក់ទៅក៏ឃើញមានក្តើង នេះត្រង់ផ្លូវនោះ រួលមកប្រាប់ពួកវិញ ។ ពួកក៏ប្រាប់ថា ត្រូវយើង ទៅតាមផ្លូវគាត់ដែលមានក្តើងនេះនោះវិញ ពាហានថា ផ្លូវគាត់ដែលមាន ក្តើងនោះ ខ្ញុំបានឃើញថាពួកសត្រូវ នឹងមកបង្កប់តួន ៣ទីនោះជា ប្រាកដ ហេតុម្តេចបានជាលោកនឹងឲ្យទៅផ្លូវនោះវិញ ។

ពួកថា យើងដឹងថាគំនិតខ្មាំងគិតនោះ ប្រុងនឹងបញ្ឆោតយើង ទើបក្តើងឲ្យយកក្តើងមកតជុតទៅមាត់ផ្លូវគាត់ ហើយយកពាហានទៅ បង្កប់ពុកពាងផ្លូវធំ បំណងនឹងឲ្យយើងគិតភ្ញាក់ពាងផ្លូវដែលមានគំនរក្តើង នោះ នឹងមានពាហានតួនបង្កប់តែជាយពិតនោះដូច្នេះទេ គឺប្រាកដជា មានពាហានបង្កប់ទៅពាងផ្លូវធំ ។ ពាហានពួកពួនឮដូច្នោះ កំយល់ឃើញ ដូចពួកថាពាំងអស់គ្នា នាំគ្នាមិនគេចដម្រង់ទៅតាមផ្លូវគាត់ ដែល មានគំនរក្តើងជុតនោះវិញ ។

កាលពួកដើរតាមទៅនោះ អស់ពួកពាហានសឹងតែមានបួសពិតារ

ដោយគ្រឿងសស្ត្រាវុធជាច្រើន មានសេចក្តីលំបាកណាស់ ខ្លះកំពុងឈឺ
ហត់ដោយអត់អា ហាវំនួយស្បៃដើរទៅស៊ូរមិនរួច ខ្លះកំលួចលបឈប់
ក្រោមម្លប់ឈើ ខ្លះកំដើរចូលផ្ទះដោយក្រែកភ្នំ ខ្លះកំយំប្រាប់គ្នា ចូរអ្នក
ឯកមកសួរថា ហេតុអ្វីបានជាអ្នកទាំងនោះគ្មានស្រួលទៀតបាត់ ឥឡូវនេះ
ប្រាប់តទៅ ឆ្លើយថា ព្រោះឃើញបាប់ដោយរបួសជាការ, មានកំពុងយំដោះ
ស្រយាលណាស់ ទំនួរសែងដើរកាត់ផ្លូវបង្កើតល្បាប់សឹងតែថប់ឈើ
តាន់តាប់មកតាមផ្លូវ ព្រោះតែព្រឹកឆាប់ភ្លឿនមកគ្រាផ្លូវគំនរលកក់ធុន
ដោយរំលុងអណ្តូងពិបាកណាស់ ទាំងរសះទាំងមន្ទស្សកំពិបាកជួបគ្នា
បានជាកវែកប្រវែកគ្នានៅដូច្នេះ ។

ចូរឮដូច្នោះនឹងណាស់ថា កាលពីដើមយើងនឹងលើកកងទ័ពមក
នោះ ទាំងអស់គ្នាសុទ្ធតែសុំយកតាសាថានឹងតស៊ូធ្វើចម្បាំង គ្រាតែអស់
ជីវិត តោះបក្ខពួកយើងមកច្បាំងដឹងទៅពីមុខកំត្រូវតែរត់គ្រសុកចូលទៅឲ្យ
ដល់ តួនឹងធ្វើបន្ទាស់ចងស្ពានថ្នល់ឆ្លងទៅកំត្រូវតែធ្វើឲ្យបាន មិនត្រូវ
ឈប់ខានឲ្យយូរការ ឬអ្នកចាំងអស់គ្នាតាមខ្ញុំបញ្ជើតណាស់ទៅ
ហើយ ចូរឆ្លងយាយហើយ កំហែមទុស្សដែលឈឺបួសនោះគ្រាក
ដើរមកពីខាងក្រោយ ឲ្យតាមដែលដើរមុខគាប់ឈើរមកដំរៀបកយ
លើថ្នល់ឆ្លងរំលុងអណ្តូង ឲ្យសេះទាំងហ្វូងដើរទៅជាស្រួលបាន បើអ្នក

ឯណាឈប់ទាន់មិនព្រមធ្វើតាម ត្រូវឲ្យគាត់ក្បាលខុកជាប់ពាមតទៅ
ទៀតឲ្យទៅចុះ, សុំឡើងនាំតាហានត្រួតត្រាការពារពីក្រោយ ចោរឃើញអ្នក
ចេះឯណាមិនខំដើរ បណ្តោយឲ្យយឺតយូរ តំត្រូវឲ្យសម្ងាប់ចេញកុំឲ្យ
សត្រូវមកជួបប្រទះឃើញឲ្យសោះ ។ ពួកតាហានអម្បាលណោះ តំបាំង
តែធ្វើតាមចួនចួបគ្នាប់ ។ ចួនកំបង្គំកងទ័ពឲ្យស្រួតដើរទៅ ។ ណោះនោះ
តាហានតាំងពួនកំទ្រីស្រួតត្រួតដើរពារចំរុះលើគ្នា ពួកដែលចេះសពិការកំដួល
ស្ទាប់ទៅខ្លះ ។ ដែលខំដើរទៅមិនរួចសោះ តាហានតាំងនោះកំសម្ងាប់
ចោលទៅខ្លះ ពួកចេះសគ្រៅពីនោះកំចេះតែភ័យខ្លាច នាំគ្នាស្រែកយំ
រត់តាមផ្លូវទៅ ។

ចួនឮសំឡេងយំសោកដូច្នោះ កំរិតណាស់ស្រែកថា ហេតុម្តេច
បានជាគាត់យំរង់ឈឺដូច្នេះ ការដែលវាស់ខឹងស្ទាប់នោះកំស្រួចតែបាប-
កម្មប្រចាំរូបកាយតាំងអស់គ្នា ។ លុះយាត្រាទៅផុតប្រភក្តំ កំក្រ
ឡេកមកក្រោយ ឃើញតាហានដែលសស់ទៅជាមួយនោះ ប្រហែល
៣០ ឬ ៤០ នាក់ ចួនកំបង្គំឲ្យមេទាយស្រួតដើរទៅ តាហានតាំងអស់កំនិយាយ
ព្រមឡើងថា សេះនឹងមនុស្សកំអស់កំឆ្កាំងណាស់ទៅហើយ សុំឲ្យ
លោកបង្អង់ឈប់បន្តិចសិន រួចសឹមលើកទៅទៀត ។ ចួនថាឲ្យចាំទៅ
ឲ្យដល់ស្រុកកោងជាសិនសឹមឈប់ចុះ ហើយកំស្រួតបាសេះទៅតាមនោះ

ចាន់ច្រវែល ៥០ សិន (៦គម) ដល់ដំបន់ហ៊ូយ៉ុង ចូរឆ្លងកំអស់
សំណើចឡើងវិត ។ ពាហានទាំងឡាយឮដូច្នោះ កំមានសេចក្តីសង្ស័យ
សួរទៅចូរឆ្លងថា លោកសើច ២ ដងមកហើយ ចេះតែមានហេតុឲ្យគ័យ
ក្រែងគ្រា ឥឡូវលោកសើចធ្វើអ្វីទៀត ? ។ ចូរឆ្លងប្រាប់ថា យើងសើចចំអកតំនិត
តិតរបស់ខ្មែនចេងនឹងដីវាយ ព្រោះខ្មែនចំណាប់ស្រួលណាស់ មិនគួរនឹង
មិនបង្កើបពាហានខ្មុក បើសិនណាជាមានពួកខ្មែនចេង ជាវាយមកចាំ
ស្កាត់ទៅត្រង់ណោះ យើងកំនឹងបានសេចក្តីអន្តរាយជាប្រាកដ លុះ-
និយាយផុតមាត់កំឮសំឡេងជាវ ហើយឃើញគួនអ្នកដែះសេះគាន់ជាវ
ចេញមកត្រមាំងពាហាន ឈរខ្មែនមុខត្រង់ផ្លូវដែលនឹងទៅនោះ ។

ចូរឆ្លងឃើញដូច្នោះ កំតក់ស្លុតស្មារតីភ័យណាស់ នឹងរកប្រកលុក
រត់ចៀសទៅខាងណាកំមិនបាន ហើយមានចិត្តមានះឡើងថា ឥឡូវ
យើងពាល់គ្នាពាល់ប្រក នឹងរត់ជ្រកទៅខាងណាមិនរួច, ត្រូវតែ
តាំងចិត្តស៊ូច្បាំងឲ្យត្រប់គ្នាទៅខាងមុខចុះ ។ ពាហានទាំងពួងនោះកំ
ឆ្លើយថា ពួករបស់យើងខ្មែនបយកំច្បាំងអស់ហើយ ទាំងសេះកំអស់
កំច្បាំង ឃើញថានឹងប្រឹងទៅមិនបាន ព្រោះមិនមានកំច្បាំងទាំង
មនុស្សនឹងសេះស្មើគ្នា ។ ឆៀយ៉ុកឆ្លើយថា បើនឹងរត់ចៀសទៅខាង
ណាកំមិនបាន ព្រោះមិនមានកំច្បាំងទាំងមនុស្សនឹងសេះស្មើគ្នា ។

ឆ្ងៀយ៉ុកឆ្ងើយថា បើទំនិរតំរៀសទៅខាងណាក៏មិនបាន ឯសន្តានចិត្ត
របស់គួនអ្ងួនោះ ជាជាតិខាហានកំមែន តែថាបើយើញអ្នកឯណាមិន
ហ៊ានតស៊ូទំនឹងបម្បាំនហើយ គំមិនបានធ្ងើអន្តរាយដល់អ្នកនោះទេ ។ ប្រ
ការ ១ ទៀត គួនអ្ងួជាមនុស្សមានសេចក្តីសត្យានុស័ត្យ ព្រមទាំង
កតញ្ញូដឹងគុណគេជាទីបំផុត ប្រសិនបើលោកនឹងបួលទៅនិយាយលួងឆ្ងួ
លោមដោយល្អំអុតល្អសុភាព មុខជាគួនអ្ងួនឹងជ្រួតជ្រាបក្នុងចិត្ត មិន
បានតតឹងធ្ងើអន្តរាយដល់លោកទេ ។ បួនួយលំយើញត្រូវ គំញាក់
សេះបាបួលទៅជិត ហើយបន្ទន់ខ្លួនទន្ទេនគំទាប់ស្រែកសួរថាតាំងពីអ្នក
ឃ្លាតបាតពីយើងមក អ្នកបានប្រកបដោយសេចក្តីសុខសប្បាយទេឬ ។
គួនអ្ងួឮដូច្នោះក៏បង្អ្ងាន់ខ្លួនគំទាប់តបហើយថា សុខទំនឹងក្តីនោះក៏
ជាប្រមាណ តែឥឡូវនេះឯងឲ្យខ្ញុំមកសម្លាប់មហាឧបាជវេញ ។ បួនួ
ថា ដែលខ្ញុំបែកចំពាត់ត្រឡប់មកដល់ទីនេះ ក៏បានសេចក្តីខុសឡំបាក
តាំងប្រមាណណាស់ អ្នកគួរយើញផ្លូវមេត្រីរបស់ខ្ញុំដែលបានចងការម្នាំ
ខុតនឹងអ្នកមកពីដើមនោះចុះ សុំឲ្យអ្នកគន្ធុគ្រោះបើកផ្លូវឲ្យខ្ញុំទៅផង ។
គួនអ្ងួថា ដែលមហាឧបាជមានឧបការគុណដល់ខ្ញុំនោះ ក៏មែនណាស់
ខ្ញុំក៏ចាំបាស់ច្រាកដ តែថាការចត្រាអ្ងួនសៀវលើកចំពាត់ទៅបាំងនឹងលោក
នៅដំបន់ថៃបែះនោះ ខ្ញុំក៏ខ្លួសការសាចេញទៅកាប់សម្លាប់ឆ្ងីនលៀង,

ប៉ុន្តែជាតបគុណាសោកក្តួចហើយ គ្រានេះជាការរបស់ខ្ញុំនឹងប្រើឲ្យខ្ញុំមកដែលសោកនឹងឲ្យខ្ញុំចេញផ្លូវឲ្យទៅនោះ ខ្ញុំនឹងនឹងមិនយកពេលខ្ញុំប៉ុន្មាន។

ឯចូរនួយថា ដែលអ្នកថាបានតបគុណខ្ញុំគ្រានោះម្តងហើយក៏មែន តែកាលអ្នកយាមល្បាតចេញមកដល់ច្រាំងជំពន់ជាលំដាប ហើយបានទាំងសម្ងាត់ដាយតយល្បាតនឹងហៅហ្វាយស្រុក ខ្ញុំរាប់តាហានរបស់ខ្ញុំបានជាច្រើន ខ្ញុំក៏មិនតបដែរ ព្រោះបានដឹងដល់ពាក្យដែលអ្នកនិយាយពុំពីថ្ងៃមុនទាំងអស់ រំលោះនោះខ្ញុំក៏បានចេញសំបុត្រទៅដល់ហៃហ៊ូនដែលនៅឈរទ័ពនៅហងនោ ហាថាឲ្យចាប់អ្នកទៅ តាប៉ូវនេះខ្ញុំបានចូលមកជាប់ចំណាម ជាដូចមនុស្សធ្លាក់ទឹក ហើយខ្ញុំក៏មិនបាននឹកនឹងតស៊ូនឹងអ្នកទេ គួរអ្នកយើញសេចក្តីមេត្រីរបស់ខ្ញុំដែលបានអង្វរលន់តួនេះចុះ សុំឲ្យអ្នកអនុគ្រោះចាកខ្ញុំឲ្យបានរួចផុតពីភ័យអន្តរាយ ។ គួនអ៊ូវឮដូនិយាយដូច្នោះក៏តើតសេចក្តីអាណិតផ្នែកក្នុងទុកគិតពិចារណាយើញដល់គុណដែលមានមកពីដើម ក៏ញាក់សេះវេះចេញពីផ្លូវ នាំតាហានលើតទៅផុតពីខែនោះ ។

ចូតួយើញដូច្នោះ ក៏សើយយល្ហើយកន្ធិតិត្ត ទំពង្រឹតពលតាហានឲ្យស្រួតរួតហួសទៅ ។ ឯតាហានដែលសល់នៅប្រហែល ៣០ នាក់ដើរតាក្រោយ ។ គួនអ៊ូយើញតាហានដើរចណ្តាយតាមចូតួរទៅក៏ស្រែកគំហកដោយសំរួនខ្លាំង ។ តាហានដែលជិះសេះដើរដើង បានឮដូច្នោះក៏

ភ័យតក់ស្លុតលុតជង្គង់ចុះគំនាប់គួនអ៊ូពាំងអស់គ្នា ។ គួនអ៊ូឃើញពាហាន
ពាំងនោះមិនហ៊ានទាំគ្នាតដៃ កំមានសេចក្តីគណិតមេត្តាមិនហ៊ានថាក្រ
ការម្តេច ពាហានពាំងនោះកំគំនាប់លាគួនអ៊ូស្រួតតាមចូនួ ។

កាលចូនួទៅដល់ដំបន់ហ៊ីយ៉ុងហើយ ក្រេឡេកមើលក្រោយឃើញ
ពាហានដែលតាមមក២៧ទាក់ ។ ខណៈកាលដើរផ្លូវទៅនោះ ចូនួកំសារ
សើរគួនអ៊ូថាមានសេចក្តីស័ត្យកតញ្ញូណាស់ លុះវេលាព្រលប់ចូនួកំឃើញ
កងទ័ព ១ក្រុមដុតតប់ភ្លើងលើកមកពីខាងមុខច្រើនណាស់ គឺគតក់ស្លុត
ក្នុងចិត្តថាគ្រានេះជីវិតនឹងដល់សេចក្តីអន្តរាយហើយ លុះដឹតចូលមកកំក្រ
ឡេកស្គាល់ឮសំថាចោយ៉ិន ចូនួចូរស្រាលតំយកតិត ។ ចោយ៉ិនចូលមក
គំនាប់ចូនួហើយនិយាយថា ខ្ញុំបាទដឹងដំណឹងថា មហាឧបរាជចោយ៉ិនដឹង
សឹកសត្រូវ បានជាលើកពាហានកាត់ផ្លូវមកត្រង់ទីនេះ ដើម្បីទទឹងចាំទទួល
លោក ។ ចូនួកំរៀបរាប់ប្រាប់ទុក្ខលំបាកឲ្យចោយ៉ិនស្តាប់ រួចយកគំនាំ
ពាហានចូលទៅកងស្រុកឡាំកុន ។ ចោយ៉ិនកំឲ្យរៀបតុលៀងអាហារ
អញ្ជើញចូនួនឹងប្រឹក្សាបរិភោគផឹកស្រា ប្រាថ្នាឲ្យស្រួយល្ហើយទុក្ខ ។

ខណៈកាលកំពុងបរិភោគអាហារនោះ ចូនួកំឱនក្បុំយំ ។ ទីប្រឹក្សា
ធំឯពាហានពាំងពួនឃើញដូច្នោះ កំសង្ស័យណាស់ ទើបនាំគ្នាសួរចូនួថា
កាលបែកខ្ញុំតមកកណ្តាលផ្លូវ បានសេចក្តីទុក្ខលំបាកវេទនាជាច្រើនជាន់

ណាស់ យើងខ្ញុំគិតឃើញថា លោកគ្មានទ្រព្យធនប៉ុន្មាន ឥឡូវនេះ ហួសខុក្ខជានសេចក្តីសុខក្សេមក្សាន្តបន្តិចមកហើយ គួរតែធនឹងប្រមូលបញ្ចូលសេនាគហានលើកទៅធ្វើការសង្គ្រាមវិញឲ្យភ្លាន ហេតុម្តេចក៏លោកមកព្រួយរំខានយំសោកដូច្នេះ ? ។ ចូឆួថា ដោយយើងយំសោកដូច្នេះ ព្រោះហេតុតែដល់គុយកែ បើគុយកែរស់នៅមិនស្លាប់ត្រានេះ ក៏គង់ជាប់មកជាមួយនឹងយើង យើងក៏មិនមកព្រួយលំបាកវេទនាដល់ពីនេះ ជាដូច្នោះហើយក៏យំសោកវិលក៏ឃើយដល់គុយកែ ។

លុះវេលាព្រឹក ចូឆួក៏និយាយនឹងចាយ៉ងថា យើងនឹងត្រឡប់ទៅស្រុកហ៊ូគោសិន ដើម្បីនឹងចាត់ចែងប្រុងប្រៀបរៀបចំបំរុងនាហានទឹងលើកមកវាយយកស្រុកកាំងគាំងឲ្យបាន ខ្លួនអ្នកត្រូវនៅរក្សាស្រុកឡាំកុនយើងនឹងសរសេរសំបុត្រចំនួនស្រោមពុកឲ្យចម្រើរក្សាខ្លួន បើជួបអាប់ចុងវេលាណា ក៏ឲ្យហែកស្រោមមើល ហើយឲ្យធ្វើតាមសេចក្តីពន្យល់ក្នុងសំបុត្រនោះឲ្យសព្វគ្រប់ ទើបពួកស្រុកកាំងគាំងនឹងមកញាំញីមិនបានហើយក៏សរសេរសំបុត្រប្រកស្រោមប្រគល់ឲ្យទៅចាយ៉ង ។ ទទួលយកសំបុត្រហើយថា ស្រុកហ័បង៉ាន្ទោះជាដែនតដែនទឹងស្រុកកាំងគាំង តើលោកនឹងឲ្យនរណាទៅឈរក្សា ចូឆួថា ស្រុកកេងជាវេនស្រុកឡាំកុន នាះទៅបួរក្សាពុកឲ្យមាំមួនចុះ ឯស្រុកសុងយ៉ុងនោះយើងនឹងឲ្យហែហួខុន

នៅឈរក្បែរ តែស្រុកហ៊ីចប៉ាំយើងត្រូវទៀវលៀវធ្វើចៅហ្វាយស្រុក ឲ្យលើខ្នងឯងក៏ជាធ្វើបាលដ្ឋ បើមានការអ្វីជាកម្រកំឲ្យះធ្វើសំបុត្រទៅគ្នាឯងមកដួយ ហើយបួនធ្លុកំប្រុងប្រៀបខាហាន ឯងមុំនត្រង់ភ្នាក់ងារស្រុកកេងដីវៃជាស្រេច កំលើកទ័ពត្រឡប់ទៅស្រុកហ៊ូតោ ចោយឯងកំឲ្យចោហាងជាប្អូនលើកខាហានទៅនៅក្បែរគយអ៊ីឡែន ។

ឯគួនអ៊ូគ្រាដែលបើកផ្លូវឲ្យបួនធ្លុទៅហើយ កំលើកខាហានត្រឡប់ទៅជល់មុខបន្ទាយហែទៅ ព្រមគ្នាឯងទៀវហ៊ុយ, ជូឡែន កងខណៈនោះ ទៀវហ៊ុយ, ជូឡែន បានខាហានឯងសេះខ្លាអស់គ្រឿងសស្ត្រាវុធចេស់ច្រើនផ្សេង ។ នាំទៅជូនខុងឯចេង ។ លុះដឹងថាគួនអ៊ូមកជល់មុខបន្ទាយ កំនាំទៅពីធ្វើជាចេញទៅខ្លួល ហើយនិយាយសួរទៅគួនអ៊ូថា យើងដឹងថាអ្នកមានចិត្តសុចរិតជួយខំទុកបុំនិងដែនដី បានទៅតាត់សិរសី គួរសឹកសត្រូវកជសម្បត្តិមក បានជាយើងចេញមកចាំខ្លួលអ្នកដោយសេចក្តីត្រេកអរដំរៃលែង ។

គួនអ៊ូឮដូច្នោះក៏ស្ងៀមមិនធ្វើយ ខុងចេងឃើញគួនអ៊ូធ្វើធ្ងន់ដូច្នោះក៏ភ្លែងដង្ខោនសួរថា អ្នកតូចចិត្តនឹងយើង ព្រោះមិនបានចេញទៅខ្លួលជល់តាក់តណ្តាលផ្លូវឬអ្វី ? ហើយងាកទៅបន្ទោសខាហានដទៃថា ហេតុម្តេចបានជាអ្នកកលគ្នាមិនស្រួតមកប្រាប់យើងឲ្យដឹង ឯងបានចេញមក

ខ្ញុំលួតគួនអ៊ូដូច្នោះ គួរតែយកគោសខ្ញុំសងំឯងអស់គ្នា ពីព្រោះចង្វើឲ្យគួនអ៊ូ
ទាស់ចិត្តបានជាចិត្តមានមិនស្កប់ចិត្តដល់យើង ។ គួនអ៊ូឮពុំដែលចង់ឃើញយ៉ាង
ដូច្នោះក៏ឆ្លើយថា ខ្ញុំបានយកគោសមកឲ្យលួតគោស ។ ពុំដែលក្លែងសួរទៅ
វិញថា អ្នកទៅធ្វើការនោះមិនដូចនឹងចូលទេឬ ឲ្យអ្នកមកកាត់យកក្បាល
យើងដំនួសបុះ ។ គួនអ៊ូឆ្លើយថា ខ្ញុំបានទៅដូចនឹងចូលដូចប្រសាសន៍
លោកថាប្រាកដ តែថាខ្ញុំបានដូចជាអត់ថ្លៃដៃសោះ ឯចូលក៏ដោះអត់ទៅ
បាន ។ ពុំដែលឮហើយក៏អស់សំណើច ហើយសួរគួនអ៊ូថា ដែលចូលទ្រត់រួចខ្លួនទៅនោះ បុះចំណែកខាហានរបស់ចូល តើអ្នកបានចាប់បានមកខ្លះ
ដែរឬទេ ? គួនអ៊ូឆ្លើយថា សូម្បីខាហានរបស់ចូលក៏ខ្ញុំបានចាប់ខ្លួនពុំបាន
ពុំដែលក៏ធ្វើជាទំនើហើយថា ខ្លួនអ្នកឯងបានទៅដួចប្រទះនឹងចូលហើយ
ម្តេចឡើយក៏បើកឲ្យគេរត់រួចទាំងខ្លួនចូលនឹងពួកខាហានអស់ទៅ ឬអ្នកឯង
មកតិះដៀលនឹករលឹកគុណគេ ៖ ចើបបានជាមិនចាប់ខ្លួនកាត់យកក្បាលមកឲ្យ
យើងទោសអ្នកឯងជួនណាស់ ដែលអ្នកបានធ្វើកតិកាសញ្ញាពុំនឹងយើង
នោះអ្នកភ្លេចអស់ហើយឬ ? ។ គួនអ៊ូឆ្លើយថា ដែលខ្ញុំបានឆ្លើយ
សញ្ញាពុំនឹងលោកថា បើខ្ញុំបានប្រទះដួចនឹងចូលហើយមិនបានកាត់
យកក្បាលមកជូនលោកទេ ឲ្យកាត់ក្បាលខ្ញុំបានតាមសញ្ញាវិញចុះ ហើយ
កំហូតក្រចើឡើងនឹងកាត់ក្បាលរបស់ខ្លួនជូនពុំដែលបាន ។ ឃើញគួនអ៊ូហួត

ក្រមុំនឹងកាត់ក្បាលខ្លួនជូនព្នោះ កំសុះចូលទៅដណ្តើមយកក្រមុំពីដៃចេញ
បាន ហើយឃាត់ហាមថា ដែលយើងត្រមប្រើអ្នកឲ្យទៅធ្វើការគ្រានេះ
ក្រែងខ្លាំងនឹងឲ្យអ្នកទៅតបស្នងសងគុណចូលមួយរបេ យើងមិនបានប្រុង
នឹងយកទោសអ្នក នឹងកាត់ក្បាលឲ្យយើងតាមសញ្ញានោះកិត្រូវហើយ
ព្រោះជាភាក្យស័ត្យពិតត្រង់គួរជាជាតិខាហានឲ្យទៅចុះ ។ គួនអ៊ូញដូច្នោះ
កំសោមនស្សត្រេកអរ សុំយកក្រមុំទៅសិកក្នុងស្រោមវិញ ទុងបេងនឹង
ទៀតក៏នាំគួនអ៊ូចូលទៅក្នុងបន្ទាយឲ្យរង្វាន់បំណាច់តាមសមគួរ ។

ឯជីវយើ កាលបានជ័យជំនះឈ្នះចូលហើយ កំលើកកងច័ត្រឡប់
ទៅបន្ទាយ ឲ្យចែករង្វាន់បំណាច់សេនាខាហានធំតូចតាំងពួងតាមគុណ
បំណាច់ ហើយកំឲ្យយកទូកចម្បាំងផ្លុកខាហានចូលដែលចាប់បានជា
ឈ្លើយនោះ បញ្ជានទៅឲ្យស៊ុនគួនដល់មាត់កំពង់ស្រុកកាំងតាំង ហើយ
ជីវយើកំលើកកងច័ត្រទៅតាំងនៅទីជិតបន់លីមកាំង ចំឯនឹងរិះគិតទៅរក
យកស្រុកភ្នំកុនទៀត ។

ឯទៀត កំចាត់បុរសឲ្យសម្រាច់លៀងខាហានឲ្យស៊ុនខៀនទាំ
ទៅតំនាប់ជីវយើ ស៊ុនខៀនកំនាំយកបុរសទៅឲ្យជីវយើ ។ កំសួរស៊ុន-
ខៀនថា ឥឡូវទៀតទៅហ្វាយអ្នកឯងនៅទីជិតបន់ណា ? ។ ស៊ុនខៀន
ឆ្លើយថា ទៀតនឹងទុងបេងនាំខាហានទៅតាំងនៅកំពង់ស្រុកអីកាំង ។

(នៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

រឿងស្តេចចាយង្ការ

លោក ញ៉ែម-ទឹម រៀបរៀង

ក្នុងសម័យត្រេតាយ ក្រុងស្រីអយុធ្យាជានគរមួយសប្បាយក្រៃលែង ។ ព្រះមហាក្សត្រនៃប្រទេសនោះព្រះនាមៈស្តេចតំលង ព្រះមហាក្សត្រិយានីព្រះនាមនាងសក់ក្រអូប ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គទ្រង់គង់នៅឯក្នុងព្រះបរមរាជវាំង ទ្រង់មានព្រះរាជបុត្រពីរព្រះអង្គ មួយជាព្រះរាជបុត្រា មួយជាព្រះរាជបុត្រី ។ ព្រះរាជបុត្រាព្រះនាមស្តេចចាយង្ការ, ព្រះរាជបុត្រីព្រះនាមនាង សបូករៈ ។ ព្រះនាងមានព្រះជន្ម ១៩ ឆ្នាំ ។

ថ្ងៃមួយព្រះអង្គម្ចាស់ក្សត្រី កំពុងតែក្តីក្តៅក្រហាយក្នុងព្រះទ័យ, ចង់យាងចេញទៅមុជទឹកលេង ទៅត្រង់មុខវត្តជីងកញ្ជុំ ដែលអ្នកៗយើងគិតអាជាទៅអធិការ ។ អាស្រ័យហេតុដូច្នេះ ព្រះនាងក៏ទ្រង់ត្រាស់ហៅស្រីស្នំក្រមការ ឲ្យជូនព្រះនាងទៅស្រង់ទឹកនៅមុខវត្តនោះ ។

មានដំណាលថាៈ នៅមុខវត្តនោះមានក្រតើមួយគាបសាហាវណាស់ ។ ក្រតើនោះបានគាប់ចាំងឃាំងហើយ ហែលចេញមកចាប់ព្រះនាងតាំយកទៅជាមួយវាទៅ ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គ ជាព្រះ

បិតាមាតាព្រះនាង ឲ្យចេញទៅកាន់ទីឲ្យឆ្ងាយ ដែលចេះមន្តអាគម ខាងចាប់ក្រពើឲ្យមកចាប់ក្រពើ ដែលបានពាំព្រះរាជបុត្រីព្រះអង្គទៅ ។

គ្រូហ្នឹកំរៀបធ្វើពែមួយដាក់លាជពីលើ ។ កាលធ្វើរួចហើយ, គាត់ក៏បានសូត្រមន្តអាគមប្រសិទ្ធពរលើពែនោះ រួចក៏បណ្តែតពែនោះឲ្យចេញទៅតាមកន្លែងក្រពើ ។ កាលបើពែនោះបានរសាត់ទៅដល់ខាងដើមព្រៃត្រមូង ; ព្រះកញ្ញាដែលទ្រង់បានយោងតាមពែនោះជាប់ជានិច្ចមក, ក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេបញ្ឈប់ពែនោះ ដើម្បីឲ្យពួកពលព្រះអង្គឈប់សម្រាកដណ្តើមបាយបរិភោគ ។ លុះពួកពលបានចំអិនបាយម្ហូបអាហារសព្វគ្រប់អស់ហើយ, ព្រះកញ្ញាទ្រង់ត្រាស់បង្គាប់ឲ្យគ្រូហ្នឹចូលរួបខ្លួនឯងមើល (បញ្ជាន់រូប) ។ នៅពេលនោះព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យគេផ្ទុំប៊ីពក ដើម្បីប្រគំគ្រូដែលស្ថិតនៅខាងលិចព្រៃនោះ ។ គ្រូហ្នឹកំពុងមន្តគាថាសំបូងសង្រ្គង ដើម្បីហៅក្រពើឲ្យឡើងមកលើគួលឱ្យច់ ដែលស្ថិតនៅខាងទិសពាយ័ពនៃព្រៃត្រមូង ។ ដោយព្រះអាទិត្យមានកំដៅក្តៅពន់ពេក ព្រះកញ្ញាទ្រង់ត្រាស់បង្គាប់ឲ្យគេយកផ្ទៃតទៅពាំងឲ្យហ្ន ។ គោះបីគ្រូហ្នឹទំសូត្រសែកមន្តអាគមយ៉ាំងណា ក៏នៅតែកក្រពើពុំឃើញ ។ អាស្រ័យហេតុនោះ, ទើបព្រះបាទបាយង្គោទ្រង់ព្រះកញ្ញាដល់កងសេនាគហានទាំងអស់ ឲ្យលើកចំនប់ចប់ទឹកកុំឲ្យហូរមកពីលើ ហើយ

បបួលគ្នាបាចទ្បើងដើម្បីចាប់ក្រពើ ។

លុះចាប់ក្រពើបានគាលណា គេក៏សម្លាប់វា រះពោះតាយយកសពព្រះអង្គម្ចាស់ក្សត្រីចេញមក ។ ព្រះមហាក្សត្រជាព្រះវរបិតាព្រះនាងទ្រង់ដោះយកគ្រឿងមាសក្រាក់ ដែលជាប់នៅនឹងព្រះកាយព្រះនាងចាំងចុំន្នានចេញអស់ ។ បន្ទាប់មក, ព្រះអង្គទ្រង់គ្រាស់បង្គាប់ឲ្យតាមហានគ្នារៃព្រមួយកន្ទែង ដើម្បីជាំលួយកគ្រាប់ធ្វើនំ រៀបធ្វើបុណ្យបូជាព្រះសពព្រះរាជបុត្រីព្រះអង្គ ។

តំបន់តាំងពីពេលនោះមកហើយ បានជាកន្ទែងខ្លះនៃតំបន់នោះមានឈ្មោះថា: ខំនប់ក្អកក្រពើ, ភូមិព្រៃអំពក, ភ្នំម្ជុត, ភូមិបឹងអិដ្ឋ, វត្តទ្រមូង, ភូមិត្រពាំងសម្ង, ព្រៃធំ ។

ដំណាលពីព្រះនាងសក់ក្រអូបវិញ ដែលជាមហេសីនៃស្តេចតំលង់ព្រះរូបសម្បើមដ៏ល្អឆើតឆាយរបស់ព្រះនាង ត្រូវបានលេចឮទ្បើងដល់ទៅប្រទេសចិន និងប្រទេសសៀម ។

ព្រះរាជានៃប្រទេសចិន កាលបើទ្រង់ជ្រាបថាព្រះទេពីនៃស្តេចតំលង់សោយរាជ្យនៅក្នុងនគរស្រីអយុធ្យា មានព្រះរូបឆោមលោមពណ៌ល្អប្រឹមប្រិយ័ក្រៃលែង គ្មានស្រីណាមួយនៅក្រោមមេឃលើដី អាចប្រៀបផ្ទឹមបាន ក៏ទ្រង់គ្រាស់ប្រើប្រាស់ដល់នាយសំពៅចិនម្នាក់ ឲ្យបើកសំពៅចេញ

មក មានជាក់ពាំនឹងឮតែបីដង តម្រង់មកនគរស្រីអយុធ្យា ដើម្បីមកចាប់ដណ្តើមយកព្រះនាងសក់ក្រអូប ជាក់សំពៅនាំយកទៅថ្វាយព្រះអង្គឲ្យបានកុំខាន ។

ម្ចាស់សំពៅឲ្លួលបង្គាប់ព្រះពជាចេតសំពៅចូលមកក្នុងនគរស្រីអយុធ្យាឈប់ចោះយុថ្កានៅមុខវត្តដើងតញ្ជុំដែលអ្នកយើងអិកអីតធំនៅ ។

លុះស្អែកឡើង, នាយសំពៅក៏យកឥឡឹកបីនោះទៅថ្វាយព្រះបាទចុយង្គោរ សូមឲ្យព្រះអង្គរកអ្នកប្រាជ្ញឯណាដែលចេះទាយ ឲ្យទាយថាតើឥឡឹកនីមួយ ។ នោះមានគ្រាប់ប៉ុន្មាន ។ នាយសំពៅបានពោលបន្ទន្ទមថា បើព្រះនរបតីពុំអាចរកអ្នកប្រាជ្ញណាមួយទាយត្រូវទេ, នោះត្រូវព្រះអង្គប្រគល់ព្រះនាងសក់ក្រអូបទៅឲ្យស្តេចក្រុងចិន ។ ឮដំព្រះសណ្តាប់ដូច្នោះ, ស្តេចគំលង់កំឮដំកិតភ័យជាខ្លាំងទើបចាត់ព្រះពជបំរើឲ្យទៅតាមរកអ្នកយើងអិកអី ។ អ្នកយើងកាលបើបានឮដំណឹងថា ស្តេចត្រូវការឲ្យទាយអំពីរបស់ដូចគ្នាយ៉ាងនេះ ក៏យល់ថាពុំអាចទាយត្រូវទេ ហើយសម្រេចចិត្តថានឹងទៅលោតទឹកសម្លាប់ខ្លួនជាជាង ។ តែដូច្នោះហើយ, អ្នកយើងក៏និមន្តទៅលោតទឹកទន្ទេសម្លាប់ព្រះអង្គមែន ។ ប៉ុន្តែ, ដល់លោតទៅធ្លាក់ទឹក, លោកក៏ឮកស្រឡាញ់ជីវិតលោកវិញ ហើយទំហែលទឹកទៅច្រះនឹងសំពៅចិន ក៏គោងនៅនឹងខ្សែយុថ្កាសំពៅ

នោះវិញ ។ នៅខណៈនោះ លោកបានស្តាប់ឮនាយសំពៅចិននិយាយថា ឥឡឹកដែលធំជាងគេមានគ្រាប់ប៊ី, ឥឡឹកធំល្មមមានគ្រាប់ពីរ, ឯឥឡឹកដែលតូចជាងគេបង្អស់ មានគ្រាប់តែមួយទេ ។

កាលបើបានឮដូច្នោះ អ្នកយើងក៏ត្រឡប់ហែលសំដៅទៅខាងហើយកំនិមន្តចូលទៅក្នុងវត្តវិញ ។

លុះថ្ងៃស្អែកឡើង, នាយសំពៅឡើងចូលទៅគាល់ស្តេចគំលង់យកតាំងឥឡឹកប៊ីនោះទៅជាមួយផង ហើយទូលរៀបរាប់អំពីបេសកកម្មដែលស្តេចក្រុងចិនបានទ្រង់ចាត់គាត់ឲ្យមកកាន់ពីនេះ ។ ក្រោយពីទ្រង់ព្រះសណ្តាប់ការក្រាបទូលនៃនាយសំពៅហើយ ស្តេចគំលង់ទ្រង់ភ័យញាប់ញ័រក្នុងព្រះចិត្តជាក្រៃលែង ទ្រង់ចាត់ព្រះកជបំរើឲ្យទៅនិមន្តអ្នកយើងអាកអី ។ កាលអ្នកយើងអាកអីនិមន្តមកដល់, ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូល ទូលរឿងហេតុនោះដល់អ្នកយើងភ្លាម ហើយទ្រង់គ្រាស់បង្គាប់ឲ្យលោកធ្វើយតាមហេតុការណ៍នោះ ។ អ្នកយើងមានពុទ្ធដីការហៅអាមោកទំនិអាតាំងជាភ្លូនសិស្ស ឲ្យយកក្តារឈ្នួនទំនិដ៏ស ។ លុះបានក្តារហើយ អ្នកយើងក៏ធ្វើហាក់ដូចជាខំយកចិត្តពុះពារដាក់ខាងណាស់ រួចក៏ខាងយ៉ា កាលបើគេពុះឥឡឹកប៊ីនេះទៅ គេនឹងឃើញឥឡឹកធំជាងគេមានគ្រាប់ប៊ី, ឥឡឹកកណ្តាលមានគ្រាប់ពីរ, ទើបឥឡឹកតូចជាង

នេះបន្តិចសំមានគ្រាប់មួយ ។ នេះក៏ពុះផ្តួលកំពង់ចីនោះឡើង ហើយឃើញចំនួនគ្រាប់ពិតដូចអ្នកគ្រូយើងបានទាយមែន ។ តមក, នៅពេលដែលនាយសំពៅថ្វាយបង្គំព្រះពាលាត្រឡប់ទៅកាន់សំពៅ រួចលើកក្តោងបើកសំដៅត្រឡប់ទៅប្រទេសចិនវិញ, អ្នកយើងអាកអាកំនិមន្តត្រឡប់ទៅវត្តវិញដែរ ។

លុះកាលក្រោយបន្តិចមក, ព្រះមហាក្សត្រនៃប្រទេសសៀមក៏ទ្រង់ចាត់ទាលួងម្នាក់ ឲ្យបើកសំពៅកេត្រាបញ្ជូនពួកភ្ងេងនឹងពួកនាដការីជាច្រើនចូលមកទទួលអយុធ្យា, ដើម្បីនាំយកនាងសក់ក្រអូបទៅថ្វាយព្រះអង្គ ។

ទាលួងក៏បានបើកសំពៅមកឈប់នៅទៀបត្រៃ ជិតភ្នំព្រះបាទជាន់ដុំ ។ ក្រោយបន្តិចមក, គេលេងភ្ងេងកំប្រឹងពេញលើសំពៅមានរួចពួកទាលួងក៏ចាត់មន្ត្រីមានបណ្តាស័ក្តិម្នាក់ឲ្យចូលទៅក្រាបទូលសុំឲ្យស្តេចតំលង់ មានព្រះពាជបញ្ជាឲ្យវាយជូនទូលកេរ៉ែ ដើម្បីឲ្យអស់មន្ត្រីធំ-តូច ឥណាប្រជាទុកស្តួចទៅបានជីងបចូលគ្នាមកមើលល្ខោនដែលស្តេចក្រុងសៀម បាននាំយកមកលេងថ្វាយស្តេចទទួលស្រីអយុធ្យា ។ កាលបើបានឮសេចក្តីអញ្ជើញដូច្នេះ ព្រះនាងសក់ក្រអូបទ្រង់មានព្រះទ័យសោមនស្សជាក្រៃលែងនឹងយាងទៅទតរបាំនោះ ។ ដូច្នេះព្រះនាងក៏យាងចូលទៅ

សុំសេចក្តីអនុញ្ញាតពីព្រះស្វាមី, តែស្តេចតំលង់ឃ្លានទ្រង់ប្រកែកជាងាប់ ខាតមិនព្រមឲ្យព្រះនាងយាងទៅទតមហាស្រព ។ ព្រះទេពីក៏ទ្រង់ព្រះវិតក្កអផ្សុកក្រៃលែង, ទើបទៅពេលពាក់កណ្តាលអាធ្រាត្រ ព្រះនាងទ្រង់ត្រាស់ហៅស្រីស្មំក្រមការ, យាងចេញពីមហាប្រាសាទ, ទៅគង់លើសំពៅចក្រសំដៅ ៧កាន់សំពៅខាលួង ។ អាស្រ័យដោយហេតុដូច្នេះទើបព្រះនាងបានយាងទៅទតមហាស្រពសៀមដោយសេចក្តីរីករាយ ។

លុះដល់មាន់រងាវខៀបភ្លឺ នោះពេលដែលពួកភ្លេងកំពុងតែបញ្ចេញសិល្បៈបម្រើខ្លួនយ៉ាងប៉ិនប្រសប់ ខាលួងក៏លបស្រាយពួរលើកយុថ្កាសំពៅចក្តាងសំដៅទៅប្រទេសសៀម ។ ព្រះនាងសក់ក្រអូបតំរាតែបានទ្រង់ជ្រាបថា គេបានចក្រសំពៅសំដៅទៅប្រទេសសៀម, ពេលវេលាក៏កន្លងផ្តុលហួសអស់, ទើបព្រះនាងទ្រង់ស្រែកផ្តែផ្តាំលាព្រះនគរលាព្រះស្វាមី, លាព្រះពជបុត្រទីងពួកស្រីស្មំតាំងឡាយដែលពុំបានទៅជាមួយព្រះនាង ។

លុះព្រះនាងមានព្រះសារទីយ៍ផ្តែផ្តាំចប់, ខាលួងបង្គាប់ឲ្យពួកភ្លេងលេងបន្តែផ្តាំផ្ញើ ហើយទៅពេលដែលគេកំពុងប្រគំបទខាងក្រោយនេះសំពៅក៏បានលឿនទៅមុខ, នាំព្រះនាងយកទៅថ្វាយព្រះចៅក្រុងសៀមដែលកំពុងគង់រង់ចាំជាយូរមកហើយ ដោយសេចក្តីអន្ទះអន្ទែងឥតឧបមា;

លុះព្រះនាងបានយាងទៅដល់ដែនដីសៀមកាលណា, ស្តេចស្រុកសៀម
តំលើកព្រះនាងធ្វើជាព្រះអគ្គមហេសីមួយ, ហើយឃាត់ឃាំងព្រះនាង
ទុកនៅក្នុងឥន្ទមហាប្រាសាទអស់ពេលជាច្រើនឆ្នាំ ។

សូមដំណាលពីព្រះបាទចាយង្គោរវិញ នៅពេលដែលខាលួងបានលួច
ចាប់ដោយកលល្បិចយកព្រះនាងសក់ក្រអូបជាព្រះវរមាតា ទៅឃុំឃាំង
ទុកនៅស្រុកសៀមនោះ, ព្រះអង្គទ្រង់មានព្រះជន្មាយុបាន២០ឆ្នាំហើយ ។
នៅពេលនោះ ព្រះអង្គម្ចាស់ក៏ទ្រង់មានព្រះបន្ទូលសួរទៅព្រះវរបិតាថា
ព្រះមាតាគង់នៅឯណា ? ។ ព្រះបិតាទ្រង់មានព្រះបន្ទូលប្រាប់ថា ព្រះ
មាតាត្រូវខាញ់កលល្បិចខាលួង, ខាលួងបានចាប់នាំយកទៅថ្វាយស្តេច
ក្រុងសៀមបាត់ទៅហើយ ។ កាលបើទ្រង់ព្រះសណ្តាប់ព្រះបន្ទូលព្រះ
បិតាចប់ហើយ, ព្រះអង្គម្ចាស់ប៉ាយង្គោរនឹកតូចព្រះទ័យជាក្រៃលែង,
ក៏ទ្រង់ក្រាបបង្គំសុំអនុញ្ញាតព្រះបិតា ដើម្បីលើកទ័ពទៅប្រាំងនឹងនគរ
សៀមដណ្តើមយកព្រះមាតាមកវិញ ។ ព្រះកាទ្រង់យល់ព្រម ហើយ
ប្រដុំកងទ័ពចាំងអស់នៅក្នុងស្រែ ខាងកើតក្នុងព្រះបាទជាន់ដុំ ។ កងទ័ព
នោះមានចំនួនចាំងអស់ប្រហែលជាមួយម៉ឺនស្រែ គឺបានសេចក្តីថាកងទ័ព
ស្ថិតនៅត្រៀបត្រាលើផ្ទៃស្រែចំនួនមួយម៉ឺន (រាល់ ១ ម៉ឺនស្រែ) ។

បន្ទាប់មក, ព្រះអង្គម្ចាស់ប៉ាយង្គោរទ្រង់បញ្ជាកងទ័ពតម្រង់ទៅ

ថ្ងៃខែរសៀម, ក៏យប្រហារទ័ពសត្រូវហើយចាប់បានស្តេចរសៀម, រួចក៏ធ្វើគត់ទៅ ទើបលើកកងទ័ពវិលសម្រុកចូលសំដៅទៅព្រះពជ្ជាទី, ដណ្តើមយកបានព្រះនាងសក់ក្រអូប, ដែលទៅតែមានព្រះសម្រស់ល្អជាដែល, មានតែល្អលើសពេលមុនរសៀមចាប់យកទៅទៀត ។ ប៉ុន្តែព្រះអង្គម្ចាស់តតបានស្គាល់ព្រះនាងសក់ក្រអូបថាជាព្រះមាតាទេ, ក៏ទ្រង់រួមរក្សារស្នេហាជាមួយព្រះនាង ហើយនាំព្រះនាងមកព្រះនគរធ្វើជាមហេសី ទៅ ។ លុះយាងមកដល់ព្រះនគរវិញ, ព្រះអង្គម្ចាស់បានចូលទៅក្រាបទូលពតិមានដល់ព្រះបិតា អំពីដំណើរនៃបេសកកម្មដែលព្រះអង្គបានបំពេញដើម្បីសងសឹកស្តេចក្រុងរសៀម, ព្រះវរបិតាក៏ទ្រង់ជាក់ជ្រះ, ហើយទ្រង់ប្រគល់ពជសម្បត្តិទាំងអស់ ក្នុងព្រះពជអាណាចក្រទាំងមូលឲ្យព្រះពជបុត្រ ។

លុះពេលកន្លងក្រោយបន្តិចមក ព្រះនាងសក់ក្រអូបទ្រង់បានសង្កេតមើលព្រះកេសព្រះបាទបាយង្គោរជាព្រះស្វាមី, ឃើញសញ្ញាមួយដែលធ្វើឲ្យព្រះនាងស្គាល់ ហើយនឹកឃើញថា ព្រះស្វាមីព្រះនាង គឺជាព្រះពជបុត្រព្រះនាង ។ ព្រះនាងក៏មានព្រះសទ្ធាយ៉ាងខ្លាំងនោះប្រាប់ព្រះអង្គម្ចាស់ ។ ទ្រង់មានព្រះបន្ទូលកប់រៀបទូលព្រះនាងសក់ក្រអូប អំពីហេតុបណ្តាលឲ្យព្រះអង្គលើកទ័ពទៅធ្វើសង្គ្រាមជាមួយនឹងប្រទេសរសៀម ។

អាស្រ័យហេតុនេះ, ព្រះទេពីកំទ្រង់ស្គាល់ព្រះអង្គម្ចាស់ថាជាព្រះរាជបុត្រតិតប្រាកដ ។ ព្រះនាងកំទ្រង់ព្រះកន្សែងរៀបរាប់ប្រាប់ព្រះរាជបុត្រអំពីរឿងហេតុផ្សេង ។ ដែលបានកើតមានឡើងចាប់តាំងពីថ្ងៃដែលក្រុងសៀមបានចាប់ព្រះនាងយកទៅ ។ ព្រះបាទចុយង្គោរបានឮព្រះមាតាមានព្រះសារីរយ៍ដូច្នោះ, កំទ្រង់តិតក័យជាក្រៃលែង ហើយដោយទឹកចិត្តលាងបាបដែលព្រះអង្គបានប្រព្រឹត្តអំពើពុតប្បី, ព្រះអង្គកំទ្រង់សាងព្រះចេតិយ ១០០០ ទីស្រះ ១០០០ (ស្រះអង្គត្រាំង) ។ ព្រះវរបិតារបស់ព្រះអង្គទ្រង់បានដាក់ទំនាយថា ព្រះរាជបុត្រព្រះអង្គនឹងចាកចេញផុតពីស្ថាននេះមកវិញបាន លុះត្រាតែចេតិយទីស្រះទាំងឡាយរលាយបាត់អស់ហើយគេយកឥដ្ឋនឹងទាំងនោះ ធ្វើជាស្រែសម្រាប់ដាំស្រូវទៅវិញ ។ អាស្រ័យហេតុដូចបានពាក់រៀបមកនេះហើយ, បានជាទៅកន្លែងខ្លះមានឈ្មោះដាប់រហូតមកដល់សព្វថ្ងៃនេះដូចជាឈ្មោះថា ស្រែវាល់ពស, ត្រាំងស្រង់ ទីឆ្ងាយភ្លា ។

កាលចេសង់ព្រះចេតិយ ទីឆ្ងាយរួចស្រេចហើយ, ព្រះបាទចុយង្គោរកំទ្រង់ចាត់ព្រះរាជប្រតិភូ ឲ្យចូលទៅដណ្តឹងព្រះរាជបុត្រីព្រះបាទអង្គរបូរីធ្វើជាមហេសី ប៉ុន្តែព្រះបាទអង្គរបូរីទ្រង់ប្រកែកពុំព្រមឲ្យដោយទ្រង់មានព្រះបន្ទូលថា ព្រះបាទចុយង្គោរទ្រង់មានទោសធ្ងន់

ណាស់ ។ ព្រះបាទបាយង្គារនឹកតបចិត្តព្រះទ័យជាខ្លាំងក៏លើកទ័ពចេញទៅ
ច្បាំងតតាំងនឹងស្តេចអង្គរបូរីដើម្បីដណ្តើមយកព្រះរាជបុត្រ ប៉ុន្តែត្រូវ
បរាជ័យហើយត្រឡប់ទ័យឆាងត្រឡប់មកព្រះនគរវិញ , អាស្រ័យហេតុនេះ
ហើយ , បានជានៅត្រង់កន្លែងមួយជិតទីរាសមរភូមិនោះ គេហៅថា
ច្រកអូរឈាម ។

ហឿងត្រែងប្រទេសវៀណាហ្សួយអេឡា (១)

បែងអ៊ំពីបម្រៀងទី១

តកូ ម៉ែន-រៀម

សិស្សវត្តទ្វីតមហាវិទ្យាល័យព្រះសីហនុពជ

ប្រែជាភាសាអង់គ្លេស

សម័យមួយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់មានព្រះពជបុត្រ ៣ ព្រះអង្គ ព្រះនាម ប៉ែង្រ, ហ៊ីយអាន និងហ៊ីយសេ ។ ពេលមួយនោះ ព្រឹត្តិការណ៍បានកើតឡើងដល់ព្រះអង្គ បណ្តាលឲ្យចក្ខុវិញ្ញាណរបស់ព្រះអង្គ ខន់ខ្សោយចុះបន្តិចម្តង ។ ដរាបដល់ទ្រង់ឆ្ងឹតលែងឧតម្ល៉ឺយញ៉ ។ ពេលដ៏ជំនាញ។ ទាំងឡាយក្នុងប្រទេសរបស់ព្រះអង្គ បានខំជួយព្យាបាលណាស់ដែរ តែអ្នកទាំងនោះមិនអាចធ្វើអ្វីកើតឡើយ ។

ទីបំផុត, វេជ្ជបណ្ឌិតម្នាក់ទូលព្រះអង្គថា ដើម្បីព្រះចក្ខុរបស់ព្រះអង្គនោះ មិនមានចំណុះដល់ថ្នាក់អាចកិច្ចាការនៅឡើយទេ, មានឧសថមួយដែលវិកាតពីផ្កាអូលីវ អាចព្យាបាលឲ្យជាបាន ។

កាលទ្រង់ឮពាក្យនេះ, ទ្រង់សប្បាយព្រះទ័យពន់ពេក ។ ប៉ុន្តែ

១- នៅអាមេរិកខាងត្បូង ។

គេលនោះ ព្រះរាំតើងថា តើអញនឹងកក្តាអូលីវតែមួយណា ជាន ? ចើប្រទេសបេះអញគ្មានដើមអូលីវសោះយ៉ាងនេះ ! ”

ដោយសេចក្តីអស់សង្ឃឹម, ព្រះអង្គជាន់ហៅព្រះរាជបុត្រទាំង ៣ មកប្រាប់តីរឿងសេចដែលត្រូវកើតគ យកមកពន្យាបាលព្រះទ័យទ្រង់ឲ្យជាជាន ចើប្រសិនណាជាជាន ផ្តាអូលីវមួយមុខមកថែមទៀត ។ គេលនោះទ្រង់សុំឲ្យព្រះរាជបុត្រទាំង ៣ អង្គនោះ ជួយទ្រង់កងរឿងនេះ ។

ក្រោយណានោះ, ព្រះអង្គម្ចាស់ចើដ្រូ ជាព្រះរាជបុត្រច្បង ទ្រង់ថ្វាយបង្គំទៅកាន់ព្រះបិតាថា :

– « ខ្ញុំព្រះអង្គសូមទទួលការៈ ទៅកក្តាអូលីវនោះ; ប៉ុន្តែការដើរត្រូវចំចែកន្លែង ក្នុងការស្វែងរកយ៉ាងនេះ ត្រូវចន្ទីភាគសោហ៊ុយច្រើន ដូច្នេះ សូមព្រះបិតាមេត្តាព្រះរាជទានមតិក ជាចំណែកខ្ញុំព្រះអង្គនោះមក ខ្ញុំព្រះអង្គនឹងចាប់ផ្តើមធ្វើដំណើរស្វែងរកឥឡូវនេះ» ។

ព្រះមហាក្សត្រ ជាន់ព្រះរាជទានមតិកនោះតាមពាក្យសុំ, ជាន ហើយព្រះអង្គម្ចាស់ចើដ្រូ ក៏ទ្រង់ត្រាច់ចេញទៅ ។ ព្រះរាជបុត្រនេះជាន ធ្វើដំណើរចេញទៅឆ្ងាយ រួចជាន ជួបស្ត្រីចាស់ម្នាក់ អង្គុយសុំទាន ទៅលើចិញ្ចើមថ្នល់ ។ ប៉ុន្តែ ព្រះអង្គម្ចាស់ចើដ្រូ មិនជានជាអ្នកមានចិត្តសប្បុរសទួលចំណូលយេ, ទ្រង់ប្រកែកមិនព្រមជាក់ទានអ្វីបន្តិច

ឲ្យយាយយាចកនោះសោះឡើយ ។ ព្រះអង្គម្ចាស់ចេះតែបន្តព្រះដំណើរ
ទៅមុខទៀត ខ្ពោះទៅរកឥដ្ឋដែតែមួយ គឺស្ទូងរកផ្លាអូលីវនោះឯង ។
សប្តាហ៍ ទំនែ្ងថាច្រើន ចេះតែកន្ទុងទៅ ។ ព្រះអង្គម្ចាស់នៅតែ
រកផ្លាអូលីវ មិនទាន់បាន ។

ព្រះមហាក្សត្រ ដោយបាត់ព្រះរាជបុត្រច្បងអស់កាលយូរ មិន
ឃើញត្រឡប់លែវិញដូច្នោះ, ទ្រង់ត្រាស់ហៅព្រះរាជបុត្របន្ទាប់ព្រះនាម
ហ្ស៊ុយអាន; មកហើយ ទ្រង់បង្គាប់ឲ្យចេញដំណើរ ទៅស្ទូងរកផ្លា
អូលីវនោះទៀត ។ ព្រះអង្គម្ចាស់ ហ្ស៊ុយអាននេះ បានសុំមតិកជាចំ
ណែកទ្រព្យចំនួនពាក់កណ្តាល រួចទ្រង់ធ្វើដំណើរចេញទៅ ។ នៅលើ
ច្រាំងភ្នំមួយ, ទ្រង់បានជួបនឹងយាយយាចក ដែលអង្វរយកទាននោះ
ទៀត ។ ដូចព្រះរៀមព្រះអង្គដែរ, ព្រះអង្គម្ចាស់នេះ បានប្រែកែក
មិនព្រមដាក់ទានអ្វី ឲ្យយាយអត់ឮនោះទេ គឺតែទ្រង់ធ្វើដំណើរទៅ
មុខទៀត ។ ទ្រង់ត្រាច់ទៅត្រប់ទិសទី, ពិនិត្យមើលទេសភាពដោយ
ចក្ខុទ្រង់ តែមិនបានប៉ះព្រះនេត្រ ទំនឹងដើមអូលីវនោះឡើយ ។ សប្តាហ៍
ជាច្រើន ក៏ចេះតែកន្ទុងទៅ ។ ។

កាលដែលព្រះរាជបុត្រទៅព្រះនាមហ្ស៊ូសេ មិនឃើញព្រះជង្ឃ
ទាំងខ្វេរបស់ទ្រង់ រំលែត្រឡប់មកវិញដូច្នោះ ហើយដោយព្រះចក្ខុកោត

របស់ព្រះមហាកស្សបជាព្រះបិតាទ្រង់ ចេះតែមានដំណើរមិនស្រួលរាល់ ។ ថ្ងៃមួយនោះ, ទ្រង់ចូលទៅទូលព្រះមហាកស្សបជាព្រះបិតាថា ៖

- " សូមព្រះបិតា មេត្តាប្រសិទ្ធពរជ័យមកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងលាចេញទៅរកផ្កាអូលីវនោះ ដើម្បីគាល់ព្រះចក្ខុព្រះបិតាឲ្យបានជាឆាប់ ! " ។

ព្រះមហាកស្សប បានប្រទានពរសំដែងសាធុការដល់ព្រះរាជបុត្រទៅ រួចហើយព្រះរាជបុត្រនេះ ក៏ចាប់ផ្តើមធ្វើដំណើរចេញទៅ ។ ព្រះអង្គធ្វើដំណើរទៅឆ្ងាយ ឆ្ងាយទាល់តែបានទៅដល់កន្លែងស្ត្រីចាស់ ដែលអង្គុយសុំទាននោះឯង ។ ព្រះអង្គមានសេចក្តីអាណិតស្រឡាញ់ណាស់ ដោយមេត្តានឹងករុណា ចំពោះខុតិតកាពរបស់យាយកំសត់នោះយ៉ាងក្រៃលែង ទ្រង់ពោលទៅកាន់យាយខុតិតថា ៖

- " យាយ ! ខ្ញុំគ្មានប្រាក់ដូនយាយទេ, តែខ្ញុំនឹងចែកអាហារដូនយាយពិសារ ដោយសប្បាយចិត្ត, " ។

ពោលរួចហើយ ទ្រង់ស្រាយស្បៀងចេញ រួចដូនអ្វីដែលមានក្នុងស្បៀងនោះចំនួនពាក់កណ្តាល ទៅយាយអភ័ព្វ ។ អ្នកចាំងព័ន្ធប្រាណ បានអង្គុយបរិភោគជាមួយគ្នា រួចទ្រង់បានព័ន្ធប្រាប់រឿងសែនវេទរបស់ទ្រង់ ដល់យាយនោះ ។

ដូនចាស់ គោលតបថា

- " ចៅអើយ ! អ្នកណា អាចរកដើមអូលីវក្នុងប្រទេសនេះបាន ! " ។

ព្រះអង្គម្ចាស់ បានឮក់ព្រះសំរេងការយល់ស្រប ។ ប៉ុន្តែនៅពេលដែលយាយបង្ហើយកិច្ចបរិកោគរួចហើយ, គាត់មានប្រសាសន៍បន្តទៅទៀតថា ៖

- « យាយសូមប្រាប់ចៅឯង ឲ្យស្គាល់កន្លែងដែលមានដើមអូលីវនោះដុះ ។ ចំនួនជាច្រើនម៉ែល(១)ទៅខាងលិចឯណោះ, មានភ្នំមួយ, ឡើងតាមជំហរលើកខាងកើតនៃភ្នំនោះទៅ, មានព្រៃដង្កឹមួយ ពេញទៅដោយដើមអូលីវ; នៅទីនោះ ចៅឯងមុខតែបានឃើញផ្កាអូលីវដោយពិត » ។

ពេលនោះ អ្នកទាំងពីរបានបែកគ្នា ព្រះអង្គម្ចាស់ហ៊ីរ៉ូសទ្រង់យាងត្រង់ទៅទិសខាងលិច ដរាបដល់ភ្នំនោះឯង ។ ទៅតាមចំណោតភ្នំបែកខាងកើត ទ្រង់បានឃើញដង្កៀព្រៃអូលីវមានផ្កាកែស្គុះស្គាយដូចពាក្យយាយទុតិតប្រាប់មែន ។ ព្រះអង្គមានព្រះទ័យរីករាយយ៉ាងខ្លាំង, បានបេះផ្កាអូលីវនោះ រួចនាំយកត្រឡប់លៃទៅជានីព្រះបិតាវិញ

(១) ១ ម៉ែល ១៦០៩ ម៉ែត្រ ។

យ៉ាន៎រួសរាន់ ។

នៅឯមន្ទីរ ទ្រង់ចាន់ជួបព្រះរាជ្ញាទាំងពីរបស់ព្រះអង្គ ដែលមិនអាចស្វែងរកផ្កាអូលីវបាន សូម្បីមួយខ្សែឡើយ ។ ជំនួសសេចក្តីរីករាយចំពោះព្រះកនិដ្ឋារបស់ព្រះអង្គ ដែលបានជោគជ័យក្នុងការស្វែងរកផ្កាអូលីវ, ព្រះរាជ្ញាទាំង ២ នោះ ទៅជាមានរសេចក្តីប្រណាំនចំពោះការបំពេញកិច្ច បានសំរេចនេះទៅវិញ ។ ក្នុមនោះ ទ្រង់ទាំងពីរកំដណ្តើមផ្កាអូលីវ អំពីប្អូន ហើយកាលដែលទ្រង់ដណ្តើមនោះ ទ្រង់ទាំងយប្អូនយ៉ាន៎ដំណាំ ជាបដល់ដួលចុះទៅលើផែនដី, បាត់ព្រះវាចាលែងមានចលនាតទៅទៀតបាន ។

ភ័យចំពោះអំពើលាមក ក្រែងគេដឹង្ឍ, ព្រះរាជបុត្រច្បងទាំងពីរបានតាយដីតបំប្អូនទៅនោះក្បែរមាត់ផ្លូវ រួចប្រញាប់ប្រញាល់ឆ្ពោះទៅដំណាក់ព្រះបិតាព្រះអង្គ ។

ព្រះមហាក្សត្រ, កាលបើជ្រួ ឥន្ធិហ្ស៊ុយអាន ជាព្រះរាជបុត្រច្បងទាំងពីរ បានត្រឡប់មកវិញ យកទាំងផ្កាអូលីវមកជាមួយផងដូច្នេះ, ព្រះអង្គសោមនស្សយ៉ាន៎ក្រៃលែង ។ ពេលនោះ ចក្ខុប្រសាទព្រះមហាក្សត្រ ត្រូវរៃដួចណ្តើតឡាចុលឲ្យជាល្អវិញដូចដើម, ខ្ញុំះហើយមហាកត្តិយស ក៏បានភ្ជាក់មកលើព្រះរាជបុត្រច្បងទាំងពីរនោះ ។ តែ

ដោយព្រះពាជបុត្រទៅបង់ព្រះអង្គ មិនឃើញត្រឡប់វិលវិញ ហើយ
ចេះតែបាត់ទៅ ។ នោះ, ព្រះទ័យព្រះមហាក្សត្រ តេញវិលទៅ
ដោយសេចក្តីទុក្ខត្រួយពាល់វិលា ។

នៅលើទីដែលព្រះអង្គម្ចាស់ ហ៊ុយអាន ឧងបែជ្រូ កប់ប្អូនទៅព្រះ
អង្គនោះ, វត្តចម្ការមួយ បានកើតឡើង ។ ដើមប្រចុះសាំងឡាយ
បានដុះចេញមកគ្រាំ ចំពីលើផ្នូរនោះ ។

ថ្ងៃមួយ អ្នកតង្វាលចៀមម្នាក់ បានដើរកាត់តាមទីនោះ ស្រាប់
តែឮសម្រែកក្មេង ផ្សាយចេញពីដើមប្រចុះសាំងនោះមក ។ គាត់
ប្តូលទៅជិត រួចផ្ទៀងស្តាប់, ចម្រៀងនៃប្រុសតំណែះ បានហ៊ោចេញមក
យ៉ាងពីរោះថា ៖

ឧបាធ – ឃ្វាលចៀមផ្ទុំខ្ញុំមក ! . . .

ដើម្បី – ខ្ញុំយកអំណោយស្តី . . .

ថ្ងៃឯក្រាប់ – រឿងពិតតាមសេចក្តី

ជលជនប្រុសស្រីពីផ្កាអូលី ! . . . » (១) ។

ឮពីរោះដូច្នេះ, អ្នកតង្វាលចៀម តំណាត់យកប្រចុះនោះមួយដើម

---

(១) បទនេះ, បើអ្នកអាន ចេះបទសម័យថ្មីណែះ «ផ្កាលីលាត្រី» អាចមើលត្រូវ
តាមសង្វាក់ឥតខ្ចោះ ។

មកធ្វើជាខ្ញុយ ។ កាលណាគាត់ផ្ដុំខ្ញុយនោះ ចម្រៀងដ៏តាំពេះ កំដរ
ដោយបទភ្លេងដដែលនោះ កំលាន់ចេញមកដូចមុន ។ អ្នកតង្វាល
ចៀម តែងគ្រាច់ទៅគ្រប់ទីកន្លែងក្នុងប្រទេស ជាមួយនឹងខ្ញុយដ៏វិចិត្រ
របស់គាត់នោះ, ម្ចាស់ហើយ ជនគ្រប់ដំបន់ បានស្ដាប់ហើយចាប់ចិត្ត
ចំពោះចម្រៀងខ្ញុយនោះគ្រប់គ្នា ។

តិត្តិនាមនៃខ្ញុយ បានផ្សាយទៅគ្រប់ទីកន្លែង, ជ្រោះរហូតដល់
ព្រះមហាក្សត្រ ជាហេតុឲ្យព្រះអង្គ ចង់ស្ដាប់ចម្រៀងដ៏ចំឡែកនោះ ។
គ្រានោះ អ្នកតង្វាលចៀម បានត្រូវព្រះមហាក្សត្រ បង្គាប់ឲ្យ
ចូលខ្លួនទៅគាល់ ដើម្បីផ្ដុំខ្ញុយថ្វាយទ្រង់ព្រះសណ្ដាប់ ។ គាត់បាន
ចូលខ្លួនទៅឈរពីមុខព្រះភក្ត្រព្រះមហាក្សត្រ, រួចហើយ គាត់កំលើក
ខ្ញុយមកផ្ដុំ ថ្វាយទ្រង់ព្រះសណ្ដាប់ដោយសុភាពរាបសារ ។ ចម្រៀង
នៃប្រុសកំព្លោះកំលាន់ចេញមកថា ៖

« ទ្រព្រះ - បិតាផ្ដុំខ្ញុំម៉ក ! . . .
ដើម្បី - ខ្ញុំយកអំណាចស្ដី . . .
ក្រាបទូលរឿងពិតតាមសេចក្ដី
ជាន់ជ្រាបតាមន័យផ្ទាអូលីវ ! . . . » ។

ចម្រៀកណាស់, ព្រះមហាក្សត្រ កំពុងគ្រាក់យកខ្ញុយនោះមកផ្ដុំ

ដោយព្រះអង្គឯង ។ គេលនោះ ព្រះអង្គឮច្បាស់ជាសម្ដែងហ៊ីរ៉ាសេ បុត្រតៅរបស់ព្រះអង្គ ទូលព្រះអង្គអំពីការដែលខ្លួនកេយើញផ្កាអូលីវ ទំងពីរតើដែលបុត្រឮងទាំងពីរបានវាយទ្រង់ រួចកប់ទ្រង់ក្នុងផ្នូរថ្ម ។

ដោយសេចក្ដីទុក្ខព្រួយ ទំងការគោរពតំងតប់ប្រមល់ព្រះហឫទ័យពេក, ព្រះមហាក្សត្រមិនបានឲ្យគេចាប់ខ្លួន បើ្រ ទំងហ៊ីរ៉ុយអាន តៅជាក់គុក ។ ភ្លាមនោះ ទ្រង់ក៏ចេញដំណើរឆ្ពោះតៅកន្លែងនៃព្រាជបុត្រតៅរបស់ព្រះអង្គ ។ កាលខាងបានរបស់ព្រះអង្គ បានកេយើញកន្លែងតើមែប្រជុំសនៅទីកន្លែងថ្ម់នោះហើយ កំជាកគាស់ដីត្រង់នោះ រួចបានយើញព្រះអង្គម្ចាស់ហ៊ីរ៉ាសេ ត្រង់ទីនោះមែន ។ ប៉ុន្តែ អព្ភូតហេតុ មិនទាន់ចប់នៅឡើយទេ, ព្រះអង្គម្ចាស់ហ៊ីរ៉ាសេ មិនទាន់សុគត ដូចដែលព្រះជង្ឃទាំងពីរស្មានទេ ។ ព្រះអង្គបានក្រោកឡើង រួចស្ទុះតៅឧបព្រះមហាក្សត្រជាព្រះបិតា ។ ទ្រង់ព្រះសំណេរ ដោយសេចក្ដីសប្បាយព្រះទ័យខ្លាំងពេក ។ គេលនោះឯង មានធ្វើពិធីបុណ្យ យ៉ាងធ្លាកេខ្លួលអំណរចំពោះការខិតខ្ពង់នៃព្រះពាជបុត្រតៅ ។

ដោយព្រះមហាក្សត្រ សប្បាយព្រះទ័យខ្លាំង ដោយហេតុបានជាសះសៀយនៃចក្ខុពេត ទំងការខិតខ្ពង់វិញ នៃព្រះពាជបុត្រតៅនោះ ព្រះអង្គបានដោះលែង ហ៊ីរ៉ុយអាន ទំង បើ្រ ចេញពីពន្ធនាគារវិញភោង ។

គួរដឹងទំនៀមខ្លះនៅប្រទេសឥណ្ឌូណេស៊ី

អ្នកស្រី ពេជ-សល់ នាមដើម សារ៉ះយ៉ាន់ ប្រែ

ត្រណឹមធំបំផុតនៅប្រទេសឥណ្ឌូណេស៊ី គឺមិនឲ្យពាល់ដល់មួក-ឈ្នួតក្បាល មុខ ឬ សក់នៃជនប្រុសស្រីឲ្យសោះ ។ ការពាល់ដូច្នេះជាការមើលងាយគេ ព្រោះថាក្បាលជាកំពូលធំហើយគេគោរពក្បាលណាស់ ប្រហែលគ្នានឹងទំនៀមខ្មែរយើងដែរ ។

បើអ្នកដើរទៅជួបនឹងមនុស្សស្រីដែលអ្នកស្គាល់, ការបើកមួកមិនមែនជាការចាំបាច់ទេ, ព្រោះអ្នកកាន់សាសនាមូយស៊ុលមាំនពាក់មួកជាដរាប; ប៉ុន្តែអ្នកត្រូវខ្មៅគោរពគេ ហើយចាប់ដៃស្តាំ ឬ យកដៃអ្នកទាំងពីរទៅចាប់ដៃស្តាំគេទៅវិញ ហើយពួកមូយស៊ុលមាំនច្រើនតែចំពេញការគោរពដោយយកដៃទាំងពីរមកជាក់នៅច្រមុះខ្លួនឯង ។

ពេលបរិភោគអាហារ, បើអ្នកជាម្ចាស់ផ្ទះ អ្នកមិនត្រូវឈប់បរិភោគមុនភ្ញៀវទេ ហើយមិនត្រូវលែងម៉ុនភ្ញៀវផង ។ ប៉ុន្តែបើអ្នកជាភ្ញៀវវិញ អ្នកត្រូវបរិភោគឲ្យរួសពន់ដើម្បីកុំឲ្យម្ចាស់ផ្ទះពិបាកចំអ្នក ។ បើអ្នកអញ្ជើញទៅពិសាបាយនៅស្រុកស្រែវិញ អ្នកត្រូវពិសាដោយផ្ទាល់ដៃ, ហើយម្ចាស់ផ្ទះកាលបើពុំទាន់ចាប់ផ្តើមសួរអ្នកជាមុនថាតើអ្នកលែងត្រូវការអ្វីទៀតហើយឬ ? នោះគេពុំហ៊ានលាដៃទេ ។ ឯចំណែក

អ្នកជាកូរីវិញ ត្រូវចាំឲ្យម្ចាស់ផ្ទះលាងដៃសិន សឹមលោងឆាមគ្រាយ
បើពុំនោះទេ គេថាអ្នកជាមនុស្សឥតច្បាប់ ឬថាមើលងាយគេទៀតផង ។

បើចង់ហុចអ្វីឲ្យគេ ត្រូវចៀសវាងកុំហុចដៃឆ្វេងឲ្យសោះ ប្រើដៃ
ឆ្វេងសំដែងការឥតច្បាប់ចំផុត ។ បើនិនិយាយទៅកាន់មនុស្សប្រុស
ចាស់ ទោះមនុស្សនោះហាន:ជាអ្វីក៏ដោយ (អ្នកបោសថ្នល់ អ្នក
សួមភាន អ្នកបំរើ នាយមន្ទីរ ឬរដ្ឋមន្ត្រី) អ្នកត្រូវហៅថា "ឪពុក"
ពាំងអស់ ឲ្យតែមនុស្សនោះចាស់ច្រើនជាងអ្នក ។ បើនិនិយាយ
ទៅកាន់ស្ត្រីវិញ ទោះស្ត្រីនោះជាអ្វីក៏ដោយក៏ត្រូវហៅ "ម៉ែ" វែរ ។

បើតាលណាត្រូវទទួលអ្នកធំ មនុស្សដែលទៅទទួលនោះ ស្រែក
ថា " មែរដើស ! មែរដើស ! ឬ ចាំមែរដេកា មែរដេកា ! ដែលបានន
សេចក្តីថា "ឪពុកអើយ ! សេដ្ឋាបាន" ។

ចំនោះស្ត្រីថ្ងៃ = ឧទាហរណ៍ដ៏ក្រុងដ៏ ហ្សាតាអា ឬ ស្ត្រីអំពី
កំពង់ចំណតនាវា ស៊ូព័ត្តយ៉ាំ ស្រីត្រមុំច្រើនពុំសូវគាន់ច្បាប់ឥណីណេ ។
ក្រៅអំពីពាក្យពាំងតាមលើនេះ អ្នកត្រូវប្រយ័ត្នកុំពោលពាក្យចៃចង់ស្រី
ដោយផ្ទាល់ឲ្យសោះ ព្រោះសាសនា អ៊ីស្លាមគេហាមដាច់ ប៉ើអ្នកធ្វើ
ដូច្នេះ មុខជាមានរឿងនាំឲ្យអាស់ជាពុំខាន ។

នៅក្រុងស៊ូម៉ាត្រា ដែលគេនិយមយកម្ហាយជាធំ ត្រូវកុំយក

ឈ្មោះឪពុកទៅហៅកូនគេឲ្យសោះ អ្នកហៅដូច្នេះហាក់ដូចជាជេរគេថា គេគ្មានគ្រូសារត្រឹមត្រូវ ប៉ុន្តែត្រូវយកឈ្មោះបងប្រុសរបស់ម្ដាយកូននោះទៅហៅវិញទើបប្រសើរ ហើយអ្នកកុំភ្លេចប្រគល់ឲ្យក្មេងនោះបន្ទិចបន្ទួចផង ។ នៅស្រុកនេះ ប្ដីគេទុកជាអ្នកបន្ទាប់បន្សំទេ ក្នុងមែកធាងនៃគ្រួសារគេ ។

បើអ្នកទៅសំណាក់ផ្ទះគេ ហើយនៅពេលដែលគេនាំអ្នកទៅបង្ហាញបន្ទប់ បើគេសួរអ្នកថា « អ្នកត្រូវការប្រពន្ធជាតិហ៊ុលដាំដេរឬទេ ? » នោះ អ្នកកុំស្មានថាគេនាំស្រីម្នាក់មកឲ្យអ្នកឲ្យសោះ, ពាក្យនោះគេសម្រាប់ហៅខ្ទើយនុបម្យ៉ាង ដែលខ្លះជារណបសម្រាប់កល់ខ្នងឯណើងអ្នក ឲ្យបានស្រួលប៉ុណ្ណោះទេ ។

អារ្យធម៌នៅក្រុងបាលី មានសភាពល្អិតល្អន់ពេកណាស់ ហើយពិបាកដល់ជនជាតិបែកជស្ថិមប្រទេសទៀតផង ព្រោះក្នុងស្រុកនោះមានចែកជនជាតពួកជាកង ប្រហែលគ្នានឹងនៅប្រទេសឥណ្ឌាដែរ ។

គោលធំបំផុត គឺយើងត្រូវតែដឹងខ្លួនថា តើយើងត្រូវបានបង្គាប់អង្គុយឬទេ ខ្លួនជាន់ណោកកំពស់ណា ។ ធម្មតាកូនស្រីរបស់ព្រាហ្មណ៍ត្រូវដេកខ្ពស់ជាងអ្នកបម្រើយ៉ាងតិចត្រឹម ១ ម៉ឺ ៩០ ។ បើដូច្នេះ គួរតែយើងរង់ចាំគេបង្គាប់បង្ហាញកន្លែងសិនសឹមកន្លុយឬទេ ខ្លួនជាន់ណោក ។

ចំពោះជនបស្ចិមប្រទេសវិញគេច្រើនតែឲ្យតំលៃខ្ពស់ជាងគេ ។ ក៏ប៉ុន្តែដើងម៉ា ជាទំនិញសំបុត្រ ដែលគេអាចជូនជាកិត្តិយសដល់អ្នកអង្គុយ ។

បើអ្នកឃើញស្រីក្រមុំក្តី ស្រីមានប្តីក្តី ស្រីចាស់ក្តី លែងដោះទេ អ្នកកុំស្មានថាគេលែងបញ្ចើរអ្នកឲ្យសោះ គឺជាធម្មតារបស់គេទេ ។ ស្រីអ្នកស្រែ បើគាល់ណាគេឃើញអ្នកហើយ គេចាញ់ក្រមាមកតំឡូក មិនមែនជាគេខ្មាស់អ្នកទេ, គឺគេគួរសមគំនាប់អ្នកហើយ ។ ប៉ុន្តែ បើចូលទៅប្រជុំវិញ ស្រីស្រុកចាស់តែងសំលៀកបំពាក់ណាស់ ។ បើអ្នកទៅលេងផ្ទះគេ ចូរអ្នកកុំភ្លេចយកវេរបស់អ្វីបន្តិចបន្តួចទៅជូនគេជាការគួរសមផង ព្រោះជនជាតិចាស់ពាន់ការឲ្យគ្នាណាស់ ហើយតែកាលណាអ្នកមានការទាក់ទងនឹងជីតជីតនឹងគេហើយ. . . មុខជាគេជូនវេរបស់អ្វីដល់អ្នកជាពុំខាន ។ ប៉ុន្តែ ចូលអ្នកប្រយ័ត្ន ! កុំយកផ្ការដែលជាក់ថ្លៃវេរបស់នោះចេញឲ្យសោះ គេខ្លួលអំណោយដោយសប្បាយចិត្ត ទឹងបានដឹងតម្លៃតៃរបស់អ្នក ហើយគេនឹងបានលែលកយកមកជូនអ្នកវិញ ឲ្យបានប្រសើជាងបន្តិចផង ។

បើអ្នកឃើញស្រី ។ លែងដោះទេ អ្នកកុំសង្ឃឹមថានឹងបានចំណេញអ្វីក្រៅពៀត ហួសអំពីការដែលគ្រាន់តែបានមើលទេនោះ

ឡើយ ព្រោះលែងតែជាមួយនឹងស្រីក្នុងមាស ។

បើអ្នកចង់បានរតន លុះត្រាតែអ្នកមានគំនិតខ្ជិលត្រឹមត្រូវ ហើយអ្នកជម្ពើងគេការទៅ ពេលនោះអ្នកចង់ការប្រពន្ធប៉ុន្មានក៏បាន ចង់បានអ្នកបំរើប៉ុន្មានក៏បាន ។

បើគេអញ្ជើញអ្នកទៅបុណ្យខ្មោច ជូរអ្នកចៀសវាងកុំធ្វើទឹកមុខស្រះញាន ព្រោះបុណ្យខ្មោចជាបុណ្យដែលគេត្រូវសប្បាយ ហើយនឹងត្រូវបង្ហាញសេចក្តីក្រៀវក្រាំជាទីបំផុត ។ ប៉ុន្តែ បើគេអញ្ជើញអ្នកទៅបុណ្យខ្មោចឆ្លងជនដែលនៅ «តាណាគន» ដែលជាកូមិនៅលើភ្នំវិញនោះ អ្នកមុខជានឹងត្រូវគេឲ្យបរិភោគជាយ ដែលចំអិនដោយទឹកដែលយកមកពីស្រាចលើខ្មោច រហើយត្រង់យកពីក្រោមមួសពុំខានឡើយ ។ គេបរិភោគដូច្នេះ ដើម្បីឲ្យបានទទួលនូវគុណសម្បត្តិរបស់បុគ្គលនោះ ។

(ចាកនិបាតជាតក.បកិណ្ណកនិបាត)

ដោយ ហេង-សមអាន

សាមគ្គីជាកម្លាំង

ចទព្រហ្មគីតិ

ក្នុងកាលដំបូរយោរ　　នៅក្រុងពារាណសី
កាលនោះមានវត្តក៏(១)　　ទំហ្មាតខ្ចីចរលើលា ។
ចូលព្រៃរកកាប់ឈើ　　យកមកធ្វើកិច្ចនានា
ជួបកូនក្រុកកំព្រា　　ញ៉ាំរ៉ាំកន្លះណ្តើ ។
ជាងឈើបានឃើញហើយ　　ពុំកន្ទើយចរចុះទៅ
លើកចេញពីរណ្តៅ　　នាំយកទៅទុកឯផ្ទះ ។
ចិញ្ចឹមឲ្យបានយូរទឹក　　ទាំងយាច់ព្រឹកមិនឲ្យខ្វះ
ក្រុកធាក់ធំរហ័ស　　ឲ្យឈ្មោះតច្ចកៈប្រសើរ ។
ក្រុកជួយធ្វើកិច្ចការ　　ប្រមៀលក្តារនឹងអូសឈើ
តាមការសព្វសារពើ　　ដែលគាចធ្វើបាននោះណា ។
ជាងឈើគាត់គាណិត　　គិតក្នុងចិត្តម្នាក់ឯងថា

១– ជាងឈើ ។

"ចើមកជ្រូកនេះណា រនាំខ្ញុំនេះលុះយូរៗទៅ ។
ក្រែងមានមនុស្សល្អចាប់ កាប់សម្លាប់នាំហ្មងសៅ
គួរតែអញនាំទៅ លែងព្រៃជ្រៅទើបបានសុខ" ។
នាំជ្រូកធាប់រៃ ចូលកងព្រៃធំជ្រៅស្ងាត
លែងជ្រូកឲ្យដើរក្រុក រើរកសុខតាមចិត្ត ។
ជ្រូកដើរតែឯកឯង វែងចំងៃឯកងព្រឹក្សា
បានជួបហ្វូងសុកពា កំពោលថា "អឺ! ពួកក្រុម ! ។
ពួកយើងដើរស្វែងរក ញាតិតាមញាកច្រកល្អាកភ្នំ
តាមព្រៃព្រឹក្សតួចធំ កំឯខ្ញុំស្វែងរកញាតិ ។
គ្រាន់ខំឯងបានពីឯពួន ឥឡូវជួនជួបនឹងជាតិ
ជាក្រុមស័ង្គមញាតិ ដូចចំណងខ្ញុំប្រាថ្នា ។
ម៉ែមឈើមានតគោក បរិភោគតាមចិត្ត
មានទឹកស្រះរងឹថ្លា ជាកន្លែងគួររីករាយ ។
យើងនឹងបានក្សេមក្សាន្ត សុខសាន្តគ្រាណាសែនសប្បាយ"
ឮហើយជ្រូកពាំងឡាយ មិនខ្វល់ខ្វាយប្រាប់ទៅថា ។
"តួកៈ! អ្នកចូរទៅ រកលំនៅទៀតចុះណា
នៅនេះមិនសុខា មានសត្រូវទៀតចៀនត្រួម ។

ចាប់ជ្រូកស៊ីកលាំថ្ងៃ　　មិនសំចៃគាំងតូច-ធំ»

តុក្កៈស្ងួតក្រែងក្រម　　ថា «ប្រាប់ខ្ញុំនរណាអេះ ? ។

អង្គីអាចគាចយោរយៅ　　ជាសត្រូវនៅទីនេះ

ញាំញីអ្នកដល់ម្ល៉េះ　　ឲ្យរបេះសង្គ្រាមជាតិ ? ។

ដែលរួមគ្នាជិតស្និទ្ធ　　ចិត្តគំនិតមិនរវាត

ចូរប្រាប់អ្នកពិឃាត　　ឆាប់ៗមកកុំតក់ស្លុត ? » ។

ហ្វូងជ្រូកប្រាប់ទៅថា　　«នែអ្នកគ្រូហានមោះមុត

មានខ្លាធំបំផុត　　ចង្រ្កមមុតគាចគេកក្រៃ ។

វាមកចាប់ជ្រូកស៊ី　　នៅកន្លែងនេះពាលាំថ្ងៃ »

តុក្កៈប្រាប់ថា «ម្នៃ　　មិត្រមួយណាមគ្រប់រូបកាយ ។

ពួកយើងចង្រ្កមគ្មាន　　តែយើងមានកម្លាំងកាយ ។

ឲ្យតែចិត្តស្រុះស្រោយ　　រួបរួមគ្នាជាសាមគ្គី ។

កំគាចនឹងចាប់សត្វ　　ដែលមុឺងម៉ាត់ដោយឫទ្ធី

សម្លាប់ផ្តាច់ជីវី　　កុំឲ្យនៅមានជីវ៉ា» ។

ហ្វូងជ្រូកស្តាប់ឮឮស្ងាស់　　ត្រេកអរណាស់ឥតឧបមា

ទ្វេីយប្រាប់ទៅវិញថា　　«មិត្រស្នេហាពោលពីកេះ ។

ពីកេះណាស់តុក្កៈ　　ពាក្យដែលអ្នកពោលមកនោះ

សែនតេញជាតីពេះ ត្រេចកំខ្ញុំពន់ពេកក្រៃ ។
ពួកយើងត្រូវតែប្តូរ ចាំឯងតស៊ូឲ្យដឹងដៃ
ឪឯងអាត្មាចង្រៃ យកជាញាដ៏យូរនានតែបាន ។
ពេលចាំងចើនណា រត់ព្រោះការមិនក្លាហាន
ចាំងរួចយើងមិនខាន សន្ធាប់ទេអ្នកខោះណា» ។
តប្តូក:ចិត្តអង់អាច ពាំងមានច្រុងជ្រួញសក្តៀក្តា
នាំជ្រូកកូនព្រឹក្សា ឲ្យរួមគ្នាជាសាមគ្គី ។
ហ្វូងជ្រូកស្រុះស្រួលចិត្ត មួលគំនិតស្មើមុខត្រី
ចេះស្តាប់តាក្យសំដី ពាក្យបង្គាប់គ្នាឯងគ្នា ។
ហើយជ្រូកតប្តូក: ដែលជាអ្នកឲ្យបញ្ញា
ចាកចេញចរលីលា រកកេរដំគ្រប់កន្លែង ។
រដោយឆ្នាសយុទ្ធវិធី យល់ថាពីហានេះឯង
ឪឯងយកដំយជាក់ស្តែង កូនកន្លែងនេះពុំបាន ។
កំរិបប្រឹងឃ្លាតខ្លី រកកេរដីគ្រប់សណ្ឋាន
ដើរកេរតាល់តែបាន កេរដីល្អពេកណាស់ណា ។
តប្តូក: រៀបក្បួនប្រ- យុទ្ធតាំងតនឹងស្តេចខ្លា
ចាត់រៀបក្បួនយុទ្ធនា គឺរៀបក្បួនបទុមព្យូហ៍ ។

ក្បួនបង្គុមត្បូហ៍នេះ តាមខ្ញុំបេះបានគិតគូរ
ថាក្បួនបង្គុមត្បូហ៍ នេះគឺក្បួនសំបុកឃ្មុំ(១) ។
តួចកៈរៀបខ័ពជ្រក ដូចផ្កាឈូកនៅក្រពុំ
ឬដូចជាសត្វឃ្មុំ កំពុងហើរលើអាកាស ។
ចាត់រៀបជ្រកជក ដែលគ្រាំគ្រាខ្លុះច្រើមណាស់
ឱនកូនជ្រកដេរដាស់ នៅជុំដោះព្រមគាំងមេ ។
ឲ្យនៅកន្លែងមួយ មិនឲ្យត្រួយគិតរិះរេ
ចាត់ជ្រកខ្យាយជាដំគេ ឱនជ្រកមេពេញក្រមុំ ។
ឲ្យនៅថែរក្សា ញាតិគ្រួសារដែលនៅជុំ
ចាត់ជ្រកមាឧធំ។ ឲ្យតទ្ធហ៊ុំក្រុមគ្រួសារ ។
ហើយចាត់ជ្រកកម្លោះ នៅបន្ទោះនោះឯងណា
ដើម្បីឲ្យជួយការ- ពារមុតមាំបានវែងបុងឆ ។
រួចជ្រើសជ្រកចំណាន ចិត្តក្លាហានស្មារតីវែង
សម្រាប់គ្រាន់នឹងពីង ចេញប្លាំងនឹងភ្នាក់ម្ចៅ ។
ហើយចាត់ជ្រកឲ្យឈ្មោស ដើមម្ទុះជារណ្តៅ

---

(១) សម័យមុនហៅថា «ក្បួនបង្គុមត្បូហ៍» បច្ចុប្បន្នសម័យនេះហៅថាក្បួនសំបុកឃ្មុំ (Formation en essaim)

បណ្ដោតខ្លាធំខ្លៅ ឲ្យធ្លាក់ស្លាប់សូន្យដីវ ។
តច្ចកៈ រៀបក្បួនហើយ ពុំកន្ដើយខ្ញុំខ្ញាន់ថា
«ម្នាលមិត្តជាតិសុភក ចូរអ្នកកុំជ្រួសស្មារតី ។
តាំងចិត្តឲ្យអង់អាច កុំតក់ឈ្លាចចោរពៃរី
កម្លាំងសាមគ្គី អាចយកជ័យជំនះបាន ។
ពេលសាយណ្ហសម័យ នៅក្នុងព្រៃព្រឹក្សាឋាន
ហ្វូងជ្រូករួមគ្រប់ប្រាណ មូលមិត្រស្និទ្ធជាផ្នែកក្រម ។
គ្រឿមខ្លួនពុកសម្រាំង ចាំប្រុងបា្លំដន្ដឹងខ្លាធំ
ការពារក្រុមសង្គម ឲ្យរួចបាកពីខ្លុកា ។
ក្នុងពេលនោះឯងព្រះ - អាទិត្យរះស្មើព្រឹក្សា
បំភ្លឺមនុស្សលោកា ក្នុងទ្វីបាគ្រប់ទាំងអស់ ។
ពេលភ្ញាក់ពីដេក មានចិត្តត្រេកអរមុខស្រស់
សែងគេឲ្យត្បាបរបស់ សម្រាប់រស់នៅជាសុខ ។
ថ្ងៃដដែលឯស្ដេចខ្លា ភ្ញាក់កាលណាមិនស្រណុក
ក្នុងនោះញ៉ាំរប៉ំផ្លុក ឃ្លានចង់ធ្វើសាច់ជ្រូកនៅ ។
ចេញចាកពីសំណាក់ ដដែលម្នាក់ចិត្តឃោរឃៅ
ដើរលឿនឆ្ពោះត្រង់ទៅ ទីលំនៅហ្វូងសុភក ។

ហ្វូងជ្រូកបានឃើញហើយ　　មិនកន្តើយប្រាប់ភ្លាមថា

ឯលោកមេបញ្ជាការ　　ឥឡូវខ្លាក់មកហើយ" ។

តបភ្លេត: បានឃើញពិត　　ពោលថា "មិត្រទាំងឡាយអើយ

ចូរអ្នកកុំភ័យខ្លើយ　　ប្រុងស្មារតីកុំបរណ្តាយ ។

បើខ្លាធំវាធ្លើ　　ខ្ញុំវាអំពើណាក៏ដោយ

ចូរមិត្រកុំឲ្យភ្ញាយ　　ធ្វើឲ្យដួចវាកុំបាន ។

ដើម្បីឲ្យដឹងថា　　ហ្វូងសុភកប្រុងប្រៀបប្រាណ

ប្រតាំងជាមិនខាន　　គួរតេយ្យុទ្ធយាងពេញចិ ។

ខ្លាលុតខ្លួនប្រុងតែ　　ស្រែកន្ធែត់ញ៉ែរណើ

នោមវាត់ជាន់ញាក់ញ៉ី　　ស្លុតខ្លួចខ្លីព្រៃព្រឹក្សា ។

ហាក់លោតស្ទុះទៅលួក　　សង្គ្រាមជ្រូកដួចជម្មតា

ជ្រូកធ្វើខ្លាវិកិរយា　　តាមស្តួចខ្លាគ្រប់រូបកាយ ។

ខ្លាយល់អាការ:　　យាំងបា្លស់ជាក់ពីចម្ងាយ

តំរាកចៀសចេញឆ្ងាយ　　ដោយគិតស្គាយពន់ពេកក្រៃ ។

ខ្លាគិតកន្ធិចិត្តថា　　"ថ្ងៃនេះណាថ្ងៃកជាធិថ្ងៃ

មុនៗគួរសង្ឃឹយ　　គួរពិភាល់ទីធីសុភក ។

ប្រហែលជាវាបាន　　អ្នកក្លាហានតបបញ្ញា

ជាមេនាំចាត់ការ ចានជាវប្រុងប្រយ័ត្ន ។
រួមគ្នាជាសង្គម តាំងតួចធំច្រើនពេកក្តាត់
អញគួរកុំចាប់សត្វ ដឹកាហានយ៉ាងនេះឡើយ ។
គិតហើយក៏ចូលទៅ ទីលំនៅឯកន្លែង
គ្មានស្តីធ្វើព្រងើយ សម្ងំនៅតែឯកឯង ។
ជដិលកោងអង្គុយ ស្បៀមមុយៗផ្អែកចំរែង
ចាំខ្លាត្រង់ផ្លូវតែង មិនដែលមានថ្ងៃណាម្តង ។
ពេលមុនខ្លាវិលមក តែងនាំយកសាច់ពស់ផង
ពេលនេះមិនដូចច្បង ដែលធ្លាប់មានហើយពោលថា ។
«ថ្ងៃនេះថ្ងៃស្អាក់ស្ទើរ ឥតអំពើ គ្មានចានការ
ប្រហែលជាស្តេចខ្លា រៀរចាំៗចាំងាតចាត ។
អត័យទានឲ្យដល់ សត្វសាកលមិនឲ្យផ្តាត
ឬមានគេធ្វើឃាត នឹងចង្អុលចាក់ឬអត្ត ? ។
ចានជាអ្នកចូលទៅ ដល់លំនៅហ្ងួនសុការ:
មកវិញញ័រញញ័រញាក់ អាណិតអ្នកពេកណាស់ណា" ។
ខ្លាំងស្តាប់ឮហើយ កំឆ្នួនឆ្លើយច្រាប់ទៅថា
«ក្រចកនឹងពាហា(១) តាំងកម្ងាំងខ្ញុំទៅមាន ។

---

១ បង្គួម ។

តែខ្ញុំយើញសុភក នៅត្រៀបត្រាក់ដំណែរហាន
ប្រុងប្រៀបប្រយ័ត្នប្រាណ រួបរួមគ្នាជាសាមគ្គី ។
ថ្ងៃមុនជ្រកយើញខ្ញុំ រត់ចោលក្រមៅកេរ៉ី
តួនខ្លួនក្បែរតែរី ត្រប់ទិសទីតាំងតួច-ធំ ។
ថ្ងៃនេះជ្រកតាំងឡាយ ព្រមព្រៀងការយជាសន្ធឹម
ប្រយ័ត្នតាំងតួច-ធំ រួមមូលផ្តុំជុំជិតគ្នា ។
ហ្វូងជ្រកចេះរួមក្បែ ដោយមានអ្នកមេបញ្ជា
ឲ្យជាតិរបស់ពាំ មូលមិត្រគ្នាជាសាមគ្គី ។
ហ្វូងជ្រកតាំងឡាយនោះ ប្រុងប្រទុស្តខ្ញុំពេញទី
យើញខ្ញុំមិនញញើ ញញើរកតួនគាត្មា ។
ចានជាខ្ញុំមិនហ៊ាន ចូលចំពានចាប់សុភក
ក្រែងនាំឲ្យថ្នាក់ការ ដល់គាត្មាក្រែយដើរ" ។
ជដិលកោងចានស្តាប់ ខ្លាសាស័ព្ទច្រាប់សព្វទី
ឃល់ថាមិនចានស៊ី ឆ្លើងជំនីជ្រកមែនពិត ។
ហើយគោលបញ្ឆោតថា "នែស្តេចខ្លា! មានពលចូរខ្លី
មានតាំងអំណាចពិត កុំភ័យកិតតក់ស្លុតខ្លាច ។
គ្រាន់តែស្រែកសំឡុត ហាក់ស្ទុះលុតចូលអង់អាច

សម្តែងចិត្តមិនណាច ជ្រកមិនអាចរួមគ្នាបាន" ។
ខ្ញុំឮពាក្យបញ្ជោរ ឡើងដំនោរហួសប្រមាណ
កើតចិត្តយាងគ្រហាទ មិនខ្វាចប្រាណបានមក: ។
ហើយចោលបួលសំដៅ ត្រោះលំនៅហ្លួងសុករ:
ជាគូប្រតិបក្ស ប្រុងប្រយ័ត្នត្រង់អាត្ម ។
ខ្ញុំលោតទន្ទ្រាំដំ ស៊ុះក្រញាំចាប់សុកព
ចំជ្រកមេចាត់ការ តែដោយសារស្មារតីឆី ។
តប្តកៈ លោតចេញជាក់ ខ្ញុំកំផ្លាត់កងរណ្តៅ
ដៃលបានដីកយាំងជ្រៅ ខ្ទុកបញ្ជោតន្ទុះស្តេចខ្លា ។
តប្តកៈ សុករ: ស៊ុះលោតចាក់ប្តុកប្រហារ
ឆឹងខ្លាយស្រួចមុតថ្លា ដល់ដីពស់ខួចក្បាលក្បែយ ។
តប្តកៈ បានសម្លាប់ ស្តេចខ្លាស្លាប់ត្រេកអរក្រៃ
នាំគ្នាបួលតដៃ ឆឹងជដិលគោងខៀតណា ។
ហ្លួងជ្រកចោលបួលទៅ ទីលំនៅរបស់គ -
ជដិលដែលត្រូវជា ចៅហ្វាយខាយខ្លាំងឡៅ ។
នាំគ្នាខាំប្រតាយ គាញប្រញាយហែកឆីទៅ
ឆីអស់មិនឲ្យនៅ សេសសល់ពុកជាកំរៃ ។

ពេលនោះទេពាត៌ស្ស ដែលជាអ្នកកក្ខវៃត្រ
ឃើញហេតុអស្ចារ្យត្រៃ បានបន្ទឹកាសិតថា ។
"ញាតិមានច្រើនប្រពៃ ឈើកងព្រៃក៏ដូចគ្នា
ហ្វូងជ្រូកមានសាមគ្គា ព្រមព្រៀងគ្នាជាសង្គម ។
ញុំាងសេចក្តីអង់អាច មិនភ័យខ្លាចឲ្យមូលមុម
សម្លាប់ខ្លាឃ្មាំងធំ ទឹងជដិលឲ្យស្លាប់បាន" ។
ហ្វូងជ្រូកបានសម្លាប់ សត្រូវស្លាប់ទាំងពីរប្រាណ
រួចស្រេចហើយក៏បាន លើកតួចកៈឲ្យជាធំ ។
ជាស្តេចគ្រងត្រួតត្រា លើសុកពពាំងសង្គម
ការពារពាំងតូច-ធំ កុងសង្គមតរៀហោង ॥ ។

សារណាកាព្យ

បទកាកគតិ

ពួកជ្រូកគ្រប់ប្រាណ

ជាជាតិតិរច្ឆាន នៅកងព្រឹក្សា គ្មានសៀវភៅមើល
គ្មានត្រូវអាចារ្យ គ្មានបានសិក្សា ន.មោ-ឃសិទ្ធ ។

រាល់ថេរស្រឡាញ់

ចិត្តគួចកាញ់ រួមគ្នាជិតស្និទ្ធ ការពារសាច់ញាតិ

រួមជាតិសោហ៊ិត រួចរាកត័យកិត ឥតមហន្តរាយ ។

ជ្រកម្លួមសាមគ្គី

ចាំងឈ្មោលចាំងញី ចិត្តស្រួលស្រុះស្រោយ កំចាត់សត្រូវ

ដល់ខ្លួវគន្ធរាយ វិនាសខ្ចាត់ខ្ចាយ រួបកាយមត៌ ។

ហេតុនេះជាតិអើយ

កុំនៅព្រងើយ ស្ទុះក្រោកឡើងវិ ឈរឱ្យត្រង់ខ្លួន

ឱនខ្នងស្មារតី ទំប្រឹងឃ្នាតខ្លី ពួតកម្លាំងគ្នា ។

ចូរម្លួមសាមគ្គី !

ចាំងប្រុសចាំងស្រី ប្រឹងប្រែងពុះពារ ខ្លួវទប់ស័ត្រ

រួមកំសៀវមួលគ្នា ដើម្បីការពារ ខ្លួវប្រទេសជាតិ ។

ចូរម្លួមសាមគ្គី !

ចាំងប្រុសចាំងស្រី ប្រឹងប្រែងខ្លីឃ្នាត ជ្រោងពុទ្ធសាស្ត្រ

សាស្ត្រាលោកនាថ ឱ្យថ្កើងដល់ខ្ពាត ប្រាំពាន់វស្សា ។

ចូរម្លួមសាមគ្គី !

ចាំងប្រុសចាំងស្រី ការពារការក្សា ព្រះពជបល្ល័ង្ក

រាក់ឯបញ្ជា– មិត្រគ្រប់ទិសា កុំឱ្យក្សត់បាន ។

ឱនអញ្ជាក្រឹត្យ

ឯកពជ្ឈតិតា ជាតិខ្មែរគ្រប់ប្រការ ប្រឹងប្រែងតស៊ូធ

ឲ្យរីងចំនួនបាន រុងរឿងថ្កើងថ្កាន ជាថាវរៈ ។

បើមែសាមគ្គី

គ្មានអំណាចអ្វី ឬទបសត្តៈ ចូលមកកំណត់

យាយីឲ្យធ្លាក់ ចុះក្នុងហិនៈ ឥសៈបានឡើយ ។

មានតែចុំថ្កើង

ចំរើនខ្ពស់ឡើង សម្បូណិឥតសៅយ្យ ឋានសន្តិសុខ

គ្មានទុក្ខព្រួយឡើយ ព្រស្តុបានរហ័យ ទាំងអ្នកពជការ ។

ពិធីបុណ្យព្រហ្មទាន

ចែករង្វាន់សមណានិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត និង ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនិ ឆ្នាំ ១៩៦០ ក្រោមព្រះរាជាធិបតានីភាព នៃសម្តេចព្រះមហាក្សត្រីយានីជាអម្ចាស់ជីវិតលើត្បូង ។

កាលពីថ្ងៃទី ១៩ ខែតុលា ១៩៦០ វេលាម៉ោង ៨, ៣០នាទី ក្រសួងធម្មការបានធ្វើពិធីបុណ្យព្រហ្មទាន ចែករង្វាន់ដល់សមណានិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ចំនួន ៦០ រូប និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចំនួន ៧១ រូប រួមជា ១៣១ រូប ក្រោមព្រះរាជាធិបតានីភាពនៃសម្តេចព្រះមហាក្សត្រីយានីជាអម្ចាស់ជីវិតលើត្បូង ។

មានឥស្សរជនជាន់ឋពូជតជាន់គ្រហស្ថ ចូលរួមបួងអង្វើញមកជាច្រើនក្នុងពិធីបុណ្យនេះ ។

ឥស្សរជនផ្នែកខាងឋពូជត គឺសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុជម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត, រាជាគណៈ, ហានាទុក្រម, សាស្ត្រាចារ្យ ព្រមទាំងព្រះថេរានុត្ថេរៈជាន់ឡាយ ។

ឥស្សរជនផ្នែកខាងគ្រហស្ថមាន : សហជីវិន ជួប-ហែល ប្រមុខ

រដ្ឋស្ដីទី, សហជីវិនប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ សហជីវិនទាយករដ្ឋមន្ត្រីស្ដីទី សមាជិករដ្ឋាភិបាល, នាហ្មឺនសព្វមុខមន្ត្រីទាំងឡាយ ព្រហ្មាទាំងជាដើម ។

ពេលម៉ោង ៩ ព្រឹក, សម្ដេចព្រះមហាក្សត្រីយានី ស្ដេចយាងមកដល់ មានក្រុមគាហានរក្សាព្រះអង្គធ្វើគារវកិច្ច ទីង ភ្លេងជាតិប្រគំថ្វាយជាព្រះរាជកិត្តិយស ។

ពេលម៉ោង ៩,០៥ នាទី, សហជីវិន សរ-គិមកួយ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងខ្លឹមសារសុន្ទរកថាដូចតទៅនេះ ។

សូមព្រះតេជៈដ៏កល់លើសួរ្គ !

សូមព្រះរាជទានក្រាបបង្គំទូល សម្ដេចព្រះមហាក្សត្រីយានីជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ក្រែមលន់ធួលីព្រះបាទ ។

កន្លងមានៃព្រះរាជរដ្ឋាភិបាល ទីឯកន្លងមានៃខ្ញុំព្រះបង្គំជាខ្ញុំ ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងខ្ញុំអំណរព្រះករុណាចំពោះសម្ដេចជាម្ចាស់ ដែលបានស្ដេចយាងជាព្រះរាជាធិបតានីភាពក្នុងពិធីបុណ្យចែកព្រហ្មាទានដល់សមណនិស្សិតក្នុងថ្ងៃនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស !

រង្វាន់ព្រហ្មទានដែលបានរៀបចំយ៉ាងវិចិត្រដំកល់នៅចំពោះព្រះភក្ត្រ
ព្រះអង្គនេះ គឺជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ព្រះអង្គ ទ្រង់ព្រះមេត្តា
ប្រោសព្រះរាជទានដល់សហជីវិន ប្រធានសមាគមពុទ្ធិកវិទ្យាល័យ នូវ
ព្រហ្មទានជាកញ្ចាប់ចំនួន ៧៦ ចីពរ ៤៨ ដែលពួកក្រុមអភិបាលសមាគម
ធនធុទ្ធចរិស័ទ បានចាត់ចែងរៀបចំគ្រឿងបរិក្ខារ ធនព្រហ្មទានថែមទៀត
ដើម្បីសូមព្រះរាជទានចាប់មគ្គផលជាមួយព្រះអង្គ បានគ្រប់ជាព្រហ្មទាន
ចំនួន ១៣១ ។

ព្រះឧត្តមគតិជាមហាកុសល ដែលបានផុសអណ្តែតត្រសែតក្នុង
ពេលនេះ អាចចាត់ទុកបានថាជាមហាពលិកម្ម ១ ដ៏ថ្លៃថ្លា ចំពោះព្រះ
ពុទ្ធសាសនា ប្រៀបបីដូចជាទុសច៍ដ៏វិសេស សម្រាប់ប្រស់ព្រឹទ្ធិព្រះច័ន្ទ
របស់សមណនិស្សិតពុទ្ធិកវិទ្យាល័យ ធនធុទ្ធិកមហាវិទ្យាល័យ ឲ្យមាន
សេចក្តីភ្លឺហាន តស៊ូក្នុងការរៀនសូត្រខាងព្រះពុទ្ធសាសនា ឲ្យបាន
ចំរើនលូតលាស់ឡើង ។

មួយវិញទៀត, ព្រះពលិកម្មជាមហាកុសលរបស់ព្រះអង្គនេះ ជាទី
ញ៉ាំងចិត្តព្រះច័ន្ទនៃព្រះសង្ឃទាំងអស់ មានសមណនិស្សិតជាដើមឲ្យ
រីករាយ ហើយចង់ចាំជានិច្ចតុំបានភ្លេចឡើយ ព្រោះព្រះពលិកម្មនេះអាច
ជួយសម្រាលទុក្ខបន្ទុកដ៏ធ្ងន់ នៃសមណនិស្សិតដែលមានសេចក្តីខ្វះខាត

ចំពោះគ្រឿងបរិក្ខារ ជាមធ្យោបាយដ៏ប្រសើរ សម្រាប់គ្រាលព្រះពុទ្ធ
សាសនាឲ្យមានរស្មីរតែតែកូតគ្រប់គ្រងធំល្អើន ក្នុងសាកលលោក ។

ដោយព្រះអង្គទ្រង់ព្រះតម្រិះឈ្លេងយល់អត្ថប្រយោជន៍ជាសារវន្តនេះ
ទើបព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជទានទូរព្រហ្មទានទាន
លើនេះ ជានិមិត្តរូបដ៏ទុតម្មនៃទឹកព្រះរាជហឫទ័យដ៏ស្មោះសរបស់ព្រះអង្គ ។

សូមទ្រង់ព្រះមេត្តាប្រោស !

បន្ទាប់តពីនេះទៅ ខ្ញុំលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជ-
វាយោកាសព្រះអង្គ ថ្វែងសេចក្តីប្រាស្រ័យជាមួយព្រះសង្ឃនីធីអស់លោក
ទាំងឡាយ ដែលបានឧទ្ទិសអញ្ជើញមកកាន់តំណបុណ្យនេះ ។

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំង ២ គណៈ ព្រម
ទាំងព្រះថេរានុត្ថេរៈទាំងអស់ -

-ទ្រង់

-ឯកឧត្តម

-អស់លោក

វេលានេះ ខ្ញុំព្រះករុណា-ខ្ញុំ មានសេចក្តីត្រេកអរក៏កើតឡើងពេក
ដោយបានឃើញសម្តេច-ទ្រង់-ឯកឧត្តម ទាំងអស់លោកទាំងឡាយ
បានឧទ្ទិសកុសល-យាង-អញ្ជើញមកជួបជុំក្នុងឱកាសនេះ ដោយព្រះទ័យប្រកបដោយ

សោមនស្សចេតនាជាមហាកុសលដ៏ប្រសើរ ដើម្បីចំពេញកិច្ចការកុសលនេះឲ្យមានសភាពរុងរឿងជាទីគ្រាក់ សមតាមប្រពៃណីនៃពុទ្ធសាសនាជាពិសេសតិអស់លោក ដែលបានចូលព្រហ្មចរិយ ជាអ្នាន់ដល់សមណនិស្សិតថែមទៀត ដើម្បីជួយបៃហារព្រះត្រហ្មចរិយសម្តេចជាព្រះមាតាជាតិឲ្យបានអធិកអធម ជាកិរិយាកាត ។

ក្រសួងធម្មការមានសេចក្តីសង្ឃឹមយ៉ាងមាំពុកជាមុន លើព្រះគុណជានិស្សិតគ្រប់ព្រះអង្គនេះ ថានឹងព្យាយាមសិក្សារៀនសូត្រខាងពុទ្ធសាសនាឲ្យបានចំរើនលូតលាស់ដុសជាលទៅជាល់ជាប់ ទើងបានជាអនាគតរបស់ប្រទេសកម្ពុជាបៃតងពុទ្ធបក្ស ព្រមទាំងទិតទំចំរើជាតិ-សាសនា-ទើងព្រះមហាក្សត្រ ដែលជាទៃ្រទ្ធដោយស្មោះត្រង់អស់ពីដួងព្រះទ័យគ្រប់ព្រះអង្គ ។

ជាអវសានៃសុន្ទរកថានេះ ខ្ញុំលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា-ខ្ញុំសូមសំដែងដោយគោរពនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ហើយសូមលើកយកកុសលកុសលកុសលដ៏ថ្លៃថ្លានេះ ថ្វាយចំពោះព្រះអង្គ ទើងសម្តេចព្រះទេពរាជ សូមព្រះអង្គបិតនៅក្នុងព្រះបរមសុខ ទើងជាម្ចប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋ ទាំងព្រះសង្ឃទើងត្រហស្ថគ្រប់ប្រភេទ សូមព្រះអង្គឈ្នះមារសត្រូវគ្រប់ទិសទីប្រកប

ដោយសិរីសួស្តីជ័យមង្គលគ្រប់ប្រការ សូមសត្រូវចាំឆ្លាយរលាយ
រលត់បាត់បង់ទៅជាអហោសិកម្ម ។

មួយវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រគេន ជូន សម្តេចចាំង ២
ព្រះអង្គ ឧទ្ទិសលោកចាំងអស់ដែលបានជួយចាប់មគ្គផលក្នុងការកុសល
នេះ សូមឲ្យបានជួបប្រទះនូវសេចក្តីសុខចំរើន ចាប់ពីពេលនេះតរៀងទៅ។

លុះសហជីវិន អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានថ្វាយ
សុន្ទរកថាចប់ហើយ, ព្រះតេជៈព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិក.
សិក្សា បានហ្វាងពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត បានថ្វាយនូវសុន្ទរកថាដូច
តទៅនេះ ។

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត !

ឧកាសនេះ អាត្មាភាព ក្នុងនាមនៃសាស្ត្រាចារ្យទំាងបុគ្គលិកទំាង
អស់ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជ ឧទ្ទិកវិទ្យាល័យព្រះ
សុកម្រឹត សូមថ្វាយនូវមនោសញ្ចេតនាដ៏សម្បយុត្តដោយប្រតិភ្ជាមោជ
ចំពោះសម្តេចជាព្រះមាតាជាតិ ដែលទ្រង់មានព្រះពជហឫទ័យប្រកប
ដោយមេត្តាករុណា ស្តេចយាងមកជាព្រះពជាធិបតីនៃពិធីបុណ្យប្រគេន
ព្រហ្មទានដល់សមណនិស្សិតទំាងឡាយនៅពុទ្ធិកវិទ្យាល័យ ឧទ្ទិក-
មហាវិទ្យាល័យនេះ ។

បុណ្យប្រគេនព្រហ្មទានដល់សមណនិស្សិតទាំងឡាយ ដែលមានព្រះអង្គសម្តេចព្រះមាតាជាតិជាព្រះពាន់ធិបតី ព្រមទាំងសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ទំនង់ទ្រង់ ឯកទត្តម អស់លោកទាំងឡាយ ដែលបានទិមន្ត ស្តេចយាង អញ្ជើញមកប្រជុំរួមជាមួយផងនេះ អាចជាតំណាងមហាកត្តិយសដ៏ប្រសើរ ទំនងជាមហាមង្គលដ៏ឧត្តម ទាំងឲ្យពុទ្ធកមហាវិទ្យាល័យ ទទឹង ពុទ្ធកវិទ្យាល័យ ចារឹកទុកក្នុងប្រវត្តិរបស់ខ្លួនតទៅអនាគត ។

សូមថ្វាយព្រះពរ ។

ព្រហ្មទានដែលសម្តេចទ្រង់សព្វព្រះពជហប្តិ៍យ ប្រោសព្រះពជទាន ប្រគេនដល់សមណនិស្សិតទាំងឡាយក្នុងគ្រានេះ ឈ្មោះថាជាមហាកុសលមួយដ៏ថ្លៃថ្លាណាស់ ដោយរួបរួមជាមួយនឹងព្រហ្មទានរបស់សមាគមពុទ្ធកវិទ្យាល័យ ទទឹងពុទ្ធបរិស័ទទាំងឡាយផង ព្រោះជាហេតុនាំឲ្យសមណនិស្សិតទាំងឡាយ មានចិត្តរីករាយប្រកបដោយកតញ្ញូតាធម៌ចំពោះព្រះមហាករុណាគុណនៃសម្តេចជាព្រះមាតាជាតិ ដែលមិនអាចនឹងបំភ្លេចបានឡើយ ។

អាត្មាភាពមានសេចក្តីសង្ឃឹមថា ព្រហ្មទាននេះ នឹងអាចប្រព្រឹត្តទៅជាគ្រឿងឧបករណ៍មួយយ៉ាងវិសេសវិសាល បណ្តាលឲ្យចិត្តនៃសមណនិស្សិតទាំងឡាយ ជិតជាប់ក្នុងការសិក្សាតទៅ រហូតដល់ជាន

ខ្ញុំលើខ្ញុំវិលខ្ញុំផលក្នុងអនាគតតុំ ។

លំដាប់អំពីមេះ អាត្មាភាពសូមព្រះពុទ្ធានព្រះពុទ្ធវៀកាស ដើម្បី
ថ្លែងនូវសេចក្តីលើក ចំពោះសមណានិស្សិតចាំឆ្លើយ ។

អស់លោកជាសមណានិស្សិត !

លោកគ្រប់រូបសុទ្ធសឹងតែជាកូនវៀ នៃប្រជាពលរដ្ឋក្នុងប្រទេស
កម្ពុជា ចាលះបង់ញាតិញោមដែលនៅតាមខេត្ត ស្រុក-ឃុំ និគម-
ជនបទ ហើយចូលមកសិក្សាក្នុងមហាវិទ្យាល័យ ទឹង វិទ្យាល័យនៅ
ក្នុងរាជធានីនេះ ជាកន្លែងសិក្សាដែលបិតនៅក្រោមព្រះបរមរាជូបត្ថម្ភ នៃ
សម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ ទឹងសម្តេចជាព្រះប្រមុខរដ្ឋ
ដោយមានការជ្រោតជ្រាលនៃសង្គមកម្ពុជាយមជួយជ្រោមជ្រែងគាំទ្រថែង ។

ព្រះបរមរាជូបត្ថម្ភនៃព្រះពុទ្ធបល្ល័ង្ក ទឹងការជួយជ្រោមជ្រែងនៃការ-
ប្រជាជន ចំពោះពុទ្ធិកវិទ្យាល័យ ទឹងពុទ្ធិកមហាវិទ្យាល័យនេះ នាំឲ្យ
ពុទ្ធិកសិក្សាមានដំណើរប្រព្រឹត្តទៅស្រួល តាំងពីអតីតកាលរហូតមក
ដល់កន្លែងបច្ចុប្បន្នកាលនេះ ទឹងតទៅក្នុងអនាគតកាលទៀត ។

ដូចេ្នះ, សូមឲ្យអស់លោកចាំឆ្លើយ បណ្តុះកតញ្ញូតាធម៌ឲ្យមាន
នៅកន្លែងចិត្តជានិច្ច ចំពោះព្រះគុណដ៏ខ្ពង់ខ្ពស់នេះ កុំបីធ្វេសប្រហែស
ឡើយ ហើយខំសិក្សាឲ្យបានចេះដឹងយ៉ាងជ្រៅជ្រះ ឲ្យសមតាមពុទ្ធន្តរ៍ទ

នៃព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូផង ឲ្យសមតាមគោលចំណងនៃពាក្យថ្លែង-
កិច្ចការ ដែលមានសម្តេចព្រះប្រមុខរដ្ឋជាព្រះអគ្គមគ្គុទ្ទេសក៍ផង ។

អស់លោកចាំងឮយល់ច្បាស់ទេ ? ការសិក្សាខាងព្រះពុទ្ធសាសនា
នេះ កាលពីក្នុងសម័យអាណាព្យាបាលបានពិសេស មានបន្តិចបន្តួច
មិនសូវមានសេចក្តីដុះជាលចំរុងចំរើនប៉ុន្មានទេ ។ តាំងពីប្រទេសកម្ពុជា
យើងបានទទួលឯករាជ្យឡើង សម្តេចព្រះប្រមុខរដ្ឋការ
គង់លើព្រះរាជបល្ល័ង្កនៅឡើយ ព្រះអង្គបានលើកស្ទួយការសិក្សាខាងព្រះ
ពុទ្ធសាសនានេះឲ្យមានកំពស់ខ្ពស់ឡើង គឺឲ្យមានពុទ្ធិកវិទ្យាល័យនិងពុទ្ធិ-
កមហាវិទ្យាល័យជាវិទ្យាល័យ ដែលប្រកបដោយមូលដ្ឋានដ៏ខ្ពស់ ចាំង
ខាងព្រះពុទ្ធសាសនា ចាំងខាងផ្លូវលោក សម្រាប់កុលបុត្រជាអ្នកបួសក្នុង
ព្រះពុទ្ធសាសនា គឺភិក្ខុសាមណេរ បានសិក្សាឲ្យបានចេះដឹងចំណេះវិជ្ជា
ប្រសើរឡើង ព្រោះសម្តេចព្រះប្រមុខរដ្ឋទ្រង់ប្រកបដោយព្រះវិចារណ-
ញាណ ឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ ទ្រង់ឈ្វេងយល់ឃើញថា:

១-ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ជាសាសនារបស់រដ្ឋតេញ៉ូ

២-ប្រជាពលរដ្ឋក្នុងប្រទេសមានចំនួន ៩៨ ភាគរយ សុទ្ធតែជាអ្នក
គោរពព្រះពុទ្ធសាសនា

៣- ព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេសកម្ពុជា កាលពីក្នុងអតីត-

សម័យ ភ្ជាប់ធ្វើជាគ្រឹះនៃយុវជនក្នុងប្រទេស ជាកូនចៅនៃប្រជាពលរដ្ឋ តមកតទៅនេះ និស្ស័យទាំងឲ្យប្រជាពលរដ្ឋមានតាំងចិត្តចំពោះព្រះសង្ឃជាដរាបមក;

៤- ក្នុងសម័យបច្ចុប្បន្ននេះ ប្រទេសជាតិអស់ក្នុងលោកមួយចំនួនប្រទេសកម្ពុជាផង កំពុងក្រាក់ឮកហើយគ្រោកដើរបែរមុខឆ្ពោះទៅរកវិនាសកាល ខាងចំណេះវិជ្ជាការចេះដឹង ។

៥- ព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេសកម្ពុជាឯករាជ្យបច្ចុប្បន្ននេះ មិនគួរនឹងបណ្តោយឲ្យបិតនៅក្នុងសភាពល្ងង់ងឹតឥតខ្លឹកខ្លាំងឡើយ ។ ព្រោះព្រះសង្ឃនេះភ្ជាប់តែមានចំណេះចេះដឹង តែងធ្វើជាគ្រឹះអាចារ្យ លើគ្រហស្ថតាំងពីអតីតសម័យមក គួរតែចាត់ចែងរៀបចំបណ្តុះបណ្តាលឲ្យព្រះសង្ឃពុទ្ធសាសនិក មានចំណេះវិជ្ជាច្រើនឡើងខ្ពស់ឡើង កុំឲ្យអន់ថយជាងគ្រហស្ថ ដើម្បីកុំឲ្យខូចតារាកេរ្តិ៍របស់គ្រហស្ថចំពោះព្រះសង្ឃឲ្យគន់នៅបិតថេរតៅ ព្រោះថា បើកាលណាព្រះសង្ឃល្ងង់ខ្លៅហើយ តារាកេរ្តិ៍ឯកត្តកាតរបស់គ្រហស្ថតាំងពីបុរាណ នឹងលោយរលត់ជាក់ខ្លាំងបន្តិចម្តងៗ ហួតដល់អស់លើឯកន្លែងនោះឯង ហើយព្រះពុទ្ធសាសនានឹងត្រូវអស់ពន្លឺស្មើ គឺជាត្រូវសោយសូន្យ ។

ម្យ៉ាងទៀត ដើម្បីឲ្យព្រះសង្ឃក្នុងប្រទេសមានគុណសម្បត្តិប្រសើរ

ឡើង ដោយសារការចេះដឹងច្រើន កុំឲ្យអន់ថយជាងព្រះសង្ឃពុទ្ធសាសនិកបរទេស ព្រោះប្រទេសគាំងឡាយ ឯទៀតដែលមានព្រះពុទ្ធសាសនាដូចប្រទេសយើងដែរ គេបានរៀបចំបង្កើតឲ្យមានមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា សម្រាប់បណ្តុះបណ្តាលព្រះសង្ឃក្នុងប្រទេសគេមុនប្រទេសយើងច្រើនឆ្នាំមកហើយ ។

ដោយអាស្រ័យហេតុដូចខាងលើនេះ ទើបសម្តេចព្រះប្រមុខរដ្ឋខ្ពស់បានសម្រេចព្រះពជហឫទ័យ បង្កើតឲ្យមានការសិក្សាខាងព្រះពុទ្ធសាសនា ព្រមគាំងខ្ពស់មានព្រះពជបញ្ជាឲ្យរៀបចំការសិក្សានេះ ឲ្យមានរបៀបរៀបរយល្អឡើង គឺឲ្យមានពុទ្ធិកថបមសិក្សា ពុទ្ធិកមជ្ឈមសិក្សា និងពុទ្ធិកឧត្តមសិក្សា ដូចសព្វថ្ងៃនេះ ។

អស់លោកជាសមណនិស្សិតគាំងឡាយ តបស្រាំដឹងឲ្យច្បាស់ម្យ៉ាងទៀតថា ពុទ្ធិកសិក្សាដែលកើតឡើងហើយ ប្រសិនបើខ្វះការឧបត្ថម្ភ ខ្វះការជ្រោមជ្រែង ក៏មិនអាចនឹងមានជីវិតរស់នៅបានឡើយ ដែលមានជីវិតរស់នៅហើយបានចំរើនដោយលំដាប់រហូតមកនេះ គឺប្រាកដជាដោយសារសេចក្តីឧបត្ថម្ភ និងការជ្រោមជ្រែងនៃពជរដ្ឋាភិបាលសង្គមកស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋជាប្រធាន ក្នុងការផ្គត់ផ្គង់ឲ្យមានគ្រឿងសម្ភារៈ ឲ្យមានសាស្ត្រាចារ្យ និងបុគ្គលិកត្រប់ប្រកេរ មិនឲ្យខ្វះ

ទាន ជាពិសេសទៅទៀត គឺជួយផ្តល់អាហារូបករណ៍ដល់សមណនិស្សិតទាំងឡាយ នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ។

អស់លោកជាសមណនិស្សិតទាំងឡាយ ប្រហែលជាធ្លាប់បានដឹងដែរ ក្នុងប្រទេសកម្ពុជាយើងនេះ តាំងពីបុរាណកាលមក មានប្រវត្តិសាស្ត្រច្បាប់យើងឲ្យដឹងច្បាស់ថា ព្រះពុទ្ធសាសនាក្តី ការស៊ក្សាខាងព្រះពុទ្ធសាសនាក្តី រមែងបានដុះដាលចំរើនឡើង រុងរឿងឡើង ដោយអាស្រ័យនឹងព្រះមហាក្សត្រ ។ រឿងនេះមិនមែនជារឿងព្រេងទេ គឺជារឿងពិត សឹងមានប្រវត្តិនៃពុទ្ធិកសិក្សាក្នុងបច្ចុប្បន្ននេះ ដែលបានរៀបចំដោយសង្ឃបរូបមកហើយ ជាសក្ខីភាពយ៉ាងច្បាស់ខែង ។

ដូច្នេះ, ខ្ញុំសូមរំលឹកអស់លោកទាំងឡាយ សូមកុំឲ្យធ្វេសប្រហែសឲ្យទំយកចិត្តទុកដាក់ក្នុងការរៀនសូត្រ បើទុកជាជួបប្រទះនឹងទុបសគ្គខ្លះក្នុងពេលកំពុងសិក្សា ក៏ត្រូវទំប្រឹងអត់ធន់ ហើយតស៊ូពុះពារទុបសគ្គនោះឲ្យត្រាតែបានសម្រេចដល់អវសានទៃនការសិក្សា ដើម្បីនឹងបានបំពេញការណ៍យកច្បាប់ស្វាមី ដែលជាកិច្ចតបទុបការគុណ ចំពោះព្រះពុទ្ធសាសនា ចំពោះព្រះពជបល្ល័ង្ក នឹងចំពោះពជរដ្ឋាភិបាល ដែលអស់លោកទាំងឡាយបានជ្រកកោន បានតាំងផ្ទៃក្រយមកហើយ ឲ្យសមជាលំហានៈរបស់ខ្លួនជាសមណៈ នឹងជាភតញ្ញូបុគ្គល ។

ក្រៅពីនេះ មានកិច្ចម្យ៉ាងទៀត ដែលអស់លោកចាំងឡាយត្រូវយកចិត្តទុកដាក់គឺអនាគតនៃព្រះពុទ្ធសាសនា ។ អនាគតនៃព្រះពុទ្ធសាសនានោះ ទឹងជាការៈលើអស់លោកចាំងឡាយ ជាយុវសមណនិស្សិត ។ សូមអស់លោកចាំងឡាយ កុំបណ្តុះគំនិតលាក់លៀមគិតដោះខ្លួនចេញពីព្រះពុទ្ធសាសនាឡើយ ព្រោះព្រះពុទ្ធសាសនា បើតាមធម្មតាទឹងតាមការពិត ទឹងត្រូវការប្រគល់អនាគតដល់អស់លោកចាំងឡាយដែលជាយុវសមណៈ ហើយជាអ្នកសិក្សាមានចំណេះវេចដឹងអាចទឹងទទួលការៈនេះបាន ។

នៅអវសានេះ អាត្មាភាពសូមរំលឹកនូវគុណនៃព្រះរតនត្រ័យ ហើយសូមអានុភាពនៃព្រះពុទ្ធសាសនា ជួយអភិបាលរក្សាសម្តេចព្រះមហាក្សត្រិយានីជាព្រះមាតាជាតិ ទឹងសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់ជាន ប្រកបដោយសុខសួស្តីនឹងជ័យមង្គលគ្រប់ប្រការ អស់កាលជានិច្ចនិរន្តរ៍តរៀងទៅ ដើម្បីទឹងបានជាម្ចាស់ជាទីជ្រកកោននៃពុទ្ធសាសនិកជនចាំងឡាយ ទឹងប្រជាពលរដ្ឋទូទៅ ក្នុងព្រះពាជអាណាចក្រកម្ពុជា ។

ម្យ៉ាងទៀត ដោយតេជានុភាពនៃព្រះរតនត្រ័យ សូមសម្តេចព្រះសង្ឃនាយកចាំងពីរព្រះអង្គ ព្រះពាជវង្សានុវង្ស ឥស្សរជនចាំងឡាយ ទឹងពុទ្ធបរិស័ទចាំងឡាយ ចានបរិតទៅកងសេចក្តីសុខ-ចំរើនអស់កាលជានិច្ច

តរៀនៗកុំបីឃ្លៀងឃ្លាតឡើយ ។

លុះចប់សុទ្ធតែថាព្រះសោធិវង្សហើយ, ទើបសម្តេចព្រះមហាក្សត្រិយានី ទ្រង់ប្រគេនព្រហ្មទានដំ ១ ចំពោះព្រះមហាឃ្លួន-ព៉ន សមណានិស្សិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ថ្នាក់ទី ២ រួចទើបព្រះតេជព្រះគុណព្រះសោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា បានសូត្រព្រះនាមព្រះសង្ឃទាំង ១៣១ រូប ដែលត្រូវទទួលព្រហ្មទាន ។

លំដាប់តមក, ព្រះសង្ឃសូត្រជយន្តោ ខណៈអនុមោទនាគាថាតាមគួរជាកិច្ចបង្ហើយបុណ្យ ។

ម៉ោង ១០ ព្រឹក សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងទ្រង់ស្តេចព្រះពាជទិវត្តន៍ទៅព្រះបរមរាជវាំងវិញ ។

រួច, ទើបសហជីវិន ឈឹម-សុមន៍ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បានសូត្រតាលច័ត្រឡើងស្បែរជនមានម្ចាស់ព្រហ្មទានជាដើមប្រគេនសមណានិស្សិតទាំង ១៣០ រូបដែលនៅសល់ពុំទាន់ប្រគេន ។

ពិធីបុណ្យនេះបានបញ្ចប់នៅម៉ោង ១១ តរ ។

(តទៅ)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិនិ:គ្ឃ្ន គុ. ដែលមានសំឡេងមិនមាន ដោយក្រៃលែង, ដែលមិនមានសំឡេងសោះ, ដែលស្ងាត់ស្ងប់ឈឹង ។

អតិនិ:ក្ឃ្ន ឈាតុ. ជាងឆ្លើយ ។

អតិនិប្ឋ្ន គុ. ដែលឥតមានការុណាក្រៃពេក ។

អតិនិឞ្ឋ្ន គុ. ដែលស្បែងមើលដោយក្រៃលែង, ដែលដំនាញណាស់ ។

អតិនិហ្ន ឈាតុ. បងិសេធក្រៃលែង, ខាត់ចោល ។

អតិនី ឈាតុ តាំចេញក្រៃលែង. ស្រោចស្រង់ ។

អតិនីបៃស៊ ក្រ. វិ. ក្លួចក្រៃពេក, ទាបក្រៃពេក ។

អតិនេទ្ធ, ឈាតុ. ពេញក្រៃពេក, ពេញត្រៀប ។

អតិបដិយាំស៊ គុ. ដែលរៀងវៃជាងក្រៃពេក, ដែលរស់រើកជាង ។

អតិបតិ ឈាតុ. និយាយលើក, សរសើរ ។

អតិបត៌ ឈាតុ. ធ្វាក់ក្រៃពេក, ហោះហើរ, ឯកទាន,ស្ទុះ ប្រព្រឹត្តខុសច្បាប់ ។

អតិបទ៌ ឈាតុ. ប្រមាទ, ប្រហែស, ខុប ។